របាយការណ៍
សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំយុត្តិធម៌ឆ្នាំ ២០២៤
និងកំណត់ទិសដៅការងារឆ្នាំអាទិភាពឆ្នាំ ២០២៥

ថ្ងៃទី១២-១៣-១៤ ខែមីនា ឆ្នាំ២០២៥

បញ្ជីឯកសារ

សន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារជាអាទិភាពឆ្នាំ២០២៥

---

១. របៀបវារៈនៃសន្និបាត

២. **ឯកសារផ្នែកទី១** - របាយការណ៍ស្តីពីលទ្ធផលការងារក្រសួងយុត្តិធម៌ឆ្នាំ២០២៤

៣. **ឧបសម្ព័ន្ធទី១** - បទបង្ហាញអំពីទិន្នន័យសំណុំរឿងទូទាំងប្រទេសឆ្នាំ២០២៤

៤. **ឯកសារផ្នែកទី២** - របាយការណ៍លទ្ធផលការងារសាលាជម្រះក្តីឆ្នាំ២០២៤

៥. **ឯកសារផ្នែកទី៣** - របាយការណ៍លទ្ធផលយុទ្ធនាការរយៈពេល ១ឆ្នាំ

របៀបវារៈ
សន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារជាអាទិភាពឆ្នាំ២០២៥
ថ្ងៃទី១២-១៣-១៤ ខែមីនា ឆ្នាំ២០២៥
នៅសណ្ឋាគារ សុខាភ្នំពេញ

ពេលវេលា	កម្មវិធី	រយៈពេល
ថ្ងៃទី១៖ ថ្ងៃពុធ ទី១២ ខែមីនា ឆ្នាំ២០២៥		
១៣:០០ - ១៤:០០	ចុះឈ្មោះអ្នកចូលរួម	**៦០ នាទី**
១៤:០០ - ១៤:១៥	ការអញ្ជើញមកដល់របស់គណៈអធិបតី	**១៥ នាទី**
១៤:១៥ - ១៤:២០	ប្រកាសហេតុ ប្រកាសសមាសភាពគណៈអធិបតី គោរពភ្លេងជាតិ	**៥ នាទី**
១៤:២០ - ១៤:៣៥	ចំណាប់អារម្មណ៍បើកសន្និបាតរបស់លោកជំទាវ **ជា លាង** អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល	**១៥ នាទី**
១៤:៣៥ - ១៤:៥០	ចំណាប់អារម្មណ៍បើកសន្និបាតរបស់ឯកឧត្តមបណ្ឌិត **ជីវ កេង** ប្រធានតុលាការកំពូល	**១៥ នាទី**
១៤:៥០ - ១៥:៣៥	សុន្ទរកថាបើកសន្និបាត ដោយឯកឧត្តម **កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**	**៤៥ នាទី**
១៥:៣៥ - ១៦:៣៥	ថតរូបអនុស្សាវរីយ៍	**៦០ នាទី**
១៥:៣៥ - ១៦:៣៥	អាហារសម្រន់	**២០ នាទី**
១៦:៣៥ - ១៧:៣០	របាយការណ៍លទ្ធផលការងារវិស័យយុត្តិធម៌ឆ្នាំ២០២៤	**៤៥ នាទី**
ចាប់ពី ១៧:៣០	ពិធីបំពាក់គ្រឿងឥស្សរិយយស	
ថ្ងៃទី២៖ ថ្ងៃព្រហស្បតិ៍ ទី១៣ ខែមីនា ឆ្នាំ២០២៥		
០៨:៣០ - ០៩:៣០	បទបង្ហាញ និងសំណួរ-ចម្លើយ៖ - កិច្ចការរដ្ឋបាលតុលាការ - កិច្ចការហិរញ្ញវត្ថុក្នុងវិស័យយុត្តិធម៌	**៦០ នាទី**
០៩:៣០ - ១០:៣០	បទបង្ហាញ និងសំណួរ-ចម្លើយ ៖ ការអនុវត្តសំណើជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ និងបត្យាប័ន	**៦០ នាទី**
១០:៣០ - ១០:៥០	អាហារសម្រន់	**២០ នាទី**

១០:៥០ - ១២:០០	បទបង្ហាញ និងសំណួរ-ចម្លើយ៖ កិច្ចការកែទម្រង់ប្រព័ន្ធយុត្តិធម៌និងការអនុវត្តយុទ្ធនាការជំរុញនិងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និងយុទ្ធនាការត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ	**៧០ នាទី**
១២:០០ - ១៣:៣០	សម្រាក ពិសាអាហារថ្ងៃត្រង់	**៩០ នាទី**
១៣:៣០ - ១៤:១៥	បទបង្ហាញ៖ ការកំណត់ការប្រាក់ និងការប្រាក់ពិន័យ	**៤៥ នាទី**
	អាហារសម្រន់	
១៤:១៥ - ១៧:០០	កិច្ចពិភាក្សារួម៖ ការកំណត់ការប្រាក់ និងការប្រាក់ពិន័យ	**១៦៥ នាទី**
ចាប់ពី ១៧:០០	ពិធីបំពាក់គ្រឿងឥស្សរិយយស	
ថ្ងៃទី៣៖ ថ្ងៃសុក្រ ទី១៤ ខែមីនា ឆ្នាំ២០២៥		
០៨:៣០ - ០៩:១៥	បទបង្ហាញ៖ ការទទួលស្គាល់សន្តតិជន និងការបែងចែកមត៌ក	**៤៥ នាទី**
	អាហារសម្រន់	
០៩:១៥ - ១១:១៥	កិច្ចពិភាក្សារួម៖ ការទទួលស្គាល់សន្តតិជន និងការបែងចែកមត៌ក	**១២០ នាទី**
១១:១៥ - ១២:០០	បទបង្ហាញ៖ ការប្រើប្រាស់សិទ្ធិអំណាច និងឆន្ទានុសិទ្ធិរបស់តុលាការ	**៤៥ នាទី**
១១:៥០ - ១៣:៣០	សម្រាក ពិសាអាហារថ្ងៃត្រង់	**១០០ នាទី**
ពិធីបិទសន្និបាត		
១៣:៣០ - ១៤:១៥	របាយការណ៍ស្តីពីលទ្ធផល និងសេចក្តីសម្រេចចិត្តនៃអង្គសន្និបាត	**៤៥ នាទី**
១៤:១៥ - ១៤:៣០	ចំណាប់អារម្មណ៍បិទសន្និបាតរបស់លោកជំទាវ **ជា លាង** អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល	**១៥ នាទី**
១៤:៣០ - ១៤:៤៥	ចំណាប់អារម្មណ៍បិទសន្និបាតរបស់ឯកឧត្តមបណ្ឌិត **ជឹង ភេង** ប្រធានតុលាការកំពូល	**១៥ នាទី**
ចាប់ពី ១៤:៤៥	- មតិបូកសរុប និងសុន្ទរកថាបិទសន្និបាត ដោយឯកឧត្តម **កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** - ពិធីបំពាក់គ្រឿងឥស្សរិយយស - គោរពភ្លេងជាតិបិទកម្មវិធី	
ចប់កម្មវិធី		

កម្មវិធីអាចកែប្រែតាមការចាំបាច់

ឯកសារផ្នែកទី១

របាយការណ៍លទ្ធផលការងារ

ក្រសួងយុត្តិធម៌ឆ្នាំ២០២៤

របាយការណ៍

សន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារជាអាទិភាពឆ្នាំ២០២៥

មាតិកាសង្ខេប

ជំពូកទី ១ : សេចក្តីផ្តើម

ជំពូកទី ២ : លទ្ធផលការងារសម្រេចបាន

ផ្នែកទី ១. លទ្ធផលការងារក្រសួងយុត្តិធម៌ឆ្នាំ២០២៤

ផ្នែកទី ២. លទ្ធផលការងាររបស់សាលាដម្រះក្តីឆ្នាំ២០២៤

ផ្នែកទី ៣. លទ្ធផលនៃការអនុវត្តយុទ្ធនាការរយៈពេល ១ឆ្នាំ

ផ្នែកទី ៤. ស្ថាប័ន និងអង្គភាពពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យយុត្តិធម៌

ជំពូកទី ៣ : បញ្ហាប្រឈម

ជំពូកទី ៤ : ដំណោះស្រាយ

ជំពូកទី ៥ : ទិសដៅការងារជាអាទិភាពឆ្នាំ២០២៥

ជំពូកទី ៦ : សេចក្តីសន្និដ្ឋាន

របាយការណ៍
សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំយុត្តិធម៌ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារឆ្នាំអាទិភាពឆ្នាំ២០២៥

មាតិកា

ជំពូកទី១ - សេចក្តីផ្តើម ១

ជំពូកទី២ - លទ្ធផលការងារសម្រេចបាន ២

ផ្នែកទី១ - លទ្ធផលការងារក្រសួងយុត្តិធម៌ឆ្នាំ២០២៤ ..... ២

១. អគ្គលេខាធិការដ្ឋានក្រសួងយុត្តិធម៌ ២

១.១. កិច្ចការបុគ្គលិក ៣

១.១.១. ការងារគ្រប់គ្រងបុគ្គលិក ៣

១.១.២. ការងារអភិវឌ្ឍន៍ធនធានមនុស្ស ៤

១.២ កិច្ចការហិរញ្ញវត្ថុ ៤

១.២.១. រចនាសម្ព័ន្ធថវិកាកម្មវិធី ៤

១.២.២. ការអនុវត្តចំណូល និងចំណាយ ៤

១.២.៣. ការងារហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ៥

១.២.៤. ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងវិស័យយុត្តិធម៌ ៥

១.២.៥. ការងារបណ្តុះបណ្តាល និងផ្សព្វផ្សាយកិច្ចការហិរញ្ញវត្ថុ ៥

១.៣. កិច្ចការរដ្ឋបាល ៦

១.៣.១. ការងារចរាចរលិខិតរដ្ឋបាល និងការងាររៀប ៦

១.៣.២. ការងារពិធីការ ៦

១.៣.៣. ការងារបូកសរុប ៧

១.៣.៤. ការងារសន្តិសុខ និងសណ្តាប់ធ្នាប់ ៧

១.៤. កិច្ចការព័ត៌មានវិទ្យា និងបរិវត្តកម្មឌីជីថល ៧

១.៤.១. ការងារព័ត៌មានវិទ្យា ៧

១.៤.២. ការងារផ្សព្វផ្សាយ និងឋានរូបភាព ៧

២. អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ ៨

២.១. ការងារផ្នែកបាល ៨
២.២. ការងារបុគ្គលិក ៨
២.៣. ការងារបច្ចេកទេស និងចំណេះជំនាញផ្នែកបាលតុលាការ ៨
៣. អគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ៩
៣.១. កិច្ចការរដ្ឋប្បវេណី ៩
៣.១.១. ចំណាត់ការលើពាក្យសុំអន្តរាគមន៍ ៩
៣.១.២. ការពិនិត្យពាក្យសុំនីតិសម្បទាជាន់គរបាលយុត្តិធម៌ ៩
៣.២. កិច្ចការព្រហ្មទណ្ឌ និងឆន្ទានុសិទ្ធិ ១០
៣.៣. កិច្ចការគ្រប់គ្រងវត្ថុតាង និងផលនៃបទល្មើស ១០
៣.៤. ការរៀបចំ និងចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំ ១០
៤. អគ្គនាយកដ្ឋានកិច្ចការទោសព្រហ្មទណ្ឌ ១០
៤.១. កិច្ចការរដ្ឋបាល ១០
៤.២. កិច្ចការផ្តាំលទោស ១១
៤.២.១. អំពីការបញ្ជូនសលាកបត្រផ្តន្ទាទោសតាមប្រព័ន្ធបច្ចេកវិទ្យា ១១
៤.២.២. អំពីការទទួលបានពាក្យសុំ និងចេញព្រឹត្តិបត្រផ្តាំលទោស ១១
៤.៣. កិច្ចការអនុគ្រោះទោស ១១
៤.៣.១. សំណើសុំបន្ធូរបន្ថយទោស និងលើកលែងទោស ១១
៤.៣.២. ព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងលើកលែងទោស ១២
៤.៤. កិច្ចការអនុវត្តទោស ១២
៤.៤.១. ទិន្នន័យជនជាប់ឃុំនៅក្នុងមណ្ឌលអប់រំកែប្រែ និងពន្ធនាគារាជធានី-ខេត្ត ១២
៤.៤.២. ការដោះលែងដោយមានលក្ខខណ្ឌ ១២
៤.៤.៣. ការអនុវត្តទោសការងារសហគមន៍ ១៣
៥. អគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ១៣
៥.១. ការចូលរួមអនុវត្តសកម្មភាពក្នុងយុទ្ធនាការរបស់ក្រសួងយុត្តិធម៌ ១៣
៥.២. ការងារផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ១៣
៥.៣. ការងារតាមដានការអនុវត្តច្បាប់រដ្ឋប្បវេណីនៅតាមតុលាការ ១៥
៥.៤. ការចូលរួមក្នុងក្រុមការងារចំពោះកិច្ច ១៥
៥.៥. ការចុះបំពេញបេសកកម្មក្រៅប្រទេស និងក្នុងប្រទេស ១៦
៥.៦. ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងជំនួយផ្នែកច្បាប់ ១៦

៥.៦.១. ការអនុវត្តសកម្មភាពការងារ ១៦
៥.៦.២. ការផ្តល់សេវាយុត្តិធម៌នៅមូលដ្ឋានជូនប្រជាពលរដ្ឋ ១៧
៦. អគ្គាធិការដ្ឋានកិច្ចការតុលាការ ១៨
៧. អគ្គនាយកដ្ឋានកិច្ចការអន្តរជាតិ និងអតិថិជ្ឈន៍ទិសម័យយុត្តិធម៌ ១៩
៧.១. កិច្ចការអាជ្ញាធរកណ្តាល ១៩
៧.១.១. ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ១៩
៧.១.២. ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យរដ្ឋប្បវេណី ២០
៧.១.៣. កិច្ចការផ្ទេរទណ្ឌិត ២០
៧.១.៤. កិច្ចការបត្យាប័ន ២០
៧.២. កិច្ចសហប្រតិបត្តិការជាមួយអាស៊ាន ២០
៧.២.១. កិច្ចសហប្រតិបត្តិការផ្នែកច្បាប់ក្នុងក្របខណ្ឌអាស៊ាន ២០
៧.២.២. កិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយបណ្តាប្រទេសជាសមាជិកអាស៊ាន ២០
៧.២.៣. កិច្ចការស្រាវជ្រាវនិងផ្សព្វផ្សាយច្បាប់អាស៊ាន ២១
៧.៣. កិច្ចការចំណាក់ចំនងអន្តរជាតិ និងសហប្រតិបត្តិការផ្នែកច្បាប់ ២១
៧.៣.១. កិច្ចសហប្រតិបត្តិការផ្នែកច្បាប់ ២១
៧.៣.២. កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ២២
៧.៣.៣. កិច្ចការផ្តល់យោបល់គតិយុត្តលើហិរញ្ញប្បទានពីបរទេស និងដៃគូអន្តរជាតិ ២២
៧.៣.៤. កិច្ចការសហប្រតិបត្តិការ និងសម្របសម្រួលការងារសិទ្ធិមនុស្ស ២២
៧.៤. កិច្ចការអ្នកបកប្រែនិងអ្នកជំនាញក្នុងវិស័យច្បាប់ និងយុត្តិធម៌ ២២
៧.៤.១. កិច្ចការគ្រប់គ្រងអ្នកបកប្រែក្នុងវិស័យច្បាប់ និងយុត្តិធម៌ ២២
៧.៤.២. កិច្ចការអ្នកជំនាញក្នុងវិស័យច្បាប់ និងយុត្តិធម៌ ២៣
៧.៥. កិច្ចការផ្សព្វផ្សាយ និងការបណ្តុះបណ្តាលច្បាប់ ២៣
៧.៥.១. ការងារផ្សព្វផ្សាយ និងការបណ្តុះបណ្តាលច្បាប់ ២៣
៧.៥.២. លទ្ធផលការងារផ្សព្វផ្សាយ និងបណ្តុះបណ្តាលច្បាប់តាមរយៈបណ្តាញសង្គមក្នុងឆ្នាំ ២០២៤ ធៀបនឹងឆ្នាំ ២០២៣ ..... ២៣
៧.៥.៣. អត្ថបទច្បាប់ ពន្យល់ពាក្យច្បាប់ និងស្តតអប់រំខ្លី ដែលបានផ្សព្វផ្សាយតាមបណ្តាញសង្គមទាំង៤ របស់នាយកដ្ឋានផ្សព្វផ្សាយ និងបណ្តុះបណ្តាលច្បាប់ ២៤
៧.៥.៤. សមិទ្ធផលការងារផ្សេងៗដែលសម្រេចបាន ២៥
៧.៦. កិច្ចការស្រាវជ្រាវ និងផែនការ ២៥

៨. ការងារនីតិកម្ម ២៦

៨.១. សេចក្តីព្រាងច្បាប់ ២៦

៨.១.១. សេចក្តីព្រាងច្បាប់កំពុងពិនិត្យ ២៦

៨.១.២. សេចក្តីព្រាងច្បាប់ដែលបានពិនិត្យរួច ២៦

៨.២. សេចក្តីព្រាងព្រះរាជក្រឹត្យ និងអនុក្រឹត្យ ២៦

៨.៣. សេចក្តីព្រាងប្រកាស និងសេចក្តីសម្រេច ២៧

៩. ការងារឌីជីថលូបនីយកម្ម និងបរិវត្តកម្មឌីជីថល ២៧

៩.១. ការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធបណ្តាញឌីជីថលនៃទីស្តីការក្រសួងយុត្តិធម៌ ២៧

៩.២. ការរៀបចំគេហទំព័រ (Website) និងប្រព័ន្ធសារអេឡិចត្រូនិច (Mail System) ថ្មីសម្រាប់ក្រសួងយុត្តិធម៌ ២៧

៩.៣. ការអភិវឌ្ឍកម្មវិធីសម្រាប់ក្រសួងយុត្តិធម៌ ២៨

៩.៤. ទិន្នន័យនៃការគាំពារបណ្តាញសង្គមរបស់ក្រសួងយុត្តិធម៌ (គិតត្រឹមឆ្នាំ២០២៤) ២៨

១០. ការងារនាយកដ្ឋានសវនកម្មផ្ទៃក្នុង ២៨

១១. ការងារយេនឌ័រ និងកុមារ ៣០

១១.១. ការផ្សព្វផ្សាយ និងបណ្តុះបណ្តាលច្បាប់ ៣០

១១.២. ការអភិវឌ្ឍសមត្ថភាពសម្រាប់មន្ត្រីរាជការ និងមន្ត្រីអនុវត្តច្បាប់ជាស្ត្រីនៅក្នុងវិស័យយុត្តិធម៌ ៣០

១១.៣. អំពីការរៀបចំទិនានិទ្ទេស ៨មីនា ៣១

១១.៤. ការរៀបចំលិខិតបទដ្ឋានគតិយុត្ត ៣១

១១.៥. ការចូលរួមសរសេរចាយការណ៍ ៣១

១២. ការងារផ្តល់សេវាជំនួយផ្នែកច្បាប់ ៣១

១២.១. គម្រោងផ្តល់មេធាវីការពារក្តីជូនជនក្រីក្រក្រោមកិច្ចសហការជាមួយក្រសួងយុត្តិធម៌ ៣២

១២.២. គម្រោងផ្តល់មេធាវីការពារក្តីជូនស្ត្រីនិងក្មេងស្រីក្រីក្រដែលរងគ្រោះ ៣២

១២.៣. ការចូលរួមពីមេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រដោយមិនគិតកម្រៃ ៣៣

ផ្នែកទី២. លទ្ធផលការងាររបស់សាលាដំបូងក្នុងឆ្នាំ២០២៤ ..... ៣៣
ផ្នែកទី៣. លទ្ធផលនៃការអនុវត្តយុទ្ធនាការរយៈពេល ១ឆ្នាំ ៣៣
ផ្នែកទី៤. ស្ថាប័ន និងអង្គភាពពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យយុត្តិធម៌ ៣៤
១. ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ៣៤
១.១. អំពីការងាររបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ៣៤
១.២. ការងាររបស់ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ៣៤
១.៣. ការងាររបស់អគ្គលេខាធិការដ្ឋាន ៣៥
១.៣.១. លទ្ធផលការងាររបស់នាយកដ្ឋានកិច្ចការអាជីពចៅក្រម និងព្រះរាជអាជ្ញា ៣៥
១.៣.២.ការងាររបស់នាយកដ្ឋានទទួលពាក្យបណ្តឹង និងកិច្ចការវិន័យ ៣៦
១.៣.៣. ការងាររបស់នាយកដ្ឋានកិច្ចការរដ្ឋបាល បុគ្គលិក និងហិរញ្ញកិច្ច ៣៧
១.៤. ការងារការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ៣៩
២. គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ៣៩
២.១. កិច្ចការផែនការ និងយុទ្ធសាស្ត្រ ៣៩
២.២. ការងារផ្សព្វផ្សាយ ៣៩
២.៣. ការងារអន្តរស្ថាប័ន ៣៩
២.៤. កិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ ៤០
៣. បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ៤០
៣.១. ការប្រឡងប្រជែងជ្រើសរើសសិស្សវិជ្ជាជីវៈគុណភាពនៃឆ្នាំ២០២៤ ..... ៤០
៣.១.១. សិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញាជំនាន់ទី ១២ ..... ៤០
៣.១.២. សិស្សក្រឡាបញ្ជីជំនាន់ទី ៩ ..... ៤១
៣.១.៣. សិស្សអាជ្ញាសាលាជំនាន់ទី ៣ ..... ៤១
៣.១.៤. សិស្សសារការីជំនាន់ទី ៤ ..... ៤១
៣.១.៥. សិស្សថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញតុលាការជំនាន់ទី ១ ..... ៤១
៣.២. ការបណ្តុះបណ្តាលដំបូងនៅក្នុងឆ្នាំ២០២៤ ..... ៤២
៣.២.១. សាលាភូមិន្ទចៅក្រម និងព្រះរាជអាជ្ញា ៤២
៣.២.២. សាលាភូមិន្ទក្រឡាបញ្ជី ៤៣
៣.២.៣. សាលាភូមិន្ទអាជ្ញាសាលា ៤៣
៣.២.៤. សាលាភូមិន្ទសារការី ៤៤
៣.២.៥. សាលាច្បាប់ ៤៤

៣.៣. ការបណ្តុះបណ្តាលបន្ត, សុក្រឹត្យការ និងវិក្រឹតការ នៅក្នុងឆ្នាំ២០២៤ ..... ៤៥
៣.៤. កិច្ចសហប្រតិបត្តិការអន្តរជាតិ នៅក្នុងឆ្នាំ២០២៤ ..... ៤៥
៣.៥. ការងាររដ្ឋបាល និងបដិសណ្ឋារកិច្ច ៤៦
៤. ក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ ៤៦
៤.១. ការងាររដ្ឋបាល និងបុគ្គលិក ៤៦
៤.១.១. ការងាររដ្ឋបាល ៤៦
៤.១.២. អំពីស្ថិតិមន្ត្រី ៤៧
៤.១.៣. អំពីរចនាសម្ព័ន្ធអង្គភាពចំណុះឱ្យលេខាធិការដ្ឋាន ៤៧
៤.២. អំពីផែនការសកម្មភាពការងារប្រចាំឆ្នាំ ៤៧
៤.២.១. អំពីផែនការសកម្មភាព ៤៧
៤.២.២. អំពីការងារហិរញ្ញវត្ថុ ៤៧
៤.២.៣. អំពីការងារចំពោះកិច្ច ៤៨
៥. អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (អ.ជ.ក.) ៤៨
៥.១. ការជ្រើសរើស ការបណ្តុះបណ្តាល និងផ្តល់នីតិសម្បទាជូនមន្ត្រីសម្រុះសម្រួល ដោះស្រាយវិវាទ ៤៨
៥.២. អំពីការដោះស្រាយវិវាទនៅក្នុងក្របខណ្ឌនៃ អ.ជ.ក. ៤៩
៥.៣. អំពីការរៀបចំ និងអនុវត្តគម្រោងចុះដោះស្រាយវិវាទ និងសិក្ខាសាលាផ្សព្វផ្សាយរបស់ អ.ជ.ក. នៅថ្នាក់មូលដ្ឋាន ៥០
៥.៣.១. ...ការរៀបចំ និងការអនុវត្តគម្រោងចុះដោះស្រាយវិវាទជូនប្រជាពលរដ្ឋនៅតំបន់ជនជាតិដើមភាគតិចរស់នៅតំបន់ភូមិភាគឦសាន្ត និងតំបន់ដាច់ស្រយាល ៥០
៥.៣.២. ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលនៅថ្នាក់មូលដ្ឋាន ៥០
៥.៤. អំពីកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នដៃគូ ៥១
៥.៥. អំពីការងារផ្សព្វផ្សាយ និងសាធារណមតិ ៥១
ជំពូកទី៣ - បញ្ហាប្រឈម ៥២
១. បញ្ហាប្រឈមរបស់ក្រសួងយុត្តិធម៌ និង អង្គភាពពាក់ព័ន្ធ ៥២
១.១. ធនធានមនុស្ស ៥២
១.២. ហេដ្ឋារចនាសម្ព័ន្ធ ៥៣
១.៣. កិច្ចការហិរញ្ញវត្ថុ ៥៣
១.៤. បញ្ហាប្រឈមក្នុងការអនុវត្តច្បាប់ ៥៣

១.៤.១. ការអនុវត្តច្បាប់ក្នុងវិស័យរដ្ឋប្បវេណី ៥៣
១.៤.២.ការអនុវត្តច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ៥៤
១.៤.៣. បញ្ហាប្រឈមរួមផ្សេងទៀត ៥៤
២. បញ្ហាប្រឈមរបស់សាលាដម្រះក្តី ៥៥
២.១. ធនធានមនុស្ស ៥៥
២.២. ហិរញ្ញវត្ថុ ៥៥
២.៣. សម្ភារៈ ៥៦
២.៤. ហេដ្ឋារចនាសម្ព័ន្ធ ៥៦
២.៥. បញ្ហាប្រឈមផ្សេងទៀត ៥៦
ជំពូកទី៤ - ដំណោះស្រាយ ៥៧
ជំពូកទី៥ - ទិសដៅការងារជារអនិតាពឆ្នាំ២០២៥ ..... ៥៨
១. ការអនុវត្តវិធានការគន្លឹះក្នុងវិស័យយុត្តិធម៌ ៥៨
២. ការរៀបចំផែនការធនធានមនុស្ស ៥៨
៣. ការរៀបចំផែនការកែទម្រង់ហិរញ្ញវត្ថុ ៥៩
៤. ការរៀបចំផែនការយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងកម្មវិធីរអនិតាព (២០២៥-២០៣៥) ៥៩
៥. ការងារនីតិកម្មក្នុងវិស័យយុត្តិធម៌ ៥៩
៦. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ៦០
៧. ការងារឌីជីថលូបនីយកម្ម និងបរិវត្តកម្មឌីជីថល ៦០
៨. ការងារផ្សេងៗ ៦០
ជំពូកទី៦ - សេចក្តីសន្និដ្ឋាន ៦២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

របាយការណ៍
សន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារជាអាទិភាពឆ្នាំ២០២៥

ជំពូកទី១
សេចក្តីផ្តើម

វិស័យយុត្តិធម៌ដើរតួនាទីយ៉ាងសំខាន់ក្នុងការកសាង និងពង្រឹង "**សង្គមនីតិរដ្ឋ**" មួយរឹងមាំ និងគ្រប់ជ្រុងជ្រោយ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, បង្កើនគុណភាពនៃ "**យុត្តិធម៌នៅក្នុងសង្គម**", លើកកម្ពស់នៃការគោរពសិទ្ធិ និងសេរីភាពបុគ្គល, លុបបំបាត់នូវ "**និទណ្ឌភាព**", ពង្រឹង "**វប្បធម៌នៃការគោរពច្បាប់**" និង "**អភិបាលកិច្ចល្អ**" ដែលជាកត្តារួមចំណែកដ៏សំខាន់ក្នុងការពង្រឹង "**វប្បធម៌សន្តិភាព**" និងស្ថិរភាពសង្គម ដែលជាគ្រឹះសម្រាប់វិបុលភាព និងភាពសុខសាន្តរបស់ប្រទេសជាតិ និងប្រជាជន ព្រមទាំងការអភិវឌ្ឍប្រកបដោយចីរភាព ក្រោមដំបូលនៃរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ជាតិ។ ក្នុងន័យនេះ "**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**" ត្រូវបានដៅជាអាទិភាពចម្បងមួយដែលនឹងត្រូវបន្តអនុវត្តជាជំហានៗឥតដាច់ក្នុងដំណើរឈានឡើងជាបន្តបន្ទាប់របស់កម្ពុជា។ ទន្ទឹមនេះ ការពង្រឹងនិងលើកកម្ពស់ប្រសិទ្ធភាពនៃច្បាប់និងប្រព័ន្ធយុត្តិធម៌ គឺជាវិធានការគន្លឹះមួយក្នុងចំណោមវិធានការគន្លឹះទាំង៥ ដែលត្រូវសម្រេចឱ្យចេញជាលទ្ធផលជាក់ស្តែងក្នុងនីតិកាលទី៧នេះ តាមរយៈ (១)- ការធ្វើឱ្យប្រសើរឡើងនូវគុណភាពនិងប្រសិទ្ធភាព ទាំងទៅលើការផ្តល់សេវាយុត្តិធម៌ និងទាំងទៅលើគុណភាពនៃយុត្តិធម៌ និង (២)-ការបង្កើតនូវយន្តការដោះស្រាយវិវាទដែលមានភាពងាយស្រួល និងសម្បូរបែបឱ្យកាន់តែខិតទៅជិតប្រជាពលរដ្ឋនៅមូលដ្ឋាន។

កាលពីថ្ងៃទី២៧ ដល់ទី២៩ ខែមីនា ឆ្នាំ២០២៤ កន្លងទៅនេះ ក្រសួងយុត្តិធម៌ និងសាលាដម្រះក្តីគ្រប់ជាន់ថ្នាក់ បានសហការរៀបចំនូវមហាសន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ទូទាំងប្រទេសឆ្នាំ២០២៣ និងកំណត់ទិសដៅការងារជាអាទិភាពបន្ត ដែលជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃវិស័យយុត្តិធម៌ បានដាក់ចេញនូវសេចក្តីសម្រេចចិត្ត ដោយបានឯកភាពគ្នាកំណត់នូវដំណោះស្រាយសំខាន់ៗ ដែលជាចក្ខុវិស័យការងារចំពោះបញ្ហាប្រឈមលើប្រធានបទចំនួន ៨ ដែលបានប៉ះពាល់ដល់ប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ និងប្រសិទ្ធភាព

នៃការផ្តល់សេវាយុត្តិធម៌, ចំពោះការងារមួយចំនួនពាក់ព័ន្ធនឹងការលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃរដ្ឋបាលតុលាការ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងវិស័យយុត្តិធម៌ក្រោមបរិបទគណនេយ្យសមិទ្ធកម្ម។

បន្តពីព្រឹត្តិការណ៍មហាសន្និបាត, សន្និបាតវិស័យយុត្តិធម៌ដែលត្រូវបានប្រារព្ធឡើងនាឆ្នាំនេះ គឺជាវេទិកាប្រចាំឆ្នាំដ៏ធំមួយដែលផ្តល់ឱកាសដល់អ្នកដែលបំពេញការងារនៅក្នុងវិស័យយុត្តិធម៌ ក្នុងការជួបពិគ្រោះ និងពិភាក្សាគ្នា ព្រមទាំងធ្វើការវាយតម្លៃអំពីប្រសិទ្ធភាព និងបញ្ហាប្រឈមនៃការអនុវត្តច្បាប់នៅក្នុងសង្គមកម្ពុជា ដោយបានសម្រេចយកប្រធានបទពិភាក្សាជាអាទិភាពសំខាន់ៗ ជាអាទិ៍ ការកំណត់ការប្រាក់ និងការប្រាក់ពិន័យ, ការទទួលស្គាល់សន្តតិជន និងការបែងចែកមត៌ក, ការអនុវត្តសំណើជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ និងបត្យាប័ន, ការប្រើប្រាស់សិទ្ធិអំណាច និងឆន្ទានុសិទ្ធិរបស់ចៅតុលាការ។ ជាមួយគ្នានេះ, អង្គសន្និបាតនឹងសម្រេចដាក់ចេញនូវសេចក្តីណែនាំ និងវិធានការចាំបាច់នានា ដើម្បីដោះស្រាយបញ្ហាប្រឈមដែលបានជួបប្រទះក្នុងការអនុវត្តការងារនាពេលកន្លងមក។

ទន្ទឹមនេះ, សន្និបាតក្នុងវិស័យយុត្តិធម៌នេះ ក៏ត្រូវបានរៀបចំធ្វើឡើងក្នុងគោលបំណងពិនិត្យ តាមដាន និងវាយតម្លៃនូវកាល់ផែនការសកម្មភាពដែលបានដាក់ចេញសម្រាប់អនុវត្តនាពេលកន្លងមក និងសមិទ្ធផលសម្រេចបានពីការអនុវត្តសកម្មភាពដែលបានដាក់ចេញទាំងនោះ ដើម្បីកំណត់អំពីបញ្ហាប្រឈម ដែលបាននិងកំពុងបន្តអត្ថិភាពជាធរមាននៅក្នុងវិស័យយុត្តិធម៌ក្នុងឆ្នាំ២០២៥ និងជាមូលដ្ឋានក្នុងការកំណត់ទិសដៅការងារជាអាទិភាពសម្រាប់ឆ្នាំ២០២៥ ដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងធ្វើឱ្យកាន់តែប្រសើរឡើងនូវកិច្ចការកែទម្រង់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ស្របតាមគោលនយោបាយនិងស្នូលនៃយុទ្ធសាស្ត្រដូចបានកំណត់ក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា និងវិធានការគន្លឹះទី៥។

ជំពូកទី២

លទ្ធផលការងារសម្រេចបាន

ផ្នែកទី១

លទ្ធផលការងារក្រសួងយុត្តិធម៌ឆ្នាំ២០២៤

១. អគ្គលេខាធិការដ្ឋានក្រសួងយុត្តិធម៌

នៅក្នុងឆ្នាំ២០២៤, អគ្គលេខាធិការដ្ឋាន នៃក្រសួងយុត្តិធម៌ សម្រេចបានលទ្ធផលការងារមានដូចខាងក្រោម៖

១.១. កិច្ចការបុគ្គលិក

១.១.១. ការងារគ្រប់គ្រងបុគ្គលិក

ក្នុងឆ្នាំ២០២៤ មន្ត្រីរាជការនៃទីស្តីការក្រសួងយុត្តិធម៌មានចំនួនសរុប ១១០៣រូប (ស្រី ៣៣៩រូប) ក្នុងនោះមានក្របខណ្ឌចំនួន ៥៦៦រូប (ស្រី ១៩៥រូប) គ្មានក្របខណ្ឌចំនួន ៤១៤រូប (ស្រី ៨៩រូប) និងមន្ត្រីជាប់កិច្ចសន្យាចំនួន ១២៣រូប (ស្រី ៥៥រូប)។

ការគ្រប់គ្រងក្របខណ្ឌ និងបម្រែបម្រួលស្ថានភាពមន្ត្រីរាជការស៊ីវិល នៃក្រសួងយុត្តិធម៌មានដូចខាងក្រោម៖

- បាននឹងកំពុងបញ្ចូលទិន្នន័យមន្ត្រីក្របខណ្ឌក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ត្រីរាជការ (HRMIS)
- បានស្នើដំឡើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការនៅទីស្តីការក្រសួងយុត្តិធម៌ ចំនួន ២១៩រូប ក្នុងនោះប្រចាំឆ្នាំចំនួន ១៨៣រូប និងតាមកម្រិតសញ្ញាបត្រចំនួន ៣៦រូប
- បានស្នើសុំគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការចំនួន ១៣៨រូប
- បញ្ចូលក្នុងក្របខណ្ឌក្រសួងយុត្តិធម៌ ចំនួន ១២រូប (សិស្សមន្ត្រីមកពីសាលាកូមិន្នរដ្ឋបាលចំនួន ១១រូប និងផ្ទេរក្របខណ្ឌពីក្រសួងនានា ចំនួន ១រូប)
- ផ្ទេរក្របខណ្ឌមន្ត្រីរាជការ ពីក្រសួងយុត្តិធម៌ឱ្យទៅបម្រើការងារនៅក្រសួងស្ថាប័នផ្សេងទៀត ចំនួន ៣រូប
- លុបក្របខណ្ឌមន្ត្រីរាជការចំនួន ៦រូប ក្នុងនោះ ៤រូប សាមីខ្លួនស្នើសុំឈប់ ១រូប ទណ្ឌកម្មវិន័យ និង ១រូបទៀតផ្តន្ទាទោសពីតុលាការ
- បានដាក់ឱ្យមន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស មានចំនួន ២១រូប និងដាក់ឱ្យស្ថិតនៅក្រៅក្របខណ្ឌដើមចំនួន ៦រូប ព្រមទាំងអនុញ្ញាតឱ្យមន្ត្រីរាជការចូលបម្រើការងារវិញក្រោយពីដាក់ឱ្យស្ថិតនៅក្នុងទំនេរគ្មានបៀវត្សចំនួន ៣រូប
- បានស្នើសុំអត្តសញ្ញាណបណ្ណមន្ត្រីរាជការស៊ីវិល (សុពលភាព ១០ឆ្នាំ) ជូនមន្ត្រីរាជការក្រសួងយុត្តិធម៌ចំនួន ៣១៦រូប
- បានស្នើសុំបណ្ណសមាជិក ប.ស.ស. ជូនមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាក្រសួងយុត្តិធម៌ សរុបចំនួន ៥៦៤បណ្ណ និងអ្នកក្នុងបន្ទុកមន្ត្រីរាជការ (សហព័ទ្ធ និងកូន) ក្រសួងយុត្តិធម៌ ចំនួន ១០៨បណ្ណ
- បានធ្វើតេស្តរហ័សរកសារធាតុញៀនតាមទឹកមូត្រនៅទីស្តីការក្រសួងដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ចំនួន ៩១២រូប (លទ្ធផលអវិជ្ជមានទាំងអស់)
- បានផ្តល់ទិន្នន័យមន្ត្រីរាជការ ជូនក្រុមការងាររៀបចំផែនការធនធានមនុស្សក្នុងវិស័យយុត្តិធម៌ ដើម្បីជាមូលដ្ឋានក្នុងការវិភាគមុខងារ និងរៀបចំផែនការធនធានមនុស្សស្របតាមកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល។

១.១.២. ការងារអភិវឌ្ឍន៍ធនធានមនុស្ស

ផ្អែកតាមតម្រូវការអភិវឌ្ឍន៍ធនធានមនុស្ស និងសមត្ថភាពបំពេញការងាររបស់មន្ត្រីរាជការ នាយកដ្ឋាន កិច្ចការបុគ្គលិក បានផ្សព្វផ្សាយអាហារូបករណ៍ និងវគ្គបណ្តុះបណ្តាលនានា ព្រមទាំងបានសម្របសម្រួលចាត់បញ្ជូនមន្ត្រីរាជការចូលរួមវគ្គបណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាលចំនួន ២៩០រូប (វគ្គតម្រង់ទិសដំបូងចំនួន ២៨១រូប វគ្គវិក្រឹតការចំនួន ៤រូប និងវគ្គផ្សេងទៀតចំនួន ៥រូប) និងបានចាត់បញ្ជូនមន្ត្រីរាជការមួយចំនួនទៀតទៅទទួលការបណ្តុះបណ្តាលនៅបរទេស។

១.២ កិច្ចការហិរញ្ញវត្ថុ

១.២.១. រចនាសម្ព័ន្ធថវិកាកម្មវិធី

រចនាសម្ព័ន្ធថវិកាកម្មវិធីរបស់វិស័យយុត្តិធម៌ បែងចែកជា ៣ កម្មវិធី ១៦ អនុកម្មវិធី និង ៧៣ ចង្កោមសកម្មភាព ដូចខាងក្រោម៖

- កម្មវិធីទី១. កិច្ចការច្បាប់ មាន ៥ អនុកម្មវិធី និង ១៩ ចង្កោមសកម្មភាព
- កម្មវិធីទី២. កិច្ចការតុលាការ មាន ៩ អនុកម្មវិធី និង ៤៧ ចង្កោមសកម្មភាព
- កម្មវិធីទី៣. សេវាគាំទ្រទូទៅ មាន ២ អនុកម្មវិធី និង ៧ ចង្កោមសកម្មភាព

១.២.២. ការអនុវត្តចំណូល និងចំណាយ

ក. ការអនុវត្តចំណូល និងចំណាយ ឆ្នាំ២០២៤

យោងរបាយការណ៍ហិរញ្ញវត្ថុបឋម គិតត្រឹមបំណាច់ខែធ្នូ ឆ្នាំ២០២៤ វិស័យយុត្តិធម៌ បានប្រមូលចំណូលសរុបចំនួន ១៥,៦១៤.៨ លានរៀល ស្មើនឹង ១៤០.៦% ធៀបនឹងច្បាប់ថវិកាប្រចាំឆ្នាំ។ ក្នុងនោះរដ្ឋបាលកណ្តាលក្រសួងយុត្តិធម៌ បានប្រមូលចំណូលសរុប ចំនួន ៤,៦៧១.៤ លានរៀល ស្មើនឹង ១៣៣.៥% ធៀបនឹងច្បាប់ថវិកាប្រចាំឆ្នាំ។ ទន្ទឹមនេះ ការអនុវត្តចំណាយក្នុងវិស័យយុត្តិធម៌ សម្រេចបានសរុប ចំនួន ២៣៤, ៥២១.៧ លានរៀល ស្មើនឹង ១០៨.៧% ធៀបនឹងច្បាប់ថវិកាប្រចាំឆ្នាំ។ ក្នុងនោះរដ្ឋបាលកណ្តាលក្រសួងយុត្តិធម៌ បានអនុវត្តចំណាយសរុបចំនួន ៨២,២៨៧.៦ លានរៀល ស្មើនឹង ១២៦.៩% ធៀបនឹងច្បាប់ថវិកាប្រចាំឆ្នាំ។

ខ. ផែនការចំណូល និងចំណាយ ឆ្នាំ២០២៥

ក្នុងឆ្នាំ២០២៥ វិស័យយុត្តិធម៌គ្រោងប្រមូលចំណូលសរុបចំនួន ១៦,០៧៨.៦ លានរៀល ស្មើនឹង ១៤៤.៨% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២៤។ ក្នុងនោះរដ្ឋបាលកណ្តាលក្រសួងយុត្តិធម៌ គ្រោងប្រមូលចំណូលសរុប ចំនួន ៧,៨៦៩ លានរៀល ស្មើនឹង ២២៤.៨% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២៤។ ទន្ទឹមនេះ ចំពោះផែនការចំណាយ វិស័យយុត្តិធម៌ គ្រោងនឹងអនុវត្តចំណាយ សរុបចំនួន ២៣៦,២២៥ លានរៀល ស្មើនឹង ១០៩.៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២៤។ ក្នុងនោះ រដ្ឋបាលកណ្តាលក្រសួងយុត្តិធម៌ គ្រោងនឹងអនុវត្តចំណាយសរុបចំនួន ៧៣,៥៤៦ លានរៀល ស្មើនឹង ១១៣.៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២៤។

១.២.៣. ការងារហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

ក្រសួងយុត្តិធម៌ បានបញ្ចប់ការជួសជុលកែលម្អអគារទីស្តីការក្រសួងយុត្តិធម៌ ចំនួន ៣គឺ អគារបុរាណ ដែលមានអាយុកាលជិត ១០០ឆ្នាំ (អគារសាលាយុត្តិធម្ម), អតីតអគារ JICA និងអតីតអគារមហាអយ្យការ អមសាលាឧទ្ធរណ៍ភ្នំពេញ។ ទន្ទឹមនេះ ក្រសួងយុត្តិធម៌ កំពុងបន្តការជួសជុលកែលម្អអគារចំនួន ២បន្ថែមទៀត និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានារបស់ទីស្តីការក្រសួងយុត្តិធម៌។ ជាមួយគ្នានេះ ក្រសួងយុត្តិធម៌ កំពុងបន្តសាងសង់អគារសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តស្វាយរៀង និងគ្រោងធ្វើការសាងសង់អគារសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកែប ជាបន្តទៀត។

១.២.៤. ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងវិស័យយុត្តិធម៌

អនុវត្តតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងវិស័យយុត្តិធម៌ ឆ្នាំ២០២៤ ក្រសួងយុត្តិធម៌ បានសម្រេចនូវសូចនាករគន្លឹះសំខាន់ៗ រួមមាន៖

- បានធ្វើប្រតិភូកម្ម តួនាទី សិទ្ធិអំណាច និងការទទួលខុសត្រូវជូនអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ សរុបចំនួន ៤២ ដែលក្នុងនោះមានអង្គភាពថវិកាថ្មី ចំនួន១០។
- បានអនុវត្តថវិកាសមិទ្ធកម្ម ជាអាទិ៍៖ ផែនការសមិទ្ធកម្ម កិច្ចព្រមព្រៀងសមិទ្ធកម្ម របាយការណ៍សមិទ្ធកម្ម
- បានអនុវត្តប្រព័ន្ធ FMIS ទាំងស្រុង
- បានអនុវត្តប្រព័ន្ធគ្រប់គ្រងចំណូល NRMIS
- បានអនុវត្តប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ SARMIS។

១.២.៥. ការងារបណ្តុះបណ្តាល និងផ្សព្វផ្សាយកិច្ចការហិរញ្ញវត្ថុ

- បានធ្វើការបណ្តុះបណ្តាលវគ្គខ្លីលើកិច្ចការហិរញ្ញវត្ថុជូនមន្ត្រីទទួលបន្ទុកកិច្ចការហិរញ្ញវត្ថុនៅតាមអង្គភាពថវិកាសរុបចំនួន ១៩០រូប
- បានធ្វើសិក្ខាសាលាផ្សព្វផ្សាយ អំពីការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងវិស័យយុត្តិធម៌ជូនមន្ត្រីទទួលបន្ទុកកិច្ចការហិរញ្ញវត្ថុនៅតាមអង្គភាពថវិកាសរុប ចំនួន ១៩០រូប
- បានបញ្ជូនមន្ត្រីទទួលបន្ទុកកិច្ចការហិរញ្ញវត្ថុនៅតាមអង្គភាពថវិកា ទៅចូលរួមវគ្គបណ្តុះបណ្តាលវគ្គជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែងសរុប ចំនួន ៣៣រូប
- បានបញ្ជូនមន្ត្រីទទួលបន្ទុកកិច្ចការហិរញ្ញវត្ថុនៅតាមអង្គភាពថវិកា ទៅចូលរួមវគ្គបណ្តុះបណ្តាលវគ្គស្តីពីការប្រើប្រាស់ប្រព័ន្ធ FMIS សរុបចំនួន ៨៦រូប
- បានធ្វើការពន្យល់ និងផ្សព្វផ្សាយអំពីបែបបទ នីតិវិធី និងចែករំលែកបទពិសោធន៍ក្នុងការអនុវត្តការងារហិរញ្ញវត្ថុ ជូនមន្ត្រីទទួលបន្ទុកកិច្ចការហិរញ្ញវត្ថុនៅតាមអង្គភាពថវិកាជាប្រចាំ។

១.៣. កិច្ចការរដ្ឋបាល

១.៣.១. ការងារចរាចរលិខិតរដ្ឋបាល និងការងាររៀប

- ទទួលលិខិតចូលសរុបចំនួន ៨,៥២៧ លិខិត ក្នុងនោះមានសំណុំលិខិតពីសាលាដម្រះក្តីគ្រប់ជាន់ថ្នាក់ និងអយ្យការអមសាលាដម្រះក្តីគ្រប់ជាន់ថ្នាក់ បានចំនួន ៥,០៩៤ ច្បាប់ និងលិខិតមកពីតាមក្រសួងស្ថាប័ននានាចំនួន ៣,៤៣៣ ច្បាប់
- ចុះលេខលិខិតចេញសរុបចំនួន ៤,២៧៥ លិខិត
- ចេញលិខិតឧទ្ទេសនាម ៦៤៥ លិខិត និងលិខិតបញ្ជាបេសកកម្មសរុប ចំនួន ៦៤៥ លិខិត
- ទទួលពាក្យបណ្តឹងអន្តរាគមន៍សរុបចំនួន ១,០៥៧ សំណុំរឿង ពីប្រជាពលរដ្ឋ មេធាវី និងពាក្យបណ្តឹងដែលបង្វែរមកពី **ឧុទ្ធរណ៍យសម្តេចតេជោ** ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រសួង ស្ថាប័ននៃអំណាចនីតិប្រតិបត្តិ និងស្ថាប័ននៃអំណាចនីតិប្បញ្ញត្តិ ព្រមទាំងប្រភពផ្សេងៗទៀត
- ចាត់ចែងបញ្ជូនលិខិតចេញរបស់អង្គភាពនានាចំណុះក្រសួងយុត្តិធម៌ចំនួន ៤,៤១៥ លិខិត ទៅកាន់បណ្តាក្រសួង ស្ថាប័នផ្សេងៗ
- ផ្សព្វផ្សាយលិខិត ព្រះរាជក្រម អនុក្រឹត្យ និងលិខិតផ្សេងៗទៀត ជូនថ្នាក់ដឹកនាំ និងអង្គភាពនានាក្នុងក្រសួងយុត្តិធម៌ដោយផ្ទាល់ និងតាមរយៈតេឡេក្រាមរបស់ក្រសួងយុត្តិធម៌
- រៀបចំចាត់ចែងផ្តល់បណ្ណចេញ-ចូល សរុបចំនួន ១,៣៨០ បណ្ណ។

១.៣.២. ការងារពិធីការ

- រៀបចំផលិត ចងបដា ពាក្យស្លោក ទង់ជាតិ ព្រមទាំងតុបតែងព្រះឆាយាលក្ខណ៍ព្រះមហាក្សត្រ ព្រះមហាក្សត្រី និងព្រះបរមរតនកោដ្ឋ នៅមុខក្រសួងយុត្តិធម៌ តាមកម្មវិធីបុណ្យជាតិនានា ស្របតាមគោលការណ៍ណែនាំរបស់គណៈកម្មាធិការរៀបចំបុណ្យជាតិ-អន្តរជាតិ
- រៀបចំកិច្ចប្រជុំជូន**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និងថ្នាក់ដឹកនាំក្រសួងសរុបចំនួន ៣៨៦ លើក
- រៀបចំកញ្ចប់សម្ភារៈប្រើប្រាស់ប្រគល់ជូនទៅគណៈកម្មាធិការរៀបចំបុណ្យជាតិ-អន្តរជាតិសម្រាប់ចែកដល់ចាស់ជរា និងជនក្រីក្រ
- ចុះសួរសុខទុក្ខ និងនាំយកប្រាក់ឧបត្ថម្ភរបស់ថ្នាក់ដឹកនាំក្រសួងជូនមន្ត្រីរាជការមានជំងឺ
- រៀបចំលម្អបរិវេណក្រសួងយុត្តិធម៌ រួមមានសួនច្បារ ចំណតយានយន្ត ភ្លើងបំភ្លឺពេលយប់ នៅតាមរបង និងតាមអគារនានា
- រៀបចំសម្របសម្រួលលើការងារពិធីការ និងសម្ភារៈចាំបាច់នានាជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និងថ្នាក់ដឹកនាំ ដើម្បីអាចអញ្ជើញចូលរួមកម្មវិធីផ្សេងៗ
- រៀបចំរចនាផ្ទាំងរូបភាពសម្រាប់ផ្សព្វផ្សាយនៅលើបណ្តាញសង្គមរបស់ក្រសួង។

១.៣.៣. ការងារបូកសរុប

រៀបចំរបាយការណ៍ជូនរាជរដ្ឋាភិបាល តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី អំពីសកម្មភាព និងសមិទ្ធផលការងារដែលថ្នាក់ដឹកនាំក្រសួង និងអង្គភាពចំណុះក្រសួងសម្រេចបាន ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ។

១.៣.៤. ការងារសន្តិសុខ និងសណ្តាប់ធ្នាប់

- ពង្រឹងសន្តិសុខ និងសណ្តាប់ធ្នាប់នៅតាមច្រកទ្វារចេញ-ចូលនៃក្រសួងយុត្តិធម៌
- ត្រួតពិនិត្យជាប្រចាំចំពោះរថយន្តដែលមាន ឬគ្មានបណ្ណ និងអនុញ្ញាតឱ្យចេញ-ចូលក្រសួង សម្រាប់សាធារណជនដែលត្រូវមកទទួលសេវាកម្មលិខិតថ្កោលទោស
- សម្របសម្រួលទីតាំងចតយានយន្តរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងរថយន្តរបស់ភ្ញៀវ ខណៈដែលទីធ្លាសម្រាប់ចតរថយន្តមិនសមាមាត្រទៅនឹងចំនួនរថយន្ត
- រៀបចំសណ្តាប់ធ្នាប់ និងសម្រួលដល់ចរន្តចេញ-ចូលក្រសួងការងារ ក្នុងអំឡុងពេលដែលបរិវេណក្រសួងយុត្តិធម៌កំពុងស្ថិតក្នុងដំណាក់កាលនៃការសាងសង់ជួសជុលកែលម្អ។

១.៤. កិច្ចការព័ត៌មានវិទ្យា និងបរិវត្តកម្មឌីជីថល

១.៤.១. ការងារព័ត៌មានវិទ្យា

- គ្រប់គ្រងការងារទូទៅពាក់ព័ន្ធនឹងការអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យា និងទូរគមនាគមន៍សម្រាប់វិស័យយុត្តិធម៌
- អភិវឌ្ឍន៍គេហទំព័រ និងគ្រប់គ្រងបណ្តាញទំនាក់ទំនងសង្គមផ្សេងៗរបស់ក្រសួង
- បណ្តុះបណ្តាល និងផ្សព្វផ្សាយការប្រើប្រាស់ ការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា កម្មវិធីកុំព្យូទ័រដល់មន្ត្រីបម្រើការងារនៅក្នុងក្រសួង និងមន្ត្រីនៃវិស័យយុត្តិធម៌
- ជួសជុល ថែទាំ ម៉ាស៊ីនកុំព្យូទ័រ ឧបករណ៍ព័ត៌មានវិទ្យា និងកម្មវិធីកុំព្យូទ័រ
- ប្រមូលផ្តុំ និងចងក្រងឯកសារការងារផ្សេងៗ សម្រាប់ផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានវិទ្យា។

១.៤.២. ការងារផ្សព្វផ្សាយ និងថតរូបភាព

- ផ្សព្វផ្សាយសកម្មភាពរបស់ក្រសួងនៅលើបណ្តាញទំនាក់ទំនងសង្គម Telegram និង Facebook Page ចំនួន ១,៣០៧ លើក ក្នុងនោះមានដូចជា៖
  - ផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំ បានចំនួន ៨៤០ លើក
  - ផ្សព្វផ្សាយច្បាប់ បានចំនួន ១៩៨ ច្បាប់
  - ផ្សព្វផ្សាយលិខិតផ្សេងៗ បានចំនួន ២៦៩ លិខិត
- បានចុះយកព័ត៌មានអំពីសកម្មភាពការងារសំខាន់ៗរបស់ថ្នាក់ដឹកនាំក្រសួង និងអង្គភាពនានាចំណុះក្រសួងយុត្តិធម៌

- តាមដានជាប្រចាំអំពីមតិយោបល់របស់សាធារណជន ដែលបានលើកឡើងក្នុងបណ្តាញសង្គម និងធ្វើជារបាយការណ៍ជូនថ្នាក់ដឹកនាំ
- ឆ្លើយតបជូនសាធារណជន អំពីមតិយោបល់ ឬសំណួរនានាដែលពាក់ព័ន្ធនឹងសមត្ថកិច្ចការងាររបស់ក្រសួង តាមការណែនាំរបស់ថ្នាក់ដឹកនាំក្រសួង។

២. អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ

នៅក្នុងឆ្នាំ២០២៤,អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ សម្រេចបានលទ្ធផលការងារដូចខាងក្រោម៖

២.១. ការងាររដ្ឋបាល

- បានទទួលឯកសារចូល ១,០៥២ ច្បាប់
- បានធ្វើឯកសារ និងបញ្ជូនចេញ ៦៨៨ ច្បាប់

២.២. ការងារបុគ្គលិក

អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ មានមន្ត្រីសរុបចំនួន ១១៤រូប (ស្រី៣៨រូប) និងមន្ត្រីនៅតាមសាលាជម្រះក្តីសរុបចំនួន ៣,២៣៣រូប គិតត្រឹមឆ្នាំ២០២៤ ។

២.៣. ការងារបច្ចេកទេស និងទំនើបកម្មរដ្ឋបាលតុលាការ

សម្រាប់ឆ្នាំ២០២៤ អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ បានអនុវត្តសកម្មភាព និងទទួលបានចំណាត់ការឯកសារជាលទ្ធផលរួមមាន៖

- បានធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងទិន្នន័យសំណុំរឿងព្រហ្មទណ្ឌនៅតាមសាលាដំបូងរាជធានី-ខេត្ត ឱ្យកាន់តែល្អប្រសើរ
- បានកែសម្រួលសៀវភៅចុះបញ្ជីសំណុំរឿងព្រហ្មទណ្ឌឱ្យមានលក្ខណៈល្អប្រសើរ
- បានធ្វើបច្ចុប្បន្នភាពទម្រង់របាយការណ៍សកម្មភាពរបស់សាលាជម្រះក្តីឱ្យមានលក្ខណៈតែមួយ ដើម្បីងាយស្រួលធ្វើការគ្រប់គ្រង និងការបូកសរុប
- បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការងារចុះបញ្ជីសំណុំរឿងក្តី ការគ្រប់គ្រងថែរក្សាសំណុំរឿង និងឯកសារដល់មន្ត្រីរដ្ឋបាល, មុខងារថ្មីៗនៃប្រព័ន្ធចុះបញ្ជីសំណុំរឿងក្តីតាមប្រព័ន្ធអេឡិចត្រូនិក, តួនាទីភារកិច្ចអង្គភាពរដ្ឋបាលតុលាការ និងសេវាគាំទ្រផ្ទៃក្នុងតុលាការ
- បានត្រួតពិនិត្យ រៀបចំ និងកែសម្រួលសេចក្តីសម្រេចបង្កើតក្រុមការងារបញ្ជីសារពើកណ្តាលទ្រព្យសម្បត្តិរដ្ឋ និងប្រកាសតែងតាំងក្រុមលទ្ធកម្មរបស់អង្គភាពថវិកាជាថ្មីស្របតាមសំណើ និងសមាសភាពជាក់ស្តែងរបស់សាលាជម្រះក្តី
- បានបូកសរុបកញ្ចប់ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៥-២០២៧ និងគម្រោងចំណូល-ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៥ របស់សាលាជម្រះក្តី និងអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ

- រៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី "ការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** នៅបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤។

៣. អគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ

នៅក្នុងឆ្នាំ២០២៤, អគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ សម្រេចបានលទ្ធផលការងារដូចខាងក្រោម៖

៣.១. កិច្ចការអយ្យការ

៣.១.១. ចំណាត់ការលើពាក្យសុំអន្តរាគមន៍

ក. ពាក្យសុំអន្តរាគមន៍លើចំណាត់ការរបស់ស្ថាប័នអយ្យការ

ក្នុងឆ្នាំ២០២៤ កន្លងទៅនេះ, ពាក្យសុំអន្តរាគមន៍លើចំណាត់ការរបស់ស្ថាប័នអយ្យការមានចំនួនសរុប ៥២ករណី ក្នុងនោះពាក្យសុំអន្តរាគមន៍សល់ពីមុនមានចំនួន ២៧ករណី និងពាក្យសុំអន្តរាគមន៍ចូលថ្មីមានចំនួន ២៥ករណី ហើយពាក្យសុំអន្តរាគមន៍ទាំងនេះបានចាត់ការរួចហើយ។ កម្មវត្ថុនៃពាក្យសុំអន្តរាគមន៍រួមមាន ពាក្យសុំឱ្យអយ្យការធ្វើការចោទប្រកាន់, ពាក្យសុំឱ្យតម្កល់រឿងទុកឥតចាត់ការ, ពាក្យសុំប្តឹងអយ្យការ, ពាក្យសុំលើចំណាត់ការផ្សេងៗរបស់អយ្យការ, ពាក្យសុំឱ្យជួយពន្លឿននីតិវិធី, ពាក្យសុំផ្ទេរសមត្ថកិច្ច, ពាក្យសុំផ្អាកការអនុវត្តសាលក្រម ឬសាលដីកា។

ខ. ពាក្យសុំអន្តរាគមន៍លើចំណាត់ការរបស់សាលាដំបូង

ក្នុងឆ្នាំ២០២៤ កន្លងទៅនេះ, ពាក្យសុំអន្តរាគមន៍លើចំណាត់ការរបស់សាលាដំបូងមានចំនួនសរុប ៣២ករណី ក្នុងនោះពាក្យសុំអន្តរាគមន៍សល់ពីមុនមានចំនួន ១០ករណី និងពាក្យសុំអន្តរាគមន៍ចូលថ្មីមានចំនួន ២២ករណី ហើយពាក្យសុំអន្តរាគមន៍ទាំងនេះបានចាត់ការរួចហើយ។ កម្មវត្ថុនៃពាក្យសុំអន្តរាគមន៍រួមមាន ពាក្យសុំឱ្យជួយបង្អង់នីតិវិធី, ពាក្យសុំផ្ទេរសមត្ថកិច្ចតុលាការ, ពាក្យសុំទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន, ពាក្យសុំទាក់ទងនឹងដីកាដំណោះស្រាយ, ពាក្យសុំឱ្យជូនដំណឹងពីសាលក្រម ឬពាក្យសុំអនុវត្តសាលក្រម។

គ. ពាក្យសុំអន្តរាគមន៍នៅសាលាឧទ្ធរណ៍

ក្នុងឆ្នាំ២០២៤ កន្លងទៅនេះ, ពាក្យសុំអន្តរាគមន៍លើចំណាត់ការរបស់សាលាឧទ្ធរណ៍ មានចំនួនសរុប ២ករណី ហើយពាក្យសុំអន្តរាគមន៍ទាំងនេះបានចាត់ការរួចហើយ។ កម្មវត្ថុនៃពាក្យសុំអន្តរាគមន៍ រួមមានពាក្យសុំអន្តរាគមន៍ជួយបង្អង់នីតិវិធី និងពាក្យសុំផ្ទេរសមត្ថកិច្ចតុលាការ។

៣.១.២. ការពិនិត្យពាក្យសុំនីតិសម្បទាជាន់គរបាលយុត្តិធម៌

ក្រសួងយុត្តិធម៌ បានផ្តល់នីតិសម្បទាជាន់គរបាលយុត្តិធម៌ដល់មន្ត្រីរបស់ក្រសួង ស្ថាប័ននានា បានសរុបចំនួន ១,០៨៩រូប ក្នុងនោះរួមមាន៖ ក្រសួងមហាផ្ទៃចំនួន ៥៣១រូប, អាជ្ញាធរសេរ៉ាហិរញ្ញវត្ថុមិនមែន

ធនាគារចំនួន ១២រូប, ក្រសួងអភិវឌ្ឍន៍ជនបទចំនួន ១២៤រូប, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ៥៥រូប, ក្រសួងការពារជាតិចំនួន ១០៧រូប និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន ២៥៩រូប។

៣.២. កិច្ចការព្រហ្មទណ្ឌ និងនគរបាលយុត្តិធម៌

ដើម្បីជាមូលដ្ឋានក្នុងការបង្ហាញអំពីស្ថានភាពជាក់ស្តែង និងចំណាត់ការនៃសំណុំរឿងព្រហ្មទណ្ឌនៅតាមសាលាជម្រះក្តីទូទាំងប្រទេស, សូមមេត្តាពិនិត្យមើលរបាយការណ៍ស្ថិតិសំណុំរឿងលម្អិតដូចមានជូនភ្ជាប់នៅក្នុង "ឧបសម្ព័ន្ធទី១ - បទបង្ហាញអំពីទិន្នន័យសំណុំរឿងទូទាំងប្រទេស ឆ្នាំ២០២៤"។

៣.៣. កិច្ចការគ្រប់គ្រងវត្ថុតាង និងផលនៃបទល្មើស

វត្ថុតាងក្នុងបទល្មើសព្រហ្មទណ្ឌទូទៅដែលទទួលបានពីសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី ខេត្ត រួមមាន អាវុធជាតិផ្ទុះចំនួន ១,៣៧២, រថយន្តចំនួន ៦១គ្រឿង, ម៉ូតូចំនួន ៨៣៤គ្រឿង,ទូរសព្ទចំនួន ១,៩២៩គ្រឿង, រូបិយបណ្ណប្រាក់ដុល្លារអាម៉េរិកចំនួន ៧០,៩៩៤ និងវត្ថុតាងផ្សេងៗ ចំនួន ៣,៣៨៩វត្ថុ។

៣.៤. ការរៀបចំ និងចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំ

អគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ បានរៀបចំ និងចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំចំនួន ២០៣ដង ដែលមានមន្ត្រីចូលរួមម្តងចំនួន ៣ ទៅ ៤រូប ដោយរួមមាន ការងារប្រឆាំងការជួញដូរមនុស្ស (ចំនួន ៤១ដង), ការងារប្រឆាំងការសម្អាតប្រាក់ (ចំនួន ៤៤ដង), ការងារយុត្តិធម៌អនីតិជន (ចំនួន ៨ដង), កិច្ចការនគរបាលយុត្តិធម៌ (ចំនួន ២ដង), កិច្ចការវត្ថុតាង និងផលនៃបទល្មើស(ចំនួន ៣ដង), កិច្ចការហិរញ្ញវត្ថុ (ចំនួន ៣៨ដង), កិច្ចប្រជុំផ្ទៃក្នុងអគ្គនាយកដ្ឋាន (ចំនួន ៣ដង) និងកិច្ចប្រជុំជាមួយស្ថាប័នពាក់ព័ន្ធ (ចំនួន ៦៤ដង)។

៤. អគ្គនាយកដ្ឋានកិច្ចការទោសព្រហ្មទណ្ឌ

នៅក្នុងឆ្នាំ២០២៤, អគ្គនាយកដ្ឋានកិច្ចការទោសព្រហ្មទណ្ឌ សម្រេចបានលទ្ធផលការងារដូចខាងក្រោម៖

៤.១. កិច្ចការរដ្ឋបាល

- លិខិតស្នាមផ្សេងៗ មកពីក្រសួង-មន្ទីរនានា	៩៨	ច្បាប់
- ចេញលិខិតស្នាមផ្សេងៗ ទៅក្រសួង-មន្ទីរនានា	២៧៦	ច្បាប់
- លិខិតស្នាមផ្សេងៗ មកពីសាលាដំបូងរាជធានី-ខេត្ត	១៨៤	ច្បាប់
- ចេញលិខិតស្នាមផ្សេងៗ ទៅសាលាដំបូងរាជធានី-ខេត្ត	១៤៦	ច្បាប់
- សាលក្រម	១២,០១១	ច្បាប់
- សាលដីកា	៣,០១០	ច្បាប់
- ពាក្យបណ្តឹងសល់ពីមុន	៤	ច្បាប់

- ពាក្យបណ្តឹងចូលថ្មី ១៧ ច្បាប់
- ពាក្យបណ្តឹងចាត់ការរួច ១៨ ច្បាប់
- ពាក្យបណ្តឹងកំពុងចាត់ការ ៦ ច្បាប់

៤.២. កិច្ចការឆ្ពោះទោស

៤.២.១. អំពីការបញ្ចូលសលាកបត្រផ្តន្ទាទោសតាមប្រព័ន្ធបច្ចេកវិទ្យា

- បានបញ្ចូលឈ្មោះទណ្ឌិតទៅក្នុងសលាកបត្រផ្តន្ទាទោសនៃបញ្ជីឆ្ពោលទោស តាមប្រព័ន្ធព័ត៌មានវិទ្យាបានចំនួន ៧១,៨១០រូប។
- បានបញ្ចូលទិន្នន័យសាលក្រម សាលដីកាព្រហ្មទណ្ឌស្កាពរ (Scan) ទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យាបានចំនួន ២,៧៧០ច្បាប់។

៤.២.២. អំពីការទទួលបានពាក្យសុំ និងចេញព្រឹត្តិបត្រឆ្ពោលទោស

- បានទទួលពាក្យសុំ និងចេញព្រឹត្តិបត្រឆ្ពោលទោស ជូនសាធារណជនមានដូចខាងក្រោម៖
  - ទទួលពាក្យសុំព្រឹត្តិបត្រឆ្ពោលទោសលេខ៣ ក្នុងឆ្នាំ២០២៤ មានចំនួន ៧៣,៥១៣ ច្បាប់ ក្នុងនោះមានទទួលពាក្យតាម Online ចំនួន ២១,១១១ច្បាប់។
  - ចេញព្រឹត្តិបត្រឆ្ពោលទោសលេខ៣ ក្នុងឆ្នាំ២០២៤ បានចំនួន ៧១,១៩៤ច្បាប់ ក្នុងនោះមានចេញតាម Online ចំនួន ៥២២ច្បាប់។
  - កំពុងចាត់ការបន្តព្រឹត្តិបត្រឆ្ពោលទោសលេខ៣ ចាប់ពីថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៤ ចំនួន ២,៣១៩ច្បាប់។

៤.៣. កិច្ចការអនុគ្រោះទោស

៤.៣.១. សំណើសុំបន្ធូរបន្ថយទោស និងលើកលែងទោស

បានទទួលសំណើសុំបន្ធូរបន្ថយទោស និងលើកលែងទោសពីគណៈកម្មការរាជធានីខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ មានទណ្ឌិតសរុបចំនួន ១,៧៣៥រូប (ស្រី ១៤៦រូប) រួមមាន៖

- ស្នើសុំបន្ធូរបន្ថយទោស ៣ខែ ចំនួន ១,០៣២រូប (ស្រី ៨១រូប)
- ស្នើសុំបន្ធូរបន្ថយទោស ៦ខែ ចំនួន ៤៦៤រូប (ស្រី ៤រូប)
- ស្នើសុំបន្ធូរបន្ថយទោស ៩ខែ ចំនួន ១២៧រូប (ស្រី ១៧រូប)
- ស្នើសុំបន្ធូរបន្ថយទោស ១២ខែ ចំនួន ៣០រូប (ស្រី ០០រូប)
- ស្នើសុំបន្ថយទោសមួយជីវិតមកនៅ៣០ឆ្នាំ ចំនួន ៤រូប (ស្រី ០០រូប)
- ស្នើសុំលើកលែងទោស ចំនួន ៧៨រូប (ស្រី ៦រូប)។

៤.៣.២. ព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងលើកលែងទោស

ក្នុងឆ្នាំ២០២៤នេះ គោរពអនុវត្តតាមព្រះរាជក្រឹត្យគ្រាស់បង្គាប់ការបន្ធូរបន្ថយទោស និងការលើកលែងទោសដល់ទណ្ឌិតសរុបចំនួន ១,១៤៣រូប (ស្រី ១០៤រូប) រួមមាន៖

- ទទួលបានការបន្ធូរបន្ថយទោស ៣ខែ ចំនួន ៨១៥រូប (ស្រី ៦៥រូប)
- ទទួលបានការបន្ធូរបន្ថយទោស ៦ខែ ចំនួន ២៦៦រូប (ស្រី ២៩រូប)
- ទទួលបានការបន្ធូរបន្ថយទោស ៩ខែ ចំនួន ២៥រូប (ស្រី ៦រូប)
- ទទួលបានការបន្ធូរបន្ថយទោស ១២ខែ ចំនួន ៦រូប (ស្រី ១រូប)
- ទទួលបានការបន្ថយទោសមួយជីវិតមកនៅ៣០ឆ្នាំ ចំនួន ១រូប (ស្រី ០០រូប)
- ទទួលបានការលើកលែងទោស ចំនួន ៣០រូប (ស្រី ៣រូប)។

ការលើកលែងទោសក្នុងករណីផ្សេងៗមានចំនួន ២៨រូប (ស្រី ៣រូប)។

៤.៤. កិច្ចការអនុវត្តន៍ទោស

៤.៤.១. ទិន្នន័យជនជាប់ឃុំនៅក្នុងមណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី-ខេត្ត

គិតត្រឹមថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤ ជនជាប់ឃុំទូទាំងប្រទេសមានចំនួន ៥៣ ៦៨៧ រូប (ស្រី ៣ ២១៥ រូប) ដែលកំពុងឃុំនៅតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី-ខេត្ត ក្នុងនោះរួមមាន៖

១. ជនត្រូវចោទ	ចំនួន	១១,៩៥៣រូប	(ស្រី ៧៧៩រូប)
២. ជនជាប់ចោទ	ចំនួន	៦,១០៥រូប	(ស្រី ៤០៧រូប)
៣. ពិរុទ្ធជន	ចំនួន	២១,៥២២រូប	(ស្រី ១,២៧៨រូប)
៤. ទណ្ឌិត	ចំនួន	១៤,១០៧រូប	(ស្រី ៧៥១រូប) ។

ជនជាប់ឃុំក្នុងថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤ កើនឡើងជនជាប់ឃុំជារួមចំនួន ១៣០រូប និងស្ត្រីកើនចំនួន ២៤រូប។

៤.៤.២. ការដោះលែងដោយមានលក្ខខណ្ឌ

- បានទទួលសំណើសុំការដោះលែងដោយមានលក្ខខណ្ឌពីសាលាដំបូងរាជធានី-ខេត្ត ចំនួន ៣២ ពាក្យស្នើសុំ (ស្រី ២រូប)
- ក្នុងចំណោម ៣២ ពាក្យស្នើសុំ, គណៈកម្មការជាតិដោះលែងដោយមានលក្ខខណ្ឌបានផ្តល់យោបល់ទៅតាមសាលាដំបូងរាជធានី-ខេត្ត វិញមានចំនួន ៣២ ពាក្យស្នើសុំ
  - គប្បីដោះលែង ចំនួន ២រូប
  - មិនគប្បីដោះលែង ចំនួន ៣០រូប (ស្រី ២រូប)។
- បានទទួលសេចក្តីសម្រេចពីសាលាដំបូងរាជធានី-ខេត្ត មានចំនួន៖
  - សម្រេចដោះលែងមានចំនួន ៦រូប
  - មិនសម្រេចដោះលែងមានចំនួន ១៣រូប (ស្រី ១រូប)

- ស្ថិតក្នុងចំណាត់ការចំនួន ១៣រូប (ស្រី ១រូប)។

៤.៤.៣. ការអនុវត្តទោសការងារសហគមន៍

បានរៀបចំឯកសារទស្សនាទាន ក្នុងការត្រៀមដាក់អនុវត្តទោសការងារសហគមន៍ ព្រមទាំងកំពុងរៀបចំការពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ដើម្បីស្វែងរកការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ។

៥. អគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

នៅក្នុងឆ្នាំ២០២៤, អគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី សម្រេចបានលទ្ធផលការងារ ដូចខាងក្រោម៖

៥.១. ការចូលរួមអនុវត្តសកម្មភាពក្នុងយុទ្ធនាការរបស់ក្រសួងយុត្តិធម៌

ក្នុងនាមជាអង្គភាពជំនាញបច្ចេកទេសរបស់ក្រសួងយុត្តិធម៌, ថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី បានចូលរួមជាអនុប្រធាន និងសមាជិកនៃក្រុមការងារនៃយុទ្ធនាការ និងអង្គភាពចំណុះគណៈបញ្ជាការដឹកនាំយុទ្ធនាការ ក្រោមការដឹកនាំដោយផ្ទាល់របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** ដោយក្នុងនោះ៖

- មន្ត្រីចំនួន ៨រូប ជាសមាជិកនៃគណៈកម្មការដឹកនាំនិងអនុវត្តយុទ្ធនាការជំរុញនិងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ
- ថ្នាក់ដឹកនាំ និងមន្ត្រីចំនួន ១៩រូប ជាអនុប្រធាន និងសមាជិកនៃគណៈកម្មការដឹកនាំ និងអនុវត្តយុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ
- មន្ត្រីចំនួន ៥រូប ជាសមាជិកនៃលេខាធិការដ្ឋានគណៈបញ្ជាការដឹកនាំយុទ្ធនាការ។

ថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី បានចូលរួមចំណែកយ៉ាងសកម្មក្នុងយុទ្ធនាការទាំងពីរខាងលើរបស់ក្រសួងយុត្តិធម៌, ពិសេស ការងារពិនិត្យ និងដោះស្រាយលើបណ្តឹងរបស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងសំណុំរឿងរដ្ឋប្បវេណី។

៥.២. ការងារផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព

អគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ដែលមាននាយកដ្ឋានចំណុះចំនួន ៥ បានរៀបចំជាសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងវិស័យជំនាញក្នុងសមត្ថកិច្ចរបស់ខ្លួន ដូចខាងក្រោម៖

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្ន ក្នុងសំណុំរឿងក្សីយធន
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ទាក់ទងនឹងការអនុវត្តវិជ្ជាជីវៈសារការី
- រៀបចំសិក្ខាសាលាផ្លាស់ប្តូរបទពិសោធន៍ទាក់ទងនឹងការអនុវត្តវិជ្ជាជីវៈសារការី
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយពាក់ព័ន្ធនឹងក្រមរដ្ឋប្បវេណី
- រៀបចំសិក្ខាសាលាពាក់ព័ន្ធនឹងជំនួយផ្នែកច្បាប់ ចំនួន ២ លើក

- រៀបចំវគ្គបណ្តុះបណ្តាលពង្រឹងបច្ចេកទេសសន្ទានកម្ម នៅខេត្តកណ្តាល និងខេត្តតាកែវ ចំនួន ១ លើក។

ទន្ទឹមនេះ ដោយមានការអនុញ្ញាតពី **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** និងថ្នាក់ដឹកនាំក្រសួងដែលទទួលបន្ទុក, អគ្គនាយកដ្ឋានក៏បានចាត់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលជាច្រើន រួមមាន៖

- ជំនួបពិភាក្សាជាមួយ ឯកឧត្តមអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ សហការជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ អំពីគម្រោងបើកវគ្គបណ្តុះបណ្តាលអំពីអនុសញ្ញាស្តីពីជនពិការដល់មន្ត្រីយុត្តិធម៌
- ចូលរួមកិច្ចប្រជុំនៃក្រុមការងារបច្ចេកទេស ដើម្បីអនុវត្តផែនការប្រតិបត្តិ និងផែនការសកម្មភាពនៃគម្រោងអភិវឌ្ឍន៍វិស័យច្បាប់ និងយុត្តិធម៌ ដំហានទី៦
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីបទដ្ឋានគតិយុត្ត នៃការធ្វើហិរញ្ញប្បទានដោយវិស័យឯកជន សម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន
- ចូលរួមកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើឯកសារសម្រាប់រៀបចំផែនការធនធានមនុស្សក្នុងវិស័យយុត្តិធម៌ របស់អគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី និងពិភាក្សាលើការពិនិត្យឡើងវិញ វិភាគមុខងារ រចនាសម្ព័ន្ធ និងផែនការធនធានមនុស្សជាមួយអង្គភាពចំណុះឱ្យវិស័យយុត្តិធម៌
- ចូលរួមពិភាក្សាការងារ និងពិគ្រោះយោបល់ជាមួយប្រធានបេសកកម្មរបស់មូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំកម្ពុជា
- ចូលរួមសិក្ខាសាលាស្តីពីការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធនៃក្រសួងយុត្តិធម៌ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង ឯកឧត្តម ហ៊ុន ម៉ានី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ** នៅបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា
- ផ្តល់កិច្ចសម្ភាសន៍ ជាមួយក្រុមការងារនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងទីប្រឹក្សាឯករាជ្យដែលគាំទ្រដោយអង្គការ Vital Strategies ពាក់ព័ន្ធនឹងទិដ្ឋភាពទូទៅនៃការអនុវត្តច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម
- ចូលរួមកិច្ចប្រជុំកម្មវិធីអំពីការផ្តល់ហិរញ្ញប្បទាន ដើម្បីអភិវឌ្ឍន៍គោលនយោបាយ និងភាពធន់របស់កម្ពុជា លើកទី២ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចឆ្នាំ ២០២៥-២០៣៥ នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- ចូលរួមសិក្ខាសាលាស្តីពីទីផ្សារឧបករណ៍និស្សន្ទ និងកិច្ចពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី " Close-Out Netting" នៅសណ្ឋាគារ Raffle Le Royal ភ្នំពេញ។

ជាមួយគ្នានេះ ពាក់ព័ន្ធនឹងការងារផ្សព្វផ្សាយលើវិស័យការងារជំនាញដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន, អគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី បានអនុវត្តសកម្មភាពដូចខាងក្រោម៖

- បានចូលរួមជាវាគ្មិនកិត្តិយសក្នុងក្នុងកម្មវិធីអំណាចច្បាប់ (Legal Power) របស់ស្ថានីយ៍ទូរទស្សន៍ CNC និង CBS Digital ចំនួន ៥ លើក ដោយផ្តោតលើប្រធានបទសំខាន់ៗ ដូចជា (ទី១)- "បទរំលោភអំណាចមេបា", (ទី២)- "នីតិវិធីនៃការលក់ទ្រព្យកូនបំណុលសងម្ចាស់បំណុល", (ទី៣)- "នីតិវិធីនៃកែតម្រូវអត្តសញ្ញាណ និងការដោះស្រាយសំណុំរឿងអត្រានុកូលដ្ឋាន" (ទី៤)- "ធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដូចម្តេចឱ្យត្រឹមត្រូវតាមច្បាប់?" និង (ទី៥)- "ភាពខុសគ្នារវាងសារការី និងមេធាវី"
- បានរៀបចំផលិតវីដេអូខ្លីដើម្បីផ្សព្វផ្សាយអំពីវិជ្ជាជីវៈសារការីក្នុងរឿងសន្តតិកម្ម និងវីដេអូខ្លី ផ្សព្វផ្សាយពាក់ព័ន្ធនឹងសំណុំរឿងក្ស័យធន។

៥.៣. ការងារតាមជានការអនុវត្តច្បាប់ឆ្លងប្បវេណីនៅតាមតុលាការ

អគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី តាមរយៈអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ និងក្រុមលេខាធិការដ្ឋានយុទ្ធនាការ បានប្រមូលទិន្នន័យចំណាត់ការសំណុំរឿង ដែលបែងចែកជាប្រភេទនៃពាក្យបណ្តឹង និងប្រភេទនៃវិវាទ ដែលចាត់ការដោយតុលាការរាជធានីខេត្ត សម្រាប់រយៈពេលពេញមួយឆ្នាំ២០២៤។

ដើម្បីជាមូលដ្ឋានក្នុងការបង្ហាញអំពីស្ថានភាពជាក់ស្តែង និងចំណាត់ការនៃសំណុំរឿងព្រហ្មទណ្ឌនៅតាមសាលាជម្រះក្តីទូទាំងប្រទេស, សូមមេត្តាពិនិត្យមើលរបាយការណ៍ស្ថិតិសំណុំរឿងលម្អិតដូចមានជូនភ្ជាប់នៅក្នុង "ឧបសម្ព័ន្ធទី១ - បទបង្ហាញអំពីទិន្នន័យសំណុំរឿងទូទាំងប្រទេស ឆ្នាំ២០២៤"។

៥.៤. ការចូលរួមក្នុងក្រុមការងារចំពោះកិច្ច

បន្ថែមលើការអនុវត្តការងារស្នូលរបស់អគ្គនាយកដ្ឋាន, **ឯកឧត្តម យ៉ម ផារ៉ូត** ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយកកិច្ចការរដ្ឋប្បវេណី និង**លោក កាន់ សុទ្ធប៉ូលីន** ប្រធាននាយកដ្ឋាន ត្រូវបានចាត់ឱ្យចូលរួមជាសមាជិកក្រុមការងារជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ ដើម្បីអនុវត្ត "កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ ឆ្នាំ២០២៤" ដែលជាកម្មវិធីអាទិភាពមួយក្នុងការជំរុញសកម្មភាពវិនិយោគនៅក្នុងខេត្តព្រះសីហនុ។ ក្នុងនាមជាសមាជិកក្រុមការងារ, **ឯកឧត្តម យ៉ម ផារ៉ូត** និង**លោក កាន់ សុទ្ធប៉ូលីន** បានចូលរួមកិច្ចប្រជុំពិនិត្យដោះស្រាយគម្រោងអគារជាប់គាំងនៅខេត្តព្រះសីហនុ បានចំនួន ២១គម្រោង។

ជាមួយគ្នានេះ **ឯកឧត្តម យ៉ម ផារ៉ូត** និង**លោក កាន់ សុទ្ធប៉ូលីន** បានចូលរួមកិច្ចប្រជុំជាមួយតំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, រដ្ឋបាលខេត្តព្រះសីហនុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីសម្របសម្រួលដោះស្រាយបញ្ចប់វិវាទក្រៅប្រព័ន្ធតុលាការ លើគម្រោងអគារជាប់គាំងចំនួន **១៣ ទីតាំង** ដែលសុទ្ធសឹងជាវិវាទរ៉ាំរ៉ៃអូសបន្លាយពេលពី ៣ ទៅ ៤ឆ្នាំ។

ក្រៅពីក្រុមការងារខាងលើ, ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានក៏បានចូលរួមក្នុងក្រុមការងារចំពោះកិច្ចមួយចំនួនផ្សេងទៀត ដែលពាក់ព័ន្ធនឹងវិស័យការងារ, វិស័យសង្គមកិច្ច, វិស័យសេដ្ឋកិច្ច និងវិនិយោគ ជាដើម។

៥.៥. ការចុះបំពេញបេសកកម្មក្រៅប្រទេស និងក្នុងប្រទេស

- បានដឹកនាំគណៈប្រតិភូចូលរួមទស្សនកិច្ចសិក្សាស្វែងយល់ និងផ្លាស់ប្តូរបទពិសោធន៍អំពីកិច្ចការច្បាប់ក្នុងវិស័យរដ្ឋប្បវេណី និងកិច្ចការសារការី នៅសាធារណរដ្ឋប្រជាមានិតចិន
- បានចុះត្រួតពិនិត្យអំពីការអនុវត្តច្បាប់ក្នុងវិស័យរដ្ឋប្បវេណី នៅសាលាដំបូងខេត្តបាត់ដំបង, ខេត្តកំពង់ធំ និងខេត្តសៀមរាប
- បានចុះស្រាវជ្រាវ និងតាមដានការអនុវត្តសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី នៅសាលាដំបូងខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តកំពង់ឆ្នាំង
- បានចុះសិក្សា ស្រាវជ្រាវ និងវាយតម្លៃពាក់ព័ន្ធកិច្ចការក្សេមធន អភិបាលបណ្តោះអាសន្ន និងអ្នកជម្រះបញ្ជី នៅសាលាដំបូងខេត្តកំពង់ធំ ខេត្តព្រះសីហនុ និងខេត្តសៀមរាប
- បានចុះសិក្សា ស្រាវជ្រាវ និងវាយតម្លៃពាក់ព័ន្ធនឹងកិច្ចការសារការីនៅសាលាដំបូងខេត្តសៀមរាប និងសាលាដំបូងខេត្តបាត់ដំបង។

៥.៦. ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងជំនួយផ្នែកច្បាប់

ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងជំនួយផ្នែកច្បាប់ ក៏ជាការងារអាទិភាព និងស្នូលមួយផងដែររបស់ក្រសួងយុត្តិធម៌ ក៏ដូចជារបស់អគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីផងដែរ។ អគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី តាមរយៈនាយកដ្ឋានដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងជំនួយផ្នែកច្បាប់ បានអនុវត្តសកម្មភាពមួយចំនួនដូចខាងក្រោម៖

៥.៦.១. ការអនុវត្តសកម្មភាពការងារ

- ចូលរួមកិច្ចប្រជុំពាក់ព័ន្ធនឹងការងារផ្តល់ជំនួយផ្នែកច្បាប់ ចំនួន ៥ ដង
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការរៀបចំគម្រោងសម្រាប់ការដោះស្រាយវិវាទ និងជំនួយផ្នែកច្បាប់ ជូនប្រជាពលរដ្ឋរស់នៅតំបន់ដាច់ស្រយាល និងតំបន់ជនជាតិដើមភាគតិច
- ចុះជួបពិភាក្សាជាមួយ អភិបាល អភិបាលរង និងមន្ត្រីការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន ដើម្បីពិនិត្យ តាមដាន វាយតម្លៃ លើការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ក្នុងខេត្តចំនួន ៩ និងក្រុង ស្រុក ចំនួន ២៧
- ជួបប្រជុំពិភាក្សាការងារជាមួយអង្គការនារីដើម្បីសន្តិភាព លើការរៀបចំសៀវភៅណែនាំប្រតិបត្តិ សម្រាប់មន្ត្រីការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋានក្រុង ស្រុក ខណ្ឌ

- ចូលរួមផ្តល់បទឧទ្ទេសនាម សម្រាប់ក្រុមគោលដៅជាប្រធានការិយាល័យក្រុង ស្រុក ខណ្ឌ ស្តីពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅទីស្តីការក្រសួងមហាផ្ទៃ
- ចូលរួមផ្តល់បទឧទ្ទេសនាម សម្រាប់ក្រុមគោលដៅជាអភិបាលរងក្រុង ស្រុក ស្តីពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅទីស្តីការក្រសួងមហាផ្ទៃ
- ចូលរួមផ្តល់បទឧទ្ទេសនាម សម្រាប់ក្រុមគោលដៅជាអភិបាលរងរាជធានី ខេត្ត ស្តីពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅទីស្តីការក្រសួងមហាផ្ទៃ
- ចូលរួមជាគ្រូឧទ្ទេសនាមនៃវគ្គបណ្តុះបណ្តាលស្តីពីការសម្របសម្រួល និងការដោះស្រាយវិវាទដល់ថ្នាក់ដឹកនាំដែលជាអគ្គនាយករង, ប្រធាន-អនុប្រធាននាយកដ្ឋាន, ប្រធាន-អនុប្រធានការិយាល័យ និងមន្ត្រី នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

៥.៦.២. ការផ្តល់សេវាយុត្តិធម៌នៅមូលដ្ឋានជូនប្រជាពលរដ្ឋ

ក. ការប្រឹក្សាយោបល់ផ្នែកច្បាប់ជូនប្រជាពលរដ្ឋ

នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធមួយចំនួន បានផ្តល់ប្រឹក្សាយោបល់ផ្នែកច្បាប់សរុបចំនួន ១,១៧៧ ករណី ដោយក្នុងនោះ៖

- នាយកដ្ឋានបានទទួលប្រឹក្សាយោបល់ផ្នែកច្បាប់ជូនប្រជាពលរដ្ឋចំនួន ៣៧ ករណី
- ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋានចំនួន ៩០ក្រុង ស្រុក ខណ្ឌ ស្ថិតក្នុងខេត្ត ចំនួន១៣ បានទទួលប្រឹក្សាយោបល់ផ្នែកច្បាប់ជូនប្រជាពលរដ្ឋបានចំនួន ៨៥៩ ករណី
- គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ចំនួន ៥៦ នៃខេត្ត ចំនួន ៦ បានទទួលប្រឹក្សាយោបល់ផ្នែកច្បាប់ជូនប្រជាពលរដ្ឋបានចំនួន ២៨១ ករណី

ខ. ការសម្រុះសម្រួលវិវាទជូនប្រជាពលរដ្ឋ

ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋានចំនួន ៩០ ក្រុង ស្រុក ខណ្ឌ ស្ថិតក្នុងរាជធានី ខេត្ត ចំនួន ១៣ បានផ្តល់សេវាសម្រុះសម្រួលវិវាទជូនប្រជាពលរដ្ឋ បានចំនួន ៣,២០៣ ករណី ក្នុងនោះបានដោះស្រាយករណីវិវាទសរុបចំនួន ៖

- គូភាគីបានព្រមព្រៀងចំនួន ១,៤៤៩ ករណី
- កំពុងសម្រុះសម្រួលចំនួន ៦២០ ករណី
- តម្កល់ចំនួន ៦៥៨ ករណី
- ចង្អុលបង្ហាញចំនួន ៤៧៦ ករណី ។

គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ-សង្កាត់ បានផ្តល់សេវាសម្រុះសម្រួលវិវាទជូនប្រជាពលរដ្ឋបានចំនួន ៤១១ ករណី។

គ. អំពីជំនួយផ្នែកច្បាប់ និងសិទ្ធិទទួលបានយុត្តិធម៌

នាយកដ្ឋានបានចុះប្រជុំ ត្រួតពិនិត្យ និងវាយតម្លៃការផ្តល់សេវាជំនួយផ្នែកច្បាប់នៅតាមសាលាដំបូងខេត្ត ចំនួន ១៦ រួមមាន៖ សាលាដំបូងខេត្តតាកែវ ខេត្តកែប ខេត្តកំពង់ស្ពឺ ខេត្តកំពត ខេត្តពង់ឆ្នាំង ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តមណ្ឌលគិរី ខេត្តរតនគិរី ខេត្តព្រៃវែង និងខេត្តស្វាយរៀង ដោយទទួលបានស្ថិតិសំណុំរឿងសរុបចំនួន ២៤,៩៤២ សំណុំរឿង (សំណុំរឿងព្រហ្មទណ្ឌចំនួន ១៤,៤៥៧ និងសំណុំរឿងរដ្ឋប្បវេណីចំនួន ១០,៤៨៥) ដែលមានមេធាវីការពារចំនួន ៣,៧៦៩ ករណី និងសំណុំរឿងមិនទាន់មានមេធាវីការពារមានចំនួន ២១,១៧៣ ករណី។

ឃ. ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

នៅក្នុងឆ្នាំ២០២៤, នាយកដ្ឋានបានចុះប្រជុំ និងវាយតម្លៃការអនុវត្តការងាររបស់ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាននៃរដ្ឋបាលក្រុង ស្រុកចំនួន ១៨ នៃខេត្តគោលដៅចំនួន ៦ រួមមាន ខេត្តបន្ទាយមានជ័យ, ខេត្តបាត់ដំបង, ខេត្តតាកែវ, ខេត្តកំពង់ឆ្នាំង, ខេត្តកំពត និងខេត្តកំពង់ស្ពឺ ជាលទ្ធផលនាយកដ្ឋានពិនិត្យឃើញថា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ បានសរុបចំនួន ៤៧៩ ករណី (បានព្រមព្រៀងបញ្ចប់វិវាទ ២៣៧ ករណី, កំពុងសម្រុះសម្រួល ១៣៨ ករណី, នីតិវិធីបន្ត ៦៦ ករណី និងតម្កល់ ៣៨ ករណី)។

៦. អគ្គាធិការដ្ឋានកិច្ចការតុលាការ

នៅក្នុងឆ្នាំ២០២៤, អគ្គាធិការដ្ឋានកិច្ចការតុលាការ សម្រេចបានចាត់ការសំណុំរឿងសរុបចំនួន **៩១** សំណុំរឿង ក្នុងនោះ សំណុំរឿងព្រហ្មទណ្ឌចំនួន **៦០** និង សំណុំរឿងរដ្ឋប្បវេណីចំនួន **៣១**

- ធ្វើលិខិតជូនដំណឹងទៅម្ចាស់បណ្តឹង៖ មានចំនួន **២៤**សំណុំរឿង
- សំណុំរឿងតម្កល់ទុកតាមដាន៖ មានចំនួន **១១**សំណុំរឿង
- ធ្វើលិខិតចាត់បញ្ជូន និងស្នើសុំឱ្យស្ថាប័នតុលាការ និងអយ្យការលើកយកសំណុំរឿងមកចាត់ការឱ្យបានឆាប់ស្របតាមនីតិវិធីច្បាប់៖ មានចំនួន **២៣**សំណុំរឿង
- ធ្វើលិខិតឱ្យស្ថាប័នតុលាការ និងអយ្យការធ្វើរបាយការណ៍បំភ្លឺមកក្រសួងដើម្បីមានមូលដ្ឋានគ្រប់គ្រាន់ សម្រាប់ចាត់ការទៅតាមនីតិវិធីច្បាប់៖ មានចំនួន **១៥**សំណុំរឿង
- ធ្វើលិខិតចាត់បញ្ជូនសំណុំរឿងវិន័យ ទៅក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម៖ មានចំនួន **៩**សំណុំរឿង
- ធ្វើលិខិតអញ្ជើញឱ្យមកឆ្លើយបំភ្លឺនៅទីស្តីការក្រសួង៖ មានចំនួន **៧**សំណុំរឿង
- សមត្ថកិច្ចសាលាជម្រះក្តី (ផ្ទេរសំណុំរឿង)៖ មានចំនួន **២**សំណុំរឿង ក្នុងនោះសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត មានចំនួន **២**សំណុំរឿង ។

៧. អគ្គនាយកដ្ឋានកិច្ចការអន្តរជាតិ និងអភិវឌ្ឍន៍វិស័យយុត្តិធម៌

នៅក្នុងឆ្នាំ២០២៤, អគ្គនាយកដ្ឋានកិច្ចការអន្តរជាតិ និងអភិវឌ្ឍន៍វិស័យយុត្តិធម៌ សម្រេចបានលទ្ធផលការងារ ដូចខាងក្រោម៖

៧.១. កិច្ចការអាជ្ញាធរកណ្តាល

នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងសហប្រតិបត្តិការផ្នែកច្បាប់ និងនាយកដ្ឋានកិច្ចការច្បាប់ និងកិច្ចសហប្រតិបត្តិការអាស៊ាន ជាសេនាធិការឱ្យក្រសួងយុត្តិធម៌លើការងារអាជ្ញាធរកណ្តាលសម្រាប់កិច្ចសហប្រតិបត្តិការផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនិងវិស័យរដ្ឋប្បវេណី បត្យាប័ន និងការផ្ទេរទណ្ឌិត ដែលក្នុងនោះនាយកដ្ឋានកិច្ចការច្បាប់ និងកិច្ចសហប្រតិបត្តិការអាស៊ានទទួលបន្ទុកបណ្តាប្រទេសជាសមាជិកអាស៊ាន ហើយនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងសហប្រតិបត្តិការផ្នែកច្បាប់ ទទួលបន្ទុកបណ្តាប្រទេសផ្សេងទៀតក្រៅពីប្រទេសជាសមាជិកអាស៊ាន។

ក្នុងឆ្នាំ២០២៤ ក្នុងនាមជាសេនាធិការឱ្យអាជ្ញាធរកណ្តាល អគ្គនាយកដ្ឋានទទួលបានសំណើចូលនិងរៀបចំសំណើចេញ សម្រាប់កិច្ចសហប្រតិបត្តិការផ្នែកច្បាប់ រួមមានការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យរដ្ឋប្បវេណី, បត្យាប័ន និងការផ្ទេរទណ្ឌិត មានសរុបចំនួន **១៩៥ សំណើ** ដែលក្នុងនោះរួមមាន៖ (**១**)-សំណើចូលសរុបចំនួន **១៧៨** សំណុំរឿង ដោយសំណុំរឿងបានចាត់ការរួចមានចំនួន ៦០ ស្មើនឹង **៣៤%**, សំណុំរឿងកំពុងរង់ចាំការឆ្លើយតបមានចំនួន ៦៤ ស្មើនឹង **៣៦%**, និងសំណុំរឿងកំពុងពិនិត្យនិយ័តភាពមានចំនួន ៥៤ ស្មើនឹង **៣០%**, និង (**២**)-សំណើចេញសរុបមានចំនួន ១៦សំណុំរឿង ដោយសំណុំរឿងបានចាត់ការរួចមានចំនួន ១០ ស្មើនឹង **៦៣%**, សំណុំរឿងកំពុងរង់ចាំការឆ្លើយតបមានចំនួន ៥ ស្មើនឹង **៣១%** ហើយសំណុំរឿងកំពុងពិនិត្យនិយ័តភាពមានចំនួន ១ ស្មើនឹង **៦%**។

៧.១.១. ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ

អគ្គនាយកដ្ឋានបានទទួលសំណើចំនួន ៧៩ ពីប្រទេសចំនួន ២១ ដែលក្នុងនោះមានមកពីប្រទេសជាសមាជិកអាស៊ានចំនួន ៥ ដោយក្នុងនោះ សំណើពីប្រទេសជាសមាជិកអាស៊ានមានចំនួន ៤៦ និងប្រទេសផ្សេងទៀតមានចំនួន ៣៣។ ក្នុងចំណោមសំណើដែលបានទទួលសរុប មានសំណើចំនួន ២៤ ករណី ត្រូវបានចាត់ការរួច។ ដោយឡែក សំណើចំនួន ១៩ ករណី កំពុងស្ថិតក្នុងការរង់ចាំការឆ្លើយតបពីស្ថាប័នមានសមត្ថកិច្ចអនុវត្តសំណើពាក់ព័ន្ធ និងសំណើចំនួន ៣៦ កំពុងពិនិត្យនិយ័តភាព។ ជាមួយគ្នានេះ ក្រសួងបានស្នើសុំ MLA ព្រហ្មទណ្ឌចំនួន ៤ករណី ទៅប្រទេសជាសមាជិកអាស៊ានចំនួន ២។ បច្ចុប្បន្ន ក្រសួងកំពុងរង់ចាំការឆ្លើយតបចំនួន ៣ករណី និងកំពុងពិនិត្យនិយ័តភាពចំនួន ១ករណី។

៧.១.២. ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យរដ្ឋប្បវេណី

អគ្គនាយកដ្ឋានបានទទួលសំណើពាក់ព័ន្ធនឹងការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យរដ្ឋប្បវេណី ចំនួន ៩១ករណី ពីប្រទេសចំនួន ៩ ក្នុងនោះសំណើសុំចំនួន ២៩ ករណីបានចាត់ការរួចរាល់, សំណើចំនួន ៤១ករណី កំពុងរង់ចាំការឆ្លើយតបពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងសំណើចំនួន ២១ កំពុងពិនិត្យនិយ័តភាព។ ទន្ទឹមនេះ អគ្គនាយកដ្ឋានបានរៀបចំសំណើសុំការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យរដ្ឋប្បវេណីចំនួន ១០ សំណើ ទៅប្រទេសចំនួន ៤។ សំណើចេញត្រូវបានចាត់ការរួចចំនួន ១០ ករណី។

៧.១.៣. កិច្ចការផ្ទេរទណ្ឌិត

អគ្គនាយកដ្ឋានបានទទួលសំណើសុំផ្ទេរទណ្ឌិតចំនួន ២ ករណី ពីប្រទេសចំនួន ២។

៧.១.៤. កិច្ចការបត្យាប័ន

អគ្គនាយកដ្ឋានបានទទួលសំណើសុំបត្យាប័នចំនួន ៦សំណើ ពីប្រទេសចំនួន ៤ ក្នុងនោះប្រទេសជាសមាជិកអាស៊ានចំនួន ២ករណី និងក្រៅប្រទេសអាស៊ាន ២ករណី ហើយមានសំណើចំនួន ២ បានចាត់ការរួច និងកំពុងរង់ចាំចម្លើយចំនួន ២ករណី ព្រមទាំងកំពុងពិនិត្យនិយ័តភាពចំនួន ២ករណី។ ក្រសួងយុត្តិធម៌ បានស្នើសុំធ្វើបត្យាប័នចំនួន ២ករណី ពីប្រទេសចំនួន ២ ផ្សេងៗគ្នា។

៧.២. កិច្ចសហប្រតិបត្តិការជាមួយអាស៊ាន

នាយកដ្ឋានកិច្ចការច្បាប់ និងកិច្ចសហប្រតិបត្តិការអាស៊ាន បានអនុវត្តការងារដោយទទួលបាននូវសមិទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

៧.២.១. កិច្ចសហប្រតិបត្តិការផ្នែកច្បាប់ក្នុងក្របខណ្ឌអាស៊ាន

បានចូលរួមកិច្ចប្រជុំកិច្ចការច្បាប់អាស៊ានសំខាន់ៗ ក្នុងនោះរួមមាន៖ (១)-កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីច្បាប់អាស៊ានតាមប្រព័ន្ធវីដេអូ, (២)-កិច្ចប្រជុំថ្នាក់ឧត្តមមន្ត្រីច្បាប់អាស៊ានលើកទី២២ និងកិច្ចប្រជុំថ្នាក់ឧត្តមមន្ត្រីច្បាប់អាស៊ានលើកទី២៣, (៣)-កិច្ចប្រជុំក្រុមការងារឧត្តមមន្ត្រីច្បាប់អាស៊ាន ស្តីពីសុខដុមនីយកម្មនៃច្បាប់ពាណិជ្ជកម្មអាស៊ានលើកទី១៣, (៤)-កិច្ចប្រជុំពិគ្រោះយោបល់ឧត្តមមន្ត្រីច្បាប់អាស៊ាន-ជប៉ុនលើកទី៣, (៥)-កិច្ចប្រជុំឧត្តមមន្ត្រីនៃអាជ្ញាធរកណ្តាលលើការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌលើកទី៣ និង (៦)-កិច្ចប្រជុំក្រុមការងារឧត្តមមន្ត្រីច្បាប់អាស៊ានស្តីពីបត្យាប័នចំនួន ៤លើក។

៧.២.២. កិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយបណ្តាប្រទេសជាសមាជិកអាស៊ាន

នាយកដ្ឋានមានសកម្មភាពសំខាន់ៗមួយចំនួន រួមមាន៖ (១)-ជំនួបពិភាក្សាការងារជាមួយគណៈប្រតិភូក្រសួងយុត្តិធម៌វៀតណាម ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ, (២)-រៀបចំឯកសាររបាយការណ៍ និងឯកសារជំនួយស្មារតី ស្តីពីវឌ្ឍនភាពការងារនៃកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌទ្វេភាគីនៃបណ្តាប្រទេសជាសមាជិកអាស៊ាន សម្រាប់ថ្នាក់ដឹកនាំ និងក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ,

និង(៣)-រៀបចំរបាយការណ៍វឌ្ឍនភាព និងជាតុចូលសម្រាប់កិច្ចប្រជុំគណៈកម្មការចម្រុះនៃកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយប្រទេសហ្វីលីពីន ឡាវ វៀតណាម ថៃ សិង្ហបុរី (JC Meeting)។

៧.២.៣. កិច្ចការស្រាវជ្រាវនិងផ្សព្វផ្សាយច្បាប់អាស៊ាន

បានសិក្សា និងផ្តល់ជាតុចូលលើកិច្ចការសំខាន់ៗមួយចំនួនរួមមាន៖ (១)-ទម្រង់ទូទៅ (Form A) និងទម្រង់សាមញ្ញ (Form B) នៃសំណើសុំការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌសម្រាប់ប្រទេសជាសមាជិកអាស៊ាន, (២)-សេចក្តីព្រាងនៃសន្ធិសញ្ញា ស្តីពីបត្យាប័នអាស៊ាន ក្នុងកម្រិតនាយកដ្ឋាន និងអគ្គនាយកដ្ឋាន, (៣)-របាយការណ៍វឌ្ឍនភាពសម្រាប់ក្រុមការងារនៃឧត្តមមន្ត្រីច្បាប់អាស៊ាន ស្តីពីសុខដុមនីយកម្មនៃច្បាប់ពាណិជ្ជកម្មអាស៊ាន, (៤)-បានសិក្សាស្រាវជ្រាវទាក់ទងនឹងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មអន្តរជាតិ, (៥)-រៀបចំកិច្ចប្រជុំជាមួយអង្គភាពដែលពាក់ព័ន្ធដើម្បីផ្តល់ជាតុចូលតាមការស្នើសុំរបស់អគ្គលេខាធិការដ្ឋានអាស៊ាន និង (៦)-បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយការងារច្បាប់អាស៊ាន។

៧.៣. កិច្ចការទំនាក់ទំនងអន្តរជាតិ និងសហប្រតិបត្តិការផ្នែកច្បាប់

នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងសហប្រតិបត្តិការផ្នែកច្បាប់ បានអនុវត្តការងារ និងទទួលបានលទ្ធផលមួយចំនួន ដូចខាងក្រោម៖

៧.៣.១. កិច្ចសហប្រតិបត្តិការផ្នែកច្បាប់

នាយកដ្ឋានបាន និងកំពុងការពិនិត្យ និងរៀបចំកិច្ចចរចាទ្វេភាគី លើសេចក្តីព្រាងកិច្ចព្រមព្រៀងអន្តរជាតិចំនួន ៥ រួមមាន៖

- បាន និងកំពុងពិនិត្យពិភាក្សាលើសេចក្តីព្រាងសន្ធិសញ្ញាបត្យាប័នរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងឥណ្ឌា (ក្នុងកម្រិតបច្ចេកទេស)
- បាន និងកំពុងពិនិត្យពិភាក្សាលើសេចក្តីព្រាងសន្ធិសញ្ញាការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងឥណ្ឌា
- បាន និងកំពុងពិនិត្យពិភាក្សាលើសេចក្តីព្រាងសន្ធិសញ្ញាស្តីពីការផ្ទេរទណ្ឌិតរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ (ក្នុងកម្រិតបច្ចេកទេស)
- បាន និងកំពុងពិនិត្យពិភាក្សាលើសេចក្តីព្រាងសន្ធិសញ្ញាស្តីពីការផ្ទេរទណ្ឌិតរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងប៊ែលហ្សិក (ក្នុងកម្រិតបច្ចេកទេស)
- បាន និងកំពុងពិនិត្យពិភាក្សាលើសេចក្តីព្រាងសន្ធិសញ្ញាស្តីពីការផ្ទេរទណ្ឌិតរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលសហព័ន្ធរុស្ស៊ី (ក្នុងកម្រិតបច្ចេកទេស)។

៧.៣.២. កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល

នាយកដ្ឋានបានដួបពិភាក្សាការងារពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ និងការបណ្តុះបណ្តាលផ្នែកបច្ចេកទេសដល់មន្ត្រីរបស់ក្រសួងជាមួយអង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍មួយចំនួន រួមមាន៖ ការិយាល័យអង្គការសហប្រជាជាតិស្តីពីគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC), អង្គការមូលនិធិហិរញ្ញវត្ថុអន្តរជាតិ (IMF), UNAFEI, UNDP, JICA, JICE, អង្គការ Konrad Adenauer Stiftung, OXFAM, និងការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សនៅកម្ពុជា (OHCHR)។

៧.៣.៣. កិច្ចការផ្តល់យោបល់គតិយុត្តលើហិរញ្ញប្បទានពីបរទេស និងដៃគូអន្តរជាតិ

ដោយគិតចាប់ពីថ្ងៃទី២ ខែមករា ឆ្នាំ២០២៤ ដល់ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៤ នាយកដ្ឋានបានផ្តល់គតិយុត្តលើកិច្ចព្រមព្រៀងឥណទានសម្បទានចំនួន ២៣គម្រោង ដែលក្នុងនោះមានកិច្ចព្រមព្រៀងឥណទានសម្បទាន ពីធនាគារពិភពលោក (World Bank) ចំនួន ៧គម្រោង, ពីទីភ្នាក់ងារអង្គការ JICA ចំនួន ៣គម្រោង, ពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ចំនួន ៣គម្រោង, ពីធនាគារនីហរ័ណ-អាហរ័ណកូរ៉ (Korean Export-Import Bank) ចំនួន ៦គម្រោង, ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) ចំនួន ៤គម្រោង។

៧.៣.៤. កិច្ចការសហប្រតិបត្តិការ និងសម្របសម្រួលការងារសិទ្ធិមនុស្ស

នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងសហប្រតិបត្តិការផ្នែកច្បាប់ ដើរតួនាទីជាអ្នកសម្របសម្រួល និងសហការលើកិច្ចការសិទ្ធិមនុស្សសម្រាប់ក្រសួងយុត្តិធម៌ ជាមួយបណ្តាអង្គភាពចំណុះក្រសួង ដើម្បីរៀបចំប្រមូលចងក្រងជាតុចូល និងផ្តល់របាយការណ៍វឌ្ឍនភាពពាក់ព័ន្ធនឹងសិទ្ធិមនុស្សបណ្តាក្រសួង-ស្ថាប័នជាតិ និងអន្តរជាតិ។

៧.៤. កិច្ចការអ្នកបកប្រែនិងអ្នកជំនាញក្នុងវិស័យច្បាប់ និងយុត្តិធម៌

នាយកដ្ឋានអ្នកបកប្រែ និងអ្នកជំនាញក្នុងវិស័យច្បាប់ និងយុត្តិធម៌ ទទួលបន្ទុកលើការងារគ្រប់គ្រងអ្នកបកប្រែ និងអ្នកជំនាញក្នុងវិស័យច្បាប់និងយុត្តិធម៌។ នាយកដ្ឋាន បានអនុវត្តការងារដោយសម្រេចបាននូវសមិទ្ធផលជាច្រើនក្នុងនោះមានសមិទ្ធផលសំខាន់ៗរួមមាន៖

៧.៤.១. កិច្ចការគ្រប់គ្រងអ្នកបកប្រែក្នុងវិស័យច្បាប់ និងយុត្តិធម៌

នាយកដ្ឋាន បានបញ្ចប់ការរៀបចំសេចក្តីព្រាង "ប្រកាសស្តីពីការទទួលស្គាល់អ្នកបកប្រែ និងក្រុមហ៊ុនបកប្រែក្នុងវិស័យយុត្តិធម៌" បន្ទាប់ពីបានរៀបចំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងចំនួន ៥ លើក។ ជាមួយគ្នានេះ នាយកដ្ឋានបានសិក្សារៀបចំឯកសារជារបាយការណ៍ សេចក្តីព្រាងទស្សនាទាន និងឯកសារស្រាវជ្រាវបានចំនួន ៣ រួមមាន៖ (១)- របាយការណ៍នៃការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងលក្ខខណ្ឌគុណវុឌ្ឍិការបណ្តុះបណ្តាល ការអនុវត្តវិជ្ជាជីវៈ របស់អ្នកបកប្រែផ្តាល់មាត់នៅសហរដ្ឋអាមេរិក, អូស្ត្រាលី, សិង្ហបុរី និងចិន, (២)-សេចក្តីព្រាងឯកសារទស្សនាទាន ស្តីពីការផ្តល់សេវាបកប្រែផ្លូវការលើលិខិត និងឯកសារផ្សេងៗពាក់ព័ន្ធនឹងវិស័យច្បាប់ និងយុត្តិធម៌ និង(៣)-របាយការណ៍នៃការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹង ទិន្នន័យជន

បរទេសជាប់ពាក់ព័ន្ធនឹងបទល្មើសនៅកម្ពុជា។ គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៤ មានជនបរទេសចំនួនប្រមាណ ៦៩០នាក់ ពាក់ព័ន្ធនឹងបទល្មើសនានានៅកម្ពុជា (ទិន្នន័យលម្អិតសូមមើលឧបសម្ព័ន្ធ)។

នាយកដ្ឋាន បានរៀបចំសម្របសម្រួលផ្តល់អ្នកបកប្រែភាសាបរទេសចំនួន ១០ សំណើ ស្មើនឹង ៨ ភាសា និងជាជនជាប់ចោទនិងជនត្រូវចោទចំនួន ៣០ រូប។

៧.៤.២. កិច្ចការអ្នកជំនាញក្នុងវិស័យច្បាប់ និងយុត្តិធម៌

នាយកដ្ឋានបានទំនាក់ទំនង ជាមួយបណ្ឌិត្យសភាវិទ្យាសាស្ត្រកោសលវិច័យនៃក្រសួងយុត្តិធម៌ ប្រទេសចិន ជាច្រើនដង ដើម្បីពិភាក្សាការងារពីលទ្ធភាពនៃការរៀបចំកិច្ចសហប្រតិបត្តិការលើវិស័យច្បាប់និង យុត្តិធម៌។ ជាលទ្ធផល នាយកដ្ឋានបានរៀបចំសេចក្តីព្រាងបឋមកម្រិតនាយកដ្ឋានស្តីពីអនុស្សរណៈនៃការ យោគយល់គ្នា (MoU) ជាមួយបណ្ឌិត្យសភាវិទ្យាសាស្ត្រកោសលវិច័យ នៃក្រសួងយុត្តិធម៌ចិន។

៧.៥. កិច្ចការផ្សព្វផ្សាយ និងការបណ្តុះបណ្តាលច្បាប់

នាយកដ្ឋានផ្សព្វផ្សាយ និងការបណ្តុះបណ្តាលច្បាប់ បានអនុវត្តការងារដោយសម្រេចបាននូវលទ្ធផល ជាច្រើនរួមមាន៖

៧.៥.១. ការងារផ្សព្វផ្សាយ និងការបណ្តុះបណ្តាលច្បាប់

កិច្ចប្រជុំ តាមរយៈសិក្ខាសាលា វគ្គបណ្តុះបណ្តាល ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ ការចុះសិក្សា វាយតម្លៃ ការចុះសិក្សាស្រាវជ្រាវ ចំនួន ៩ សកម្មភាព។

៧.៥.២. លទ្ធផលការងារផ្សព្វផ្សាយ និងបណ្តុះបណ្តាលច្បាប់តាមរយៈបណ្តាញសង្គមក្នុងឆ្នាំ ២០២៤ ធៀបនឹងឆ្នាំ ២០២៣

នាយកដ្ឋានផ្សព្វផ្សាយនិងបណ្តុះបណ្តាលច្បាប់ បានបង្កើតនូវប្រព័ន្ធផ្សព្វផ្សាយច្បាប់ក្នុងវិស័យយុត្តិធម៌ ចំនួន ៤ រួមមាន TiK Tok, Youtube Channel, Facebook Page, និង Channel Telegram ដែលក្នុងនោះ បានទទួលនូវកំណើនយ៉ាងច្រើនពីការចូលទស្សនា ការពេញចិត្ត និងការចុះឈ្មោះជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយ របស់នាយកដ្ឋានផ្សព្វផ្សាយនិងបណ្តុះបណ្តាលច្បាប់ ដូចមានបង្ហាញក្នុងតារាងខាងក្រោម៖



៧.៥.៣. អត្ថបទច្បាប់ ពន្យល់ពាក្យច្បាប់ និងស្តតអប់រំខ្លី ដែលបានផ្សព្វផ្សាយតាមបណ្តាញសង្គមទាំង៤ របស់នាយកដ្ឋានផ្សព្វផ្សាយ និងបណ្តុះបណ្តាលច្បាប់

បានរៀបចំអត្ថបទច្បាប់ផ្នែករដ្ឋប្បវេណីចំនួន ៣០ អត្ថបទ អត្ថបទទូទៅចំនួន ២១ អត្ថបទច្បាប់ផ្នែកព្រហ្មទណ្ឌចំនួន ១៧ អត្ថបទស្តីពីការពន្យល់ពាក្យបច្ចេកទេសច្បាប់ចំនួន ៦៣ អត្ថបទ និងការរៀបចំអត្ថបទ និងថតវីដេអូផ្សព្វផ្សាយចំនួន ១២ ។ ប្រធានបទនៃអត្ថបទដែលបានរៀបចំទាំង ១៤៣ អត្ថបទ មានក្នុងតារាងដូចខាងក្រោម៖

ក) អត្ថបទច្បាប់ផ្នែករដ្ឋប្បវេណីមានចំនួន ៣០ អត្ថបទ

១. អំពើអនីត្យានុកូល	១៦. ការអនុវត្តដោយបង្ខំ
២. បណ្តឹង និងការទាមទារ	១៧. សិទ្ធិឃាត់ទុកលើអចលនវត្ថុ
៣. ការចុះបញ្ជីហ៊ីប៉ូតែត	១៨. បណ្តឹងឧបាស្រ័យក្នុងនីតិវិធីរដ្ឋប្បវេណី
៤. ការអនុវត្តជាក់ស្តែងនៃការលែងលះ	១៩. ហ៊ីប៉ូតែត
៥. រចនាសម្ព័ន្ធញាតិ	២០. នីតិវិធីរដ្ឋប្បវេណី ការបញ្ជូន
៦. សេចក្តីពន្យល់ទូទៅអំពីក្រមនីតិវិធីរដ្ឋប្បវេណី	២១. ការទទួលខុសត្រូវរបស់អ្នកកាន់កាប់សត្វ
៧. លំហូរនីតិវិធីនៃការជម្រះក្តីលើកទី១	២២. សន្តតិកម្មតាមច្បាប់
៨. លំហូរដោមូលដ្ឋាននៃនីតិវិធីអនុវត្តហ៊ីប៉ូតែត	២៣. ការបង្កើតអាពាហ៍ពិពាហ៍
៩. នីតិវិធីសម្រាប់ទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់	២៤. លំហូរនីតិវិធីនៃពាក្យសុំឧបាស្រ័យ ការចាត់ចែងរក្សាការពារ
១០. បណ្តឹងទាស់	២៥. អំពីនីតិវិធីចុះបញ្ជីអចលនវត្ថុ
១១. បណ្តឹងឧបាស្រ័យ	២៦. មូលហេតុនៃការលត់កាតព្វកិច្ច
១២. បណ្តឹងសារទុក្ខ	២៧. សៀវភៅស្តីអំពីការពន្យល់អំពីនីតិវិធីសាលាជម្រះក្តីលើកទី១
១៣. សិទ្ធឧបាទេសកម្មរបស់ម្ចាស់បំណុល (ករណីទី១ ដល់ករណីទី២១ចប់)	២៨. សិទ្ធលើការបញ្ចាំលើអចលវត្ថុ
១៤. ប្រកាសស្តីពីខសន្យាមិនសុចរិត	២៩. ការអនុវត្តជាក់ស្តែងនៃការលែងលះ
១៥. អំពីការសន្យាលក់ជាមុន	៣០. សេចក្តីពន្យល់ទូទៅក្រមរដ្ឋប្បវេណី

ខ) អត្ថបទច្បាប់ផ្នែកព្រហ្មទណ្ឌ មានចំនួន ១៧ អត្ថបទ

១. អំពីទោស
២. នីតិវិធីបណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា និងព្រះរាជអាជ្ញា
៣. លទ្ធភាពនៃការអនុវត្តទោសការងារសហគមន៍ ជោះលែងដោយមានលក្ខខណ្ឌ
៤. អំពីបទល្មើសព្រហ្មទណ្ឌ
៥. អំពីជនល្មើស
៦. អំពីការទទួលខុសត្រូវព្រហ្មទណ្ឌ
៧. អំពីទោសព្រហ្មទណ្ឌ
៨. អំពីការប្រកាសទោស
៩. បច្ចេកទេសស្តាប់ចម្លើយក្នុងរឿងក្តីព្រហ្មទណ្ឌ
១០. ឯកសារ ជំណាក់កាលរឿងក្តីព្រហ្មទណ្ឌ សម្រាប់មន្ត្រីអប្រវត្តច្បាប់នៅកម្ពុជា
១១. បទរំលោភសេពសន្តវៈ និងស្ថានទម្ងន់ទោស
១២. ជីកាសម្រេចដម្កល់រឿងទុកឥតចាត់ការ
១៣. បទឃាតកម្មដោយមានទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្តវៈ
១៤. បទជំនួញឥទ្ធិពលអកម្ម
១៥. អំពើលួច និងអភ័យឯកសិទ្ធគ្រួសារ
១៦. អំពើអនីត្យានុកូល
១៧. ការជោះលែងដោយមានលក្ខខណ្ឌ

គ) អត្ថបទទូទៅ មានចំនួន ២១ អត្ថបទ

១. សេចក្តីណែនាំរបស់ក្រសួងយុត្តិធម៌ស្តីពីនីតិវិធីដែលត្រូវអនុវត្តចំពោះជនរងគ្រោះជាអនីតិជន នៅក្នុងសំនុំរឿងព្រហ្មទណ្ឌ	១៤. ច្បាប់នៃការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជាឆ្នាំ១៩៩៣
២. ជីកាសម្រេច	១៥. បច្ចេកទេសដឹកនាំសម្របសម្រួលមន្ត្រីនគរបាលយុត្តិធម៌ក្នុងការបង្ក្រាប់បទល្មើសព្រហ្មទណ្ឌ
៣. ការហៅឈ្មោះបុគ្គលដែលបានប្រព្រឹត្តបទល្មើស	១៦. ប្រកាស់ស្តីពី បែបបទនៃការឃ្លាំមើលតាមដាន ការត្រួតពិនិត្យ និងការបញ្ជូនទៅក្នុងសង្គមវិញ នៃបណ្តឹតដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌ
៤. ការធ្វើឯកសារ (ពាក្យបណ្តឹង ឯកសារចម្លើយ ឯកសារត្រៀម)	១៧. តួនាទីរបស់អង្គភាពរដ្ឋបាលតុលាការ
៥. នីតិវិធីនៃការពិន័យអន្តរកាលលើអំពើល្មើសពាក់ព័ន្ធនឹងច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ	១៨. ព្រះរាជក្រិត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃរចនាសម្ព័ន្ធចំណុះបណ្ឌិតសភាភូមិន្ទយុត្តិធម៌ភ្នំពេញ
៦. ព្រះរាជក្រិត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃរាជបណ្ឌិតសភាភូមិន្ទយុត្តិធម៌ភ្នំពេញ	១៩. អនុក្រិត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃ
៧. ការតាក់តែងពាក្យបណ្តឹង	២០. រចនាសម្ព័ន្ធចំណុះបណ្ឌិតសភាភូមិន្ទយុត្តិធម៌ភ្នំពេញ ប្រកាស់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃការបណ្តុះបណ្តាលរបស់សិស្សចៅក្រមផ្នែកក្នុង
៨. ជីកាបញ្ជាឱ្យចុលខ្លួន	២១. សេចក្តីណែនាំលេខ០១កយ.សណន/២៣ស្តីពីនីតិវិធីដែលត្រូវអនុវត្តចំពោះជនរងគ្រោះជាអនីតិជន ក្នុងសំណុំរឿងពញរហ្មទណ្ឌ
៩. គ្រោះថ្នាក់បណ្តាលមកពីគ្រឿងញៀន	
១០. បច្ចេកទេសការសរសេរពាក្យបណ្តឹងព្រហ្មទណ្ឌ	
១១. ច្បាប់ស្តីពី នីតិវិធីដំនុំដំរៈផ្នែកព្រហ្មទណ្ឌឆ្នាំ១៩៩៩	
១២. ច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារឆ្នាំ១៩៩៩	
១៣. ការអប់រំជនល្មើសដោយផ្អែកលើទោសសហគមន៍	

(ហើយក៏មានឯកសារមួយចំនួនទៀតដូចជា សេចក្តីប្រកាស អនុក្រិត្យ ព្រះរាជក្រិត្យ)

ឃ) វីដេអូ មានចំនួន ១២

១. បទរំលោភសេពសន្តវៈ
២. គោលការណ៍ទូទៅនៃក្រមព្រហ្មទណ្ឌ
៣. ជែនអនុវត្តនៃក្រមព្រហ្មទណ្ឌ
៤. ការទទួលខុសត្រូវព្រហ្មទណ្ឌ
៥. ទោសព្រហ្មទណ្ឌភាគ១
៦. ទោសព្រហ្មទណ្ឌភាគ២
៧. របបនៃការប្រកាសទោសភាគ១
៨. របបនៃការប្រកាសទោសភាគ២
៩. ការចាប់ ការឃុំឃាំង និងការបង្ខាំងដោយខុសច្បាប់
១០. អំពើទទួលផលចោរកម្ម
១១. សន្តិកម្មតាមច្បាប់ និងចំណែកមរតកដែលច្បាប់បានកំណត់
១២. បទហឹង្សាដោយចេតនា

ង) ពន្យល់ពាក្យច្បាប់ មានចំនួន ៦៣ អត្ថបទ

១.កាតព្វកិច្ច	១០.អនុប្បទាន	១៩.បទល្មើស	២៨.អ្នកសមគំនិត	៣៧.កាតព្វកិច្ចចម្បង	៤៦.កាតព្វកិច្ចអនីយ័ត	៥៥.កាតព្វកិច្ចដោយសាមគ្គីភាព		
២.កិច្ចសន្យា	១១.តតិយជន	២០.មោឃភាព	២៩.អ្នកផ្តើមគំនិត	៣៨.កាតព្វកិច្ចធានា	៤៧.បទប្រទូស្តកេរខ្មាស	៥៦.បទបរិហាកេរ្តិ៍ជាសាធារណៈ		
៣.ស្វ័ការ	១២.អនីតិជន	២១.សកម្មភាព	៣០.អំណាចមេបា	៣៩.ប្រភេទនៃទោស	៤៨.បទបង្ហាញកេរភេទ	៥៧.បទផលិត ឬធ្វើចរាចរណ៍អាវុធសម្រាប់ប្រហារផ្សេងៗ		
៤.អនុភាព	១៣.បទឧក្រិដ្ឋ	២២.សច្ចានុមតិ	៣១.បទឃាតកម្ម	៤០.សិទ្ធលើបំណុល	៤៩.អាហារកាតព្វកិច្ច	៥៨.បទកាន់កាប់ ឬដឹកអាវុធដោយគ្មានការអនុញ្ញាត		
៥.វិការៈ	១៤.បទមជ្ឈឹម	២៣.កំដាប់ពាក្យ	៣២.ព្យាកុលភាព	៤១.អាណាព្យាបាល	៥០.កិច្ចសន្យាម៉ៅការ	៥៩.បទហឹង្សាដោយចេតនា		
៦.ចារី	១៥.មូលទោស	២៤.អនុតំណាង	៣៣.ការពូនស្នាក់	៤២.បបនីយផ្លូវចិត្ត	៥១.ការអនុវត្តជំនួស	៦០.បទឃាតកម្មគិតទុកជាមុន		
៧.សហចារី	១៦.តាវកាលិក	២៥.ការតំណាង	៣៤.ឧបាទេសិក	៤៣.ការទម្ងន់ទោស	៥២.សកម្មភាពឯកតោភាគី	៦១.បទមនុស្សឃាតដោយចេតនា		
៨.នត្តិភាព	១៧.ទ្វេពន្ធភាព	២៦.សន្តតិកម្ម	៣៥.ទោសជំនួស	៤៤.លិខិតយថាភូត	៥៣.អ្នករាជការសាធារណៈ	៦២.បទរំលោភលំនៅដ្ឋាន		
៩.នវកម្ម	១៨.បទលហុ	២៧.សន្តតិជន	៣៦.ទោសបន្ថែម	៤៥.ឧបាទេសកម្ម	៥៤.បទរំលោភសេពសន្តវៈ	៦៣.ការអនុវត្តដោយបង្ខំ		

៧.៥.៤. សមិទ្ធផលការងារផ្សេងៗដែលសម្រេចបាន

- ប្រមូល សិក្សាស្រាវជ្រាវ និងចងក្រងនូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ក៏ដូចជាមេពាក្យច្បាប់ដែលពាក់ព័ន្ធនឹងវិស័យរដ្ឋប្បវេណី និងព្រហ្មទណ្ឌ និងអត្ថបទមេរៀនសំខាន់ដែលពាក់ព័ន្ធនឹងវិស័យសំខាន់ទាំងពីរនេះ ដើម្បីយកទៅធ្វើការផ្សព្វផ្សាយតាមបណ្តាញសង្គម
- ប្រមូល និងសិក្សាស្រាវជ្រាវនូវស្ថិតិសំណុំរឿងរដ្ឋប្បវេណី និងព្រហ្មទណ្ឌ ដើម្បីយកទៅរៀបចំជាទិន្នន័យសំណុំរឿងដើម្បីរៀបចំមេរៀនសម្រាប់ធ្វើការផ្សព្វផ្សាយ និងបណ្តុះបណ្តាល
- រៀបចំសេចក្តីព្រាងបញ្ចប់ ផែនការយុទ្ធសាស្ត្រស្តីពី ការលើកកម្ពស់ការយល់ដឹងអំពីច្បាប់ដល់សាធារណជន និងការអភិវឌ្ឍសមត្ថភាពមន្ត្រី ២០២៤-២០២៨ សម្រាប់ជាផែនទីបង្ហាញការងារសម្រាប់នាយកដ្ឋាន។

៧.៦. កិច្ចការស្រាវជ្រាវ និងផែនការ

ក្នុងរយៈពេលមួយឆ្នាំនេះ នាយកដ្ឋានស្រាវជ្រាវ និងផែនការ បានអនុវត្តការងារយ៉ាងសកម្ម និងខ្ជាប់ខ្ជួន ប្រកបដោយការទទួលខុសត្រូវខ្ពស់ ហើយបានសម្រេចនូវលទ្ធផលសំខាន់ៗដូចខាងក្រោម៖

- បានរៀបចំឯកសារជាតុចូលសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០២៤-២០២៨ អំពីសមិទ្ធផលនៃការអនុវត្ត ផ.យ.អ.ជ រយៈពេល ៥ឆ្នាំ (២០១៩-២០២៣)
- បានរៀបចំឯកសារស្តីពីការពិនិត្យឡើងវិញ ការវិភាគមុខងារ និងរចនាសម្ព័ន្ធ របស់ក្រសួងយុត្តិធម៌ តាមរយៈក្រុមការងាររៀបចំផែនការធនធានមនុស្សក្នុងវិស័យយុត្តិធម៌
- សហការរៀបចំសិក្ខាសាលាស្តីពីការពិនិត្យឡើងវិញ និងវិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួងស្ថាប័នដែលបានសហការរៀបចំដោយក្រសួងមុខងារសាធារណៈ ជាមួយក្រសួងយុត្តិធម៌ បានប្រព្រឹត្តទៅនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៤ នៅបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ដោយមានសមាសភាពចូលរួមកម្រិតចាប់ពីប្រធាននាយកដ្ឋានឡើងទៅ
- បានរៀបចំដាក់ចេញជាសេចក្តីព្រាងបឋមស្តីពី ការរៀបចំផែនការធនធានមនុស្សក្នុងវិស័យយុត្តិធម៌រយៈពេល ៥ឆ្នាំ ២០២៤-២០២៨ និងបានរៀបចំដាក់ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយថ្នាក់ដឹកនាំមួយចំនួន និងប្រធានអង្គភាពទាំងអស់ កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៤
- ការផ្តល់យោបល់លើឯកសារសេចក្តីព្រាងក្របខណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់ គ.យ.ប នៃទីស្តីការគណៈរដ្ឋមន្ត្រី
- ការសិក្សា ស្រាវជ្រាវ និងចងក្រងឯកសារ៖ នាយកដ្ឋានបានរៀបចំស្រាវជ្រាវ ប្រមូល ចងក្រងឯកសារពាក់ព័ន្ធនឹងការរៀបចំ និងការប្រព្រឹត្តទៅរបស់ (១)-អង្គភាពចំណុះឱ្យទីស្តីការក្រសួងយុត្តិធម៌តាមអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌ (២)-អង្គភាពចំណុះឱ្យវិស័យយុត្តិធម៌ទាំងអស់ និង (៣)-អង្គភាពរដ្ឋបាលតុលាការនៅតាមសាលាដម្រះក្តីរាជធានី-ខេត្ត និងកំពុងរៀបចំគូសគំនូសជាតា

រាងស្តីពីរចនាសម្ព័ន្ធអង្គភាពទាំងអស់នៅក្នុងវិស័យយុត្តិធម៌ ដោយផ្អែកតាមអនុក្រឹត្យលេខ ១៣០ និងលិខិតបទដ្ឋានគតិយុត្តនានាស្តីពីការបង្កើតរចនាសម្ព័ន្ធ និងអង្គភាពមួយចំនួន។

៨. ការងារនីតិកម្ម

អគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី, អគ្គនាយកដ្ឋានកិច្ចអយ្យការ និងព្រហ្មទណ្ឌ និងក្រុមការងារដឹកនាំការត្រួតពិនិត្យផ្នែកទោសប្បញ្ញត្តិ នៃសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានា បានធ្វើការពិនិត្យលើកិច្ចការនីតិកម្ម ដោយសម្រេចបានលទ្ធផលដូចខាងក្រោម៖

៨.១. សេចក្តីព្រាងច្បាប់

៨.១.១. សេចក្តីព្រាងច្បាប់កំពុងពិនិត្យ

- សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិក:សារការី
- សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិក:អាជ្ញាសាលា
- សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់លក្ខន្តិក:មេធាវី
- សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ
- សេចក្តីព្រាងច្បាប់ស្តីពីការចាត់ចែងជាបណ្តោះអាសន្នលើវត្ថុចាប់យក
- សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ
- សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី
- សេចក្តីព្រាងច្បាប់ស្តីពីការដាក់ឱ្យដំណើរការតុលាការការងារ និងតុលាការពាណិជ្ជកម្ម។

៨.១.២. សេចក្តីព្រាងច្បាប់ដែលបានពិនិត្យរួច

- សេចក្តីព្រាងច្បាប់ស្តីពី ការដឹកជញ្ជូនតាមផ្លូវទឹក
- សេចក្តីព្រាងច្បាប់ស្តីពី ប្រព័ន្ធទឹកកខ្វក់
- សេចក្តីព្រាងច្បាប់ស្តីពី ជលផល
- សេចក្តីព្រាងច្បាប់ស្តីពី ការទទួលខុសត្រូវលើផលិតផលមានវិការៈ។

៨.២. សេចក្តីព្រាងព្រះរាជក្រឹត្យ និងអនុក្រឹត្យ

- សេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទនិងនីតិវិធីនៃការអនុញ្ញាតឱ្យជនបរទេសមិនមែនអន្តោប្រវេសន្តចូល ចេញ ឆ្លងកាត់ និងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- សេចក្តីព្រាងអនុក្រឹត្យស្តីពីប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ
- សេចក្តីព្រាងអនុក្រឹត្យស្តីពីការពិន័យអន្តរការណ៍ចំពោះបទល្មើសនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម។

៨.៣. សេចក្តីព្រាងប្រកាស និងសេចក្តីសម្រេច

- ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្ន
- សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពី នីតិវិធីនៃការពិន័យអន្តរការណ៍ចំពោះបទល្មើសនឹងបទប្បញ្ញត្តិស្តីពីនគរូបនីយកម្មនិងសំណង់
- សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពី បែបបទ និងនីតិវិធីនៃការគ្រប់គ្រងអនីតិជនជាប់ឃុំក្នុងមណ្ឌលយុវនីតិសម្បទា
- សេចក្តីព្រាងប្រកាសស្តីពី "លក្ខខណ្ឌ និងនីតិវិធីនៃការបន្តការផ្អាក និងការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង" ស្នើដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- សេចក្តីព្រាងសេចក្តីសម្រេចស្តីពី "នីតិវិធី និងយន្តការនៃការដោះស្រាយវិវាទ ឬបណ្តឹងដោយ **ន.ស.ស.**" ស្នើដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- សេចក្តីព្រាងប្រកាសស្តីពី "ការទទួលស្គាល់ អ្នកជម្រះបញ្ជីក្នុងវិស័យធានារ៉ាប់រង" ស្នើដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- សេចក្តីព្រាងប្រកាសស្តីពីមជ្ឈមដ្ឋានចុះបញ្ជីមតកសាសន៍
- សេចក្តីព្រាងប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់អភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្សីយធន
- សេចក្តីព្រាងប្រកាសរួមស្តីពីកម្រៃនៃអាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្ន។

៩. ការងារឌីជីថលូបនីយកម្ម និងបរិវត្តកម្មឌីជីថល

៩.១. ការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធបណ្តាញឌីជីថល នៃទីស្តីការក្រសួងយុត្តិធម៌

- រៀបចំហេដ្ឋារចនាសម្ព័ន្ធបណ្តាញខាងក្នុង និងបណ្តាញអ៊ិនធឺណិត
- តាមដានការបំពាក់ការមេ៉ាសុវត្ថិភាពនៅតាមអគារនីមួយៗ និងតាមដានការតំឡើងប្រព័ន្ធចាប់លេខរៀង (QMS) សម្រាប់បម្រើសេវាសាធារណៈ នៃនាយកដ្ឋានកិច្ចការប្តោលទោស
- បានបញ្ចប់ការងារសិក្សាប្រព័ន្ធរក្សាទុកទិន្នន័យផ្ទៃក្នុងរបស់**ឧទ្ធរណ៍យុត្តិធម៌**

៩.២.ការរៀបចំគេហទំព័រ (Website) និងប្រព័ន្ធសារអេឡិចត្រូនិច (Mail System) ថ្មីសម្រាប់ក្រសួងយុត្តិធម៌

- គេហទំព័រ (Website) បានធ្វើកំណែទម្រង់ថ្មីឡើងវិញរួចរាល់ ១០០% បច្ចុប្បន្ននេះ ចំនួនអ្នកចូលទស្សនា និងទាញយកឯកសារច្បាប់នានា តាមរយៈគេហទំព័ររបស់ក្រសួងយុត្តិធម៌ www.moj.gov.kh មានចំនួនប្រមាណ **៤០,០០០នាក់** ក្នុងមួយថ្ងៃ

- បានសហការជាមួយអគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីក្នុងការបង្កើត Platform ថ្មីមួយសម្រាប់ "សេចក្តីជូនដំណឹងនៃការលក់ដោយបង្ខំ"
- ប្រព័ន្ធសារអេឡិចត្រូនិច (Mail System) បានធ្វើកំណែទម្រង់ថ្មីឡើងវិញរួចរាល់ ១០០% និងបានរៀបចំរួចរាល់ នូវនីតិវិធីនៃការស្នើសុំ Email ផ្លូវការនេះផងដែរ

៩.៣. ការអភិវឌ្ឍកម្មវិធីសម្រាប់ក្រសួងយុត្តិធម៌

- ប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ក្រសួងយុត្តិធម៌-DMS (បង្កើតឡើងដើម្បី ពិនិត្យ តាមដាន និងវាយតម្លៃ រាល់ការងារឌីជីថលទាំងអស់របស់អង្គភាពចំណុះឱ្យក្រសួងយុត្តិធម៌) ដោយសម្រេចបានជោគជ័យ ១០០% ដោយបច្ចុប្បន្នប្រព័ន្ធនេះបានកំពុងធ្វើប្រតិបត្តិការងារ ពិនិត្យ តាមដាន និងវាយតម្លៃ ប្រព័ន្ធស្នើសុំព្រឹត្តិបត្រថ្កោលទោសផងដែរ។
- កំពុងបន្តបង្កើតប្រព័ន្ធតាមអង្គភាពនីមួយៗចំណុះក្រសួងយុត្តិធម៌៖
  - ប្រព័ន្ធកិច្ចការអនុគ្រោះទោស (សម្រាប់ពិធីបុណ្យជាតិផ្សេងៗ)
  - ប្រព័ន្ធគ្រប់គ្រងសាលក្រម (ដើម្បីធានាបាននូវសន្តិសុខជាតិ)
  - ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សរបស់ក្រសួងយុត្តិធម៌ (ដើម្បីធានាបាននូវអព្យាក្រឹតភាព និងប្រសិទ្ធភាពក្នុងការគ្រប់គ្រងមន្ត្រីរាជការនៅក្នុងក្រសួងយុត្តិធម៌)
  - ប្រព័ន្ធត្រួតពិនិត្យ ផ្តល់យោបល់ និងអនុម័តឯកសារតាមប្រព័ន្ធ Online។

៩.៤. ទិន្នន័យនៃការតាមដានបណ្តាញសង្គមរបស់ក្រសួងយុត្តិធម៌ (គិតត្រឹមឆ្នាំ ២០២៤)

- Website (មានអ្នកចូលទស្សនាចំនួនសរុប ៧លានដង)
- Facebook Page (មានអ្នក Followers ២៦៣ ០០០ នាក់)
- Telegram Channel (មាន Subscribers ចំនួន ២២ ៨៧៣ រូប)
- សម្រាប់ទិន្នន័យលិខិតបទដ្ឋានគតិយុត្ត និងឯកសារច្បាប់ផ្សេងៗដែលបានបញ្ចូលទៅក្នុងគេហទំព័ររបស់ក្រសួងយុត្តិធម៌មានចំនួន ២១០០០ ច្បាប់
- សម្រាប់ទិន្នន័យនៃការប្រើប្រាស់ Bot Telegram (MOJ-SERVICE) របស់ក្រសួងយុត្តិធម៌ជាមធ្យមមានចំនួន ៥០០០ រូប ក្នុងមួយខែ។

បន្ថែមពីសមិទ្ធផលខាងលើ ក្រុមការងារក៏បានគាំទ្រនូវបញ្ហាបច្ចេកទេសឌីជីថលផ្សេងៗតាមតម្រូវការ និងកើតមានឡើងនៅទីស្តីការក្រសួងផងដែរ។

១០. ការងារនាយកដ្ឋានសវនកម្មផ្ទៃក្នុង

នៅក្នុងឆ្នាំ២០២៤, នាយកដ្ឋានសវនកម្មផ្ទៃក្នុងសម្រេចបានលទ្ធផលការងារ ដូចខាងក្រោម៖

- បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីសវនកម្ម និងស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី សិទ្ធិអំណាចការទទួលខុសត្រូវនិងនីតិវិធីអនុវត្តថវិការបស់អង្គភាពថវិកា
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តចំណាយថវិកានិងការចែករំលែកបទពិសោធន៍ការងារអនុវត្តចំណាយថវិកា
- បានចូលរួមកិច្ចប្រជុំរបស់ក្រុមការងារអន្តរក្រសួងស្តីពីរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុងនៅទីស្តីការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីសវនកម្មសមិទ្ធកម្ម ករណីសិក្សាលើការអនុវត្តកម្មវិធី បង្ការ និងថៃទាំព្យាបាលជម្ងឺគ្រុនចាញ់ និងឈាម
- បានចូលរួមកិច្ចប្រជុំក្រុមការងាររៀបចំក្របខណ្ឌ និងវិធានៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ចនៅទីស្តីការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយអំពីកិច្ចសហប្រតិបត្តិការតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា វៀតណាម ឡាវ ប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**
- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយស្តីពីការធ្វើតេស្តរហ័សរកសារធាតុញៀនតាមទឹកមូត្រ នៅទីស្តីការក្រសួងយុត្តិធម៌
- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយស្តីពីការអនុវត្តរបបសន្តិសុខសង្គមផ្នែកថៃទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់អ្នកក្នុងបន្ទុកសមាជិក ប.ស.ស. ជាមន្ត្រីសាធារណៈ
- បានចូលរួមសិក្ខាសាលាស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគាំទ្រវិស័យយុត្តិធម៌ និងកម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌
- មន្ត្រីនាយកដ្ឋានសវនកម្មទាំងអស់ បានចុះបំពេញការងារបេសកកម្មនៅតាមសាលាដំបូងរាជធានីខេត្ត ចំនួន ១៦អង្គភាព។

ការងារសវនកម្មស្របទៅតាមនីតិវិធី និងវិធីសាស្ត្រសវនកម្ម ទៅលើការគ្រប់គ្រងហិរញ្ញវត្ថុ ការប្រតិបត្តិការងារ និងភាពអនុលោមទៅតាមច្បាប់ជាលទ្ធផលគណៈប្រតិភូបានទទួលការសហការពីអង្គភាពរងសវនកម្ម បានធ្វើការងារអស់រយៈពេលប្រាំថ្ងៃ ហើយប្រធានប្រតិភូបានផ្តល់នូវអនុសាសន៍មួយចំនួនដល់អង្គភាពរងសវនកម្ម។ អង្គភាពរងសវនកម្មបានទទួលយកនូវអនុសាសន៍ទាំងនោះ ហើយបានសន្យាថានឹងធ្វើការកែលម្អនៅឆ្នាំបន្ទាប់។

នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានស្នើសុំកិច្ចសហការពី ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គលេខាធិការដើម្បីធ្វើការសម្របសម្រួលជាមួយអាជ្ញាធរសវនកម្មជាតិក្នុងការចុះប្រមូលព័ត៌មានដើម្បីធ្វើការរៀបចំផែនការសវនកម្ម និងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុនៅក្រសួងយុត្តិធម៌និងអង្គភាពក្រោមឱវាទព្រមទាំង

បានធ្វើការសម្របសម្រួលរវាងអាជ្ញាធរសវនកម្មជាតិ និងសាលាដំបូងរាជធានីខេត្ត ចំនួន៦ បន្ថែមទៀតរួមមាន សាលាដំបូងរាជធានីភ្នំពេញ, សាលាដំបូងខេត្តកណ្តាល, សាលាដំបូងខេត្តកំពង់ស្ពឺ, សាលាដំបូងខេត្តព្រះសីហនុ, សាលាដំបូងខេត្តកំពង់ធំ និងសាលាដំបូងខេត្តសៀមរាប។

១១. ការចារយេនឌ័រ និងកុមារ

១១.១. ការផ្សព្វផ្សាយ និងបណ្តុះបណ្តាលច្បាប់

គណៈកម្មការយេនឌ័រប្រចាំក្រសួងយុត្តិធម៌ ដោយបានទទួលថវិកាតាមកម្មវិធី ពីរាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងយុត្តិធម៌ បានបន្តចុះតាមដានការដោះស្រាយរឿងក្តីស្ត្រី នៅតាមសាលាដំបូង និងបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងបណ្តុះបណ្តាល អំពីអនុសញ្ញា CEDAW និងច្បាប់ជាតិពាក់ព័ន្ធ រួមទាំងបទប្បញ្ញត្តិទាក់ទងទៅនឹង **"ការប្រើប្រាស់សិទ្ធិរដ្ឋប្បវេណីរបស់ស្ត្រី"** ដែលបានការពារដោយច្បាប់ឆ្លើយតបទៅនឹងអនុសញ្ញា CEDAW ដល់ចៅក្រម ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ក្រឡាបញ្ជី មន្ត្រីរដ្ឋបាលតុលាការ និងមន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធ ដែលរៀបចំនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តមួយចំនួនដូចខាងក្រោម៖

- ចុះតាមដានដំណើរការដោះស្រាយរឿងក្តីស្ត្រី នៅសាលាដំបូងខេត្តព្រះសីហនុ និងខេត្តរតនគិរី សរុបអ្នកចូលរួមចំនួន ៦០រូប ស្រីចំនួន ១៣រូប
- សិក្ខាសាលាផ្សព្វផ្សាយស្តីពី ច្បាប់ជាតិ អន្តរជាតិដែលពាក់ព័ន្ធនឹងស្ត្រី ចំនួន២វគ្គ នៅខេត្តបាត់ដំបង និងខេត្តព្រៃវែង សរុបសិក្ខាកាមចំនួន ២៤០រូប ស្រីចំនួន ១០៦រូប
- សិក្ខាសាលាផ្សព្វផ្សាយស្តីពី ច្បាប់ជាតិ អន្តរជាតិដែលពាក់ព័ន្ធនឹងស្ត្រី ដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការជានារី ចំនួន១វគ្គ សរុបសិក្ខាកាមចំនួន ១០០រូប
- វគ្គបណ្តុះបណ្តាលជនបង្គោលយេនឌ័រអំពីច្បាប់ជាតិ អន្តរជាតិ ដែលពាក់ព័ន្ធនឹងស្ត្រី ចំនួន ១វគ្គ នៅភ្នំពេញ សរុបសិក្ខាកាមចំនួន ១២០រូប ស្រីចំនួន ៤៤រូប
- សិក្ខាសាលាថ្នាក់ជាតិ ស្តីពី "ការអនុវត្តកុមារមេត្រីនៅតាមសាលាដំបូង" ចំនួន ១វគ្គ នៅកំពង់ចាម សរុបសិក្ខាកាមចំនួន ១២០រូប ស្រីចំនួន ៤៧រូប
- សិក្ខាសាលាថ្នាក់ជាតិ ស្តីពី "សិទ្ធិទទួលបានយុត្តិធម៌សម្រាប់ស្ត្រី" ចំនួន ១វគ្គ នៅភ្នំពេញ សិក្ខាកាមចូលរួមសរុប ១៥០រូប ស្រីចំនួន ៩១រូប។

១១.២. ការអភិវឌ្ឍសមត្ថភាពសម្រាប់មន្ត្រីរាជការ និងមន្ត្រីអនុវត្តច្បាប់ជាស្ត្រីនៅក្នុងវិស័យយុត្តិធម៌

នៅឆ្នាំ២០២៤នេះ ក្រសួងបានបញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការជានារី ឱ្យចូលរួមនិងបង្កើនសមត្ថភាពរបស់ខ្លួន តាមរយៈវគ្គបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស សរុបចំនួន ១៥លើក ដែលមានមន្ត្រីជាស្ត្រីចូលរួមសរុប ២៨រូប។

១១.៣. អំពីការរៀបចំទិវាសិទ្ធិនារី ៨មីនា

នៅក្នុងពិធីអបអរសាទរទិវាអន្តរជាតិនារី ៨ មីនា ខួបលើកទី ១១៣ ឆ្នាំ២០២៤ ក្រោមមូលបទ "**ស្ត្រី និងក្មេងស្រី ក្នុងបរិវត្តកម្មឌីជីថល**" **ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** និង **លោកជំទាវ** ព្រមទាំងថ្នាក់ដឹកនាំក្រសួងយុត្តិធម៌ បានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ដល់សមាជិកជានារីទាំងអស់ នៃក្រសួងយុត្តិធម៌, ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា បានជួបជុំសំណេះសំណាល និងពិសារអាហារសាមគ្គីរួមគ្នា ព្រមទាំងឧបត្ថម្ភនូវវត្ថុអនុស្សាវរីយ៍សម្រាប់ថ្នាក់ដឹកនាំ និងភរិយាថ្នាក់ដឹកនាំ សរុប៣៦រូប ក្នុងម្នាក់ៗ សំពត់ហូល ១ក្បិន និងសមាជិកនារីចំនួន ២៧០រូប ក្នុងម្នាក់ សំពត់សឹង ១ និងទឹកប្រាក់ ១០ម៉ឺនរៀល លើសពីនេះទៀតគឺការចាប់រង្វាន់ ដែលបានផ្តល់នូវបរិយាកាសសប្បាយរីករាយ និងស្និទ្ធស្នាលបំផុត។

១១.៤. ការរៀបចំលិខិតបទដ្ឋានគតិយុត្ត

នៅក្នុងឆ្នាំ ២០២៤នេះ គណៈកម្មការយេនឌ័របានចូលរួមពិនិត្យ ធ្វើវិសោធនកម្មក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋវេណី ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងរៀបចំសេចក្តីព្រាងច្បាប់មួយចំនួន ដូចជា៖ លក្ខន្តិកៈក្រឡាបញ្ជី លក្ខន្តិកៈមន្ត្រីអាជ្ញាសាលា លក្ខន្តិកៈសារការី សេចក្តីព្រាងច្បាប់តុលាការការងារ សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃសាលាជម្រះក្តីពាណិជ្ជកម្ម និងបទប្បញ្ញត្តិនីតិវិធីពាណិជ្ជកម្ម សេចក្តីព្រាងច្បាប់ស្តីពីការចាត់ចែងបណ្តោះអាសន្ននូវវត្ថុចាប់យក។

១១.៥. ការចូលរួមសរសេរបាយការណ៍

- បានរៀបចំរបាយការណ៍លទ្ធផលការងាររយៈពេល ៩ខែ ឆ្នាំ២០២៤ របស់ក្រសួងយុត្តិធម៌ ក្នុងការអនុវត្តកិច្ចការពារសិទ្ធិស្ត្រី ដែលអនុវត្តតាមអនុសាសន៍ ១២ចំណុច របស់ **សម្តេចមហាបវរធិបតី** និងបានដាក់ជូនក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- បានរៀបចំរបាយការណ៍វឌ្ឍនភាពរបស់ក្រសួងយុត្តិធម៌ ក្នុងការអនុវត្តសេចក្តីសង្កេតសន្និដ្ឋាន ៥៧ ចំណុច របស់គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ដោយអនុវត្តតាមអនុសញ្ញា CEDAW (របាយការណ៍លើកទី៦របស់កម្ពុជា)និងដាក់ជូនគណៈកម្មការ CEDAW
- ចូលរួមផ្តល់ធាតុចូលផែនការសកម្មភាព ២០២៥-២០២៧ នៃគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ របស់ក្រសួងផែនការ។

១២. ការងារផ្តល់សេវាជំនួយផ្នែកច្បាប់

សកម្មភាពផ្តល់ជំនួយផ្នែកច្បាប់ជូនដល់ជនក្រីក្រ របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាធ្វើឡើងក្នុងក្របខណ្ឌទូទាំងប្រទេសនិងគ្រប់សាលាជម្រះក្តី។ សកម្មភាពនេះអាចដំណើរការរលូនទៅបាន ដោយសារមានកិច្ចសហការផ្តល់ជំនួយថវិកាពីរាជរដ្ឋាភិបាលកម្ពុជា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងមានការចូលរួមពីមេធាវីស្ម័គ្រចិត្តដួយការពារក្តី និងពិគ្រោះយោបល់ដោយឥតគិតកម្រៃ។ ជាលទ្ធផលក្នុងការអនុវត្តសកម្មភាព

ក្នុងឆ្នាំ២០២៤នេះ គណៈមេធាវីបានផ្តល់មេធាវីដើម្បីការពារក្តីជូនជនក្រីក្របានចំនួន **៩,១២៨ករណី** មានកូនក្តីសរុប **១៥,៣២០រូប** (ស្រីចំនួន **១,៣២០រូប** និងអនីតិជនចំនួន **៥,៦៩៨រូប**) និងការពិគ្រោះយោបល់ផ្នែកច្បាប់បានចំនួន **៨៥០ករណី** ក្នុងនោះមាន៖

១២.១. គម្រោងផ្តល់មេធាវីការពារក្តីជូនជនក្រីក្រក្រោមកិច្ចសហការជាមួយក្រសួងយុត្តិធម៌

សកម្មភាពការពារក្តីជូនជនក្រីក្រក្នុងឆ្នាំ២០២៤ ក្រោមជំនួយឧបត្ថម្ភថវិកាពីរាជរដ្ឋាភិបាលចំនួន **២,៦០០,០០០,០០០ (ពីរពាន់ប្រាំមួយរយលាន) រៀល** មានមេធាវីចូលរួមសហការចំនួន **៧៦៧រូប**។ ជាលទ្ធផលគណៈមេធាវីបានផ្តល់មេធាវីការពារក្តីជូនជនក្រីក្របានចំនួន **៨,៤១៥ ករណី** មានកូនក្តីសរុបចំនួន **១៤,៣៣៩រូប** (ស្រីចំនួន **៥៥៤រូប**)។

ក្នុងចំណោមរឿងក្តីទាំង **៨,៤១៥ករណី** មានរឿងក្តីដែលមានកូនក្តីជាអនីតិជនចំនួន **២,៩០៥ ករណី** មានអនីតិជនសរុបចំនួន **៥,២១១រូប** (កុមារីចំនួន **២០៨រូប**) និងលទ្ធផលនៃកិច្ចពិគ្រោះយោបល់ផ្នែកច្បាប់ជូនជនក្រីក្របានចំនួន **៤៥៦ករណី**។ ចំពោះរឿងក្តីដែលបានបិទបញ្ចប់មានចំនួន **៧,១៥៣ករណី** លទ្ធផលអាចទទួលយកបានចំនួន **៥,៧២៣**ករណី ស្មើនឹង**៨០%** នៃរឿងក្តីសរុបដែលបានបិទបញ្ចប់។

នៅក្នុងឆ្នាំ២០២៤នេះ ដើម្បីទ្រទ្រង់យន្តការប្រតិភូគណៈមេធាវីនៅតាមបណ្តារាជធានី ខេត្ត ក្នុងការផ្តល់ជំនួយផ្នែកច្បាប់ជូនដល់ជនក្រីក្រឱ្យបានរហ័ស ទាន់ពេលវេលា មានប្រសិទ្ធភាពនិងខិតទៅជិតប្រជាពលរដ្ឋដែលត្រូវការជំនួយផ្នែកច្បាប់ គណៈមេធាវីបានប្រើប្រាស់ថវិកាផ្ទាល់ខ្លួនប្រមាណជាង **៦១៨,០០០,០០០ (ប្រាំមួយរយដប់ប្រាំបីលាន) រៀល** ដើម្បីចំណាយសម្រាប់ឧបត្ថម្ភដល់ប្រតិភូ និងលេខាប្រតិភូ ព្រមទាំងចំណាយសម្រាប់ទ្រទ្រង់រដ្ឋបាល សម្ភារៈការិយាល័យ និងបណ្តាញអ៊ីនធឺណេតជាដើម។ **ដោយឡែកថវិកាដែលឧបត្ថម្ភដោយរាជរដ្ឋាភិបាល គឺសម្រាប់តែចំណាយលើសោហ៊ុយក្នុងប្រតិបត្តិការជំនួយផ្នែកច្បាប់ជូនដល់ជនក្រីក្រតែប៉ុណ្ណោះ ដោយក្នុងមួយសំណុំរឿងឧបត្ថម្ភជូនមេធាវីចំនួន ៤០០,០០០ (បួនសែន) រៀល។**

១២.២. គម្រោងផ្តល់មេធាវីការពារក្តីជូនស្ត្រីនិងក្មេងស្រីក្រីក្រដែលរងគ្រោះ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានបន្តកិច្ចសហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដើម្បីផ្តល់សេវាការពារក្តីជូនស្ត្រី និងក្មេងស្រីក្រីក្រដែលរងគ្រោះដោយអំពើហិង្សា ផ្តោតលើអំពើហិង្សាក្នុងគ្រួសារ អំពើរំលោភបំពានផ្លូវភេទ ករណីធ្វើអាជីវកម្មផ្លូវភេទ ករណីលែងលះបណ្តាលមកពីអំពើហិង្សា និងករណីពិសេសពាក់ព័ន្ធនឹងការបំពានសិទ្ធិ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ស្ត្រី តាមរយៈអនុស្សរណៈនៃការយោគយល់រវាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៤។ ក្នុងឆ្នាំ២០២៤នេះ គម្រោងផ្តល់មេធាវីការពារសិទ្ធិជូនស្ត្រីនិងក្មេងស្រីក្រីក្ររងគ្រោះ មានកញ្ចប់ថវិកាសម្រាប់អនុវត្តចំនួន **៣០០,០០០,០០០ (បីរយលាន) រៀល** ព្រមទាំងមានមេធាវីស្ម័គ្រចិត្តចូលរួមការពារក្តីចំនួន **១៦៨រូប** ជាលទ្ធផលបានផ្តល់មេធាវីការពារសិទ្ធិជូនស្ត្រី និងក្មេងស្រីក្រីក្រដែលរងគ្រោះបានចំនួន **៣០៧ ករណី** មានជនរងគ្រោះសរុបចំនួន **៣២៤រូប** ក្នុងនោះកុមារីចំនួន **២៦៤រូប**។ ចំពោះមេធាវីដែល

ការពារក្តីនៅក្នុងគម្រោងនេះ ទទួលបានប្រាក់ឧបត្ថម្ភក្នុងមួយករណីចំនួន ១,២០០,០០០ (មួយលានពីរយពាន់) រៀល សម្រាប់ប៉ាប់រងការចំណាយផ្សេងៗក្នុងការការពារក្តី ដូចជាការថតចម្លងសំណុំរឿង ការធ្វើដំណើរ ការហូបចុក និងការស្នាក់នៅជាដើម។

១២.៣. ការចូលរួមពីមេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រដោយមិនគិតកម្រៃ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដាក់ចេញនូវគោលនយោបាយពិគ្រោះយោបល់ផ្នែកច្បាប់ និងការពារក្តីជូនដល់ជនក្រីក្រដោយឥតគិតកម្រៃ។ គោលនយោបាយនេះមានគោលដៅចូលរួមចំណែកធ្វើឱ្យ មានប្រសិទ្ធភាពការងារដើម្បីជួយការពារក្តី និងផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ជូនជនក្រីក្រ ក៏ដូចជា សាធារណជនគ្រប់ស្រទាប់វណ្ណៈទាំងអស់ ដែលត្រូវការជាចាំបាច់នូវជំនួយផ្នែកច្បាប់ទូទៅ និងគ្រប់កិច្ចនីតិវិធី របស់តុលាការគ្រប់ជាន់ថ្នាក់។ ជាលទ្ធផលក្នុងការអនុវត្តគោលនយោបាយនេះ គណៈមេធាវីបានចាត់តាំង មេធាវីជួយកូនក្តីបានចំនួន ៤០៦ ករណី (រឿងក្តីរដ្ឋប្បវេណីចំនួន ៩ករណី) មានកូនក្តីសរុបចំនួន ៦៥៧រូប (ស្ត្រីចំនួន ៧២រូប និងអនីតិជនចំនួន ២២៣រូប) ព្រមទាំងបានផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ជូនដល់ ប្រជាពលរដ្ឋបានចំនួន ៣៩៤ករណី។ ចំពោះចំណាយទាំងឡាយនៅក្នុងគោលនយោបាយនេះគឺជាបន្ទុក របស់មេធាវីស្ម័គ្រចិត្តទាំងស្រុង។

ផ្នែកទី២

លទ្ធផលការងាររបស់សាលាជម្រះក្តីឆ្នាំ២០២៤

ខ្លឹមសារលម្អិតនៃលទ្ធផលការងាររបស់សាលាជម្រះក្តីឆ្នាំ២០២៤ មានជូនភ្ជាប់នៅក្នុង "ឯកសារ ផ្នែកទី២ - របាយការណ៍លទ្ធផលការងាររបស់សាលាជម្រះក្តីឆ្នាំ២០២៤"។

ផ្នែកទី៣

លទ្ធផលនៃការអនុវត្តយុទ្ធនាការរយៈពេល ១ឆ្នាំ

ខ្លឹមសារលម្អិតនៃលទ្ធផលការអនុវត្តយុទ្ធនាការរយៈពេល ១ឆ្នាំ មានជូនភ្ជាប់នៅក្នុង "ឯកសារផ្នែកទី ៣ - របាយការណ៍លទ្ធផលយុទ្ធនាការរយៈពេល ១ឆ្នាំ"។

ផ្នែកទី៤

ស្ថាប័ន និងអង្គភាពពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យយុត្តិធម៌

១. ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

១.១. អំពីការងាររបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ក្នុងឆ្នាំ២០២៤ កន្លងមកនេះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបានធ្វើការពិនិត្យ និងសម្រេច អំពីការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់ឱ្យនៅក្រៅក្របខណ្ឌ ការដាក់ឱ្យនៅទំនេរ ការលុបឈ្មោះ ការដំឡើងថ្នាក់ ការដំឡើងឋានន្តរស័ក្តិ និងការចូលនិវត្តន៍ របស់ចៅក្រម និងព្រះរាជអាជ្ញាទូទាំងប្រទេស ដែលរួមមានដូចខាងក្រោម៖

- តែងតាំងចៅក្រម នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចំនួន ២រូប
- ដាក់ឱ្យផ្តាច់ពីមុខងារព្រះរាជអាជ្ញា ចំនួន ២រូប
- អនុញ្ញាតឱ្យចៅក្រម ព្រះរាជអាជ្ញា នៃសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ដែលដល់អាយុចូលនិវត្តន៍បានបន្តការងាររយៈពេល ១ឆ្នាំបន្ត ចំនួន ៦រូប
- តាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា ចំពោះព្រះរាជអាជ្ញារងកម្មសិក្សា ចំនួន ៣២រូប
- អនុញ្ញាតឱ្យចូលបំពេញមុខងារជាចៅក្រមវិញ ចំនួន ២រូប
- ដាក់ឱ្យចូលនិវត្តន៍ក្នុងក្របខណ្ឌចៅក្រម ចំនួន ២រូប
- លុបឈ្មោះពីក្របខណ្ឌព្រះរាជអាជ្ញា ដោយបណ្តេញចេញពីក្របខណ្ឌ ចំនួន ១រូប
- លុបឈ្មោះចេញពីក្របខណ្ឌចៅក្រម និងក្របខណ្ឌព្រះរាជអាជ្ញា ចំនួន ២រូប ដោយមរណភាព។

១.២. ការងាររបស់ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ក្នុងឆ្នាំ២០២៤ កន្លងមកនេះ ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានធ្វើការប្រជុំដើម្បីពិនិត្យ សម្រេច លើបណ្តឹងពាក់ព័ន្ធករណីចៅក្រម និងករណីព្រះរាជអាជ្ញា សរុបចំនួន ១៥ករណី។

ក. ករណីពាក់ព័ន្ធនឹងចៅក្រម

ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានប្រជុំសម្រេចលើសំណុំរឿងវិន័យ ចំនួន ៧ករណី ដែលពាក់ព័ន្ធនឹងចៅក្រមចំនួន ៩រូប ក្រុមប្រឹក្សាវិន័យ បានពិនិត្យ សម្រេចលើវិន័យការងារ ដូចខាងក្រោម៖

- ផ្អាកមិនឱ្យចុះឈ្មោះក្នុង តារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិមួយរយៈតែមិនត្រូវឱ្យលើសពី ២ឆ្នាំទេ ឬលុបឈ្មោះចេញពីតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិវិញក្នុងករណីដែលបានចុះឈ្មោះរួចហើយ មានចំនួន ១រូប
- ផ្លាស់ដោយបង្ខំអាចតម្រូវឱ្យទទួលការបណ្តុះបណ្តាលបន្ថែម មានចំនួន ១រូប
- ស្តីបន្ទោសដោយផ្ទាល់មាត់ មានចំនួន ៥រូប
- ព្យួរពីការងារមិនឱ្យមានបៀវត្សរយៈពេល ៦ខែ មានចំនួន ១រូប

- ផ្លាស់ដោយបង្ខំ ឱ្យទៅជាអនុប្រធានសាលាដំបូងខេត្តណាមួយ មានចំនួន ១រូប។

ខ. ករណីពាក់ព័ន្ធនឹងព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង

ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបានប្រជុំពិនិត្យ និងសម្រេច លើសំណុំរឿងវិន័យ សរុបចំនួន ៨ករណី ពាក់ព័ន្ធនឹងព្រះរាជអាជ្ញាចំនួន ៨រូប ដែលបានដាក់វិន័យក្រោមរូបភាព៖

- ដាក់វិន័យដោយបណ្តេញចេញពីក្របខណ្ឌព្រះរាជអាជ្ញា ចំនួន ១រូប
- ស្តីបន្ទោសដោយចុះក្នុងសំណុំលិខិតផ្ទាល់ខ្លួន ចំនួន ៣រូប
- ផ្លាស់ដោយបង្ខំ អាចតម្រូវឱ្យទទួលការបណ្តុះបណ្តាលបន្ថែម ចំនួន ២រូប
- រួចផុតពីវិន័យ ចំនួន ២រូប។

១.៣. ការងាររបស់អគ្គលេខាធិការដ្ឋាន

ក្នុងឆ្នាំ២០២៤ កន្លងមកនេះ អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រេចបាននូវលទ្ធផលការងារដូចខាងក្រោម៖

១.៣.១. លទ្ធផលការងាររបស់នាយកដ្ឋានកិច្ចការអាជីពចៅក្រម និងព្រះរាជអាជ្ញា

ក្នុងឆ្នាំ២០២៤ កន្លងមកនេះ នាយកដ្ឋានកិច្ចការអាជីពចៅក្រម និងព្រះរាជអាជ្ញា បានបំពេញការងាររួមមាន៖

- បានត្រៀមរៀបចំឯកសារ របាយការណ៍ និងធ្វើសេចក្តីព្រាងរបៀបវារៈ សម្រាប់សម័យប្រជុំឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកទី៣៨ នាពេលខាងមុខ (ចំនួន ១លើក)
- រៀបចំ និងធ្វើរបាយការណ៍អមសេចក្តីព្រាងព្រះរាជក្រឹត្យ ជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** ដើម្បីទូលថ្វាយ **ព្រះករុណាជាអម្ចាស់ ព្រះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម** បន្ទាប់ពីបានការពិនិត្យ សម្រេច ពិគ្រោះយោបល់ពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានចំនួន ២១ សេចក្តីព្រាងព្រះរាជក្រឹត្យ
- រៀបចំកម្មវិធីសម្រាប់សម័យប្រជុំឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានចំនួន ១លើក, រៀបចំឯកសារបោះឆ្នោតដោយប្រយោលបានចំនួន ៣លើក និងបានរៀបចំឯកសារពិគ្រោះយោបល់ចំនួន ១១លើក
- រៀបចំបែបបទ និងនីតិវិធីបោះឆ្នោតសម្រាប់ការជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រាប់អាណត្តិទី៣
- រៀបចំបញ្ជីឈ្មោះចៅក្រម និងព្រះរាជអាជ្ញា ដែលដល់វេនអតីតភាពសម្រាប់ធ្វើការផ្លាស់ប្តូរ ចំនួន ៨៥រូប

- រៀបចំបញ្ជីតារាង និងព្រឹត្តិបត្រវាយតម្លៃ សម្រាប់ការស្នើដំឡើងថ្នាក់ ឬឋានន្តរស័ក្តិ តាមវេន អតីតភាព ចំពោះចៅក្រម ព្រះរាជអាជ្ញា នៅគ្រប់សាលាជម្រះក្តីនៅទូទាំងប្រទេស សរុប មានចំនួន ៣២៦រូប និងតាមកម្រិតសញ្ញាបត្រ មានចំនួន ៦៨រូប
- រៀបចំបញ្ជីឈ្មោះចៅក្រម និងព្រះរាជអាជ្ញាសម្រាប់ការស្នើសុំផ្តល់គ្រឿងឥស្សរិយយស មានចំនួន ២៨៥រូប
- បានរៀបចំបញ្ជីឈ្មោះ សម្រាប់ការស្នើបោះពុម្ព បណ្ណសម្គាល់ខ្លួនចៅក្រម ព្រះរាជអាជ្ញា ចំនួន ២៩៤រូប
- បានរៀបចំបញ្ជីឈ្មោះចៅក្រម និងព្រះរាជអាជ្ញា ដែលដល់អាយុចូលនិវត្តន៍ សរុបចំនួន ១១រូប(ក្នុងឆ្នាំ២០២៤ ចំនួន ៥រូប) និងតាមការស្នើសុំរបស់សាមីខ្លួន ចំនួន ១រូប
- រៀបចំបញ្ជីឈ្មោះ និងព្រឹត្តិបត្រវាយតម្លៃ សម្រាប់ការស្នើតាំងស៊ប់ក្នុងក្របខណ្ឌចៅក្រម និងក្របខណ្ឌព្រះរាជអាជ្ញា សរុបចំនួន ៨៧រូប
- រៀបចំបញ្ចូលទិន្នន័យទាក់ទងនឹងប្រវត្តិរូបចៅក្រម និងព្រះរាជអាជ្ញា ទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យា បានចំនួន ៦៥៣រូប
- រៀបចំសំណើសុំអនុញ្ញាតច្បាប់របស់ចៅក្រម និងព្រះរាជអាជ្ញា សរុបចំនួន ៧៣រូប គោរពជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** ដើម្បីពិនិត្យសម្រេច។

១.៣.២.ការងាររបស់នាយកដ្ឋានទទួលពាក្យបណ្តឹង និងកិច្ចការវិន័យ

ក្នុងឆ្នាំ២០២៤កន្លងមកនេះ នាយកដ្ឋានទទួលពាក្យបណ្តឹង និងកិច្ចការវិន័យ នៃអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានទទួលពាក្យបណ្តឹងពាក់ព័ន្ធនឹងវិន័យការងាររបស់ចៅក្រម និងព្រះរាជអាជ្ញា សរុបចំនួន ៩៥ពាក្យបណ្តឹង និងបានរៀបចំបញ្ជូនទៅតាមនីតិវិធី រួមមានដូចខាងក្រោម៖

ក្នុងឆ្នាំ២០២៤កន្លងមកនេះ នាយកដ្ឋានទទួលពាក្យបណ្តឹង និងកិច្ចការវិន័យ នៃអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានទទួលពាក្យបណ្តឹងដែលពាក់ព័ន្ធនឹងចំណាត់ការការងាររបស់ចៅក្រម និងព្រះរាជអាជ្ញា សរុបមានចំនួន ៩៥ករណី ក្នុងនោះរួមមាន៖

- ពាក្យបណ្តឹងពាក់ព័ន្ធនឹងចំណាត់ការការងាររបស់ចៅក្រម មានចំនួន ៥៩ករណី
- ពាក្យបណ្តឹងពាក់ព័ន្ធនឹងចំណាត់ការការងាររបស់ព្រះរាជអាជ្ញា មានចំនួន ៣៦ករណី។

ក្នុងចំណោមពាក្យបណ្តឹងទាំង ៩៥ករណី ខាងលើនេះ មានពាក្យបណ្តឹងពាក់ព័ន្ធនឹងចំណាត់ការការងាររបស់ចៅក្រម ចំនួន ៥៩ករណី ហើយបានចាត់ការដូចខាងក្រោម៖

- ពាក្យបណ្តឹង ចំនួន ៥១ករណី អគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានរៀបចំធ្វើកំណត់បង្ហាញ គោរពជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** ដើម្បីពិនិត្យសម្រេច

- សំណុំរឿង ចំនួន ៦ករណី ជាសំណុំរឿងដែលទទួលបានពីគណៈកម្មការជាតិដោះលែង ដោយមានលក្ខខណ្ឌ និងគណៈកម្មការដឹកនាំ និងអនុវត្តយុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ
- ពាក្យបណ្តឹង ចំនួន ២ករណី ម្ចាស់បណ្តឹងបានស្នើសុំដកពាក្យបណ្តឹងរបស់ខ្លួនវិញ។

ក្នុងចំណោមពាក្យបណ្តឹង និងសំណុំរឿងទាំងអស់ខាងលើនេះ បន្ទាប់ពីទទួលបានការពិនិត្យ សម្រេចពី **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌,** អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានរៀបចំ និងបញ្ជូនទៅក្រុមប្រឹក្សាវិន័យ ចំនួន ៥៧ករណី។

ដោយឡែកពាក្យបណ្តឹងពាក់ព័ន្ធនឹងចំណាត់ការការងាររបស់ព្រះរាជអាជ្ញា មានចំនួន ៣៦ករណី ហើយបានចាត់ការ ដូចខាងក្រោម៖

- ពាក្យបណ្តឹង ចំនួន ៣២ករណី អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានរៀបចំធ្វើកំណត់បង្ហាញ គោរពជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** ដើម្បីពិនិត្យសម្រេច
- សំណុំរឿង ចំនួន ៣ករណី ជាពាក្យបណ្តឹងដែលទទួលបានពីគណៈកម្មការដឹកនាំ និងអនុវត្តយុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ
- ពាក្យបណ្តឹង ចំនួន ១ករណី ម្ចាស់បណ្តឹងបានស្នើសុំដកពាក្យបណ្តឹងរបស់ខ្លួនវិញ។

ក្នុងចំណោមពាក្យបណ្តឹង និងសំណុំរឿងទាំងអស់ខាងលើនេះ បន្ទាប់ពីទទួលបានការពិនិត្យ សម្រេចពី **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌,** អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានរៀបចំ និងបញ្ជូនទៅក្រុមប្រឹក្សាវិន័យ ចំនួន ៣៤ករណី។

នៅក្នុងឆ្នាំ២០២៤ កន្លងមកនេះ ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានធ្វើការប្រជុំដើម្បីពិនិត្យ សម្រេច លើបណ្តឹង សរុបចំនួន ១៥ករណី ពាក់ព័ន្ធនឹងចៅក្រម និងព្រះរាជអាជ្ញា សរុបចំនួន ១៧រូប។

១.៣.៣. ការងាររបស់នាយកដ្ឋានកិច្ចការរដ្ឋបាល បុគ្គលិក និងហិរញ្ញកិច្ច

ក្នុងឆ្នាំ២០២៤ កន្លងមកនេះ នាយកដ្ឋានកិច្ចការរដ្ឋបាល បុគ្គលិក និងហិរញ្ញកិច្ចនៃអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានទទួលលិខិតចូលចំនួន ៨២៦ច្បាប់ និងលិខិតចេញចំនួន ៨៨៨ច្បាប់។

ថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានចូលរួមកិច្ចប្រជុំ និងសិក្ខាសាលាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ជាអាទិ៍៖

- ប្រជុំក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចំនួន ១៥លើក
- រៀបចំការជួបប្រជុំជូនសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចំនួន ៣២លើក
- រៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាណត្តិទី៣
- ចូលរួមកិច្ចប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលសរុប ចំនួន ៦៥លើក

- អគ្គលេខាធិការដ្ឋានឧត្តក្រុមប្រឹក្សានៃអង្គចៅក្រម បានរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានបានចំនួន ២លើក មួយលើកនៅខេត្តកំពត និងមួយលើកទៀតនៅខេត្តមណ្ឌលគិរី
- ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អញ្ជើញចូលរួមសិក្ខាសាលានៅបរទេសចំនួន ៥លើក។

ក. ការងារកិច្ចការហិរញ្ញវត្ថុ និងថវិកាព័ត៌មានសមិទ្ធកម្ម នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ស្ថិតក្នុងកម្មវិធីទី២ "កិច្ចការតុលាការ" អនុកម្មវិធីទី៩ "សេវាគាំទ្រដល់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម"។ គោលបំណងអនុកម្មវិធីនេះ គឺផ្តល់មូលនិធិឱ្យអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ធ្វើជាសេនាធិការក្នុងការផ្តល់សេវាជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

សម្រាប់កិច្ចការហិរញ្ញកិច្ចដែលបានអនុវត្តក្នុងឆ្នាំ២០២៤ គឺបានអនុវត្តទាំងស្រុងទៅតាមប្រព័ន្ធ FMIS (Financial Management Information System)។ ការទូទាត់អាណត្តិ បានចំនួន ៨០អាណត្តិ, ការវិភាជន៍ថវិកាបានចំនួន ៣លើក និងសំណើសុំគោលការណ៍ទូទាត់ចំណាយ បានចំនួន ១៣លើក។ ចំពោះអនុមុខងាររៀបចំថវិកាសមិទ្ធកម្ម និងរៀបចំផែនការយុទ្ធសាស្ត្រថវិកា, អនុមុខងាររៀបចំចំណាយប្រាក់បៀវត្សមន្ត្រីរាជការ និងអនុមុខងាររៀបផែនការចំណាយថវិកា ត្រូវបានអនុវត្តតាមប្រព័ន្ធ BPS (Budget Planning System)។ ក្នុងឆ្នាំ២០២៤ ចំពោះថវិការបស់អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបានចំណាយសរុបចំនួន ៤,៩៤១,៧៣៣,៦៩៩រៀល គិតជាភាគរយ ៩៣.៧៣% នៃច្បាប់ថវិកាឆ្នាំ២០២៤។

ខ. ការងារព័ត៌មានវិទ្យា និងបណ្ណាសារ

នៅក្នុងឆ្នាំ២០២៤ កន្លងមកនេះ ការងារព័ត៌មានវិទ្យា និងបណ្ណាសារ របស់អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានសម្រេចការងារមួយចំនួនដូចខាងក្រោម៖

- រៀបចំបោះពុម្ពបណ្ណសម្គាល់ខ្លួន ជូនសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចៅក្រម និងព្រះរាជអាជ្ញានៅទូទាំងប្រទេស និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សរុបទាំងអស់ចំនួន ៤៥៨បណ្ណ
- បានធ្វើការថែទាំប្រព័ន្ធទិន្នន័យចំនួន ៤ និងធ្វើការដំឡើងថែទាំជួសជុលកុំព្យូទ័រ ម៉ាស៊ីនព្រីនធឺរ បណ្តាញណេតវើក (Network) និងអ៊ិនធឺណេត (Internet)។

គ. អង្គភាពលទ្ធកម្ម

ក្នុងឆ្នាំ២០២៤នេះ អង្គភាពលទ្ធកម្មបានរៀបចំផែនការលទ្ធកម្ម ដោយផ្អែកទៅលើកញ្ចប់ថវិកាប្រចាំឆ្នាំដែលបានអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីផ្គត់ផ្គង់ទំនិញ សំណង់ និងសេវាកម្ម សម្រាប់

បំពេញឱ្យតម្រូវការប្រើប្រាស់ប្រចាំឆ្នាំ របស់អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបានអនុវត្តកិច្ចលទ្ធកម្មចប់ជាស្តាពរចំនួន ១១គម្រោង។

១.៤. ការងារការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ

ក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានអនុវត្តផែនការសកម្មភាពលម្អិតតាមគោលដៅនៃសូចនាករសមិទ្ធកម្មគន្លឹះ ប្រចាំឆ្នាំ២០២៤ មានសកម្មភាពចំនួន ២០សកម្មភាព ហើយសម្រេចបាន១០០% ក្នុងនោះ៖

ផ្នែកទី១៖ ការបន្តពង្រឹងភាពជឿទុកចិត្តនៃវដ្តថវិកា បានអនុវត្ត ចំនួន ៨សកម្មភាព
ផ្នែកទី២៖ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ បានអនុវត្ត ចំនួន ៥សកម្មភាព
ផ្នែកទី៣៖ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ បានអនុវត្ត ចំនួន ១សកម្មភាព
ផ្នែកទី៤៖ ការឈានឆ្ពោះទៅគណនេយ្យសមិទ្ធកម្ម បានអនុវត្ត ចំនួន ២សកម្មភាព និង
ផ្នែកទី៥៖ ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត បានអនុវត្ត ចំនួន ៤សកម្មភាព។

២. គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

នៅក្នុងឆ្នាំ២០២៤ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌សម្រេចបានលទ្ធផលការងារ ដូចខាងក្រោម៖

២.១. កិច្ចការផែនការ និងយុទ្ធសាស្ត្រ

- រៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធយុត្តិធម៌ ត្រូវបានពិនិត្យពិភាក្សា និងធ្វើការកែសម្រួលត្រឹមកម្រិតថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋាន

២.២. ការងារផ្សព្វផ្សាយ

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ចំនួន ៤ដង ដល់មន្ត្រីពាក់ព័ន្ធចំនួន ២៥០ រូប
- ផលិតស្តុតអំពីកម្មវិធីកំណែទម្រង់ និងសមិទ្ធផល សម្រាប់ចាក់ផ្សាយតាមរយៈវិទ្យុ និងទូរទស្សន៍ ចំនួន ២ ដង
- រៀបចំផ្សព្វផ្សាយអំពីកម្មវិធីការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងសមិទ្ធផល តាមរយៈវិទ្យុនិងទូរទស្សន៍ ព្រមទាំងអង្គភាពសារព័ត៌ផ្សេងៗ ចំនួន ៣៦ ដង

២.៣. ការងារអន្តរស្ថាប័ន

អ.គ.ក.ប.យ. បានចូលរួមជាមួយយន្តការនៃការដ្ឋានកែទម្រង់ ៤ ផ្សេងទៀត ដូចជា លេខាធិការដ្ឋាននៃគណៈកម្មាធិការអភិវឌ្ឍតាមបែបប្រជាធិតេយ្យ, អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់ការ

គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ អគ្គ-លេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ធ្វើការជួបប្រជុំ វិបស្សនា និងសិក្ខាសាលាជាច្រើនលើកច្រើនសារ ដើម្បីពិនិត្យ និងពិភាក្សាលើវឌ្ឍនភាពនៃការអនុវត្តសកម្មភាពសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះ នៃរាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។ អ.គ.ក.ប.យ. បានចូលរួមសហការជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រៀបចំជាសិក្ខាសាលាស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគាំទ្រវិស័យយុត្តិធម៌ និងកម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌ កាលពីថ្ងៃទី២៨-២៩ ខែវិច្ឆិកា ឆ្នាំ២០២៤។

២.៤. កិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ បានដើរនាទីយ៉ាងសកម្មក្នុងការធ្វើទំនាក់ទំនងការងារជាមួយដៃគូអភិវឌ្ឍន៍ លើការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌ រួមមាន (១)-កិច្ចសហការជាមួយការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាក្នុងក្របខណ្ឌប្រធានប្តូរវេន TWG ជាវេទិការវាងក្រសួងយុត្តិធម៌ និងអង្គការសង្គមស៊ីវិល, (២)-បានរៀបចំសូចនាករួមគ្នាក្នុងក្របខណ្ឌតាមដានរួមអំពីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ សម្រាប់ឆ្នាំ២០២៤-២០២៨៖ បច្ចុប្បន្នភាពសូចនាករតាមដានរួមសម្រាប់ឆ្នាំ២០២៤-២០២៥ ជាមួយការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា និង (៣)-កិច្ចសហការជាមួយ ក្រសួងយុត្តិធម៌កូរ៉េ លើការផ្លាស់ប្តូរទស្សនកិច្ចសិក្សារវាងប្រព័ន្ធយុត្តិធម៌នៃប្រទេសទាំងពីរ។

៣. បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា

គិតត្រឹមឆ្នាំ២០២៥, បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ផលិតបានធនធានជាចៅក្រម, ព្រះរាជអាជ្ញា, ក្រឡាបញ្ជី, អាជ្ញាសាលា និង សារការី សរុបចំនួន **២,១៣០** នាក់ ក្នុងនោះ ចៅក្រម និងព្រះរាជអាជ្ញា សរុបចំនួន **៥៩៧** នាក់, ក្រឡាបញ្ជី សរុបចំនួន **១,៤៦៨** នាក់ (ក្នុងនោះមន្ត្រីសុក្រឹត្យការក្រឡាបញ្ជីមានចំនួន **៦១៦** នាក់), អាជ្ញាសាលា សរុបចំនួន **២៨** នាក់, សារការី សរុបចំនួន **៣៧** នាក់។

៣.១. ការប្រឡងប្រជែងជ្រើសរើសសិស្សវិជ្ជាជីវៈតុលាការ នៃឆ្នាំ២០២៤

ដោយទទួលបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល និងក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានក្រុមប្រឹក្សាភិបាល នៃ ប.ភ.យ.ក.** បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា បានរៀបចំការប្រឡងប្រជែងជ្រើសរើស៖

៣.១.១. សិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញាជំនាន់ទី១២

នៅក្នុងអំឡុងខែធ្នូ ឆ្នាំ២០២៣ ដល់ខែកុម្ភៈ ឆ្នាំ២០២៤ បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា បានរៀបចំការប្រឡងប្រជែងជ្រើសរើសសិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញា ជំនាន់ទី១២ ដោយជ្រើសរើសបានជ័យលាភីជាសិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញា ជំនាន់ទី១២ ចំនួន ៥៥រូប (ស្រី ១៧រូប)។

៣.១.២. សិស្សក្រឡាបញ្ជីជំនាន់ទី៩

នៅក្នុងអំឡុងខែធ្នូ ដល់ខែកុម្ភៈ ឆ្នាំ២០២៤ បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ក៏បានរៀបចំការប្រឡងប្រជែងជ្រើសរើសសិស្សក្រឡាបញ្ជី ជំនាន់ទី៩ ដោយជ្រើសរើសបានដំយលាភីជាសិស្សក្រឡាបញ្ជី ជំនាន់ទី៩ ចំនួន ១០៥ រូប (ស្រី ៤៤ រូប)។ បេក្ខភាពដំយលាភី ចំនួន ៦ រូប (ស្រី ៣រូប) បានស្នើសុំបោះបង់សិទ្ធិជាសិស្សក្រឡាបញ្ជី ជំនាន់ទី៩ ដោយមូលហេតុផ្ទាល់ខ្លួន។

ដោយសារករណីនេះ សិស្សក្រឡាបញ្ជី ជំនាន់ទី៩ ដែលបាន និងកំពុងទទួលការបណ្តុះបណ្តាលនៅបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា មានចំនួនត្រឹមតែ ៩៩រូប (ស្រី ៤១ រូប) ប៉ុណ្ណោះ។

៣.១.៣. សិស្សអាជ្ញាសាលាជំនាន់ទី៣

នៅខែឧសភា ឆ្នាំ២០២៤ បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា បានរៀបចំការប្រឡងប្រជែងជ្រើសរើសសិស្សអាជ្ញាសាលា ជំនាន់ទី៣។ ជាលទ្ធផលទទួលបានសិស្សអាជ្ញាសាលា ជំនាន់ទី៣ ចំនួន ៥៥រូប (ស្រី ៩រូប) ដែលបាន និងកំពុងទទួលការបណ្តុះបណ្តាលនៅបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ចាប់ពីខែសីហា ឆ្នាំ២០២៤ មក។

៣.១.៤. សិស្សសារការីជំនាន់ទី៤

នៅខែមិថុនា ឆ្នាំ២០២៤ បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា បានរៀបចំការប្រឡងប្រជែងជ្រើសរើសសិស្សសារការី ជំនាន់ទី៤។ ជាលទ្ធផល ទទួលបានដំយលាភីជាសិស្សសារការី ជំនាន់ទី៤ មានចំនួន ៥០រូប (ស្រី ២៧រូប)។ ក្នុងចំណោមដំយលាភីទាំង ៥០រូប មាន ១រូប បានស្នើសុំបោះបង់សិទ្ធិជាសិស្សសារការី ជំនាន់ទី៤ ដោយមូលហេតុសាមីខ្លួនបានប្រឡងជាប់ជាមន្ត្រីរាជការ នៃអង្គភាពប្រឆាំងអំពើពុករលួយ។ ដូចនេះ សិស្សសារការី ជំនាន់ទី៤ ដែលបាន និងកំពុងទទួលការបណ្តុះបណ្តាលនៅបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ចាប់ពីខែសីហា ឆ្នាំ២០២៤ មកដល់ពេលបច្ចុប្បន្ន មានចំនួន ៤៩រូប (ស្រី ២៧រូប)។

៣.១.៥. សិស្សថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញតុលាការជំនាន់ទី១

នៅក្នុងខែធ្នូ ឆ្នាំ២០២៤ បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ក៏បានរៀបចំការប្រឡងប្រជែងជ្រើសរើសសិស្សឱ្យចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញតុលាការ ជំនាន់ទី១ សម្រាប់ការបណ្តុះបណ្តាលនៅសាលាច្បាប់។ ជាលទ្ធផល បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជាជ្រើសរើសបានដំយលាភីជាសិស្សថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញតុលាការ ជំនាន់ទី១ ចំនួន ១៧៣រូប (ស្រី ៦៦រូប)។

ដោយទទួលបានគោលការណ៍អនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** នៅក្នុងឆ្នាំ២០២៤ បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ក៏បានសហការជាមួយអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដើម្បីរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ឱ្យចូលបម្រើការងារនៅអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការផងដែរ។

ការប្រឡងប្រជែងជ្រើសរើសសិស្សវិជ្ជាជីវៈតុលាការ នៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ត្រូវបានរៀបចំឡើងក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានក្រុមប្រឹក្សាភិបាល នៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា** និងមានការចូលរួមពីតំណាងក្រសួងស្ថាប័នសំខាន់ៗដែលពាក់ព័ន្ធ ជាពិសេសមានការចូលរួមសង្កេតការណ៍នៅគ្រប់ដំណាក់កាលនៃការរៀបចំការប្រឡងប្រជែងពីអង្គភាពប្រឆាំងអំពើពុករលួយ។

ចាប់ពីខែតុលា ឆ្នាំ២០២៤ មកដល់ពេលបច្ចុប្បន្ននេះ បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា បាន និងកំពុងទទួលពាក្យសុំប្រឡងប្រជែងជ្រើសរើសសិស្សសាលាភូមិន្ទវិជ្ជាជីវៈទាំង ៤ សម្រាប់ការប្រឡងប្រជែងជ្រើសរើសសិស្សជំនាន់បន្ទាប់ នៃសាលាភូមិន្ទវិជ្ជាជីវៈនីមួយៗ។ គិតមកដល់សប្តាហ៍ទី៣ នៃខែមករា ឆ្នាំ២០២៥ បេក្ខជនដាក់ពាក្យសុំប្រឡងប្រជែងជ្រើសរើស៖

- សិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញា ជំនាន់ទី១៣ បានចំនួន ២៥៦រូប
- សិស្សក្រឡាបញ្ជី ជំនាន់ទី១០ បានចំនួន ៥១០រូប
- សិស្សអាជ្ញាសាលា ជំនាន់ទី៤ បានចំនួន ១៧១រូប
- សិស្សសារការី ជំនាន់ទី៥ បានចំនួន ៨៨រូប។

៣.២. ការបណ្តុះបណ្តាលដំបូងនៅក្នុងឆ្នាំ២០២៤

៣.២.១. សាលាភូមិន្នចៅក្រម និងព្រះរាជអាជ្ញា

ក. សិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញា ជំនាន់ទី១១

មកដល់ពេលបច្ចុប្បន្ននេះ សិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញា ជំនាន់ទី១១ ចំនួន ៥៦រូប (ស្រី ១២រូប) បានបញ្ចប់ការបណ្តុះបណ្តាលវគ្គសិក្ខាគារិកភាព ម៉ូឌុល ៤ "ឯកទេសកម្ម" នៅសប្តាហ៍ទី២ នៃខែមករា ឆ្នាំ២០២៥ នេះ។ បន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាលវគ្គសិក្ខាគារិភាព សិស្សត្រូវចុះកម្មសិក្សាសម្រាប់ម៉ូឌុល ៤ "ឯកទេសកម្ម" រយៈពេល ៤ ខែបន្តទៀត នៅតាមសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី ខេត្ត ចំនួន ៥ រួមមាន សាលាដំបូងនិងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តតាកែវ និងខេត្តស្វាយរៀង តាមជំនាញឯកទេសរបស់ខ្លួនជាចៅក្រមអាសនៈ ចំនួន ៣៨រូប (ស្រី ១១រូប) និងចៅក្រមអយ្យការ ចំនួន ១៨រូប (ស្រី ១រូប)។ ការចុះកម្មសិក្សានេះគ្រោងនឹងប្រព្រឹត្តចាប់ពីសប្តាហ៍ទី៤ នៃខែមករា រហូតដល់ខែឧសភា ឆ្នាំ២០២៥។

ខ. សិស្សចៅក្រមផ្នែកក្នុងជំនាន់ទី២

សិស្សចៅក្រមផ្នែកក្នុងជំនាន់ទី២ ចំនួន ១៥រូប (ស្រី ៥រូប) បានបញ្ចប់ការបណ្តុះបណ្តាលនៅបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា នៅក្នុងអំឡុងខែកញ្ញា ឆ្នាំ២០២៤។ យោងតាមលទ្ធផលនៃការបូកស្រង់ពិន្ទុតាមសេចក្តីសម្រេចលេខ ១៤.កយ.សសរ/២០ ស្តីពីការកែសម្រួលប្រការ ៦៩ ប្រការ ៧១ និងប្រការ ៧៤ ថ្មី នៃបទបញ្ជាផ្ទៃក្នុង សម្រាប់សិស្ស មន្ត្រីសុក្រឹត្យការ និងមន្ត្រីវិក្រឹតការ សិស្សចៅក្រមផ្នែកក្នុងជំនាន់ទី២ ទទួលបាន

ជោគជ័យជាស្តាពរគ្រប់ៗគ្នា។ សិស្សនឹងត្រូវចេញទៅបម្រើការងារនៅតាមអង្គភាពចំណុះនានា នៃក្រសួងយុត្តិធម៌វិញ។

គ. សិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញា ជំនាន់ទី១២

សិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញា ជំនាន់ទី១២ ចំនួន ៥៥រូប (ស្រី ១៧រូប) បាន និងកំពុងទទួលការបណ្តុះបណ្តាលវគ្គសិក្ខាគារិកភាព ម៉ូឌុល ១ "សិក្ខាគារិកភាពដំបូង" និងម៉ូឌុល ២ "សិក្ខាគារិកភាពជំនាញរួម" នៅបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ចាប់ពីខែកក្កដា ឆ្នាំ២០២៤ មកដល់ពេលបច្ចុប្បន្ន។

៣.២.២. សាលាភូមិន្ទក្រឡាបញ្ជី

ក. សិស្សក្រឡាបញ្ជីវគ្គពិសេស ជំនាន់ទី៤

សាលាភូមិន្ទក្រឡាបញ្ជីបាន និងកំពុងបណ្តុះបណ្តាលសិស្សក្រឡាបញ្ជី វគ្គពិសេស ជំនាន់ទី៤ ចំនួន ៦៨រូប (ស្រី ២៣រូប) ចាប់ពីខែកញ្ញា ឆ្នាំ២០២៣ សម្រាប់វគ្គសិក្ខាគារិភាពរយៈពេល ៦ខែ និងវគ្គកម្មសិក្សារយៈពេល ៦ខែ។ សិស្សក្រឡាបញ្ជីវគ្គពិសេស ជំនាន់ទី៤ ទើបតែបានបញ្ចប់វគ្គកម្មសិក្សា នៅតាមសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ទាំង ៤ នៅក្នុងអំឡុងសប្តាហ៍ទី ៤ នៃខែធ្នូ ឆ្នាំ២០២៤។ បច្ចុប្បន្ន សិស្សកំពុងត្រៀមការពាររបាយការណ៍កម្មសិក្សារបស់ខ្លួន ដែលកម្មវិធីការពាររបាយការណ៍កម្មសិក្សានេះគ្រោងនឹងប្រព្រឹត្តទៅនៅក្នុងអំឡុងសប្តាហ៍ទី១ នៃខែកុម្ភៈ ឆ្នាំ២០២៥។ បន្ទាប់ពីបញ្ចប់ការការពាររបាយការណ៍កម្មសិក្សា សិស្សនឹងត្រូវប្រឡងបញ្ចប់ការសិក្សានាពេលឆាប់ៗ ខាងមុខនេះ។

ខ. សិស្សក្រឡាបញ្ជី ជំនាន់ទី៩

សិស្សក្រឡាបញ្ជី ជំនាន់ទី៩ ចំនួន ១០៥រូប (ស្រី ៤៤រូប) បានទទួលការបណ្តុះបណ្តាលវគ្គសិក្ខាគារិកភាព នៅបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ចាប់ពីខែមិថុនា ឆ្នាំ២០២៤ សម្រាប់រយៈពេល ៦ខែ។ សិស្សក្រឡាបញ្ជី ជំនាន់ទី៩ បានបញ្ចប់ការបណ្តុះបណ្តាលវគ្គសិក្ខាគារិកភាពនៅក្នុងខែធ្នូ ឆ្នាំ២០២៤។ ផ្អែកតាមកម្មវិធីសិក្សារបស់សាលាភូមិន្ទក្រឡាបញ្ជី បន្ទាប់ពីបានបញ្ចប់ការបណ្តុះបណ្តាលវគ្គសិក្ខាគារិកភាព សិស្សនឹងត្រូវចុះកម្មសិក្សារយៈពេល ៦ខែបន្តទៀត នៅតាមសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តចំនួន ៦ រួមមានសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកំពត ខេត្តពោធិ៍សាត់ ខេត្តកំពង់ចាម ខេត្តបាត់ដំបង ខេត្តព្រះសីហនុ និងខេត្តសៀមរាប ដែលគ្រោងនឹងប្រព្រឹត្តទៅចាប់ពីខែមករា ដល់ខែកក្កដា ឆ្នាំ២០២៥។

៣.២.៣. សាលាភូមិន្ទអាជ្ញាសាលា

ក. សិស្សអាជ្ញាសាលា ជំនាន់ទី២

សិស្សអាជ្ញាសាលា ជំនាន់ទី២ ចំនួន ២៨រូប (ស្រី ៦រូប) បានបញ្ចប់ការចុះកម្មសិក្សានៅតាមសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ព្រមទាំងបានការពាររបាយការណ៍កម្មសិក្សារបស់ខ្លួនរួចរាល់ នៅក្នុងខែកញ្ញា ឆ្នាំ២០២៤។ សិស្សបានប្រឡងបញ្ចប់ការសិក្សារួចរាល់ នៅក្នុងអំឡុងខែធ្នូ

ឆ្នាំ២០២៤។ បន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាលជាស្តាពរ សិស្សត្រូវចាប់ប៉ុស្តិ៍ចេញបម្រើការងារនៅតាមសាលាជម្រះក្តី រាជធានី-ខេត្ត នាពេលឆាប់ៗ ខាងមុខនេះ។

ខ. សិស្សអាជ្ញាសាលា ជំនាន់ទី៣

សិស្សអាជ្ញាសាលា ជំនាន់ទី៣ ចំនួន ៥៥រូប (ស្រី ៩រូប) បានចាប់ផ្តើមទទួលការបណ្តុះបណ្តាលវគ្គសិក្ខាគារិកភាព សម្រាប់រយៈពេល ១ ឆ្នាំ ចាប់ពីខែសីហា ឆ្នាំ២០២៤។ តាមកម្មវិធីសិក្សារបស់សាលាភូមិន្ទអាជ្ញាសាលា សម្រាប់សិស្សអាជ្ញាសាលា ជំនាន់ទី២ សិស្សត្រូវទទួលការបណ្តុះបណ្តាល ចំនួន ៦៤ មុខវិជ្ជា សម្រាប់វគ្គសិក្ខាគារិកភាព។ មកដល់ពេលបច្ចុប្បន្ននេះ សិស្សបានទទួលការបណ្តុះបណ្តាលវគ្គសិក្ខាគារិកភាពចប់ បានចំនួន ២៨ មុខវិជ្ជា និងបានប្រឡងត្រួតពិនិត្យចំណេះដឹងរួចរាល់ បានចំនួន ៩ មុខវិជ្ជា។ សិស្សត្រូវចុះកម្មសិក្សារយៈពេល ១ឆ្នាំ បន្តទៀត បន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាលវគ្គសិក្ខាគារិកភាព នៅបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា។

៣.២.៤. សាលាភូមិន្ទសារការី

ក. សិស្សសារការី ជំនាន់ទី៣

សិស្សសារការី ជំនាន់ទី៣ ចំនួន ១៩រូប (ស្រី ៩រូប) ត្រូវទទួលការបណ្តុះបណ្តាលរយៈពេល ២ឆ្នាំ និង ៦ខែ នៅបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ដោយចាប់ផ្តើមពីខែឧសភា ឆ្នាំ២០២២។ សិស្សសារការី ជំនាន់ទី៣ បាននិងកំពុងចុះកម្មសិក្សានៅតាមអង្គភាព និងស្ថាប័នដែលពាក់ព័ន្ធតាមដំណាក់កាលនានា ដូចមានគ្រោងទុកក្នុងកម្មវិធីសិក្សា សម្រាប់រយៈពេល ១ឆ្នាំ និង ៦ខែ។ សិស្សសារការី ជំនាន់ទី៣ ត្រូវបញ្ចប់វគ្គកម្មសិក្សានៅតាមមន្ទីរសារការីនានាក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជាកម្មសិក្សាដំណាក់កាលចុងក្រោយ នៅក្នុងសប្តាហ៍ទី២ ខែមករា ឆ្នាំ២០២៥។ បន្ទាប់ពីបានបញ្ចប់វគ្គកម្មសិក្សាទាំង ៨ ដំណាក់កាល សិស្សត្រូវការពាររបាយការណ៍កម្មសិក្សា និងប្រឡងបញ្ចប់ការសិក្សានាពេលឆាប់ៗ ខាងមុខនេះ។

ខ. សិស្សសារការីជំនាន់ទី៤

សិស្សសារការី ជំនាន់ទី៤ ចំនួន ៥០រូប (ស្រី ២៧រូប) បានចាប់ផ្តើមទទួលការបណ្តុះបណ្តាលវគ្គសិក្ខាគារិភាព នៅបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ចាប់ពីខែសីហា ឆ្នាំ២០២៤ មក ដែលមានរយៈពេល ១ ឆ្នាំ មុននឹងបន្តចុះកម្មសិក្សារយៈពេល ១ឆ្នាំ និង ៦ខែទៀត សម្រាប់ ៨ ដំណាក់កាល នៅតាមអង្គភាពពាក់ព័ន្ធនានាក្នុងព្រះរាជាណាចក្រកម្ពុជា។

៣.២.៥. សាលាច្បាប់

សាលាច្បាប់ត្រូវបានបង្កើតថ្មី និងបញ្ចូលក្នុងរចនាសម្ព័ន្ធ នៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា នៅក្នុងឆ្នាំ២០២៣។ មកដល់ពេលបច្ចុប្បន្ននេះ សាលាច្បាប់បានដំណើរការការងារមួយចំនួនស្របតាមបេសកកម្មតួនាទី និងភារកិច្ចរបស់ខ្លួន ក្នុងនោះ នៅក្នុងឆ្នាំ២០២៤ នេះ សាលាច្បាប់បានបើកវគ្គរៀនត្រៀមសម្រាប់ការប្រឡងប្រជែងជ្រើសរើសសិស្សចៅក្រម សិស្សព្រះរាជអាជ្ញា សិស្សសារការី សិស្សអាជ្ញាសាលា និងសិស្ស

ក្រឡាបញ្ជី ដែលគ្រោងនឹងបញ្ចប់នៅក្នុងដើមឆ្នាំ២០២៥ នេះ។ សាលាច្បាប់ ក៏បានផ្តល់ការបណ្តុះបណ្តាលដំបូងដល់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទជំនាន់ទី១ នៃអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ចំនួន ៨៩រូប (ស្រី ១៨រូប)។ ជាមួយគ្នានេះដែរ សាលាច្បាប់បានរៀបចំវគ្គបណ្តុះបណ្តាលដំបូងដល់មន្ត្រីរដ្ឋបាលតុលាការ ចំនួន ២វគ្គ រួចមកហើយ នៅក្នុងអំឡុងខែសីហា ដល់ខែតុលា ឆ្នាំ២០២៤ ដែលក្នុង ១វគ្គៗ មានរយៈពេល ១ខែ។ វគ្គទី១ មានមន្ត្រីរដ្ឋបាលតុលាការទទួលការបណ្តុះបណ្តាល ចំនួន ៤៩រូប (ស្រី ២៤រូប) និងវគ្គទី២ មានមន្ត្រីរដ្ឋបាលតុលាការទទួលការបណ្តុះបណ្តាល ចំនួន ៤៩រូប (ស្រី ២៧រូប)។ សមាសភាពមន្ត្រីរដ្ឋបាលតុលាការដែលបានមកទទួលការបណ្តុះបណ្តាលនេះ ត្រូវបានអញ្ជើញមកពីតាមសាលាដម្រះក្តី រាជធានី ខេត្ត និងអង្គភាពចំណុះនានា នៃក្រសួងយុត្តិធម៌។

៣.៣. ការបណ្តុះបណ្តាលបន្ត, សុក្រឹត្យការ និងឥតិក្រឹតការ នៅក្នុងឆ្នាំ២០២៤

នៅក្នុងឆ្នាំ២០២៤ បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា បានរៀបចំកម្មវិធីបណ្តុះបណ្តាលបន្ត រួមមានសិក្ខាសាលា វគ្គបណ្តុះបណ្តាល បទបាឋកថា ជូនដល់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា សារការី និងអ្នកអនុវត្តច្បាប់ពាក់ព័ន្ធជាបន្តបន្ទាប់។ ការបណ្តុះបណ្តាលបន្តទាំងនេះ គឺក្នុងគោលបំណងពង្រឹងសមត្ថភាពបន្ថែម និងចែករំលែកចំណេះដឹងថ្មីៗ ដល់សិក្ខាកាម ដើម្បីជានាដល់ការអនុវត្តច្បាប់ប្រកប ដោយតម្លាភាព និងប្រសិទ្ធភាពខ្ពស់។ ជាមួយគ្នានេះដែរ ដើម្បីពង្រឹងគុណភាពនៃការបណ្តុះបណ្តាល និងរក្សាបាននូវប្រសិទ្ធភាពការងារ សម្រាប់ពេលបច្ចុប្បន្ន និងពេលអនាគត បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា បានបន្តពង្រឹងការបណ្តុះ-បណ្តាលគ្រូបង្គោលផ្នែកព្រហ្មទណ្ឌ គ្រូបង្គោលផ្នែករដ្ឋប្បវេណី និងគ្រូបង្គោលពាក់ព័ន្ធនឹងជំនាញពិសេសផ្សេងៗ ទៀត រួមមានគ្រូបង្គោលពាណិជ្ជកម្ម និងគ្រូបង្គោលផ្នែកជួញដូរមនុស្សជាដើម ក្រោមកិច្ចខិតខំប្រឹងប្រែង និងការពង្រឹងកិច្ចសហប្រតិបត្តិការ ជាមួយស្ថាប័នជាតិ ស្ថាប័នអន្តរជាតិ និងដៃគូអភិវឌ្ឍនានា។ ឆ្លងតាមការបំពេញតួនាទី និងភារកិច្ច ក្នុងការអនុវត្តសកម្មភាពការងាររបស់ខ្លួន បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា សម្រេចបានលទ្ធផលជាផ្លែផ្កាស្របតាមកម្មវិធីបណ្តុះបណ្តាល និងផែនការសកម្មភាពដែលបានគ្រោងទុក។

៣.៤. កិច្ចសហប្រតិបត្តិការអន្តរជាតិ នៅក្នុងឆ្នាំ២០២៤

បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា បានបន្តកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយស្ថាប័ន និងអង្គការជាដៃគូអភិវឌ្ឍមួយចំនួន ក្នុងនោះរួមមាន៖

- កិច្ចសហការជាមួយធនាគារអភិវឌ្ឍអាស៊ី (ADB) ពាក់ព័ន្ធនឹងការបណ្តុះបណ្តាលគ្រូបង្គោលលើវិវាទច្បាប់ពាណិជ្ជកម្ម និងការបណ្តុះបណ្តាលគរុកោសល្យដល់គ្រូបង្គោល។ ជាមួយគ្នានេះដែរក៏មានការសហការរៀបចំសិក្ខាសាលាស្តីពី "ការរៀបចំកម្មវិធីសិក្សាច្បាប់បរិស្ថាន" និងវគ្គបណ្តុះ-បណ្តាលស្តីពី "ច្បាប់បរិស្ថាន និងធនធានធម្មជាតិកម្ពុជា ព្រមទាំងច្បាប់បរិស្ថានអន្តរជាតិ និង ASEAN"។ កិច្ចសហប្រតិបត្តិការរវាងបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជាជាមួយ ADB ក៏ត្រូវបានរៀបចំផងដែរពាក់ព័ន្ធនឹងវិវាទ និងដំណោះស្រាយក្នុងច្បាប់ពាណិជ្ជកម្ម។ ជាមួយគ្នានេះដែរ បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ក៏បានសហការជាមួយ ADB ដើម្បីរៀបចំវគ្គបណ្តុះបណ្តាល

ស្តីពី "ការរៀបចំសំណុំរឿងតុលាការពាក់ព័ន្ធផ្នែកបរិស្ថាន" ដល់សិក្ខាកាមជាចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធ។

- កិច្ចសហការជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) និងអង្គការ វីនរ៉ក់ (WIN ROCK) ដោយរៀបចំការបណ្តុះបណ្តាលដល់ចៅក្រម ព្រះរាជអាជ្ញា លើជំនាញ "ការដោះស្រាយរឿងក្តីជួញដូរមនុស្ស" និងលើជំនាញ "ការស៊ើបអង្កេតលើទិន្នន័យប្រភពបើកចំហ និងការវិភាគបទល្មើសជួញដូរមនុស្សតាមប្រព័ន្ធអនឡាញ (OSINT)"។
- កិច្ចសហប្រតិបត្តិការជាមួយ ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងបទឧក្រិដ្ឋ ប្រចាំតំបន់អាស៊ីអាគ្នេយ៍ និងប៉ាស៊ីហ្វិក (UNODC) ពាក់ព័ន្ធនឹងការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ និងការធ្វើបត្យាប័ន ដោយបានរៀបចំវគ្គបណ្តុះបណ្តាល មូលដ្ឋាន ដល់សិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញា ជំនាន់ទី១១ និងសិស្សចៅក្រមផ្នែកក្នុង ជំនាន់ទី២។
- កិច្ចសហប្រតិបត្តិការជាមួយនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ (ICD) នៃវិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាល (RIT) នៃក្រសួងយុត្តិធម៌ប្រទេសជប៉ុន ដោយរៀបចំសិក្ខាសាលាស្តីពី "វិធានបង្ខំដោយប្រយោល" ដល់ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធ។

កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នអន្តរជាតិ និងដៃគូអភិវឌ្ឍនានា គឺផ្តោតសំខាន់ទៅលើការធ្វើអន្តរជាតិនីយកម្មនៃកម្មវិធីបណ្តុះបណ្តាលទាំងបឋម និងបន្ត ការផ្លាស់ប្តូរបទពិសោធន៍ បច្ចេកទេស គរុកោសល្យ ក្នុងការងារបណ្តុះបណ្តាល ការងារដឹកនាំ គ្រប់គ្រង ការសិក្សាស្រាវជ្រាវរួមគ្នា ដើម្បីចូលរួមពង្រឹងគុណភាព និងធានាបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការបណ្តុះបណ្តាលបឋម និងបន្ត ក៏ដូចជាការអនុវត្តការងារជាក់ស្តែង។

៣.៥. ការងាររដ្ឋបាល និងបដិសណ្ឋារកិច្ច

ចំពោះដំណើរការការងាររដ្ឋបាលប្រចាំថ្ងៃ បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា បានផ្តល់ទីកន្លែងសមស្របសម្រាប់ការរៀបចំកិច្ចប្រជុំ សន្និបាត សិក្ខាសាលា វគ្គបណ្តុះបណ្តាល បទឧទ្ទេសនាម បទបាឋកថា និងពិធីផ្លូវការផ្សេងៗ ជូនដល់អង្គភាពចំណុះក្រសួងយុត្តិធម៌ និងអង្គភាពពាក់ព័ន្ធដទៃទៀតដែលមានតម្រូវការខ្ចីបន្ទប់ ឬសាលប្រជុំ នៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា សម្រាប់រៀបចំកម្មវិធីនានាដូចខាងលើនេះ ក្រោមការចង្អុលបង្ហាញ និងការផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានក្រុមប្រឹក្សាភិបាល នៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា**។

៤. ក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌

៤.១. ការងាររដ្ឋបាល និងបុគ្គលិក

៤.១.១. ការងាររដ្ឋបាល

- បានទទួលលិខិតចូល ចំនួន ២១
- បានផ្ញើចេញលិខិត ចំនួន ៨៧

៤.១.២. អំពីស្ថិតិមន្ត្រី

ក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ បានធ្វើបានកែសម្រួល និងតែងតាំងសមាសភាពថ្មីតាមព្រះរាជក្រឹត្យ លេខ នស/រកត/១០២៣/២២២៣ ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣ ដែលមានសមាជិកចំនួន ៣៤រូប។ យោងតាមព្រះរាជក្រឹត្យលេខ នស/រកត/០៣២៤/២៩៦ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៤ បាន តែងតាំងសមាភាពអនុប្រធាន និងសមាជិកបន្ថែមក្នុងក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម ចំនួន ៧រូប។ បច្ចុប្បន្ន, ប្រធាន ក.ន.យ. ដឹកនាំដោយ **ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** និងមានអនុប្រធានទី១ មួយរូប អនុប្រធានប្រចាំការ មួយរូប និងសមាជិក សរុប ចំនួន ៤១រូប។ ដោយឡែក លេខាធិការដ្ឋាននៃក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ មានមន្ត្រីបម្រើការងារសរុប ៧រូប។

៤.១.៣. អំពីរចនាសម្ព័ន្ធអង្គភាពចំណុះឱ្យលេខាធិការដ្ឋាន

- ការិយាល័យកិច្ចការទូទៅ
- ការិយាល័យកិច្ចការច្បាប់
- ការិយាល័យកិច្ចការយុត្តិធម៌
- ការិយាល័យកិច្ចការស្រាវជ្រាវ និងវិភាគ។

៤.២. អំពីផែនការសកម្មភាពការងារប្រចាំឆ្នាំ

៤.២.១. អំពីផែនការសកម្មភាព

ក. អំពីផែនការសកម្មភាព

ក្នុងឆ្នាំ២០២៤ ក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ មានសកម្មភាពអនុវត្ត ដូចខាងក្រោម៖

- កិច្ចប្រជុំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ សម្រាប់រយៈពេលខ្លី និង រំង
- កិច្ចប្រជុំក្រុមការងារពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងស្តីពីការតាក់តែងទោសប្បញ្ញត្តិ
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីគោលការណ៍ណែនាំការតាក់តែងទោសប្បញ្ញត្តិ
- ចុះសិក្សាស្រាវជ្រាវការងារនីតិកម្ម និងយុត្តិធម៌នៅតាមសាលាជម្រះក្តីនានា (ខេត្តព្រះសីហនុ ខេត្តកែប ខេត្តកំពង់ចាម ខេត្តកំពង់ធំ និង ខេត្តត្បូងឃ្មុំ)។

៤.២.២. អំពីការងារហិរញ្ញវត្ថុ

ក្រោយពីទទួលបានការផ្ទេរសិទ្ធិក្នុងនាមជាអង្គភាពហិរញ្ញវត្ថុ លេខាធិការដ្ឋាននៃក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ បានចាត់បញ្ជូនមន្ត្រីដែលទទួលបានការតែងតាំងក្នុងនាមជាមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ និងរដ្ឋទេយ្យការបុរេប្រទានដែលជួយលើការងារហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ ចំនួន ៣រូប ឱ្យទៅចូលរួមវគ្គបណ្តុះបណ្តាលនៅវិទ្យាស្ថានហិរញ្ញវត្ថុ។

៤.២.៣. អំពីការងារចំពោះកិច្ច

តាមរយៈសេចក្តីសម្រេចលេខ ៦៩ កយ. សសរ/២៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣ ក្រុមការងារដើម្បីរៀបចំផែនការយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ រយៈពេលខ្លី និង វែង ត្រូវបានបង្កើតឡើង ដែលមាន **ឯកឧត្តម ជីវ សុខហាក់** ជាប្រធានក្រុមការងារ។ ក្នុងនោះ បានរៀបចំបែងចែកការងារចំនួន ២ ក្រុមតូចបន្ថែមទៀត ដោយក្រុមទីមួយ ប្រគល់ជូន **ឯកឧត្តម សួន វិសាល** រៀបចំ និងដឹកនាំរៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការហិរញ្ញវត្ថុ និងក្រុមទីពីរ ប្រគល់ជូន **ឯកឧត្តម តាន់ហ៊ាង ជាវ័ណ្ណ** ដឹកនាំជួយ ល.ក.ន.យ. លើការងាររដ្ឋបាល ការងារជួយតម្រង់ទិសការអនុវត្តផែនការថវិកាប្រចាំឆ្នាំ២០២៤។ ចំពោះវឌ្ឍនភាពនៃការរៀបចំសេចក្តីផែនការយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ រយៈពេលខ្លី និង វែង កំពុងពិនិត្យដើម្បីសិក្សាឱ្យបានគ្រប់ជ្រុងជ្រោយ មុនដាក់ជូនក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ ពិនិត្យ និងផ្តល់យោបល់បន្ថែម។

ដោយឡែក **ឯកឧត្តម ជីវ សុងហាក់** អនុប្រធានទី១ បានដឹកនាំក្រុមការងាររបស់ដែលមានសមាជិកចូលរួមក្នុងការរៀបចំជាសេចក្តីព្រាងស្តីពីការតាក់តែងទោសប្បញ្ញត្តិ ដើម្បីឱ្យការពិនិត្យទោសប្បញ្ញត្តិមានសង្គតិភាព និងប្រសិទ្ធភាពក្នុងការតាក់តែងទោសប្បញ្ញត្តិ។

៥. អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (អ.ដ.ក.)

អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (អ.ដ.ក.) ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ លេខ នស/រកត/១១២៣/២៣៨១ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣, អ.ដ.ក. ដែលមានអគ្គលេខាធិការដ្ឋាន នៃ អ.ដ.ក. ជាសេនាធិការ បានបំពេញភារកិច្ចខ្លួនដោយសកម្ម និងសម្រេចបាននូវជោគជ័យជាបន្តបន្ទាប់ ទាំងលើការរៀបចំកិច្ចដំណើរការស្ថាប័ន រួមមាន ការរៀបចំធនធានមនុស្ស ការកសាងលិខិតបទដ្ឋានគតិយុត្ត ចាំបាច់នានា ការបណ្តុះបណ្តាល និងការផ្តល់នីតិសម្បទាដល់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ទាំងលើការដោះស្រាយវិវាទជូនប្រជាពលរដ្ឋ។ នៅក្នុងឆ្នាំ២០២៤ នេះ អ.ដ.ក. បានប្រមូលផ្តុំលើការអនុវត្តការងារស្នូលចំនួន ៤ របស់ខ្លួន គឺ៖ (១)-ការដោះស្រាយសំណុំរឿងក្នុងក្របខណ្ឌ អ.ដ.ក. (២)-ការរៀបចំ និងអនុវត្តគម្រោងដោះស្រាយវិវាទជូនប្រជាពលរដ្ឋនៅតំបន់ជនជាតិដើមភាគតិច និងនៅតំបន់ដាច់ស្រយាល (៣)-ការបង្កើន និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នដៃគូ និង (៤)-ការងារផ្សព្វផ្សាយ និងសាធារណមតិ។

៥.១. ការជ្រើសរើស ការបណ្តុះបណ្តាល និងផ្តល់នីតិសម្បទាដល់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ

ផ្អែកតាមព្រះរាជក្រឹត្យរបស់ អ.ដ.ក. ការដោះស្រាយវិវាទនៅក្នុងក្របខណ្ឌ អ.ដ.ក. ត្រូវធ្វើឡើងដោយមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ អ.ដ.ក.។ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ គឺជាប្រតិបត្តិករផ្នែកក្នុងការដោះស្រាយវិវាទជូនប្រជាពលរដ្ឋ ដែលផ្អែកតាមច្បាប់ មុននឹងអាចបំពេញមុខងាររបស់ខ្លួន, មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ត្រូវធ្វើការជ្រើសរើស បណ្តុះបណ្តាល និងទទួលបាននីតិសម្បទាពី អ.ដ.ក.។ក្នុងន័យនេះ ដោយទទួលបានគោលការណ៍អនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីសម្តេចប្រមុខរាជរដ្ឋាភិបាល, សម្រាប់

ឆ្នាំ២០២៤ នេះ អ.ជ.ក. បានធ្វើការជ្រើសរើស និងបណ្តុះបណ្តាលមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ចំនួន ២ លើក ដោយក្នុងនោះ៖

- លើកទី១ ៖ នាដើមត្រីមាសទី១ ឆ្នាំ២០២៤ អ.ជ.ក. បានជ្រើសរើសបានមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទបម្រើការងាររពេញម៉ោង ចំនួន ២៨ រូប ពីក្នុងចំណោមបេក្ខជនដែលសុទ្ធសឹងជាអ្នកប្រកបវិជ្ជាជីវៈច្បាប់ និងអ្នកដែលមានបទពិសោធន៍ពាក់ព័ន្ធនឹងការងារដោះស្រាយវិវាទ។ ទន្ទឹមនេះ អ.ជ.ក. ក៏បានធ្វើការជ្រើសរើសបន្ថែមនូវមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទស្ម័គ្រចិត្ត ចំនួន ៥៨ រូប ដែលមន្ត្រីស្ម័គ្រចិត្តទាំងនេះ មិនធ្វើការពេញម៉ោងនៅ អ.ជ.ក. និងមិនទទួលប្រាក់ឧបត្ថម្ភពីរដ្ឋនោះទេ តែគាត់ជួយដោះស្រាយវិវាទទៅតាមករណី និងតាមការចាត់តាំងពី អ.ជ.ក.។
- លើកទី២ ៖ នាខែធ្នូ អ.ជ.ក. បានជ្រើសរើសបន្ថែមនូវមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទបម្រើការងាររពេញម៉ោង ចំនួន ៣២ រូប ដែលបច្ចុប្បន្ន មន្ត្រីទាំង ៣២ រូបនេះ កំពុងស្ថិតក្នុងដំណាក់កាលរង់ចាំទទួលការបណ្តុះបណ្តាលរយៈពេល ៣ ខែ ដោយបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា។

៥.២. អំពីការដោះស្រាយវិវាទនៅក្នុងក្របខណ្ឌនៃ អ.ជ.ក.

អ.ជ.ក. បានចាប់ផ្តើមទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ ដើម្បីធ្វើការពិនិត្យ និងដោះស្រាយ ចាប់តាំងពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២៤ កន្លងមក។ បើគិតចាប់តាំងពីថ្ងៃចាប់ផ្តើមទទួលពាក្យបណ្តឹង រហូតមកដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ កន្លងទៅនេះ, អ.ជ.ក. បានទទួលពាក្យបណ្តឹងសរុបចំនួន ៤៦៦ ករណីពីប្រជាពលរដ្ឋនៅតាមបណ្តារាជធានី ខេត្តទូទាំងប្រទេស ដែលក្នុងនោះ បណ្តឹងភាគច្រើន គឺទទួលបានពីប្រជាពលរដ្ឋរស់នៅរាជធានីភ្នំពេញ។

ក្នុងចំណោមពាក្យបណ្តឹងទាំងអស់ខាងលើ ពិនិត្យឃើញថា វិវាទដែល អ.ជ.ក. ទទួលបានច្រើនជាងគេ គឺវិវាទកិច្ចសន្យាខ្ចីប្រាក់ ចំនួន ៣៧%, វិវាទដីធ្លី ចំនួន ៣១%, វិវាទពាក់ព័ន្ធនឹងអចលនវត្ថុ (ដូចជា ការទិញលក់ ការជួល) ចំនួន ១១% និងវិវាទកិច្ចសន្យាផ្សេងៗ ចំនួន ៨%។ ដោយឡែក វិវាទដែលបានដាក់ចូលមក អ.ជ.ក. តិចជាងគេ គឺវិវាទពាណិជ្ជកម្ម, វិវាទមត៌ក និងវិវាទគ្រួសារ។

ពាក់ព័ន្ធនឹងចំណាត់ការសំណុំរឿងដែល អ.ជ.ក. បានទទួល, បើគិតចាប់ពីថ្ងៃទី១ ខែកក្កដា ដែលជាថ្ងៃចាប់ផ្តើមដំណើរការការដោះស្រាយវិវាទ រហូតមកដល់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ នេះ អ.ជ.ក. បានចាត់ការសំណុំរឿងបានចំនួន ១៥១ ក្នុងចំណោមសំណុំរឿងសរុប ៤៦៦ ករណីដោយក្នុងនោះ៖

- ៨២ សំណុំរឿង ៖ បានដោះស្រាយបញ្ចប់ដោយជោគជ័យ
- ៤០ សំណុំរឿង ៖ បានបិទសំណុំរឿងដោយសារ ភាគីវិវាទបដិសេធមិនចូលមកសម្រុះ-សម្រួល ដកពាក្យបណ្តឹង ឬការសម្រុះសម្រួលមិនទទួលបានលទ្ធផល
- ២៩ សំណុំរឿង ៖ បានលើកចោល ដោយសារមិនស្ថិតក្នុងសមត្ថកិច្ចរបស់ អ.ជ.ក.
- ៣១៥ សំណុំរឿង ៖ កំពុងស្ថិតក្នុងចំណាត់ការក្នុងក្របខណ្ឌ អ.ជ.ក.។

៥.៣. អំពីការរៀបចំ និងអនុវត្តគម្រោងចុះដោះស្រាយវិវាទ និងសិក្ខាសាលាផ្សព្វផ្សាយរបស់ អ.ជ.ក. នៅថ្នាក់មូលដ្ឋាន

៥.៣.១. ការរៀបចំ និងការអនុវត្តគម្រោងចុះដោះស្រាយវិវាទជូនប្រជាពលរដ្ឋនៅតំបន់ជនជាតិដើមភាគតិចរស់នៅតំបន់ភូមិភាគឦសាន្ត និងតំបន់ជាច់ស្រយាល

ដោយទទួលបានគោលការណ៍អនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមឧបនាយករដ្ឋមន្ត្រី, នៅក្នុងខែសីហា រហូតដល់ខែតុលា ឆ្នាំ២០២៤ លោកជំទាវ ជា វាសនា សមាជិកនៃ អ.ជ.ក. បានដឹកនាំសហការីចុះធ្វើការស្រាវជ្រាវបឋមនៅតាមបណ្តាក្រុង ស្រុកគោលដៅដែលស្ថិតក្នុងខេត្តចំនួន ៤ គឺ ខេត្តរតនគិរី, ខេត្តមណ្ឌលគិរី, ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ ដើម្បីជាមូលដ្ឋាននៃការសិក្សា និងរៀបចំគម្រោងចុះដោះស្រាយវិវាទជូនប្រជាពលរដ្ឋនៅតំបន់ជនជាតិដើមភាគតិច និងតំបន់ជាច់ស្រយាល។ ផ្អែកលើលទ្ធផលនៃការស្រាវជ្រាវបឋមនេះ, នៅក្នុងកិច្ចប្រជុំលើកទី៧ របស់ អ.ជ.ក. នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤, អ.ជ.ក. បានផ្តល់ការគាំទ្រលើការរៀបចំ និងការអនុវត្តនូវគម្រោងចុះដោះស្រាយវិវាទជូនប្រជាពលរដ្ឋនៅតំបន់ជនជាតិដើមភាគតិច និងនៅតំបន់ជាច់ស្រយាល និងបានសម្រេចបង្កើតក្រុមការងារមួយទទួលបន្ទុករៀបចំ និងអនុវត្តគម្រោងចុះដោះស្រាយវិវាទជូនប្រជាពលរដ្ឋនៅតំបន់ជនជាតិដើមភាគតិច និងនៅតំបន់ជាច់ស្រយាល។ ក្រុមការងារនេះ ដឹកនាំដោយ ឯកឧត្តមបណ្ឌិត ជិន ម៉ាលីន អនុប្រធានប្រចាំការនៃ អ.ជ.ក. បាននឹងកំពុងជំរុញការងាររៀបចំគម្រោងនេះ ដើម្បីអាចប្រកាសអនុវត្តចាប់ពីដើមឆ្នាំ២០២៥ នេះ។

៥.៣.២. ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលនៅថ្នាក់មូលដ្ឋាន

ដោយទទួលបានគោលការណ៍អនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី និងជាប្រធាន អ.ជ.ក.** ជាមួយនឹងការគាំទ្រ និងផ្តល់កិច្ចសហការពីក្រសួងមហាផ្ទៃ តាមរយៈលិខិតលេខ ២៣២១ សជណ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៤, ក្រុមការងារមួយក្រោមការដឹកនាំរបស់ឯកឧត្តមបណ្ឌិត ជិន ម៉ាលីន អនុប្រធានប្រចាំការនៃ អ.ជ.ក. បានចុះទៅតាមបណ្តាខេត្តគោលដៅមួយចំនួន ដើម្បីអនុវត្តសកម្មភាពសំខាន់ចំនួន ២ គឺ (ទី១)-ការផ្សព្វផ្សាយបញ្ជាបការយល់ដឹងអំពីបេសកកម្មរបស់ អ.ជ.ក. និងរបៀបនៃការដោះស្រាយបញ្ចប់ជាស្តាពរនូវវិវាទ តាមរយៈយន្តការ អ.ជ.ក. ដែលកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទធ្វើឡើងដោយ អ.ជ.ក. មានអានុភាពអនុវត្តដូចសាលក្រមស្តាពររបស់តុលាការ និង(ទី២)- រៀបចំវគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសនៃការសម្រុះសម្រួលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ បើគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ នេះ អ.ជ.ក. បានចុះធ្វើសិក្ខាសាលាផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលជំនាញដោះស្រាយវិវាទ នៅតាមបណ្តារាជធានី ខេត្ត គោលដៅចំនួន ១១ រួមមាន៖ ខេត្តបាត់ដំបង, ខេត្តកណ្តាល, ខេត្តបន្ទាយមានជ័យ, ខេត្តព្រៃវែង, ខេត្តកំពង់ស្ពឺ, ខេត្តត្បូងឃ្មុំ, ខេត្តកំពង់ឆ្នាំង, ខេត្តកំពត, ខេត្តកំពង់ធំ, រាជធានីភ្នំពេញ និងខេត្តសៀមរាប និងដោយមានសិក្ខាកាមចូលរួមសរុបប្រមាណ ៣,២០០រូប។

៥.៤. អំពីកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នដៃគូ

នៅក្នុងឆ្នាំ២០២៤ នេះ អ.ដ.ក. បានបន្តធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាដៃគូ ទាំងដៃគូជាតិ ទាំងដៃគូអន្តរជាតិ ដើម្បីពង្រឹង និងពង្រីកយន្តការនៃការដោះស្រាយវិវាទឱ្យកាន់តែមានភាពងាយស្រួល និងសម្បូរបែបជូនដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការនេះ អ.ដ.ក. បានចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការដោះស្រាយវិវាទ (MOU) ជាមួយស្ថាប័នពាក់ព័ន្ធចំនួន ៦ គឺ (ទី១)-គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, (ទី២)-មជ្ឈមណ្ឌលជាតិមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, (ទី៣)-អង្គការនារីដើម្បីសន្តិភាព, (ទី៤)-រដ្ឋបាលខេត្តកណ្តាល, (ទី៥)-រដ្ឋបាលខេត្តបាត់ដំបង និង(ទី៦)-រដ្ឋបាលខេត្តកំពង់ឆ្នាំង ហើយចំពោះស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ដទៃទៀត ដែលក្រុមការងារបច្ចេកទេសនៃ អ.ដ.ក. បានពិភាក្សារួចហើយអំពីលទ្ធភាពនៃការចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការដោះស្រាយវិវាទ (MOU) នេះ ក៏គ្រោងនឹងចុះ MOU នេះ ជាបន្តបន្ទាប់នៅឆ្នាំ២០២៥។

ដូចគ្នាដែរ អ.ដ.ក. ក៏បានពិភាក្សាលើកិច្ចសហប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិល និងស្ថាប័នដៃគូអន្តរជាតិ រួមមាន៖ (ទី១)-អង្គការអ៊ុកស្វាមប្រចាំនៅកម្ពុជា, (ទី២)-ទីភ្នាក់ការសហប្រតិបត្តិការ JICA និង(ទី៣)-ក្រសួងយុត្តិធម៌នៃសាធារណរដ្ឋកូរ៉េ។ ផ្អែកលើកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័នដៃគូ, អ.ដ.ក. ទទួលបានការគាំទ្រ ជំនួយបច្ចេកទេស និងជំនួយជាថវិកាដូចខាងក្រោម៖

- ភាគីកូរ៉េបានអញ្ជើញថ្នាក់ដឹកនាំ អ.ដ.ក. និងមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ សរុបចំនួន ២០រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលជំនាញដោះស្រាយវិវាទនៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ កាលពីខែកញ្ញា ឆ្នាំ២០២៤។
- តាមរយៈឯកឧត្តម ប៉ូច សោភ័ណ សមាជិកនៃ អ.ដ.ក. អង្គការនារីដើម្បីសន្តិភាពបានគាំទ្រលើការរៀបចំវគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសនៃការសម្រុះសម្រួលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិនៅខេត្តត្បូងឃ្មុំ ខេត្តកំពង់ឆ្នាំង និងខេត្តកំពត ដែលគិតជាទឹកប្រាក់ចំនួន ប្រមាណជិត ៨,០០០ (ប្រាំបីពាន់) ដុល្លារអាមេរិក។
- តាមរយៈឯកឧត្តម ប៉ូច សោភ័ណ សមាជិកនៃ អ.ដ.ក. អង្គការអ៊ុកស្វាមប្រចាំនៅកម្ពុជា បានជួយគាំទ្រលើការរៀបចំសិក្ខាសាលា និងការបណ្តុះបណ្តាលអំពីបច្ចេកទេសនៃការសម្រុះសម្រួលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅរាជធានីភ្នំពេញ, ខេត្តកំពង់ធំ និងខេត្តសៀមរាប ដែលគិតជាទឹកប្រាក់ចំនួនសរុបប្រមាណជិត ២០,០០០ (ម្ភៃពាន់) ដុល្លារអាម៉េរិក។

៥.៥. អំពីការងារផ្សព្វផ្សាយ និងសាធារណមតិ

សម្រាប់ឆ្នាំ២០២៤ ការងារផ្សព្វផ្សាយ និងសាធារណមតិ គឺជាការងារអាទិភាពមួយ ដែល អ.ដ.ក. បានបន្តយកចិត្តទុកដាក់ក្នុងការអនុវត្ត ដើម្បីធានាថា ប្រជាពលរដ្ឋ និងសាធារណជនអាចទទួលបាននូវ

ព័ត៌មានច្បាស់លាស់ និងត្រឹមត្រូវអំពីបេសកកម្មរបស់ អ.ដ.ក. សកម្មភាពនៃការដោះស្រាយវិវាទជូនប្រជាពលរដ្ឋ ក្នុងក្របខណ្ឌនៃ អ.ដ.ក. ពិសេស អំពីទិសដៅការងារកែទម្រង់របស់រាជរដ្ឋាភិបាល។

ជាក់ស្តែង លើការងារផ្សព្វផ្សាយ និងសាធារណមតិនេះ អ.ដ.ក. បានធ្វើការផ្សព្វផ្សាយ និងទទួលបានលទ្ធផលដូចខាងក្រោម៖

- គេហទំព័រផ្លូវការរបស់ អ.ដ.ក. (មានអ្នកចូលទស្សនាចំនួន ២៧,៩១០ រូប) និង ហ្វេសប៊ុកផេក (មាន follower ចំនួន ១៧ ៩៨៥រូប និងមានអ្នកទស្សនាជាមធ្យមចំនួន ៧,០០០រូប)
- ឆានែលតេឡេក្រាមផ្ទាល់របស់ អ.ដ.ក. ដែលមានអ្នកចូល Subscribe ចំនួនប្រមាណជា ៧,៥០០រូប និងមានអ្នកទស្សនាជាមធ្យមចំនួន ៣,០០០រូប (៣K) សម្រាប់ការផ្សព្វផ្សាយព័ត៌មានក្នុងមួយលើកៗ
- បង្កើតវីដេអូឯកសារ វីដេអូបទយកការណ៍ និងវីដេអូខ្លីៗ សរុបចំនួន ១០៣ ដើម្បីផ្សព្វផ្សាយអំពីយន្តការដោះស្រាយវិវាទរបស់ អ.ដ.ក. និងបានផ្សព្វផ្សាយនៅគ្រប់ករណីសំណុំរឿងវិវាទដែលបានដោះស្រាយដោយជោគជ័យក្នុងក្របខណ្ឌនៃ អ.ដ.ក.
- ធ្វើការផ្សព្វផ្សាយអំពីសកម្មភាព និងលទ្ធផលការងារ អ.ដ.ក. តាមបណ្តាញស្ថានីយ៍ទូរទស្សន៍ រួមមាន៖ ស្ថានីយ៍ទូរទស្សន៍ជាតិ ទ.ទ.ក., ស្ថានីយ៍ CTN/CNC, ស្ថានីយ៍បាយ័ន, ស្ថានីយ៍ហង្សមាស ស្ថានីយអប្សរា ចំនួន ៤០ ដង
- ធ្វើការផ្សព្វផ្សាយនូវរាល់សកម្មភាព និងលទ្ធផលការងារ អ.ដ.ក. នៅតាមបណ្តាញសារព័ត៌មាន Online ដូចជា Freshnews, EAC News, CEN, S.A TVHD, i24 News Channel និងបណ្តាញសារព័ត៌មានមួយចំនួនទៀត។

ទន្ទឹមនឹងនេះ អ.ដ.ក. បានរៀបចំបោះពុម្ពផ្សាយនូវសៀវភៅកម្រងឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗពាក់ព័ន្ធនឹងអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ព្រមទាំង POSTER សម្រាប់ផ្សព្វផ្សាយអំពី អ.ដ.ក. ចំនួន ៣,០០០ ច្បាប់ ដើម្បីផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយថែមទៀត។

ជំពូកទី៣
បញ្ហាប្រឈម

១. បញ្ហាប្រឈមរបស់ក្រសួងយុត្តិធម៌ និង អង្គភាពពាក់ព័ន្ធ

១.១. ធនធានមនុស្ស

បញ្ហាធនធានមនុស្សនៅតែជាបញ្ហាប្រឈមសម្រាប់វិស័យយុត្តិធម៌ នាពេលកន្លងមក ក៏ដូចជានៅក្នុងឆ្នាំ២០២៤ នេះ។ បញ្ហាប្រឈម ដែលក្រសួងយុត្តិធម៌ និងសាលាដម្រះក្តីបាន និងកំពុងជួបប្រទះ រួមមាន៖

- បរិមាណ និងគុណភាពមន្ត្រីពុំទាន់អាចឆ្លើយតបនឹងតម្រូវការការងារ
- កង្វះគ្រូឧទ្ទេសនាមសម្រាប់វគ្គសិក្ខាសាលាផ្សព្វផ្សាយ និងបណ្តុះបណ្តាលក្នុងវិស័យព្រហ្មទណ្ឌ វិស័យរដ្ឋប្បវេណី និងការងាររដ្ឋបាលតុលាការ។

១.២. ហេដ្ឋារចនាសម្ព័ន្ធ

ហេដ្ឋារចនាសម្ព័ន្ធ ដើរតួយ៉ាងសំខាន់នៅក្នុងការគាំទ្រកិច្ចដំណើរការ និងការអភិវឌ្ឍវិស័យយុត្តិធម៌។ ដោយឡែកហេដ្ឋារចនាសម្ព័ន្ធសម្រាប់វិស័យយុត្តិធម៌ នៅពុំទាន់អាចឆ្លើយតបនឹងតម្រូវការជាក់ស្តែងនៅឡើយ។ បញ្ហាប្រឈមទាំងនោះ រួមមាន៖

- ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទិន្នន័យតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅពុំទាន់បានប្រើប្រាស់ទូលំទូលាយ
- ការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់កិច្ចការហិរញ្ញវត្ថុ នៅពុំទាន់មានភាពរលូន
- អគារសាលាជម្រះក្តីមួយចំនួនមានសភាពចាស់ទ្រុឌទ្រោម ទំហំ និងមុខងារប្រើប្រាស់ដែលមិនទាន់ឆ្លើយតបបានទៅនឹងតម្រូវការជាក់ស្តែង
- ចំនួនឃ្លាំងសម្រាប់រក្សាទុកវត្ថុតាងនៅពុំទាន់មានគ្រប់គ្រាន់
- ផ្ទះមុខងារសម្រាប់ចៅក្រម និងព្រះរាជអាជ្ញានៅពុំទាន់មាននៅឡើយ
- ការិយាល័យកិច្ចការអាជ្ញាសាលានៅអមលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានី ខេត្ត នៅពុំទាន់មាននៅឡើយ។

១.៣. កិច្ចការហិរញ្ញវត្ថុ

ហិរញ្ញវត្ថុដើរតួនាទីស្នូលក្នុងការគាំទ្រកិច្ចដំណើរ និងការអភិវឌ្ឍនៃវិស័យយុត្តិធម៌។ ប៉ុន្តែវិស័យយុត្តិធម៌នៅតែជួបប្រទះនូវបញ្ហាប្រឈមពាក់ព័ន្ធនឹងកិច្ចការហិរញ្ញវត្ថុ ដែលក្នុងនោះរួមមាន៖

- អង្គភាពថវិកាអាណាប័កផ្ទៀសិទ្ធិពេញលេញត្រូវការពេលវេលា ធនធានហិរញ្ញវត្ថុ និងធនធានមនុស្សបន្ថែមសម្រាប់អនុវត្តសកម្មភាពការងារឱ្យបានរលូន
- ការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់កិច្ចការហិរញ្ញវត្ថុ នៅពុំទាន់មានភាពរលូន
- នីតិវិធីចំណាយមួយចំនួននៅពុំទាន់អាចអនុវត្តបានដោយរលូន ជាពិសេស មុខសញ្ញាចំណាយប្រាក់, បេសកកម្មនៅក្រៅប្រទេស និងមុខសញ្ញាចំណាយដែលមានទំហំទឹកប្រាក់តិច ប៉ុន្តែ ត្រូវអនុវត្តនីតិវិធីលទ្ធកម្ម
- កង្វះសម្ភារៈការិយាល័យសម្រាប់គាំទ្រកិច្ចដំណើរការការងារប្រចាំថ្ងៃ។

១.៤. បញ្ហាប្រឈមក្នុងការអនុវត្តច្បាប់

១.៤.១. ការអនុវត្តច្បាប់ក្នុងវិស័យរដ្ឋប្បវេណី

- ប្រសិទ្ធភាព និងបញ្ហាប្រឈមនៃការអនុវត្តក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី
- ការចេញដីកាសម្រេចរក្សាការពារ
- ការលើកកម្ពស់ប្រសិទ្ធភាព និងជំនឿទុកចិត្តលើការលក់ដោយបង្ខំនូវអចលនវត្ថុ
- ការជូនដំណឹង និងការបញ្ជូនសេចក្តីសម្រេចរបស់តុលាការ
- ខ្វះការផ្សព្វផ្សាយ អំពីតួនាទី និងការកិច្ចរបស់មន្ត្រីអាជ្ញាសាលា និងសារៈសំខាន់នៃស្ថាប័ន

អនុវត្តទៅក្រសួង-មន្ទីរ កងកម្លាំងសមត្ថកិច្ចពាក់ព័ន្ធនានាដើម្បីចូលរួមសហការក្នុងការអនុវត្តសេចក្តីសម្រេច

- កង្វះលិខិតបទដ្ឋានគតិយុត្តិក្នុងការគ្រប់គ្រង អភិវឌ្ឍន៍ វិស័យអភិបាលបណ្តោះអាសន្ន និងអ្នកជម្រះបញ្ជី
- កង្វះលិខិតបទដ្ឋានគតិយុត្តក្នុងការគ្រប់គ្រង អភិវឌ្ឍន៍វិស័យសារការី។

១.៤.២.ការអនុវត្តច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ

- ប្រសិទ្ធភាព និងបញ្ហាប្រឈមនៃការអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ
- ការប្រើប្រាស់សិទ្ធិអំណាច និងឆន្ទានុសិទ្ធិរបស់តុលាការ
- ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ
- ពាក្យស្នើសុំពីខាងសាលាដំបូងរាជធានី ខេត្តមួយចំនួន និងពន្ធនាគារឯកសារមិនគ្រប់គ្រាន់
- ស្នើសុំកំណត់យកឃ:ពេលវេងទោសដែលនៅសល់យ៉ាងតិច ១ឆ្នាំ ដើម្បីសម្រួលនូវដំណើរការនីតិវិធីនៃការស្នើសុំដោះលែងដោយមានលក្ខខណ្ឌ
- សំណើសុំផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌របស់ស្ថាប័នមួយចំនួនឯកសារភ្ជាប់មិនគ្រប់គ្រាន់ និងមិនគ្រប់លក្ខខណ្ឌ។
- ពុំទាន់មានប្រព័ន្ធ Data Base ក្នុងការគ្រប់គ្រង់ស្ថិតិទណ្ឌិតដែលទទួលបានការអនុគ្រោះទោស
- ពុំដែលបានទទួលទិន្នន័យ អំពីការអនុវត្តទោស ឬបង្ខំដល់រូបរាងកាយ និងការដោះលែងដោយមានលក្ខខណ្ឌ
- ការបញ្ជូនឯកសារពីបណ្តាពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែមានភាពយឺតយ៉ាវ និងមួយចំនួនពុំត្រឹមត្រូវមិនមានមូលដ្ឋានសម្រាប់ដាក់ជូនគណៈកម្មការថ្នាក់ជាតិ ដើម្បីពិនិត្យ និងសម្រេចលើសំណើសុំបន្ធូរបន្ថយទោស និងលើកលែងទោស។

១.៤.៣. បញ្ហាប្រឈមរួមផ្សេងទៀត

- ពាក្យស្នើសុំអន្តរាគមន៍របស់ប្រជាពលរដ្ឋមួយចំនួន ពុំមានឯកសារភ្ជាប់មកគ្រប់គ្រាន់
- ការទទួលទិន្នន័យសាលក្រមស្តាពរ សាលដីកាស្តាពរ និងដីកាសម្រេច ពីសាលាដម្រះក្តីមានភាពយឺតយ៉ាវ
- ការផ្តល់ស្ថិតិវិាទរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ នៃរាជធានី ខេត្ត មិនទាន់មានកិច្ចសហការល្អជាមួយមន្ត្រីជំនាញពាក់ព័ន្ធនឹងការងារដោះស្រាយវិាទក្រៅប្រព័ន្ធតុលាការ
- ការឆ្លើយតបលើសំណើការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ និងវិស័យរដ្ឋប្បវេណី បត្យាប័ន និងផ្នែរទណ្ឌិតពីក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធមានភាពយឺតយ៉ាវ
- កង្វះខាតជំនាញបច្ចេកទេសនៃការសិក្សានិងការរៀបចំសំណើនៃការជួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ វិស័យរដ្ឋប្បវេណី បត្យាប័ន និងការផ្នែរទណ្ឌិត ដើម្បីអាចអនុវត្ត

ទាន់ពេលនូវទំហំការងារដែលកំពុងមាន

- មិនទាន់មានប្រព័ន្ធចងក្រង និងទិន្នន័យច្បាស់លាស់ក្នុងទទួល និងការផ្តល់របាយការណ៍ពាក់ព័ន្ធដំនួយផ្នែកច្បាប់
- ការប្រមូលព័ត៌មាន និងធាតុចូល ពីក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធការងារសិទ្ធមនុស្សមានភាពយឺតយ៉ាវ
- ការផ្សព្វផ្សាយអំពីកិច្ចការសារការីនៅមានកម្រិតនៅឡើយ
- ការបណ្តុះបណ្តាលជំនាញសន្ធានកម្មមិនទាន់បានគ្រប់ដល់គ្រប់រដ្ឋបាលរាជធានី ខេត្ត
- មិនទាន់ទទួលបានស្ថិតិវិវាទពីគ្រប់ការិយាល័យក្រុង ស្រុក ខណ្ឌ នៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- ទិន្នន័យសំណុំរឿង និងការបូកសរុបរបាយការណ៍ផ្សេងៗ
- ប្រជាពលរដ្ឋ និងមន្ត្រីមូលដ្ឋានមួយចំនួនពុំទាន់បានជ្រាបច្បាស់អំពីយន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ក៏ដូចជាស្គាល់អំពី អ.ដ.ក. ដែលជាស្ថាប័នទើបបង្កើតថ្មី
- បច្ចេកទេសនៃការរៀបចំកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ របស់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទហាក់នៅមានកម្រិត ដែលនាំឱ្យមានការព្រួយបារម្ភចំពោះការមិនអាចអនុវត្តបាន ឬអនុវត្តមិនបានជោគជ័យនូវកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទរបស់ អ.ដ.ក.
- មធ្យោបាយ ឬយន្តការនៃការទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ នៅមិនទាន់បានទូលំទូលាយនៅឡើយ ដោយបច្ចុប្បន្ន រាល់ការដាក់ពាក្យបណ្តឹង ត្រូវធ្វើនៅអគ្គលេខាធិការដ្ឋាននៃ អ.ដ.ក. ផ្ទាល់
- ស្ថាប័នដៃគូសហការរបស់ អ.ដ.ក. ពិសេសនៅថ្នាក់ក្រោមជាតិ ដើម្បីជួយដំរុញយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅមានចំនួនតិចនៅឡើយ
- កង្វះកិច្ចសហការល្អពីបុគ្គល និងស្ថាប័នពាក់ព័ន្ធមួយចំនួនលើការងារអធិការកិច្ច
- ប្រព័ន្ធទិន្នន័យក្នុងការចុះបញ្ជីតាមដាន និងត្រួតពិនិត្យសំណុំរឿងអធិការកិច្ច តាមប្រព័ន្ធកុំព្យូទ័រ (IT) នៅមានកម្រិត ដែលជាហេតុធ្វើឱ្យមានការលំបាកក្នុងការគ្រប់គ្រងទិន្នន័យសំណុំរឿង និងការបូកសរុបរបាយការណ៍ផ្សេងៗ។

២. បញ្ហាប្រឈមរបស់សាលាដម្រះក្តី

២.១. ធនធានមនុស្ស

- កង្វះអ្នកបកប្រែភាសាបរទេស ក្នុងរឿងក្តីព្រហ្មទណ្ឌ។
- ពិបាករកអ្នកវាយតម្លៃចលនវត្ថុដើម្បីមានមូលដ្ឋានសម្រេចកំណត់តម្លៃលក់ឡាយឡុង។

២.២. ហិរញ្ញវត្ថុ

- ខ្វះខាតប្រាក់ឧបត្ថម្ភសម្រាប់ចុះបេសកកម្ម

- កង្វះធនធានមនុស្ស ជាអាទិ៍ ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា អ្នកជំនាញព័ត៌មានវិទ្យា អ្នកជំនាញវាយតម្លៃអចលនវត្ថុក្នុងនីតិវិធីលក់ឡាយឡុង និងមន្ត្រីរដ្ឋបាល។

២.៣. សម្ភារៈ

- ខ្វះខាតសម្ភារៈ និងមធ្យោបាយសម្រាប់បម្រើការងារកិច្ចការតុលាការ ព្រមទាំងប្រព័ន្ធ Database
- មិនមានឯកសណ្ឋានសម្រាប់មន្ត្រីរដ្ឋបាលតុលាការ។

២.៤. ហេដ្ឋារចនាសម្ព័ន្ធ

- ខ្វះហេត្ថារចនាសម្ព័ន្ធ សម្រាប់បម្រើការងារ និងស្នាក់នៅ ជាអាទិ៍ អគារធ្វើការ អគារស្នាក់នៅ ឃ្លាំងសម្រាប់ទុកឯកសារ និងរក្សាវត្ថុតាង។

២.៥. បញ្ហាប្រឈមផ្សេងទៀត

- ការបញ្ជូនសាលក្រម និងសាលដីកា មានភាពយឺតយ៉ាវ និងកង្វះឯកសារភ្ជាប់
- ការសម្រេចពាក់ព័ន្ធនឹងការបែងចែកទ្រព្យសម្បត្តិដល់ភាគីនៅក្នុងរឿងក្តីរដ្ឋប្បវេណីដែលធ្វើឡើងដោយសារដំបូង មានអាចអនុវត្តបាននៅក្នុងកាលៈទេសៈមួយចំនួន
- ការសរសេរសំអាងហេតុ និងសេចក្តីសម្រេចបញ្ចប់នៅក្នុងសាលក្រម ឬដីកាសម្រេចក្នុងរឿងព្រហ្មទណ្ឌ នៅមានភាពមិនទាន់ច្បាស់លាស់សម្រាប់ករណីមួយចំនួន
- មិនបានកំណត់ភាគីនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ជាពិសេស អ្នកទទួលខុសត្រូវរដ្ឋប្បវេណី
- ការអនុវត្តមិនមានសង្គតិភាពគ្នារវាងសាលាជម្រះក្តី ចំពោះវិវាទដីធ្លីដែលមិនទាន់ចុះបញ្ជី
- ការបញ្ជូនដីកា និងឯកសារផ្សេងៗ តាមរយៈប្រៃសណីយ៍មានការយឺតយ៉ាវ ដែលធ្វើឱ្យប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធី
- ការអនុវត្តនីតិវិធីទារប្រាក់ពិន័យពីទណ្ឌិតមានការលំបាកដោយសារទណ្ឌិតជាជនក្រីក្រ
- ការបញ្ជាក់ស្ថាពរលើសាលក្រមព្រហ្មទណ្ឌមានភាពយឺតយ៉ាវ
- ការយល់ដឹងរបស់ប្រជាពលរដ្ឋដែលមកដាក់ពាក្យបណ្តឹងនៅមានកម្រិត
- ការជូនដំណឹងអំពីដីកាតម្កល់រឿងទុកឥតចាត់ការ ឬសាលក្រមកំបាំងមុខនៅក្នុងសំណុំរឿងមួយចំនួន មិនបានបញ្ជូនទៅដល់ភាគីដែលមានការពាក់ព័ន្ធ
- មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទមិនចូលរួមក្នុងនីតិវិធីសវនាការ និងលើកពេលជាច្រើនសារក្នុងគោលបំណងពន្យារពេល
- ពុំមានអ្នកចូលរួមក្នុងការដេញថ្លៃទិញថ្លៃទិញអចលនវត្ថុនៅក្នុងសំណុំរឿងអនុវត្តដោយបង្ខំ
- បច្ចេកទេសក្នុងការកសាងសំណុំរឿងរបស់មន្ត្រីនគរបាលយុត្តិធម៌ នៅមានកម្រិត
- ក្នុងករណីខ្លះ ដីកាចាត់ឱ្យស៊ើបសួរជំនួស មិនទទួលបានរបាយការណ៍នៃការអនុវត្តត្រឡប់មកវិញ

- ការធ្វើកោសលវិច័យ មានភាពយឺតយ៉ាវដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធី ឬការសម្រេចសេចក្តី
- ការកោះហៅ និងការបញ្ជូនឯកសារនីតិវិធី ដោយត្រូវធ្វើឡើងឆ្លងខេត្ត តែងជួបការលំបាក
- កង្វះមេធាវីសម្រាប់ការពារអនីតិជន ឬជនជាប់ចោទក្នុងករណីបទឧក្រិដ្ឋ
- កិច្ចសហការពីស្ថាប័ន ឬមន្ត្រីជំនាញ នៅមានកម្រិត
- ទម្រង់របាយការណ៍មានច្រើន និងមិនមានសង្គតិភាព ជាហេតុធ្វើឱ្យមន្ត្រីទទួលបន្ទុក ជួបការលំបាកក្នុងការបំពេញ និងផ្តល់លទ្ធផលត្រឡប់មកវិញ។

ជំពូកទី៤
ដំណោះស្រាយ

- កំណត់សកម្មភាពលើ "ការរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ ប្រព័ន្ធគ្រប់គ្រងឯកសារ និងប្រព័ន្ធគ្រប់គ្រងលំហូរឯកសារ" ជាអាទិភាព
- ពិនិត្យឡើងវិញអំពីតួនាទី និងការកិច្ចរបស់អគ្គលេខាធិការដ្ឋាន និងអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ លើការងារគ្រប់គ្រងធនធានមនុស្ស
- បុរេសកម្មក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការសកម្មភាពថវិកា
- រៀបចំផែនការអនុវត្ត (ផែនការសកម្មភាពការងារ និងផែនការសាច់ប្រាក់) ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ឱ្យបានច្បាស់លាស់ និងទាន់ពេលវេលា
- ក្រសួងយុត្តិធម៌គួរផ្តល់ការណែនាំដល់សាលាដម្រះក្តីឱ្យយកចិត្តទុកដាក់ និងពន្លឿនការចុះបញ្ជីសំណុំរឿងក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យសំណុំរឿងព្រហ្មទណ្ឌ
- សម្របសម្រួល និងពិភាក្សាជាមួយអគ្គលេខាធិការដ្ឋានក្រសួងយុត្តិធម៌ ដើម្បីរៀបចំបោះពុម្ពសៀវភៅចុះបញ្ជីសំណុំរឿង ក្របសំណុំរឿងព្រហ្មទណ្ឌ និងរដ្ឋប្បវេណីដល់សាលាដំបូងឱ្យបានទាន់ពេលវេលា
- ស្នើសុំបង្កើតអង្គភាពអាជ្ញាសាលាអមតាមសាលាដំបូងរាជធានី ខេត្ត
- ស្នើសុំបន្ថែមចំនួនចៅក្រម ព្រះរាជអាជ្ញា អាជ្ញាសាលា ក្រឡាបញ្ជី មន្ត្រីរដ្ឋបាល និងមន្ត្រីជាប់កិច្ចសន្យា
- ស្នើសុំផ្តល់ធនធានមនុស្សផ្នែកព័ត៌មានវិទ្យា សម្រាប់គាំទ្រដំណើរការសវនកម្ម និងប្រសិទ្ធភាពផ្នែកឌីជីថល ប្រព័ន្ធគាំទ្រតុលាការឌីជីថល និងប្រព័ន្ធគ្រប់គ្រងទិន្នន័យ
- ស្នើសុំជំរុញ និងពន្លឿនអាជ្ញាធរមានសមត្ថកិច្ច មន្ត្រីនគរបាលយុត្តិធម៌ និងមន្ត្រីទទួលបន្ទុកកិច្ចការស្រាវជ្រាវសាវតាធ្វើរបាយការណ៍ និងបញ្ជូនដីកា ក្នុងរឿងព្រហ្មទណ្ឌត្រឡប់មកចៅក្រមវិញឱ្យបានឆាប់រហ័ស ដើម្បីមានចំណាត់ការនីតិវិធីបន្ត

- ស្នើសុំចេញលិខិតណែនាំមួយចំនួនដល់ក្រឡាបញ្ជី ដើម្បីធានាប្រសិទ្ធភាពការងារឆាប់រហ័ស និងស្របតាមបរិបទសង្គមជាក់ស្តែង
- រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យសុំណុំរឿង វត្ថុតាង សំណើសុំផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ឧក្រិដ្ឋវិទ្យា និងអន្តរជាតិ (ជួញដូរមនុស្ស អនីតិជន និងនគរបាលយុត្តិធម៌)

ជំពូកទី៥
ទិសដៅការងារជារូបភាពឆ្នាំ២០២៥

១. ការអនុវត្តវិធានការគន្លឹះក្នុងវិស័យយុត្តិធម៌

ផ្អែកតាមលទ្ធផលកាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០២៥, **ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានគណៈបញ្ជាការដឹកនាំយុទ្ធនាការ** បានដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារក្នុងការអនុវត្តយុទ្ធនាការរយៈពេល ១ឆ្នាំ ដោយមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំនៃសាលាដម្រះក្តី និងអង្គការអយ្យការអមសាលាដម្រះក្តីទូទាំងប្រទេស។ ជាមួយនឹងលទ្ធផលជាវិជ្ជមាននេះ គណៈបញ្ជាការដឹកនាំយុទ្ធនាការបានដាក់ចេញនូវទិសដៅបន្តអនុវត្តយុទ្ធនាការទាំង២ និងសំណុំរឿងអាទិភាពទាំង ៤ សម្រាប់ឆ្នាំទី២ ដោយដកយកបទពិសោធន៍ពីការអនុវត្តយុទ្ធនាការ រយៈពេល១ឆ្នាំ កន្លងទៅនេះ ដើម្បីជំរុញឱ្យការអនុវត្តយុទ្ធនាការនៅឆ្នាំទី២ នេះ កាន់តែមានប្រសិទ្ធភាពខ្ពស់។ គណៈបញ្ជាការដឹកនាំយុទ្ធនាការរំពឹងថានឹងអាចដោះស្រាយការកកស្ទះសំណុំរឿងនៅតាមតុលាការបាននៅក្នុងរយៈពេល ១ឆ្នាំកន្លះទៀត ស្របទៅតាមទិសដៅ ដែលបានដាក់ចេញកាលពីពេលប្រកាសដាក់ចេញនូវយុទ្ធនាការ ចំណែកយុទ្ធនាការត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការនឹងត្រូវបន្តធ្វើពេញមួយអាណត្តិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។

២. ការរៀបចំផែនការធនធានមនុស្ស

ចំពោះការពិនិត្យឡើងវិញ ការវិភាគមុខងារ និងរចនាសម្ព័ន្ធរបស់ក្រសួងយុត្តិធម៌ ក្រុមការងារនឹងបន្តសហការតាមការណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងមុខងារសាធារណៈ ដោយឈរលើទស្សនៈ **"ពង្រឹង បង្រួម ពង្រាយ តែមិនពង្រីក និងភាពចាំបាច់"**។ ទន្ទឹមនេះ, ចំពោះការរៀបចំផែនការធនធានមនុស្សក្រសួងយុត្តិធម៌ រយៈពេល ៥ឆ្នាំ (២០២៤-២០២៨) បន្ទាប់ពីទទួលបានអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** ក្រុមការងារនឹងបន្តពិនិត្យ និងកែលម្អបន្ថែម តាមការណែនាំរបស់ថ្នាក់ដឹកនាំ និងបន្តរៀបចំផែនការធនធានមនុស្សឱ្យមានសង្គតិភាព គ្រប់ជ្រុងជ្រោយ គុណភាព និងប្រសិទ្ធភាពសម្រាប់ស្ថាប័នវិស័យយុត្តិធម៌ និងបន្តពិនិត្យលទ្ធភាពរៀបចំកិច្ចប្រជុំពិគ្រោះយោបល់តាមភាពចាំបាច់។

លើសពីនេះ, បន្ទាប់ពីការរៀបចំផែនការធនធានមនុស្សក្រសួងយុត្តិធម៌រយៈពេល ៥ឆ្នាំ ខាងលើរួចហើយ ក្រុមការងារនឹងបន្តសិក្សាស្រាវជ្រាវរៀបចំផែនការធនធានមនុស្សសម្រាប់វិជ្ជាជីវៈតុលាការ និងអង្គភាពរដ្ឋបាល តាមសាលាជម្រះក្តីផងដែរ។

៣. ការរៀបចំផែនការកែទម្រង់ហិរញ្ញវត្ថុ

ពាក់ព័ន្ធនឹងកិច្ចការកែទម្រង់ហិរញ្ញវត្ថុ, ទិសដៅការងារដាអាទិភាព រួមមាន៖

- ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការសកម្មភាពថវិកា
- ពង្រឹងការងារសវនកម្មស្របទៅតាមនីតិវិធី និងវិធីសាស្ត្រសវនកម្ម ទៅលើការគ្រប់គ្រងហិរញ្ញវត្ថុ ការប្រតិបត្តិការងារ និងភាពអនុលោមទៅតាមច្បាប់
- បន្តរៀបចំផែនការសកម្មភាពការងារ និងថវិកា សម្រាប់អនុវត្តស្របតាមផែនការដែលគ្រោងទុកក្នុងឆ្នាំ២០២៥។

៤. ការរៀបចំផែនការយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងកម្មវិធីអាទិភាព (២០២៥-២០៣៥)

បេសកកម្មចម្បងរបស់គណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ គឺការសម្រេចឱ្យបាននូវ **"ផែនការយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធយុត្តិធម៌"** សម្រាប់រយៈពេល ១០ឆ្នាំ (២០២៥-២០៣៥) និងផែនការសកម្មភាពដែលជាផែនទីបង្ហាញផ្លូវសម្រាប់តម្រង់ទិសក្នុងការកែទម្រង់ប្រព័ន្ធយុត្តិធម៌ គ្រោងនឹងដាក់ជូនគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ធ្វើការពិនិត្យ មុននឹងដាក់ជូនគណៈរដ្ឋមន្ត្រីដើម្បីធ្វើការអនុម័ត។ ក្រោយពីឯកសារនេះត្រូវបានអនុម័តជាផ្លូវការ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ នឹងត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីប្រសិទ្ធភាពនៃការអនុវត្ត។

៥. ការជារនីតិកម្មក្នុងវិស័យយុត្តិធម៌

គណៈកម្មការ និងក្រុមការងារចំពោះកិច្ចនៃក្រសួងយុត្តិធម៌ បាននឹងកំពុងរៀបចំសេចក្តីព្រាងច្បាប់សំខាន់ៗដែលជាតម្រូវការចាំបាច់ក្នុងវិស័យយុត្តិធម៌ រួមមាន សេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា, សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃសារការី, សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី, សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, សេចក្តីព្រាងវិសោធនកម្មច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ និងវិស័យរដ្ឋប្បវេណីជាពិសេស ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី, ក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់ដំណើរការតុលាការជំនាញផ្សេងៗ, សេចក្តីព្រាងសន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិមួយចំនួនទៀតក្នុងវិស័យព្រហ្មទណ្ឌ និងវិស័យរដ្ឋប្បវេណី ព្រមទាំងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀតតាមការចាំបាច់។ ជាទិសដៅការងារអាទិភាព គណៈកម្មការ និងក្រុមការងារចំពោះកិច្ចនៃក្រសួងយុត្តិធម៌ គ្រោងនឹងពិនិត្យ និងរៀបចំឱ្យបានរួចរាល់ឆាប់រហ័ស នូវសេចក្តីព្រាងច្បាប់សំខាន់ៗខាងលើ ដើម្បីបំពេញតម្រូវការជាក់ស្តែង ដោះស្រាយបញ្ហាប្រឈមនានាក្នុងការអនុវត្តច្បាប់ និងធ្វើឱ្យស្របតាមការវិវត្តន៍នៃសង្គម សេដ្ឋកិច្ច។

៦. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ

ក្រសួងយុត្តិធម៌ កំពុងដំណើរការជួសជុលកែលម្អអាគារ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានារបស់ទីស្តីការក្រសួងយុត្តិធម៌ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់មន្ត្រីរាជការដែលកំពុងបម្រើការងារជាក់ស្តែង ដែលគម្រោងនេះអាចនឹងត្រូវបញ្ចប់នៅក្នុងអំឡុងខែមិថុនា ឆ្នាំ២០២៥។ ទន្ទឹមនេះ នៅតាមសាលាដម្រះក្តីមួយចំនួន កំពុងត្រូវបានធ្វើការកែលម្អ និងសាសង់អគារថ្មីបន្ថែមសម្រាប់បំពេញការងារ ដើម្បីអាចឆ្លើយតបទៅនឹងតម្រូវជាក់ស្តែងនាពេលបច្ចុប្បន្ន សំដៅបង្កើនប្រសិទ្ធភាពការងារ។

៧. ការងារឌីជីថលូបនីយកម្ម និងបរិវត្តកម្មឌីជីថល

- ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ ប្រព័ន្ធគ្រប់គ្រងឯកសារ និងប្រព័ន្ធគ្រប់គ្រងលំហូរឯកសារសម្រាប់ក្រសួងយុត្តិធម៌ ឱ្យទៅជាការគ្រប់គ្រងតាមបែបឌីជីថល
- កែលម្អគេហទំព័រក្រសួងយុត្តិធម៌ឱ្យកាន់តែប្រសើរឡើងមានភាពងាយស្រួល និងសំបូរបែបសម្រាប់អ្នកប្រើប្រាស់
- បង្កើនការផ្សព្វផ្សាយសមិទ្ធផលការងារវិស័យយុត្តិធម៌ក្នុងបណ្តាញទំនាក់ទំនងសង្គមឱ្យបានទូលំទូលាយ
- បន្តធ្វើបច្ចុប្បន្នភាពនៅទំនើបកម្ម និងពង្រីកមុខងារថ្មីៗនៃប្រព័ន្ធគ្រប់គ្រងទិន្នន័យសំណុំរឿងព្រហ្មទណ្ឌសម្រាប់បំពេញតម្រូវការជាក់ស្តែង
- រៀបចំបង្កើតប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យសំណុំរឿងរដ្ឋប្បវេណី និងដាក់ឱ្យប្រើប្រាស់សាកល្បងនៅតាមសាលាដំបូងរាជធានី ខេត្តមួយចំនួន
- រៀបចំផែនការយុទ្ធសាស្ត្រឆ្នាំ២០២៥ និងសកម្មភាពតាមការអភិវឌ្ឍវិស័យយុត្តិធម៌ក្នុងបរិបទឌីជីថល
- ពង្រឹងសេវាឌីជីថលឱ្យមានគុណភាព និងប្រសិទ្ធភាពកាន់តែប្រសើរឡើង
- ពង្រឹងវិន័យ និងការទទួលខុសត្រូវលើការងារ ព្រមទាំងពង្រឹងសមត្ថភាពមន្ត្រីទទួលបន្ទុកផ្នែកប្រព័ន្ធព័ត៌មានវិទ្យា

៨. ការងារផ្សេងៗ

- បន្តរៀបចំទម្រង់របាយការណ៍ទិន្នន័យសំណុំរឿង ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយជាងមុន មុននឹងដាក់ឱ្យអនុវត្ត នៅតាមសាលាដម្រះក្តីទូទាំងប្រទេស ហើយអាចឱ្យគ្រប់អង្គភាពពាក់ព័ន្ធក្នុងវិស័យយុត្តិធម៌ អាចទាញយកព័ត៌មានពីរបាយការណ៍តែមួយនេះ មកប្រើប្រាស់បានទាំងអស់គ្នា
- រៀបចំបង្កើតប្រព័ន្ធចុះបញ្ជីសំណុំរឿងរដ្ឋប្បវេណី និងដាក់ឱ្យប្រើប្រាស់សាកល្បង
- ចុះស្រាវជ្រាវ ស៊ើបអង្កេត ប្រមូលព័ត៌មានពាក់ព័ន្ធនិងកិច្ចការអធិបញ្ជា និងបណ្តឹងសើរើ
- បន្តជំរុញចំណាត់ការពាក្យបណ្តឹងអន្តរាគមន៍របស់ប្រជាពលរដ្ឋឱ្យបានកាន់តែឆាប់រហ័ស និងមានប្រសិទ្ធភាព

- ពង្រឹងការប្រមូល និងការគ្រប់គ្រងទិន្នន័យសំណុំរឿង សាលក្រម ឬសាលដីកាស្តាពរ និងដីកាសម្រេច
- បន្តចុះតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីនៅតាមសាលាដម្រះក្តី
- បន្តចុះតាមដាន និងវាយតម្លៃ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរៀបចំប្រមូលទិន្នន័យស្ថិតិវិវាទឱ្យបានទូទាំងប្រទេស
- ផ្សព្វផ្សាយ និងប្រមូលធាតុចូលបន្ថែម ដើម្បីរៀបចំសៀវភៅប្រតិបត្តិការសម្រាប់ដាក់ឱ្យអនុវត្តនៅការិយាល័យនីតិកម្ម និងសម្របសម្រួលវិវាទក្រុង ស្រុក ខណ្ឌ
- រៀបចំឯកសារទស្សនាទានអំពីគោលនយោបាយជំនួយផ្នែកច្បាប់ និងផែនការសកម្មភាពសម្រាប់អនុវត្តទាក់ទងនឹងការផ្តល់សេវាជំនួយផ្នែកច្បាប់
- លើកកម្ពស់ការងារអធិការកិច្ច និងការអនុវត្តវិធានការវិន័យនៅតាមស្ថាប័នតុលាការ
- បន្តពង្រឹង និងយកចិត្តទុកដាក់លើកិច្ចការនានា ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- ជម្រុញកិច្ចការសិក្សាស្រាវជ្រាវ ចងក្រងនូវច្បាប់ លិខិតបទដ្ឋានគតិយុត្ត អត្ថបទសំខាន់ៗដើម្បីធ្វើការបោះពុម្ព និងផ្សព្វផ្សាយតាមបណ្តាញសង្គម
- ពង្រឹងការងារសវនកម្មស្របទៅតាមនីតិវិធី និងវិធីសាស្ត្រសវនកម្ម ទៅលើការគ្រប់គ្រងហិរញ្ញវត្ថុ ការប្រតិបត្តិការងារ នឹងភាពអនុលោមទៅតាមច្បាប់
- ពង្រឹងការចុះធ្វើសវនកម្ម ដល់អង្គភាពរងសវនកម្មឱ្យបាន២៥ រួមទាំងសាលាឧទ្ធរណ៍តំបន់ និងអង្គភាពដែលស្ថិតក្រោមឱវាទក្រសួងយុត្តិធម៌
- ពង្រឹងប្រសិទ្ធភាព និងពន្លឿនការដោះស្រាយវិវាទដែលបានប្តឹងមក អ.ជ.ក.
- ពិនិត្យលទ្ធភាពក្នុងការពង្រីកយន្តការនៃការទទួលពាក្យបណ្តឹងឱ្យបានកាន់តែល្អប្រសើរ និងមានភាពងាយស្រួល ជាពិសេស ការរៀបចំចល័តមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ឱ្យចុះដោះស្រាយវិវាទជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋានដោយផ្ទាល់ ជាពិសេស ប្រជាពលរដ្ឋដែលជាជនជាតិដើមភាគតិចរស់នៅតំបន់ភូមិភាគឦសាន និងតំបន់ដាច់ស្រយាល
- បន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយតួអង្គពាក់ព័ន្ធ ពិសេស តាមរយៈការបន្តចុះអនុស្សរណៈនៃការយោគយល់គ្នា (MOU) ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅបង្កើនប្រសិទ្ធភាពនៃការដោះស្រាយវិវាទជូនប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរ
- បន្តធ្វើការផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយអំពីបេសកកម្មការងារ និងយន្តការដោះស្រាយវិវាទរបស់ អ.ជ.ក. សំដៅឱ្យសាធារណជនអាចយល់ដឹងកាន់តែច្បាស់អំពីយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ពិសេស វិធីសាស្ត្រនៃការដោះស្រាយបញ្ចប់វិវាទជាស្ថាពរដោយ អ.ជ.ក.ម៉្យាង លើកទឹកចិត្តឱ្យប្រជាពលរដ្ឋប្រើប្រាស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងម៉្យាងទៀត

ដើម្បីរួមចំណែកកាត់បន្ថយសំណុំរឿងនៅតាមតុលាការ និងអាចបង្កើតសេវាយុត្តិធម៌ឱ្យកាន់តែកៀកជិតប្រជាពលរដ្ឋ

- បន្តគាំទ្រ និងពង្រឹងការចូលរួមអនុវត្តយុទ្ធនាការ "ជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ" និង "ត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ" ប្រកបដោយឆន្ទៈនិងស្មារតីទទួលខុសត្រូវខ្ពស់ ស្របតាមទិសដៅដែលបានដាក់ដោយគណៈបញ្ជាការដឹកនាំយុទ្ធនាការ។

ជំពូកទី៦
សេចក្តីសន្និដ្ឋាន

ក្រសួងយុត្តិធម៌ និងសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់បានខិតខំប្រឹងប្រែងអនុវត្តសកម្មភាពការងារជាច្រើនក្នុងឆ្នាំ២០២៤ កន្លងទៅនេះ ស្របតាមទិសដៅអាទិភាពនៃការងារកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយបានផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការលើកកម្ពស់សេវាយុត្តិធម៌ សំដៅពង្រឹងជំនឿទុកចិត្តពីសាធារណជនលើវិស័យនេះ ព្រមទាំងការប្រយុទ្ធប្រឆាំងនឹងអំពើរំលោភបំពានដោយអយុត្តិធម៌ក្នុងសង្គម តាមរយៈការពង្រឹងការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ ការពង្រឹងភាពស្អាតស្អំនិងក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីអនុវត្តច្បាប់ ការពង្រឹងយន្តការវិន័យការងារ និងការធ្វើទំនើបកម្មរដ្ឋបាលយុត្តិធម៌ ការលើកកម្ពស់ការផ្តល់សេវាផ្នែកច្បាប់ដែលអាចឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងរបស់សង្គមប្រកបដោយប្រសិទ្ធភាព និងការដាក់ចេញនូវយុទ្ធនាការចំនួន២ ក្នុងនោះរួមមាន៖ (១)-យុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និង (២)-យុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ ព្រមជាមួយនឹងការពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃយន្តការដោះស្រាយវិវាទទាំងក្នុងប្រព័ន្ធតុលាការទាំងក្រៅប្រព័ន្ធតុលាការ។ ផ្អែកតាមការបូកសរុបលទ្ធផលការងារក្នុងការអនុវត្តយុទ្ធនាការរយៈពេល ១ឆ្នាំ ដែលទទួលបាននូវលទ្ធផលជាវិជ្ជមាន និងគួរជាទីមោទន សមិទ្ធផលនេះបានក្លាយជាកត្តាដ៏សំខាន់ក្នុងការឆ្លុះបញ្ចាំងឱ្យឃើញពីកិច្ចខិតខំប្រឹងប្រែងរបស់ស្ថាប័នតុលាការ និងតួអង្គពាក់ព័ន្ធទាំងអស់ ដែលជាការរួមចំណែកក្នុងការអនុវត្តនូវកម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌ស្របតាមទិសដៅដែលបានដាក់ចេញនាពេលកន្លងមក។

ជាលទ្ធផលក្នុងឆ្នាំ២០២៤ ក្រសួងយុត្តិធម៌ សម្រេចបាននូវសមិទ្ធផលការងារសំខាន់ៗជាច្រើន ជាអាទិ៍ ការបន្តកសាង និងធ្វើបច្ចុប្បន្នភាពនូវក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាច្រើន ដើម្បីបម្រើឱ្យសេចក្តីត្រូវការចាំបាច់នានា និងការវិវត្តន៍របស់សង្គម សេដ្ឋកិច្ច, ការពង្រឹង និងលើកកម្ពស់សមត្ថភាពមន្ត្រីអនុវត្តច្បាប់ និងសមត្ថភាពស្ថាប័នក្នុងវិស័យយុត្តិធម៌ ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងការផ្តល់សេវាយុត្តិធម៌ឱ្យបានកាន់តែល្អប្រសើរ, ការពង្រឹងប្រសិទ្ធភាពនៃយន្តការអធិការកិច្ច ដើម្បីលើកកម្ពស់វិន័យការងារ ក្រមសីលធម៌ និងសេចក្តីថ្លៃថ្នូររបស់មន្ត្រីអនុវត្តច្បាប់ក្នុងវិស័យយុត្តិធម៌, ការលើកកម្ពស់យន្តការនៃការផ្តល់សេវាជំនួយផ្នែកច្បាប់, ការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ សំដៅបង្កើនប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាយុត្តិធម៌របស់ស្ថាប័នតុលាការ និងពង្រឹងគុណភាពនៃយុត្តិធម៌ជូនប្រជាពលរដ្ឋ។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានខាងលើ វិស័យយុត្តិធម៌ក្នុងឆ្នាំ២០២៤ ក៏នៅជួបប្រទះបញ្ហាប្រឈមគួរឱ្យកត់សម្គាល់មួយចំនួនដែលប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងប្រសិទ្ធភាពនៃការលើកកម្ពស់សេវាយុត្តិធម៌ ព្រមទាំងជំនឿទុកចិត្តពីប្រជាពលរដ្ឋមកលើវិស័យយុត្តិធម៌ ក្នុងនោះរួមមាន (១)-ភាពមានកម្រិតនៃសមត្ថភាពស្ថាប័ន និងធនធានមនុស្សក្នុងវិស័យយុត្តិធម៌ ដែលពុំទាន់អាចឆ្លើយតបបានទៅនឹងតម្រូវការជាក់ស្តែងបានទាំងស្រុង, (២)-ការពង្រឹងការងារអធិការកិច្ចនៅមិនទាន់អាចអនុវត្តបានពេញលេញនៅឡើយជាពិសេស លើផ្នែកវិន័យការងារ ក្រមសីលធម៌ និងលើផ្នែកគុណភាពនៃចំណាត់ការ សំណុំរឿងរបស់មន្ត្រីអនុវត្តច្បាប់, (៣)-ការគាំទ្រផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងបច្ចេកវិទ្យាឌីជីថល សម្រាប់បម្រើដល់ការអនុវត្តការងាររបស់ក្រសួងយុត្តិធម៌ និងសាលាជម្រះក្តីនៅមានកម្រិត និង (៤)-តម្រូវការក្នុងការកសាងបន្ថែមនូវក្របខណ្ឌច្បាប់ចាំបាច់មួយចំនួន និងការធ្វើបច្ចុប្បន្នភាពនៃច្បាប់ជាធរមាន ដើម្បីអាចឆ្លើយតបបានជាមួយនឹងស្ថានភាពជាក់ស្តែងរបស់សង្គម សេដ្ឋកិច្ច។

ជាទិសដៅការងារអាទិភាពបន្ត, ក្រសួងយុត្តិធម៌ នឹងផ្តោតការយកចិត្តទុកដាក់លើការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីពង្រឹងគុណភាព និងប្រសិទ្ធភាពនៃច្បាប់និងប្រព័ន្ធយុត្តិធម៌ តាមរយៈការបន្តគាំទ្រនិងចូលរួមអនុវត្តយុទ្ធនាការទាំង២ ដែលបានដាក់ចេញដោយក្រសួងយុត្តិធម៌នៅឆ្នាំបន្តបន្ទាប់ ប្រកបដោយឆន្ទៈនិងស្មារតីទទួលខុសត្រូវខ្ពស់, បន្តពង្រឹងវិន័យ និងក្រមសីលធម៌ក្នុងការងារ និងបន្តអនុវត្តតាមទិសដៅកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការលើកកម្ពស់ ការគោរពសិទ្ធិនិងសេរីភាពបុគ្គល លើកកម្ពស់យុត្តិធម៌នៅក្នុងសង្គម ពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងស្ថិរភាពសង្គម, យកចិត្តទុកចិត្តលើកិច្ចការនីតិកម្ម, បង្កើនប្រសិទ្ធភាពនៃយន្តការសម្រុះសម្រួលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ព្រមទាំងការពង្រឹងសុក្រឹតកម្មការងាររបស់មន្ត្រីអនុវត្តច្បាប់ ដើម្បីការបង្កើនជំនឿទុកចិត្តពីសាធារណជនលើវិស័យច្បាប់និងយុត្តិធម៌ឱ្យកាន់តែប្រសើរឡើង។

ឧបសម្ព័ន្ធទី១

បទបង្ហាញអំពី

ទិន្នន័យសំណុំរឿងទូទាំងប្រទេសឆ្នាំ២០២៤

1

សំណុំរឿងព្រហ្មទណ្ឌ

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)

2

2

ទិន្នន័យ សំណុំរឿងព្រហ្មទណ្ឌ - តាមដំណាក់កាល (ចាស់ និង ថ្មី)
សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី ខេត្ត
(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)



3

3

ចំនួនសំណុំរឿងព្រហ្មទណ្ឌសរុប ទូទាំងប្រទេស ឆ្នាំ២០២៣



4

4

ឯកសន័យ សំណុំរឿងព្រហ្មទណ្ឌ - តាមប្រភេទបទល្មើស - ចាំង៣ដំណាក់កាល
(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)



5

សំណុំរឿងព្រហ្មទណ្ឌ
តាមប្រភេទបទល្មើស

6

6

សំណុំរឿងព្រហ្មទណ្ឌ - ឧក្រិដ្ឋ - ដំណាក់កាលអយ្យការ (សំណុំរឿងចាស់ និង ថ្មី)

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)

តាមប្រភេទបទល្មើស



7

ប្រភេទបទល្មើសឧក្រិដ្ឋ ទាំង ៥

ក្នុងសំណុំរឿងព្រហ្មទណ្ឌនៅ ឆ្នាំ២០២៣ - ដំណាក់កាលអយ្យការ



8

សំណុំរឿងព្រហ្មទណ្ឌ - ឧក្រិដ្ឋ - ដំណាក់កាលអយ្យការ (សំណុំរឿងចាស់ និង ថ្មី)

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)

បទល្មើសគ្រឿងញៀន



9

សំណុំរឿងព្រហ្មទណ្ឌ - ឧក្រិដ្ឋ - ដំណាក់កាលអយ្យការ (សំណុំរឿងចាស់ និង ថ្មី)

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)

លួចមានស្ថានទម្ងន់ទោស



10

សំណុំរឿងព្រហ្មទណ្ឌ - ឧក្រិដ្ឋ - ដំណាក់កាលអយ្យការ (សំណុំរឿងចាស់ និង ថ្មី)

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)

បទល្មើសរំលោភសេពសន្ថវៈ



11

11

សំណុំរឿងរំលោភសេពសន្ថវៈលើកុមារ ដែលមានទំនាក់ទំនងជាសាច់ញាតិ ក្នុងឆ្នាំ២០២៤ - ដំណាក់កាលអយ្យការ

12

12

ទំនាក់ទំនងរវាងជនរងគ្រោះ និង ជនល្មើស
(មានទំនាក់ទំនងជាសាច់ញាតិជាមួយជនរងគ្រោះ)
ក្នុងសំណុំរឿងរំលោភសេពសន្ថវៈ ក្នុងឆ្នាំ២០២៤ - ដំណាក់កាលរយៈការ



13

ទំនាក់ទំនងរវាងជនរងគ្រោះ និងជនល្មើស
(មានទំនាក់ទំនងជាសាច់ញាតិជាមួយជនរងគ្រោះ)
ក្នុងសំណុំរឿងរំលោភសេពសន្ថវៈ ក្នុងឆ្នាំ២០២៣ - ដំណាក់កាលរយៈការ



14

ចំនួនករណីសំណុំរឿងរំលោភសេពសន្ថវៈ
(មានចំនាក់ចំនងជាសាច់ញាតិជាមួយជនរងគ្រោះ)
តាមអយ្យការអមសាលាដំបូងរាជធានី ខេត្ត ក្នុងឆ្នាំ២០២៤



15

អាយុរបស់ជនរងគ្រោះ ក្នុងសំណុំរឿងរំលោភសេពសន្ថវៈ
ក្នុងឆ្នាំ២០២៤ - ដំណាក់កាលអយ្យការ



16

សំណុំរឿងព្រហ្មទណ្ឌ - ឧក្រិដ្ឋ - ដំណាក់កាលអយ្យការ (សំណុំរឿងចាស់ និង ថ្មី)

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)

បទល្មើសកាប់រាន ឈូសឆាយ ហ៊ុំព័ទ្ធដីព្រៃ



17

សំណុំរឿងព្រហ្មទណ្ឌ - ឧក្រិដ្ឋ - ដំណាក់កាលអយ្យការ (សំណុំរឿងចាស់ និង ថ្មី)

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)

បទល្មើសក្លែងបន្លំឯកសារសាធារណៈ



18

សំណុំរឿងព្រហ្មទណ្ឌ - មជ្ឈិម - ដំណាក់កាលអយ្យការ (សំណុំរឿងចាស់ និងថ្មី)

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)

តាមប្រភេទបទល្មើស



19

ប្រភេទបទល្មើសមជ្ឈិម ទាំង ៥

ក្នុងសំណុំរឿងព្រហ្មទណ្ឌឆ្នាំ២០២៣ - ដំណាក់កាលអយ្យការ



20

ចំនួនជនជាប់ឃុំឃាំង

21

21

ចំនួនជនជាប់ឃុំសរុប
(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)



22

22

ចំនួនជនជាប់ឃុំសរុប
(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)



23

23

សំណុំរឿងព្រហ្មទណ្ឌ - មជ្ឈិម - ដំណាក់កាលអយ្យការ (សំណុំរឿងចាស់ និងថ្មី)
(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)
បទល្មើសគ្រឿងញៀន



24

24

សំណុំរឿងព្រហ្មទណ្ឌ - មជ្ឈិម - ដំណាក់កាលអយ្យការ (សំណុំរឿងចាស់ និងថ្មី)

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)

បទល្មើសលួច



25

សំណុំរឿងព្រហ្មទណ្ឌ - មជ្ឈិម - ដំណាក់កាលអយ្យការ (សំណុំរឿងចាស់ និងថ្មី)

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)

បទល្មើសរំលោភលើទំនុកចិត្ត



26

សំណុំរឿងព្រហ្មទណ្ឌ - មជ្ឈិម - ដំណាក់កាលអយ្យការ (សំណុំរឿងចាស់ និងថ្មី)

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)

បទល្មើសឆបោក



27

27

សំណុំរឿងព្រហ្មទណ្ឌ - មជ្ឈិម - ដំណាក់កាលអយ្យការ (សំណុំរឿងចាស់ និងថ្មី)

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)

បទល្មើសចរាចរណ៍



28

28

ទិន្នន័យ
គ្រោះថ្នាក់ចរាចរណ៍តាមផ្លូវជាតិ

29

29

ទិន្នន័យ គ្រោះថ្នាក់ចរាចរណ៍ សរុប តាមផ្លូវជាតិសំខាន់ៗទូទាំងប្រទេស
ទិន្នន័យពីអយ្យការអមសាលាដំបូងរាជធានី ខេត្ត
(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)



30

30

ទិន្នន័យ គ្រោះថ្នាក់ចរាចរណ៍ តាមផ្លូវជាតិសំខាន់ៗនៃទាំងប្រទេស
ទិន្នន័យពីអង្គការអនុសាសាដំបូងរាជធានី ខេត្ត
(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)



31

31

ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌ
ដំណាក់កាលអយ្យការ

32

32

ទិន្នន័យ សំណុំរឿងព្រហ្មទណ្ឌ សរុប ដំណាក់កាលអយ្យការ (ចាស់ និង ថ្មី)
សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី ខេត្ត
(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)



33

33

សំណុំរឿងព្រហ្មទណ្ឌ - ចំណាត់ការ - ដំណាក់កាលអយ្យការ (សំណុំរឿងចាស់ និង ថ្មី)
ប្រភេទចំណាត់ការសរុប



34

34

សំណុំរឿងព្រហ្មទណ្ឌ - ចំណាត់ការ - ដំណាក់កាលអយ្យការ (សំណុំរឿងចាស់ និង ថ្មី)
បើកការស៊ើបសួរ (RI)



35

35

សំណុំរឿងព្រហ្មទណ្ឌ - ចំណាត់ការ - ដំណាក់កាលអយ្យការ (សំណុំរឿងចាស់ និង ថ្មី)
បង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម (CI)



36

36

សំណុំរឿងព្រហ្មទណ្ឌ - ចំណាត់ការ - ដំណាក់កាលរយៈការ (សំណុំរឿងចាស់ និង ថ្មី)
បញ្ជូនរឿងទៅដំឡុងម្រះផ្ទាល់ (CD)



37

សំណុំរឿងព្រហ្មទណ្ឌ - ចំណាត់ការ - ដំណាក់កាលរយៈការ (សំណុំរឿងចាស់ និង ថ្មី)
តម្កល់រឿងឆុកឥតចាត់ការ



38

ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌ ដំណាក់កាលស៊ើបសួរ

39

ទិន្នន័យ សំណុំរឿងព្រហ្មទណ្ឌ សរុប ដំណាក់កាលស៊ើបសួរ (ចាស់ និង ថ្មី)
សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី ខេត្ត
(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)



40



41

ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌ

ដំណាក់កាលជំនុំជម្រះ

42

42

ទិន្នន័យ សំណុំរឿងព្រហ្មទណ្ឌ សរុប ដំណាក់កាលជំនុំជម្រះ (ចាស់ និង ថ្មី)
សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី ខេត្ត
(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)



43

សំណុំរឿងព្រហ្មទណ្ឌ - ចំណាត់ការ - ដំណាក់កាលជំនុំជម្រះ (សំណុំរឿងចាស់ និង ថ្មី)
(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)



44

សំណុំរឿងព្រហ្មទណ្ឌ - ចំណាត់ការ - ដំណាក់កាលជំនុំជម្រះ (សំណុំរឿងចាស់ និង ថ្មី)

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)



45

45

សំណុំរឿងរដ្ឋប្បវេណី

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)

46

46

សំណុំរឿងរដ្ឋប្បវេណី តាមប្រភេទនៃវិវាទ

47

សំណុំរឿងរដ្ឋប្បវេណី តាមប្រភេទវិវាទ (សំណុំរឿងចាស់ និង ថ្មី)

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)



48

សំណុំរឿងរដ្ឋប្បវេណី (សំណុំរឿងចាស់ និង ថ្មី)

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)

ប្រភេទកិច្ចសន្យាធិញ្ញ-លក់អចលនវត្ថុ



49

49

សំណុំរឿងរដ្ឋប្បវេណី (សំណុំរឿងចាស់ និង ថ្មី)

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)

ប្រភេទកិច្ចសន្យាធិញ្ញ-លក់ចលនវត្ថុ



50

50

សំណុំរឿងរដ្ឋប្បវេណី (សំណុំរឿងចាស់ និង ថ្មី)

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)

ប្រភេទកិច្ចសន្យាជួលអចលនវត្ថុ



51

សំណុំរឿងរដ្ឋប្បវេណី (សំណុំរឿងចាស់ និង ថ្មី)

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)

ប្រភេទកិច្ចសន្យាជួលអចលនវត្ថុ



52

សំណុំរឿងរដ្ឋប្បវេណី (សំណុំរឿងចាស់ និង ថ្មី)

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)

ប្រតេទកិច្ចសន្យាជួលអចលនវត្ថុ



53

53

សំណុំរឿងរដ្ឋប្បវេណី

តាមកម្មវត្ថុនៃបណ្តឹង

54

54

ទិន្នន័យ និង ចំណាត់ការ សំណុំរឿងរដ្ឋប្បវេណី សរុប (ចាស់ និង ថ្មី)
សាលាដំបូងរាជធានី ខេត្ត
(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)



55

ទិន្នន័យ សំណុំរឿងរដ្ឋប្បវេណី តាមប្រភេទបណ្តឹង សរុប (ចាស់ និង ថ្មី)
សាលាដំបូងរាជធានី ខេត្ត
(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)



56

ទិន្នន័យ សំណុំរឿងរដ្ឋប្បវេណី តាមប្រភេទបណ្តឹង ចាត់ការសរុប (ចាស់ និង ថ្មី)
សាលាដំបូងរាជធានី ខេត្ត
(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)



57

ទិន្នន័យ សំណុំរឿងរដ្ឋប្បវេណី តាមប្រភេទបណ្តឹង សល់កំពុងចាត់ការសរុប (ចាស់ និង ថ្មី)
សាលាដំបូងរាជធានី ខេត្ត
(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)



58

ទិន្នន័យ សំណុំរឿងរដ្ឋប្បវេណី (អនុវត្តដោយបច្ចុំ) ៦ខែ, ៩ខែ និង ១ឆ្នាំ នៃយុទ្ធនាការ



59

59

សំណុំរឿងរដ្ឋប្បវេណី ផ្សះផ្សាសះជា និងមានកំណត់ហេតុ សាលាដំបូងរាជធានី ខេត្ត

60

60

ភាពឈ្លានពានលើធនធានធម្មជាតិ ដែលបានផ្សះផ្សារសេះជា និងមានកំណត់ហេតុ សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី ខេត្ត

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)



61

61

ភាពឈ្លានពានលើធនធានធម្មជាតិ ដែលបានផ្សះផ្សារសេះជា និងមានកំណត់ហេតុ អ.ដ.ក. និង សាលាដម្រះក្តីជាន់ខ្ពស់

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)



62

62

លទ្ធផលចំណាត់ការសំណុំរឿង សាលាដម្រះក្តីគ្រប់ជាន់ថ្នាក់ សំណុំរឿងព្រហ្មទណ្ឌ និងរដ្ឋប្បវេណី

63

63

លទ្ធផលនៃចំណាត់ការលើ សំណុំរឿងព្រហ្មទណ្ឌ និង រដ្ឋប្បវេណី
សាលាដម្រះក្តីគ្រប់ជាន់ថ្នាក់
(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ - ១ឆ្នាំនៃយុទ្ធនាការ)

១. សំណុំរឿងព្រហ្មទណ្ឌ ទូទាំងប្រទេស ៖

- សំណុំរឿងសរុប (ចាស់ និង ថ្មី) ៖ 120,816
- ចាត់ការរួចសរុប (ចាស់ និង ថ្មី) ៖ 101,712 ស្មើនឹង 84.19%
- នៅសល់កំពុងចាត់ការសរុប (ចាស់ និង ថ្មី) ៖ 19,104 ស្មើនឹង 15.81%

២. សំណុំរឿងរដ្ឋប្បវេណី ទូទាំងប្រទេស ៖

- សំណុំរឿងសរុប (ចាស់ និង ថ្មី) ៖ 108,456
- ចាត់ការរួចសរុប (ចាស់ និង ថ្មី) ៖ 87,230 ស្មើនឹង 80.43%
- នៅសល់កំពុងចាត់ការសរុប (ចាស់ និងថ្មី) ៖ 21,226 ស្មើនឹង 19.57%

>>> សំណុំរឿងព្រហ្មទណ្ឌ និង សំណុំរឿងរដ្ឋប្បវេណី ទូទាំងប្រទេស (សរុបរួមទាំងអស់)៖

- សំណុំរឿងសរុប (ចាស់ និង ថ្មី) ៖ 229,272 (កើន 48,611)
- ចាត់ការរួចសរុប (ចាស់ និង ថ្មី) ៖ 188,942 ស្មើនឹង 82.41%
- នៅសល់កំពុងចាត់ការសរុប (ចាស់ និង ថ្មី) ៖ 40,330 ស្មើនឹង 17.59%

64

64

ធនធានមនុស្សនៅតាមសាលាដម្រះក្តីគ្រប់ជាន់ថ្នាក់

65

ធនធានមនុស្សនៅតាមសាលាដម្រះក្តីគ្រប់ជាន់ថ្នាក់
(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)



66

67

ឯកសារផ្នែកទី២

រចាយការណ៍លទ្ធផលការងារ

របស់សាលាដម្រះក្តីឆ្នាំ២០២៤

មាតិកា
របាយការណ៍សង្ខេបរបស់សាលាដម្រះក្តីចូរាំងប្រទេស
សម្រាប់សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំយុត្តិធម៌ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារឆ្នាំអនាគតឆ្នាំ២០២៥

ឈ្មោះឯកសារ **ចំនួនទំព័រ**

១. តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល..... ១២ ទំព័រ

២. សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ..... ៧ ទំព័រ

៣. សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង..... ៧ ទំព័រ

៤. សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍តួ្បងឃ្មុំ.....៧ ទំព័រ

៥. សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ..... ៧ ទំព័រ

៦. សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ..... ៦ ទំព័រ

៧. សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកណ្តាល..... ៦ ទំព័រ

៨. សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ.....៦ ទំព័រ

៩. សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង..... ៦ ទំព័រ

១០. សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តព្រៃវែង.....៦ ទំព័រ

១១. សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តស្វាយរៀង.....៦ ទំព័រ

១២. សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តតាកែវ..... ៦ ទំព័រ

១៣. សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង.....៦ ទំព័រ

១៤. សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តពោធ៍សាត់.....៥ ទំព័រ

១៥. សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តប៉ៃលិន.....៤ ទំព័រ

១៦. សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ.....៦ ទំព័រ

១៧. សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ.....៦ ទំព័រ

១៨. សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តសៀមរាប.....៦ ទំព័រ

១៩. សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ..... ៦ ទំព័រ

២០. សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកោះកុង..... ៦ ទំព័រ

២១. សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកំពត..... ៦ ទំព័រ

២២. សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកែប..... ៦ ទំព័រ

២៣. សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ.....៦ ទំព័រ

២៤. សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកំពង់ចាម..... ៦ ទំព័រ

២៥. សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកំពង់ធំ.....៦ ទំព័រ

២៦. សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តព្រះវិហារ.....៤ ទំព័រ

២៧. សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តក្រចេះ.....៦ ទំព័រ

២៨. សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តស្ទឹងត្រែង.....៦ ទំព័រ

២៩. សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តរតនគិរី..... ៦ ទំព័រ

៣០. សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តមណ្ឌលគិរី..... ៦ ទំព័រ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល និង មហាអយ្យការ
អមតុលាការកំពូល

លេខ :..៣.៤.៣/.....តកក.អ.ក

របាយការណ៍ការងារសង្ខេបរបស់សាលាដម្រះក្តី
សម្រាប់សន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារអាទិភាព ឆ្នាំ២០២៥
តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល

==========

១- ស្ថានភាពទូទៅ

ក- ធនធានមនុស្ស

ចំនួនស្ថិតិចៅក្រម						ចំនួនស្ថិតិព្រះរាជអាជ្ញា					
ចំនួនសរុប	ស្រី	ប្រធាន	អនុប្រធាន	ចៅក្រម	ស្រី	ចំនួនសរុប	ស្រី	អគ្គព្រះរាជអាជ្ញា	អគ្គព្រះរាជអាជ្ញារង	ព្រះរាជអាជ្ញា	ស្រី
២៥	៣	១	៦	១៨	៣	១១	១	១	៤	៦	០

ស្ថិតិក្រឡាបញ្ជី

ក្រឡាបញ្ជីតុលាការ	ស្រី	ក្រឡាបញ្ជីអយ្យការ	ស្រី
៤០ នាក់	១៩ នាក់	៧ នាក់	២ នាក់

ស្ថិតិមន្ត្រីរដ្ឋបាល

ល.រ	តួនាទី	ចំនួន	ស្រី	ប្រភេទក្របខ័ណ្ឌ		
				"ក"	"ខ"	"គ"
១	អគ្គលេខាធិការ	១	១	១	០	០
២	អគ្គលេខាធិការរង	៤	១	៤	០	០
៣	ប្រធាននាយកដ្ឋាន	៤	១	៣	១	០
៤	អនុប្រធាននាយកដ្ឋាន	៨	២	៧	១	០
៥	ប្រធានការិយាល័យ	១១	៥	១១	០	០
៦	អនុប្រធានការិយាល័យ	៤	២	២	១	១
៧	មន្ត្រីគ្រប់គ្រងរដ្ឋបាល	១៩	១០	១៧	២	០
៨	លេខាធិការរដ្ឋបាល	១	១	០	០	១
៩	ទំនេរគ្មានបៀវត្ស	៤	១	៣	០	០
១០	មន្ត្រីជាប់កិច្ចសន្យា	៤៣	២០			

ខ- ហេដ្ឋារចនាសម្ព័ន្ធ

តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល បច្ចុប្បន្នជាអតីតរដ្ឋសភាចាស់ស្ថិតនៅលើមហាវិថីសម្តេចសុធារស សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កែងផ្លូវ២៤០ មានអគារចំនួន៤ អគារ A (អគារអតីតរដ្ឋសភាចាស់), អគារ B (អគារមហាអយ្យការអមតុលាការកំពូល), អគារ C (អគារចិន) និងអគារ D សាងសង់ថ្មីកម្ពស់៤ជាន់ រួមមាន៖

- សាលសវនាការទី១ ពេញអង្គ
- សាលសវនាការទី២ ព្រហ្មទណ្ឌ
- សាលសវនាការទី៣ រដ្ឋប្បវេណី
- សាលពិភាក្សាធំចំនួន១
- សាលពិភាក្សាតូចចំនួន២
- សាលប្រជុំតូចចំនួន១
- ឃ្លាំងដាក់សំណុំរឿងតូចចំនួន១
- បន្ទប់ដាក់ពិរុទ្ធជនចំនួន១
- រោងចតរថយន្តរបស់តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល។

បានជួលទីតាំងមួយកន្លែងសម្រាប់បំពេញការងារជាបណ្តោះអាសន្ននៅក្នុងឆ្នាំ២០២៤ ឆ្នាំ២០២៥។

គ- លទ្ធផលសន្និបាតផ្ទៃក្នុងស្ថាប័នឆ្នាំ ២០២៤

តាមរយៈសន្និបាតបូកសរុបការងារឆ្នាំ២០២៤ បង្ហាញឱ្យឃើញថាការងារដែលតុលាការកំពូលសម្រេចបានក្នុងឆ្នាំ២០២៤ ទទួលបានលទ្ធផលវិកចម្រើនក្នុងការដោះស្រាយរឿងក្តី ក្នុងនោះរឿងក្តីគ្រប់ប្រភេទត្រូវបានចាត់ការកើនឡើងចំនួន ៣៩៧ រឿង បើធៀបនឹងឆ្នាំ២០២៣។ ជាងនេះទៅទៀត អង្គសន្និបាតបានពិភាក្សាយ៉ាងផុលផុសប្រកបដោយបរិយាកាស រីករាយស្និទ្ធស្នាល ព្រមទាំងផ្តល់នូវមតិយោបល់ល្អៗសម្រាប់ដោះស្រាយបញ្ហាប្រឈម ចំណុចខ្វះខាត និងលើកទិសដៅការងារបន្តសម្រាប់ឆ្នាំ២០២៥ ដែលបានធ្វើឱ្យអង្គសន្និបាតទទួលបានលទ្ធផលជោគជ័យដ៏ត្រចះត្រចង់ និងទទួលយកនូវដំណោះស្រាយទាំងឡាយដែលជាផ្លែផ្កានៃអង្គសន្និបាត ទៅអនុវត្តដោយស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីវឌ្ឍនភាព និងជំនឿទុកចិត្តលើប្រព័ន្ធយុត្តិធម៌។

ឃ- សកម្មភាពការងារផ្សេងៗ

ឃ.១- សកម្មភាពក្នុងប្រទេស

- តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ស្តីពី «**កិច្ចសហប្រតិបត្តិការដាក់ឱ្យប្រើប្រាស់ផ្ទៀងផ្ទាត់ឯកសារ Verify.gov.kh និងការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងការតភ្ជាប់អ៊ីនធឺណិត**» កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤។

- ថ្នាក់ដឹកនាំតុលាការកំពូល និងមហាអយ្យការ មានឯកឧត្តម **ជីវ កេង** ប្រធានតុលាការកំពូល លោកជំទាវ **ជា លាង** អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល បានអញ្ជើញចូលរួមដោយផ្ទាល់ ឬចាត់តំណាងឱ្យទៅចូលរួមក្នុងពិធី និងកម្មវិធីផ្សេងៗ មានដូចជា ៖ ខួបលើកទី៤៥ នៃទិវាជ័យជម្នះថ្ងៃ៧មករា, ពិធី «**វគ្គទិវា**», ទិវាបង្កើតកងរាជអាវុធហត្ថ (១៤កក្កដា ១៩៩៣-១៤កក្កដា ២០២៤), ទិវាបុណ្យឯករាជ្យជាតិ៩វិច្ឆិកា, ទិវា

ជាតិប្រឆាំងការជួញដូរមនុស្ស១២ឆ្នូ, ខួបលើកទី២៥នៃការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា និងការអនុវត្ត ប្រកបដោយជោគជ័យនូវនយោបាយឈ្នះ-ឈ្នះ ព្រមទាំងខួប៥ឆ្នាំនៃការកសាងវិមានឈ្នះ-ឈ្នះ, បុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ, ព្រះរាជពិធីច្រត់ព្រះនង្គ័ល, ព្រះរាជពិធីថ្វាយព្រះភ្លើងជូនព្រះបរមសពសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេស **ទេព វង្ស**, បុណ្យកាន់បិណ្ឌចំនួន៥លើក, បុណ្យមាឃបូជា, បុណ្យវិសាខបូជា, ថ្វាយកម្រងផ្កាគោរពវិញ្ញាណក្ខន្ធ ព្រះបាទសម្តេចព្រះបរមរតនកោដ្ឋ **នរោត្តម សីហនុ**, ពិធីសម្ពោធវិមានរដ្ឋធម្មនុញ្ញ, ពិធីបញ្ចុះបឋមសិលាជានិមិត្តរូប និងការប្រកាសបង្កើតវិទ្យាស្ថានកេរដំណែលរបស់ អ.វ.ត.ក., ប្រារព្ធខួបលើកទី៣១ និងពិធីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់សាលមហោស្រព «គោកធ្លក», ពិធីបើកសម័យប្រជុំដំបូងព្រឹទ្ធសភានីតិកាលទី៥, កិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (ក.ជ.ក.ស.), សន្និសីទស្តីពី «**អនាគតកម្ពុជា គ្មានអំពើប្រល័យពូជសាសន៍**», ចូលរួមសិក្ខាសាលា ចំនួន **៥**លើក, កិច្ចប្រជុំផ្សេងៗចំនួន**៥**លើក, បទឧទ្ទេសនាមចំនួន**៥**លើក និងវគ្គបណ្តុះបណ្តាលចំនួន **១**លើក។

- តុលាការកំពូលបានបញ្ជូនចៅក្រមចំនួន ១០រូប ទៅបង្រៀនសិស្សចៅក្រម សិស្សសារការី សិស្សក្រឡាបញ្ជី សិស្សអាជ្ញាសាលា និងសិស្សមន្ត្រីលេខាធិការដ្ឋាន និងបានបញ្ជូនចៅក្រមទៅចូលរួមសិក្ខាសាលា និងចូលរួមជាសមាជិកក្រុមការងារអនុវត្តគម្រោង JICA ជំហានទី៦ នៅបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា។

- តុលាការកំពូលបានទទួលការធ្វើទស្សនកិច្ចសិក្សារបស់សិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញាជំនាន់ទី១២, អ្នកជំនាញការ JICA រួមជាមួយនឹងសិក្ខាកាមជប៉ុន ដឹកនាំដោយប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងយុត្តិធម៌ជប៉ុន (ICD), និងនិស្សិតនៃវិទ្យាស្ថានប៊ែលជីអន្តរជាតិចំនួន **២**លើក។

- មហាអយ្យការអមតុលាការកំពូលបានជួបពិភាក្សាការងារចំនួន **២**លើក និងចូលរួមធ្វើគណៈមេប្រយោគប្រឡងសញ្ញាបត្រជាន់ខ្ពស់មន្ត្រីនគរបាលយុត្តិធម៌ចំនួន **២លើក**។

ឃ.២- សកម្មភាពទាក់ទងនឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ

- ឯកឧត្តម **ជឹម គេង** ប្រធានតុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូតុលាការកំពូលដើម្បីចូលរួមក្នុងកិច្ចប្រជុំលើកទី១១ នៃក្រុមប្រឹក្សាប្រធានតុលាការកំពូលអាស៊ាន ហៅកាត់ថា CACJ ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៤, កិច្ចប្រជុំប្រធានតុលាការកំពូលអាស៊ានជាមួយតុលាការកំពូលនៃសាធារណរដ្ឋប្រជាមានិតចិន តុលាការកំពូលជប៉ុន និងតុលាការកំពូល នៃសាធារណរដ្ឋកូរ៉េ ហៅកាត់ថា កិច្ចប្រជុំអាស៊ានបូក (ASEAN+Meeting) និងកិច្ចប្រជុំលើកទី១ នៃចៅក្រមជំនាញខាងក្សេមធន នៅទីក្រុងសេប៊ូនៃសាធារណរដ្ឋហ្វីលីពីន។ ជាលទ្ធផល នៃកិច្ចប្រជុំនេះ «**សេចក្តីប្រកាសទីក្រុងសេប៊ូ**» ត្រូវបានចុះហត្ថលេខា ដើម្បីបន្តជំរុញកិច្ចសហប្រតិបត្តិការក្នុងវិស័យតុលាការតាមរយៈក្រុមការងារជំនាញនៃក្រុមប្រឹក្សាប្រធានតុលាការកំពូលអាស៊ាន។

- ឯកឧត្តម **ជឹម គេង** ប្រធានតុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូតុលាការកំពូល, ប្រធានសាលាឧទ្ធរណ៍តំបន់ដែលមានសមត្ថកិច្ចដែនដីនៅខេត្តដាប់ព្រំដែន, ប្រធានសាលាដំបូងខេត្តដាប់ព្រំដែនកម្ពុជា វៀតណាម និងឡាវ ចូលរួមក្នុងសន្និសីទតុលាការនៃបណ្តាខេត្តដាប់ព្រំដែនលើកទី៧ ដែលបានប្រព្រឹត្តទៅនៅទីក្រុងហូយអាន ខេត្តក្វាងណាម ប្រទេសវៀតណាម ពីថ្ងៃទី១៨-១៩ ខែកក្កដា ឆ្នាំ២០២៤។ ដោយយល់ឃើញពីភាពចាំបាច់ និងប្រសិទ្ធភាពក្នុងការអនុវត្តសេចក្តីប្រកាសរួមលើកទី**៦** អង្គសន្និសីទបានឯកភាពចុះហត្ថលេខាលើ «**សេចក្តីប្រកាសរួមលើកទី៧**» ដើម្បីបន្តពង្រឹងកិច្ចសហប្រតិបត្តិការ

រវាងប្រទេសទាំងបីជាបន្តទៀត ក្នុងគោលដៅធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ស្ថិរភាព និងសេចក្តីសុខសាន្តរបស់ប្រជាពលរដ្ឋតាមបណ្តាខេត្តជាប់ព្រំដែននៃប្រទេសទាំងបី។

- តុលាការកំពូលបានចាត់តំណាងឱ្យទៅចូលរួមក្នុងកិច្ចប្រជុំអន្តរជាតិចំនួន ៨លើក និងចូលរួមកិច្ចប្រជុំតាម Online ចំនួន ៥លើក។

- មហាអយ្យការអមតុលាការកំពូល បានទទួលរៀបចំ **«ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការ រវាងមហាអយ្យការអមតុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជា និងអយ្យការប្រជាជនតុលាការកំពូលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ»** នៅមហាអយ្យការអមតុលាការកំពូល នៅថ្ងៃទី៣០ ខែកក្កដា ដល់ថ្ងៃទី៣ ខែសីហា ឆ្នាំ២០២៤។

- លោកជំទាវ **ជា លាង** អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលបានដឹកនាំគណៈប្រតិភូ ចូលរួមប្រជុំវេទិកាសេដ្ឋកិច្ចបូព៌ា (EEF) នៅទីក្រុង Vladivostock សហព័ន្ធ**រុស្ស៊ី** និង **«ចុះអនុស្សរណៈនៃការយោគយល់គ្នារវាងមហាអយ្យការអមតុលាការកំពូល និងការិយាល័យអគ្គរដ្ឋអាជ្ញានៃសហព័ន្ធរុស្ស៊ី»** នៅថ្ងៃទី១ ដល់ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២៤, ចូលរួមក្នុងសន្និសីទអគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន នៅប្រទេសសិង្ហបុរី ក្រោមប្រធានបទ **«ការជំរុញកិច្ចសហប្រតិបត្តិការលើការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មហិរញ្ញវត្ថុ»** នៅថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៤, ចូលរួមជាវាគ្មិនចែករំលែកបទពិសោធន៍លើប្រធានបទ អន្តរយុត្តិធម៌ នាសម័យប្រជុំពេញអង្គសភា អន្តរជាតិដើម្បីភាពអត់ឱននិងសន្តិភាព (IPTP) លើកទី១១ នៅសណ្ឋាគារសុខាភ្នំពេញ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤។

- ឯកឧត្តម **ជាន់ វណ្ណវ័ត្ន** អគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល និងជាតំណាងលោកជំទាវអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលបានចូលរួមកិច្ចប្រជុំអន្តរជាតិចំនួន ២លើក និងបានដឹកនាំរៀបចំកិច្ចប្រជុំពិភាក្សានិងពិគ្រោះយោបល់លើកទី៣ ស្តីពី**«ការបង្កើតអង្គភាព ឬស្ថាប័នព្រះរាជអាជ្ញាអាស៊ានទាំង១០ប្រទេស»** នៅខេត្តសៀមរាប ថ្ងៃទី២៩ ខែវិច្ឆិកា ដល់ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៤។

២- សមិទ្ធផលការងារ

ក- មហាអយ្យការអមតុលាការកំពូល

- ចំណាត់ការលើសំណុំរឿង

បានទទួលសំណុំរឿងព្រហ្មទណ្ឌដើម្បីធ្វើសេចក្តីសន្និដ្ឋានចំនួន **១.០៧៣** , កោះហៅឱ្យចូលរួមជំនុំជម្រះចំនួន **១.១៦២** ,បានទទួលសំណុំរឿងព្រហ្មទណ្ឌសើរើចំនួន **៤២** ,បានទទួលសំណុំរឿងព្រហ្មទណ្ឌធ្វើសារណាចំនួន **២១** ,ចូលរួមជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌបានចំនួន **៩៦២** និងចូលរួមជំនុំជម្រះសំណុំរឿងរដ្ឋប្បវេណីចំនួន **៥៤២** ។

បានទទួលសាលដីកាព្រហ្មទណ្ឌរបស់តុលាការកំពូលចំនួន **៩១៩** និងបានបញ្ជូនសាលដីកាច្បាប់ចម្លង ទៅ ៖ ក្រសួងយុត្តិធម៌ចំនួន **៩១៩** ,អយ្យការអមសាលាដំបូងរាជធានី-ខេត្តចំនួន **៩១៩** , អគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃចំនួន **៣២២** ,ពន្ធនាគារម១ (ព្រៃស) ចំនួន **១៣៩**, ពន្ធនាគារ ម២ (ព្រៃស) ចំនួន **៤៨**, ពន្ធនាគាររាជធានីភ្នំពេញ (PJ) ចំនួន **២៥** ,ពន្ធនាគារ ម៣ (ត្រពាំងថ្លឹង) ចំនួន **១៨**, , ពន្ធនាគារ ម៤ (ម៤) ចំនួន **២**, ពន្ធនាគារខេត្ត ចំនួន **៤៤**, បានធ្វើដីកាដោះលែងជនជាប់ឃុំ ចំនួន **៣៥** នាក់ និងធ្វើដីកាបញ្ឈប់ចាប់ខ្លួន ចំនួន **១** នាក់ ។

បានទទួលសាលដីកាព្រហ្មទណ្ឌពីសាលាឧទ្ធរណ៍សរុបចំនួន **៥.១០០** (សាលាឧទ្ធរណ៍ភ្នំពេញចំនួន **២.៩២៣**, សាលាឧទ្ធរណ៍ព្រះសីហនុចំនួន **៣៩៥**, សាលាឧទ្ធរណ៍បាត់ដំបងចំនួន **១.០៨១** និងសាលាឧទ្ធរណ៍ត្បូងឃ្មុំចំនួន **៧០១**) ក្នុងនោះមានសាលដីកាហួសរយៈពេលប្តឹងសាទុក្ខរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលចំនួន **២២៩** និងសាលដីកាមិនទាន់ហួសរយៈពេលប្តឹងសាទុក្ខចំនួន **៤.៨៧១** សាលដីកា។

អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូលបានធ្វើបណ្តឹងសាទុក្ខ ចំពោះសាលដីកាសការសើបសួរ និងសាលដីកាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍សរុបចំនួន **២៦**សាលដីកា ក្នុងនោះសាលាឧទ្ធរណ៍ភ្នំពេញចំនួន **១៤**សាលដីកា, សាលាឧទ្ធរណ៍ព្រះសីហនុចំនួន **២**សាលដីកា, សាលាឧទ្ធរណ៍បាត់ដំបងចំនួន **៤**សាលដីកា និងសាលាឧទ្ធរណ៍ត្បូងឃ្មុំចំនួន **៦**សាលដីកា។

- **ការងារបញ្ជូនសាលដីកា** ៖ បានបញ្ជូនសាលដីកាព្រហ្មទណ្ឌច្បាប់ចម្លងទៅក្រសួងយុត្តិធម៌ចំនួន **៩១៩**, អយ្យការអមសាលាដំបូងរាជធានី-ខេត្តចំនួន **៩១៩**, អគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃចំនួន **៣២២**, ពន្ធនាគារ១(ព្រៃស)ចំនួន **១៣៩**, ពន្ធនាគារ២(ព្រៃស)ចំនួន **៤៨**, ពន្ធនាគាររាជធានីភ្នំពេញ(PJ)ចំនួន **២៥**, ពន្ធនាគារ៣(ត្រពាំងផ្លុង)ចំនួន **១៨** និងពន្ធនាគារខេត្តចំនួន **៤៤**។

- មហាអយ្យការអមតុលាការកំពូលបានចេញសេចក្តីសម្រេចចំនួន ៣ ពាក់ព័ន្ធនឹងការរៀបចំគណៈមេប្រយោគប្រឡងសញ្ញាបត្រជាន់ខ្ពស់មន្ត្រីនគរបាលយុត្តិធម៌ និងចាត់អគ្គព្រះរាជអាជ្ញារងចូលរួមក្នុងគណៈកម្មការវិសោធនកម្មច្បាប់។

ខ- តុលាការកំពូល

ខ.១- លទ្ធផលការងាររបស់សភាព្រហ្មទណ្ឌ និងសភាពេញអង្គ

សំណុំរឿង	សំណុំរឿង សល់ពីឆ្នាំ២០២៣	សំណុំរឿង ចូលថ្មី	សំណុំរឿង ចាត់ការរួច	សំណុំរឿង កំពុងចាត់ការ
អង្គសេចក្តី (សាទុក្ខលើកទី១)	៣៥៦	៩៣៨	៨១៩	៤៧៥
អង្គសេចក្តី (សាទុក្ខលើកទី២)	១៩	៥៤	៤១	៣២
មុនអង្គសេចក្តី	២៩	១៥៣	១៥៩	២៣
ស្រូបទោស	៩	៣៣	៣៧	៥
សើរើ	២៦	៦៣	៤៧	៤២
សរុប	**៤៣៩**	**១.២៤១**	**១.១០៣**	**៥៧៧**

ខ.២- លទ្ធផលការងាររបស់សភាវិជ្ជាវេណី និងសភាពេញអង្គ

សំណុំរឿង	សំណុំរឿង សល់ពីឆ្នាំ២០២៣	សំណុំរឿង ចូលថ្មី	សំណុំរឿង ចាត់ការរួច	សំណុំរឿង កំពុងចាត់ការ
អង្គសេចក្តី (សាទុក្ខលើកទី១)	២៥៦	៥០៤	៤៨៦	២៧៤
អង្គសេចក្តី (សាទុក្ខលើកទី២)	៦៣	៦៤	៦៦	៦១
មុនអង្គសេចក្តី (បណ្តឹងជំទាស់)	២៥	៨៥	៨២	២៨
ជំនុំជម្រះសាជាថ្មី	៥៤	១០៣	១៣៤	២៣
ដិតចិត្តចៅក្រម	១	៥	៦	០
សរុប	**៣៩៩**	**៧៦១**	**៧៧៤**	**៣៨៦**

ខ.៣- កិច្ចការផ្សេងៗទៀតរបស់តុលាការកំពូល

- តុលាការកំពូលបានជ្រើសរើសសេចក្តីសម្រេចរដ្ឋប្បវេណី និងព្រហ្មទណ្ឌដើម្បីចងក្រងជាព្រឹត្តិបត្រសាលដីកាបានចំនួន២ឆមាស គឺព្រឹត្តិបត្រឆមាសទី១ និងព្រឹត្តិបត្រ ឆមាសទី២ ដើម្បីធ្វើការផ្សព្វផ្សាយ។

- តុលាការកំពូលបានចេញសេចក្តីសម្រេច ដីកាសម្រេច និងសេចក្តីណែនាំចំនួន **១៦** រួមមាន៖

+សេចក្តីសម្រេចមានជាអាទិ៍ សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារសិក្សា និងជ្រើសរើសបញ្ហាវិវាទអំពីច្បាប់អនុវត្តនៅតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល, សេចក្តីសម្រេចស្តីពីការកែសម្រួលសមាសភាព និងតួនាទីក្រុមអធិការកិច្ចផ្ទៃក្នុងរបស់តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល, សេចក្តីសម្រេចស្តីពីការបន្ថែមសមាសភាពក្រុមការងារអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យា, សេចក្តីសម្រេច ស្តីពីការកែសម្រួលសេចក្តីសម្រេចពាក់ព័ន្ធនឹងកិច្ចការអន្តរជាតិ, សេចក្តីសម្រេចស្តីពីការបង្កើតក្រុមជំនួយការនៃក្រុមការងារសម្របសម្រួលកិច្ចការអន្តរជាតិ, សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារតុលាការកម្ពុជាជំនាញ, សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារដើម្បីដុតបំផ្លាញឯកសារ សំណុំរឿងរដ្ឋប្បវេណីចន្លោះឆ្នាំ១៩៩៤ ដល់ឆ្នាំ២០០០។

+ដីកាសម្រេចមានជាអាទិ៍ ដីកាសម្រេចស្តីពីការចាត់តាំងចៅក្រមឱ្យបំពេញការកិច្ចក្នុងសភារដ្ឋប្បវេណី, ដីកាសម្រេចស្តីពីការចាត់តាំងចៅក្រមឱ្យបំពេញការកិច្ចក្នុងសភាព្រហ្មទណ្ឌ, ដីកាសម្រេចស្តីពីការចាត់តាំងប្រធានអង្គជំនុំជម្រះលើរឿងក្តីរដ្ឋប្បវេណី, ដីកាសម្រេចស្តីពីការចាត់តាំងប្រធានអង្គជំនុំជម្រះលើរឿងក្តីព្រហ្មទណ្ឌ។ល។

+សេចក្តីណែនាំ មានជាអាទិ៍ សេចក្តីណែនាំស្តីពីការជ្រើសរើសសេចក្តីសម្រេចដើម្បីចងក្រងព្រឹត្តិបត្រសាលដីកាតុលាការកំពូល, សេចក្តីណែនាំស្តីពីការរៀបចំតាក់តែងកំណត់ហេតុនៃការជំនុំជម្រះនៅតុលាការកំពូល, សេចក្តីណែនាំស្តីពីការតាក់តែងទម្រង់ឯកសារនៅតុលាការកំពូល។

៣- បញ្ហាប្រឈម

៣.១- កង្វះខាតធនធានជាច្រើន ដូចជា ធនធានសម្ភារៈ ឧបករណ៍បច្ចេកវិទ្យាព័ត៌មាន រួមទាំងធនធានមនុស្ស ជាអាទិ៍ អ្នកបកប្រែភាសាបរទេស មន្ត្រីជំនាញព័ត៌មានវិទ្យា និងមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន។ អគារសម្រាប់បំពេញការងារបច្ចុប្បន្ននៅមិនទាន់សមស្របនឹងទំហំការងារដែលកើនឡើងជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ។

៣.២- ការបញ្ជូនសាលដីកាមួយចំនួនពីសាលាឧទ្ធរណ៍មក គឺផុតរយៈពេលប្តឹងសាទុក្ខ។ សាលដីកាខ្លះទៀតត្រូវបានបញ្ជូនមកកៀកថ្ងៃផុតកំណត់ប្តឹងសាទុក្ខ ដែលជាហេតុនាំឱ្យមហាអយ្យការពុំអាចចាត់ការបានទាន់ពេលវេលា។ ការបញ្ជូនសាលដីការបស់តុលាការកំពូលទៅអគ្គនាយកដ្ឋានពន្ធនាគារ នៅមានបញ្ហាប្រឈមនៅឡើយ ដោយហេតុថា អគ្គនាយកដ្ឋានពន្ធនាគារពុំបានគ្រប់គ្រងទិន្នន័យសាលដីកាឱ្យបានច្បាស់លាស់ ពេលខ្លះបានធ្វើរបាយការណ៍មកតុលាការកំពូលបញ្ជាក់ថា ខ្វះសាលដីកា ហើយពុំបានភ្ជាប់មកជាមួយនូវលេខសំណុំរឿង ឈ្មោះជនជាប់ចោទ ថ្ងៃខែឆ្នាំដំនុំជម្រះឱ្យបានច្បាស់លាស់។

៣.៣- បញ្ហាប្រឈមនិងដំណោះស្រាយទាក់ទងនឹងការអនុវត្តច្បាប់សារធាតុនិងច្បាប់នីតិវិធីមានដូចជា៖

ក- កិច្ចការរដ្ឋប្បវេណី

ក.១- ការបែងចែកកម្មសិទ្ធិអវិភាគ

ក្នុងការអនុវត្តជាក់ស្តែង នៅពេលមានការទាមទារបែងចែកទ្រព្យសម្បត្តិពាក់កណ្តាលម្នាក់ ឬស្មើគ្នា រវាងសហព័ន្ធ ឬអនីតិសង្វាស ឬម្ចាស់កម្មសិទ្ធិអវិភាគ ឬសហសន្តិជន ឃើញថា ចៅក្រមតែងតែចេញសេចក្តីសម្រេចបញ្ចប់ឱ្យធ្វើការបែងចែងដី ឬផ្ទះ ឬទ្រព្យសម្បត្តិផ្សេងទៀត ស្មើគ្នា ឬក្នុងចំណែកស្មើគ្នា ឬតាមចំណែកជាភាគ(១/៣ឬ១/៥)ជាដើម សេចក្តីសម្រេចបែបនេះ មានករណីខ្លះមិនអាចអនុវត្តបានទេ។

ចំពោះដំណោះស្រាយលើបញ្ហាប្រឈមខាងលើនេះ អង្គសន្និបាតបានសម្រេចជាឯកច្ឆន្ទថា តុលាការត្រូវពិចារណាអនុវត្តបទប្បញ្ញត្តិនៃមាត្រា២១២ (វិធីបែងចែកវត្ថុកម្មសិទ្ធិអវិភាគ) នៃក្រមរដ្ឋប្បវេណី និងលើសពីនេះទៀត ពាក់ព័ន្ធនឹងបណ្តឹងក្នុងរឿងក្តីនៃហានៈបុគ្គល តុលាការត្រូវមានភាពសកម្ម ដូចជា៖

- ត្រូវកំណត់ឱ្យបានច្បាស់លាស់ជាមុនសិនថា តើចំណុចវិវាទពាក់ព័ន្ធនឹងការកំណត់ចំណែក ឬការបែងចែកទ្រព្យសម្បត្តិជាក់ស្តែង។

- អាចប្រើសិទ្ធិឱ្យបំភ្លឺ តាមមាត្រា៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដើម្បីបញ្ជាក់ឱ្យច្បាស់ថា តើវិវាទនេះពាក់ព័ន្ធនឹងការកំណត់ចំណែក ឬជាការបែងចែកទ្រព្យសម្បត្តិជាក់ស្តែង។

- ក្នុងករណីជាវិវាទនៃការបែងចែកទ្រព្យសម្បត្តិជាក់ស្តែង អនុវត្តតាមមាត្រា២១២ នៃក្រមរដ្ឋប្បវេណី និងបញ្ញត្តិពាក់ព័ន្ធដូចបានរៀបរាប់ខាងលើ។

ក.២- សំអាងហេតុ និងសេចក្តីសម្រេចក្នុងរឿងរដ្ឋប្បវេណី

តាមរយៈការដោះស្រាយរឿងក្តីនៅតុលាការកំពូល យើងសង្កេតឃើញថា សំអាងហេតុ និងសេចក្តីសម្រេចបញ្ចប់មួយចំនួននៅមានបញ្ហានៅឡើយ ដូចជា ការសរសេរពាក្យពេចន៍ អក្ខរាវិរុទ្ធ លេខ មិនទាន់បានត្រឹមត្រូវ, ការសរសេរសំអាងហេតុមិនបានវាយតម្លៃលើកស្តុតាងដើម្បីទទួលស្គាល់អង្គហេតុ ដែលជាចំណុចវិវាទ, ពុំមានសំអាងហេតុអំពីអង្គច្បាប់, មានភាពផ្ទុយគ្នា, មិនតាមលំដាប់លំដោយ, ការសរសេរសេចក្តីសម្រេចផ្ទុយនឹងគោលការណ៍នៃសិទ្ធិចាត់ចែង, ផ្ទុយនឹងបទប្បញ្ញត្តិ “ការចាត់ទុកថា បានបង្ហាញឆន្ទៈ”, ធ្វើឱ្យមានការបកស្រាយក្នុងការអនុវត្ត, មិនបញ្ចប់វិវាទ, មិនស្របនឹងវិសាលភាពនៃបុគ្គលដែលត្រូវទទួលអានុភាពនៃសាលក្រមស្តាពរ, និងមិនអាចអនុវត្តបាន តាមចំណុច ក កថាខណ្ឌទី២ មាត្រា៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ចំពោះដំណោះស្រាយលើបញ្ហាប្រឈមខាងលើនេះ អង្គសន្និបាតបានសម្រេចជាឯកច្ឆន្ទថា៖

ក.២.១- តុលាការត្រូវយកចិត្តទុកដាក់សរសេរសំអាងហេតុឱ្យបានត្រឹមត្រូវ ដូចខាងក្រោម៖

- ប្រើប្រាស់ពាក្យពេចន៍ច្បាស់លាស់ សរសេរអក្ខរាវិរុទ្ធឱ្យបានត្រឹមត្រូវតាមវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត និងវចនានុក្រមខ្មែរឆ្នាំ២០២២។ សរសេរលេខ និងអក្សរបញ្ជាក់ចំនួនលេខឱ្យបានត្រឹមត្រូវតាមច្បាប់។

- រៀបចំការអះអាង កំណត់ចំណុចវិវាទ រៀបចំកស្តុតាងឱ្យបានត្រឹមត្រូវតាមមាត្រា១០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ តុលាការត្រូវកំណត់ឱ្យច្បាស់លាស់នូវភាគីដែលត្រូវទទួលបន្ទុកក្នុងការបញ្ជាក់កស្តុតាង ហើយធ្វើការវាយតម្លៃកស្តុតាងឱ្យបានត្រឹមត្រូវដោយមិនគ្រាន់តែចម្លងចម្លើយរបស់ភាគី សាក្សី ... ហើយថាអាចពិចារណាបាន ឬមិនអាចពិចារណាបាននោះទេ។

- ត្រូវមានសំអាងហេតុអំពីអង្គច្បាប់ដើម្បីទទួលស្គាល់អត្ថិភាព ឬនត្ថិភាពនៃសិទ្ធិទាមទារឱ្យបានច្បាស់លាស់។

- សំអាងហេតុមិនត្រូវមានភាពផ្ទុយគ្នា និងសំអាងហេតុមិនត្រូវផ្ទុយនឹងសេចក្តីសម្រេច។

- សរសេរសំអាងហេតុតាមលំដាប់លំដោយ គប្បីយល់ឃើញអំពីករណីផ្សេងៗដូចជា អវត្តមានភាគី ការសុំពន្យារពេលសវនាការជាមុន មុននឹងធ្វើការវិនិច្ឆ័យដល់អង្គសេចក្តី។ មិនគប្បីទទួលស្គាល់ការទាមទារជាមុនដោយមិនទាន់បានទទួលស្គាល់អង្គហេតុដោយផ្អែកលើកស្តុតាងតាមមាត្រា១២៣ និងមាត្រា១៨៤ នោះទេ។

ក.២.២- តុលាការត្រូវយកចិត្តទុកដាក់សរសេរសេចក្តីសម្រេចឱ្យបានត្រឹមត្រូវ ដូចខាងក្រោម៖

- សរសេរសេចក្តីសម្រេច ដោយគោរពតាមគោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគី តាមមាត្រា១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

- មិនត្រូវសរសេរសេចក្តីសម្រេចដែលបង្គាប់ឱ្យមន្ទីររៀបចំដែនដីធ្វើនីតិវិធីចុះបញ្ជី និងមិនត្រូវប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នពាក់ព័ន្ធនឹងការចុះបញ្ជីនោះទេ ព្រោះផ្ទុយនឹងបទប្បញ្ញត្តិ "ការចាត់ទុកថាបានបង្ហាញឆន្ទៈ" តាមមាត្រា ៥២៩នៃក្រមនីតិវិធីរដ្ឋប្បវេណី។

- មិនត្រូវសរសេរសេចក្តីសម្រេចដែលធ្វើឱ្យមានការបកស្រាយក្នុងការអនុវត្តដូចជា សម្រេចឱ្យចុងចម្លើយចាកចេញ ប៉ុន្តែត្រូវសម្រេចបង្គាប់ឱ្យចុងចម្លើយប្រគល់ដី (សញ្ញាណនៃដី) ដែលត្រូវអនុវត្តតាមមាត្រា៥២៤ (ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ)។

- មិនត្រូវចេញសេចក្តីសម្រេចដែលមិនអាចអនុវត្តបាន និងមិនបញ្ចប់វិវាទរបស់គូភាគី ដូចជាសម្រេចប្រគល់ដីដែលមានទំហំ ឬទីតាំងមិនច្បាស់លាស់ ដូច្នេះត្រូវមានគំនូសបង្ហាញទីតាំង និងទំហំដីទំនាស់ច្បាស់លាស់ ដោយអនុវត្តនូវសិទ្ធិបំភ្លឺតាមមាត្រា៩០, ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ កថាខណ្ឌទី២ មាត្រា១២៤, ការពិនិត្យភស្តុតាងដោយការត្រួតពិនិត្យតាមមាត្រា១៦១ ជាដើម។

- មិនត្រូវចេញសេចក្តីសម្រេចដែលមិនអាចអនុវត្តបានដូចជាបង្គាប់ឱ្យចុងចម្លើយអនុវត្តតាមកិច្ចសន្យាដែលមិនស្របនឹងចំណុច ក កថាខណ្ឌទី២ មាត្រា៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

- មិនត្រូវសម្រេចសេចក្តីដោយភ្ជាប់ឈ្មោះមេធាវីតំណាងដោយអាណត្តិជាមួយឈ្មោះភាគីនោះទេ ព្រោះមិនស្របនឹងវិសាលភាពនៃបុគ្គលដែលត្រូវទទួលអានុភាពរបស់សាលក្រមស្តាពរ ដូចក្នុងមាត្រា ១៩៨ និងមាត្រា៣៥១ នៃក្រមដដែល។

ក.៣- ការប្រើប្រាស់នីតិវិធី តាមប្រភេទបណ្តឹង ឬពាក្យសុំ និងការបង់ពន្ធលើបណ្តឹងសាទុក្ខ

ក.៣.១- ការប្រើប្រាស់នីតិវិធី តាមប្រភេទនៃបណ្តឹង ឬពាក្យសុំ

តាមការកំណត់សម្គាល់របស់តុលាការកំពូលកន្លងមក ឃើញថា ការទាមទាររបស់ភាគីក្នុងរឿងក្តីរដ្ឋប្បវេណី និងការប្រើប្រាស់នីតិវិធីដោះស្រាយរឿងក្តីរបស់តុលាការអង្គសេចក្តីមួយចំនួន ធ្វើឡើងមិនបានត្រឹមត្រូវស្របតាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី, ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល និងច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលជាហេតុនាំឱ្យកើតមាន ផលវិបាកគតិយុត្ត ដូចជា៖ ការដោះស្រាយរឿងក្តីមានភាពយឺតយ៉ាវ ការកើនឡើងនូវបន្ទុកចំណាយរបស់គាគី និងការបាត់ជំនឿទុកចិត្តមកលើស្ថាប័នតុលាការ ជាដើម ដោយមូលហេតុ ក.ការលុបចោល ឬបដិសេធនូវសេចក្តីសម្រេច និងលើកចោលនូវពាក្យបណ្តឹងឬពាក្យសុំ និងខ.ការលុបចោល ឬបដិសេធ នូវសេចក្តីសម្រេច និងបញ្ជូនសំណុំរឿងត្រឡប់

ទៅតុលាការដើមវិញ ដោយតុលាការនៃបណ្តឹងឧបាស្រ័យ ដោយហេតុថា នីតិវិធីដោះស្រាយរឿងក្តីរបស់តុលាការដើម ផ្ទុយនឹងច្បាប់ធ្ងន់ធ្ងរ។

ចំពោះបញ្ហាប្រឈមនេះ អង្គសន្និបាតបានយល់ស្របគ្នាថា មានភាពចាំបាច់ក្នុងការរៀបចំដាទម្រង់គំរូទៅតាមប្រភេទនៃបណ្តឹងឬពាក្យសុំ ហើយមន្ត្រីលេខាធិការដ្ឋានដែលទទួលការបណ្តុះបណ្តាលត្រឹមត្រូវមានភារកិច្ចពន្យល់ដល់ភាគីលើការប្រើប្រាស់ទម្រង់គំរូនេះ។ ក្រៅពីនេះ ប្រសិនបើមានការដាក់ពាក្យសុំ ឬពាក្យបណ្តឹងមិនត្រឹមត្រូវតាមប្រភេទនៃពាក្យសុំ ឬបណ្តឹង តុលាការអាចពិចារណាលើជម្រើស៣យ៉ាងទៅតាមស្ថានភាពនីមួយៗ៖

(១) ចៅក្រមទទួលបន្ទុកណែនាំអ្នកដាក់ពាក្យបណ្តឹង ឬពាក្យសុំអំពីប្រភេទនៃនីតិវិធីដោះស្រាយចំពោះការទាមទារ ហើយប្រសិនបើមិនដកពាក្យបណ្តឹង ឬពាក្យសុំ តុលាការសម្រេចតាមមាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

(២) ចៅក្រមទទួលបន្ទុកបង្គាប់ឱ្យអ្នកដាក់ពាក្យបណ្តឹង ឬពាក្យសុំកែតម្រូវពាក្យបណ្តឹង ឬពាក្យសុំនោះតាមកថាខណ្ឌទី១ មាត្រា៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី និងសម្រេចលើកចោលពាក្យបណ្តឹង ឬពាក្យសុំនោះដោយដីកាសម្រេច តាមបញ្ញត្តិកថាខណ្ឌទី២ មាត្រា៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រសិនបើមិនមានការកែតម្រូវ។

(៣) ផ្ទេរនីតិវិធីបណ្តឹងតាមដីកាសម្រេច ទៅនីតិវិធីដែលត្រឹមត្រូវ តាមការបកស្រាយប្រដូចនឹងមាត្រា ៣២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ក្នុងករណីនេះ តុលាការត្រូវសម្រេចលើការបង្គាប់ឱ្យបង់ប្រាក់ពន្ធបន្ថែមឱ្យបានត្រឹមត្រូវតាមមាត្រា៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ក.៣.២- ការបង់ពន្ធលើបណ្តឹងសាទុក្ខ

កន្លងមក នៅពេលដាក់ពាក្យបណ្តឹងសាទុក្ខលើកទី២ចំពោះសាលដីការបស់សាលាឧទ្ធរណ៍ ដែលសម្រេចលើសំណុំរឿងដែលត្រូវបានបញ្ជូនទៅសាលាឧទ្ធរណ៍ឱ្យជំនុំជម្រះឡើងវិញ (មាត្រា២៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី) តុលាការកំពូលសង្កេតឃើញថា ដើមបណ្តឹងសាទុក្ខលើកទី២ មិនត្រូវបានបង្គាប់ឱ្យបង់ប្រាក់ពន្ធចំពោះការដាក់ពាក្យបណ្តឹងសាទុក្ខលើកទី២នេះទេ។

អង្គសន្និបាតបានយល់ស្របគ្នាលើដំណោះស្រាយថា តាមខ្លឹមសារនៃកថាខណ្ឌទី៣ មាត្រា៦១ និងការអនុវត្តដូចគ្នាតាមបញ្ញត្តិនៃ មាត្រា២៧៣ និងមាត្រា២៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដើមបណ្តឹងសាទុក្ខលើកទី២ ត្រូវបង់ពន្ធចំពោះការដាក់ពាក្យបណ្តឹងសាទុក្ខ។ **ប៉ុន្តែ ទោះបីជាយ៉ាងណា ការណ៍នេះមិនរារាំងការអនុវត្តបញ្ញត្តិនៃមាត្រា៦៩ (ការផ្តល់ជំនួយសង្គ្រោះលើបណ្តឹង) នៃក្រមនីតិវិធីរដ្ឋប្បវេណីឡើយ។**

ខ- អតិថិការព្រហ្មទណ្ឌ

ខ.១- សំអាងហេតុ និងសេចក្តីសម្រេចក្នុងរឿងព្រហ្មទណ្ឌ

យើងក៏សង្កេតឃើញថា សំអាងហេតុ និង សេចក្តីសម្រេចបញ្ចប់មួយចំនួនក្នុងរឿងព្រហ្មទណ្ឌ ក៏នៅមានបញ្ហានៅឡើយ ដូចជា ការសរសេរពាក្យពេចន៍ អក្ខរាវិរុទ្ធ លេខ មិនទាន់បានត្រឹមត្រូវ, ការសរសេរសំអាងហេតុមិនបានវាយតម្លៃលើកស្តុតាងដែលមានក្នុងសំណុំរឿង, សំអាងហេតុអំពីអង្គច្បាប់ មិនត្រឹមត្រូវ, មានភាពផ្ទុយគ្នា, មិនតាមលំដាប់លំដោយ, ការសរសេរសេចក្តីសម្រេចមិនចុះនិទ្ទេស "កថាខណ្ឌ", មិនពិន័យជាប្រាក់ក្នុងករណីដែលច្បាប់តម្រូវ, ការផ្តល់ស្ថានសម្រាលមិនស្របតាម មាត្រា៣២ និងមាត្រា៣៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ដំណោះស្រាយលើបញ្ហាប្រឈមខាងលើនេះ អង្គសន្និបាតបានយល់ស្របគ្នាថា៖

(១)- តុលាការត្រូវយកចិត្តទុកដាក់សរសេរសំអាងហេតុឱ្យបានត្រឹមត្រូវ ដូចខាងក្រោម៖

- សរសេរពាក្យពេចន៍, អក្ខរាវិរុទ្ធ និងលេខ តាមវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត, វចនានុក្រមខ្មែរឆ្នាំ២០២២ និងមាត្រាច្បាប់ជាធរមាន ដូចជា មាត្រា២១៥ នៃក្រមព្រហ្មទណ្ឌ និងកាលបរិច្ឆេទកំណើត តាមមាត្រា៣៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយមិនត្រូវសរសេរអាយុទេ។

- មិនត្រូវសរសេរសំអាងហេតុ ដោយប្រើពាក្យមិនច្បាស់លាស់ដូចជាពាក្យ វាមិនទំនងជា...” ហាក់ដូចជា...” ជាដើម

- សរសេរសំអាងហេតុតាមវិធីវាយតម្លៃកស្តុតាងដែលមាននៅក្នុងសំណុំរឿង គប្បីស្រង់នូវខ្លឹមសារ ហើយវាយតម្លៃអំពីភាពត្រឹមត្រូវឬមិនត្រឹមត្រូវដោយផ្អែកលើភាពស៊ីចង្វាក់នៃកស្តុតាងច្បាស់លាស់ផ្សេងៗទៀត ជាដើម ដោយមិនគប្បីគ្រាន់តែចម្លងរបាយការណ៍, ចម្លើយ... ហើយថា អាចពិចារណាបាន ឬមិនអាចពិចារណាបាននោះទេ។

- សរសេរអំពីអង្គច្បាប់ឱ្យបានត្រឹមត្រូវ ដើម្បីផ្តន្ទាទោសលើជនជាប់ចោទ។ ឧទាហរណ៍ បទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តុលាការត្រូវតែសំអាងហេតុពាក់ព័ន្ធនឹងអំពើប្រព្រឹត្តត្រូវនឹងកថាខណ្ឌណាមួយនៃមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

- សរសេរកំណត់ឈ្មោះបទល្មើសឱ្យបានច្បាស់លាស់ ដោយមិនត្រូវប្រើពាក្យ “ឬ” នោះទេ។ ឧទាហរណ៍ មិនត្រូវសរសេរថាបទហិង្សាដោយចេតនាប្រព្រឹត្តដោយសហព័ទ្ធ ឬអនីតិសង្វាសជន។

- មិនត្រូវសរសេរសំអាងហេតុផ្ទុយគ្នា ឬសំអាងហេតុផ្ទុយនឹងសេចក្តីសម្រេចនោះឡើយ។

(២)- តុលាការត្រូវយកចិត្តទុកដាក់សរសេរសេចក្តីសម្រេច ឱ្យបានត្រឹមត្រូវ ដូចខាងក្រោម៖

- ត្រូវចុះនិទ្ទេស “កថាខណ្ឌ” ស្របតាមមាត្រា ៤០ (ច.ត.គ.ញ)

- ការពិន័យជាប្រាក់ត្រូវអនុវត្តតាមមាត្រា ២៧ (ការអនុវត្តបទប្បញ្ញត្តិទូទៅនៃក្រមព្រហ្មទណ្ឌ) (ច.ត.គ.ញ), មាត្រា ២៨ (ការប្រកាសមូលទោស) (ច.ត.គ.ញ), មាត្រា ៦៦៨ (ការអនុវត្តបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែក) (ក.ព្រ.ទ)

- ការផ្តល់ស្ថានសម្រាលពាក់ព័ន្ធនឹងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមមាត្រា ៣២ (ច.ត.គ.ញ) ស្ថានសម្រាលតែក្នុងករណីពិសេស⩽ មាត្រា ៣៣ (ច.ត.គ.ញ) មិនឱ្យអនុវត្តមាត្រា ៩៣, ៩៤, ៩៥ នៃ(ក.ព្រ.ទ)ចំពោះបទឧក្រិដ្ឋទាំងឡាយដែលមានចែងក្នុង (ច.ត.គ.ញ)។

ខ.២- ការគណនាអំឡុងពេលក្នុងនីតិវិធីព្រហ្មទណ្ឌ

ដោយហេតុថា ក្រមនីតិវិធីព្រហ្មទណ្ឌមិនបានចែងពីរបៀបគណនាអំឡុងពេល ឬរយៈពេល ដែលត្រូវបានកំណត់នៅក្នុងរឿងព្រហ្មទណ្ឌទេ គឺមានតែមាត្រា៤៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៥០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងពីរបៀបនៃការគណនាថិរវេលានៃទោសដាក់ពន្ធនាគារប៉ុណ្ណោះ។

នៅក្នុងការអនុវត្តជាក់ស្តែង ការគណនាអំឡុងពេល ឬរយៈពេលនៃការប្តឹងឧទ្ធរណ៍ ឬការប្តឹងសាទុក្ខនៅក្នុងរឿងព្រហ្មទណ្ឌ មិនត្រូវបានធ្វើឡើងស្របគ្នាជាមួយនឹងការគណនាអំឡុងពេល ក្នុងរឿងរដ្ឋប្បវេណីនោះទេ ជាពិសេសគឺការរាប់បញ្ចូលឬមិនរាប់បញ្ចូល“ថ្ងៃចាប់ផ្តើម”ទៅក្នុងការគណនានេះ។

ដើម្បីឱ្យមានសង្គតិភាពនៃការអនុវត្តច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ និងវិស័យរដ្ឋប្បវេណី ជាពិសេសពាក់ព័ន្ធនឹងការគណនារយៈពេល ឬអំឡុងពេលនៃការធ្វើបណ្តឹងឧបាស្រ័យ **អង្គសន្និបាតបានយល់ស្របគ្នាថា** គប្បីអនុវត្ត

តាមបទប្បញ្ញត្តិរដ្ឋប្បវេណី គឺមាត្រា៣៣៤ និងមាត្រា៣៣៥ នៃក្រមរដ្ឋប្បវេណី ចំពោះការគណនារយៈពេលនៃការធ្វើបណ្តឹងឧបាស្រ័យក្នុងរឿងព្រហ្មទណ្ឌ។

ខ.៣- ការកំណត់ភាគីក្នុងរឿងព្រហ្មទណ្ឌ (អ្នកទទួលខុសត្រូវរដ្ឋប្បវេណី)

សេចក្តីសម្រេចតុលាការមួយចំនួនក្នុងរឿងព្រហ្មទណ្ឌ មិនបានកំណត់ភាគីក្នុងរឿងព្រហ្មទណ្ឌ ឱ្យបានច្បាស់លាស់ ជាពិសេសពាក់ព័ន្ធនឹងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ហើយក្នុងករណីខ្លះ មានការសម្រេចឱ្យអ្នកទទួលខុសត្រូវរដ្ឋប្បវេណីសងសំណងនៃការខូចខាត ដោយពុំបានកំណត់អ្នកទទួលខុសត្រូវរដ្ឋប្បវេណីជាភាគីជាមុន ដើម្បីអនុវត្តសិទ្ធិស្របតាមច្បាប់នោះដែរ។

អង្គសន្និបាតបានយល់ស្របគ្នាថា អាជ្ញាធរតុលាការត្រូវសកម្ម ដើម្បីសួរព័ត៌មានអំពីអត្តសញ្ញាណអ្នកទទួលខុសត្រូវរដ្ឋប្បវេណីថា តើជាអាណាព្យាបាល ឬជានិយោជក ដើម្បីជាប្រយោជន៍នៃយុត្តិធម៌ សម្រាប់ភាគីក្នុងរឿងក្តី និងភាពឆាប់រហ័សនៃនីតិវិធី ក៏ដូចជាធ្វើឱ្យភាគីបានទទួលនូវសំណងរដ្ឋប្បវេណី ឆាប់រហ័ស ព្រមទាំងការគោរពសិទ្ធិតាមផ្លូវច្បាប់របស់ភាគីគឺក្នុងហានៈជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។

បន្ថែមពីលើនេះ អាជ្ញាធរតុលាការជាពិសេសចៅក្រមជំនុំជម្រះ គប្បីពិនិត្យផងដែរអំពីគុណសម្បត្តិនៃអ្នកទទួលខុសត្រូវរដ្ឋប្បវេណី តាមបញ្ញត្តិនៃមាត្រា៧៤៦ និងមាត្រា៧៤៧ នៃក្រមរដ្ឋប្បវេណី។

អង្គសន្និបាតក៏សម្រេចផងដែរថា បន្ថែមពីលើនេះគប្បីមានការតាក់តែងសេចក្តីឯកភាពដើម្បីអនុវត្ត។

៤- ទិសដៅការងារសម្រាប់ឆ្នាំ ២០២៥

១- ការពង្រឹងកិច្ចការរដ្ឋបាល និងកិច្ចសហប្រតិបត្តិការ

- ខិតខំដោះស្រាយបញ្ហាប្រឈមដូចបានលើកឡើងខាងលើ។

- ជំរុញឱ្យមានការប្រជុំផ្ទៃក្នុងឱ្យបានទៀងទាត់ ដើម្បីដោះស្រាយបញ្ហាប្រឈមផ្សេងៗឱ្យបានល្អប្រសើរ និងទាន់ពេលវេលា។

- បន្តកិច្ចការអនុវត្តអនុស្សរណៈនៃការយោគយល់ជាមួយក្រសួងប្រៃសណីយ៍ ពាក់ព័ន្ធនឹងកិច្ចអភិវឌ្ឍន៍ព័ត៌មានវិទ្យា។

- បន្តកិច្ចសហប្រតិបត្តិការជាមួយអង្គភាពពាក់ព័ន្ធ និងបន្តកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយបណ្តាតុលាការកំពូល ឬមហាអយ្យការនៃប្រទេសអាស៊ាន ក៏ដូចជាប្រទេសផ្សេងៗទៀតនៅក្នុងពិភពលោក និងជាមួយអង្គការអន្តរជាតិនានា។

២- ការជំរុញចំណាត់ការសំណុំរឿង និងការបង្កើនគុណភាពនៃសេចក្តីសម្រេច

- បន្តជំរុញការដោះស្រាយរឿងក្តីគ្រប់ប្រភេទឱ្យបានត្រឹមត្រូវ យុត្តិធម៌ ឆាប់រហ័ស ប្រកបដោយគុណភាព តាមរយៈការបន្ថែមចំនួនសំណុំរឿងក្នុងមួយកម្មវិធីជំនុំជម្រះ បន្ថែមកម្មវិធីជំនុំជម្រះ (ព្រឹក និងល្ងាច) និងបន្ថែមចំនួនអង្គជំនុំជម្រះ។

- ប្រជុំក្រុមបច្ចេកទេសសិក្សាលើនីតិវិធី ដើម្បីរកវិធីសាស្ត្រអនុវត្តនីតិវិធីឱ្យបានឆាប់រហ័ស។

- បន្តប្រជុំពិភាក្សាដោះស្រាយរាល់បញ្ហាស្មុគស្មាញក្នុងការអនុវត្តច្បាប់ និងចំណុចមិនឯកភាពគ្នាក្នុងការបកស្រាយ។

- បន្តបង្កើនសមត្ថភាពធនធានមនុស្សដែលមានស្រាប់ ដើម្បីឱ្យទាន់បរិបទសង្គមជាក់ស្តែងខាងបច្ចេកទេសព័ត៌មានវិទ្យា។

- បន្ត និងជំរុញការបោះពុម្ព និងផ្សព្វផ្សាយព្រឹត្តិបត្រសាលដីការបស់តុលាការកំពូល។

- បន្តប្រជុំធ្វើបច្ចុប្បន្នភាពនូវរាល់ទម្រង់សេចក្តីសម្រេចសំខាន់ៗបន្តទៀត ដើម្បីដាក់ឱ្យប្រើមានទម្រង់ឯកភាពគ្នា។

- បង្កើតបណ្ណាល័យតុលាការកំពូល ដើម្បីតម្កល់ទុកនូវលិខិតបទដ្ឋានគតិយុត្ត ព្រឹត្តិបត្រ និងឯកសារស្រាវជ្រាវ។

៣- ការបន្តគាំទ្រ និងពង្រឹងកិច្ចសហការអនុវត្តគោលនយោបាយកំណែទម្រង់

- បន្តគាំទ្រ និងសហការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ ក្រោមការដឹកនាំប្រកបដោយឋាមពល សក្តានុពល និងឈ្លាសវៃរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ជានាយករដ្ឋមន្ត្រី** ដែលបានកំណត់យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ មានស្នូលនៃយុទ្ធសាស្ត្រ គឺផ្តោតលើ **"ការកែទម្រង់ និងការពង្រឹងអភិបាលកិច្ច"** ជាពិសេសត្រង់មុំទី៤ **"ការលើកកម្ពស់និងការពង្រឹងប្រសិទ្ធភាពនៃច្បាប់និងប្រព័ន្ធយុត្តិធម៌"** តាមរយៈការពង្រឹងពង្រីកកិច្ចសហការ ឱ្យកាន់តែល្អជាមួយក្រសួងយុត្តិធម៌ និងគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌។

- បន្តគាំទ្រ និងចូលរួមអនុវត្តក្នុងយុទ្ធនាការរបស់ក្រសួងយុត្តិធម៌ដឹកនាំដោយ**ឯកឧត្តម កើត រិទ្ធ** ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រួមមាន យុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តី នៅតាមតុលាការ និងយុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ និងបន្តជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីអាទិភាព ពាក់ព័ន្ធនឹងគ្រឿងញៀន សម្អាតប្រាក់ គ្រោះថ្នាក់ចរាចរណ៍ ក្មេងទំនើង និងអត្រានុកូលដ្ឋាន។

- បន្តគាំទ្រ និងសហការអនុវត្តការងារវិសោធនកម្មច្បាប់ក្នុងវិស័យរដ្ឋប្បវេណី និងព្រហ្មទណ្ឌដែលដាក់ចេញដោយក្រសួងយុត្តិធម៌ តាមរយៈការបញ្ជូនចៅក្រម ព្រះរាជអាជ្ញា ឱ្យទៅចូលរួមក្នុងគណៈកម្មការទទួលបន្ទុកដឹកនាំការរៀបចំធ្វើវិសោធនកម្មជាមួយក្រសួងយុត្តិធម៌។

ថ្ងៃ៣ ៧ កើត ខែផល្គុន ឆ្នាំរោង បញ្ចស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែមីនា ឆ្នាំ២០២៥

អគ្គលេខាធិការ

ម៉ៅ ធីតា

បានឃើញ និងឯកភាព

ថ្ងៃ៣ ៧ កើត ខែផល្គុន ឆ្នាំរោង បញ្ចស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែមីនា ឆ្នាំ២០២៥

ប្រធានតុលាការកំពូល

ជីវ កេង

អគ្គព្រះរាជអាជ្ញា

ជា លាង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ
និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ

លេខ.តស/ត.សឧ/២៥

របាយការណ៍ការងារសង្ខេបរបស់សាលាដម្រះក្តី
សម្រាប់សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំយុត្តិធម៌ ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារឆ្នាំអធិការ ឆ្នាំ២០២៥
សាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ

១.ស្ថានភាពទូទៅ

ក- ធនធានមនុស្ស

❖ ផ្នែកសាលាឧទ្ធរណ៍ភ្នំពេញ

សាលាឧទ្ធរណ៍ភ្នំពេញមាន ប្រធាន ១រូប, អនុប្រធាន ៦រូប, ចៅក្រម ១៦រូប, សរុប ២៣រូប (ស្រី៥រូប) ក្នុងនោះមានអនុប្រធាន ១រូប ស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស បច្ចុប្បន្នចៅក្រមទទួលបន្ទុកជំនុំជម្រះមាន ២២រូប និងមានក្រឡាបញ្ជី ៣៤រូប (ស្រី១៥រូប) ក្នុងនោះក្រឡាបញ្ជី ៣រូប(ស្រី១រូប) ស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស។

❖ ផ្នែកមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ

មហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញមាន អគ្គព្រះរាជអាជ្ញា ១រូប, អគ្គព្រះរាជអាជ្ញារង ៥រូប និងព្រះរាជអាជ្ញា ១០រូប សរុប ១៦រូប (ស្រី៤រូប) និងមានក្រឡាបញ្ជី ១១រូប (ស្រី៥រូប) ក្នុងនោះក្រឡាបញ្ជី ២រូប(ស្រី១រូប) ស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស។

❖ ផ្នែកអគ្គលេខាធិការដ្ឋានរដ្ឋបាល

អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ភ្នំពេញមាន អគ្គលេខាធិការ ១រូប អគ្គលេខាធិការរង ៤រូប (ស្រី៣រូប) ប្រធាននាយកដ្ឋាន ៤រូប (ស្រី១រូប) អនុប្រធាននាយកដ្ឋាន ២០រូប (ស្រី ៨រូប) ប្រធានការិយាល័យ ៩រូប (ស្រី០៤រូប) អនុប្រធានការិយាល័យ ០៣រូប និងមន្ត្រីរដ្ឋបាល ៤០រូប (ស្រី២២រូប) សរុប ៨១រូប (ស្រី៣៨រូប) ក្នុងនោះមន្ត្រីរដ្ឋបាល ៣រូប (ស្រី១រូប) ស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស និងមន្ត្រីជាប់កិច្ចសន្យាមាន ២៧រូប (ស្រី៩រូប)។

មានទីប្រឹក្សាអមក្រសួងយុត្តិធម៌ ១រូប ជួយការងាររដ្ឋបាលសាលាឧទ្ធរណ៍ភ្នំពេញ។

ខ-ហេដ្ឋារចនាសម្ព័ន្ធ

សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ មានទីតាំងនៅអគារសាលាយុត្តិធម្ម ស្ថិតនៅតំបន់អភិវឌ្ឍន៍ OCIC នៅតាមបណ្តោយផ្លូវលោកតាក្រហមក ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ សាលាយុត្តិធម្ម ត្រូវបានបញ្ចុះបឋមសិលាសាងសង់ ក្រោមអធិបតីភាព ឯកឧត្តម **កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ និងសម្ពោធ

ដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវសាលាយុត្តិធម៌ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី បច្ចុប្បន្នជា ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

សាលាយុត្តិធម្ម មានកំពស់ ៧ជាន់ បែងចែកជាពីរ៖

-ចំហៀងផ្នែកខាងឆ្វេង ជាអគាររបស់ សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

-ចំហៀងផ្នែកខាងស្តាំ ជាអគាររបស់ សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

សាលាយុត្តិធម្មផ្នែកខាងឆ្វេង ដែលជាអគារសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ មានកំពស់ ៧ជាន់ និងចែកចេញជា ៦១បន្ទប់ ដូចខាងក្រោម៖

-ជាន់ក្រោមដី មានបន្ទប់ឃុំខ្លួន ៣បន្ទប់

-ជាន់ផ្ទាល់ដី សរុបមានចំនួន ១៦បន្ទប់ រួមមាន បន្ទប់សវនាការ៥, បន្ទប់ពិភាក្សា៤, បន្ទប់គណៈប្រតិភូមេធាវី១, បន្ទប់អនីតិជន២, បន្ទប់សាក្សី១, កន្លែងផ្តល់ព័ត៌មាន១, បន្ទប់សន្តិសុខ១, តូបយាម១។

-ជាន់ទី១ សរុបមានចំនួន ៩បន្ទប់ រួមមាន បន្ទប់SERVER១, បន្ទប់ក្រឡាបញ្ជី១, បន្ទប់ព្រះរាជអាជ្ញា២, ឃ្លាំងសម្ភារៈ១, បន្ទប់នាយកដ្ឋានហិរញ្ញវត្ថុ១, បន្ទប់នាយកដ្ឋានកិច្ចការរដ្ឋបាល និងបុគ្គលិក១, នាយកដ្ឋានកិច្ចការតុលាការ១, បន្ទប់អគ្គលេខាធិការ១។

-ជាន់ទី២ សរុបមានចំនួន ១០បន្ទប់ រួមមាន បន្ទប់អគ្គព្រះរាជអាជ្ញា១, បន្ទប់អគ្គព្រះរាជអាជ្ញារង៥ បន្ទប់នាយកដ្ឋានកិច្ចការមហាអយ្យការ១, បន្ទប់ព្រះរាជអាជ្ញា២, បន្ទប់អគ្គលេខាធិការង១, , បន្ទប់ជំនួយការ១។

-ជាន់ទី៣ សរុបមានចំនួន ១០បន្ទប់ រួមមាន បន្ទប់អនុប្រធានសាលាឧទ្ធរណ៍២, បន្ទប់ចៅក្រម៦ បន្ទប់ក្រឡាបញ្ជី២។

-ជាន់ទី៤ សរុបមានចំនួន ១០បន្ទប់ រួមមាន បន្ទប់ប្រធានសាលាឧទ្ធរណ៍១, បន្ទប់អនុប្រធានសាលាឧទ្ធរណ៍៣, បន្ទប់ប្រជុំ១, បន្ទប់បដិសណ្ឋារកិច្ច១, បន្ទប់ទីប្រឹក្សាអមក្រសួងយុត្តិធម៌១, បន្ទប់ជំនួយការ១, បន្ទប់កេសជ្ជៈ១, បន្ទប់ទទួលភ្ញៀវ១។

-ជាន់ទី៥ សរុបមានចំនួន ៣បន្ទប់ រួមមាន បន្ទប់បុគ្គលិកហាត់ការ១, ឃ្លាំងដាក់សំណុំរឿង២។

-ជាន់ទី៦ សាលសន្និបាត (ផ្ទុកបានចំនួន៣០០នាក់)

ក- ព្រឹត្តិការណ៍ ឬ កម្មវិធីការងារនានា

-បានជួបប្រជុំការងាររវាងសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ជាមួយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ចំនួន១លើក ដើម្បីពិភាក្សា និងដោះស្រាយបញ្ហាប្រឈមមួយចំនួន ដែលទាក់ទងនឹងនីតិវិធីជំនុំជម្រះក្នុងរឿងព្រហ្មទណ្ឌ។

-កិច្ចប្រជុំស្តីពី "**ការផ្សព្វផ្សាយ និងណែនាំអំពីការអនុវត្តយុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីតាមតុលាការ**" កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤ ក្រោមអធិបតីភាព **ឯកឧត្តម សេង ស៊ីវុត្ថា** ប្រធានសាលាឧទ្ធរណ៍ភ្នំពេញ និង **ឯកឧត្តម អ៊ុក សារុង** អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ។

-កិច្ចប្រជុំស្តីពី "**គោលការណ៍ឆាប់រហ័សនៃការជំនុំជម្រះរឿងក្តី**" កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤ ក្រោមអធិបតីភាព **ឯកឧត្តម សេង ស៊ីវុត្ថា** ប្រធានសាលាឧទ្ធរណ៍ភ្នំពេញ។

-កិច្ចប្រជុំស្តីពី "**គណៈកម្មការដឹកនាំ និងអនុវត្តយុទ្ធនាការជំរុញនិងពន្លឿនការដោះស្រាយរឿងក្តីនៅសាលាឧទ្ធរណ៍ភ្នំពេញ**" កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រោមអធិបតីភាព **ឯកឧត្តម ជីវ សុងហាក់** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាប្រធានគណៈកម្មការ, **ឯកឧត្តម សេង ស៊ីវុត្ថា** ប្រធានសាលាឧទ្ធរណ៍ភ្នំពេញ និង **ឯកឧត្តម អ៊ុក សារុង** អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ នៅសាលសន្និបាតសាលាយុត្តិធម៌។

-កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ **បានរៀបចំធ្វើតេ្តសរកសារធាតុញៀន** ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ នៃសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

-កិច្ចប្រជុំស្តីពី "**ការរៀបចំទម្រង់របាយការណ៍ថ្មី កិច្ចការបញ្ជូនសាលដីកាកំពាំងមុខ សំណូមពរ និងបញ្ហាប្រឈមផ្សេងៗ**" កាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤ ក្រោមអធិបតីភាព **ឯកឧត្តម ឃុន លាងម៉េង** អនុប្រធានសាលាឧទ្ធរណ៍ភ្នំពេញ។

-កិច្ចប្រជុំស្តីពី "**ការត្រួតពិនិត្យវឌ្ឍនភាពការងារឆមាសទី១**" កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤ ក្រោមអធិបតីភាព **ឯកឧត្តម សេង ស៊ីវុត្ថា** ប្រធានសាលាឧទ្ធរណ៍ភ្នំពេញ និង **ឯកឧត្តម អ៊ុក សារុង** អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ។

-កិច្ចប្រជុំ "**ក្រុមការងារទទួលបន្ទុករៀបចំដីកាឱ្យដំណឹងអំពីសាលដីកាព្រហ្មទណ្ឌកំពាំងមុខ (សំណុំរឿងរក្សាទុកក្នុងឃ្លាំង) និងផ្សព្វផ្សាយជាសាធារណៈ**" នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ក្រោមអធិបតីភាព **ឯកឧត្តម ជូ ប៊ុនរឹន** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ភ្នំពេញ។

-បានជួបសំណេះសំណាលជាមួយ សិស្សចៅក្រម-ព្រះរាជអាជ្ញា ជំនាន់ទី១២ ចំនួន៥៥នាក់ មកទស្សនកិច្ចសិក្សាស្វែងយល់រចនាសម្ព័ន្ធសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

-បានជួបសំណេះសំណាលជាមួយនិស្សិតសមាគមសាលាត្រាជូ ចំនួន៣៨នាក់ មកទស្សនកិច្ចសិក្សាស្វែងយល់អំពីរចនាសម្ព័ន្ធ នៅសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

-បានទទួលសិស្សក្រឡាបញ្ជីកម្មសិក្សា វគ្គពិសេស ជំនាន់ទី៤ ចំនួន ២០នាក់ ចុះកម្មសិក្សានៅសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

-បានប្រជុំពង្រឹងយន្តការការងារ រវាងការងារចៅក្រម ក្រឡាបញ្ជី ជាមួយមន្ត្រីនៃអគ្គលេខាធិការដ្ឋានរដ្ឋបាល ឱ្យកាន់តែមានលក្ខណៈល្អប្រសើរ ដើម្បីជាប្រយោជន៍ ឆ្លើយតបទៅនឹងគោលការណ៍ឆាប់រហ័ស នៃការផ្តល់សេវាយុត្តិធម៌ ជូនប្រជាពលរដ្ឋ បានចំនួន២លើក ក្រោមអធិបតីភាព **ឯកឧត្តម សេង ស៊ីវុត្ថា** ប្រធានសាលាឧទ្ធរណ៍ភ្នំពេញ។

-សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ បានចុះអធិការកិច្ចតាមផែនការ ២ដងក្នុងមួយឆ្នាំ នៅតាមមន្ទីរស៊ើបសួរនៃសាលាដំបូងរាជធានី-ខេត្ត ក្នុងដែនសមត្ថកិច្ចសាលាឧទ្ធរណ៍ភ្នំពេញ។

២. សមិទ្ធផលការងារ

ក. មហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ

ក.១. កិច្ចការចំណាត់ចំណង និងរដ្ឋបាលបច្ចេកទេស

❖ **សំណុំរឿងតម្កល់រឿងទុកឥតចាត់ការ**

-សំណុំរឿងនៅសល់ពីឆ្នាំ២០២៣	ចំនួន	១៨៤	រឿង
-សំណុំរឿងចូលថ្មីក្នុងឆ្នាំ២០២៤	ចំនួន	៥៦២	រឿង
-បានតម្កល់រួច	ចំនួន	៥៣៧	រឿង
-បានអធិបញ្ជាចោទប្រកាន់	ចំនួន	១៤	រឿង
-សំណុំរឿងកំពុងចាត់ការបន្តក្នុងឆ្នាំ២០២៥	ចំនួន	១៩៥	រឿង

ក.២. រដ្ឋបាលចំណាត់ចំណង និងកិច្ចការសម្បថ

❖ **ការបំពេញនីតិវិធីសម្បថ**

-បំពេញនីតិសម្បទាឱ្យសិស្សមេធាវី ចំនួន ៨៩នាក់

-បំពេញនីតិសម្បទាជាមេធាវី តាមមាត្រា៣២នៃច្បាប់លក្ខន្តិកៈមេធាវី ចំនួន ៦៦នាក់

-បំពេញនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ចំនួន ១៩៣ នាក់

❖ **បណ្តឹងឧទ្ធរណ៍-បណ្តឹងសាទុក្ខ របស់អគ្គព្រះរាជអាជ្ញា**

-បណ្តឹងឧទ្ធរណ៍ នឹងសាលក្រម ចំនួន ៧៣ រឿង, ដីកាសម្រេច ចំនួន ០៩ រឿង

-បណ្តឹងសាទុក្ខ នឹងសាលដីកា ចំនួន ១១ រឿង

❖ **សំណុំរឿងធ្វើសេចក្តីសន្និដ្ឋានបញ្ជូនមកពីសាលាឧទ្ធរណ៍ រួមមាន៖**

-សំណុំរឿងសភាព្រហ្មទណ្ឌ ចំនួន ២៥៥៦ រឿង

-សំណុំរឿងសភាស៊ើបសួរ ចំនួន ៤៨៥ រឿង

ក.៣. កិច្ចការផ្សេងទៀតរបស់មហាអយ្យការ

-មហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ បានចុះអធិការកិច្ចនៅ អយ្យការអមសាលាដំបូង ពន្ធនាគារ មន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងដែនសមត្ថកិច្ចរបស់មហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ បានចំនួន ៩លើក។

-បានចូលរួមកិច្ចប្រជុំរបស់ថ្នាក់ដឹកនាំនៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ តាមការអញ្ជើញ របស់ក្រសួង-ស្ថាប័នផ្សេងៗ មានចំនួន ១៤លើក។

-កិច្ចប្រជុំពិភាក្សាការងារ រវាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ជាមួយក្រុមការងាររបស់ អង្គភាពការពារកុមារ(CPU) កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤។

-កិច្ចប្រជុំស្តីពី **"ការពិភាក្សាការងារបច្ចេកទេស ដើម្បីត្រៀមរៀបចំ ប្រជុំរួមជាមួយ អគ្គនាយកដ្ឋានពន្ធនាគារ និងអយ្យការអមសាលាដំបូងក្នុងដែនសមត្ថកិច្ច"** កាលពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២៤ ក្រោមអធិបតីភាព **ឯកឧត្តម អ៊ុក សាវុធ** អគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

-កិច្ចប្រជុំស្តីពី **"កិច្ចពាក់ព័ន្ធចំណាត់ការករណីក្មេងទំនើង ការងារអធិការកិច្ចពន្ធនាគារ ក្នុងដែនសមត្ថកិច្ច"** កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៤ ក្រោមអធិបតីភាព **ឯកឧត្តម អ៊ុក សាវុធ** អគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

-កិច្ចប្រជុំស្តីពី **"នីតិវិធីអនុវត្តពាក់ព័ន្ធជនជាប់ឃុំ បញ្ហាទារុណកម្មបញ្ហាប្រឈមមួយចំនួន និងសំណូមពរផ្សេងៗ"** កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៤ ក្រោមអធិបតីភាព **ឯកឧត្តម អ៊ុក សាវុធ** អគ្គព្រះរាជអាជ្ញា និង **ឯកឧត្តម ឈន សាណាត** អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារក្រសួងមហាផ្ទៃ។

ខ.សាលាឧទ្ធរណ៍ភ្នំពេញ

ខ.១.លទ្ធផលការងារសភាព្រហ្មទណ្ឌ

❖ **សំណុំរឿងសភាព្រហ្មទណ្ឌ និងស្រូបទោស**

-សំណុំរឿងបន្តចាត់ការពីឆ្នាំ២០២៣ ចំនួន ៩៨១ រឿង

-សំណុំរឿងចូលថ្មីក្នុងឆ្នាំ២០២៤ ចំនួន ២៧៦៧ រឿង

-សំណុំរឿងចាត់ការរួចក្នុងឆ្នាំ២០២៤ ចំនួន ២៨៣៦ រឿង

-សំណុំរឿងចាត់ការបន្តក្នុងឆ្នាំ២០២៥ ចំនួន ៩១២ រឿង

ខ.២.លទ្ធផលការងារសភាស៊ើបសួរ

❖ **សំណុំរឿងសភាស៊ើបសួរ**

-សំណុំរឿងបន្តចាត់ការពីឆ្នាំ២០២៣ ចំនួន ១៥ រឿង

-សំណុំរឿងចូលថ្មីក្នុងឆ្នាំ២០២៤ ចំនួន ៤៥៣ រឿង

-សំណុំរឿងចាត់ការរួចក្នុងឆ្នាំ២០២៤ ចំនួន ៤៣៨ រឿង

-សំណុំរឿងកំពុងចាត់ការបន្តក្នុងឆ្នាំ២០២៥ ចំនួន ៣០ រឿង

ខ.៣. លទ្ធផលការងារសាធារណៈប្បវេណី

❖ ចំណាត់ការសំណុំរឿងរដ្ឋប្បវេណី (អង្គសេចក្តី, មុនអង្គសេចក្តី, ដីកាសម្រេចនានា)

-សំណុំរឿងបន្តចាត់ការពីឆ្នាំ២០២៣ ចំនួន ៩៧៦ រឿង
-សំណុំរឿងចូលថ្មីក្នុងឆ្នាំ២០២៤ ចំនួន ១៤៤៧ រឿង
-សំណុំរឿងចាត់ការរួចក្នុងឆ្នាំ២០២៤ ចំនួន ១៤២៩ រឿង
-សំណុំរឿងកំពុងចាត់ការបន្តក្នុងឆ្នាំ២០២៥ ចំនួន ៩៩៤ រឿង

ខ.៤.កិច្ចការផ្សេងទៀតរបស់សាលាឧទ្ធរណ៍

- បានបោះពុម្ពសៀវភៅកម្រងសាលដីកាព្រហ្មទណ្ឌស្តាពរ ១៤ភាគ ចំនួន ៤២០ក្បាល។
- បានបោះពុម្ពសៀវភៅកម្រងសាលដីកាព្រហ្មទណ្ឌ ចំនួន ២០០ក្បាល។
- បានបោះពុម្ពទម្រង់រូបមន្តសាលដីកាសាលដីកាសភាស៊ើបសួរ និងសភាព្រហ្មទណ្ឌ សម្រាប់ប្រើប្រាស់នៅសាលាឧទ្ធរណ៍ភ្នំពេញ ចំនួន ៤០០ក្បាល។
- បានចេញសេចក្តីសម្រេច ស្តីពីការចាត់តាំងក្រុមប្រឹក្សាទទួលបន្ទុកចាត់ការ សំណុំរឿងគ្រឿងញៀន សំណុំរឿងចរាចរណ៍ និងសំណុំរឿងអត្រានុកូលដ្ឋាន។
- បានចេញសេចក្តីសម្រេច ស្តីពីការកែសម្រួលការបែងចែកការកិច្ចជូនអនុប្រធានសាលាឧទ្ធរណ៍ភ្នំពេញ។
- បានចេញសេចក្តីសម្រេច ស្តីពីការកែសម្រួលសមាសភាពក្រុមអ្នកពាក្យប្រចាំសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។
- បានចេញសេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារទទួលបន្ទុកកិច្ចការនារី និងសប្បុរសធម៌ នៃសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។
- បានចេញសេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារទទួលបន្ទុក តាមដាន ត្រួតពិនិត្យ និងបញ្ជូនសាលដីកា សាលដីកាស្តាពរ ដល់មណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី-ខេត្ត ក្នុងដែនសមត្ថកិច្ចសាលាឧទ្ធរណ៍ភ្នំពេញ។
- បានចេញសេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារទទួលបន្ទុក រៀបចំដីកាឱ្យដំណឹងអំពីសាលដីកាព្រហ្មទណ្ឌកំបាំងមុខ (សំណុំរឿងរក្សាទុកក្នុងឃ្លាំង) និងផ្សព្វផ្សាយជាសាធារណៈ តាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល។
- បានចេញលិខិតណែនាំអនុវត្ត ស្តីពីការជំរុញ និងពន្លឿនការដំនុំជម្រះរឿងក្តីនៅសាលាឧទ្ធរណ៍ភ្នំពេញ។
- បានចេញលិខិតណែនាំអនុវត្ត ស្តីពីការអនុវត្តនីតិវិធីនៃការជូនដំណឹងអំពីសាលដីកាព្រហ្មទណ្ឌកំបាំងមុខ និងការបញ្ជូនសំណុំរឿងនៃបណ្តឹងសាទុក្ខទៅតុលាការកំពូល។
- បានចេញសេចក្តីណែនាំអនុវត្ត ស្តីពីការផ្តល់ សាលដីកា និងសាលដីកាស្តាពរ ក្នុងសំណុំរឿងព្រហ្មទណ្ឌដែលមានជនជាប់ឃុំ។
- បានចេញសេចក្តីណែនាំអនុវត្ត ស្តីពីការផ្សព្វផ្សាយជាសាធារណៈអំពីការជូនដំណឹងសាលដីកាព្រហ្មទណ្ឌកំបាំងមុខ។
- បានបញ្ជូនសាលដីកាព្រហ្មទណ្ឌស្តាពរទៅក្រសួងយុត្តិធម៌ បានចំនួន៧៩៦ សាលដីកា ដើម្បីជាប្រយោជន៍ក្នុងការចេញលិខិតថ្កោលទោសជូនប្រជាពលរដ្ឋ។
- បានជម្រះសំណុំរឿងអាទិភាព សំណុំរឿងអត្រានុកូលដ្ឋាន ចំនួន **៤៥ រឿង** ស្មើនឹង **៩១,៨៣%** លើសំណុំរឿងចូលថ្មីក្នុងឆ្នាំ២០២៤ ចំនួន **៤៩រឿង**។ ស្មើនឹង **៩០%** នៃសំណុំរឿងសរុប (ចាស់, ថ្មី) **៥០រឿង**។

- បានជម្រះសំណុំរឿងអាទិភាព សំណុំរឿងចរាចរណ៍ ចំនួន **៩០រឿង** ស្មើនឹង **៩៣,៧៥%** លើសំណុំរឿងចូលថ្មីក្នុងឆ្នាំ២០២៤ ចំនួន **៩៦រឿង**។ ស្មើនឹង **៧៨,២៦%** នៃសំណុំរឿងសរុប (ចាស់, ថ្មី) **១១៥រឿង**។

- បានជម្រះសំណុំរឿងអាទិភាព សំណុំរឿងគ្រឿងញៀន ចំនួន **៩៧៣រឿង** ស្មើនឹង **១០២,៨៥%** លើសំណុំរឿងចូលថ្មីក្នុងឆ្នាំ២០២៤ ចំនួន **៩៤៦រឿង**។ ស្មើនឹង **៧៧%** នៃសំណុំរឿងសរុប (ចាស់, ថ្មី) **១២៦២រឿង**។

- បានជម្រះសំណុំរឿងអាទិភាព សំណុំរឿងក្មេងទំនើង ចំនួន **២៣រឿង** ស្មើនឹង **៥៦%** លើសំណុំរឿងចូលថ្មីក្នុងឆ្នាំ២០២៤ ចំនួន **៤១រឿង**។

- ក្រុមការងារទទួលបន្ទុកអនុវត្តការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ បានទទួលពាក្យប្តឹងសុំពន្លឿននីតិវិធី និងដោះស្រាយភាពមិនប្រក្រតីពីក្រសួងយុត្តិធម៌ សរុបចំនួន **១៨៣ករណី** (លិខិតផ្លូវការ ៦៨ករណី និងតាមក្រុមតេឡេក្រាម ១១៥ករណី) ក្នុងនោះសំណុំរឿងប្តឹងសុំជំរុញពន្លឿន៖ សំណុំរឿងរដ្ឋប្បវេណី **៤៣ករណី** សំណុំរឿងព្រហ្មទណ្ឌ **២៧ករណី** សំណុំរឿងតម្កល់ទុកឥតចាត់ការ **៤៤ករណី** និងសំណុំរឿងប្តឹងដោះស្រាយភាពមិនប្រក្រតី៖ សំណុំរឿងរដ្ឋប្បវេណី **១០ករណី** សំណុំរឿងព្រហ្មទណ្ឌ **៥៩ករណី**។ ក្រុមការងារសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ បានពិនិត្យស្រាវជ្រាវ និងឆ្លើយតបទាន់ពេលវេលា បានគ្រប់ចំនួន **១៨៣ករណី**។

II.**បញ្ហាប្រឈម**

១-កង្វះរបាយការណ៍អំពីការបញ្ជូន ទៅភាគី និងមេធាវី ដែលនាំឱ្យនីតិវិធីបណ្តឹងមានភាពយឺតយ៉ាវ។

២-កង្វះឯកសារ ឬលិខិតបញ្ជាក់ទីតាំងដីទំនាស់ ក្នុងរឿងរដ្ឋប្បវេណី ពីស្ថាប័នជំនាញ និងខ្វះការចូលរួមពីភាគីតាមការស្នើសុំរបស់សាលាឧទ្ធរណ៍ភ្នំពេញ។

៣-ការបញ្ជូន និងការទទួលសាលដីកា។

៤-កង្វះអ្នកបកប្រែភាសាបរទេស ក្នុងរឿងក្តីព្រហ្មទណ្ឌ។

៥-គ្មានមន្ត្រីអាជ្ញាសាលា និងកង្វះមន្ត្រីរដ្ឋបាល។

III.**ការកត់សម្គាល់បញ្ហាប្រឈម កង្វះខាត របស់សាលាដំបូង និងអយ្យការអមសាលាដំបូង**

១.ការបញ្ជូនសំណុំរឿងនៃបណ្តឹងឧទ្ធរណ៍មានភាពយឺតយ៉ាវ និងឯកសារមិនគ្រប់គ្រាន់។

២.ការបញ្ជូនដីកាសម្រេចនានារបស់ចៅក្រមស៊ើបសួរ និងសាលក្រម មកមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ មានភាពយឺតយ៉ាវ។

៣.ការចុះអធិការកិច្ចរបស់អយ្យការអមសាលាដំបូង (ពន្ធនាគារ និងមន្ត្រីនគរបាលយុត្តិធម៌) មានភាពអសកម្ម។

៤.ការអនុវត្តវិធានការណ៍ស្រូបទោស (ខុសសមត្ថកិច្ច)។

IV.**សំណូមពរ**

១-ស្នើសុំធ្វើវិសោធនកម្មមាត្រា២៤៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដោយផ្តល់សិទ្ធិដល់អាជ្ញាធរមូលដ្ឋាន កងកម្លាំង មានសមត្ថកិច្ចមានសិទ្ធិក្នុងការបញ្ជូន។

២-ស្នើសុំមន្ត្រីរដ្ឋបាលចំនួន ១៦រូប (មន្ត្រីផ្នែកព័ត៌មានវិទ្យា ចំនួន ០៥រូប មន្ត្រីជំនាញបកប្រែភាសាបរទេស ចំនួន ៣រូប និងមន្ត្រីផ្នែករដ្ឋបាល ចំនួន ៨រូប) ដើម្បីបំពេញតម្រូវការការងារនៅសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

V.ទិសដៅការងារសម្រាប់អនុវត្តបន្តក្នុងឆ្នាំ២០២៥

១-ជំរុញការជំនុំជម្រះសំណុំរឿងក្តីអាទិភាពរួមមាន សំណុំរឿងគ្រឿងញៀន សំណុំរឿងចរាចរណ៍ សំណុំរឿងអត្រានុកូលដ្ឋាន សំណុំរឿងក្មេងទំនើង ឱ្យបានឆាប់រហ័ស ត្រឹមត្រូវ និងយុត្តិធម៌។

២-ជំរុញការជំនុំជម្រះសំណុំរឿងក្តីគ្រប់ប្រភេទ ទាំងសំណុំរឿងចាស់ និងសំណុំរឿងថ្មី ឱ្យបានឆាប់រហ័ស ត្រឹមត្រូវ និងយុត្តិធម៌។

៣-បន្តជំរុញការងារពន្លឿន និងការដោះស្រាយរឿងក្តីនៅសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ស្របតាមសេចក្តីសម្រេចលេខ ០១ កយ.សសរ/២៤ ចុះថ្ងៃ៤ ខែមករា ឆ្នាំ២០២៤ របស់ក្រសួងយុត្តិធម៌។

៤-បន្តជំនុំជម្រះតាមគោលការណ៍ឆាប់រហ័សសំណុំរឿងក្តីព្រហ្មទណ្ឌអាទិភាពរួមមាន៖ បទជួញដូរផ្លូវភេទ បទចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ បទវិតិក្រម បទសម្អាតប្រាក់ បទពុករលួយ បទល្មើសពន្ធដារ និងគយ បទល្មើសប្រឆាំងនឹងសន្តិសុខសង្គម រឿងក្តីអនីតិជន រឿងក្តីដែលមានជនជាប់ចោទជាស្ត្រីក្រីក្រ មានផ្ទៃពោះ និងមានកូនតូចក្នុងបន្ទុក រឿងក្តីដែលសាលាដំបូងប្រកាសផ្តន្ទាទោសលើជនជាប់ចោទកម្រិតទាប និងរឿងក្តីដែលសាលាដំបូងសម្រេចឱ្យជនជាប់ចោទដែលជាប់ឃុំរួចខ្លួន ដោយមានបណ្តឹងឧទ្ធរណ៍របស់តំណាងអយ្យការ។ រឿងក្តីទាំងអស់នេះ ត្រូវចុះក្នុងប្រព័ន្ធទិន្នន័យ ចុះបញ្ជីដោយដៃ បញ្ជូនចេញ និងដាក់កម្មវិធីជំនុំជម្រះ ឱ្យបានឆាប់រហ័ស ស្របតាមគោលការណ៍ច្បាប់។

៥-បន្តអនុវត្តគោលការណ៍ឆាប់រហ័សការបញ្ជូនចេញសេចក្តីសម្រេចគ្រប់ប្រភេទជាអាទិ៍ សេចក្តីសម្រេចមិនទាន់ស្តាពរ និងស្តាពរ ដល់ភាគីពាក់ព័ន្ធ ជាពិសេសជនជាប់ឃុំ។

៦-បន្តធ្វើអធិការកិច្ចនៅមន្ទីរស៊ើបសួរសាលាដំបូងរាជធានី-ខេត្ត និងអធិការកិច្ចពន្ធនាគារ ក្នុងដែនសមត្ថកិច្ចសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីធានាដល់ដំណើរការល្អនៃមន្ទីរស៊ើបសួរ។

៧-បន្តធ្វើអធិការកិច្ចនៅអយ្យការអមសាលាដំបូងរាជធានី-ខេត្ត អង្គភាពនគរបាលយុត្តិធម៌ និងពន្ធនាគារ ក្នុងដែនសមត្ថកិច្ចសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពង្រឹងការអនុវត្តច្បាប់។

៨-ជម្រុញចេញសាលដីកាព្រហ្មទណ្ឌ និងសាលដីកាព្រហ្មទណ្ឌស្តាពរ អោយបានឆាប់រហ័ស ស្របតាមគោលការណ៍ច្បាប់។

ថ្ងៃ ៣ដ ៧កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៥

អគ្គលេខាធិការ

ជូ ឆ្លុងវិន

បានឃើញ និងឯកភាព
ថ្ងៃ ៣ដ ៧កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី៥ ខែ មីនា ឆ្នាំ២០២៥

អគ្គព្រះរាជអាជ្ញា

អ៊ុក សាវុធ

ប្រធានសាលាឧទ្ធរណ៍ភ្នំពេញ

សេង ឃុីវុត្ថា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍បាត់ដំបង
និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង

លេខ: ១១៤៧ រប/២៥

របាយការណ៍ការងារសង្ខេបរបស់សាលាដម្រះក្តី
សម្រាប់សន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារអាទិភាព ឆ្នាំ២០២៥
សាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង

==========

១. ស្ថានភាពទូទៅ

ក. បច្ចុប្បន្នភាពធនធានមនុស្ស

ក.១. សាលាឧទ្ធរណ៍

ចំនួនចៅក្រម ១១នាក់			ប្រធាន ១រូប			អនុប្រធាន ៣រូប (០ស្រី)			ចៅក្រម ៧រូប (១ស្រី)			
ឧត្តមចៅក្រម	ក.១.១	ក.១.២	ក.១.៣	ក.១.៤	ក.១.៥	ក.១.៦	វរចៅក្រម	ក.២.១	ក.២.២	ក.២.៣	ក.២.៤
ចំនួន	២នាក់	០នាក់	២នាក់	១នាក់	១នាក់	២នាក់	ចំនួន	១នាក់	១នាក់	១នាក់	០នាក់

ក.២. មហាអយ្យការអមសាលាឧទ្ធរណ៍

ចំនួនព្រះរាជអាជ្ញា ៦នាក់			អគ្គព្រះរាជអាជ្ញា ១រូប			អគ្គព្រះរាជអាជ្ញារង ២រូប(០ស្រី)			ព្រះរាជអាជ្ញា ៣រូប(០ស្រី)			
ឧត្តមព្រះរាជអាជ្ញា	ក.១.១	ក.១.២	ក.១.៣	ក.១.៤	ក.១.៥	ក.១.៦	វរព្រះរាជអាជ្ញា	ក.២.១	ក.២.២	ក.២.៣	ក.២.៤
ចំនួន	០នាក់	០នាក់	០នាក់	១នាក់	២នាក់	១នាក់	ចំនួន	១នាក់	១នាក់	០នាក់	០នាក់

ក.៣. អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍

រចនាសម្ព័ន្ធ	ចំនួនធនធាន	មន្ត្រីគ្រប់គ្រងរដ្ឋបាល "ក"	មន្ត្រីក្រមការ "ខ"	លេខាធិការ "គ"
អគ្គលេខាធិការ	១រូប (ស្រី ១រូប)	១រូប	០រូប	០រូប
អគ្គលេខាធិការរង	១រូប (ស្រី ០រូប)	១រូប	០រូប	០រូប
ប្រធាននាយកដ្ឋាន	២រូប (ស្រី ១រូប)	២រូប	០រូប	០រូប
អនុប្រធាននាយកដ្ឋាន	១៣រូប (ស្រី ៤រូប)	១០រូប	១រូប	២រូប
ប្រធានការិយាល័យ	៧រូប (ស្រី ៣រូប)	២រូប	៥រូប	០រូប
អនុប្រធានការិយាល័យ	១រូប (ស្រី ០រូប)	០រូប	១រូប	០រូប
មន្ត្រីរដ្ឋបាល	១៧រូប (ស្រី ៧រូប)	១៤រូប	៣រូប	០រូប
សរុប	៤២រូប (ស្រី ១៦រូប)	៣០រូប	១០រូប	២រូប

ក.៤.ក្រឡាបញ្ជីសរុប ២០នាក់	ក្រឡាបញ្ជីសាលាឧទ្ធរណ៍		ក្រឡាបញ្ជីមហាអយ្យការ	
	សរុប ១៣នាក់	ស្រី ៤នាក់	សរុប ៧នាក់	ស្រី ៣នាក់

ក.៥. មន្ត្រីជាប់កិច្ចសន្យាសរុប ១៧រូប (ស្រី ១១រូប)

ផ្លូវលេខ៥៧ ភូមិចំការឫស្សី សង្កាត់ព្រែកព្រះស្តេច ក្រុងបាត់ដំបង ខេត្តបាត់ដំបង
ទូរស័ព្ទលេខ: ០១២ ៨៣ ៩៥ ៤៥ / ០៧៧ ៩៧៧ ៩៨៨ / ០៦៩ ៣៤ ៣៤ ១៣ / ០៩៨ ៦៩ ៩៩ ៥៥

ខ. ហេដ្ឋារចនាសម្ព័ន្ធ

សាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង មានទីតាំងស្ថិតនៅផ្លូវលេខ ៥៧ ភូមិចំការឫស្សី សង្កាត់ព្រែកព្រះស្តេច ក្រុងបាត់ដំបង ខេត្តបាត់ដំបង ទំហំដីសរុប ៩,៣២២ ម៉ែត្រការ៉េ មានអគារសម្រាប់បម្រើការងារចំនួន ១ខ្នង បណ្តោយ ៣៦ម៉ែត្រ ទទឹង ២១ម៉ែត្រ កម្ពស់ ២ជាន់ រួមមាន៖ សាលសវនាការចំនួន ៣, សាលប្រជុំរួមចំនួន ១, បន្ទប់គណៈមេធាវីចំនួន ១, បន្ទប់សាក្សីចំនួន ១, បន្ទប់ជនជាប់ឃុំរង់ចាំសវនាការចំនួន ១ និងបន្ទប់ការិយាល័យធ្វើការផ្សេងៗទៀតចំនួន ២០ និងរថយន្តចំនួន១គ្រឿង ។

គ. លទ្ធផលសន្និបាតផ្ទៃក្នុងស្ថាប័នសម្រាប់ឆ្នាំ ២០២៤

សាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង បានរៀបចំសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៤ និងលើកទិសដៅការងារឆ្នាំ២០២៥ នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២៥ នៅសាលប្រជុំចំរើនសិរីមង្គល ក្រោមអធិបតីភាព ឯកឧត្តមប្រធានសាលាឧទ្ធរណ៍បាត់ដំបង និង ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាត់ដំបង ដោយមានការចូលរួមពី ឯកឧត្តម លោក លោកស្រី អ្នកនាង កញ្ញា ជាអនុប្រធានសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញារង ចៅក្រម ព្រះរាជអាជ្ញា អគ្គលេខាធិការរង ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ ក្រឡាបញ្ជី មន្ត្រីរដ្ឋបាលមន្ត្រីជាប់កិច្ចសន្យា និងអ្នកហាត់ការទាំងអស់ នៃសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង និងមានការចូលរួមពី ឯកឧត្តម លោក លោកស្រី ជាប្រធានសាលាដំបូង ព្រះរាជអាជ្ញា ចៅក្រម ព្រះរាជអាជ្ញារង និងប្រធានលេខាធិការដ្ឋានរដ្ឋបាលនៃសាលាដំបូង និងអយ្យការអមសាលាដំបូងក្នុងដែនសមត្ថកិច្ចទាំង០៦ខេត្ត សរុបចំនួន ១៤០នាក់ ដោយបានធ្វើកិច្ចពិភាក្សាអំពីបញ្ហាប្រឈមនានាក្នុងការអនុវត្តការងារកន្លងមក ព្រមទាំងធ្វើដោះស្រាយដោយមានការឯកភាពរួម និងការកំណត់ទិសដៅការងារសម្រាប់ឆ្នាំបន្ទាប់ បានកាន់តែល្អប្រសើរ។

ឃ. ព្រឹត្តិការណ៍ ឬកម្មវិធីការងារនានា

ក្នុងឆ្នាំ២០២៤ ថ្នាក់ដឹកនាំនៃសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង បានចូលរួមក្នុងកិច្ចការផ្សេងៗទៀតជាច្រើនមានដូចតទៅ៖

- រៀបចំកិច្ចប្រជុំផ្ទៃក្នុង ដើម្បីពង្រឹងវិន័យមន្ត្រី ដោះស្រាយបញ្ហាលំបាកដែលបានជួបប្រទះក្នុងពេលអនុវត្តការងារប្រចាំខែ និងកិច្ចប្រជុំផ្សព្វផ្សាយផ្សេងទៀតដល់មន្ត្រីក្នុងអង្គភាពចំនួន ១៩ ដង
- ធ្វើការផ្សះផ្សា សម្រុះសម្រួលភាគីក្នុងសំណុំរឿងសកម្មវិធីបានសម្រេច ចំនួន ១០រឿង
- ធ្វើការផ្សះផ្សា សម្រុះសម្រួលភាគីក្នុងសំណុំរឿងតម្កល់ទុកឥតចាត់ការបានសម្រេច ចំនួន ២រឿង
- ចូលរួមប្រជុំ និងណែនាំការអនុវត្តយុទ្ធនាការពង្រឹង លើកកម្ពស់សេវាយុត្តិធម៌ និងគុណភាពនៃយុត្តិធម៌ ព្រមទាំងយុទ្ធនាការជំរុញ និងពន្លឿនរឿងក្តីនៅតាមតុលាការ និងយុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ
- ថ្នាក់ដឹកនាំបានចូលរួមកម្មវិធីបរិច្ចាគឈាមដោយស្ម័គ្រចិត្តប្រចាំឆ្នាំ២០២៤ ក្រោមប្រធានបទ "ឈាមរបស់ខ្ញុំ ដើម្បីសង្គ្រោះជីវិតមនុស្ស" ក្រោមគំនិតផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- ចូលរួមសិក្ខាសាលា និងកិច្ចប្រជុំដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌ ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ និងស្ថាប័នពាក់ព័ន្ធ
- បានទទួលជួប និងចូលរួមកិច្ចប្រជុំជាមួយគណៈប្រតិភូគណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃរដ្ឋសភា ដែលដឹកនាំដោយឯកឧត្តម អង្គ វង្ស វឌ្ឍានា ប្រធានគណៈកម្មការទី៦ នៃរដ្ឋសភា ដើម្បីស្វែងយល់អំពីការអនុវត្តច្បាប់ និងវិស័យយុត្តិធម៌

- រៀបចំសង្ក្រាន្តឆ្នាំថ្មី មានការលេងល្បែងប្រជាប្រិយខ្មែរដូចជាទាញព្រ័ត្រ បោះអង្គញ់ ចោលឈូង ស្វាដណ្តើមស្លឹកឈើ លោតប៉ាវ រាំដណ្តើមកៅអី លាក់កន្សែង យ៉ាងច្រើនកុះករ ប្រកបដោយស្នាមញញឹមស្រស់ស្អាត ស្និតស្នាល និងភាពសប្បាយរីករាយ ដើម្បីអបអរសាទរ ពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ
- បានទទួលគណៈប្រតិភូនៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ដឹកនាំដោយ ឯកឧត្តម អ៊ិន បូផា នាយកសាលាភូមិន្ទក្រឡាបញ្ជី ដឹកនាំសិស្សក្រឡាបញ្ជីវគ្គពិសេស ជំនាន់ទី៤ ចំនួន ១៦រូប
- បានជួបប្រជុំជាមួយតំណាងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា តាមការស្នើសុំ ដើម្បី(ក.ម.ស.ម)ផ្តល់មតិយោបល់ និងជាតុចូល លើលទ្ធផលនៃរបាយការណ៍អង្កេតសវនាការរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្ស កម្ពុជា ដែលបានរកឃើញកន្លងមក (ក.ម.ស.ម)
- បានចូលរួមវាយគង ជួង ទូងស្គរ និងលើកផ្ទាំងបដា អបអរសាទរ ថ្ងៃជាប្រវត្តិសាស្ត្ររបស់ ព្រះរាជាណាចក្រកម្ពុជា នៃពិធីបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ
- បានរៀបចំពិធីសំណេះសំណាល និងប្រគល់វិញ្ញាបនបត្របញ្ជាក់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ជូនដល់មន្ត្រីនគរបាលជាតិ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប សរុបចំនួន ៧៦រូប
- បានអញ្ជើញចូលរួមក្នុងពិធីគោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតន កោដ្ឋ" គម្រប់ខួប ១២ឆ្នាំ
- រៀបចំកម្មវិធីអបអរសាទរខួបអនុស្សាវរីយ៍ទី១១៣ ទិវាសិទ្ធិនារីអន្តរជាតិ ៨ មីនា ឆ្នាំ២០២៤។

២. សមិទ្ធផលការងារ

ក. មហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង៖

ក.១. កិច្ចការទំនាក់ទំនង និងរដ្ឋបាលបច្ចេកទេស (អធិការកិច្ច, កិច្ចការសម្បថ....)

ក.១.១.ការចុះអធិការកិច្ចរបស់មហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង

ល.រ	បរិយាយ	ឆ្នាំ២០២៤	ខែមករា ឆ្នាំ២០២៥	ខែកុម្ភៈ ឆ្នាំ២០២៥	ផ្សេងៗ
១	អយ្យការអមសាលាដំបូងខេត្ត	១៥ ដង	០០ ដង	០០ ដង	
២	ពន្ធនាគារខេត្ត	០៣ ដង	០០ ដង	០០ ដង	
៣	មន្ត្រីនគរបាលយុត្តិធម៌	០៣ ដង	០០ ដង	០០ ដង	

ក.១.២.សម្បថមន្ត្រីនគរបាលយុត្តិធម៌

ល.រ	បរិយាយ	ឆ្នាំ២០២៤	ខែមករា ឆ្នាំ២០២៥	ខែកុម្ភៈ ឆ្នាំ២០២៥	ផ្សេងៗ
១	មន្ត្រីនគរបាលខេត្តសៀមរាប	៧៦ រូប	០០ រូប	០០ រូប	

ក.២. ចំណាត់ការលើសំណុំរឿងតម្កល់ទុកឥតចាត់ការ

ល.រ	បរិយាយ	ឆ្នាំ២០២៤	ខែមករា ឆ្នាំ២០២៥	ខែកុម្ភៈ ឆ្នាំ២០២៥	ផ្សេងៗ
១	សំណុំរឿងសល់ចាស់	៧៧ រឿង	៥០ រឿង	៦១ រឿង	
២	សំណុំរឿងចូលថ្មី	២០៣ រឿង	១៦ រឿង	១៧ រឿង	
៣	សំណុំរឿងចាត់ការរួច	២៣០ រឿង	០៥ រឿង	១០ រឿង	
៤	សំណុំរឿងសល់កំពុងចាត់ការ	៥០ រឿង	៦១ រឿង	៦៨ រឿង	

ក.៣. កិច្ចការផ្សេងទៀតរបស់មហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង

ក.៣.១. ធ្វើសេចក្តីសន្និដ្ឋាន

ល.រ	បរិយាយ	ឆ្នាំ២០២៤	ខែមករា ឆ្នាំ២០២៥	ខែកុម្ភៈ ឆ្នាំ២០២៥	ផ្សេងៗ
១	សំណុំរឿងសកាព្រហ្មទណ្ឌ	៩២០ រឿង	៩០ រឿង	៩៨ រឿង	
២	សំណុំរឿងសកាស៊ើបសួរ	១៨០ រឿង	១៦ រឿង	១៨ រឿង	
៣	សំណុំរឿងសការដ្ឋប្បវេណី	០០ រឿង	០០ រឿង	០០ រឿង	

ក.៣.២.បណ្តឹងឧទ្ធរណ៍ និងបណ្តឹងសាទុក្ខរបស់អគ្គព្រះរាជអាជ្ញា

ល.រ	បរិយាយ	ឆ្នាំ២០២៤	ខែមករា ឆ្នាំ២០២៥	ខែកុម្ភៈ ឆ្នាំ២០២៥	ផ្សេងៗ
១	បណ្តឹងឧទ្ធរណ៍លើដីកាសម្រេច	០១ ដីកា	០០ ដីកា	០០ ដីកា	
២	បណ្តឹងឧទ្ធរណ៍លើសាលក្រម	៧០ សាលក្រម	០៤ សាលក្រម	១៨ សាលក្រម	
៣	បណ្តឹងសាទុក្ខលើសាលដីកា	៣៥ សាលដីកា	០០ សាលដីកា	០៦ សាលដីកា	

ខ. សាលាឧទ្ធរណ៍បាត់ដំបង ៖

ខ.១. លទ្ធផលការងារបស់សកាព្រហ្មទណ្ឌ

ខ.១.១. ចំណាត់ការសំណុំរឿងសកាព្រហ្មទណ្ឌ ស្រូបទោស

ល.រ	បរិយាយ	ឆ្នាំ២០២៤	ខែមករា ឆ្នាំ២០២៥	ខែកុម្ភៈ ឆ្នាំ២០២៥	ផ្សេងៗ
១	សំណុំរឿងសល់ចាស់	១៦៤ រឿង	១៤១ រឿង	២០០ រឿង	
២	សំណុំរឿងចូលថ្មី	៨៦៦ រឿង	១០៥ រឿង	៩៧ រឿង	
៣	សំណុំរឿងចាត់ការរួច	៨៨៩ រឿង	៤៦ រឿង	៧៥ រឿង	
៤	សំណុំរឿងសល់កំពុងចាត់ការ	១៤១ រឿង	២០០ រឿង	២២២ រឿង	

ខ.១.២. សំណុំរឿងសកាព្រហ្មទណ្ឌបង្វិលពីតុលាការកំពូល

ល.រ	បរិយាយ	ឆ្នាំ២០២៤	ខែមករា ឆ្នាំ២០២៥	ខែកុម្ភៈ ឆ្នាំ២០២៥	ផ្សេងៗ
១	សំណុំរឿងសល់ចាស់	១១ រឿង	០៦ រឿង	០៩ រឿង	
២	សំណុំរឿងចូលថ្មី	២០ រឿង	០៣ រឿង	១០ រឿង	
៣	សំណុំរឿងចាត់ការរួច	២៥ រឿង	០០ រឿង	០២ រឿង	
៤	សំណុំរឿងសល់កំពុងចាត់ការ	០៦ រឿង	០៩ រឿង	១៧ រឿង	

ខ.២. លទ្ធផលការងារបស់សកាស៊ើបសួរ

ខ.២.១. ចំណាត់ការសំណុំរឿងសកាស៊ើបសួរ

ល.រ	បរិយាយ	ឆ្នាំ២០២៤	ខែមករា ឆ្នាំ២០២៥	ខែកុម្ភៈ ឆ្នាំ២០២៥	ផ្សេងៗ
១	សំណុំរឿងសល់ចាស់	១៧ រឿង	១១ រឿង	១៧ រឿង	
២	សំណុំរឿងចូលថ្មី	១៧៩ រឿង	១៩ រឿង	១៦ រឿង	
៣	សំណុំរឿងចាត់ការរួច	១៨៥ រឿង	១៣ រឿង	១៦ រឿង	
៤	សំណុំរឿងសល់កំពុងចាត់ការ	១១ រឿង	១៧ រឿង	១៧ រឿង	

ខ.២.២. ការចុះអធិការកិច្ចរបស់សភាស៊ើបសួរ

ល.រ	បរិយាយ	ឆ្នាំ២០២៤	ខែមករា ឆ្នាំ២០២៥	ខែកុម្ភៈ ឆ្នាំ២០២៥	ផ្សេងៗ
១	ចំនួនដងការចុះអធិការកិច្ច	០៦ ដង	០០ ដង	០០ ដង	

ខ.៣. លទ្ធផលការងារបស់សភាដ្ឋប្បវេណី

ខ.៣.១. ចំណាត់ការសំណុំរឿងសភាដ្ឋប្បវេណី

ល.រ	បរិយាយ	ឆ្នាំ២០២៤	ខែមករា ឆ្នាំ២០២៥	ខែកុម្ភៈ ឆ្នាំ២០២៥	ផ្សេងៗ
១	សំណុំរឿងសល់ចាស់	១៣០ រឿង	១១៨ រឿង	១១១ រឿង	
២	សំណុំរឿងចូលថ្មី	៤០៧ រឿង	០៤ រឿង	៥០ រឿង	
៣	សំណុំរឿងចាត់ការរួច	៤១៩ រឿង	១១ រឿង	៣៦ រឿង	
៤	សំណុំរឿងសល់កំពុងចាត់ការ	១១៨ រឿង	១១១ រឿង	១២៥ រឿង	

ខ.៣.២. ចំណាត់ការសំណុំរឿងសភាដ្ឋប្បវេណីបង្វិលពីតុលាការកំពូល

ល.រ	បរិយាយ	ឆ្នាំ២០២៤	ខែមករា ឆ្នាំ២០២៥	ខែកុម្ភៈ ឆ្នាំ២០២៥	ផ្សេងៗ
១	សំណុំរឿងសល់ចាស់	១៣ រឿង	១៩ រឿង	១៩ រឿង	
២	សំណុំរឿងចូលថ្មី	២៦ រឿង	០០ រឿង	០៨ រឿង	
៣	សំណុំរឿងចាត់ការរួច	២០ រឿង	០០ រឿង	០៣ រឿង	
៤	សំណុំរឿងសល់កំពុងចាត់ការ	១៩ រឿង	១៩ រឿង	២៤ រឿង	

ខ.៤. កិច្ចការផ្សេងទៀតរបស់សាលាឧទ្ធរណ៍បាត់ដំបង

ក្នុងនាមអនុប្រធានប្រចាំការ យុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តី និងភាពមិនប្រក្រតី នៅតាមសាលាដម្រះក្តី បានធ្វើការចុះទៅតាមសាលាដំបូង ក្នុងដែនសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍បាត់ដំបង

ល.រ	បរិយាយ	ឆ្នាំ២០២៤	ខែមករា ឆ្នាំ២០២៥	ខែកុម្ភៈ ឆ្នាំ២០២៥	ផ្សេងៗ
១	ការចុះនៅសាលាដំបូងខេត្តទាំង៦	០៩ ដង	០០ ដង	០០ ដង	

៣. បញ្ហាប្រឈម និងសំណូមពរ

អ. បញ្ហាប្រឈម

ក.១. អគ្គលេខាធិការដ្ឋានរដ្ឋបាល

- ខ្វះអាជ្ញាសាលា និងមន្ត្រីរដ្ឋបាល
- ខ្វះខាតប្រាក់ឧបត្ថម្ភសម្រាប់ចុះបេសកកម្ម
- ខ្វះអគារអគ្គលេខាធិការដ្ឋានរដ្ឋបាល អគារមហាអយ្យការ អគារស្នាក់នៅ
- សំណុំរឿងដែលសាលាដំបូងបញ្ជូនមកដល់សាលាឧទ្ធរណ៍ ក្រោយរយៈពេល ៣ខែ គិតចាប់ពីថ្ងៃចុះបណ្តឹងឧទ្ធរណ៍នៅតែមាន
- ការបញ្ជូនសំណុំរឿងប្តឹងឧទ្ធរណ៍មកសាលាឧទ្ធរណ៍ មានការបាត់ឯកសារផ្សេងៗ ខ្វះហត្ថលេខាអ្នកពាក់ព័ន្ធ ត្រាអង្គភាព ត្រាឈ្មោះជាដើម

ក.២. សាលាឧទ្ធរណ៍បាត់ដំបង

- ការបង្គាប់ឱ្យមន្ទីរសុរិយោដីធ្វើការវាស់វែង និងកំណត់អត្តសញ្ញាណដីវិវាទ ខាងសុរិយោដីធ្វើចំណាត់ការយឺតយ៉ាវ

- ការអនុវត្តមិនទាន់បានឯកភាពគ្នាក្នុងសំណុំរឿងវិវាទដីធ្លីដែលមិនទាន់ចុះបញ្ជី
- ការបញ្ជូននៅតែមានបញ្ហាផ្នែកបច្ចេកទេសចំពោះមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន
- ក្នុងករណីភាគីគាត់ស្នើសុំទៅចៅក្រមស៊ើបសួរសាលាដំបូង ឱ្យបំពេញកិច្ចណាមួយហើយចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេលដែលច្បាប់កំណត់ បើហួសពេលកំណត់ហើយ ចៅក្រមស៊ើបសួរមិនត្រូវចេញដីកាសម្រេចឆ្លើយតបនឹងពាក្យសុំឡើយ។ករណីភាគីបានដាក់ពាក្យសុំមកសកាស៊ើបសួរ ហើយក្នុងអំឡុងពេលសកាស៊ើបសួរទទួលចាត់ការសំណុំរឿង ចៅក្រមស៊ើបសួរសាលាដំបូងបែរជាសម្រេចទៅវិញ តាមផ្លូវច្បាប់ចៅក្រមស៊ើបសួរសាលាដំបូងមិនគប្បីធ្វើការសម្រេចដោយសារហួសរយៈពេលហើយ
- ការចោទប្រកាន់ និងផ្តន្ទាទោសក្នុងបទល្មើសគ្រឿងញៀនពុំបានចង្អុលបង្ហាញកថាខណ្ឌឱ្យបានត្រឹមត្រូវដើម្បីកំណត់ចំណាត់ថ្នាក់នៃបទល្មើស (មជ្ឈិម ឬឧក្រិដ្ឋ)

ក.៣. មហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង

- ពុំមានការបង្វិលលិខិតជូនដំណឹងអំពីសាលដីកាកំបាំងមុខ ឬអ្នកទទួលមិនមែនជាសាមីខ្លួន
- ការបញ្ជូនសាលក្រមសាលាដំបូងក្នុងដែនសមត្ថកិច្ចទាំង០៦ខេត្ត ដែលបានបញ្ជូនមកមហាអយ្យការអមសាលាឧទ្ធរណ៍នៅតែមានហួសរយៈពេលកំណត់ ជាហេតុនាំឱ្យមហាអយ្យការហួសថេរវេលាប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់
- កង្វះសាលក្រម សាលក្រមស្តាពរ នៅតាមពន្ធនាគារទាំង០៦ខេត្ត នៅមានចំនួនច្រើន។ ករណីបែបនេះនឹងមិនកើតមានឡើងទេ ប្រសិនបើអនុវត្តបានត្រឹមត្រូវតាមមាត្រា ៣៥៨ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- ភាពមិនអាចទទួលយកបានសម្រាប់បណ្តឹងឧទ្ធរណ៍របស់តំណាងអយ្យការ ករណីខ្លះពុំបានឆ្លងព្រះរាជអាជ្ញា (ពុំមាន ជ ឬ តប ព្រះរាជអាជ្ញា)
- កង្វះចំនួនមន្ត្រីនគរបាលយុត្តិធម៌ច្រើនតាមបណ្តាខេត្ត បណ្តាលឱ្យការចុះហត្ថលេខាលើកំណត់ហេតុនិងកសាងសំណុំរឿងមិនបានត្រឹមត្រូវតាមច្បាប់កំណត់។ សំណុំរឿងព្រហ្មទណ្ឌកសាងមក អ្នកពុំទាន់មាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ចុះហត្ថលេខា អាចប្រឈមនឹងបណ្តឹងសុំមោយភាពរបស់មេធាវី ឬភាគីពាក់ព័ន្ធ។

ខ. សំណូមពរ

- ស្នើសុំអាជ្ញាសាលាចំនួន ០២ រូប និងមន្ត្រីរដ្ឋបាល ០៦ រូប
- ស្នើសុំឱ្យមានវគ្គបណ្តុះបណ្តាលដើម្បីលើកកម្ពស់សមត្ថភាពមន្ត្រី និងក្រឡាបញ្ជី
- ស្នើសុំឱ្យមានប្រព័ន្ធ Data Base សម្រាប់បញ្ចូលទិន្នន័យសំណុំរឿង និងសម្ភារៈបច្ចេកទេសបន្ថែម
- ស្នើសុំអគារអគ្គលេខាធិការដ្ឋាន អគារសម្រាប់មហាអយ្យការ និងអគារស្នាក់នៅ
- ស្នើសុំឱ្យមន្ត្រីនៃសាលាដំបូង នៅពេលទទួលសំណុំរឿងប្តឹងឧទ្ធរណ៍ពីក្រឡាបញ្ជី ត្រូវពិនិត្យលើបញ្ជីរាយលិខិត និងឯកសារក្នុងសំណុំរឿងឱ្យបានត្រឹមត្រូវជាមុន រួចបញ្ជូនមកសាលាឧទ្ធរណ៍ ឱ្យបានលឿនតាមកំណត់ច្បាប់
- សុំឱ្យមានប្រាក់សវនាការសម្រាប់មន្ត្រីពន្ធនាគារ និងក្រឡាបញ្ជីមហាអយ្យការ
- ស្នើសុំរថយន្តចំនួន ០២គ្រឿង សម្រាប់បម្រើការក្នុងអង្គភាព

៤. ទិសដៅការងារសម្រាប់ឆ្នាំ ២០២៥

- បន្តជំរុញការដោះស្រាយគ្រប់រឿងក្តីឱ្យបានយុត្តិធម៌ និងឆាប់រហ័ស
- ប្រឹងប្រែងរៀបចំផែនការថវិកាប្រចាំឆ្នាំ ដើម្បីដោះស្រាយការខ្វះខាតក្នុងអង្គភាព និងរៀបចំសំណើសុំអាជ្ញាសាលា និងមន្ត្រីរដ្ឋបាល
- បង្កើនសមត្ថភាពធនធានមនុស្សដែលមានស្រាប់ ដើម្បីដើរឱ្យទាន់បរិបទសង្គមជាក់ស្តែងតាមរយៈការរៀបចំឱ្យមានការសិក្សាស្រាវជ្រាវបន្ថែម សិក្ខាសាលា ការប្រជុំផ្សព្វផ្សាយ

- បន្តពង្រឹងក្រមសីលធម៌ វិន័យការងារ និងរៀបចំរបាយការណ៍ក្នុងអង្គភាព ឱ្យបានឆាប់រហ័ស និងទាន់ពេលវេលា
- ទំនាក់ទំនងជាមួយប្រធានលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងក្នុងដែនសមត្ថកិច្ច ដើម្បីអនុវត្តការងារបញ្ជូនសំណុំរឿងឱ្យបានឆាប់រហ័ស និងត្រឹមត្រូវ
- ព្យាយាមប្រើប្រាស់នីតិវិធីផ្សះផ្សាសម្របសម្រួលក្នុងសំណុំរឿងរដ្ឋប្បវេណីឱ្យបានច្រើន ដើម្បីធ្វើឱ្យមានភាពសុខដុមរមនាក្នុងសង្គម ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- បង្កើតក្រុមការងារបច្ចេកទេស រៀបចំសេចក្តីណែនាំអំពីការអនុវត្តការងារឱ្យកាន់តែមានប្រសិទ្ធភាពរវាងសាលាឧទ្ធរណ៍ មហាអយ្យការអមសាលាឧទ្ធរណ៍ និងអគ្គលេខាធិការដ្ឋានរដ្ឋបាល
- បង្កើតក្រុមការងារបច្ចេកទេស រៀបចំទម្រង់រូបមន្តអនុវត្ត សាលដីកា ដីកាសម្រេច សម្រាប់ប្រើប្រាស់ក្នុងសាលាឧទ្ធរណ៍បាត់ដំបង ដែលមានការឯកភាពរួមគ្នាតែមួយ
- ប្រជុំពិភាក្សាដោះស្រាយរាល់បញ្ហាស្មុគស្មាញ ចំណុចមិនទាន់ឯកភាពគ្នាពាក់ព័ន្ធការអនុវត្តច្បាប់ការលើកកម្ពស់សេវាយុត្តិធម៌ និងរួមគ្នាពិនិត្យធ្វើការដោះស្រាយបញ្ហាប្រឈមទាំងនោះ ឱ្យមានការឯកភាពរួម ទទួលបានលទ្ធផលល្អប្រសើរ
- សភាស៊ើបសួរបន្តចុះអធិការកិច្ចនៅមន្ទីរស៊ើបសួរសាលាដំបូង ក្នុងដែនសមត្ថកិច្ចទាំង០៦ខេត្តឱ្យបានទៀងទាត់
- ពង្រឹងមន្ត្រីអនុវត្តកិច្ចការបញ្ជូននៅស្នងការដ្ឋាននគរបាល សហការជាមួយលោក លោកស្រីក្រឡាបញ្ជីមហាអយ្យការ អនុវត្តការជូនដំណឹងអំពីសាលដីកាកំពាំងមុខឱ្យបានលទ្ធផលល្អប្រសើរ
- ជំរុញឱ្យស្ថាប័នអយ្យការអមសាលាដំបូងខេត្ត អនុវត្តការងារឱ្យបានត្រឹមត្រូវ និងម៉ឺងម៉ាត់ ព្រមទាំងដោះស្រាយការខ្វះសាលក្រម សាលក្រមស្ថាពរជាមួយពន្ធនាគារក្នុងដែនសមត្ថកិច្ច
- ដោះស្រាយបញ្ហាភាពមិនអាចទទួលយកបានសម្រាប់បណ្តឹងឧទ្ធរណ៍របស់តំណាងអយ្យការ ករណីខ្លះពុំបានឆ្លងព្រះរាជអាជ្ញា (ពុំមាន ជ ឬ តប ព្រះរាជអាជ្ញា)
- ដោះស្រាយបញ្ហាខ្វះចំនួនមន្ត្រីនគរបាលយុត្តិធម៌ក្នុងដែនសមត្ថកិច្ចទាំង០៦ខេត្ត
- ក្រុមការងារមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង បន្តចុះអធិការកិច្ចនៅពន្ធនាគារ ស្នងការដ្ឋានបញ្ជាការដ្ឋាន និងអយ្យការអមសាលាដំបូងក្នុងដែនសមត្ថកិច្ចទាំង០៦ខេត្ត ដើម្បីពង្រឹងការអនុវត្តច្បាប់ក្នុងគោលបំណងរួមដើម្បីចំណាត់ការរឿងក្តីឱ្យមានប្រសិទ្ធភាព និងឆាប់រហ័ស។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។
សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

ថ្ងៃពុធ ៧កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
បាត់ដំបង ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៥
អគ្គលេខាធិការ

ឡៀង.សីយួរ

បានឃើញ និង ឯកភាព
បាត់ដំបង ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៥

អគ្គព្រះរាជអាជ្ញា **ប្រធានសាលាឧទ្ធរណ៍**

ឈួន.សាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ និងមហាអយ្យការអម
សាលាឧទ្ធរណ៍ត្បូងឃ្មុំ

របាយការណ៍ការងារសង្ខេបរបស់សាលាដម្រះក្តី
សម្រាប់សន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារអនាគត ឆ្នាំ២០២៥
សាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ

==========

១. ស្ថានភាពទូទៅ

ក. ធនធានមនុស្ស

ចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី របស់សាលាឧទ្ធរណ៍និងមហាអយ្យការ អមសាលាឧទ្ធរណ៍មាន ចំនួន ៣៤រូប ដែលក្នុងនោះចែកចេញជា ៖

- **ផ្នែកសាលាឧទ្ធរណ៍ ៖** មាន ប្រធានសាលាឧទ្ធរណ៍ចំនួន ០១រូប អនុប្រធានចំនួន ០៣រូប ចៅក្រម ចំនួន ៥រូប និងក្រឡាបញ្ជី ចំនួន ១៤រូប (ចៅក្រម ០១រូប ស្ថិតក្នុងស្ថានភាពទំនេរគ្មានបៀវត្ស)។
- **ផ្នែកមហាអយ្យការ ៖** មាន អគ្គព្រះរាជអាជ្ញា ចំនួន ០១រូប អគ្គព្រះរាជអាជ្ញារង ០២រូប ព្រះរាជអាជ្ញា ចំនួន ០២រូប និងក្រឡាបញ្ជី ០៥រូប។
- **មន្ត្រីនៃអគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ ៖** អគ្គលេខាធិការ ចំនួន ០១រូប អគ្គលេខាធិការរង ចំនួន ០១រូប ប្រធាននាយកដ្ឋាន ចំនួន ០៤រូប អនុប្រធាននាយកដ្ឋាន ចំនួន ០៤រូប ប្រធានការិយាល័យ ចំនួន ០០រូប អនុប្រធានការិយាល័យ ចំនួន ០០រូប មន្ត្រីគ្រប់គ្រងរដ្ឋបាល ចំនួន ១១រូប មន្ត្រីក្រមការ ចំនួន ០៨រូប មន្ត្រីជាប់កិច្ចសន្យា ចំនួន ១៨រូប។

ខ. ហេដ្ឋារចនាសម្ព័ន្ធ

សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ មានទីតាំងស្ថិតនៅភូមិនិគមលើ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។ សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ មានអគារ រដ្ឋបាលចំនួន ០១ ដែលមានសាលសវនាការចំនួន ០១បន្ទប់ សាលប្រជុំចំនួន ០១បន្ទប់ និងបន្ទប់ធ្វើការចំនួន ២០បន្ទប់។ បច្ចុប្បន្ននេះ អង្គភាពបានសាងសង់រួចរាល់ និងបានដាក់ឱ្យដំណើរការនូវសាលសវនាការចំនួន ០២ បន្ទប់ផ្សេងទៀត ដើម្បីបម្រើឱ្យការជំនុំជម្រះក្តីបានប្រព្រឹត្តទៅលឿន រហ័ស និងប្រកបដោយយុត្តិធម៌។ អង្គភាព មានដីទំនេរមួយកន្លែងដែលទទួលបានពីរដ្ឋបាលខេត្តត្បូងឃ្មុំ មានទំហំ ៩០x៣០ ម៉ែត្រការ៉េ សម្រាប់សាងសង់ អគារស្នាក់នៅជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ដែលស្ថិតនៅទិសខាងលិច នៃអគាររដ្ឋបាលរបស់សាលាដំបូង និង អយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ។

គ. លទ្ធផលសន្និបាតផ្ទៃក្នុងស្ថាប័នសម្រាប់ឆ្នាំ២០២៤

ឆ្លងកាត់ការពិភាក្សាផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមក ការលើកឡើងពីបញ្ហាប្រឈមនានា ការចូលរួមដោះស្រាយរបស់សមាជិក សមាជិកា ដែលបានចូលរួមក្នុងអង្គសន្និបាតនាពេលនេះបានរកឃើញនូវការឯកភាពរួមចំណុចខ្លាំង និងចំណុចខ្សោយរបស់ស្ថាប័នដូចខាងក្រោម ៖

- បន្តជំរុញការដោះស្រាយរឿងក្តីព្រហ្មទណ្ឌ និងរឿងក្តីរដ្ឋប្បវេណីឱ្យបានលឿន ឆាប់រហ័ស និងត្រឹមត្រូវ។
- បន្តជំរុញអនុវត្តនីតិវិធីផ្សះផ្សាក្នុងសំណុំរឿងរដ្ឋប្បវេណីឱ្យបានច្រើន ដើម្បីធ្វើឱ្យមានសុខដុមរម្យនាក្នុងសង្គម។
- ពង្រឹងឱ្យកាន់តែមានប្រសិទ្ធិភាពបន្ថែមទៀត លើកិច្ចការងារបញ្ជូនជាមួយប្រៃសណីយ៍កម្ពុជាលើដីការកោះរឿងក្តីរដ្ឋប្បវេណី និងដីការកោះរឿងក្តីព្រហ្មទណ្ឌ។
- ការស្នើសុំមោយភាពចំពោះការផ្ទេរសមត្ថកិច្ចក្នុងរឿងក្តីព្រហ្មទណ្ឌ ស្របតាមមាត្រា១២៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រសិនបើចៅក្រមស៊ើបសួរមើលឃើញថាមិនមានសមត្ថកិច្ច។
- ការស្នើសុំយកវត្ថុតាងយកទៅប្រើប្រាស់ តាមគោលការណ៍ច្បាប់ យើងមិនមានសិទ្ធិអំណាចក្នុងការចាត់ចែងនោះទេ ព្រោះវត្ថុតាងអាចត្រូវបានប្រគល់ទៅឱ្យម្ចាស់ដើមវិញ។
- ពាក់ព័ន្ធនឹងដីរដ្ឋដែលមានការកាត់ឃ្លៀល ហើយមានទំនាស់គូភាគីជាពលរដ្ឋ តាមច្បាប់អំណាចរបស់ព្រះរាជអាជ្ញា អាចអនុវត្តតាមគោលការណ៍កាលានុវត្តភាព ដែលជាឆន្ទានុសិទ្ធិក្នុងការអនុវត្ត ឬតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។
- ចំពោះជនដែលត្រូវបានឃាត់ខ្លួនក្នុងករណីគ្រឿងញៀន អាស្រ័យលើព្រះរាជអាជ្ញា ថាតើត្រូវឃុំខ្លួនបន្ត ឬដោះលែងដោយអាស្រ័យលើអង្គហេតុ វត្ថុតាងនិងសំណុំរឿងនីមួយៗ។
- ពាក់ព័ន្ធការខ្វះមន្ត្រីនគរបាលយុត្តិធម៌មន្ត្រីដែលមានគុណសម្បត្តិក្នុងការទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ អាចស្នើសុំទៅក្រសួងសាមី ដើម្បីក្រសួងសាមីចេញប្រកាសស្នើសុំនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ មកក្រសួងយុត្តិធម៌។
- ពាក់ព័ន្ធនឹងពន្ធនាគារសូមឱ្យប្រធានពន្ធនាគារទាំងអស់ជជែកជាមួយអគ្គនាយកដ្ឋានពន្ធនាគារ នៃក្រសួងមហាផ្ទៃ ពាក់ព័ន្ធការផ្ទេរជនជាប់ឃុំពីពន្ធនាគារមួយទៅពន្ធនាគារមួយទៀត ត្រូវតែមានឯកសារគ្រប់គ្រាន់និងត្រឹមត្រូវ មុនពេលទទួលឃុំខ្លួនបន្ត។
- ពង្រឹងការអនុវត្តន៍លើការជូនដំណឹងអំពីសាលដីកាកំបាំងមុខឱ្យបានល្អប្រសើរ។
- សម្រាប់ការដោះលែងជនណាម្នាក់ដោយសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ និងសាលដីការបស់សភាស៊ើបសួរពុំចាំបាច់មានសេចក្តីសម្រេច ឬដីកាបង្គាប់ឱ្យដោះលែងនោះទេ។
- រាល់ដីកាឃុំខ្លួន របស់សាលាដំបូងភាគច្រើនអត់មានសំអាងហេតុ ស្នើសុំឱ្យមានសំអាងហេតុត្រឹមត្រូវ។
- ស្នើសុំធ្វើវិសោធនកម្មច្បាប់ភូមិបាលមាត្រា២៥៣ ក្នុងដំណោះស្រាយរឿងក្តីរដ្ឋប្បវេណី។
- តុលាការត្រូវចេញសាលក្រមចំពោះការទាមទាររបស់គូភាគីស្នើសុំ មិនត្រូវចេញសាលក្រមចំពោះចំណុចណាដែលភាគីមិនបានស្នើសុំទេ (មាត្រា១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- តុលាការត្រូវសម្រេចសេចក្តីអំពីករណីយកិច្ចទទួលបន្ទុកប្រាក់ប្រដាប់ក្តី ទោះបីគ្មានការស្នើសុំក៏ដោយ។
- ពង្រឹងលើការបញ្ជូនដីការកោះរឿងក្តីព្រហ្មទណ្ឌ ឱ្យបញ្ជូនដល់ដៃគូភាគីក្នុងសំណុំរឿងតាមរយៈសេវាប្រៃសណីយ៍។
- ដើម្បីឱ្យការដោះស្រាយសំណុំរឿងបានឆាប់រហ័ស ជៀសវាងការបង្វិលសំណុំរឿងចុះឡើង ដែលធ្វើឱ្យគូភាគីត្រូវចំណាយពេលវេលាច្រើននៅក្នុងដំណើរការរឿងក្តី ចៅក្រមទទួលបន្ទុកដោះស្រាយលើសំណុំរឿងដែលពាក់ព័ន្ធនឹងដីធ្លី ត្រូវចុះធ្វើការពិនិត្យដល់ទីតាំងដីទំនាស់ ឬចាត់ឱ្យធ្វើការគូសគំនូសបង្ហាញទីតាំងដីទំនាស់ដើម្បីកំណត់ឱ្យបានច្បាស់លាស់នូវអត្តសញ្ញាណដីដែលមានវិវាទ។
- ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន របស់ចៅក្រមស៊ើបសួរត្រូវសរសេរសំអាងហេតុឱ្យបានច្បាស់លាស់ស្របតាមស្ថានភាពជាក់ស្តែងនៃសំណុំរឿង ដោយមិនត្រូវបន្តប្រើរូបមន្តគូសធីច(√) ដដែលនោះទេ។
- ក្នុងសំណុំរឿងជាអនីតិជន ពេលស្តាប់ចម្លើយជនត្រូវចោទជាអនីតិជន ចៅក្រមស៊ើបសួរត្រូវចាត់តាំងមេធាវីមកអមអនីតិជន ដូចបានកំណត់ក្នុងបញ្ញត្តិមាត្រា៣២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ជៀសវាងការរំលោភបំពានសិទ្ធិរបស់អនីតិជន។

- សំណុំរឿងរំលោភសេពសន្តវៈ ឬរួមភេទជាមួយអនីតិជនមួយចំនួន ចៅក្រមស៊ើបសួរត្រូវចាត់មន្ត្រីជំនាញឱ្យធ្វើកោសល្យវិច័យលើផ្លូវភេទរបស់ជនរងគ្រោះភ្លាម នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ជៀសវាងឱ្យបាត់កស្តុតាងដាក់បន្ទុក ឬដោះបន្ទុកលើជនត្រូវចោទ។
- ក្នុងសំណុំរឿងព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរត្រូវធ្វើការស៊ើបសួរកអត្តសញ្ញាណ(អត្តសញ្ញាណប័ណ្ណ) របស់ជនត្រូវចោទឱ្យបានច្បាស់លាស់ មិនត្រូវផ្អែកលើតែអត្តសញ្ញាណរបស់ជនត្រូវចោទដែលមន្ត្រីនគរបាលយុត្តិធម៌កសាងសំណុំរឿងបញ្ជូនមកនោះទេ ជៀសវាងតុលាការផ្តន្ទាទោសលើជនជាប់ចោទខុសអត្តសញ្ញាណ។
- ចៅក្រមស៊ើបសួរ ត្រូវធ្វើការស៊ើបសួរលើអង្គហេតុនីមួយៗដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរឱ្យបានច្បាស់លាស់ លើជនត្រូវចោទអំពីទីកន្លែង និងពេលវេលានៃការប្រព្រឹត្តបទល្មើស រួមទាំងកស្តុតាងដាក់បន្ទុក ឬដោះបន្ទុកផ្សេងៗទៀត ជៀលវាងពេលចេញដីកាដំណោះស្រាយបញ្ជូនរឿងមកជំនុំជម្រះ ចៅក្រមស៊ើបសួរមិនបានកំណត់អំពីទីកន្លែង និងពេលវេលានៃការប្រព្រឹត្តបទល្មើសចំពោះអង្គហេតុនីមួយៗឱ្យដាច់ដោយឡែកពីគ្នា និងការកំណត់យកទីកន្លែង និងពេលវេលានៃការប្រព្រឹត្តបទល្មើសតែមួយគឺនៅទីកន្លែង និងពេលវេលាចាប់ឃាត់ខ្លួនជនត្រូវចោទ។
- ការចេញដីកាដំណោះស្រាយបញ្ជូនជនត្រូវចោទមកជំនុំជម្រះ ពីបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចៅក្រមស៊ើបសួរត្រូវកំណត់អំពីកថាខណ្ឌឱ្យបានច្បាស់ ដើម្បីជាមូលដ្ឋានការសម្រេចសេចក្តីផ្តន្ទាទោសលើជនជាប់ចោទ។

ឃ. ព្រឹត្តិការណ៍ ឬកម្មវិធីការចារនានា

- ឯកឧត្តម **ម៉ុង មុនីចរិយា** ប្រធានសាលាឧទ្ធរណ៍ និងឯកឧត្តម **ហួត វុទ្ធី** អគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ បានអញ្ជើញចូលរួមកិច្ចប្រជុំស្តីពី ការបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកផែនការសកម្មភាពការងារឆ្នាំ២០២៤ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី(ក.ជ.ក.ស) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា នៅរាជធានីភ្នំពេញ។
- ឯកឧត្តម **ម៉ុង មុនីចរិយា** ប្រធានសាលាឧទ្ធរណ៍ បានចូលរួមកិច្ចប្រជុំ របស់គណៈកម្មការទទួលបន្ទុកដឹកនាំរៀបចំធ្វើវិសោធនកម្មច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ និងរដ្ឋប្បវេណី និងកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ចំនួន១០លើក ក្នុងរយៈពេល១២ខែ ឆ្នាំ២០២៤ រួមទាំងកិច្ចប្រជុំពិភាក្សាស្តីពីការរៀបចំតុលាការពាណិជ្ជកម្ម ស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។
- ឯកឧត្តម **ម៉ុង មុនីចរិយា** ប្រធានសាលាឧទ្ធរណ៍ និងឯកឧត្តម **ហួត វុទ្ធី** អគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ បានចូលរួមក្នុងកម្មវិធីសិក្ខាសាលាពិគ្រោះយោបល់លើ សេចក្តីព្រាងច្បាប់ស្តីពីការចាត់ចែងជាបណ្តោះអាសន្ននូវរ៉ែត្មចាប់យក ស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។
- ឯកឧត្តម **ម៉ុង មុនីចរិយា** ប្រធានសាលាឧទ្ធរណ៍ និងឯកឧត្តម **ហួត វុទ្ធី** អគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ បានចូលរួមសន្និបាតបូកសរុបការងារឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤ របស់តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល។
- ឯកឧត្តម **ម៉ុង មុនីចរិយា** ប្រធានសាលាឧទ្ធរណ៍ បានអញ្ជើញចូលរួមកិច្ចប្រជុំពិនិត្យសេចក្តីព្រាងវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌ តាមវិធីសាស្ត្រថ្មី និងបានអញ្ជើញចូលរួមប្រជុំក្រុមការងារបច្ចេកទេសទី១ នៅទីស្តីការក្រសួងយុត្តិធម៌។
- ឯកឧត្តម **ម៉ុង មុនីចរិយា** ប្រធានសាលាឧទ្ធរណ៍ និងឯកឧត្តម **ហួត វុទ្ធី** អគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពី កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគាំទ្រវិស័យយុត្តិធម៌ និងកម្មវិធីកំណែទម្រង់ប្រព័ន្ធយុត្តិធម៌។
- ឯកឧត្តម **ម៉ុង មុនីចរិយា** ប្រធានសាលាឧទ្ធរណ៍ និងឯកឧត្តម **យ៉ា ណារិន** អនុប្រធានសាលាឧទ្ធរណ៍ បានអញ្ជើញចូលរួមកម្មវិធីជួបសំណេះសំណាលជាមួយចៅក្រមជាតិ និងចៅក្រម NOGUCHI រួមទាំងបាន

អញ្ជើញចូលរួមសិក្ខាសាលាស្តីពី"សមិទ្ធផលសម្រេចបាន និងកេរដំណែលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

- ឯកឧត្តម **ង៉ុំ សោភ័ណ** អគ្គលេខាធិការ បានអញ្ជើញដឹកនាំមន្ត្រីរាជការមួយចំនួនមកពីនាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ ចូលរួមប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២៣ នៃការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ឯកឧត្តម **ង៉ុំ សោភ័ណ** អគ្គលេខាធិការ បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពី កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគាំទ្រវិស័យយុត្តិធម៌ និងកម្មវិធីកំណែទម្រង់ប្រព័ន្ធយុត្តិធម៌។

២. សមិទ្ធផលការងារ

ក. មហាអយ្យការអមសាលាឧទ្ធរណ៍៖

ក.១ កិច្ចការទំនាក់ទំនង និងរដ្ឋបាលបច្ចេកទេស (អធិការកិច្ច កិច្ចការសម្បថមេធាវី និងមន្ត្រីនគរបាលយុត្តិធម៌)

ក.១.១ អធិការកិច្ចមហាអយ្យការ៖ ចុះពង្រឹងកិច្ចការអយ្យការអមសាលាដំបូង នគរបាលយុត្តិធម៌ និងពិនិត្យអង្កេតពន្ធនាគារខេត្តត្បូងឃ្មុំ កំពង់ចាម កំពង់ធំ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលអប់រំកែប្រែទី៣(ត្រពាំងផ្លុង)។

ក.២ ចំណាត់ការលើសំណុំរឿង

ក.២.១ ចំណាត់ការសំណុំរឿងសភាព្រហ្មទណ្ឌ និងសភាស៊ើបសួរ

ប្រភេទចំណាត់ការ		សំណុំរឿង			ចាត់ការរួច	កំពុងចាត់ការ	ផ្សេងៗ
		សល់ពីមុន	ចូលថ្មី	សរុប			
១	សំណុំរឿងសភាស៊ើបសួរ	០០	១៥៦	១៥៦	១៥៦	០០	
២	សំណុំរឿងសភាព្រហ្មទណ្ឌ	០០	៦១១	៦១១	៦១១	០០	(ស្របទោស៤ បង្វិលពីកំពូល៨)
៣	សំណុំរឿងរដ្ឋប្បវេណី (បានចូលរួម)	០០	០០	០០	០០	០០	

ក.២.២ ចំណាត់ការសំណុំរឿងតម្កល់ទុកឥតចាត់ការ

	សំណុំរឿង			សំណុំរឿងចាត់ការរួច		រឿងសល់កំពុងចាត់ការ
	សល់ពីមុន	ចូលថ្មី	សរុប	តម្កល់	អធិបញ្ជា	
សរុប	៤៩	១៣៦	១៨៥	១៤៣	០៦	៣៦

ក.៣ កិច្ចការផ្សេងទៀតរបស់មហាអយ្យការ

- កិច្ចប្រជុំពិភាក្សាការងារជាមួយអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ និងមណ្ឌលអប់រំកែប្រែទី៣ (ត្រពាំងផ្លុង) ក្រោមអធិបតីភាព ឯកឧត្តម **ហៀង សុភក្ត្រ** អគ្គព្រះរាជអាជ្ញារង នៃមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ។

ខ. សាលាឧទ្ធរណ៍៖

ខ.១ ទិន្នន័យចំណាត់ការសភាព្រហ្មទណ្ឌ

សំណុំរឿង			ចាត់ការរួច	សល់កំពុងចាត់ការ
សល់ពីមុន	ចូលថ្មី	សរុប		
១៤៥	៥៩៥	៧៤០	៥៩៦	១៤៤

ខ.២ ទិន្នន័យចំណាត់ការសភាស៊ើបសួរ

សំណុំរឿង			ចាត់ការរួច	សល់កំពុងចាត់ការ
សល់ពីមុន	ចូលថ្មី	សរុប		
៣០	១៥១	១៨១	១៦៣	១៨

ខ.៣ ទិន្នន័យចំណាត់ការសំណុំរឿងរដ្ឋប្បវេណី (មុនអង្គសេចក្តី)

សំណុំរឿង				សំណុំរឿងចាត់ការរួច					រឿងសល់កំពុងចាត់ការ
សាលាជម្រះក្តី	សល់ពីមុន	ចូលថ្មី	សរុប	ដកពាក្យបណ្តឹង	សះជា	ផ្ទេរសមត្ថកិច្ច	ជម្រះរួច	សរុប	សរុប
សាលាដំបូង	៣៦	៤២	៧៨	០៨	០០	០០	៦២	៧០	០៨
តុលាការកំពូល	០០	០០	០០	០០	០០	០០	០០	០០	០០

ខ.៤ ទិន្នន័យចំណាត់ការសំណុំរឿងរដ្ឋប្បវេណី (អង្គសេចក្តី)

សំណុំរឿង				សំណុំរឿងចាត់ការរួច					រឿងសល់កំពុងចាត់ការ
សាលាជម្រះក្តី	សល់ពីមុន	ចូលថ្មី	សរុប	ដកពាក្យបណ្តឹង	សះជា	ផ្ទេរសមត្ថកិច្ច	ជម្រះរួច	សរុប	
សាលាដំបូង	១១៦	១៥៤	២៧០	១៦	០៥	០០	១៣៨	១៥៩	១១១
តុលាការកំពូល	០១	១០	១១	០០	០០	០០	០៥	០៥	០៦

ខ.៥ ទិន្នន័យចំណាត់ការសំណុំរឿងជំនុំជម្រះសាជាថ្មី

សំណុំរឿង				សំណុំរឿងចាត់ការរួច					សល់កំពុងចាត់ការ
សាលាជម្រះក្តី	សល់ពីមុន	ចូលថ្មី	សរុប	ដកពាក្យបណ្តឹង	សះជា	ផ្ទេរសមត្ថកិច្ច	ជម្រះរួច	សរុប	សរុប
សាលាដំបូង	០៨	០១	០៩	០០	០០	០០	០៩	០៨	០០

ខ.៦ ទិន្នន័យសំណុំរឿងរដ្ឋប្បវេណី (រក្សាការពារ)

សំណុំរឿង			សំណុំរឿងចាត់ការរួច					រឿងកំពុងចាត់ការបន្ត
សល់ពីមុន	ចូលថ្មី	សរុប	ដកពាក្យបណ្តឹង	សះជា	ផ្ទេរសមត្ថកិច្ច	ជម្រះរួច	សរុប	
៤២	៣៩	៨១	០៦	០០	០០	៥៣	៥៩	២២

៣. បញ្ហាប្រឈម និងសំណូមពរ

ក. បញ្ហាប្រឈម

- ធនធានមន្ត្រីរដ្ឋបាលសម្រាប់ជំនាញគាំទ្រនីតិវិធីតុលាការ នៅខ្វះ និងមន្ត្រីខ្លះ មិនទាន់មានសមត្ថភាពគ្រប់គ្រាន់ និងយល់ដឹងពីនីតិវិធីតុលាការ។
- ចំនួនចៅក្រមអសនៈ ចៅក្រមអយ្យការ នៅមានចំនួនតិចមិនទាន់សមាមាត្រនឹងចំនួនសំណុំរឿង ដែលធ្វើឱ្យការពិនិត្យ និងដោះស្រាយសំណុំរឿងមួយចំនួនតូចមិនទាន់ពេលវេលា។
- អយ្យការអមសាលាដំបូងខេត្តមួយចំនួនពុំបានផ្តល់សាលក្រម ដីកាសម្រេច របាយការណ៍របស់អយ្យការអមសាលាដំបូង និងបញ្ជីរាយនាមជនជាប់ឃុំ មកមហាអយ្យការ មិនបានទៀងទាត់។
- ពុំមានមន្ត្រីអាជ្ញាសាលា សម្រាប់ទទួលបន្ទុកកិច្ចការបញ្ជូន។
- ពុំទាន់មានថវិកា សម្រាប់សាងសង់អគាររដ្ឋបាលបន្ថែម របស់សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍តួរងឃ្មុំ និងអគារស្នាក់នៅរបស់មន្ត្រីរាជការ។
- ពុំមានសម្ភារៈ បរិក្ខា ថវិកា ប្រើប្រាស់គ្រប់គ្រាន់ ក្នុងការបំពេញការងារ និងការចុះបេសកកម្ម។
- មានការលំបាក មិនមានកន្លែងស្នាក់នៅ សម្រាប់មន្ត្រីដែលមានលំនៅដ្ឋានក្រៅខេត្តតួរងឃ្មុំ ដែលជាទីតាំងសាលាឧទ្ធរណ៍ស្ថិតនៅ។
- មន្ត្រីជាប់កិច្ចសន្យានៅមានចំនួនតិចនៅឡើយ។

ខ. សំណូមពរ

- ស្នើសុំមន្ត្រីរាជការបន្ថែមដើម្បីបំពេញតម្រូវការ និងទំហំការងារដែលមានជាក់ស្តែងរបស់សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ។
- ស្នើសុំមន្ត្រីជាប់កិច្ចសន្យាចំនួន ១០នាក់បន្ថែមទៀត ដើម្បីជួយការងារនៅតាមនាយកដ្ឋានដែលកំពុងមានការខ្វះខាតមន្ត្រី។
- ស្នើសុំឥណទានថវិកាបន្ថែម។
- ស្នើសុំថវិកាសម្រាប់សាងសង់អគាររដ្ឋបាល និងអគារស្នាក់នៅរបស់មន្ត្រីសាលាឧទ្ធរណ៍ត្បូងឃ្មុំ។
- ស្នើសុំរថយន្តចំនួន ០៤គ្រឿង សម្រាប់ធ្វើដំណើរបំពេញបេសកកម្មរដ្ឋបាល ការចុះពិនិត្យទីតាំងជាក់ស្តែង និងការចុះអធិការកិច្ចនៅតាមបណ្តាខេត្តក្នុងដែនសមត្ថកិច្ចសាលាឧទ្ធរណ៍ត្បូងឃ្មុំ។

៤. ទិសដៅការងារសម្រាប់ឆ្នាំ២០២៥

១. <u>ទិសដៅការងាររដ្ឋបាលទូទៅ</u>

- សម្រួល និងពង្រឹងយន្តការ ការងាររបស់ចៅក្រម ក្រឡាបញ្ជី សម្របសម្រួលឱ្យការងាររដ្ឋបាល និងរដ្ឋបាលគាំទ្រ កាន់តែមានភាពច្បាស់លាស់។
- ពង្រឹងការងារបន្ថែមទៀត ចំពោះការគ្រប់គ្រង ការផ្ទេរ ការតម្កល់នូវសំណុំរឿងក្នុងដំណាក់កាលនៃការទទួលខុសត្រូវរបស់ចៅក្រម ក្រឡាបញ្ជី និងរដ្ឋបាល។
- ធានាឱ្យបាននូវកិច្ចការដំណើរការ ការងាររដ្ឋបាលរបស់សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ប្រកបដោយប្រសិទ្ធភាព រហ័ស និងទាន់ពេលវេលា ។
- បន្តការងារបញ្ជូនសំណុំរឿងជាប់បណ្តឹងសាទុក្ខទៅតុលាការកំពូលអោយបានឆាប់រហ័ស តាមច្បាប់ជាធរមាន។
- បន្តការផ្សព្វផ្សាយសកម្មភាពនានា របស់សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងលិខិតបទដ្ឋានគតិយុត្ត ឱ្យបានកាន់តែទូលំទូលាយ តាមរយៈគេហទំព័រ និងហ្វេសបុកផេក របស់អង្គភាព។
- រៀបចំប្រព័ន្ធព័ត៌មានវិទ្យា ឱ្យកាន់តែបំពេញមុខងារបានច្រើន និងសកម្មថែមទៀត។
- ពង្រឹងការចុះបញ្ជីរឿងក្តីឱ្យបានល្អប្រសើរ ។
- ជម្រុញមន្ត្រីរាជការនៅសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ឱ្យប្តេជ្ញាចិត្តបំពេញការងារដោយមានការទទួលខុសត្រូវខ្ពស់ និងសកម្ម។
- បន្តជ្រើសរើសសាលក្រមល្អៗពីសាលាដំបូងខេត្តទាំង៨ មួយចំនួន ដើម្បីដាក់ចូលក្នុង Website។
- បន្តអនុវត្តនូវគម្រោងចុះបញ្ជីសំណុំរឿងព្រហ្មទណ្ឌ រវាងសាលាឧទ្ធរណ៍ និងសាលាដំបូងខេត្តទាំង៨។

២. <u>ទិសដៅការងារពង្រឹងសេវា និងគុណភាពយុត្តិធម៌</u>

- ពង្រឹងការយកចិត្តទុកដាក់បន្ថែមគ្រប់ផ្នែក ដើម្បីផ្តល់យុត្តិធម៌ ធានាបាននូវការការពារ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម អាយុជីវិត សេចក្តីថ្លៃថ្នូរ ផលប្រយោជន៍រដ្ឋ និងឯកជន តាមច្បាប់ និងប្រកាន់ខ្ជាប់នូវការដាស់តឿនអនុវត្តអភិក្រម៥ គឺ "**ងូតទឹក ដុសក្អែល ឆ្នុះកញ្ចក់ ព្យាបាល និងរះកាត់**"។
- ចូលរួមអនុវត្តនូវយុទ្ធនាការជម្រុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ របស់ក្រសួងយុត្តិធម៌ ដោយគោរពឱ្យបានម៉ឺងម៉ាត់នូវអភិក្រម "**លឿន ត្រឹមត្រូវ និងយុត្តិធម៌ ដោយផ្អែកលើច្បាប់**"។
- ចូលរួមអនុវត្តនូវយុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ របស់ក្រសួងយុត្តិធម៌ ដោយគោរពឱ្យបានម៉ឺងម៉ាត់នូវអភិក្រម៣ គឺ "**មិនធ្វើឱ្យប៉ះពាល់ដល់ឯករាជ្យនៃអំណាចតុលាការ, មិនធ្វើបុរេនិច្ឆ័យលើការសម្រេចសេចក្តីរបស់តុលាការ, អនុវត្តដោយតម្លាភាព ភាពច្បាស់លាស់ ភាពត្រឹមត្រូវ និងយុត្តិធម៌**"។
- បន្តការដោះស្រាយសំណុំរឿងជាអាទិភាព និងដោយម៉ឺងម៉ាត់ មានដូចជា សំណុំរឿងគ្រឿងញៀន សំណុំរឿងគ្រោះថ្នាក់ចរាចរណ៍ សំណុំរឿងបទល្មើសព្រៃឈើ ឱ្យបានឆាប់រហ័ស ត្រឹមត្រូវ និងយុត្តិធម៌។
- ពន្លឿនសវនាការជំនុំជម្រះក្តី ឱ្យលឿនជៀសផុតពីការកកស្ទះ ស្របតាមការណែនាំរបស់ក្រសួងយុត្តិធម៌។

- បន្តការចុះអធិការកិច្ចរបស់សភាស៊ើបសួរ និងអង្កេតមន្ទីរស៊ើបសួរសាលាដំបូងខេត្តទាំង៨ ឱ្យបានទាន់កម្មវិធីការគ្រោងទុក ប្រកបដោយប្រសិទ្ធភាពនិងដើម្បីធានាឱ្យបាននូវកិច្ចដំណើរការបានល្អប្រសើរ ត្រឹមត្រូវស្របតាមនីតិវិធីជាធរមាន។
- បន្តការចុះអធិការកិច្ចរបស់មហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ទៅតាមអយ្យការអមសាលាដំបូងខេត្តទាំង៨ ពង្រឹងនគរបាលយុត្តិធម៌ និងអង្កេតពន្ធនាគារ ឱ្យបានទាន់កម្មវិធីដែលបានគ្រោងទុកប្រកបដោយប្រសិទ្ធភាព និងដើម្បីធានាឱ្យបាននូវកិច្ចដំណើរការបានល្អប្រសើរ ត្រឹមត្រូវស្របតាមនីតិវិធីជាធរមាន ។
- រៀបចំបង្កើនសមត្ថភាពប្រព័ន្ធទិន្នន័យចុះបញ្ជីសំណុំរឿង ដោយបន្ថែមនូវបណ្តុំបទល្មើសឱ្យកាន់តែមានប្រសិទ្ធភាព។
- បន្តក្នុងការលើកកម្ពស់ប្រសិទ្ធភាព គុណភាព សមត្ថភាពស្ថាប័នតុលាការក្នុងការផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋ។
- បន្តការផ្សព្វផ្សាយកម្មវិធីជំនុំជម្រះ របស់សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំឱ្យបានកាន់តែទូលំទូលាយ តាមរយៈគេហទំព័រ និងហ្វេសបុកផេក របស់អង្គភាព។
- ពង្រឹង និងបង្កើនសមត្ថភាពនៃការតាក់តែងសេចក្តីសម្រេចប្រកបដោយគុណភាព។
- បន្តផ្តល់អាទិភាពជាចម្បងដល់សំណុំរឿងទាំងឡាយណាដែលពាក់ព័ន្ធនឹងស្ត្រី និងកុមារ (អនីតិជន) ពាក់ព័ន្ធជនជាប់ឃុំក្នុងពន្ធនាគារ ត្រូវពន្លឿននីតិវិធីដោះស្រាយឱ្យបានឆាប់រហ័ស និងដាក់កម្មវិធីជំនុំជម្រះជាអាទិភាពផងដែរ។
- បន្តរៀបចំប្រជុំជាមួយមន្ត្រីពន្ធនាគារ និងមន្ត្រីនគរបាលយុត្តិធម៌ជារៀងរាល់ត្រីមាស។
- បន្តយកចិត្តទុកដាក់ក្នុងការអនុវត្តការងារអាទិភាព ដែលដាក់ចេញដោយក្រសួងយុត្តិធម៌។

ថ្ងៃចន្ទ ៥កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
ត្បូងឃ្មុំ ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៥
អគ្គលេខាធិការ

ឌុំ សោភ័ណ

បានឃើញ និង ឯកភាព
ត្បូងឃ្មុំ ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៥

អគ្គព្រះរាជអជ្ញា

ហួត ភូដ្ឋី

ប្រធានសាលាឧទ្ធរណ៍

ម៉ុង មុនីចរិយា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការ
អមសាលាឧទ្ធរណ៍ព្រះសីហនុ
អគ្គលេខាធិការដ្ឋានរដ្ឋបាល
លេខ ៤៧៤ សបអ.អ/ច៥

របាយការណ៍ការងារសង្ខេបរបស់សាលាដម្រះក្តី
សម្រាប់សន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារអាទិភាព ឆ្នាំ២០២៥
សាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ
សូមគោរពជូន
ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

១. ស្ថានភាពទូទៅ

-ស្ថិតិធនធានមនុស្ស

ល.រ	មុខតំណែង	ចំនួន	ស្រី	ជនពិការ
សាលាឧទ្ធរណ៍		១១រូប	០១រូប	
១	ឯកឧត្តមប្រធាន	១រូប	០រូប	
២	ឯកឧត្តមអនុប្រធាន	៣រូប	០រូប	
៣	ចៅក្រម	៧រូប	១រូប	
មហាអយ្យការអមសាលាឧទ្ធរណ៍		៦រូប	១រូប	
១	ឯកឧត្តមអគ្គព្រះរាជអាជ្ញា	១រូប	០រូប	
២	ឯកឧត្តមអគ្គព្រះរាជអាជ្ញារង	២រូប	១រូប	
៣	ព្រះរាជអាជ្ញា	៣រូប	០រូប	
ក្រឡាបញ្ជី		១៧រូប	៦រូប	
១	ក្រឡាបញ្ជីតុលាការ	៩រូប	៦រូប	
២	ក្រឡាបញ្ជីមហាអយ្យការ	៤រូប	០រូប	
៣	ក្រឡាបញ្ជីកម្មសិក្សា	៤រូប	២រូប	
អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍		៤៩រូប	៦រូប	
១	អគ្គលេខាធិការ	១រូប	០រូប	
២	អគ្គលេខាធិការរង	៤រូប	០រូប	
៣	ប្រធាននាយកដ្ឋាន	៤រូប	១រូប	
៤	អនុប្រធាននាយកដ្ឋាន	៥រូប	១រូប	
៥	ប្រធានការិយាល័យ	០រូប	០រូប	
៦	អនុប្រធានការិយាល័យ	១រូប	០រូប	
៧	មន្ត្រីគ្រប់គ្រងរដ្ឋបាល "ក"	១០រូប	៤រូប	
៨	មន្ត្រីក្រមការ "ខ"	៤រូប	១រូប	
៩	លេខាធិការ "គ"	០រូប	០រូប	
១០	មន្ត្រីកម្មសិក្សា	៣រូប	០រូប	
១១	មន្ត្រីជាប់កិច្ចសន្យា	១៧រូប	៦រូប	

-ហេដ្ឋារចនាសម្ព័ន្ធ

សាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ មានទីតាំងស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានអគារចំនួន០១ កម្ពស់៣ជាន់ ដែលមានបន្ទប់ដូចខាងក្រោម៖

*មានចំនួន២៨បន្ទប់ ក្នុងនោះបន្ទប់ធ្វើការមានចំនួន២១, សាលប្រជុំចំនួន០២ (សាលប្រជុំធំ១ និងតូច១) សាលសវនាការចំនួន០៣ (ព្រហ្មទណ្ឌ២ និងរដ្ឋប្បវេណី១), ឃ្លាំងរក្សាទុកសំណុំរឿងចំនួន១ និងបន្ទប់មេធាវីចំនួន១។

-លទ្ធផលសន្និបាតថ្នៃក្នុងស្ថាប័ន ឆ្នាំ២០២៤

សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៤ និងកំណត់ទិសដៅការងារអាទិភាពឆ្នាំ២០២៥ បានប្រព្រឹត្តទៅរយៈពេលពេញមួយថ្ងៃ នាថ្ងៃទី២២ ខែមករា ឆ្នាំ២០២៥ ។

ឯកឧត្តមអគ្គព្រះរាជអាជ្ញា បានថ្លែងសុន្ទរកថាអន្តរាគមន៍ ដោយបានរំលេចនូវអត្ថន័យសំខាន់ៗដែលមានខ្លឹមសារថា៖

១-គោលការណ៍សំខាន់ យើងនៅតែបន្តអនុវត្តជាប់រហូត ដោយពុំមានការកែប្រែឡើយ។

២-សន្និបាតនាពេលនេះ គប្បីលើកប្រធានបទឲ្យកាន់តែស៊ីជម្រៅថែមទៀតទៅលើការធ្វើអធិការកិច្ចនៅអង្គការអយ្យការ-មន្ទីរស៊ើបសួរនៃសាលាដំបូង, ពន្ធនាគារ និងនគរបាលយុត្តិធម៌គ្រប់ផ្នែក ដើម្បីពង្រឹងការបង្កសំណុំរឿងរហូតដល់ការសម្រេចសេចក្តីពោរពេញដោយគុណភាព។

៣-ត្រូវពង្រឹងជាចាំបាច់នូវកិច្ចដំណើរការរដ្ឋបាល ដើម្បីឲ្យមានសេវាគាំទ្រវិងមាំ និងមានភាពច្បាស់លាស់ធ្វើយ៉ាងណាអនុវត្តឲ្យបាននូវអភិក្រមការងាររបស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** គឺ **លឿន ត្រឹមត្រូវ យុត្តិធម៌ និងមិនពុករលួយ** ។ ការងារបន្ថែមថ្មីទៀតដែលត្រូវយកចិត្តទុកដាក់ខ្ពស់បំផុតនោះគឺ **យុទ្ធនាការជម្រុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតំបន់ដែលសមត្ថកិច្ចសាលាឧទ្ធរណ៍ព្រះសីហនុយើងនេះ** និង **យុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ។**

ក្នុងឱកាសនោះ **ឯកឧត្តម សុខ កល្យាណ** ប្រធានសាលាឧទ្ធរណ៍ព្រះសីហនុ បានថ្លែងសុន្ទរកថាអន្តរាគមន៍ដែលមានខ្លឹមសារសំខាន់ៗជាអាទិ៍៖

១-ឯកឧត្តមបានរំលេចអំពីស្ថិតិ និងវឌ្ឍនភាពនៃការដោះស្រាយរឿងក្តីព្រហ្មទណ្ឌ និងរឿងក្តីរដ្ឋប្បវេណីនៅសាលាឧទ្ធរណ៍ព្រះសីហនុក្នុងឆ្នាំ២០២៤ ព្រមទាំងសំណុំរឿងក្តីផ្សេងទៀត នៅតាមសាលាជម្រះក្តីក្នុងតំបន់ឧទ្ធរណ៍ព្រះសីហនុ។

២-ក្រៅអំពីការងារស្នូលក្នុងសាលាឧទ្ធរណ៍ សាលាជម្រះក្តីក្នុងតំបន់ **ឯកឧត្តមប្រធាន** បានយកចិត្តទុកដាក់ការអនុវត្តយុទ្ធនាការរបស់ក្រសួងយុត្តិធម៌ រួមមាន៖ ១.យុទ្ធនាការជម្រុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និង ២.យុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ ព្រមទាំងណែនាំឱ្យចៅក្រមព្រះរាជអាជ្ញា ប្រតិបត្តិដោយម៉ឺត់ចត់ និងចំណាត់ការនូវបទល្មើសជាអាទិភាពចំនួន ៤ប្រភេទគឺ ៖ បទល្មើសគ្រឿងញៀន បទល្មើសចរាចរណ៍ អត្រានុកូលដ្ឋាន និងបទល្មើសក្មេងទំនើង។

៣-ទន្ទឹមនឹងលទ្ធផលការងារខាងលើ **ឯកឧត្តមប្រធាន** បានកត់សម្គាល់ឃើញភាពខ្វះខាតមួយចំនួនដែលត្រូវធ្វើការកែលំអរ ដើម្បីលើកកម្ពស់ប្រសិទ្ធិភាពការងារឱ្យល្អប្រសើរ បន្ថែមទៀតក្នុងវគ្គបំណងឆ្លើយតបទៅនឹងគោលនយោបាយថ្នាក់ជាតិ ក៏ដូចជាគោលនយោបាយរបស់ក្រសួងយុត្តិធម៌។

៤-**ឯកឧត្តមប្រធាន** បានធ្វើការណែនាំចៅក្រម សាលាឧទ្ធរណ៍ និងចៅក្រម សាលាជម្រះក្តីក្នុងតំបន់ឧទ្ធរណ៍ព្រះសីហនុ៖

- ត្រូវចេញសាលក្រម ឬសាលដីកាយ៉ាងយូរពីរសប្តាហ៍
- ត្រូវជូនដំណឹងអំពីសាលក្រម និងសាលដីកាកំបាំងមុខ ឱ្យបានត្រឹមត្រូវតាម នីតិវិធី ។
- ការតាក់តែងសាលក្រម ឬ សាលដីកា ឱ្យបានត្រឹមត្រូវតាមទម្រង់ និងខ្លឹមសារ ប្រកបដោយគុណភាព ធានាបានយុត្តិធម៌ជូនដល់ភាគី ។

• ចំពោះរឿងដៃប្បវេណី ត្រូវពិនិត្យបណ្តឹង និងរៀបចំចំណុចវិវាទឱ្យបានត្រឹមត្រូវ, ដីការក្សា ការពារត្រូវកំណត់ប្រភេទចាត់ចែងរក្សាការពារឱ្យបានច្បាស់លាស់ ។ល។

៥-ជាងនេះទៅទៀតឯកឧត្តមប្រធានសាលាឧទ្ធរណ៍ បានបង្ហាញនូវក្តីបារម្ភណ៍ទាក់ទងទៅនឹងស្ថានភាព នៃការអនុវត្តដោយបង្ខំ ដោយឯកឧត្តមបានលើកឡើងថា ការអនុវត្តដោយបង្ខំនៅមិនទាន់មានប្រសិទ្ធិភាព ដោយសារការខ្វះខាតធនធាន ភាពរឹងមាំនៃស្ថាប័នអនុវត្ត និងការចូលរួមសហការពីសំណាក់ស្ថាប័នពាក់ព័ន្ធផ្សេងៗ ។

-ព្រឹត្តិការណ៍ ឬកម្មវិធីការងារនានា

-ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤ សាលាឧទ្ធរណ៍ព្រះសីហនុ មហាអយ្យការអមសាលាឧទ្ធរណ៍ ព្រះសីហនុ និងអគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ព្រះសីហនុ បានប្រារព្ធពិធីសន្និបាតបូកសរុបការងារលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារសម្រាប់ឆ្នាំ២០២៤ ក្រោមអធិបតីភាព ឯកឧត្តមប្រធានសាលាឧទ្ធរណ៍ និងឯកឧត្តមអគ្គព្រះរាជអាជ្ញា ។

២.សមិទ្ធផលការងារ

ក.មហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ

ក.១. កិច្ចការទំនាក់ទំនង និងរដ្ឋបាលបច្ចេកទេស (អធិការកិច្ច, កិច្ចការសម្បថ)

ល.រ	បរិយាយ	ចំនួន	ផ្សេងៗ
១	ការចុះអធិការកិច្ចនៅអយ្យការអមសាលាដំបូង	១	
២	ការចុះអធិការកិច្ចពន្ធនាគារាជធានី-ខេត្ត	១	
៣	ការចុះអធិការកិច្ចនៅអង្គភាពនគរបាលយុត្តិធម៌	១	
៤	បំពេញនីតិសម្បទាឱ្យសិស្សមេធាវី	០	
៥	បំពេញសម្បថមេធាវីស្របតាមមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី	០	
៦	បំពេញនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌(នាក់)	០	
៧	បញ្ជូនសាលដីកាសកាស៊ើបសួរ និងសកាព្រហ្មទណ្ឌ ទៅមហាអយ្យការអមតុលាការកំពូល	០	
៨	បញ្ជូនសាលដីកាសកាស៊ើបសួរ និងសកាព្រហ្មទណ្ឌ ទៅអយ្យការអមសាលាដំបូងខេត្ត	៤០៥	
៩	បញ្ជូនសាលដីកាសកាព្រហ្មទណ្ឌស្តាពរ ទៅអយ្យការអមសាលាដំបូង	១៤៦	
១០	បញ្ជូនសាលដីកាសកាស៊ើបសួរ និងសកាព្រហ្មទណ្ឌ ទៅអគ្គនាយកដ្ឋានពន្ធនាគារ នៃក្រសួងមហាផ្ទៃ	០	
១១	បញ្ជូនសាលដីកាសកាព្រហ្មទណ្ឌស្តាពរ ទៅអគ្គនាយកដ្ឋានពន្ធនាគារ នៃក្រសួងមហាផ្ទៃ	០	
១២	បញ្ជូនសាលដីកាសកាព្រហ្មទណ្ឌ និងសកាស៊ើបសួរ ទៅពន្ធនាគារ	៤០៥	
១៣	បញ្ជូនសាលដីកាសកាព្រហ្មទណ្ឌស្តាពរ ទៅពន្ធនាគារ	១៤៦	

ក.២. ចំណាត់ការសំណុំរឿង

ក.២.១. ទិន្នន័យសំណុំរឿងតម្កល់ទុកឥតចាត់ការ

សំណុំរឿង			សំណុំរឿងចាត់ការរួច			រឿងសល់កំពុងចាត់ការ
សល់ពីមុន	ចូលថ្មី	សរុប	តម្កល់	សម្រេចឲ្យចោទប្រកាន់	សរុប	
៣៦	៩៣	១២៩	៨៦	០៥	៩១	៣៨

ក.២.២. សិត្តិសំណុំរឿងចូលធ្វើសេចក្តីសន្និដ្ឋាន

ល.រ	ប្រភេទចំណាត់ការ	សំណុំរឿង			ចាត់ការរួច	រឿងសល់កំពុងចាត់ការ
		សល់ពីមុន	ចូលថ្មី	សរុប		
១	សំណុំរឿងសកាស៊ើបសួរ	៤	៩៥	៩៩	៩៧	២
២	សំណុំរឿងសកាព្រហ្មទណ្ឌ	៥	៣១៤	៣១៩	២៩៩	២០

៣	សំណុំរឿងស្រូបទោស	០	៦	៦	៦	០
៤	សំណុំរឿងរដ្ឋប្បវេណី(បានចូលរួម)	០	២	២	២	០

ក.២.៣. ទិន្នន័យបណ្តឹងឧទ្ធរណ៍ និងបណ្តឹងសាទុក្ខលើរឿងក្តីព្រហ្មទណ្ឌ

ជីកាសម្រេច						សាលក្រម						សាលដីកា					
			ចាត់ការរួច						ចាត់ការរួច						ចាត់ការរួច		
សរុប	រឿងសល់ពីមុន	រឿងចូលថ្មី	សរុប	បណ្តឹងឧទ្ធរណ៍	សល់កំពុងចាត់ការ	សរុប	រឿងសល់ពីមុន	រឿងចូលថ្មី	សរុប	បណ្តឹងឧទ្ធរណ៍	សល់កំពុងចាត់ការ	សរុប	រឿងសល់ពីមុន	រឿងចូលថ្មី	សរុប	បណ្តឹងឧទ្ធរណ៍	សល់កំពុងចាត់ការ
១	២	៣	៤	៥	៦	៧	៨	៩	១០	១១	១២	១៣	១៤	១៥	១៦	១៧	១៨
៣០៦៤	០	៣០៦៤	៣០៦៤	០	០	២២២៧	០	២២២៧	២២២៧	៥	០	៥៦៤	០	៥៦៤	៥៦៤	៩	០

ខ.សាលាឧទ្ធរណ៍ព្រះសីហនុ

ខ.១. លទ្ធផលការងាររបស់សភាព្រហ្មទណ្ឌ

ទិន្នន័យសំណុំរឿងសភាព្រហ្មទណ្ឌ				
សល់ពីមុន	ចូលថ្មី	សរុប	ចាត់ការរួច	សល់កំពុងចាត់ការ
១	២	៣=១+២	៤	៥=៣-៤
៥៦	**៣១៩**	**៣៧៥**	**២៩៨**	**៧៧**
ទិន្នន័យសំណុំរឿងស្រូបទោស				
សល់ពីមុន	ចូលថ្មី	សរុប	ចាត់ការរួច	សល់កំពុងចាត់ការ
១	២	៣=១+២	៤	៥=៣-៤
០២	**០៨**	**១០**	**០៨**	**០២**
ទិន្នន័យសំណុំរឿងបង្វិលពីតុលាការកំពូល				
សល់ពីមុន	ចូលថ្មី	សរុប	ចាត់ការរួច	សល់កំពុងចាត់ការ
១	២	៣=១+២	៤	៥=៣-៤
០៦	**០៤**	**១០**	**០២**	**០៨**

ខ.២. លទ្ធផលការងាររបស់សភាស៊ើបសួរ

សំណុំរឿងសភាស៊ើបសួរ				
សល់ពីមុន	ចូលថ្មី	សរុប	ចាត់ការរួច	សល់កំពុងចាត់ការ
១	២	៣=១+២	៤	៥=៣-៤
០៦	**៩៨**	**១០៤**	**៩៨**	**០៦**

ខ.៣. លទ្ធផលការងាររបស់សការដ្ឋប្បវេណី

ខ.៣.១ ទិន្នន័យចំណាត់ការសំណុំរឿងរដ្ឋប្បវេណី (មុនអង្គសេចក្តី)

សំណុំរឿង				សំណុំរឿងចាត់ការរួច					រឿងសល់កំពុងចាត់ការ
សាលាជម្រះក្តី	សល់ពីមុន	ចូលថ្មី	សរុប	ដកពាក្យបណ្តឹង	សះជា	ផ្ទេរសមត្ថកិច្ច	ជម្រះរួច	សរុប	
១	២	៣	៤=២+៣	៥	៦	៧	០៨	០៩=៥++៨	១០
សាលាដំបូង	១៩	៤៨	៦៨	០៣	០០	០០	៤៥	៤៨	២០
តុលាការកំពូល	០០	០០	០០	០០	០០	០០	០០	០០	០០

ខ.៣.២. ទិន្នន័យចំណាត់ការសំណុំរឿងរដ្ឋប្បវេណី (អង្គសេចក្តី)

សំណុំរឿង				សំណុំរឿងចាត់ការរួច					រឿងសល់កំពុងចាត់ការ
សាលាជម្រះក្តី	សល់ពីមុន	ចូលថ្មី	សរុប	ដកពាក្យបណ្តឹង	សះជា	ផ្ទេរសមត្ថកិច្ច	ជម្រះរួច	សរុប	
១	២	៣	៤=២+៣	៥	៦	៧	០៨	០៩=៥++៨	១០=៤-៩
សាលាដំបូង	៦៤	១០២	១៦៦	០៦	០៣	០៤	៨៦	៩៩	៦៧
តុលាការកំពូល	០៥	០៨	១៣	០០	០១	០០	០៥	០៦	០៧

ខ.៣.៣. ទិន្នន័យចំណាត់ការសំណុំរឿងជំនុំជម្រះសាជាថ្មី

សំណុំរឿង			សំណុំរឿងចាត់ការរួច					រឿងសល់កំពុងចាត់ការ
សល់ពីមុន	ចូលថ្មី	សរុប	ដកពាក្យបណ្តឹង	សះជា	ផ្ទេរសមត្ថកិច្ច	ជម្រះរួច	សរុប	
១	២	៣=១+២	៤	៥	៦	៧	៨=៤+៧	៩
០៣	០៥	០៨	០០	០០	០១	០៤	០៥	០៣

ខ.៣.៤. ទិន្នន័យសំណុំរឿងរដ្ឋប្បវេណី (រក្សាការពារ)

សំណុំរឿង			សំណុំរឿងចាត់ការរួច					រឿងសល់កំពុងចាត់ការ
សល់ពីមុន	ចូលថ្មី	សរុប	ដកពាក្យបណ្តឹង	សះជា	ផ្ទេរសមត្ថកិច្ច	ជម្រះរួច	សរុប	
១	២	៣=១+២	៤	៥	៦	៧	៨=៤+៧	៩
៣៨	៥៥	៩៣	០៣	០០	០១	៥២	៥៦	៣៧

៣. បញ្ហាប្រឈម សំណូមពរ

៣.១.បញ្ហាប្រឈម

-នៅកង្វះ ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាលសម្រាប់បំពេញការងារ និងបុគ្គលិកជាប់កិច្ចសន្យាសម្រាប់បំពេញការងារ

-មានកង្វះខាតបន្ទប់សម្រាប់បំពេញការងារនៅពេលខាងមុខ បន្ទាប់ពីបង្កើតចំនួន ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាល

-ការងារបញ្ជូនដីកា និងឯកសារផ្សេងៗ មួយចំនួនតាមរយៈប្រៃសណីយ៍ នូវមានភាពយឺតយ៉ាវដោយបញ្ហាអ្នកទទួលបន្ទុកកិច្ចការបញ្ជូនចារលើបាយការណ៍បញ្ជូនពុំច្បាស់លាស់ ដែលធ្វើឱ្យតុលាការមិនអាចបន្តចំណាត់ការរបស់ខ្លួនបាន បញ្ហារកពុំឃើញអាសយដ្ឋានរបស់ភាគីជាដើម

-ខ្វះមន្ត្រីជំនាញផ្នែកព័ត៌មានវិទ្យា និងខ្វះអ្នកជំនាញបកប្រែភាសាបរទេស ខ្វះរថយន្តសម្រាប់ជាមធ្យោបាយធ្វើដំណើរ ចុះបេសកកម្មតាមបណ្តាខេត្ត ។

៣.២. សំណូមពរ

-ស្នើសុំបន្ថែម ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី មន្ត្រីក្របខណ្ឌរដ្ឋបាល និងមន្ត្រីជាប់កិច្ចសន្យា ស្របតាមទំហំការងារ

-ស្នើសុំថវិកាសាងសង់អគាររដ្ឋបាលសម្រាប់បំពេញតម្រូវការការងារនាពេលខាងមុខ និងថវិកាទិញរថយន្ត

-ស្នើសុំឲ្យមានវគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រី ដើម្បីលើកកម្ពស់គុណភាពការងារឲ្យបានប្រសើរជាលំដាប់ ស្នើសុំមន្ត្រីជំនាញព័ត៌មានវិទ្យា

-ស្នើសុំឱ្យមានវគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រី ដើម្បីលើកកម្ពស់គុណភាពការងារឱ្យបានប្រសើរជាលំដាប់ស្នើសុំ មន្ត្រីជំនាញព័ត៌មានវិទ្យា និងស្នើសុំឱ្យមានការរៀបចំបញ្ជីឈ្មោះអ្នកជំនាញបកប្រែភាសាបរទេស។

៤. ទិសដៅការងារសម្រាប់ឆ្នាំ២០២៥

ក. ទិសដៅការងាររបស់សាលាឧទ្ធរណ៍ព្រះសីហនុ

១.ទទួលអនុវត្តដោយស្មារតីទទួលខុសត្រូវ រាល់គោលនយោបាយជាតិដែលពាក់ព័ន្ធទៅនឹងការកែទម្រង់ច្បាប់ និងតុលាការ។

២.ទទួលអនុវត្តដោយស្មារតីទទួលខុសត្រូវរាល់វិធានការទាំងឡាយរបស់ក្រសួងយុត្តិធម៌ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ពាក់ព័ន្ធទៅនឹងការលើកកំពស់វិស័យយុត្តិធម៌។

៣.ពន្លឿនចំណាត់ការរឿងក្តីគ្រប់ប្រភេទអោយបានឆាប់រហ័ស ជាពិសេសប្រភេទរឿងក្តីអាទិភាពដែលដាក់ចេញដោយក្រសួងយុត្តិធម៌ រួមមាន៖ រឿងក្តីគ្រឿងញៀន រឿងក្តីចរាចរណ៍ រឿងក្តីអត្រានុកូលដ្ឋាន និងរឿងក្តីក្មេងទំនើង។

៤.ពន្លឿនការចេញសាលដីកា និងដីកាសម្រេចផ្សេងៗអោយបានឆាប់រហ័ស។

៥.លើកកម្ពស់ និងពង្រឹងឯករាជ្យភាពរបស់ចៅក្រម។

៦.លើកកម្ពស់គុណភាព និងភាពឥតលំអៀង នៃសាលដីកា និងដីកាសម្រេចផ្សេងៗ។

៧.លើកកម្ពស់ និងពង្រឹងវិន័យការងារ និងក្រមសីលធម៌វិជ្ជាជីវៈរបស់ចៅក្រម និងក្រឡាបញ្ជី។

៨.លើកកម្ពស់ និងពង្រឹងសមត្ថភាពការងាររបស់ចៅក្រម និងក្រឡាបញ្ជី។
៩.លើកកម្ពស់ និងពង្រឹងសាមគ្គីភាព និងកិច្ចសហការផ្ទៃក្នុងរវាងសាលាឧទ្ធរណ៍ព្រះសីហនុ មហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ និងអគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ ព្រះសីហនុ។
១០.លើកកំពស់កិច្ចសហការរវាងសាលាឧទ្ធរណ៍ព្រះសីហនុ ជាមួយអង្គភាពពាក់ព័ន្ធនានា នៅខេត្ត និងក្នុងតំបន់។
១១.តាមដាន និងពង្រឹងកិច្ចការស៊ើបអង្កេតនៅតាមមន្ទីរស៊ើបសួររបស់សាលាដំបូងទាំងបួនរួមមាន សាលាដំបូងខេត្តព្រះសីហនុ សាលាដំបូងខេត្តកំពត សាលាដំបូងខេត្តកោះកុង និងសាលាដំបូងខេត្តកែប។

ខ. មហាអយ្យការណ៍អមសាលាឧទ្ធរណ៍ព្រះសីហនុ

១.ផ្សព្វផ្សាយច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌចំណុចពិសេសលើតួនាទីរបស់អយ្យការអមសាលាដំបូង និងតួនាទីមហាអយ្យការអមសាលាឧទ្ធរណ៍ (ព្រះសីហនុ)។
២.តាមដានការអនុវត្តន៍ និងត្រួតពិនិត្យការអនុវត្តន៍ច្បាប់ព្រហ្មទណ្ឌ និងច្បាប់ពិសេស។
៣.ធ្វើអធិការកិច្ចស្ថាប័នអយ្យការ, ស្នងការនគរបាល, ពន្ធនាគារ, ទីបញ្ជាការអាវុធហត្ថ មន្ទីរនគរបាលយុត្តិធម៌ផ្សេងទៀត។
៤.ជម្រុញឱ្យបណ្តឹងព្រហ្មទណ្ឌមានដំណើរការ មិនឱ្យកកស្ទះនៅស្ថាប័នអយ្យការ និងស្ថាប័នមានសមត្ថកិច្ចជានគរបាលយុត្តិធម៌ផ្សេងៗ។
៥.អញ្ជើញមន្ត្រីនគរបាលយុត្តិធម៌ទាំងអស់ក្នុងក្របខណ្ឌបួនខេត្ត មកប្រជុំ ពិភាក្សា អំពីការអនុវត្តន៍លើចំណុចលំបាកស្មុគស្មាញដែលជួបប្រទះ និងរកដំណោះស្រាយ។
៦.បណ្តុះបណ្តាលទាក់ទងនីតិវិធី សម្រាប់កសាងសំណុំរឿងព្រហ្មទណ្ឌ ចំពោះមន្ត្រីនគរបាលយុត្តិធម៌ផ្សេងៗ ដែលទើបទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ថ្មីៗ។
៧.ធ្វើបច្ចុប្បន្នភាពលទ្ធផលនៃការអនុវត្តន៍ សាលក្រម សាលដីកាស្តាពរ និងដីការផ្សេងៗ។
៨.សិក្ខាសាលាមន្ត្រីនគរបាលយុត្តិធម៌ ពន្ធនាគារ យ៉ាងតិច២ដង។
៩.ជម្រុញ និងតាមដានការងារអនុវត្តកិច្ចការសម្ភាតប្រាក់ និងជួញដូរមនុស្ស។
១០.ជម្រុញ និងតាមដានការងារអនុវត្តយុទ្ធនាការរបស់ក្រសួងយុត្តិធម៌ ១.យុទ្ធនាការជម្រុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និង ២.យុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ

គ អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ព្រះសីហនុ

១.បន្តបង្កើតភាពងាយស្រួលដល់ការទទួល និងផ្តល់ព័ត៌មានសម្រាប់ភាគីពាក់ព័ន្ធក្នុងរឿងក្តី។
២.បន្តពង្រឹងសមត្ថភាពមន្ត្រី ក្នុងការងារចុះបញ្ជីសំណុំរឿងដោយដៃឱ្យបានត្រឹមត្រូវ។
៣.បន្តជម្រុញ តាមដានត្រួតពិនិត្យ និងរក្សាទុកអំពីសេចក្តីសម្រេចផ្សេងៗ និងសាលដីកា ដើម្បីផ្តល់លក្ខណៈងាយស្រួលដល់ការគ្រប់គ្រងរឿងក្តី។
៤.បន្តធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធនៃការជូនដំណឹងរបស់តុលាការ ដើម្បីធានាឱ្យជនពាក់ព័ន្ធក្នុងរឿងក្តីអាចទទួលព័ត៌មាននៅគ្រប់ដំណាក់កាលនៃរឿងក្តី។
៥.បន្តពង្រឹងគុណភាពមន្ត្រីឱ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាល (ព័ត៌មានវិទ្យា) គ្រប់គ្រងបុគ្គលិក ប្រតិទិនការងារតុលាការ ការងារបណ្តុះបណ្តាល ប្រជុំហិរញ្ញវត្ថុ និងការងារប្រមូលរបាយការណ៍ និងស្ថិតិ)។
៦.បន្តពង្រឹងក្នុងការធ្វើផែនការថវិកាប្រចាំឆ្នាំស្របតាមតម្រូវការចាំបាច់ និងនីតិវិធីឱ្យទាន់ពេលវេលា និង មានប្រសិទ្ធភាព។
៧.ធានាឱ្យមានយន្តការរៀបចំរក្សាទុកសៀវភៅចុះបញ្ជីសំណុំរឿង សៀវភៅបញ្ជីចំណូលចំណាយ និងឯកសារផ្សេងៗដែលបានតម្កល់រក្សាទុក។
៨.បន្តពង្រឹងសមត្ថភាពមន្ត្រីក្នុងការចុះបញ្ជីប្រាក់ប្រដាប់ក្តីដោយដៃ និងតាមប្រព័ន្ធបច្ចេកវិទ្យាលើការត្រួតពិនិត្យប្រាក់ពន្ធដែលត្រូវបង់ចូលថវិកាជាតិដោយផ្អែកលើក្រមនីតិវិធីរដ្ឋប្បវេណី។
៩.រៀបចំផែនការថវិកាចំណូល និងបង់ពន្ធចូលថវិកាជាតិឱ្យទាន់ពេលវេលា និងមានប្រសិទ្ធិភាពដោយផ្អែកលើការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងតាមក្រមនីតិវិធីរដ្ឋប្បវេណី។

១០.បន្តរៀបចំកម្មវិធី និងចូលរួមសម្របសម្រួលការងារចុះអធិការកិច្ចនៅអយ្យការអមសាលាដំបូង មន្ទីរស៊ើបសួរ ពន្ធនាគារ និងនគរបាលយុត្តិធម៌ ដែលថ្នាក់ដឹកនាំប្រគល់ជូន។

១១.ត្រៀមសហការជាមួយក្រសួងយុត្តិធម៌ ដើម្បីរៀបចំបង្កើតប្រព័ន្ធចុះបញ្ជីសំណុំរឿងតាមប្រព័ន្ធព័ត៌មានវិទ្យានាពេលខាងមុខ។

១២.ពង្រឹងវិន័យការងាររបស់មន្ត្រីរដ្ឋបាល អនុវត្តយ៉ាងម៉ឺងម៉ាត់តាមការណែនាំរបស់ក្រសួងយុត្តិធម៌ និងការកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃ៣ ដ ៧ កើត ខែ អស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ខេត្តព្រះសីហនុ ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២៥
អគ្គលេខាធិការ

បានឃើញ និងឯកភាព
ថ្ងៃ៣ ដ ៧ កើត ខែ អស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ខេត្តព្រះសីហនុ ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២៥
អគ្គព្រះរាជអាជ្ញា

ស.ប្រធានសាលាឧទ្ធរណ៍

លឹម ស៊ុណាត

ទៅ យ៉ាន់តុ

សរ យសថាវរ:

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

របាយការណ៍ការងារសង្ខេបរបស់សាលាដម្រះក្តី
សម្រាប់សន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារអាទិភាព ឆ្នាំ២០២៥
សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

==========

១. ស្ថានភាពទូទៅ

ក. ធនធានមនុស្ស

-ប្រធាន អនុប្រធាន ចៅក្រម	ចំនួន ៤៣ រូប	ស្ត្រី ចំនួន ១១ រូប
-ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង	ចំនួន ២៤ រូប	ស្ត្រី ចំនួន ០១ រូប
-ក្រឡាបញ្ជី	ចំនួន ១៩៩ រូប	ស្ត្រី ចំនួន ៦៦ រូប
-អាជ្ញាសាលា	ចំនួន ០៩ រូប	
-មន្ត្រីលេខាធិការដ្ឋានរដ្ឋបាល	ចំនួន ១១០ រូប	ស្ត្រីចំនួន ៥២ រូប
-មន្ត្រីជាប់កិច្ចសន្យា	ចំនួន ៨៧ រូប	ស្ត្រីចំនួន ៣៤ រូប
ធនធានមនុស្ស **សរុប**	**ចំនួន ៤៧២រូប**	**ស្ត្រី ចំនួន ១៦៤ រូប។**

ខ. ហេដ្ឋារចនាសម្ព័ន្ធ

អាគារសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ មានអាសយដ្ឋាននៅ **អាគារសាលាយុត្តិធម្ម** ផ្លូវលោកតាក្រហមក ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

គ. លទ្ធផលសន្និបាតផ្ទៃក្នុងស្ថាប័នសម្រាប់ ឆ្នាំ២០២៤

លទ្ធផលកិច្ចពិភាក្សាលើបទបង្ហាញរបស់ក្រុមការងារ៖

ក្រោយពីការធ្វើបទបង្ហាញ និងពិភាក្សារួចមក អង្គសន្និបាតបានសម្រេចដូចខាងក្រោម៖

គ.១. កិច្ចការរដ្ឋបប្បវេណី៖

អង្គសន្និបាតបានសម្រេចឯកភាពលើប្រធានបទចំនួន៣ ចំណុចដូចខាងក្រោមគឺ៖

១. សិទ្ធិតំណាងដែលមិនមែនជាមេធាវី អង្គសន្និបាតបានសម្រេចឯកភាព៖

- ទទួលយកប្រធានសាខាធនាគារអាចធ្វើសកម្មភាពបណ្តឹងបាន
- ប្រធានសាខាអាចតែងតាំងមេធាវីបាន
- ប្រធានសាខាមិនអាចតែងតាំងបុគ្គលិករបស់ខ្លួនធ្វើជាអ្នកតំណាងបានទេ
- ចំពោះក្រុមហ៊ុនផ្សេងទៀត អ្នកធ្វើសកម្មភាពបណ្តឹងបាន លុះត្រាតែជាអភិបាល ហើយអភិបាលអាចតែងតាំងមេធាវីជាតំណាងបាន។ ក៏ប៉ុន្តែអភិបាលមិនអាចតែងតាំងអ្នកតំណាង ដែលមិនមែនជាមេធាវីបានទេ។

២. អត្រាការប្រាក់,ការប្រាក់យឺតយ៉ាវ,ប្រាក់ពិន័យ,សំណងការខូតខាត និងលក្ខខណ្ឌផ្សេងទៀត អង្គសន្និបាតបានសម្រេចឯកភាពដូចខាងក្រោម៖

អត្រាការប្រាក់៖

- អត្រាការប្រាក់ ត្រូវគិតចាប់ពីថ្ងៃអាក់ខានការអនុវត្តកាតព្វកិច្ច ដល់ថ្ងៃបញ្ចប់កិច្ចសន្យា
- អត្រាការប្រាក់ ពីថ្ងៃខកខានដល់ថ្ងៃដាក់ពាក្យបណ្តឹង ប្រសិនបើកិច្ចសន្យានោះមិនទាន់ត្រូវបានបញ្ចប់
- អត្រាការប្រាក់ ពីថ្ងៃខកខានដល់ថ្ងៃបញ្ចប់កិច្ចសន្យា(អាចក្រោយដាក់បណ្តឹង)

ការប្រាក់យឺតយ៉ាវ៖

- ការប្រាក់យឺតយ៉ាវត្រូវគិតចាប់ពីថ្ងៃអាក់ខាន រហូតដល់សងចប់សព្វគ្រប់
- ចំពោះសំណងគឺឱ្យតាមទំហំសមរម្យ

ការប្រាក់ពិន័យ ឬយឺតយ៉ាវ៖

- ឱ្យពីថ្ងៃដាក់ពាក្យបណ្តឹងដល់ថ្ងៃសងប្រាក់ដើមចប់សព្វគ្រប់ - ឬពីថ្ងៃបញ្ចប់កិច្ចសន្យាដល់សងប្រាក់ដើមចប់សព្វគ្រប់

សំណងការខូចខាតទាមទារបន្ថែម៖

- ឯកភាពមិនឱ្យ - ត្រូវច្រានចោល

លក្ខខណ្ឌផ្សេងទៀត៖

- កិច្ចសន្យាបាននិយាយការប្រាក់ ប៉ុន្តែមិនបានចែងចំនួនគឺករណីបែបនេះផ្តល់ឱ្យ ៥%ក្នុងមួយឆ្នាំ
- បើកិច្ចសន្យាមិននិយាយអ្វីទាំងអស់ពីការប្រាក់គឺមិនឱ្យទេ។

៣. បញ្ហាក់សិទ្ធិប្រាតិភោគ៖

- បើទាមទារតាវកាលិកផង និងបញ្ហាក់សិទ្ធិប្រាតិភោគផង ជារួមអង្គសន្និបាតរកចំណុចឯកភាពគ្នាមិនទាន់បាន ដូច្នេះអង្គសន្និបាតសម្រេចទុកស្នើជូនទៅសន្និបាតក្រសួងយុត្តិធម៌ ដើម្បីសម្រេច។

គ.២. កិច្ចការព្រហ្មទណ្ឌ៖

អង្គសន្និបាត បានសម្រេចឯកភាព និងដោះស្រាយនូវបញ្ហាប្រឈមមួយចំនួនដែលលើកឡើងដោយតំណាងអយ្យការ និងបានសម្រេចឯកភាពទៅលើប្រធានបទចំនួន ៣ ចំណុចបន្ថែមទៀត ដូចខាងក្រោម៖

១. ដីកាបង្គាប់ឱ្យចាប់ខ្លួនរបស់ចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះ,អង្គសន្និបាត បានសម្រេច៖

- ករណីចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឱ្យចាប់ខ្លួនហើយ តែចៅក្រមជំនុំជម្រះបានផ្តន្ទាទោសព្យួរឬក្រោម១ឆ្នាំ ឬក៏លើសពី១ឆ្នាំក៏ដោយ បើចៅក្រមជំនុំជម្រះយល់ឃើញថា រឿងនេះមិនត្រូវមានវិធានការបន្ទាន់បង្ខំ ដែលត្រូវចេញដីកាបង្គាប់ឱ្យចាប់ខ្លួនទេ គឺសម្រេចចេញដីកាបញ្ឈប់ការចាប់ខ្លួន របស់ចៅក្រមស៊ើបសួរ
- ករណីដែលចៅក្រមបានផ្តន្ទាទោសស្មើ១ឆ្នាំ ឬលើសពី១ឆ្នាំ ដីកាង្គាប់ឱ្យចាប់ខ្លួនរបស់ចៅក្រមស៊ើបសួរមិនត្រូវបានចេញដីកាបញ្ឈប់ឱ្យចាប់ខ្លួនទេ តែចៅក្រមជំនុំជម្រះត្រូវចេញដីកាបង្គាប់ឱ្យចាប់ខ្លួនបន្ថែម។

២. អត្តសញ្ញាណ ឬសាវតាជនត្រូវចោទ/ជនជាប់ចោទ,អង្គសន្និបាតបានសម្រេច៖

- ករណីដែលអត្តសញ្ញាណរបស់ជនត្រូវចោទ មានតែឈ្មោះ ភេទ ទីលំនៅបច្ចុប្បន្ន ត្រូវសម្រេចលើកលែងចោទប្រកាន់

- ចៅក្រម និងតំណាងអយ្យការ ប្រឹងប្រែងស្រាវជ្រាវរកអត្តសញ្ញាណ ដោយយកចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់ឱ្យអស់លទ្ធភាព ហើយកំណត់ថាអត្តសញ្ញាណប៉ុនណា ដែលអាចសម្គាល់ជនណាមួយបានដោយមិនច្រឡំទៅនឹងជនណាមួយទៀត

- ករណីមានលិខិតឆ្លងដែន ឬ អត្តសញ្ញាណបណ្ណ័សញ្ជាតិខ្មែរ គឺកំណត់ថាមានអត្តសញ្ញាណ គ្រប់គ្រាន់អាចបញ្ជូនជម្រះបាន

- ចំពោះអាយុជនត្រូវចោទ ឬជនជាប់ចោទ ត្រូវមានបញ្ហាក់អំពីថ្ងៃ ខែ ឆ្នាំកំណើត។

៣. បទល្មើសរំលោភលើទំនុកចិត្ត បទល្មើសឆបោក និងកិច្ចសន្យារដ្ឋប្បវេណី,អង្គសន្និបាត បានសម្រេច៖

- លោក លោកស្រីចៅក្រម ព្រះរាជអាជ្ញារង ត្រូវពិនិត្យមើលឱ្យបានល្អិតល្អន់ និងច្បាស់លាស់ ដោយខ្លួនឯង ដោយយកចិត្តទុកដាក់កំណត់ឈ្មោះនៃបទល្មើស ការស្វែងរកធាតុផ្សំនៃបទល្មើស ថាតើអ្វីជាបទល្មើសរំលោភលើទំនុកចិត្ត អ្វីជាបទល្មើសឆបោក ចៀសវាងមានការចោទប្រកាន់មិនសមហេតុផលដែលនាំឱ្យ

មានបញ្ហា។ យោងតាមសេចក្តីណែនាំរបស់តុលាការកំពូល មុននឹងចោទប្រកាន់បទល្មើសរំលោភលើទំនុកចិត្ត ត្រូវតែបំពានលើកិច្ចសន្យាចំនួន៦ ចំណុច។ សូមឱ្យក្រុមការងាររៀបចំសេចក្តីសម្រេច នូវសញ្ញាណសំខាន់ៗ នៃបទល្មើសរំលោភលើទំនុកចិត្ត សញ្ញាណសំខាន់ៗ នៃធាតុផ្សំបទល្មើសឆបោក និងលក្ខណៈមួយចំនួន ដែលជាកិច្ចសន្យារដ្ឋប្បវេណីសុទ្ធសាធ។

ឃ. ព្រឹត្តិការណ៍ ឬកម្មវិធីការងារនានា

- ថ្នាក់ដឹកនាំ ចៅក្រម ព្រះរាជអាជ្ញារង ប្រធានលេខាធិការដ្ឋាន ក្រឡាបញ្ជី អាជ្ញាសាលា និងមន្ត្រីរដ្ឋបាល ចំនួន ៣៦ រូប ចូលរួមប្រជុំ និងការបណ្តុះបណ្តាល ដែលរៀបចំដោយក្រសួងយុត្តិធម៌ ចំនួន ២៣ លើក

- ចៅក្រម ព្រះរាជអាជ្ញារង ប្រធានលេខាធិការដ្ឋាន អាជ្ញាសាលា និងមន្ត្រីរដ្ឋបាល ចំនួន ៦៨ រូប ចូលរួមវគ្គបណ្តុះបណ្តាល ធ្វើបទឧទ្ទេសនាម និងប្រជុំ រៀបចំដោយបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ចំនួន ១៧ លើក

- ចៅក្រម ព្រះរាជអាជ្ញារង អាជ្ញាសាលា និងមន្ត្រីរដ្ឋបាល ចំនួន ៩ រូប ចូលរួមការបណ្តុះបណ្តាល និងសិក្ខាសាលាផ្សព្វផ្សាយ ដែលរៀបចំដោយក្រសួង ឬអង្គភាពពាក់ព័ន្ធនានា ចំនួន ៥ លើក

- ថ្នាក់ដឹកនាំ ព្រះរាជអាជ្ញារង ចៅក្រម ប្រធាន- អនុប្រធានលេខាធិការដ្ឋាន ក្រឡាបញ្ជី អាជ្ញាសាលា និងមន្ត្រីរដ្ឋបាល ចូលរួមពិធីទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងប្រគល់គ្រឿងញៀន សារធាតុគីមីផ្សំ សារធាតុគីមី ជូនគណៈកម្មការដុតបំផ្លាញគ្រឿងញៀន ដើម្បីកម្ទេចចោល ចំនួន ៧,៣៥ តោន និងចូលរួមប្រជុំពិភាក្សាការងារផ្សេងៗទៀត ជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ចំនួន ៥ លើក

- អនុប្រធានសាលាដំបូង ព្រះរាជអាជ្ញារង ចៅក្រម ចូលរួមក្នុងកិច្ចប្រជុំ និងពិធីប្រកាសចូលកាន់មុខតំណែង រៀបចំដោយសាលារាជធានីភ្នំពេញ ចំនួន ៨ លើក

- សាលាដំបូង និងអយ្យការអមសាលាដំបូង បានសហការណ៍ជាមួយពន្ធនាគារនៅរាជធានីភ្នំពេញ និងពន្ធនាគារផ្សេងទៀតបានយ៉ាងល្អប្រសើរ

- សាលាដំបូង និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សហការគ្នាបានយ៉ាងល្អប្រសើរ។ សាលាដំបូង បានផ្តល់បន្ទប់ការិយាល័យ និងសម្ភារការងាររួមទាំងការផ្គត់ផ្គង់អគ្គិសនី ផ្គត់ផ្គង់ទឹក អនាម័យផងដែរជូនដល់ប្រតិភូគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- សាលាដំបូង បានអនុញ្ញាតឱ្យសិក្ខាកាម និងនិស្សិតមកពីស្ថាប័ន និងសាកលវិទ្យាល័យ ចំនួន ១១ នៅរាជធានីភ្នំពេញ និងនៅបរទេស មកទស្សនកិច្ច កម្មសិក្សាស្រាវជ្រាវ និងចូលស្តាប់សវនាការ សរុបចំនួន ៦០៦ នាក់

- បានអនុញ្ញាត និងសម្រួលដល់អង្គការ ស្ថានទូតនានា និងអង្គភាពសារព័ត៌មានផ្សេងៗ ចូលស្តាប់សវនាការ និងបានផ្សាំងផ្ទាត់ភាពត្រឹមត្រូវ នៃសាលក្រមរដ្ឋប្បវេណី សម្រង់សាលក្រម ដីកាសម្រេច រូបមន្តអនុវត្ត និងលិខិតបញ្ជាក់ការចូលជាស្ថាពរ (តាមការស្នើសុំពីស្ថានទូត)

- ក្រុមប្រឹក្សាសម្បថ បានរៀបចំពិធីសម្បថ របស់មន្ត្រីរាជការដែលទទួលបាននីតិសម្បទា ជាមន្ត្រីនគរបាលយុត្តិធម៌ សរុបចំនួន ៨៥ រូប

- ចៅក្រម ព្រះរាជអាជ្ញារង និងមន្ត្រីរដ្ឋបាល ចំនួន ១៧ រូបបានចូលរួមប្រជុំជាមួយស្ថាប័នផ្សេងៗ ចំនួន ១៥ លើក

- សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានរៀបចំសន្និបាត សិក្ខាសាលា ប្រជុំផ្សេងៗ និងការងាររដ្ឋបាលមួយចំនួនទៀត ចំនួន ៣១ លើក។

២. សមិទ្ធផលការងារ

ក. អយ្យការអមសាលាដំបូង៖

ក.១. ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌ

រឿងចាស់	រឿងថ្មី	សរុប	ចាត់ការរួច		សល់កំពុងចាត់ការ	
			រឿងចាស់	រឿងថ្មី	រឿងចាស់	រឿងថ្មី
811	8 501	9 312	799	7 772	12	729

ក.២. កិច្ចការពាក់ព័ន្ធនឹងការអនុវត្តទោស និងពន្ធនាគារ

បរិយាយ	សរុបរួម		អនីតិជន		នីតិជន		ជនបរទេស	
	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី
ជនត្រូវចោទ	1 715	136	185	7	1 291	109	239	20
ជនជាប់ចោទ	1 077	145	143	6	793	127	141	12
ពិរុទ្ធជន	6 533	655	241	20	5 751	554	541	81
ទណ្ឌិត	1 956	365	11	2	1 702	301	243	62
សរុបជនជាប់ឃុំ	**11 281**	**1 301**	**580**	**35**	**9 537**	**1 091**	**1 164**	**175**

ក.៣. កិច្ចការពាក់ព័ន្ធជាមួយនឹងមន្ត្រីនគរបាលយុត្តិធម៌

សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ មានកិច្ចសហការយ៉ាងល្អជាមួយមន្ត្រីនគរបាលយុត្តិធម៌។

ខ. សាលាដំបូង:

ខ.១. ចំណាត់ការលើសំណុំរឿងព្រហ្មទណ្ឌ

ខ.១.១. ដំណាក់កាលស៊ើបសួរ

រឿងចាស់	រឿងថ្មី	សរុប	ចាត់ការរួច		សល់កំពុងចាត់ការ	
			រឿងចាស់	រឿងថ្មី	រឿងចាស់	រឿងថ្មី
2 751	6 137	8 888	2 257	3 957	494	2 180

ខ.១.២. ដំណាក់កាលជំនុំជម្រះ

រឿងចាស់	រឿងថ្មី	សរុប	ចាត់ការរួច		សល់កំពុងចាត់ការ	
			រឿងចាស់	រឿងថ្មី	រឿងចាស់	រឿងថ្មី
1 779	6 773	8 552	1 574	4 870	205	1 903

ខ.២. ចំណាត់ការលើសំណុំរឿងរដ្ឋប្បវេណី

រឿងចាស់	រឿងថ្មី	សរុប	ចាត់ការរួច		សល់កំពុងចាត់ការ	
			រឿងចាស់	រឿងថ្មី	រឿងចាស់	រឿងថ្មី
6 812	10 127	16 939	3 481	7 156	3 331	2 971

ខ.៣. ចំណាត់ការសំណុំរឿងផ្សេងទៀត

អាជ្ញាសាលា	រឿងនៅសល់	រឿងចូលថ្មី	រឿងសរុប	រឿងចាត់ការរួច	សល់កំពុងចាត់ការ
សរុប	248	143	391	150	241

៣. បញ្ហាប្រឈម និងសំណូមពរ:

ក.បញ្ហាប្រឈម

- សំណុំរឿងព្រហ្មទណ្ឌដែលបានចេញដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះហើយ តែនៅតាមបន្ទប់នីមួយៗ បានក្សារឿងទុកនៅក្នុងបន្ទប់យូរពេក (មិនបានធ្វើការបញ្ជូនឱ្យលឿន) បន្ទប់ខ្លះទុករហូតដល់រយៈពេល៦ ខែ ក៏មាន
- ចៅក្រមស៊ើបសួរពុំបានកំណត់ថិរវេលាក្នុងដីកាបង្គាប់ឱ្យនាំខ្លួន
- ពុំទទួលបានលទ្ធផលឆ្លើយតបអំពីការស្នើសុំជំនួយទៅវិញទៅមកផ្នែកច្បាប់ (MLA)

- ខ្វះកិច្ចសហការក្រៅផ្លូវការជាមួយប្រទេសមួយចំនួន និងខ្វះធនធានដើម្បីពិនិត្យ តាមដានលើសំណើដែលស្នើសុំ(MLA)

- ពិបាកក្នុងការស្វែងរកសំណុំរឿងចាស់ៗ ដែលជំនុំជម្រះរួច

- ប្រព័ន្ធបញ្ចូលទិន្នន័យមានបញ្ហាជាញឹកញាប់ (ERROR) ធ្វើឱ្យការបញ្ចូលទិន្នន័យមានការយឺតយ៉ាវ

- សំណុំរឿងចាស់ៗ ដែលតម្កល់ទុកក្នុងឃ្លាំង សំណុំរឿងរបស់សាលាដំបូងរាជធានីភ្នំពេញ មួយចំនួនធំគ្មានទិន្នន័យច្បាស់លាស់ ទាមទារឱ្យមានការរៀបចំធ្វើបញ្ជីឡើងវិញបន្ត ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង

- កញ្ចប់ថវិកាដែលរដ្ឋផ្តល់ឱ្យសាលាដំបូងរាជធានីភ្នំពេញ សម្រាប់ផ្គត់ផ្គង់ដំណើរការកិច្ចការរដ្ឋបាល និងកិច្ចការសំណុំរឿងនៅមិនទាន់គ្រប់តាមតម្រូវការជាក់ស្តែងនៅឡើយ

- ចៅក្រម ព្រះរាជអាជ្ញារង ក្រឡាបញ្ជី អាជ្ញាសាលា និងមន្ត្រីរដ្ឋបាលមានចំនួនតិច មិនទាន់ឆ្លើយតបនឹងទំហំការងារ សំណុំរឿងគ្រប់ប្រភេទដែលមានការកើនឡើងខ្លាំង

- ការអនុវត្តនីតិវិធីទារប្រាក់ពិន័យពីទណ្ឌិតមានការលំបាក ដោយហេតុថាទណ្ឌិតមួយចំនួនជាជនក្រីក្រ

- ការបញ្ជូនដីកា ឬសាលក្រមរបស់សាលាដំបូងតាមបណ្តាខេត្ត និងតុលាការបរទេសមានចំនួនច្រើន

- ក្រឡាបញ្ជីខ្លះមិនបានបញ្ជាក់ស្ថាពរលើសាលក្រមព្រហ្មទណ្ឌ ដែលជាហេតុធ្វើឱ្យពន្ធនាគារតែងតែដាក់លិខិតមកស្នើសុំសាលក្រមស្ថាពរ ឬរាយការណ៍ជូនថ្នាក់លើរបស់គេបណ្តាលឱ្យប៉ះពាល់ដល់កិត្តិយស

- ចំនួនវត្ថុតាង និងវត្ថុចាប់យកមានការកើនឡើងជាលំដាប់

- ប្រជាពលរដ្ឋដែលមកទទួលសេវាយុត្តិធម៌មានការយល់ដឹងនៅមានកម្រិត

- ខ្វះអ្នកបកប្រែភាសាបរទេស ជាពិសេស ភាសាអេស្ប៉ាញ ភាសាគ ភាសាបង់ក្លាដេស។ល។

ខ.សំណូមពរ

- សូមឱ្យចៅក្រម ព្រះរាជអាជ្ញារង ក្រឡាបញ្ជី អាជ្ញាសាលា និងមន្ត្រីពាក់ព័ន្ធបន្តពង្រឹងការអនុវត្តនីតិវិធីក្នុងដំណើរការចំណាត់ការសំណុំរឿងឱ្យកាន់តែហ្មត់ចត់ និងម៉ឺងម៉ាត់បន្ថែមទៀត

- សូមឱ្យក្រឡាបញ្ជីបញ្ជាក់ស្ថាពរលើសាលក្រមព្រហ្មទណ្ឌតាមនីតិវិធីច្បាប់

- សូមផ្តល់ថវិកាប្រចាំឆ្នាំបន្ថែម សម្រាប់ផ្គត់ផ្គង់ដំណើរការកិច្ចការរដ្ឋបាល និងកិច្ចការសំណុំរឿង

- ស្នើសុំក្រសួងយុត្តិធម៌ ធ្វើទំនើបកម្ម និងបច្ចុប្បន្នភាពប្រព័ន្ធចុះបញ្ជីសំណុំរឿងព្រហ្មទណ្ឌ។

៤. ទិសដៅការងារសម្រាប់ឆ្នាំ ២០២៥

ក. ការពង្រឹងការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ

- អនុវត្តតាមផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព នៃសាលាដំបូង និងអយ្យការអមសាលាដំបូង

- អនុវត្តយុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និងយុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ សម្រាប់ឆ្នាំទី២ នៃការអនុវត្ត

- ជំរុញឱ្យមានការអនុវត្តនីតិវិធីផ្សះផ្សារវិវាទក្នុងសំណុំរឿងរដ្ឋប្បវេណី

- ពង្រឹងវិន័យការងារឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ស្របតាមបទបញ្ជាផ្ទៃក្នុង

- រៀបចំគេហទំព័រអេឡិចត្រូនិចរបស់សាលាដំបូងរាជធានីភ្នំពេញ

- រៀបចំបង្កើតព្រឹត្តិបត្រព័ត៌មានសម្រាប់សាលាដំបូងរាជធានីភ្នំពេញ

- បណ្តុះបណ្តាលផ្ទៃក្នុងលើប្រធានបទស្តីពីកាបញ្ជូន និងការចុះបញ្ជី

- រៀបចំកន្លែងផ្តល់សេវាឱ្យកាន់តែមានប្រសិទ្ធភាព និងសាងសង់ឃ្លាំងបន្ថែម នៅវាលស្បូវ

- បង្កើនសមត្ថភាពមន្ត្រីក្នុងការគ្រប់គ្រងរដ្ឋបាលសារធារណៈ ដើម្បីធានាដល់កិច្ចការបម្រើសេវាយុត្តិធម៌

- រៀបចំគ្រប់គ្រង និងទុកដាក់សំណុំរឿងចាត់ការរួចតាមបទប្បញ្ញត្តិចៅក្រម ទុកដាក់ក្នុងឃ្លាំងសំណុំរឿងរបស់សាលាដំបូងរាជធានីភ្នំពេញ ឱ្យមានសណ្តាប់ធ្នាប់ ងាយស្រួលក្នុងការស្រាវជ្រាវ និងស្វែងរក

- បង្កើនប្រសិទ្ធភាពគ្រប់គ្រងទិន្នន័យ តាមការចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិចឱ្យកាន់តែប្រសើរឡើង

- គ្រប់គ្រងការប្រមូលពន្ធ និងប្រាក់ពិន័យ ដើម្បីជាប្រយោជន៍ចំណូលថវិកាជាតិ

- លើកសំណើសុំកញ្ចប់ថវិកាសម្រាប់ចំណាយឆ្នាំ២០២៦ ដើម្បីឆ្លើយតបតាមការចំណាយជាក់ស្តែង
- ធានាអនុវត្តថវិកាដែលទទួលបានក្នុងឆ្នាំ២០២៥ ឱ្យមានប្រសិទ្ធភាព និងតម្លាភាព
- ធានាក្នុងការផ្តល់យុត្តិធម៌លើរឿងក្តីគ្រប់ប្រភេទឱ្យបានឆាប់រហ័ស ដើម្បីបង្កើនជំនឿទុកចិត្តពីប្រជាពលរដ្ឋ និងរួមចំណែកពង្រឹងសុវត្ថិភាពសង្គម។

ខ. ការពង្រឹងចំណាត់ការលើសំណុំរឿង

- បន្តជំរុញសហការអនុវត្តយុទ្ធនាការបង្ក្រាបបទល្មើសលួច ឆក់ ប្លន់ គ្រឿងញៀន ចរាចរណ៍ ជួញដូរមនុស្ស សម្ពាតប្រាក់ និងបទល្មើសបរិស្ថាន/ព្រៃឈើ
- ធានាក្នុងការផ្តល់យុត្តិធម៌លើរឿងក្តីគ្រប់ប្រភេទ ដើម្បីបង្កើនជំនឿទុកចិត្តពីប្រជាពលរដ្ឋ និងរួមចំណែកពង្រឹងសុវត្ថិភាពសង្គម
- រៀបចំបញ្ជីសំណុំរឿងស្មុគស្មាញ ដើម្បីរកដំណោះស្រាយ និងចាត់វិធានការឱ្យបានទាន់ពេល ជៀសវាងការកកស្ទះសំណុំរឿង
- ពង្រឹងការអនុវត្តទារប្រាក់ពិន័យ ស្របតាមលិខិតលេខ ០០៧៨កយ.អកវត/២៣ របស់ក្រសួងយុត្តិធម៌
- រៀបចំទុកដាក់សំណុំរឿង ដែលបានចាត់ការរួចតម្កល់ទុកនៅក្នុងឃ្លាំងសំណុំរឿងឡើងវិញ និងបញ្ចូលទៅក្នុងទិន្នន័យ ដោយរៀបតាមលេខ ថ្ងៃ ខែ ឆ្នាំ ដើម្បីងាយស្រួលក្នុងការស្វែងរកសំណុំរឿង
- ជំរុញឱ្យចំណាត់ការរឿងក្តីបានឆាប់រហ័សស្របតាមនីតិវិធី ជាពិសេសសំណុំរឿងជនជាប់ឃុំ
- ជំរុញចំណាត់ការរឿងក្តីសម្ពាតប្រាក់ ស្រាវជ្រាវប្រភពទ្រព្យដើម្បីឈានទៅដល់ការបង្កក និងរឹបអូស
- ជំរុញចំណាត់ការរឿងក្តីគ្រឿងញៀន ចរាចរណ៍ និងក្មេងទំនើងឱ្យបានតឹងរឹង
- ជំរុញចំណាត់ការសំណុំរឿងអត្រានុកូលដ្ឋានឱ្យបានត្រឹមត្រូវ និងឆាប់រហ័សជូនប្រជាពលរដ្ឋ។

គ. ការពង្រឹងគុណភាពសេចក្តីសម្រេច

- រៀបចំសេចក្តីសម្រេច និងឯកសារសំខាន់ៗ
- រៀបចំសេចក្តីណែនាំអនុវត្តលើចំណាត់ការរឿងអនុវត្តដោយបង្ខំ និងអនុវត្តរក្សាការពារ
- សិក្សាស្រាវជ្រាវ និងចងក្រងសេចក្តីសម្រេចមានលក្ខណៈល្អប្រសើរ ដែលអាចទុកជាគំរូសម្រាប់ការអនុវត្ត
- ប្រជុំពិភាក្សាលើចំណាត់ការនីតិវិធី និងរបៀបសរសេរសាលក្រម និងសេចក្តីសម្រេច (បង្កើតរូបមន្ត)។

ថ្ងៃពុធ ៥ កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២៥

ប្រធានរដ្ឋបាលអធិការដ្ឋានរដ្ឋបាល

អ៊ុំ រិទ្ធ

បានឃើញ និង ឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២៥

ព្រះរាជអាជ្ញា

ច្រឹង ខ្មៅ

ប្រធានសាលាដំបូង

ឡន ណារ៉ា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



សាលាដំបូង និងអយ្យការអមសាលាដំបូង
ខេត្តកណ្តាល
លេខ ៧៣៦ រប/២៥

របាយការណ៍សង្ខេបការងាររបស់សាលាដម្រះក្តី
សម្រាប់សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំយុត្តិធម៌ ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារអាទិភាព ឆ្នាំ២០២៥
សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកណ្តាល

==========

១. ស្ថានភាពទូទៅ

ក. ធនធានមនុស្ស

មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ដែលកំពុងបម្រើការងារនៅសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកណ្តាល មានចំនួន **១៧៧រូប (ស្ត្រី ៥៨រូប)** ក្នុងនោះមាន៖

- **ប្រធានសាលាដំបូង** ចំនួន ០១រូប
- អនុប្រធានសាលាដំបូង ចំនួន ០៣រូប ក្នុងនោះមានស្ត្រីចំនួន ០០រូប
- ចៅក្រមពេញសិទ្ធិ ចំនួន ១២រូប ក្នុងនោះមានស្ត្រីចំនួន ០២រូប (សិក្សាក្រៅប្រទេសចំនួន ០១រូប)
- ចៅក្រមកម្មសិក្សា ចំនួន០១រូប ក្នុងនោះមានស្ត្រីចំនួន ០១រូប
- **ព្រះរាជអាជ្ញា** ចំនួន ០១រូប
- ព្រះរាជអាជ្ញារង ចំនួន ០៨រូប ក្នុងនោះមានស្ត្រីចំនួន ០៣រូប
- ប្រធានលេខាធិការដ្ឋានរដ្ឋបាល ចំនួន ០១រូប
- អនុប្រធានលេខាធិការដ្ឋានរដ្ឋបាល ចំនួន ០៤រូប ក្នុងនោះមានស្ត្រី ០១រូប
- ប្រធានការិយាល័យ ចំនួន ០៤រូប ក្នុងនោះមានស្ត្រី ០២រូប
- អនុប្រធានការិយាល័យ ចំនួន ១៧រូប ក្នុងនោះមានស្ត្រី ០៨រូប
- ក្រឡាបញ្ជីសាលាដំបូង ចំនួន ៤៥រូប ក្នុងនោះមានស្ត្រីចំនួន ១០រូប
- ក្រឡាបញ្ជីអយ្យការ ចំនួន ១៤រូប ក្នុងនោះមានស្ត្រីចំនួន០៤រូប
- មន្ត្រីអាជ្ញាសាលា ចំនួន ០៤រូប
- មន្ត្រីគ្រប់គ្រងរដ្ឋបាល ចំនួន ២៤រូប ក្នុងនោះមានស្ត្រីចំនួន ១០រូប
- មន្ត្រីគ្រប់គ្រងរដ្ឋបាលកម្មសិក្សា ចំនួន ២០រូប ក្នុងនោះមានស្ត្រីចំនួន ០៩រូប
- មន្ត្រីជាប់កិច្ចសន្យា ចំនួន ១៨រូប ក្នុងនោះមានស្ត្រីចំនួន ០៩រូប។

ខ. ហេដ្ឋារចនាសម្ព័ន្ធ

សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកណ្តាល មានទីតាំងស្ថិតនៅភូមិតាខ្មៅ២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល ដោយមានផ្ទៃដីទំហំ ៨៦៧៧ម៉ែត្រការ៉េ និងមានអគារចំនួន ៣ រួមមាន៖

អគារលេខាធិការដ្ឋានរដ្ឋបាល ហៅកាត់ អគារ "ក", អគារសាលាដំបូង ហៅកាត់ អគារ "ខ", និងអគារ អយ្យការអមសាលាដំបូង ហៅកាត់ អគារ "គ"។ ជាមួយគ្នានេះផងដែរ មានសាលសវនាការមានចំនួន ៦សាល, ឃ្លាំងរក្សាទុកវត្ថុតាងមានចំនួន ២, ឃ្លាំងរក្សាទុកសំណុំរឿង(ឃ្លាំងធំ)មានចំនួន ១ និងឃ្លាំងរក្សាទុកសម្ភារផ្សេងៗចំនួន ១ និងចំណតម៉ូតូ-ឡានមាន ចំនួន ២។

គ. លទ្ធផលសង្ខិបាតផ្ទៃក្នុងស្ថាប័នសម្រាប់ឆ្នាំ ២០២៤

-បន្តផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋឱ្យបានលឿន ត្រឹមត្រូវ និងយុត្តិធម៌

-អនុវត្តជាជាច់ខាត និងមានវិធានការតឹងរ៉ឹងបំផុតក្នុងចំណាត់ការនីតិវិធីសំណុំរឿងគ្រឿងញៀន ដោយធានាឱ្យបាននូវភាពស្អាតស្អំ មានតម្លាភាព និងម៉ឺងម៉ាត់ត្រឹមត្រូវតាមច្បាប់

-យកចិត្តទុកដាក់ខ្ពស់ក្នុងការជំរុញ និងពន្លឿនក្នុងចំណាត់នីតិវិធីពាក់ព័ន្ធនឹងបទល្មើសចរាចរណ៍ និង សំណុំរឿងកែតម្រូវសំបុត្រអត្រានុកូលដ្ឋាន ព្រមទាំងធានាឱ្យបាននូវភាពស្អាតស្អំ និងត្រឹមត្រូវតាមច្បាប់

-ការជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌ ក្នុងករណីព្រះរាជអាជ្ញារងដែលត្រូវបានចាត់តាំងជាតំណាងអយ្យការចូលរួមសវនាការអវត្តមាន ដោយជាប់រវល់បេសកម្ម ឬមានធុរៈចាំបាច់ ព្រះរាជអាជ្ញាត្រូវចាត់តាំងព្រះរាជអាជ្ញារងផ្សេងទៀតជាតំណាងអយ្យការជំនួស ចៀសវាងការលើកពេលសវនាការ

-ការប្រកាសសាលក្រមក្នុងសំណុំរឿងព្រហ្មទណ្ឌ ក្នុងករណីព្រះរាជអាជ្ញារងដែលបានចូលរួមសវនាការអវត្តមាន ដោយជាប់បេសកកម្ម ឬមានធុរៈចាំបាច់ ព្រះរាជអាជ្ញាចាត់តាំងព្រះរាជអាជ្ញារងផ្សេងទៀតជាតំណាងអយ្យការ ដើម្បីចូលរួមនីតិវិធីនៃការប្រកាសសាលក្រមជំនួស

-ការជំនុំជម្រះក្នុងបទល្មើសឧក្រិដ្ឋ ក្នុងករណីមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ មិនចូលរួមក្នុងនីតិវិធីសវនាការ និងស្នើសុំលើកពេលជាច្រើនលើកច្រើនសារ ក្នុងគោលបំណងពន្យារពេល ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចស្នើសុំចាត់តាំងមេធាវីផ្សេងដើម្បីការពារសិទ្ធិឱ្យជនជាប់ចោទ

-ការជំនុំជម្រះក្នុងករណីពិនិត្យឃើញថា វត្តមានមន្ត្រីនគរបាលយុត្តិធម៌នៅពេលសវនាការជាការចាំបាច់ និងមានសារៈសំខាន់ ដើម្បីស្វែងរកឱ្យឃើញការពិតក្នុងសំណុំរឿង តំណាងអយ្យការត្រូវអញ្ជើញមន្ត្រីនគរបាលយុត្តិធម៌ចូលរួមក្នុងនីតិវិធីសវនាការ។

ឃ. ព្រឹត្តិការណ៍ ឬកម្មវិធីការងារផ្សេងៗ

-នៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៤ សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកណ្តាល បានរៀបចំកិច្ចប្រជុំជាមួយគណៈប្រតិភូ និងក្រុមការងារនៃ គណៈកម្មការដឹកនាំយុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ។

-នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤ សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកណ្តាល បានរៀបចំកិច្ចប្រជុំជាមួយគណៈប្រតិភូ និងក្រុមការងារនៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញស្តីពី "ការចុះធ្វើអធិការកិច្ចនៅស្ថាប័នអយ្យការអមសាលាដំបូងខេត្តកណ្តាល" ។

-នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៤ សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកណ្តាល បានរៀបចំកិច្ចប្រជុំជាមួយគណៈប្រតិភូ និងក្រុមការងារនៃគណៈកម្មការគ្រប់គ្រង និងចាត់ចែងវត្ថុតាងស្តីពី "ការចុះត្រួតពិនិត្យ និងវាយតម្លៃលើការគ្រប់គ្រង និងស្ថានភាពជាក់ស្តែងរបស់វត្ថុតាង" ។

-នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៤ ប្រធានលេខាធិការដ្ឋានរដ្ឋបាល បានចូលរួម "កិច្ចប្រជុំពិភាក្សាពិគ្រោះយោបល់លើសេចក្តីព្រាងប្រកាសស្តីពីការទទួលស្គាល់អ្នកបកប្រែ និងក្រុមហ៊ុនបកប្រែក្នុងវិស័យ យុត្តិធម៌" នៅទីស្តីការក្រសួងយុត្តិធម៌។

-នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៤ សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកណ្តាលបានរៀបចំកិច្ចប្រជុំជាមួយគណៈប្រតិភូ និងក្រុមការងារនៃគណៈកម្មការដឹកនាំ និងអនុវត្តយុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ (គ.ជ.ព) ។

-កិច្ចប្រជុំសហប្រតិបត្តិការអន្តរជាតិលើកទី១២ ឆ្នាំ២០២៤ រវាងសាលាដំបូងខេត្តកណ្តាល សាលាដំបូងខេត្តតាកែវ និងតុលាការប្រជាជនខេត្តអានយ៉ាង នៅប្រទេសវៀតណាម នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៤។

-នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤ សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកណ្តាលបានរៀបចំកិច្ចប្រជុំជាមួយគណៈប្រតិភូ និងក្រុមការងារនៃសាលាឧទ្ធរណ៍ភ្នំពេញស្តីពី "ការពិនិត្យ និងផ្សៀងផ្ទាត់ឡើងវិញនូវការងាររបស់មន្ទីរស៊ើបសួរដែលអនុវត្តកន្លងមក ដើម្បីជៀសវាងបញ្ហាការឃុំខ្លួនហួសនីតិវិធី" ។

២.សមិទ្ធផលការងារ

ក.អយ្យការអមសាលាដំបូង

ក.១. ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌ

បរិយាយ	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	កំពុងចាត់ការ
ឆ្នាំ២០២៤	២០៨រឿង	៣ ១០៦រឿង	៣ ១២០រឿង	១៩៤រឿង

ក.២. កិច្ចការពាក់ព័ន្ធនឹងការអនុវត្តទោស និងពន្ធនាគារ

ក.២.១. ការអនុវត្តទោសដោយព្រះរាជអាជ្ញា

បរិយាយ	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	សល់កំពុងចាត់ការ
ឆ្នាំ២០២៤	៣៤៩នាក់	៥ ៨៣៥នាក់	៥ ៨១៨នាក់	៣៦៦នាក់

ក.២.២. ពន្ធនាគារខេត្តកណ្តាល

ជនជាប់ឃុំ	សរុបរួម		អនីតិជន		នីតិជន		ជនបរទេស	
	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី
ជនត្រូវចោទ	១ ៥០០នាក់	៩៥នាក់	១៥១នាក់	១០នាក់	១ ៣០១នាក់	៨៣នាក់	៤៨នាក់	០២នាក់
ជនជាប់ចោទ	៣៦៧នាក់	៣៩នាក់	៤០នាក់	០៣នាក់	៣១០នាក់	៣៣នាក់	១៧នាក់	០៣នាក់
ពិរុទ្ធជន	១ ៩៥៣នាក់	១០២នាក់	១៣៦នាក់	០៩នាក់	១ ៧៦៩នាក់	៩៣នាក់	៤៨នាក់	០០នាក់
ទណ្ឌិត	១៩៩នាក់	១៧នាក់	០៨នាក់	០១នាក់	១៨៥នាក់	១៦នាក់	០៦នាក់	០០នាក់
សរុបរួម	**៤ ០១៩នាក់**	**២៥៣នាក់**	**៣៣៥នាក់**	**២៣នាក់**	**៣ ៥៦៥នាក់**	**២២៥នាក់**	**១១៩នាក់**	**០៥នាក់**

ក.៣. កិច្ចការពាក់ព័ន្ធជាមួយនឹងមន្ត្រីនគរបាលយុត្តិធម៌

គ្រប់តំណាងអយ្យការ មានការកិច្ចចុះត្រួតពិនិត្យដល់មូលដ្ឋាន ទៅលើកិច្ចការងាររបស់អង្គភាពនគរបាលយុត្តិធម៌ក្នុងដែនសមត្ថកិច្ច រៀងរាល់ពីរដងក្នុងមួយឆ្នាំ ដើម្បីផ្សព្វផ្សាយច្បាប់ ចុះពិនិត្យលើការអនុវត្តវិធានឃាត់ខ្លួន ជាពិសេសគឺការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួនជាអាទិ៍។

ក.៤. កិច្ចការផ្សេងទៀតរបស់ស្ថាប័នអយ្យការ

អង្គការអយ្យការបានចាត់តាំងព្រះរាជអាជ្ញារងមួយរូប ទទួលបន្ទុកលើកិច្ចការងារនេះ ដោយត្រូវចុះត្រួតពិនិត្យទៅលើបញ្ហាសន្តិសុខ បរិវេណខាងក្រៅ និងខាងក្នុងអគារ តាមបន្ទប់នីមួយៗ និងពិភាក្សានូវបញ្ហាប្រឈមក្នុងពេលបំពេញការកិច្ចរបស់មន្ត្រីពន្ធនាគារ។ ជាមួយគ្នានេះផងដែរ មានការចាត់តាំងតំណាងអយ្យការចំនួន ០១រូប ទទួលបន្ទុកលើការត្រួតពិនិត្យលើកិច្ចការងាររដ្ឋបាល កិច្ចការងារចំណាត់ការ សន្តិសុខផ្ទៃក្នុង (បរិវេណខាងក្រៅ និងខាងក្នុងអគារ តាមបន្ទប់នីមួយៗ) និងកិច្ចការងារទូទៅរបស់មណ្ឌលស្តារយុវនីតិសម្បទា។

ខ.សាលាដំបូង៖

ខ.១.ចំណាត់ការលើសំណុំរឿងព្រហ្មទណ្ឌ

ខ.១.១. ដំណាក់កាលស៊ើបសួរ

បរិយាយ	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	សល់កំពុងចាត់ការ
ឆ្នាំ២០២៤	៨១៣រឿង	២ ៦២៤រឿង	២ ៦០៧រឿង	៨៣០រឿង

ខ.១.២. ដំណាក់កាលជំនុំជម្រះ

បរិយាយ	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	សល់កំពុងចាត់ការ
ឆ្នាំ២០២៤	៥៧៩រឿង	២ ៨៤២រឿង	២ ៨៧៩រឿង	៥៤២រឿង

ខ.២. ចំណាត់ការសំណុំរឿងរដ្ឋប្បវេណី

បរិយាយ	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	សល់កំពុងចាត់ការ
ឆ្នាំ២០២៤	២ ៤២១រឿង	៤ ២៩៧រឿង	៤ ៥៧២រឿង	២ ១៤៦រឿង

ខ.៣. ចំណាត់ការលើសំណុំរឿងផ្សេងទៀត

បរិយាយ	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	សល់កំពុងចាត់ការ
ឆ្នាំ២០២៤	០២រឿង	០១រឿង	០២រឿង	០១រឿង

៣.បញ្ហាប្រឈម និងសំណូមពរ

ក. បញ្ហាប្រឈម

ក.១. ក្នុងកិច្ចការរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ

-ការបំពេញការងាររបស់មន្ត្រី និងបុគ្គលិក មិនទាន់គោរពឱ្យត្រឹមត្រូវតាមពេលវេលាកំណត់

-ខ្វះថវិកាប្រចាំឆ្នាំ សម្រាប់ផ្គត់ផ្គង់ដំណើរការកិច្ចការរដ្ឋបាល និងកិច្ចការបច្ចេកទេសសំណុំរឿង

-ខ្វះខាតសម្ភារប្រើប្រាស់ដូចជា៖ កំព្យូទ័រ ម៉ាស៊ីនព្រីន ម៉ាស៊ីនស្កេន ម៉ាស៊ីនថតចម្លង ។ល។ ហើយសម្ភារកំពុងប្រើប្រាស់ខ្លះជាកម្មសិទ្ធិផ្ទាល់ខ្លួនរបស់មន្ត្រី ចំពោះសម្ភាររបស់អង្គភាពខ្លះមានសភាពចាស់ប្រើប្រាស់បណ្តើរជួសជុលបណ្តើរ មានការលំបាកក្នុងការប្រើប្រាស់ និងហានិភ័យខ្ពស់ក្នុងការរក្សាទុកទិន្នន័យ និងឯកសារផ្សេងៗ

-វត្ថុតាងគ្រប់ប្រភេទ ពុំទាន់បានចាត់ចែងតាមអំណាចសាលក្រមស្តាពរ ជាពិសេស រថយន្ត និងម៉ូតូ ជាហេតុបណ្តាលឱ្យកកស្ទះពេញអង្គភាព ធ្វើឱ្យវត្ថុតាងទាំងនោះអស់គុណភាព និងតម្លៃក្នុងការប្រមូលថវិការចូលរដ្ឋ

-ការរៀបចំយន្តការនៃបញ្ជូនសាលក្រមចំពោះមុខ និងសាលក្រមកំបាំងមុខទៅតំណាងអយ្យការ និងពន្ធនាគារ មិនទាន់គ្រប់គ្រងបានល្អនៅឡើយ។

ក.២. បញ្ហាប្រឈមក្នុងកិច្ចការបច្ចេកទេស

ក.២.១. ដំណាក់កាលអយ្យការ

-ការជូនដំណឹងអំពីដីកាតម្កល់រឿងទុកឥតចាត់ការ នៅពេលដែលតំណាងអយ្យការសម្រេចធ្វើតម្កល់រឿងទុកឥតចាត់ការ ត្រូវការធ្វើលិខិតជូនដំណឹងទៅភាគី បានន័យថាក្នុងរយៈពេលដែលធ្វើលិខិតជូនដំណឹងគឺមិនមានដីកាត្រឡប់មកវិញនោះទេ។ នៅក្នុងរយៈពេលមួយឆ្នាំ ឬពីរឆ្នាំក្រោយ ភាគីមិនបានដឹងហើយឆ្លើយថាមិនបានទទួលលិខិតជូនដំណឹងនោះ ដូចនេះត្រូវសើរើឡើងវិញហើយជូនដំណឹងទៅភាគីម្តងទៀត។

-ការជូនដំណឹងពីសាលក្រមកំបាំងមុខ នៅពេលដែលសាលាដំបូងបញ្ជូនសំណុំរឿងឱ្យតំណាងអយ្យការធ្វើការជូនដំណឹងពីសាលក្រមកំបាំងមុខទៅជនជាប់ចោទ នៅពេលដែលជូនដំណឹងទៅគាត់ហើយក៏មិនមានដីកាបង្វិលត្រឡប់មកវិញដែរ។

ក.២.២ ដំណាក់កាលចៅក្រមស៊ើបសួរ

-ការបញ្ជូនឯកសារពាក់ព័ន្ធក្នុងសំណុំរឿងទាំងបញ្ជូនចេញ និងបង្វិលត្រឡប់មកវិញមានការយឺតយ៉ាវដោយមន្ត្រីនគរបាលយុត្តិធម៌ មន្ទីរ អង្គភាព និងអ្នកជាប់ពាក់ព័ន្ធ មិនប្រគល់របាយការណ៍ស្តីពីការអនុវត្តត្រឡប់មកវិញ ឬប្រគល់ត្រឡប់មកវិញមានការយឺតយ៉ាវ

-សំណុំរឿងភាគច្រើនពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ក្នុង១សំណុំរឿងមានជនជាប់ឃុំច្រើននាក់ នីតិវិធីដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ មិនមានលក្ខណៈគ្រប់គ្រាន់ បើប្រៀបធៀបទៅនឹងបទល្មើសដែលចោទប្រកាន់ ដែលជាហេតុនាំឱ្យចៅក្រមស៊ើបសួរត្រូវសម្រេចឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន។

ក.២.៣. ដំណាក់កាលចៅក្រមជំនុំជម្រះ

-ចៅក្រមជំនុំជម្រះ និងប្រកាសសាលក្រមរួច មានការយឺតយ៉ាវប្រគល់សាលក្រមទៅជនជាប់ទាក់ទិន និងអង្គភាពពាក់ព័ន្ធ

-ការជំនុំជម្រះក្នុងបទល្មើសឧក្រិដ្ឋ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ មិនចូលរួមក្នុងនីតិវិធីសវនាការ និងស្នើសុំលើកពេលជាច្រើនលើកច្រើនសារ ក្នុងគោលបំណងពន្យាពេល។

-ការជំនុំជម្រះសំណុំរឿងខ្លះ ត្រូវមានមន្ត្រីនគរបាលយុត្តិធម៌ចូលរួមសវនាការជាការចាំបាច់ ប៉ុន្តែមិនបានអញ្ជើញមន្ត្រីនគរបាលយុត្តិធម៌ចូលរួមក្នុងនីតិវិធីសវនាការ

-ចៅក្រមជំនុំជម្រះ បានចេញសាលក្រមសម្រេចព្យួរទោសទាំងមូល ឬសម្រេចឱ្យរួចផុតពីការចោទប្រកាន់ ប៉ុន្តែមិនបានចេញដីកាបញ្ឈប់ឱ្យចាប់ខ្លួន។

ក.២.៤. បញ្ហាប្រឈមក្នុងសំណុំរឿងរដ្ឋប្បវេណី

-ការបញ្ជូនដីកា សេចក្តីសម្រេច ឬលិខិតផ្សេងៗ មិនបានសម្រេចដោយមូលហេតុមិនមានដីកាបង្វិលត្រឡប់មកវិញ

-កិច្ចសហការជាមួយមន្ត្រីជំនាញនៅមានកម្រិត ដោយមិនសូវផ្តល់លទ្ធផលតាមការស្នើសុំរបស់ចៅក្រមទទួលបន្ទុកសំណុំរឿង

-សំណុំរឿងអនុវត្តដោយបង្ខំ មិនសូវចាត់ការបានចប់ជាស្ថាពរ ដោយហេតុថា មិនមានអ្នកចូលរួមដាក់ពាក្យចូលរួមដេញថ្លៃទិញអចលនវត្ថុ។

ខ. សំណូមពរ

-ស្នើសុំថវិកាប្រចាំឆ្នាំបន្ថែមសម្រាប់ជួសជុលអគារ ផ្គត់ផ្គង់ដំណើរកិច្ចការរដ្ឋបាល និងកិច្ចការបច្ចេកទេស

-ស្នើសុំបន្ថែមចៅក្រម និងក្រឡាបញ្ជី

-ស្នើសុំបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់មន្ត្រីលើកិច្ចការរដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស កំព្យូទ័រ និងប្រព័ន្ធព័ត៌មានវិទ្យា

-ស្នើសុំពន្លឿនយន្តការនៃការចាត់ចែងវត្ថុតាងបណ្តោះអាសន្ន។

៤. ទិសដៅការងារឆ្នាំ២០២៥

ក. កិច្ចការរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ

-មន្ត្រីត្រូវអនុវត្តកាតព្វកិច្ចការងារយ:ពេល០៨(ប្រាំបី)ម៉ោងក្នុងមួយថ្ងៃ និង៥(ប្រាំ)ថ្ងៃក្នុងមួយសប្តាហ៍ ឬ៤០(សែសិប)ម៉ោងក្នុងមួយសប្តាហ៍ មន្ត្រីត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំជាធរមាន

-មន្ត្រីត្រូវចុះហត្ថលេខាលើបញ្ជីវត្តមាន រាល់ពេលចូលធ្វើការ និងពេលចេញពីធ្វើការ

-មន្ត្រីត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈ និងត្រូវប្រឹងប្រែងបំពេញការងារឱ្យកាន់តែល្អ ព្រមទាំងអភិវឌ្ឍន៍ចំណេះដឹងជំនាញវិជ្ជាជីវៈឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត

-រៀបចំសេវារដ្ឋបាលឱ្យកាន់តែមានភាពងាយស្រួលប្រើប្រាស់ ក្នុងការផ្តល់សេវាយុត្តិធម៌ឱ្យកាន់តែឆាប់រហ័ស គុណភាពនៃយុត្តិធម៌ សុក្រឹតភាព និងភាពត្រឹមត្រូវ

-បន្តពង្រឹងការចុះបញ្ជីតាមប្រព័ន្ធ Database ឱ្យបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួងយុត្តិធម៌

-ត្រូវធ្វើបញ្ជីប្រចាំខែ របាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ ឱ្យមានភាពត្រឹមត្រូវ និងទាន់ពេលវេលា តាមគំរូរបាយការណ៍ក្រសួងយុត្តិធម៌

-ផ្តល់ការសហការរវាងរដ្ឋបាលតុលាការ រដ្ឋបាលខេត្ត និងមន្ទីរ-អង្គភាពជុំវិញខេត្ត ក្នុងន័យលើកកម្ពស់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរ

ខ. កិច្ចការបច្ចេកទេស

ខ.១. កិច្ចការអយ្យការអមសាលាដំបូង

-ព្រះរាជអាជ្ញា បន្តរៀបចំកិច្ចប្រជុំជាមួយមន្ត្រីនគបាលយុត្តិធម៌ និងអង្គភាព-ស្ថាប័នពាក់ព័ន្ធផ្សេងៗ ឱ្យបានទៀងទាត់

-ករណីព្រះរាជអាជ្ញារងដែលត្រូវចូលរួមសវនាការអវត្តមានដោយជាប់រវល់បេសកម្ម ឬមានធុរៈចាំបាច់ ព្រះរាជអាជ្ញា ចាត់តាំងព្រះរាជអាជ្ញារងម្នាក់ផ្សេងទៀត ជាតំណាងអយ្យការជំនួស ចៀសវាងការលើកពេលសវនាការ។

ខ.២. កិច្ចការចៅក្រមស៊ើបសួរ

-ចៅក្រមស៊ើបសួរ ត្រូវពិនិត្យសំណុំរឿងឱ្យបានមូល និងត្រូវស៊ើបសួរទាំងដោះបន្ទុក និងដាក់បន្ទុកមុនបិទការស៊ើបសួរ និងចេញដីកាដំណោះស្រាយ ដើម្បីចៀសវាងនៅការខ្វះចន្លោះបំពេញកិច្ចណាមួយដែលធ្វើឱ្យចៅក្រមជំនុំជម្រះមិនអាចជំនុំជម្រះ និងបង្វិលសំណុំរឿងមកឱ្យស៊ើបសួរបន្ថែម។

-ចៅក្រមស៊ើបសួរ តាមដានជាប្រចាំលើដីកាចាត់ឱ្យស៊ើបសួរជំនួស ដែលបញ្ជូនទៅមន្ត្រីនគរបាលយុត្តិធម៌ ប៉ុន្តែមិនបានទទួលលទ្ធផលមកវិញ ត្រូវជូនដំណឹងទៅ ឯកឧត្តមព្រះរាជអាជ្ញា និង ឯកឧត្តមប្រធានសាលាដំបូងដើម្បីសម្របសម្រួលជូន។

ខ.៣. កិច្ចការចៅក្រមជំនុំជម្រះ

-ចៅក្រមត្រូវប្រគល់សាលក្រមព្រហ្មទណ្ឌដែលបានជំនុំជម្រះ និងប្រកាសរួច យ៉ាងយូរបំផុតរយៈពេល ១ខែ គិតចាប់ពីថ្ងៃប្រកាសសាលក្រម មកលេខាធិការដ្ឋានរដ្ឋបាលដើម្បីចាត់ចែងបន្ត

-ចៅក្រមជំនុំជម្រះ និងប្រកាសសាលក្រម រួចត្រូវប្រគល់សាលក្រមទៅជនជាប់ទាក់ទិន និងអង្គភាពពាក់ព័ន្ធឱ្យបានឆាប់រហ័ស

-ចៅក្រមជំនុំជម្រះត្រូវសម្រេចលុបចោលដីកាចាប់ខ្លួនរបស់ចៅក្រមស៊ើបសួរ នៅពេលដែលចៅក្រមជំនុំជម្រះបានចេញសាលក្រមសម្រេចព្យួរទោសទាំងមូល ឬសម្រេចឱ្យរួចផុតពីការចោទប្រកាន់ រួចធ្វើការជូនដំណឹងទៅតំណាងអយ្យការ ដើម្បីជូនដំណឹងបន្តទៅមន្ត្រីនគរបាលយុត្តិធម៌។

ខ.៤. កិច្ចការសំណុំរឿងរដ្ឋប្បវេណី

-ចៅក្រមទទួលបន្ទុកសំណុំរឿង ត្រូវពិនិត្យ និងសម្រេចឱ្យបានឆាប់រហ័ស ចំពោះពាក្យសុំពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់របស់គូភាគី

-ការបញ្ជូនដីកាកោះ ឬដីកាសម្រេចផ្សេងៗតាមការផ្សាយជាសាធារណៈ ដើម្បីជៀសវាងអូសបន្លាយពេលវេលាយូរ គឺនៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចៅក្រមត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីបន្តបន្ទាប់ទៀតតែម្តង

-បន្តយកចិត្តទុកដាក់ដោះស្រាយរឿងក្តីតាមរយៈការផ្សះផ្សាគូភាគីឱ្យសះជា

-ជំរុញ និងពន្លឿនចំណាត់ការសំណុំរឿងចាស់ និងចូលថ្មីឱ្យបានលឿន ត្រឹមត្រូវ និងយុត្តិធម៌។

ថ្ងៃ អង្គារ ៦កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

កណ្តាល ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៥

ប្រធានលេខាធិការដ្ឋានរដ្ឋបាល

សូ សារិន

បានឃើញ និងឯកភាព

កណ្តាល ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៥

ព្រះរាជអាជ្ញា

ឈាវ ផ្សែង

ប្រធានសាលាដំបូង

ជឹ ស្រ៊ុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង និងអយ្យការ
អមសាលាដំបូងខេត្តកំពង់ស្ពឺ
លេខាធិការដ្ឋានរដ្ឋបាល
លេខ៖ ១០៩០ រប/២៥

របាយការណ៍ការងារសង្ខេបរបស់សាលាដម្រះក្តី
សម្រាប់អង្គសន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារអនាគត ឆ្នាំ២០២៥
សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ

==========

១. ស្ថានភាពទូទៅ

១.១ ធនធានមនុស្ស

សាលាដំបូងខេត្តកំពង់ស្ពឺ

ប្រធានសាលាដំបូង		អនុប្រធានសាលាដំបូង		ចៅក្រម		ក្រឡាបញ្ជីតុលាការ	
សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី
១	០	៤	០	១១	២	១៧	២
សរុប ៣២ រូប (ស្រី ៤រូប)							

អយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ

ព្រះរាជអាជ្ញា		ព្រះរាជអាជ្ញារង		ក្រឡាបញ្ជីអយ្យការ	
សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី
១	០	៧	០	៨	៣
សរុប ១៦ រូប (ស្រី៣រូប)					

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តកំពង់ស្ពឺ

ប្រធានលេខា		អនុប្រធានលេខា		ប្រ.ការិយាល័យ		អនុ.ការិយាល័យ		មន្ត្រីរដ្ឋបាល		មន្ត្រី.កិច្ចសន្យា	
សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី
១	០	៤	០	៤	០	៤	២	៤៨	២៥	២៦	១១
សរុប ៨៧រូប (ស្រី៤០រូប)											

សរុប ១៣៥រូប (ស្រី ៤៧រូប)

១.២ ហេដ្ឋារចនាសម្ព័ន្ធ

សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ មានអគារធំចំនួន២អគារ និងអគារតូចចំនួន ២អគារ(ជាអគារសវនាការ, កន្លែងសម្រាប់រក្សាទុកវត្ថុចាប់យក, និងកន្លែងសម្រាប់តម្កល់សំណុំរឿងចាត់ការ រួច)សម្រាប់បំពេញការងារប្រចាំថ្ងៃហើយ ក្នុងនោះមានសាលប្រជុំធំចំនួន១, សាលប្រជុំតូចចំនួន១, បន្ទប់សវនាការចំនួន៣បន្ទប់, ឃ្លាំងដាក់សម្ភារៈចំនួន១, ឃ្លាំងតម្កល់វត្ថុតាងចំនួន២កន្លែង, ឃ្លាំងតូចបច្ចុប្បន្ននៅសាលាដំបូង១, ឃ្លាំងធំស្ថិតនៅអគារសាលាដំបូងទីតាំងចាស់, ឃ្លាំងរក្សាទុកសំណុំរឿងមានចំនួន២,រោងចំណតរថយន្តចំនួន២ ។

១.៣ លទ្ធផលសន្និបាតឆ្នៃក្នុងស្ថាប័ន ២០២៤

-ពង្រឹងសមត្ថភាព មន្ត្រីលេខាធិការដ្ឋានរដ្ឋបាលតាមរយៈការបណ្តុះបណ្តាលវគ្គសិក្សាខ្លី និង រយៈពេលវែងដោយក្រសួងយុត្តិធម៌

-បានចំណាត់ការសំណុំរឿងចាស់ និងសំណុំរឿងចូលថ្មីគ្រប់ប្រភេទ បានឆាប់រហ័ស ត្រឹមត្រូវ និងប្រកបដោយភាពយុត្តិធម៌បំផុត

-ការផ្តល់សេវាកម្មយុត្តិធម៌ប្រកបដោយក្រមសីលធម៌ វិជ្ជាជីវៈ និងការទទួលខុសត្រូវខ្ពស់បំផុត

-ពង្រឹងសមត្ថភាពមន្ត្រីនគរបាលយុត្តិធម៌ បណ្តុះបណ្តាលផ្សព្វផ្សាយពីនីតិវិធីក្រមព្រហ្មទណ្ឌ តាមរយៈការចុះអធិការកិច្ចនៅតាម ស្នងការដ្ឋាននគរបាលខេត្ត បញ្ជាការដ្ឋានកងរាជអាវុធហត្ថ និងពន្ធនាគារ

-ការចុះផ្សព្វផ្សាយ អប់រំច្បាប់តាមមូលដ្ឋាន ជាមួយរដ្ឋបាលខេត្ត អធិការក្រុងស្រុក បញ្ជាការដ្ឋានកងរាជអាវុធហត្ថក្រុងស្រុក ពាក់ពន្ធបទល្មើសចរាចរណ៍, ក្មេងទំនើង, គ្រឿងញៀន, ការជួញដូរមនុស្ស និងហិង្សាក្នុងគ្រួសារជាអាទិ៍។

១.៤ ព្រឹត្តិការណ៍ ឬកម្មវិធីការងារនានា

- នាថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤ ឯកឧត្តម **ឡុង កេសតីរម្យ** ប្រធានសាលាដំបូង និងឯកឧត្តម **សុិន ឥរៈ** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ បានបើកអង្គសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ២០២៣ លើកទិសដៅបន្តអនុវត្តឆ្នាំ២០២៤។

- នាថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ ឯកឧត្តម **ឡុង កេសតីរម្យ** ប្រធានសាលាដំបូង និង ឯកឧត្តម **សុិន ឥរៈ** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ បានបើកកិច្ចប្រជុំ ការអនុវត្តដីកាបញ្ជូនជាមួយនគរបាលយុត្តិធម៌, អធិការដ្ឋាននគរបាលក្រុង ស្រុក, បញ្ជាការដ្ឋានកងរាជអាវុធហត្ថក្រុង ស្រុក។

- នាថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៤ លោក **ចក សម្បត្តិ** ព្រះរាជអាជ្ញារង និងជាអ្នកនាំពាក្យ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ ដឹកនាំដោយឯកឧត្តមបណ្ឌិត **គឹម សន្តិភាព** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាប្រធានគណៈប្រតិភូនៃគណៈកម្មការថ្នាក់ជាតិ ពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិត ស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស អញ្ជើញដឹកនាំក្រុមការងារចុះទៅពិនិត្យស្ថានភាពទណ្ឌិតដែលមានជម្ងឺ រ៉ាំរ៉ៃ ចាស់ជរា នៅពន្ធនាគារខេត្តកំពង់ស្ពឺ ។

-នាថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤ ឯកឧត្តម **ឡុង កេសតីរម្យ** ប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ និង ឯកឧត្តម **សុិន ឥរៈ** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ រៀបចំកិច្ចប្រជុំស្តីពី ការអនុវត្ត

យុទ្ធនាការ ដំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅសាលាដំបូងខេត្តកំពង់ស្ពឺ ក្រោមអតិបតីភាព ឯកឧត្តម **ជីវ សុខហាក់** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ។

-នាថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤ ឯកឧត្តម **សុិន ទិរៈ** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ បានចុះអធិការកិច្ចត្រួតពិនិត្យស្ថានភាពជនជាប់ឃុំ និងសាកសួរសុខទុក្ខទណ្ឌិត នៅពន្ធនាគារខេត្តកំពង់ស្ពឺ។

-នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤ ឯកឧត្តម **ឡុច កេសតីរម្យ** ប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ និងឯកឧត្តម **សុិន ទិរៈ** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ បានរៀបចំកម្មវិធី តេស្តរកសារធាតុញៀន របស់មន្ត្រីរាជការ នៃសាលាដំបូង និងអយ្យការអមសាលាដំបូខេត្តកំពង់ស្ពឺ មានការចូលរួមដោយនគរបាលយុត្តិធម៌ ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការនគរបាលខេត្តកំពង់ស្ពឺ។

-នាថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២៤ ឯកឧត្តម **ឡុច កេសតីរម្យ** ប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ និងឯកឧត្តម **សុិន ទិរៈ** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ បានរៀបចំកម្មវិធី ខួបទី ១១៣ ទិវាអន្តរជាតិនារី ៨មីនា ។

-នាថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ ឯកឧត្តម **ឡុច កេសតីរម្យ** ប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ និង ឯកឧត្តម **សុិន ទិរៈ** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ បានរៀបចំកិច្ចប្រជុំស្តីពី ការចុះអធិការកិច្ច លើនគរបាលយុត្តិធម៌ និងពន្ធនាគារ ក្នុងដែនសមត្ថកិច្ច របស់មហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដឹកនាំដោយឯកឧត្តម **ឈឹម សុគន្ធា** អគ្គព្រះរាជអាជ្ញារង នៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

-នាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤ ឯកឧត្តម **សុិន ទិរៈ** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ លោក **ចក សម្បត្តិ** ព្រះរាជអាជ្ញារង លោក **ឱិន សុចិត្រា** ព្រះរាជអាជ្ញារង និងលោក **ង៉ែន ឆរិទ្ធ** ព្រះរាជអាជ្ញារង បានចុះផ្សព្វផ្សាយពង្រឹងការអនុវត្ត តួនាទី ភារកិច្ចតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

-នាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤ លោក **លាង លីហៀង** ចៅក្រមសាលាដំបូងខេត្តកំពង់ស្ពឺ ជាតំណាង ឯកឧត្តម **ឡុច កេសតីរម្យ** ប្រធានសាលាដំបូង និងលោក **ង៉ែន ឆរិទ្ធ** ព្រះរាជអាជ្ញារង តំណាង ឯកឧត្តម **សុិន ទិរៈ** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ ដឹកនាំកិច្ចប្រជុំដោយ លោក **ឯក សារឿន** អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ ចុះត្រួតពិនិត្យវឌ្ឍនភាពការងារ, បញ្ហាប្រឈម, សំណូមពរ, និងយន្តការដោះស្រាយ។

-នាថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤ លោក **ពៅ ឥសុល** ប្រធាននាយកដ្ឋាន និងជាប្រធានក្រុមការងាររដ្ឋបាលនៃ គ១ បានចុះអធិការកិច្ចលើការងាររដ្ឋបាល វត្តមាន, សៀវភៅចុះបញ្ជី និងប្រព័ន្ធ, ស្ថានភាពរដ្ឋបាលចេញចូលតែមួយ, ការគ្រប់គ្រងសៀវភៅចុះបញ្ជី និងធ្វើការណែនាំពីអត្ថប្រយោជន៍នៃការប្រើប្រាស់សៀវភៅចុះបញ្ជី។

-នាថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤ ឯកឧត្តម **ឡុច កេសតីរម្យ** ប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ និង លោក **ចក សម្បត្តិ** ព្រះរាជអាជ្ញារង តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **សុិន ទិរៈ** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ បានរៀបចំកិច្ចប្រជុំ ដឹកនាំដោយ ឯកឧត្តម **សុខ ប៊ុន** អគ្គលេខាធិការរងនៃ អ.ដ.ក. និងគណៈប្រតិភូអមដំណើរ បានចុះផ្សព្វផ្សាយពីកិច្ចដំណើរការរបស់ អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

-នាថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៤ ឯកឧត្តម **ឡុច កេសគីរម្យ** ប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ និង ឯកឧត្តម **សុិន ទិរ:** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ បានរៀបចំកម្មវិធី ស្តីពីការចុះ អធិការកិច្ច នៅអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ, នគរបាលយុត្តិធម៌ និងពន្ធនាគារខេត្តកំពង់ស្ពឺ ក្រោម អធិបតីភាព ឯកឧត្តម **ឈឹម សុគន្ធា** អគ្គព្រះរាជអាជ្ញារង នៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ និង ប្រតិភូអមដំណើរ។

-នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៤ ឯកឧត្តម **ឡុច កេសគីរម្យ** ប្រធានសាលាដំបូង និងឯកឧត្តម **សុិន ទិរ:** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ បានរៀបចំកម្មវិធីឈស្តីពី ការចុះអធិការ កិច្ច របស់ក្រុមការងារសភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ក្រោមអធិបតីភាព ឯកឧត្តម **ឃុន លាងម៉ែង** អនុប្រធានសាលាឧទ្ធរណ៍ភ្នំពេញ។

២. សមិទ្ធផលការងារ

ក. អយ្យការអមសាលាដំបូង:

ក.១. ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌ

បរិយាយ	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	សល់កំពុងចាត់ការ
ប្រចាំឆ្នាំ២០២៤	១៦៥	២២២០	២២៤៧	១៣៨

ក.២. កិច្ចការពាក់ព័ន្ធនឹងការអនុវត្តទោស និងពន្ធនាគារ

ក.២.១. ការអនុវត្តទោសដោយព្រះរាជអាជ្ញា

សេចក្តីសម្រេចស្ថាពរ	រឿងចាស់	ចូលថ្មី	សរុប	ចាត់ការរួច	សល់កំពុងចាត់ការ
សាលក្រមព្រហ្មទណ្ឌ	០	៥៧១	៥៧១	៥៧១	០
សាលដីកាព្រហ្មទណ្ឌសាលាឧទ្ធរណ៍	០	១៩	១៩	១៩	០
សាលដីកាព្រហ្មទណ្ឌតុលាការកំពូល	០	០	០	០	០
ដោះលែងដោយព្រះរាជក្រឹត្យ	០	១	១	១	០
សរុប	០	៥៩១	៥៩១	៥៩១	០

ក.២.២. ពន្ធនាគារខេត្តកំពង់ស្ពឺ

ជនជាប់ឃុំ	សរុបរួម		អនីតិជន		នីតិជន		ជនបរទេស	
	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី
ជនត្រូវចោទ	៨៣៩	៣៤	៦៩	១	៧៦០	៣២	១០	១
ជនជាប់ចោទ	៤០៦	២៧	៤៥	១	៣៦១	២៦	០	០
ពិរុទ្ធជន	៧១៧	៣៩	៥៥	០	៦៤៩	៣៧	១៣	២
ទណ្ឌិត	៣៥៦	២៤	៣៣	៣	៣២១	២១	២	០
សរុប	២៣១៨	១២៤	២០២	៥	២០៩១	១១៦	២៥	៣

ក.៣. កិច្ចការពាក់ព័ន្ធជាមួយនឹងមន្ត្រីនគរបាលយុត្តិធម៌

-នាថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤ អយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ បានរៀបចុះកិច្ចប្រជុំស្តីពី" ការចាត់តាំងជនបង្គោលអនុវត្តដីកាបញ្ជូន **តាមក្រុងស្រុក**" ដោយមានការចូលរួមពីអង្គភាពនគរបាលយុត្តិធម៌ នៃស្នងការដ្ឋានខេត្តកំពង់ស្ពឺ ក្រោមអធិបតីភាព ឯកឧត្តម **ស៊ុន ឥរិះ** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ។

ខ. សាលាដំបូង៖

ខ.១. ចំណាត់ការលើសំណុំរឿងព្រហ្មទណ្ឌ

ខ.១.១. ដំណាក់កាលស៊ើបសួរ

បរិយាយ	សំណុំរឿងចាស់	សំណុំរឿងចូលថ្មី	ចាត់ការរួច	សល់កំពុងចាត់ការ
ប្រចាំឆ្នាំ២០២៤	៦០៤	១៥៨២	១៦២៥	៥៦១

ខ.១.២. ដំណាក់កាលជំនុំជម្រះ

បរិយាយ	សំណុំរឿងចាស់	សំណុំរឿងចូលថ្មី	ចាត់ការរួច	សល់កំពុងចាត់ការ
ប្រចាំឆ្នាំ២០២៤	៤៤៨	១៦៨០	១៦៩៦	៤៣២

ខ.២. ចំណាត់ការលើសំណុំរឿងរដ្ឋប្បវេណី

បរិយាយ	សំណុំរឿងចាស់	សំណុំរឿងចូលថ្មី	ចាត់ការរួច	សល់កំពុងចាត់ការ
ប្រចាំឆ្នាំ២០២៤	១០៩៨	៤៤៦៣	៤៦៥៦	៩០៥

ខ.៣. ចំណាត់ការសំណុំរឿងអនុវត្ត

បរិយាយ	សំណុំរឿងចាស់	សំណុំរឿងចូលថ្មី	ចាត់ការរួច	សល់កំពុងចាត់ការ
ប្រចាំឆ្នាំ២០២៤	៦៩	៤៨	២៣	៩៤

៣. បញ្ហាប្រឈម និងសំណូមពរ

៣.១. បញ្ហាប្រឈម

-ទាក់ទងនឹងការអនុវត្តមិនទាន់មានអាជ្ញាសាលាអនុវត្ត

-កង្វះខាតក្រឡាបញ្ជីតាមបន្ទប់ចៅក្រម និងព្រះរាជអាជ្ញា

-ការបញ្ជូនដីកាមិនដល់ភាគីដែលត្រូវទទួលការបញ្ជូន ដោយកត្តាផ្សេងៗ ដូចជាការចំណាកស្រុកការផ្លាស់ប្តូរទីលំនៅជាដើម

-ការប្រើប្រាស់សេវាកម្មរបស់ប្រៃសណីយ៍ដើម្បីបញ្ជូន ឬ កោះហៅ ឬ ជូនដំណឹងអំពីសេចក្តីសម្រេចផ្សេងៗ របស់តុលាការមិនមានប្រសិទ្ធភាព

-សាលក្រមបានបញ្ជូនទៅពន្ធនាគាររួចរាល់ ប៉ុន្តែមន្ត្រីពន្ធនាគារពុំបានធ្វើបច្ចុប្បន្នភាពហើយទាមទារឱ្យចៅក្រមទទួលបន្ទុកផ្តល់ម្តងទៀត។

៣.២. សំណូមពរ

-ស្នើសុំឱ្យមានកិច្ចប្រជុំជាមួយពន្ធនាគារដើម្បីពិភាក្សាបញ្ហាបញ្ជូនសាលក្រម ការបញ្ជាក់លើសាលក្រមស្តាពរ

-ក្រឡាបញ្ជីសូមបញ្ជូនសាលក្រម សាលក្រមកំបាំងមុខ និងសាលក្រមស្តាពរមករដ្ឋបាលឱ្យបាន ឆាប់រហ័ស ដើម្បីរដ្ឋបាលចាត់ចែងបន្តឱ្យមានប្រសិទ្ធភាព

-ស្នើសុំឱ្យក្រឡាបញ្ជីដែលបញ្ជាក់ស្តាពរលើសាលក្រមព្រហ្មទណ្ឌ ត្រូវចុះហត្ថលេខា និងវាយត្រា មុនបញ្ជូនមកកាន់រដ្ឋបាល

-បង្កើតវគ្គបណ្តុះបណ្តាលផ្ទៃក្នុង សម្រាប់មន្ត្រីរដ្ឋបាលដែលទទួលពាក្យបណ្តឹង

៤. ទិសដៅការងារសម្រាប់ឆ្នាំ ២០២៥

- បង្កើតឲ្យមានក្រុមការងារបញ្ជូនដីកា និងឯកសារផ្សេងៗរបស់សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្ត ជាមួយមន្ទីរអង្គភាពដែលពាក់ព័ន្ធជុំវិញខេត្ត ដើម្បីងាយស្រួល និងឆាប់រហ័សដល់ការសម្រេចសេចក្តី។

- ចូលរួមយ៉ាងសកម្មជាមួយសាលាដំបូង និងអយ្យការអមសាលាដំបូង ចំពោះការធ្វើអធិការកិច្ច នៅជាមួយស្ថាប័នដែលពាក់ព័ន្ធ

- ពង្រឹងកិច្ចសហប្រតិបត្តិការការងាររវាងសាលាដំបូង និងអយ្យការអមសាលាដំបូង ព្រមទាំងអង្គភាព ពាក់ព័ន្ធ ជាពិសេសអង្គភាពមន្ត្រីនគរបាលយុត្តិធម៌ និងពន្ធនាគារ។

- ពង្រឹងវិន័យការងារ វត្តមាន) ពេលវេលា ការស្លៀកពាក់ អាកប្បកិរិយា និងឥរិយាបថ(

- រៀបចំអនុញ្ញាតឲ្យតែមន្ត្រីរាជការ មន្ត្រីកិច្ចសន្យា ឬមន្ត្រីហាត់ការ និងគណៈប្រតិភូ ទើបអាចចតយានយន្តក្នុងបរិវេណទីតាំងសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ

-

- ពង្រឹងការស្នើសុំតម្លើងឋានន្តរសក្តិ ឬថ្នាក់តាមវេនអតីតភាពការងារ និងតាមវេនជ្រើសរើស ព្រមទាំង ការស្នើសុំគ្រឿងឥស្សរិយយស មេដាយការងារ និងប័ណ្ណសរសើរ ជូនមន្ត្រីរាជការ

- បញ្ជូនសាលក្រមទៅអយ្យការជារៀងរាល់ថ្ងៃ និងពន្ធនាគារ អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ និងក្រសួង យុត្តិធម៌ ឲ្យបានក្នុងសប្តាហ៍ម្តង

- ពង្រឹងសមត្ថភាពមន្ត្រីបំរើវិស័យសាធារណៈ ក្នុងការអនុវត្តបំរើការងារប្រកបដោយការទទួលខុសត្រូវ និង មានប្រសិទ្ធភាព ជូនប្រជាពលរដ្ឋ

- ស្នើសុំឱ្យមានប្រាក់ឧបត្ថម្ភលើកទឹកចិត្តដល់មន្ត្រីប្រចាំការនៅថ្ងៃឈប់សម្រាក

- អនុវត្តតាមគោលការណែនាំ និងតាមលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ របស់ថ្នាក់ដឹកនាំ ឲ្យកាន់តែល្អប្រសើរ

ថ្ងៃព្រហស្បតិ៍ ៨កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
កំពង់ស្ពឺ, ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៥

បានឃើញ និងឯកភាព

ព្រះរាជអាជ្ញា

ស៊ុន វិរៈ

ប្រធានសាលាដំបូង

ប្រធានលេខាធិការដ្ឋានរដ្ឋបាល

ជេង-ស៊ីតំណា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង និង អយ្យការ
អមសាលាដំបូងខេត្តកំពង់ឆ្នាំង
លេខាធិការដ្ឋានរដ្ឋបាល
លេខ៖ ២១៥ រ.ប./២០២៥

របាយការណ៍ការងារសង្ខេបរបស់សាលាដម្រះក្តី
សម្រាប់សន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារអនាគត ឆ្នាំ២០២៥
សាលាដំបូងខេត្តកំពង់ឆ្នាំង និងអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង

==========

១. ស្ថានភាពទូទៅ

ក- ធនធានមនុស្ស

ល.រ	មុខតំណែង	ចំនួន	ស្រី	ជនពិការ
១.សាលាដំបូង		**សរុប ១១រូប**	**សរុប ០២រូប**	**សរុប ០០រូប**
១	ប្រធានសាលាដំបូង	១រូប	០រូប	
២	អនុប្រធានសាលាដំបូង	២រូប	០រូប	
៣	ចៅក្រម	៧រូប	២រូប	
៤	ចៅក្រមកម្មសិក្សា	១រូប	០រូប	
២.អយ្យការអមសាលាដំបូង		**សរុប ០៩រូប**	**សរុប ០១រូប**	**សរុប ០០រូប**
១	ព្រះរាជអាជ្ញា	១រូប	០ស្រី	
២	ព្រះរាជអាជ្ញារង	៧រូប	១រូប	
៣	ព្រះរាជអាជ្ញារងកម្មសិក្សា	១រូប	១រូប	
៣.ក្រឡាបញ្ជី		**សរុប ២៦រូប**	**សរុប ០៨រូប**	**សរុប ០០រូប**
១	ក្រឡាបញ្ជីតុលាការ	១៨រូប	៤រូប	
២	ក្រឡាបញ្ជីអយ្យការ	៦រូប	១រូប	
៣	ក្រឡាបញ្ជីកម្មសិក្សា	២រូប	២រូប	
៤.អាជ្ញាសាលា		**សរុប ០០រូប**	**សរុប ០០រូប**	**សរុប ០០រូប**
១	អាជ្ញាសាលា	០រូប	០រូប	
២	អាជ្ញាសាលាកម្មសិក្សា	០រូប	០រូប	
៥.លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង		**សរុប ៥៥រូប**	**សរុប ២៨រូប**	**សរុប ០១រូប**
១	ប្រធានលេខាធិការដ្ឋាន	១រូប	០រូប	
២	អនុប្រធានលេខាធិការដ្ឋាន	៤រូប	១រូប	

៣	ប្រធានការិយាល័យ	៤រូប	០រូប	
៤	អនុប្រធានការិយាល័យ	១១រូប	៥រូប	
៥	មន្ត្រីគ្រប់គ្រងរដ្ឋបាល "ក"	១៥រូប	១២រូប	
៦	មន្ត្រីក្រមការ "ខ"	៥រូប	៣រូប	
៧	លេខាធិការ "គ"	១រូប	១រូប	
៨	មន្ត្រីកម្មសិក្សា	០រូប	០រូប	
៩	មន្ត្រីជាប់កិច្ចសន្យា	១៤រូប	៦រូប	០១

ខ- ហេតុារចនាសម្ព័ន្ធស្ថាប័ន

១.មានអាគារចំនួន ៦ អគារ

បន្ទប់មន្ត្រីសម្រាប់បំរើការងារមានចំនួន ៤២ បន្ទប់, បន្ទប់ប្រជុំ មានចំនួន ២ បន្ទប់, សាលសវនាការ មានចំនួន ៣ បន្ទប់, ការិយាល័យគណាមេធាវីប្រតិភូមិមានចំនួន ២ បន្ទប់, បន្ទប់រក្សាជនជាប់ឃុំ មានចំនួន ១ បន្ទប់

២.មានឃ្លាំងដំកល់វត្ថុតាងចំនួន ១ (ជួលនៅខាងក្រៅ)

គ. លទ្ធផលសន្និបាតផ្ទៃក្នុងស្ថាប័នសម្រាប់ឆ្នាំ ២០២៤

ឯកឧត្តម **ឯក ស៊ុនរស្មី** មានប្រសាសន៍ថាសូមឱ្យលោក លោកស្រីនៅក្នុងអង្គសន្និបាតលើកពីបញ្ហាដើម្បីរួមគ្នាដោះស្រាយទាំងបញ្ហាក្នុងពេលបំពេញការងារ និងបញ្ហាផ្ទាល់ខ្លួនរបស់ឯកឧត្តមផងដែរ។ សូមកុំកូតកុហក ហើយហ៊ានិយាយការពិត។ ជាបន្ទាប់លោក **ហុង គឹមហាក់** បានអានសេចក្តីព្រាងរបាយការណ៍បូកសរុបលទ្ធផលការងារសម្រាប់ឆ្នាំ២០២៤ និងលើកទិសដៅការងារឆ្នាំ២០២៥ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំងជូនអង្គសន្និបាត។ ជាកិច្ចបញ្ចប់ឯកឧត្តម **គឹម រ័ត្នណារិន** បានបូកសរុបលទ្ធផលនៃអង្គសន្និបាត និងបានថ្លែងថាសូមបន្តចូលរួមឱ្យបានសកម្មក្នុងការអនុវត្តនូវយុទ្ធនាការទាំង២ របស់ក្រសួងយុត្តិធម៌ដោយយកចិត្តទុកដាក់បំផុត ព្រមទាំងត្រូវបន្តជំរុញឱ្យមានការយកចិត្តទុកដាក់កាន់តែខ្ពស់ក្នុងការដោះស្រាយរឿងក្តីព្រហ្មទណ្ឌ រឿងក្តីរដ្ឋប្បវេណី និងរឿងក្តីផ្សេងៗទៀត ដោយត្រូវប្រកាន់ខ្ជាប់នូវអភិក្រមទាំងបួន គឺ លឿន ត្រឹមត្រូវ យុត្តិធម៌ និងមិនមានអំពើពុករលួយ ជាពិសេសលើសំណុំរឿងអាទិភាពទាំងបួន (គ្រឿងញៀន ចរាចរណ៍ អត្រានុកូលដ្ឋាន និងក្មេងទំនើង)។

ឃ. ព្រឹត្តិការណ៍ ឬកម្មវិធីការងារផ្សេងៗ (កិច្ចប្រជុំ ឬជំនួបពិភាក្សាការងារជាមួយស្ថាប័នដែលមានការពាក់ព័ន្ធ ជាអាទិ៍ សាលាខេត្តចំនួន ៥លើក, ពន្ធនាគារចំនួន ៤លើក, មន្ត្រីនគរបាលយុត្តិធម៌ចំនួន១០លើក, ប្រតិភូ ឬក្រុមការងាររបស់ក្រសួងយុត្តិធម៌, កិច្ចប្រជុំខេត្តជាប់ព្រំដែន.....)

២. សមិទ្ធផលការងារ

ក. អយ្យការអមសាលាដំបូង៖

ក.១. ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌ

-សំណុំរឿងសល់ពីមុន 133 រឿង
-សំណុំរឿងចូលថ្មី 1214 រឿង
-សំណុំរឿងចាត់ការរួច 1278 រឿង
-សំណុំរឿងសល់កំពុងចាត់ការ 69 រឿង

ក.២. កិច្ចការពាក់ព័ន្ធនឹងការអនុវត្តទោស និងពន្ធនាគារ

បរិយាយ	សរុបរួម		អនីតិជន		នីតិជន		ជនបរទេស	
	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី
១	២=៤+៦+៨	៣=៥+៧+៩	៤	៥	៦	៧	៨	៩
ជនត្រូវចោទ	1362	75	213	0	1139	75	10	0

ជនជាប់ចោទ	353	15	45	0	307	15	1	0
ពិរុទ្ធជន	1325	61	146	3	1139	55	40	3
ទណ្ឌិត	1004	43	47	0	942	41	15	2
សរុបជនជាប់ឃុំ	**4044**	**194**	**451**	**3**	**3527**	**186**	**66**	**5**

ទិន្នន័យនៃការគ្រប់គ្រងអ្នកជាប់ឃុំក្នុងពន្ធនាគារ

ការអនុវត្តសេចក្តីសម្រេច			ចំនួនសរុប	ឧណ្ហិតកំពុងអនុវត្ត												ឧណ្ហិតត្រូវបានដោះលែង			
				សរុប		អនីតិជន	ជនបរទេស		នីតិជន		មានលក្ខខណ្ឌ		បត្យាប័ន/ផ្ទេរចេញ		មរណភាព		សរុប	អនីតិជន	ជនបរទេស	នីតិជន
							សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី				
១			២	៣=៤+៥+៧+៩+១១+១៣		៤	៥	៦	៧	៨	៩	១០	១១	១២	១៣	១៤	១៥=១៦+១៧ +១៨	១៦	១៧	១៨
ឧណ្ហិតកំពុងអនុវត្ត	អាន	សាលដីកាតុលាការកំពូល	15	12		1	0	0	11	2	0	0	0	0	0	0	3	0	0	3
		សាលដីកាសាលាឧទ្ធរណ៍	272	175		4	0	0	171	3	0	0	0	0	0	0	97	1	0	96
		សាលក្រមស្តាពរ	1192	989		34	0	0	955	30	0	0	0	0	0	0	203	47	0	156
		ដីកាសម្រេច	0	0		0	0	0	0	0	0	0	0	0	0	0	0	0	0	0
	សរុប ១		1479	1176		39	0	0	1137	35	0	0	0	0	0	0	303	48	0	255
	ពុំទាន់អាន	សាលដីកាតុលាការកំពូល	0	0		0	0	0	0	0	0	0	0	0	0	0	0	0	0	0
		សាលដីកាសាលាឧទ្ធរណ៍	0	0		0	0	0	0	0	0	0	0	0	0	0	0	0	0	0
		សាលក្រមស្តាពរ	0	0		0	0	0	0	0	0	0	0	0	0	0	0	0	0	0
		ដីកាសម្រេច	0	0		0	0	0	0	0	0	0	0	0	0	0	0	0	0	0
	សរុប ២		0	0		0	0	0	0	0	0	0	0	0	0	0	0	0	0	0
ឧណ្ហិតឈ្លើយឃុំ	អាន	សាលដីកាតុលាការកំពូល	41	8		1	0	0	7	1	0	0	0	0	0	0	33	13	14	6
		សាលដីកាសាលាឧទ្ធរណ៍	6	6		2	0	0	4	0	0	0	0	0	0	0	0	0	0	0
		សាលក្រមស្តាពរ	493	111		7	0	0	104	3	0	0	0	0	0	0	382	155	157	70

	ជីកាសម្រេច	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0
	សរុប ៣	540	125	10	0	0	115	4	0	0	0	0	0	0	415	168	171	76
ប៉ុន្មាន	សាលដីកាតុលាការកំពូល	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0
	សាលដីកាសាលាឧទ្ធរណ៍	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0
	សាលក្រមស្តាពរ	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0
	ជីកាសម្រេច	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0
	សរុប ៤	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0
សរុបរួម= សរុប ១+២+៣+៤		2019	1301	49	0	0	1252	39	0	0	0	0	0	0	718	216	171	331

ការអនុវត្តទោសដោយព្រះរាជអាជ្ញា

ល.រ	**លិខិតអនុវត្ត**	**សល់ពីមុន**	**ចូលថ្មី**	**ចាត់ការរួច**	**សល់កំពុងចាត់ការ**	**ផ្សេងៗ**
១	**<u>សាលក្រមព្រហ្មទណ្ឌ</u>**	0	1243	1243	1243	
២	សាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍	0	117	117	117	
៣	សាលដីកាព្រហ្មទណ្ឌរបស់តុលាការកំពូល	0	17	17	17	
៤	សាលក្រម ឬ សាលដីកា របស់តុលាការបរទេស	0	0	0	0	
៥	ផ្សេងៗ	-	-	-	-	
	សរុប	**0**	**1377**	**1377**	**1377**	

ក.៣. កិច្ចការពាក់ព័ន្ធជាមួយនឹងមន្ត្រីនគរបាលយុត្តិធម៌៖ បានចុះធ្វើអធិការកិច្ចតាមស្រុក និងក្រុងបានចំនួន ១៤ ដង

ក.៤. កិច្ចការផ្សេងទៀតរបស់ស្ថាប័នអយ្យការ (ប្រសិនបើមាន)

ខ. សាលាដំបូង៖

ខ.១. ចំណាត់ការលើសំណុំរឿងព្រហ្មទណ្ឌ

ខ.១.១. ដំណាក់កាលស៊ើបសួរ

-សំណុំរឿងចាស់ <u>338</u> រឿង

-សំណុំរឿងចូលថ្មី <u>694</u> រឿង

-សំណុំរឿងចាត់ការរួច <u>928</u> រឿង

-សំណុំរឿងសល់កំពុងចាត់ការ <u>104</u> រឿង

ខ.១.២. ដំណាក់កាលជំនុំជម្រះ

-សំណុំរឿងចាស់ <u>438</u> រឿង

-សំណុំរឿងថ្មី <u>982</u> រឿង

-សំណុំរឿងចាត់ការរួច <u>1337</u> រឿង

-សំណុំរឿងសល់កំពុងចាត់ការ <u>83</u> រឿង

ខ.២. ចំណាត់ការលើសំណុំរឿងរដ្ឋប្បវេណី

-សំណុំរឿងសល់ពីមុន	989	រឿង
-សំណុំរឿងចូលថ្មី	561	រឿង
-សំណុំរឿងចាត់ការរួច	1029	រឿង
-សំណុំរឿងសល់កំពុងចាត់ការ	521	រឿង

+រដ្ឋប្បវេណីមិនមែនបណ្តឹង

-សំណុំរឿងសល់ពីមុន	127	រឿង
-សំណុំរឿងចូលថ្មី	3271	រឿង
-សំណុំរឿងចាត់ការរួច	3258	រឿង
-សំណុំរឿងសល់កំពុងចាត់ការ	140	រឿង

+ដីកាសម្រេចរក្សាការពារ

-សំណុំរឿងសល់ពីមុន	79	រឿង
-សំណុំរឿងចូលថ្មី	80	រឿង
-សំណុំរឿងចាត់ការរួច	82	រឿង
-សំណុំរឿងសល់កំពុងចាត់ការ	77	រឿង

+ដីកាសម្រេចអនុវត្តរក្សាការពារ

-សំណុំរឿងសល់ពីមុន	46	រឿង
-សំណុំរឿងចូលថ្មី	37	រឿង
-សំណុំរឿងចាត់ការរួច	53	រឿង
-សំណុំរឿងសល់កំពុងចាត់ការ	30	រឿង

+សំណុំរឿងរដ្ឋប្បវេណីអនុវត្តដោយបង្ខំ

-សំណុំរឿងសល់ពីមុន	270	រឿង
-សំណុំរឿងចូលថ្មី	88	រឿង
-សំណុំរឿងចាត់ការរួច	72	រឿង
-សំណុំរឿងសល់កំពុងចាត់ការ	286	រឿង

ខ.៣. ចំណាត់ការសំណុំរឿងផ្សេងទៀត

ខ.៤. កិច្ចការផ្សេងទៀតរបស់សាលាដំបូង (ប្រសិនបើមាន)

៣. បញ្ហាប្រឈម និងសំណូមពរ

- ខ្វះខាតការិយាល័យធ្វើការរបស់ចៅក្រម,ព្រះរាអាជ្ញា,ក្រឡាបញ្ជី និងមន្ត្រី។
- រាល់ដីកាកោះបញ្ជូនទៅ ភាគច្រើនមិនដល់ដៃសាមីខ្លួន មានការលំបាក។
- ដីកាចាប់ខ្លួនមួយចំនួននគរបាលយុត្តិធម៌ ស្វែងរកចាប់ខ្លួនមិនបាន ជួបការលំបាកនិងពិបាកស្វែងរកជនមានពិរុទ្ធ
- ខ្វះខាតឃ្លាំងដាក់វត្ថុតាង
- ខ្វះខាតមធ្យោបាយចុះស៊ើបសួរព្រហ្មទណ្ឌ និងចុះការងារអនុវត្តាសាលក្រមសាលដីកា
- ខ្វះខាតសៀវភៅចុះបញ្ជីរឿងក្តី និងរូបមន្តក្នុងរឿងក្តីព្រហ្មទណ្ឌនិងរឿងក្តីរដ្ឋប្បវេណីមួយចំនួនធំ។

+សំណូមពរ

- ស្នើសុំមន្ត្រីអាជ្ញាសាលា ចំនួន ០១ រូប, ក្រឡាបញ្ជី ចំនួន ១០ រូប បន្ថែម, មន្ត្រីជាប់កិច្ចសន្យា ចំនួន ១០ រូប និងសាងសង់ឃ្លាំងវត្ថុតាង ឃ្លាំងតម្កល់រូបមន្ត ឃ្លាំងតម្កល់សំណុំរឿងចាត់ការរួច។

៤. ទិសដៅការងារសម្រាប់ឆ្នាំ ២០២៥

១-បន្តអនុវត្តគោលការណ៍ឆាប់រហ័ស ការបញ្ជូនចេញ នូវសេចក្តីសម្រេចគ្រប់ប្រភេទជាអាទិ៍ សេចក្តីសម្រេចមិនទាន់ស្តាពរ និងស្តាពរ ដល់គូភាគី ពិសេសដល់ជនជាប់ឃុំ។

២-បន្តធ្វើអធិការកិច្ចនៅតាមអង្គភាពមន្ត្រីនគបាលយុត្តិធម៌ក្នុងដែនសមត្ថកិច្ចរបស់ខេត្តកំពង់ឆ្នាំង និងអធិការកិច្ចពន្ធនាគារ ក្នុងដែនសមត្ថកិច្ចអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ដើម្បីធានារដំណើរការដ៏ល្អនៃកិច្ចស៊ើបអង្កេត និងភាពត្រឹមត្រូវនៃការឃុំខ្លួន។

៣-បន្តពង្រឹងការឃ្លាំមើលកិច្ចសហប្រតិបត្តិការងារ នគរបាលយុត្តិធម៌ និងអយ្យការអមសាលាដំបូង ក្នុងដែនសមត្ថកិច្ច ដើម្បីធានារការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវតាមនីតិវិធី។

៤-បន្តពង្រឹងការឃ្លាំមើលក្នុងការអនុវត្តសេចក្តីសម្រេចនានារបស់តុលាការ និងតំណាងអយ្យការ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តច្បាប់។

៥-បន្តជម្រុញការចេញសាលក្រមព្រហ្មទណ្ឌ រដ្ឋប្បវេណី និងសាលក្រមព្រហ្មទណ្ឌស្តាពរ និងដីកាសម្រេចផ្សេងៗ ឱ្យបានឆាប់រហ័ស ស្របតាមគោលការណ៍ច្បាប់។

៦-ជំរុញលើកទឹកចិត្តឱ្យមន្ត្រីអនុវត្តច្បាប់ដោះស្រាយរឿងក្តីតាមយន្តការ "មិនធ្វើការសម្រេចសេចក្តី" ឱ្យបានច្រើនតាមដែលអាចធ្វើបាន។

៧-ការសម្រេចសេចក្តី និងការអនុវត្តសេចក្តីសម្រេចស្តាពរ ត្រូវអនុវត្តតាមច្បាប់ និងគប្បីថ្លឹងថ្លែងអំពីគោលការណ៍មនុស្សធម៌ ផងដែរ។

៨-ក្រឡាបញ្ជីត្រូវបន្តយកចិត្តទុកដាក់ក្នុងការពន្លឿនជួយរៀបចំឯកសារ និងជួយតាមដាននូវចំណាត់ការសំណុំរឿងនានា ដោយប្រុងប្រយ័ត្ន និងស្មារតីបុរេសកម្ម។

១៦-បន្តពង្រឹងក្រមសីលធម៌ការងារ វិជ្ជាជីវៈ និងសាមគ្គីភាពផ្ទៃក្នុង និងពង្រឹងបន្ថែមនូវកិច្ចសហប្រតិបត្តិការការងារឲ្យកាន់តែប្រសើរឡើងថែមទៀត។

១៧-មន្ត្រីដែលបម្រើការងារនៅផ្នែកទទួលពាក្យបណ្តឹង ដែលបានជួប និងប្រាស្រ័យទាក់ទងជាមួយនឹងប្រជាពលរដ្ឋដោយផ្ទាល់ និងជាប់ជាប្រចាំ ក៏ដូចជាមន្ត្រីរាជការទាំងអស់ ត្រូវជៀសវាងដាច់ខាតក្នុងការបង្ហាញអាកប្បកិរិយាមិនសមរម្យ ពាក្យសម្តីមិនមានសីលធម៌ ដោយត្រូវប្រកាន់ខ្ជាប់នូវសីលធម៌ សុជីវធម៌ និងសេចក្តីថ្លៃថ្នូរក្នុងនាមជាមន្ត្រីរាជការ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ខេត្តកំពង់ឆ្នាំង ថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៥

ព្រះរាជអាជ្ញារង



ហុង គឹមហាក់

បានឃើញ និង ឯកភាព
ខេត្តកំពង់ឆ្នាំង ថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៥

ព្រះរាជអាជ្ញា

ឯក ស៊ុនស្មី

ប្រធានសាលាដំបូង

គឹម ភ្លែណារិទ្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង និងអយ្យការអម
សាលាដំបូងខេត្តព្រៃវែង
លេខាធិការដ្ឋានរដ្ឋបាល
លេខ៖ ២៣៦ រប / ២៥

របាយការណ៍ការងារសេសទ្វេបរបស់សាលាដម្រះក្តី
សម្រាប់សន្និបាតបូកសរុបលទ្ធផលការងារឆមាសយុត្តិធម៌ ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារអនាគត ឆ្នាំ២០២៥
សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តព្រៃវែង

==========

១. ស្ថានភាពទូទៅ

ក- ធនធានមនុស្ស

ក្របខណ្ឌមន្ត្រីរាជការកំពុងបំរើការងារនៅ សាលាដំបូង និងអយ្យការអមសាលាដំបូង ខេត្តព្រៃវែង ក្នុងឆ្នាំ២០២៤ មានចំនួន៨៥រូប (ស្ត្រីចំនួន ៤០រូប)ក្នុងនោះមាន:

១-ចៅក្រមអាសនៈចំនួន ១០ រូប (ស្ត្រីចំនួន០៣រូប)
២-ចៅក្រមអយ្យការចំនួន ០៧ រូប (ស្ត្រីចំនួន០១រូប)
៣-ក្រឡាបញ្ជីចំនួន ២២ រូប (ស្ត្រីចំនួន០៩រូប)
-ផ្នែកតុលាការ ១៦ រូប និងអយ្យការ ០៦ រូប
៤-មន្ត្រីលេខាធិការដ្ឋានចំនួន ២៨ រូប (ស្ត្រីចំនួន១៥រូប)
៥-មន្ត្រីជាប់កិច្ចសន្យា ចំនួន ១៨ រូប (ស្ត្រីចំនួន១៣រូប)

ខ- ហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន

សាលាដំបូង និងអយ្យការអមសាលាដំបូង ខេត្តព្រៃវែង មានទីតាំងក្នុងភូមិ៦ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង។ នៅក្នុងឆ្នាំ១៩៩៦ ស្ថិតក្រោមគំរោងក្រសួងយុត្តិធម៌ សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្ត ទទួលបានអគារបំពេញការងារមួយខ្នង ដែលបន្តអត្ថិភាពរហូតដល់បច្ចុប្បន្ន។ ឆ្លងតាមការអភិវឌ្ឍកន្លងមក ជាពិសេសការអនុវត្តគំរោងលទ្ធកម្មជាបន្តបន្ទាប់ និងដោយមានជំនួយឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍ CCJAP របស់ប្រទេស Australia និងតាមរយៈកិច្ចលទ្ធកម្មប្រចាំឆ្នាំ សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តព្រៃវែង បានដំណើរការសាងសង់អគារចំនួន ៣ បន្ថែមទៀត ក្នុងនោះមានអគារស្នាក់នៅមួយខ្នង, អគារសាលប្រជុំ និងអគារលេខាធិការដ្ឋានរដ្ឋបាលមួយខ្នង ។

គ. លទ្ធផលសន្និបាតផ្ទៃក្នុងស្ថាប័នសម្រាប់ឆ្នាំ២០២៤

គ-១-បន្តប្រកាន់ខ្ជាប់សាមគ្គីភាពផ្ទៃក្នុងក្រមសីលធម៌ចៅក្រម និង អនុវត្តរាល់កិច្ចការគំរូ ដែលបានធ្វើកន្លងមក ។

គ-២-អនុវត្តឲ្យបានត្រឹមត្រូវតាមក្រមនីតិវិធីច្បាប់ពាក់ព័ន្ធជា ពិសេសការយកចិត្តទុកដាក់អនុវត្តនីតិវិធីទាក់ទងនឹងអនីតិជន ។

គ-៣-បន្តយកចិត្តទុកដាក់ពង្រឹងការអនុវត្តច្បាប់ឲ្យបានម៉ឺងម៉ាត់លើករណី គ្រឿងញៀន ចរាចរណ៍ និងក្មេងទំនើងដែលជាសំណុំរឿងអាទិភាពរបស់ក្រសួងយុត្តិធម៌ ។

គ-៤-ត្រូវបន្តពង្រឹងទំនាក់ទំនងជាមួយស្ថាប័នផ្សេងៗ ដើម្បីជំរុញកិច្ចសហការល្អក្នុងការអនុវត្តច្បាប់ ។

គ-៥-ជំរុញចំណាត់ការរឿងក្តីព្រហ្មទណ្ឌនិងរដ្ឋប្បវេណី ឲ្យបានទាន់ពេលវេលាត្រឹមត្រូវតាមនីតិវិធីនៃច្បាប់ និងត្រូវប្រកាន់ខ្ជាប់នូវអភិក្រមទាំងបួនគឺ លឿន ត្រឹមត្រូវ យុត្តិធម៌និងមិនពុករលួយ ។

គ-៦-បន្តគាំទ្រ និងអនុវត្តនូវផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលជាអាទិ៍៖

- ការពង្រឹងការអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវ
- ការពង្រឹងភាពស្អាតស្អំ និងក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីក្នុងការអនុវត្តច្បាប់
- ពង្រឹងយន្តការវិនិយការងារ និងការធ្វើទំនើបកម្មរដ្ឋបាលយុត្តិធម៌
- លើកកម្ពស់ការផ្តល់សេវាច្បាប់ យុទ្ធសាស្ត្រលើកកម្ពស់សេវាផ្នែកច្បាប់
- ពង្រឹង និងកែលម្អយន្តការដោះស្រាយវិវាទ ដែលអាចឆ្លើយតបនឹងសភាពការណ៍ជាក់ ស្តែង របស់សង្គមប្រកបដោយប្រសិទ្ធភាព។

គ-៧-ត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅសាលាដំបូង និងអយ្យការអមសាលាដំបូង ខេត្តព្រៃវែង ឲ្យបានច្បាស់លាស់ ដែលជាសកម្មភាពចូលរួមចំណែកក្នុងកម្មវិធី នយោបាយកំណែទម្រង់វិស័យច្បាប់ និងប្រព័ន្ធយុត្តិធម៌ របស់រាជរដ្ឋាភិបាលឲ្យសម្រេចជាផ្លែផ្កាដ៏ត្រចះត្រចង់ និងជានិរន្តរភាព ។

ទន្ទឹមនឹងលទ្ធផលដូចដែលបានរៀបរាប់ខាងលើ ឯកឧត្តម ហង់ **ស៊ីថា** បានរំលេចនូវបញ្ហា ប្រឈមដូចខាងក្រោម៖

- កង្វះអ្នកបកប្រែភាសាបរទេស ព្រោះសំណុំរឿងក្នុងសាលាដំបូង ខេត្តព្រៃវែង មានជនបរទេសច្រើនជាតិសាសន៍។
- កង្វះទីតាំង ឬឃ្លាំងដាក់វត្ថុចាប់យក, កន្លែងដាក់វត្ថុចាប់យកមានភាពតូចចង្អៀត
- កង្វះក្រឡាបញ្ជី ,កង្វះមន្ត្រីអាជ្ញាសាលា
- ការស្នើសុំពន្យាពេលក្នុងនីតិវិធីច្រើនដងជាដដែលៗធ្វើឲ្យការដោះស្រាយសំណុំរឿងមានភាពយឺតយ៉ាវ។
- ចំពោះសំណុំរឿងអនុវត្តដោយបង្ខំមានការលំបាកចំពោះអចលនវត្ថុ ដែលមិនទាន់បាន ចុះបញ្ជី និងឈានដល់ដំណាក់កាលលក់តែពុំមានអ្នកទិញ ។
- ការបង្វិលត្រឡប់នៃដីកាកោះ និងឯកសារផ្សេងៗ ពុំទាន់មានប្រសិទ្ធភាពខ្ពស់។
- ជំរុញឲ្យមានការបណ្តុះបណ្តាលដល់មន្ត្រី ជំនាញរដ្ឋបាល លេខាធិការដ្ឋានរដ្ឋបាល។
- ត្រូវបន្តអនុវត្តដោយហ្មត់ចត់ និងកំណត់កាលបរិច្ឆេទជំនុំជម្រះ ឲ្យបានរាប់រហ័សក្នុងរឿងក្តី គ្រប់ប្រភេទ ជូនប្រជាពលរដ្ឋ និងលើកកម្ពស់វិស័យច្បាប់ឲ្យកាន់តែមានលក្ខណៈល្អប្រសើរ។
- ត្រូវបង្កើនសមត្ថភាពជំនាញ ការគោរពវិន័យ បទបញ្ជាផ្ទៃក្នុងឲ្យបានហ្មត់ចត់ ដោយប្រកាន់ ខ្ជាប់នូវអភិក្រមទាំងប្រាំ របស់សម្តេចអគ្គមហាសេនាបតីតេជោ (ឆ្នុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងរះកាត់) និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានខ្លឹមសារថា "សម្អាតផ្ទះយើង" ព្រមទាំងអនុវត្តឲ្យបាន ម៉ឺងម៉ាត់នូវ ក្រមសីលធម៌ វិជ្ជាជីវៈ ដែលមានចែងក្នុងច្បាប់។
- ត្រូវបន្តខិតខំរៀបចំ សេចក្តីសម្រេចគ្រប់ប្រភេទ ឲ្យមានលក្ខណៈត្រឹមត្រូវ ទាំងផ្នែកអង្គហេតុ សំអាងហេតុ និងផ្នែកសេចក្តីសម្រេច ដែលមានកំណត់ក្នុងច្បាប់។
- ត្រូវបន្តសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធនិងអង្គភាពនានា ដែលបម្រើវិស័យយុត្តិធម៌ឲ្យបានល្អប្រសើរ ដើម្បីលើកកម្ពស់ និងការពង្រឹងប្រសិទ្ធភាព នៃច្បាប់ក្នុងវិស័យយុត្តិធម៌ ឲ្យកាន់តែល្អ ប្រសើរ។

ឃ. ព្រឹត្តិការណ៍ ឬកម្មវិធីការចារនានា កិច្ចប្រជុំប្រចាំខែរបស់សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តព្រៃវែង ៖

- ចូលរួមក្នុងគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាខេត្តនិងគណៈបញ្ជាការឯកភាពខេត្តនិងស្ថាប័នពាក់ព័ន្ធ។
- ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៤ កិច្ចប្រជុំគណៈកម្មការដឹកនាំ និងអនុវត្តយុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅសាលាដំបូងខេត្តព្រៃវែង។
- ថ្ងៃទី ០៥-០៦ ខែ វិច្ឆិកា ឆ្នាំ២០២៤ ឯកឧត្តម **ហង់ ស៊ីថា** ប្រធានសាលាដំបូង និង ឯកឧត្តម **គុជ គីមឡុង** ព្រះរាជអាជ្ញាអមសាលាដំបូង បានដឹងនាំប្រតិភូសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តព្រៃវែង ទៅចូលរួមកិច្ចប្រជុំកិច្ចសហប្រតិបត្តិការខេត្តជាប់ព្រំដែន ព្រៃវែង-ស្វាយរៀង-ត្បូងឃ្មុំ នៃព្រះរាជាណាចក្រកម្ពុជា និងតែនិញ នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម ។
- ថ្ងៃទី ២៨-២៩ ខែវិច្ឆិកា ឆ្នាំ២០២៤ ឯកឧត្តម **ហង់ ស៊ីថា** ប្រធានសាលាដំបូង និងលោក **ចាន់ វណ្ណៈ** ព្រះរាជអាជ្ញារង តំណាង ឯកឧត្តម **គុជ គីមឡុង** ព្រះរាជអាជ្ញាអមសាលាដំបូង បានទទួលប្រតិភូតុលាការប្រជាជនខេត្តដុងថាប់ នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម ដែលបានមកបំពេញទស្សនៈកិច្ចពិភាក្សាការងារនៅសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តព្រៃវែង ។

២. សមិទ្ធផលការងារ

ក. អយ្យការអមសាលាដំបូង៖

ក.១. ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌ

-សំណុំរឿងសល់ពីមុន ចំនួន ២០៦ រឿង

-សំណុំរឿងចូលថ្មី ចំនួន ៩៣៣ រឿង

-សំណុំរឿងចាត់ការរួចចំនួន១០០២រឿង (ចាស់ ចំនួន២០៦ រឿង, ថ្មីចំនួន៧៩៦រឿង)

-សំណុំរឿងកំពុងចាត់ការចំនួន១៣៧ រឿង (ថ្មីចំនួន១៣៧ រឿង)

ក.២.កិច្ចការពាក់ពន្ធនឹងការអនុវត្តទោស និងពន្ធនាគារ

ក-២-១-ព័ត៌មានទូទៅជនជាប់ឃុំ

បរិយាយ	សរុបរួម		អនីតិជន		ទីតិជន		ជនបរទេស	
	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី
ជនត្រូវចោទ	1,057	55	153	1	873	53	31	1
ជនជាប់ចោទ	816	26	69	0	741	26	6	0
ពិរុទ្ធជន	868	41	40	0	804	40	24	1
ទណ្ឌិត	380	11	12	0	360	11	8	0
សរុបជនជាប់ឃុំ	**3,121**	**133**	**274**	**1**	**2,778**	**130**	**69**	**2**

ក-២-២- សំណុំរឿងបង្ខំដល់រូបកាយ (គ្មាន)

ក-២-៣-ការអនុវត្តទោសដោយព្រះរាជអាជ្ញា

ល.រ	សេចក្តីសម្រេចស្តាពរ	រឿងចាស់	ចូលថ្មី	សរុប	ចាត់ការរួច	កំពុងចាត់ការ
១	សាលក្រមព្រហ្មទណ្ឌ	131	202	333	119	214

២	សាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍	13	0	13	0	13
៣	សាលដីកាព្រហ្មទណ្ឌរបស់តុលាការកំពូល	12	0	12	0	12
៤	សាលក្រម ឬសាលដីការបស់តុលាការបរទេស	0	0	0	0	0
សរុប		**156**	**202**	**358**	**119**	**239**

-បច្ចុប្បន្នពន្ធនាគារខេត្តព្រៃវែងមានលក្ខណៈតូចចង្អៀត

ក.៣ កិច្ចការពាក់ពន្ធជាមួយនឹងមន្ត្រីនគរបាលយុត្តិធម៌

-ចុះត្រួតពិនិត្យបញ្ជីឃាត់ខ្លួន ជារៀងរាល់ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

-ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤ កិច្ចប្រជុំស្តីការចុះអធិការកិច្ចរបស់មហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញនៅអយ្យការអមសាលាដំបូងខេត្តព្រៃវែង។

-ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៤ កិច្ចប្រជុំជាមួយសភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ នៅសាលាដំបូងខេត្តព្រៃវែង ។

-កិច្ចសហការល្អរវាងមន្ត្រីនគរបាល និងអយ្យការអមសាលាដំបូងខេត្តព្រៃវែង

-អយ្យការអមសាលាដំបូងខេត្តព្រៃវែងបានជួយបង្រៀនវគ្គបណ្តុះបណ្តាលដល់មន្ត្រីនគរបាលនៃស្នងការនគរបាលខេត្តព្រៃវែង ចំនួន០២វគ្គ។

ខ. សាលាដំបូង៖

ខ.១. ចំណាត់ការលើសំណុំរឿងព្រហ្មទណ្ឌ

ខ.១.១. ដំណាក់កាលស៊ើបសួរ

សល់ពី ឆ្នាំ ២០២៣	ចូលថ្មី ឆ្នាំ ២០២៤	ចាត់ការរួច		សល់កំពុងចាត់ការ	
		រឿងចាស់	រឿងថ្មី	រឿងចាស់	រឿងថ្មី
៤៨៥	៦៣០	៤៦២ (៩៥.២៦%)	៤០០ (៦៣.៤៩%)	២៣	២៣០

ខ.១.២. ដំណាក់កាលជំនុំជម្រះ

សល់ពី ឆ្នាំ ២០២៣	ចូលថ្មី ឆ្នាំ ២០២៤	ចាត់ការរួច		សល់កំពុងចាត់ការ	
		រឿងចាស់	រឿងថ្មី	រឿងចាស់	រឿងថ្មី
២២៣	៨៩៨	១៩៦ (%៨៩.៨៧)	៥២៦ (%៥៧.៥៨)	២៧	៣៧២

ខ.២. ចំណាត់ការលើសំណុំរឿងរដ្ឋប្បវេណី

សល់ពី ឆ្នាំ ២០២៣	ចូលថ្មី ឆ្នាំ ២០២៤	ចាត់ការរួច		សល់កំពុងចាត់ការ	
		រឿងចាស់	រឿងថ្មី	រឿងចាស់	រឿងថ្មី
៩៣០	៣០៨២	៧០២ (៧៥.៤៨%)	២,៨២៧ (៩១.៧៣%)	២២៨	២៥៥

ខ.៣. ចំណាត់ការសំណុំរឿងអនុវត្តដោយបង្ខំ

-អនុវត្តដោយចៅក្រមអនុវត្ត

សល់ពី ឆ្នាំ ២០២៣	ចូលថ្មី ឆ្នាំ ២០២៤	ចាត់ការរួច		សល់កំពុងចាត់ការ	
		រឿងចាស់	រឿងថ្មី	រឿងចាស់	រឿងថ្មី
៦៦	១០២	១៨ (២៧.២៧%)	១១ (១០.៧៨%)	៤៨	៩១

-អនុវត្តដោយតំណាងអយ្យការ

សល់ពី ឆ្នាំ ២០២៣	ចូលថ្មី ឆ្នាំ ២០២៤	ចាត់ការរួច		សល់កំពុងចាត់ការ	
		រឿងចាស់	រឿងថ្មី	រឿងចាស់	រឿងថ្មី
៧៤	៤០	៥៦ (៧៥.៦៧%)	00 (00.00%)	១៨	៤០

៣. បញ្ហាប្រឈម

-កង្វះបុគ្គលិក: សម្រាប់ស្ថានភាពបច្ចុប្បន្ន ចៅក្រមម្នាក់មានក្រឡាបញ្ជីតែម្នាក់ទេ ដូច្នេះបើប្រៀបនឹងទំហំការងារមិនមានតុល្យភាពនឹងគ្នាទេ ដោយហេតុថា ចៅក្រមមានការងារច្រើន ទាំងការស៊ើបសួរ ទាំងការជំនុំជម្រះ និងទាំងការអនុវត្តដោយបង្ខំផង ប៉ុន្តែមានជំនួយការតែម្នាក់មិនអាចរ៉ាបរងការងារទាំងអស់នោះបានទេ ។

-ថវិការផ្គត់ផ្គង់មានចំនួនតិចតួច ថវិការផ្គត់ផ្គង់សម្រាប់ទិញសម្ភារៈការិយាល័យ ដូចជា ក្រដាសតម្រូវការច្រើន ទឹកថ្នាំ ដង្កៀប ទិញម៉ាស៊ីនហ្វូតូ កុំព្យូទ័រ ម៉ាស៊ីនព្រីនអាទិ៍ តុកៅអី ទូដាក់ ឯកសារ ជា ។

-ថវិការផ្គត់ផ្គង់ការចុះបំពេញបេសកកម្មជាក់ស្តែង ដល់ទីតាំងកើតហេតុមានចំនួន តិចតួចមិនអាចបំពេញតាមតម្រូវការជាក់ស្តែងបាន ។

- ការរក្សាទុកសំណុំរឿងចាស់ៗ កង្វះបច្ចេកទេសក្នុងការរក្សាទុកសំណុំរឿងចាស់ៗ ដូចជា ការដាក់ទុកចោលក្នុងបាវ និងមិនមានបន្ទប់សម្រាប់រក្សាទុកដាច់ដោយឡែកជាដើម។

៤-ទិសដៅការងារសម្រាប់២០២៥

៤-១-ការងារលេខាធិការ៖ ឯកឧត្តមប្រធាន បានបញ្ជាក់ថាលេខាធិការដ្ឋានរដ្ឋបាល គឺជាសេនាធិការឲ្យប្រធានសាលាដំបូងនិងព្រះរាជអាជ្ញារមសាលាដំបូង ហើយមន្ត្រីដែលបំរើការនៅលេខាធិការដ្ឋានរដ្ឋបាល និងនៅជួរមុខមានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវា ឱ្យបានលឿន និងរាប់ រហ័ស និងត្រូវប្រកបដោយភាពល្អាសវៃ និងត្រូវមានភាពទទួលខុសត្រូវខ្ពស់ជាពិសេសសម្រាប់ការងាររដ្ឋបាល និងបច្ចេកទេសខាងក្នុង លេខាធិការដ្ឋាន ។ លេខាធិការត្រូវប្រមូលរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ឆមាស ៩ខែ និងប្រចាំ ទាន់ពេលវេលា ដើម្បីរៀបចំបូកសរុបជូនទៅក្រសួងយុត្តិធម៌ សាលាឧទ្ធរណ៍ តុលាការកំពូល ។

៤-២-ការងារក្រឡាបញ្ជី៖ ឯកឧត្តមប្រធាន ចំពោះការងារជាមួយសាធារណៈជន គប្បីទំនាក់ទំនង និងផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋ ។ សូមចូលរួមពង្រឹងគោរពវិន័យ និងត្រូវទទួលខុសត្រូវខ្ពស់ ចំពោះការងារដែលចៅក្រមដាក់ឱ្យ និងរាយការណ៍ ត្រឡប់ទៅវិញផង។ ដោយឡែកការព្រាង សាលក្រម ដីកាសម្រេចផ្សេងៗការចារសាលក្រមចូលស្តាពរត្រូវយកចិត្តទុកដាក់ខ្ពស់។ រីឯការធ្វើរបាយការណ៍ផ្សេងៗ និងត្រូវបញ្ជូនមកលេខាធិការរដ្ឋបាលឱ្យបានទាន់ពេលវេលា ដើម្បីរដ្ឋបាលអាចធ្វើការសរុប និងបញ្ជូនបន្តទៅក្រសួងយុត្តិធម៌។ ម្យ៉ាងទៀតសំណុំរឿងដែលបានចាត់ការរួចត្រូវបិទបញ្ជីរាយមុខលិខិត និងបញ្ជូនមកលេខាធិការដ្ឋាន ដើម្បីតម្កល់ទុក។

៤-៣-ការងារចៅក្រម៖ ឯកឧត្តមប្រធាន បញ្ជាក់ជូនអង្គសន្និបាតថា ចៅក្រម ជាត្រូវខិតខំពង្រឹងការអនុវត្តច្បាប់ឲ្យកាន់តែមានភាពប្រសើរឡើងថែមទៀត សំដៅទាក់ទាញទំនុកចិត្តរបស់ប្រជាពលរដ្ឋក្នុងការជឿទុកចិត្តដល់ប្រព័ន្ធតុលាការ។ លោក- លោកស្រី ចៅក្រម ត្រូវខិតខំចំណាត់ការរឿងក្តីក្នុងដៃរបស់ខ្លួន ឲ្យបានទាន់ពេលវេលាត្រឹមត្រូវតាមនីតិវិធីច្បាប់ និង ត្រូវប្រកាន់ខ្ជាប់នូវអភិក្រមទាំងបួនគឺលឿនត្រឹមត្រូវ យុត្តិធម៌ និងមិនពុករលួយ។ លុបបំបាត់ចោលនូវរាល់ទម្រង់បាតុភាពអសកម្មនានា ដែលធ្លាប់មាននិងកំពុងមានក្នុងការងាររបស់សាលាដំបូងខេត្តព្រៃវែង។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** មេត្តាជ្រាបជា សេចក្តីរាយការណ៍ដ៏ខ្ពង់ខ្ពស់ ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ថ្ងៃ..ពុធ ២ រោច ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ព្រៃវែង, ថ្ងៃទី..១៥.... ខែ..មេសា..... ឆ្នាំ២០២៥

ប្រធានលេខាធិការដ្ឋានរដ្ឋបាល

អាត សុខន

បានឃើញ និង ឯកភាព

ព្រៃវែង, ថ្ងៃទី..១៥....ខែ..មេសា..... ឆ្នាំ២០២៥

ប្រធានសាលាដំបូង

ហង់ សុីថា

ព្រះរាជអាជ្ញា

ឈូក សីហន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង និងអយ្យការអម
សាលាដំបូងខេត្តស្វាយរៀង
លេខ : ១១១៩/ស.ដ/២៥

របាយការណ៍ការងារសសេចក្តីរបស់សាលាដម្រះក្តី
សម្រាប់សន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារអនាគត ឆ្នាំ២០២៥
សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តស្វាយរៀង

១. ស្ថានភាពទូទៅ

ក- ធនធានមនុស្ស

-ក្របខណ្ឌចាស់ ចំនួន៧៣ រូប ស្រី៣០ រូប
-ក្របខណ្ឌចូលថ្មី ចំនួន០០ រូប
-ក្របខណ្ឌផ្លាស់ចូល ចំនួន០២ រូប ស្រី០០ រូប
-ក្របខណ្ឌផ្លាស់ចេញ ចំនួន០២ រូប ស្រី០០ រូប
-ក្របខណ្ឌលាឈប់/មរណៈភាពចំនួន០០ រូប
-សុំទំនេរគ្មានបៀវត្ស ចំនួន០៣ រូប ស្រី០០ រូប

សរុបចំនួន៧៣រូប ស្រី៣០ រូប

ខ- ហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន

សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តស្វាយរៀងមានអាគារចំនួន០៣ខ្នង គឺ
-អាគារចាស់ទំហំ(១២មx២៨ម) កម្ពស់០៣ជាន់ និងមាន២០បន្ទប់
-ឃ្លាំងវត្ថុតាងទំហំ(១២មx២៣ម) ជាន់ផ្ទាល់ដី
-អាគារថ្មីមួយទំហំ(១៩,៥មx៦៣ម) កម្ពស់០៣ជាន់ មាន៦២បន្ទប់ សាលប្រជុំចំនួន០២ សាលសវនាការចំនួន០៣ ឃ្លាំងដាក់ឯកសារចំនួន០៧បន្ទប់ ដែលសាងសង់ដោយថវិការដ្ឋក្នុងគម្រោងសាងសង់របស់ក្រសួងយុត្តិធម៌។

ខ.១ សាលាដំបូង

-ឯកឧត្តមប្រធានសាលាដំបូង ចំនួន០១ រូប
-អនុប្រធានសាលាដំបូង ចំនួន០២ រូប ស្រី០០ រូប
-ចៅក្រម ចំនួន០៧ រូប ស្រី០២ រូប
-ក្រឡាបញ្ជី ចំនួន១១ រូប ស្រី០៣ រូប(សុំទំនេរគ្មានបៀវត្សចំនួន០១ រូប)

សរុបចំនួន២១ រូប ស្រីចំនួន០៥ រូប

ខ.២ អយ្យការ

-ឯកឧត្តមព្រះរាជអាជ្ញា ចំនួន០១ រូប
-ព្រះរាជអាជ្ញារង ចំនួន០៧ រូប ស្រី០១ រូប

-ក្រឡាបញ្ជី ចំនួន០៧ រូប ស្រី០០ រូប (សុំទំនេរគ្មានបៀវត្សចំនួន០១ រូប)

សរុបចំនួន១៥ រូប ស្រី០១ រូប

ខ.៣ លេខាធិការដ្ឋានរដ្ឋបាល

-ប្រធានលេខាធិការដ្ឋាន ចំនួន០១ រូប

-អនុប្រធានលេខាធិការដ្ឋាន ចំនួន០៣ រូប ស្រី០១ រូប (សុំទំនេរគ្មានបៀវត្សចំនួន០១ រូប)

-ប្រធានការិយាល័យ ចំនួន០៤ រូប ស្រី០២ រូប

-អនុប្រធានការិយាល័យ ចំនួន០៩ រូប ស្រី០៣ រូប

-មន្ត្រីលេខាធិការដ្ឋាន ចំនួន២០ រូប ស្រី១៤ រូប

-មន្ត្រីជាប់កិច្ចសន្យា ចំនួន១០ រូប ស្រី០៥ រូប

សរុបចំនួន៤៧ រូប ស្រី២៥ រូប

គ. លទ្ធផលសន្និបាតឆ្នៃក្នុងស្ថាប័នសម្រាប់ឆ្នាំ ២០២៤

១-ចំពោះសំណុំរឿងក្តីរដ្ឋប្បវេណីពាក់ព័ន្ធនឹងទំនាស់ដីធ្លី តុលាការបានបង្គាប់ឱ្យមន្ត្រីជំនាញសុរិយោដីចុះវាស់វែង ករណីមន្ត្រីជំនាញនោះបានចុះវាស់វែងរួច តែពុំផ្តល់លទ្ធផលអំពីការវាស់វែងនោះមកតុលាការ និងករណីសំណុំរឿងអនុវត្តក្បាការពារទាក់ទិននឹងការចុះបញ្ជីផ្ទុកផ្នាក់ហាមឃាត់ ឬរឹបអូស តែមន្ត្រីជំនាញសុរិយោដី ពុំផ្តល់របាយការណ៍មកវិញ ឬផ្តល់យឺតយ៉ាវនោះ ករណីនេះ **ឯកឧត្តមប្រធានសាលាដំបូង**បានណែនាំថា បើជួបបញ្ហាដូច្នេះ លោក លោកស្រីជា**ចៅក្រមសាមី** ត្រូវរាយការណ៍**ជូនប្រធានសាលាដំបូង** ដើម្បីរកដំណោះស្រាយ ដូចជាការជួបនឹងពិភាក្សាគ្នាជាមួយប្រធានអង្គភាពជំនាញពាក់ព័ន្ធទាំងនោះ មិនត្រូវទុកបញ្ហាបែបនេះ នាំឱ្យចំណាត់ការរបស់យើងយឺតយ៉ាវ និងប៉ះពាល់ដល់ផលប្រយោជន៍ភាគីនៃរឿងក្តី ករណីនេះ**ឯកឧត្តមប្រធាន**នឹងជួបធ្វើការងារនេះជាមួយប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត។

២-បញ្ហាខ្វះអ្នកបកប្រែភាសា ឬមានដែរ តែអ្នកបកប្រែពុំមែនជាអ្នកមានជំនាញវិជ្ជាជីវៈ កង្វះក្រឡាបញ្ជីអាជ្ញាសាលា ករណីនេះ **ឯកឧត្តមប្រធាន** និង**ឯកឧត្តមព្រះរាជអាជ្ញា**បានណែនាំជារួមថា សព្វថ្ងៃនេះ យើងមានអ្នកបកប្រែភាសាវៀតណាម និងចិន តែអ្នកបកប្រែទាំងនោះ ចេះតែភាសានិយាយ ពុំសូវចេះអក្សរ ការបកប្រែរបស់ពួកគាត់នៅមានចំណុចខ្វះខាតច្រើន ករណីនេះ សាលាដំបូង និងអយ្យការអមសាលាដំបូង នឹងបញ្ចូលក្នុងរបាយការណ៍សន្និបាតដើម្បីផ្ញើទៅក្រសួងយុត្តិធម៌រកដំណោះស្រាយជូន។

៣-ដោយឡែកចំពោះបញ្ហាជាមួយប្រៃសណីយ៍ និងពន្ធនាគារនោះ**ឯកឧត្តមប្រធាន**នឹងជួបពិភាក្សាផ្ទាល់លើការងារនេះជាមួយប្រធានប្រៃសណីយ៍ខេត្ត និងប្រធានពន្ធនាគារខេត្ត។

ឃ. ព្រឹត្តិការណ៍ ឬកម្មវិធីការងារផ្សេងៗ

-ថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤ ឯកឧត្តមប្រធានសាលាដំបូង និងឯកឧត្តមព្រះរាជអាជ្ញា បើកការប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣ និងលើកទិសដៅការងារប្រចាំឆ្នាំ២០២៤ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តស្វាយរៀង។

-ឯកឧត្តមប្រធានសាលាដំបូង និងឯកឧត្តមព្រះរាជអាជ្ញា ចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែរាល់ខែ ក្នុងឆ្នាំ២០២៤ របស់រដ្ឋបាលសាលាខេត្តស្វាយរៀង។

-ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤ អនុប្រធានលេខាធិការដ្ឋាន បានចូលរួមសិក្ខាសាលាផ្លាស់ប្តូរបទពិសោធន៍ក្រឡាបញ្ជី។

-ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៤ ប្រធានលេខាធិការដ្ឋាន បានចូលរួមកិច្ចប្រជុំស្តីពី ការរៀបចំគម្រោងថវិកា និងផែនការយុទ្ធសាស្ត្រថវិការបស់សាលាដម្រះក្តី។

-ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៤ ប្រធានសាលាដំបូង បានចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផល នៃការអនុវត្តយុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និងយុទ្ធនាការត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ។

-ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៤ ព្រះរាជអាជ្ញា បានចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផល នៃការអនុវត្តយុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និងយុទ្ធនាការត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ។

-ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៤ ប្រធានលេខាធិការដ្ឋាន បានចូលរួមកិច្ចប្រជុំពិភាក្សាកម្រិតបច្ចេកទេសលើគម្រោងផែនការចំណូលចំណាយថវិកា ឆ្នាំ២០២៥ របស់ក្រសួងយុត្តិធម៌ និងអង្គភាពចំណុះ។

-ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៤ ព្រះរាជអាជ្ញាបានចូលរួមកិច្ចប្រជុំអំពី នីតិវិធីអនុវត្តពាក់ព័ន្ធជនជាប់ឃុំ។

-ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៤ ព្រះរាជអាជ្ញា បានចូលរួមកិច្ចប្រជុំអំពី ការប្រកាសសមាសភាពអនុគណៈកម្មការទទួលបន្ទុកទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀនតាមច្រកទ្វារព្រំដែន។

-ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៤ ប្រធានសាលាដំបូង បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយអំពីកិច្ចសហប្រតិបត្តិការតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម។

-ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៤ ព្រះរាជអាជ្ញា បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយអំពីកិច្ចសហប្រតិបត្តិការតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម។

-ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៤ ប្រធានលេខាធិការដ្ឋាន បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយអំពីកិច្ចសហប្រតិបត្តិការតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម។

-ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២៤ ព្រះរាជអាជ្ញារង បានចូលរួមពិធីប្រកាសស្តីពី (ការទទួលស្គាល់អ្នកបកប្រែ និងក្រុមហ៊ុនបកប្រែកាសាក្នុងវិស័យយុត្តិធម៌)។

-ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៤ ចៅក្រម បានចូលរួមក្នុងសិក្ខាសាលាលើប្រធានបទស្តីពី (ការសរសេរសាលក្រមផ្តោតទៅលើការរៀបចំចំណុចវិវាទ)។

-ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២៤ ប្រធានលេខាធិការដ្ឋាន បានចូលរួមសិក្ខាសាលាស្តីពីនីតិវិធីនៃការបញ្ជូនក្នុងរឿងក្តីព្រហ្មទណ្ឌ និងរឿងក្តីរដ្ឋប្បវេណី។

-ថ្ងៃទី០៥.០៦ ខែធ្នូ ឆ្នាំ២០២៤សាលាដំបូងខេត្តស្វាយរៀងបានចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលកិច្ចសហប្រតិបត្តិការជាមួយតុលាការប្រជាជនខេត្តតែនិញនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម។

-ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៤សាលាដំបូងខេត្តស្វាយរៀងបានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលកិច្ចសហប្រតិបត្តិការជាមួយតុលាការប្រជាជនខេត្តឡុងអាននៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម។

២. សមិទ្ធផលការងារ

ក. អយ្យការអមសាលាដំបូង៖

ក.១. ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌ

-សំណុំរឿងសល់ពីមុន ចំនួន**១១៨** រឿង

-សំណុំរឿងចូលថ្មី ចំនួន**៧៥៧** រឿង

-សំណុំរឿងចាត់ការរួច ចំនួន**៨១៩** រឿង

-សំណុំរឿងកំពុងចាត់ការ ចំនួន៥៦ រឿង

ក.២. កិច្ចការពាក់ព័ន្ធនឹងការអនុវត្តទោស និងពន្ធនាគារ

-ជនត្រូវចោទ ចំនួន៦៥៣ នាក់ ស្រី៣៧ នាក់

-ជនជាប់ចោទ ចំនួន១៦៦ នាក់ ស្រី១៧ នាក់

-ពិរុទ្ធជន ចំនួន៦៤២ នាក់ ស្រី៤៤ នាក់

-ទណ្ឌិត ចំនួន១០៩ នាក់ ស្រី១ នាក់

សរុបចំនួន១,៥៧០ នាក់ ស្រី៩៩ នាក់

ក.៣. កិច្ចការពាក់ព័ន្ធជាមួយនឹងមន្ត្រីនគរបាលយុត្តិធម៌

-ចុះអធិការកិច្ចតាមអធិការនគរបាលក្រុងស្រុក។

-ចុះធ្វើការពិនិត្យបញ្ជីចុះបណ្តឹង បញ្ជីឃាត់ខ្លួននៅអង្គភាពនគរបាលយុត្តិធម៌។

ខ. សាលាដំបូង៖

ខ.១. ចំណាត់ការលើសំណុំរឿងព្រហ្មទណ្ឌ

ខ.១.១. ដំណាក់កាលស៊ើបសួរ

-សំណុំរឿងសល់ពីមុន ចំនួន១៩១ រឿង

-សំណុំរឿងចូលថ្មី ចំនួន៦២១ រឿង

-សំណុំរឿងចាត់ការរួច ចំនួន៥៩៩ រឿង

-សំណុំរឿងកំពុងចាត់ការ ចំនួន២១៣ រឿង

ខ.១.២. ដំណាក់កាលជំនុំជម្រះ

-សំណុំរឿងសល់ពីមុន ចំនួន១០៨ រឿង

-សំណុំរឿងចូលថ្មី ចំនួន៥៣៩ រឿង

-សំណុំរឿងចាត់ការរួច ចំនួន៥៥៨ រឿង

-សំណុំរឿងកំពុងចាត់ការ ចំនួន៨៩ រឿង

ខ.២. ចំណាត់ការលើសំណុំរឿងរដ្ឋប្បវេណី

-សំណុំរឿងសល់ពីមុន ចំនួន៨៤៤ រឿង

-សំណុំរឿងចូលថ្មី ចំនួន៤,៣៥៣ រឿង

-សំណុំរឿងចាត់ការរួច ចំនួន៤,៧៣៣ រឿង

-សំណុំរឿងកំពុងចាត់ការ ចំនួន៤៦៤ រឿង

ខ.៣. ចំណាត់ការសំណុំរឿងអនុវត្ត

-សំណុំរឿងសល់ពីមុន ចំនួន៤៣៦ រឿង

-សំណុំរឿងចូលថ្មី ចំនួន១០៨ រឿង

-សំណុំរឿងចាត់ការរួច ចំនួន២០០ រឿង

-សំណុំរឿងកំពុងចាត់ការ ចំនួន៣៤៤ រឿង

៣. បញ្ហាប្រឈម

១-សំណុំរឿងក្តីរដ្ឋប្បវេណីពាក់ព័ន្ធករណីទំនាស់ដីធ្លី តុលាការបានឱ្យមន្ត្រីជំនាញសុរិយោដី ធ្វើការវាស់វែងតែពុំដែលបានទទួលលទ្ធផល ឬរបាយការណ៍ឆ្លើយតបឡើយ។

២-សំណុំរឿងអនុវត្ត ពាក់ព័ន្ធនឹងការចុះបញ្ជីផ្ទុកផ្លាក់ មន្ត្រីជំនាញសុរិយោដី ពុំបានធ្វើរបាយការណ៍ឆ្លើយតបឱ្យទាន់ពេលវេលាតាមច្បាប់កំណត់ ករណីខ្លះពុំឆ្លើយតបតែម្តង។

៣-ខ្វះអ្នកបកប្រែភាសា ចំពោះមុខនេះ មានជនបរទេសប្រព្រឹត្តបទល្មើសច្រើន ពិសេសជនជាតិចិន និងជនជាតិវៀតណាម អ្នកបកប្រែពុំមានជំនាញ គ្រាន់តែចេះភាសាចិន ឬវៀតណាម ពុំចេះអក្សរច្បាស់លាស់ តែយកមកបកប្រែភាសា ដោយតម្រូវការចាំបាច់ អ្នកបកប្រែគ្មានជំនាញវិជ្ជាជីវៈ។

៤-ក្រឡាបញ្ជីម្នាក់សម្រាប់ចៅក្រម០១រូប គឺបំពេញកិច្ចការពុំទាន់នោះឡើយ។

៥-ពុំមានអាជ្ញាសាលាជាជំនួយការសម្រាប់ការងារអនុវត្ត និងកិច្ចការបញ្ជូនផ្សេងៗ។

៦-មន្ត្រីប្រៃសណីយ៍សព្វថ្ងៃ មិនអាចធានាបាននូវកិច្ចការបញ្ជូន។

៧-បញ្ហាពន្ធនាគារ សាលក្រមបញ្ជូនហើយ មិនបានដកចេញពីបញ្ជី នៅរាយការណ៍ចំនួនដដែលៗ។

៤. សំណូមពរ

១-ស្នើសុំឱ្យមានអាជ្ញាសាលាប្រចាំសាលាដំបូង។

២-ស្នើសុំក្រឡាបញ្ជីបន្ថែម។

៣-ស្នើសុំសាងសង់អាគារមុខងារចៅក្រម។

៤-ស្នើសុំបង្កើនថវិកាសម្រាប់សម្ភារៈការិយាល័យ សម្ភារៈបច្ចេកទេសបរិក្ខាមិនមែនព័ត៌មានវិទ្យា និងបេសកកម្ម។

៥. ទិសដៅការងារសម្រាប់ឆ្នាំ ២០២៥

១-ជំរុញលើការពន្លឿនក្នុងការដោះស្រាយរឿងក្តីគ្រប់ប្រភេទឱ្យបានឆាប់រហ័សប្រកាន់ភ្ជាប់នូវអភិក្រមទាំង៤ គឺ: លឿន ត្រឹមត្រូវ យុត្តិធម៌ និងមិនមានអំពើពុករលួយ។

២-ត្រូវប្រកាន់ភ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈក្នុងនាមជាចៅក្រម និងមន្ត្រីរាជការឱ្យបានខ្ជាប់ខ្ជួនពិសេសត្រូវបង្កលក្ខណៈងាយស្រួល រួសរាយរាក់ទាក់ជាមួយប្រជាពលរដ្ឋ ដែលមកប្រើប្រាស់សេវាតុលការ។

៣-ចំពោះចៅក្រមនៅពេលប្រកាសសាលក្រម ចៅក្រមត្រូវតែសរសេរសាលក្រមឱ្យបានរួចរាល់ និងបញ្ជូនមកមន្ត្រីទទួលបន្ទុកទទួលសាលក្រម ដើម្បីចាត់ចែងបន្ត។

៤-សហការផ្តល់របាយការណ៍គ្រប់ប្រភេទ ប្រចាំសប្តាហ៍ ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំមកលេខាធិការដ្ឋានរដ្ឋបាល ឱ្យបានទៀងទាត់តាមការកំណត់។

៥-ត្រូវរក្សាសាមគ្គីភាពផ្ទៃក្នុងអង្គភាពឱ្យបានល្អប្រសើរ និងមិនត្រូវយកកិច្ចការផ្ទៃក្នុងទៅបរិហារខាងក្រៅដាច់ខាត។

៦-ជួយសន្សំសំចៃ ការប្រើប្រាស់ថាមពលអគ្គិសនី ទឹក និងសម្ភារៈប្រើប្រាស់ផ្សេងៗទៀត របស់អង្គភាពឱ្យបានល្អប្រសើរ។

៧-សហការចូលរួមអនុវត្តការងារផ្សេងៗ របស់អង្គភាព របស់រដ្ឋបាលខេត្ត ការងារសង្គម និងការងារមនុស្សធម៌ រួមទាំងការងារផ្សេងៗទៀត តាមការចាត់តាំង របស់អង្គភាព។

៨-ចំណាត់ការសំណុំរឿងចាស់ឱ្យបាន៩៥% សំណុំរឿងថ្មី៨៥% និងការដោះស្រាយបញ្ហាកង្វះសាលក្រមនិងការបញ្ជូនសាលក្រមស្ថាពរទៅពន្ធនាគារឱ្យបានទាន់ពេលវេលា។

៩-ជំរុញឱ្យចំណាត់ការលើរឿងក្តី ទាំងសំណុំរឿងព្រហ្មទណ្ឌ សំណុំរឿងរដ្ឋប្បវេណី សំណុំរឿងនៅអយ្យការ រឿងអនុវត្តដោយបង្ខំ និងការអនុវត្តទណ្ឌកម្មព្រហ្មទណ្ឌ តាមអំណាចសេចក្តីសម្រេចស្ថាពរទាំងអស់ របស់តុលាការឱ្យបានត្រឹមត្រូវតាមច្បាប់ និងទាន់ពេលវេលា។

១០-ជំរុញឱ្យចំណាត់ការរឿងក្តី ដោយផ្តល់នូវអាទិភាពចាត់ការឱ្យបានឆាប់ ទាន់ពេលវេលាលើសំណុំរឿងក្តី **អាទិភាពទាំង ០៤ គឺ** សំណុំរឿងអគ្រានុកូលដ្ឋាន សំណុំរឿងគ្រឿងញៀន សំណុំរឿងគ្រោះថ្នាក់ចរាចរណ៍ និង សំណុំរឿងក្មេងទំនើង។

១១-ជំរុញឱ្យធ្វើសាលក្រមឱ្យបានទាន់ពេលវេលា គ្រប់ជ្រុងជ្រោយ និងបញ្ជូនសាលក្រមព្រហ្មទណ្ឌទាំងអស់ ទៅអយ្យការឱ្យបានទាន់ពេលវេលា តាមការកំណត់របស់ច្បាប់។

១២-ជំរុញឱ្យលោកចៅក្រមអាសនៈ និងចៅក្រមអយ្យការ ក្រឡាបញ្ជីតុលាការ អយ្យការ មន្ត្រីរដ្ឋបាល សាលាដំបូងទាំងអស់ឱ្យលើកកម្ពស់សមត្ថភាពយល់ដឹង គោរពក្រមសីលធម៌វិជ្ជាជីវៈ វិន័យការងារឱ្យបានត្រឹមត្រូវ និងស្វែងយល់ឱ្យបានស៊ីជម្រៅបន្ថែមទៀតរាល់អត្ថបទច្បាប់ទាក់ទងវិស័យយុត្តិធម៌ ដើម្បីធានាដល់ការអនុវត្តឱ្យ បានត្រឹមត្រូវ។

១៣-ចុះធ្វើការពិនិត្យបញ្ជីចុះបណ្តឹង បញ្ជីឃាត់ខ្លួននៅអង្គភាពនគរបាលយុត្តិធម៌ និងចុះត្រួតពិនិត្យប្រចាំ ខែដល់ពន្ធនាគារ ដោយចៅក្រមអយ្យការ។

១៤-ជំរុញឱ្យអនុវត្តប្រាក់ពិន័យក្នុងសំណុំរឿងព្រហ្មទណ្ឌឱ្យអស់លទ្ធភាព តាមអំណាច នៃសេចក្តី សម្រេចស្តាពររបស់តុលាការព្រហ្មទណ្ឌ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយ ការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ។

ថ្ងៃអង្គារ ៥កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ស្វាយរៀង ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៥

ប្រធានរលខាធិការដ្ឋាន

ខេត-ជល្លា

បានឃើញ និង ឯកភាព

ស្វាយរៀង ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៥

ព្រះរាជអាជ្ញា

ខាំ ស្រុងរ៉ី

ប្រធានសាលាដំបូង

អ៊ាង-ជល្លា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង និងអយ្យការអម
សាលាដំបូងខេត្តតាកែវ
លេខ:៧៨០ សដ/២០២៥

របាយការណ៍ការងារសេ្ថបរបស់សាលាដម្រះក្តី
សម្រាប់សន្និបាតបូកសរុបលទ្ធផលការងារឆមាសយុត្តិធម៌ ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារអាទិភាព ឆ្នាំ២០២៥
សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តតាកែវ

==========

១. ស្ថានភាពទូទៅ

១.១.ធនធានមនុស្ស

គិតត្រឹមថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥ សាលាដំបូងខេត្តតាកែវមានមន្ត្រីក្របខណ្ឌមុខងារសាធារណៈ និងមន្ត្រីកម្មសិក្សាសរុបចំនួន ១១១រូប ស្រី(២៩រូប)និងមន្ត្រីជាប់កិច្ចសន្យាសរុបចំនួន(១៣រូប) ស្រី(០៨រូប) ដូចខាងក្រោម៖

សាលាដំបូង

- ប្រធានសាលាដំបូង(០១រូប)
- អនុប្រធានសាលាដំបូង(០២រូប)
- ចៅក្រម(០៨រូប) ស្រី(០២រូប)
- ក្រឡាបញ្ជី(១៨រូប) ស្រី(០២រូប)
- ក្រឡាបញ្ជីកម្មសិក្សា(០១រូប) ស្រី(០១រូប)

អយ្យការអមសាលាដំបូង

- ព្រះរាជអាជ្ញា(០១រូប)
- ព្រះរាជអាជ្ញារង(០៦រូប) ស្រី(០១រូប)
- ព្រះរាជអាជ្ញារងកម្មសិក្សា(០១រូប)
- ក្រឡាបញ្ជី(០៦រូប) ស្រី(០១រូប)
- ក្រឡាបញ្ជីកម្មសិក្សា(០១រូប)

លេខាធិការដ្ឋានរដ្ឋបាល

- ប្រធានលេខាធិការដ្ឋាន(០១រូប)
- អនុប្រធានលេខាធិការដ្ឋាន(០៥រូប)
- ប្រធានការិយាល័យ(០៤រូប) ស្រី(០១រូប)
- អនុប្រធានការិយាល័យ(១៣រូប)ស្រី(០៣រូប)
- មន្ត្រី
    - មន្ត្រីក្របខណ្ឌ (១៣រូប) ស្រី(០៣រូប)
    - មន្ត្រីកម្មសិក្សា(១៧រូប) ស្រី(០៧រូប)
    - មន្ត្រជាប់កិច្ចសន្យា (១៣រូប) ស្រី(០៨រូប)

អាសយដ្ឋាន : ផ្លូវលេខ៥ ភូមិ១ សង្កាត់កោកក្នុង ក្រុងដូនកែវ ខេត្តតាកែវ ទូរស័ព្ទ : 016 808 111, 011 655 567

១.២.ហេដ្ឋារចនាសម្ព័ន្ធ

សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តតាកែវ កើតឡើងតាំងពីឆ្នាំ១៩៩៩ មានអាគារចំនួន០៣ខ្នង ដែលមានផ្ទៃដីទំហំ ២២៤១ម^{២} សម្រាប់បំពេញការងារប្រចាំថ្ងៃ ហើយក្នុងនោះមានបន្ទប់ធ្វើការចំនួន៤៣បន្ទប់,សាលប្រជុំធំចំនួន០២, បន្ទប់សវនាការចំនួន០២បន្ទប់, បន្ទប់ដាក់សំណុំរឿងចំនួន០១បន្ទប់។

១.៣.លទ្ធផលសន្និបាតផ្ទៃក្នុងឆ្នាំ២០២៤

រៀបចំនិងពង្រឹងច្រកចេញចូលតែមួយ ដើម្បីបង្កភាពងាយស្រួលដល់អ្នកប្រើប្រាស់សេវាតុលាការ និងសម្រាប់ការងារទំនាក់ទំនងសាធារណៈ,ការងាររដ្ឋបាលទូទៅ, ការងារគ្រប់គ្រងបុគ្គលិក, ការងារហិរញ្ញវត្ថុ ការងារថែរក្សាវត្ថុតាង ការរៀបចំឃ្លាំងថែរក្សាសំណុំរឿង ការចុះបញ្ជីសំណុំរឿងទាំងក្នុងសៀវភៅ និងតាមប្រព័ន្ធព័ត៌មានវិទ្យា ចំណាត់ការសំណុំរឿងក្តីរដ្ឋប្បវេណី និងសំណុំរឿងព្រហ្មទណ្ឌ ការចុះអធិការកិច្ចតាមបណ្តាអធិការដ្ឋាននគរបាល និងមូលដ្ឋាន កងរាជអាវុធហត្ថក្រុង ស្រុក រៀបចំប្រជុំជាមួយមន្ត្រីនគរបាលយុត្តិធម៌ចូលរួមកិច្ចប្រជុំផ្សេងៗដែលរៀបចំដោយរដ្ឋបាលខេត្តតាកែវ និងបានចូលរួមកិច្ចប្រជុំពង្រឹងកិច្ចសហប្រតិបត្តិការជាមួយតុលាការខេត្តអានយ៉ាង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

១.៤.ព្រឹត្តិការណ៍ ឬកម្មវិធីការងារនានា

សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តតាកែវបានចូលរួម និងរៀបចំកិច្ចប្រជុំជាមួយស្ថាប័ននានាដែលមានជារួមដូចខាងក្រោម៖

ល.រ	បរិយាយ	គោលបំណងកិច្ចប្រជុំ/ ជំនួបពិភាក្សា	ចំនួន(លើក)
០១	សាលាខេត្តតាកែវ	ប្រយុទ្ធប្រឆាំងគ្រឿងញៀន,សន្តិសុខសណ្តាប់ធ្នាប់	១៦
០២	ពន្ធនាគារ	ផ្សព្វផ្សាយច្បាប់	០៣
០៣	មន្ត្រីគរបាលយុត្តិធម៌	ចរាចរណ៍,គ្រឿងញៀន,ផ្សព្វផ្សាយច្បាប់,ក្មេងទំនើង	១៨
០៤	ប្រតិភូរបស់ក្រសួងយុតិធម៌	អធិការកិច្ចលើសំណុំរឿង,ផ្សព្វផ្សាយច្បាប់	០៩

២. សមិទ្ធផលការងារ

ក. អយ្យការអមសាលាដំបូង៖

ក.១. ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌ

បរិយាយ	សល់ពីមុន	ចូលថ្មី	សរុប	ចាត់ការរួច	សល់កំពុងចាត់ការ
ប្រចាំឆ្នាំ២០២៤	១៩១	១៥៤៨	១៧៣៩	១៦៩០	៤៩
ប្រចាំខែមករា ឆ្នាំ២០២៥	៤៩	១៣៩	១៨៨	៩៧	៩១
ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥	៩១	១២៣	២១៤	១៣៣	៨១

ក.២. កិច្ចការពាក់ព័ន្ធនឹងការអនុវត្តទោស និងពន្ធនាគារ

បរិយាយ	ជនជាប់ឃុំ	សរុបរួម		អនីតិជន		នីតិជន		ជនបរទេស	
		សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី
ប្រចាំឆ្នាំ២០២៤	ជនត្រូវចោទ	៧២២	៣៣	៩៦	០២	៦២៥	៣១	០១	០០
	ជនជាប់ចោទ	៣៧៦	១៥	៣២	០១	៣៤១	១៤	០៣	០០
	ពិរុទ្ធជន	៤៦០	១២	២៤	០០	៤៣៥	១២	០១	០០
	ទណ្ឌិត	៤៥១	០៨	១២	០០	៤៣៧	០៨	០២	០០
	សរុប	២០០៩	៦៨	១៦៤	០៣	១៨៣៨	៦៥	០៧	០០
ប្រចាំខែមករា ឆ្នាំ២០២៥	ជនត្រូវចោទ	៨១៣	៣៧	១១១	០៣	៧០០	៣៤	០២	០០
	ជនជាប់ចោទ	៣៤៧	១៤	២៩	០១	៣១៥	១៣	០៣	០០
	ពិរុទ្ធជន	៤២៦	១៣	២២	០០	៤០៣	១៣	០១	០០
	ទណ្ឌិត	៤៤២	០៩	១២	០០	៤២៨	០៩	០២	០០
	សរុប	២០២៨	៧៣	១៧៤	០៤	១៨៤៦	៦៩	០៨	០០
ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥	ជនត្រូវចោទ	៩៤៨	៤៤	១១០	០៣	៨៣៦	៤១	០២	០០
	ជនជាប់ចោទ	៣៣០	១៣	៣៩	០១	២៨៩	១២	០២	០០
	ពិរុទ្ធជន	៣៦៦	១១	០៣	០០	៣៦០	១១	០៣	០០
	ទណ្ឌិត	៤១៥	០៧	០៩	០០	៤០៥	០៧	០១	០០
	សរុប	២០៥៩	៧៥	១៦១	០៤	១៨៩០	៧១	០៨	០០

ក.២.១ ការអនុវត្តទោសដោយព្រះរាជអាជ្ញា

បរិយាយ	សល់ពីមុន	ចូលថ្មី	សរុប	ចាត់ការរួច	សល់កំពុងចាត់ការ
ប្រចាំឆ្នាំ២០២៤	២១២	៩០១	១១១៣	៧៤៦	៣៦៧
ប្រចាំខែមករា ឆ្នាំ២០២៥	៣៦៧	៩៩	៤៦៦	៨៩	៣៧៧
ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥	៣៧៧	៨៦	៤៦៣	៦៩	៣៩៤

ខ. សាលាដំបូង៖

ខ.១. ចំណាត់ការលើសំណុំរឿងព្រហ្មទណ្ឌ

ខ.១.១. ដំណាក់កាលស៊ើបសួរ

បរិយាយ	សល់ពីមុន	ចូលថ្មី	សរុប	ចាត់ការរួច	សល់កំពុងចាត់ការ
ប្រចាំឆ្នាំ២០២៤	៤៣៥	១២១២	១៦៤៧	១១៧៤	៤៧៣
ប្រចាំខែមករា ឆ្នាំ២០២៥	៤៧៣	១២៣	៥៩៦	៦០	៥៣៦
ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥	៥៣៦	១១៣	៦៤៩	៩៣	៥៥៦

ខ.១.២. ដំណាក់កាលជំនុំជម្រះ

បរិយាយ	សល់ពីមុន	ចូលថ្មី	សរុប	ចាត់ការរួច	សល់កំពុងចាត់ការ
ប្រចាំឆ្នាំ២០២៤	៣៤២	១៣៦៥	១៧០៧	១២១១	៣៩៦
ប្រចាំខែមករា ឆ្នាំ២០២៥	៣៩៦	៨៧	៤៨៣	១០០	៣៨៣
ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥	៣៨៣	៨៤	៤៦៧	១១៥	៣៥២

ខ.១.២.ចំណាត់ការលើសំណុំរឿងរដ្ឋប្បវេណី

បរិយាយ	សល់ពីមុន	ចូលថ្មី	សរុប	ចាត់ការរួច	សល់កំពុងចាត់ការ
ប្រចាំឆ្នាំ២០២៤	១០២៧	៤៧៣៩	៥៧៦៦	៤៧៧០	១០៩៦
ប្រចាំខែមករា ឆ្នាំ២០២៥	១០៩៦	៤១៩	១៥១៥	៣៥០	១១៦៥
ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥	១១៦៥	៧៦៨	១៩៣៣	៥៦០	១៣៧៣

ខ.៣. ចំណាត់ការសំណុំរឿងផ្សេងទៀត

ខ.៣.១.ការអនុវត្តដោយបង្ខំរបស់ចៅក្រម

បរិយាយ	សល់ពីមុន	ចូលថ្មី	សរុប	ចាត់ការរួច	សល់កំពុងចាត់ការ
ប្រចាំឆ្នាំ២០២៤	១៩៧	១៨០	៣៧៧	១០៥	២៧២
ប្រចាំខែមករា ឆ្នាំ២០២៥	២៧២	១៩	២៩១	០៨	២៨៣
ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥	២៨៣	១៧	៣០០	៥៤	២៤៦

ខ.៣.២.អនុវត្តសំណងរដ្ឋប្បវេណីក្នុងរឿងព្រហ្មទណ្ឌ

បរិយាយ	សល់ពីមុន	ចូលថ្មី	សរុប	ចាត់ការរួច	សល់កំពុងចាត់ការ
ប្រចាំឆ្នាំ២០២៤	១៨	១១	២៩	១០	១៩
ប្រចាំខែមករា ឆ្នាំ២០២៥	១៩	០២	២១	០១	២០
ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥	២០	០៦	២៦	០៧	១៩

៣. បញ្ហាប្រឈម និងសំណូមពរ

៣.១.បញ្ហាប្រឈម

- នៅខ្វះ ក្រឡាបញ្ជី
- មិនមានអាជ្ញាសាលាសម្រាប់បំពេញតួនាទីក្នុងការបញ្ជូនដីកា និងការអនុវត្ត
- មិនទាន់មានអគារផ្ទះមុខងារសម្រាប់ចៅក្រម និងឃ្លាំងថែរក្សាវត្ថុតាង
- មិនបានកំណត់ពីឯកសណ្ឋានបំពេញការងារប្រចាំថ្ងៃសម្រាប់មន្ត្រីលេខាធិការដ្ឋានរដ្ឋបាល និងផ្តល់ជូនឯកសណ្ឋានផ្លូវការសម្រាប់មន្ត្រី ដែលមានមុខតំណែងចាប់ពី អនុប្រធានការិយាល័យឡើងទៅ ។
- មិនទាន់ដែលបានផ្តល់វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់មន្ត្រីឱ្យបានច្រើន ជាអាទិ៍ការគ្រប់គ្រងកិច្ចការរដ្ឋបាល ការចុះបញ្ជីសំណុំរឿងទាំងក្នុងសៀវភៅ និងតាមប្រព័ន្ធព័ត៌មានវិទ្យា ការរៀបចំផែនការថវិកា កុំព្យូទ័ររដ្ឋបាល និងជំនាញទន់មួយចំនួនទៀត
- ខ្វះខាតមធ្យោបាយធ្វើដំណើរ និងប្រាក់ឧបត្ថម្ភសម្រាប់គាំទ្រដំណើរការនីតិវិធី ការចុះស៊ើបអង្កេត ចុះអធិការកិច្ច ការចុះបំពេញបេសកកម្មបង្ក្រាបបទល្មើស និងការចុះអនុវត្តសេចក្តីសម្រេចនានារបស់តុលាការ

៣.២.សំណូមពរ

- ស្នើសុំឱ្យមានអាជ្ញាសាលា
- ស្នើសុំបន្ថែមក្រឡាបញ្ជី
- ស្នើសុំរថយន្ត ០១ គ្រឿង(មួយ)សម្រាប់ប្រើប្រាស់ក្នុងលេខាធិការដ្ឋាន
- ស្នើសុំក្រសួងយុត្តិធម៌ពន្លឿនក្នុងការអនុម័ត និងដាក់ឱ្យប្រើប្រាស់នូវសេចក្តីណែនាំ ស្តីពី" **លំហូរការងាររដ្ឋបាល និងបច្ចេកទេសសំណុំរឿង**" ដល់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងជាស្តង់ដារតែមួយ ដើម្បីធានានូវប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ប្រកបដោយបរិយាប័ន្ន និងសុខដុមនីយកម្មក្នុងស្ថាប័ន
- ស្នើសុំក្រសួងយុត្តិធម៌បំពាក់ប្រព័ន្ធចុះបញ្ជីសំណុំរឿងរដ្ឋប្បវេណីឱ្យបានឆាប់
- ស្នើសុំក្រសួងយុត្តិធម៌ផ្តល់វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់មន្ត្រីឱ្យបានច្រើន ជាអាទិ៍ការគ្រប់គ្រងកិច្ចការរដ្ឋបាល ការចុះបញ្ជីសំណុំរឿងទាំងក្នុងសៀវភៅ និងតាមប្រព័ន្ធព័ត៌មានវិទ្យា ការរៀបចំផែនការថវិកា កុំព្យូទ័ររដ្ឋបាល និងជំនាញទន់មួយចំនួនទៀត
- ស្នើសុំក្រសួងយុត្តិធម៌ កំណត់ពីឯកសណ្ឋានបំពេញការងារប្រចាំថ្ងៃសម្រាប់មន្ត្រីគ្រប់គ្រងរដ្ឋបាលនៃលេខាធិការដ្ឋានរដ្ឋបាល និងផ្តល់ជូនឯកសណ្ឋានផ្លូវការសម្រាប់មន្ត្រី ដែលមានមុខតំណែងចាប់ពី អនុប្រធានការិយាល័យឡើងទៅ ។

៤. ទិសដៅការងារសម្រាប់ឆ្នាំ ២០២៥

សម្រាប់ទិសដៅការងារដោអាទិភាពក្នុងឆ្នាំ២០២៥ សាលាដំបូង និងអយ្យការអមសាលាដំបូងបានដាក់ចេញដូចខាងក្រោម៖

- ពង្រឹងកិច្ចសហប្រតិបត្តិការការងារឱ្យកាន់តែល្អប្រសើរបន្ថែមទៀត រវាងសាលាដំបូង អយ្យការអមសាលាដំបូង និងលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង
- ពង្រឹងការងារផ្តល់សេវាជូរមុខឱ្យកាន់តែប្រសើរ
- ជំរុញ និងពន្លឿនការចាត់ការសំណុំរឿងក្តីព្រហ្មទណ្ឌ និងរឿងក្តីរដ្ឋប្បវេណី ដោយគោរពឱ្យបានម៉ឺងម៉ាត់ និងប្រកាន់ខ្ជាប់នូវអភិក្រម លឿន ត្រឹមត្រូវ យុត្តិធម៌ និងមិនមានអំពើពុករលួយ
- ពង្រឹងការអនុវត្តក្រមរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមនីតិវិធីព្រហ្មទណ្ឌ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ
- ពង្រឹង និងបង្កើនសមត្ថភាពនៃការតាក់តែងសេចក្តីសម្រេចប្រកបដោយគុណភាព
- តែបន្តឹងលើបទល្មើសសម្អាតប្រាក់ ជាពិសេស បទល្មើសគ្រឿងញៀន បទល្មើសជួញដូរមនុស្ស បទល្មើសពុករលួយ ព្រមទាំងបទល្មើសចរាចរណ៍ បទល្មើសបើកបរក្រោមឥទ្ធិពលនៃគ្រឿងញៀន ក្មេងទំនើង និងបទល្មើសល្បែងស៊ីសងខុសច្បាប់
- ចុះធ្វើអធិការកិច្ច ណែនាំ និងផ្សព្វផ្សាយច្បាប់តាមបណ្តាអធិការដ្ឋាននគរបាល និងមូលដ្ឋានកងរាជអាវុធហត្ថក្រុង ស្រុក
- សហការជាមួយអាជ្ញាធរពាក់ព័ន្ធ អភិបាលក្រុង ស្រុក នាយកសាលា ដើម្បីចុះផ្សព្វផ្សាយតាមសហគមន៍ រោងចក្រ សាលារៀន ស្តីពីផលប៉ះពាល់នៃគ្រឿងញៀន ច្បាប់ចរាចរណ៍ ក្មេងទំនើង
- ពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ គ្រឿងញៀនកម/ក្មេងទំនើង និងការកសាងសំណុំរឿងចរាចរណ៍/ក្មេងទំនើង/គ្រឿងញៀន
- បន្តកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយតុលាការប្រជាជនខេត្តអានយ៉ាង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម
- សហការ និងបង្ក្រាបរាល់បទល្មើសឆ្លងដែន ដែលកើតមាននៅតាមបណ្តាព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ។

ថ្ងៃពុធ ៧កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
តាកែវ ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៥
ប្រធានលេខាធិការដ្ឋានរដ្ឋបាល

ចៅត-ជាវុធ

បានឃើញ និង ឯកភាព
ថ្ងៃពុធ ៧កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
តាកែវ ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៥

ព្រះរាជអាជ្ញា

ឯក ឆេងឃួត

ប្រធានសាលាដំបូង

ចាម ចំរើនពិសិដ្ឋ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង និងអយ្យការអម
សាលាដំបូងខេត្តបាត់ដំបង

របាយការណ៍ការងារសេ្ថបរបស់សាលាដម្រះក្តី
សម្រាប់សន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារអនាគត ឆ្នាំ២០២៥
សាលាដំបូងខេត្តបាត់ដំបង និងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង

==========

១. ស្ថានភាពទូទៅ

១.១.ស្ថិតិធនធានមនុស្ស

ល.រ	មុខតំណែង	ចំនួន	ស្រី
សាលាដំបូង		**សរុប ១៦រូប**	
១	ប្រធានសាលាដំបូង	១រូប	០ស្រី
២	អនុប្រធានសាលាដំបូង	៣រូប	១រូប
៣	ចៅក្រម	១២រូប	៤រូប
អយ្យការអមសាលាដំបូង		**សរុប ១០ រូប**	
១	ព្រះរាជអាជ្ញា	១រូប	០ស្រី
២	ព្រះរាជអាជ្ញារង	៩រូប	៤រូប
ក្រឡាបញ្ជី		**សរុប ៤០ រូប**	
១	ក្រឡាបញ្ជីតុលាការ	៣០រូប	៦រូប
២	ក្រឡាបញ្ជីអយ្យការ	១០រូប	៣រូប
អាជ្ញាសាលា		**សរុប ០១ រូប**	
១	អាជ្ញាសាលា	១រូប	០រូប
២	ជំនួយការអាជ្ញាសាលា	០រូប	០រូប
លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង		**សរុប ៨៤ រូប**	
១	ប្រធានលេខាធិការដ្ឋាន	១រូប	១រូប
២	អនុប្រធានលេខាធិការដ្ឋាន	៥រូប	០រូប
៣	ប្រធានការិយាល័យ	៤រូប	៣រូប
៤	អនុប្រធានការិយាល័យ	១២រូប	៥រូប
៥	មន្ត្រីគ្រប់គ្រងរដ្ឋបាល "ក"	១៦រូប	៧រូប
៦	មន្ត្រីក្រមការ "ខ"	១រូប	០រូប
៧	លេខាធិការ "គ"	០រូប	០រូប
៨	មន្ត្រីជាប់កិច្ចសន្យា	៤៥រូប	២៥រូប

១.២- ហេដ្ឋារចនាសម្ព័ន្ធ

សាលាដំបូងខេត្តបាត់ដំបង និងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង បានសាងសង់បន្ទប់ឃាត់ខ្លួនបណ្តោះអាសន្ន ចំនួន ១, រៀបចំបន្ទប់សវនាការបន្ថែម ចំនួន ១ ,សាងសង់បន្ទប់ទឹក ចំនួន ៣ និងជួសជុលបន្ទប់ទឹកចំនួន ២, បានជួសជុលបន្ទប់ការិយាល័យរដ្ឋបាលបុគ្គលិក,បានចាក់បេតុង ខាងកើត ទំហំ ១៣៣ ម៉ែត្រក្រឡា,បានគូសគំនូសចរាចរណ៍ បានរៀបចំសណ្តាប់ធ្នាប់កន្លែងយាមម៉ូតូ និងរថយន្តរបស់ប្រជាពលរដ្ឋ។

១.៣- លទ្ធផលសន្និបាតផ្ទៃក្នុងស្ថាប័ន ២០២៤

សន្និបាតបូកសរុបការងារឆ្នាំ២០២៤និងលើកទិសដៅការងារបន្តឆ្នាំ២០២៥ កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៥ សម្រេចដោះស្រាយបញ្ហាប្រឈមនានាដែលបានលើកឡើង និងឯកភាពគ្នាក្នុងការអនុវត្តកិច្ចការមួយចំនួនដែលមានការយល់មិនស្របគ្នាក្នុងការអនុវត្ត ព្រមទាំងបានដាក់ទិសដៅបន្តឆ្នាំ២០២៥ថែមទៀត។

១.៤- ព្រឹត្តិការណ៍ ឬកម្មវិធីការងារនានា

-ប្រជុំ និងទទួលគណៈប្រតិភូក្នុងកិច្ចការផ្សេងៗសរុបទាំងអស់បានចំនួន ៣៥ ដង សាលាដំបូង១០ដង អយ្យការ ២៥ដង

-ប្រជុំជាមួយមន្ត្រីនគរបាលយុត្តិធម៌ និងពន្ធនាគារ ចំនួន ១២លើក

-ប្រជុំជាមួយសាលាខេត្តបាត់ដំបង ២០ដង និងសាលាឧទ្ធរណ៍ ១ដង។

-ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៤ ឯកឧត្តម ជុំ ស ប្រធានសាលាដំបូង បានចូលរួមកិច្ចប្រជុំពាក់ព័ន្ធករណីក្មេងទំនើង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

-ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ ឯកឧត្តម កែវ សុជាតិ ព្រះរាជអាជ្ញា បានអញ្ជើញជា អធិបតីក្នុងពិធី ប្រគល់វិញ្ញាបនបត្រផ្នែកទ្រឹស្តី និងបណ្តុះបណ្តាល ដល់អ្នកញៀនគ្រឿងញៀនចំនួន ១២៥នាក់ វគ្គទី៣នៅមជ្ឈមណ្ឌលបន្សាប កែ ស៊ីនួន ។

២. សមិទ្ធផលការងារ

ក. អយ្យការអមសាលាដំបូង៖

ក.១. ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌ

១.ប្រចាំឆ្នាំ២០២៤

សល់ពីមុន	ចូលថ្មី	សរុប	សំណុំរឿងចាត់ការរួច							សល់កំពុងចាត់ការ
			បញ្ជូនសំណុំរឿងទៅស៊ើបសួរ	បញ្ជូនសំណុំរឿងទៅជម្រះផ្ទាល់	ដីកាដែលបង្ហាញខ្លួនភ្លាម	តម្កល់រឿងទុកឥតចាត់ការ	បញ្ចូលរឿង	ផ្ទេរសមត្ថកិច្ច	សរុប	
២៧៤	២០៣៣	២៣០៧	១១១៨	៦៣	២៣២	៦៣៤	៣២	៨	២០៨៧	២២០

២.ប្រចាំខែមករា ឆ្នាំ២០២៥

សល់ពីមុន	ចូលថ្មី	សរុប	សំណុំរឿងចាត់ការរួច							សល់កំពុងចាត់ការ
			បញ្ជូនសំណុំរឿងទៅស៊ើបសួរ	បញ្ជូនសំណុំរឿងទៅជម្រះផ្ទាល់	ដីកាដែលបង្ហាញខ្លួនភ្លាម	តម្កល់រឿងទុកឥតចាត់ការ	បញ្ចូលរឿង	ផ្ទេរសមត្ថកិច្ច	សរុប	
២២០	១២៩	៣៤៩	៨៤	៥	១៤	១៦	១	០	១២០	២២៩

៣.ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥

សល់ពីមុន	ចូលថ្មី	សរុប	សំណុំរឿងចាត់ការរួច							សល់កំពុងចាត់ការ
			បញ្ជូនសំណុំរឿងទៅស៊ើបសួរ	បញ្ជូនសំណុំរឿងទៅជម្រះផ្ទាល់	ដីកាដែលបង្ហាញខ្លួនភ្លាម	តម្កល់រឿងទុកឥតចាត់ការ	បញ្ចូលរឿង	ផ្ទេរសមត្ថកិច្ច	សរុប	
២២៩	១៧៨	៤០៧	៩៥	២	១៣	២៧	៣	១	១៤១	២៦៦

ក.២. កិច្ចការពាក់ព័ន្ធនឹងការអនុវត្តទោស និងពន្ធនាគារ

១. ពន្ធនាគារ

១.១.ប្រចាំឆ្នាំ២០២៤

បរិយាយ	សរុបរួម		អនីតិជន		នីតិជន		ជនបរទេស	
	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី
១	២	៣	៤	៥	៦	៧	៨	៩
ជនត្រូវចោទ	៣៧១	២០	៥៦	០០	៣១០	២០	០៥	០០
ជនជាប់ចោទ	១៤៥	១៧	១៨	០៣	១២៥	១៤	០២	០០
ពិរុទ្ធជន	១២៨២	៧៤	១៦១	០៣	១១១៦	៧០	០៥	០១
ទណ្ឌិត	៩៦៧	៤០	៤៨	០២	៩១៧	៣៧	០២	០១
សរុបជនជាប់ឃុំ	២៧៦៥	១៥១	២៨៣	០៨	២៤៦៨	១៤១	១៤	០២

១.២.ប្រចាំខែមករា ឆ្នាំ២០២៥

បរិយាយ	សរុបរួម		អនីតិជន		នីតិជន		ជនបរទេស	
	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី
១	២	៣	៤	៥	៦	៧	៨	៩
ជនត្រូវចោទ	៣៩៥	២៣	៦៨	០១	៣២២	២២	០៥	០០
ជនជាប់ចោទ	២៦៨	១៨	៤៣	០៣	២២២	១៥	០៣	០០
ពិរុទ្ធជន	១១៤៧	៦៨	១៤០	០៣	១០០២	៦៤	០៥	០១
ទណ្ឌិត	១០៨៤	៤៥	៦០	០២	១០២២	៤២	០២	០១
សរុបជនជាប់ឃុំ	២៨៩៤	១៥៤	៣១១	០៩	២៥៦៨	១៤៣	១៥	០២

១.៣.ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥

បរិយាយ	សរុបរួម		អនីតិជន		នីតិជន		ជនបរទេស	
	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី
១	២	៣	៤	៥	៦	៧	៨	៩
ជនត្រូវចោទ	៤៥៣	៣១	៩០	០១	៣៥៦	៣០	០៧	០០
ជនជាប់ចោទ	២១៩	១១	៣៩	០១	១៧៩	១០	០១	០០
ពិរុទ្ធជន	១៣២១	៧៨	១៣៨	០៥	១១៧៥	៧២	០៨	០១
ទណ្ឌិត	១០៤១	៤៧	៥៣	០២	៩៨៦	៤៤	០២	០១
សរុបជនជាប់ឃុំ	៣០៣៤	១៦៧	៣២០	០៩	២៦៩៦	១៥៦	១៨	០២

២.ការអនុវត្តទោស

២.១.ប្រចាំឆ្នាំ២០២៤

ល.រ	សេចក្តីសម្រេចស្ថាពរ	សល់ពីមុន	ចូលថ្មី	សរុប	ចាត់ការរួច	កំពុងចាត់ការ
១	សាលក្រមព្រហ្មទណ្ឌ	១៥៩៣	៧០០	២២៩៣	១៩៦	២០៩៧
២	សាលដីកាព្រហ្មទណ្ឌ របស់សាលាឧទ្ធរណ៍	៥៨៦	៦៨៧	១២៧៣	២៩៤	៩៧៩
៣	សាលដីកាព្រហ្មទណ្ឌ របស់តុលាការកំពូល	៥៣	៦៤	១១៧	៣៤	៨៣
៤	សាលក្រមរបស់តុលាការបរទេស	០	០	០	០	០
សរុប		២២៣២	១៤៥១	៣៦៨៣	៥២៤	៣១៥៩

២.២.ប្រចាំខែមករា ឆ្នាំ២០២៥

ល.រ	សេចក្តីសម្រេចស្ថាពរ	សល់ពីមុន	ចូលថ្មី	សរុប	ចាត់ការរួច	កំពុងចាត់ការ
១	សាលក្រមព្រហ្មទណ្ឌ	២០៩៧	១៥២	២២៤៩	១៧	២២៣២
២	សាលដីកាព្រហ្មទណ្ឌ របស់សាលាឧទ្ធរណ៍	៩៧៩	២៦	១០០៥	១០	៩៩៥
៣	សាលដីកាព្រហ្មទណ្ឌ របស់តុលាការកំពូល	៨៣	៤	៨៧	៤	៨៣
៤	សាលក្រមរបស់តុលាការបរទេស	០	០	០	០	០
សរុប		៣១៥៩	១៨២	៣៣៤១	៣១	៣៣១០

២.៣.ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥

ល.រ	សេចក្តីសម្រេចស្ថាពរ	សល់ពីមុន	ចូលថ្មី	សរុប	ចាត់ការរួច	កំពុងចាត់ការ
១	សាលក្រមព្រហ្មទណ្ឌ	២២៣២	៩	២២៤១	២	២២៣៩
២	សាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍	៩៩៥	៥១	១០៤៦	២៦	១០២០
៣	សាលដីកាព្រហ្មទណ្ឌរបស់តុលាការកំពូល	៨៣	៨	៩១	២	៨៩
៤	សាលក្រម ឬសាលដីការបស់តុលាការបរទេស	០	០	០	០	០
សរុប		៣៣១០	៦៨	៣៣៧៨	៣០	៣៣៤៨

ខ. សាលាដំបូង ៖

ខ.១. ចំណាត់ការលើសំណុំរឿងព្រហ្មទណ្ឌ

ខ.១.១. ដំណាក់កាលស៊ើបសួរ

ឆ្នាំ	សំណុំរឿងសល់ពីមុន	សំណុំរឿងចូលថ្មី	សំណុំរឿងចាត់ការរួច	សំណុំរឿងនៅសល់កំពុងចាត់ការ
២០២៤	៣១៧	១១១០	១១៦៧	២៦០
២០២៥ ខែមករា	២៦០	១០៤	៥២	៣១២
២០២៥ ខែកុម្ភៈ	៣១២	៩៨	៨០	៣៣០

ខ.១.២. ដំណាក់កាលជំនុំជម្រះ

ល.រ	សំណុំរឿងសល់ពីមុន	សំណុំរឿងចូលថ្មី	សំណុំរឿងចាត់ការរួច	សំណុំរឿងនៅសល់កំពុងចាត់ការ
២០២៤	២៣១	១២៨១	១៥០៥	៧
២០២៥ ខែមករា	៧	១៧៦	១២	១៧១
២០២៥ ខែកុម្ភៈ	១៧១	១០៤	១១៩	១៥៦

ខ.២. ចំណាត់ការលើសំណុំរឿងរដ្ឋប្បវេណី

ក. ប្រចាំឆ្នាំ ២០២៤

ប្រភេទរឿងក្តី	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	សល់កំពុងចាត់ការ
រឿងក្តីនៃបណ្តឹង	៤១១	៧២៧	៩៤៥	១៩៣
រក្សាការពារ	១៩	១០០	១១៣	៦
នីតិវិធីមិនមែនបណ្តឹង	២៣២	៣៥៧៤	៣៧៨០	២៦
ពាក្យសុំដីកាសម្រេចដាស់តឿន	០	១	១	០

ខ. ប្រចាំខែមករា ឆ្នាំ២០២៥

ប្រភេទរឿងក្តី	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	សល់កំពុងចាត់ការ
រឿងក្តីនៃបណ្តឹង	១៩៣	៨៥	៣៤	២៤៤
រក្សាការពារ	៦	៧	៥	៨
នីតិវិធីមិនមែនបណ្តឹង	២៦	៣៥៨	២៧	១០៦
ពាក្យសុំដីកាសម្រេចដាស់តឿន	០	០	០	០

គ. ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥

ប្រភេទរឿងក្តី	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	សល់កំពុងចាត់ការ
រឿងក្តីនៃបណ្តឹង	២៤៤	៦៦	៣៥	២៧៥
រក្សាការពារ	៨	១១	១៤	៥
នីតិវិធីមិនមែនបណ្តឹង	១០៦	៣៩៩	៣៩៤	១១១
ពាក្យសុំដីកាសម្រេចដាស់តឿន	០	០	០	០

ខ.៣. ចំណាត់ការសំណុំរឿងផ្សេងទៀត

ក. ប្រចាំឆ្នាំ ២០២៤

ប្រភេទរឿងក្តី	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	សល់កំពុងចាត់ការ
បណ្តឹងពាក់នឹងការអនុវត្ត	០	០	០	០
អនុវត្តរក្សាការពារ	០	៧៤	៧៤	០
ផ្ទេរប្តរវេណីលើពាក្យសុំដីកាសម្រេច	០	០	០	០
អនុវត្តដោយបង្ខំ	៥២៤	១២៩	២២៤	៤២៩

ខ. ប្រចាំខែមករា ឆ្នាំ២០២៥

ប្រភេទរឿងក្តី	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	សល់កំពុងចាត់ការ
បណ្តឹងពាក់នឹងការអនុវត្ត	០	០	០	០
អនុវត្តរក្សាការពារ	០	៣	២	១
ផ្ទេរប្តរវេណីលើពាក្យសុំដីកាសម្រេច	០	០	០	០
អនុវត្តដោយបង្ខំ	៤២៩	៨	៦	៤៣១

គ. ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥

ប្រភេទរឿងក្តី	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	សល់កំពុងចាត់ការ
បណ្តឹងពាក់នឹងការអនុវត្ត	០	០	០	០
អនុវត្តរក្សាការពារ	១	១៥	១៣	៣
ផ្ទេរប្តរវេណីលើពាក្យសុំដីកាសម្រេច	០	០	០	០
អនុវត្តដោយបង្ខំ	៤៣១	១០	១៣	៤២៨

ខ.៤. កិច្ចការផ្សេងទៀតរបស់សាលាដំបូង

អនុវត្តសំណងរដ្ឋប្បវេណីក្នុងរឿងព្រហ្មទណ្ឌ	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	សល់កំពុងចាត់ការ
ប្រចាំឆ្នាំ ២០២៤	៥៧	៥	៤៥	១៧
ប្រចាំខែមករា ២០២៥	១៧	០	២	១៥
ប្រចាំខែកុម្ភៈ ២០២៥	១៥	០	០	១៥

៣. បញ្ហាប្រឈម និងសំណូមពរ

៣.១.បញ្ហាប្រឈម

-ខ្វះម៉ាស៊ីនកុំព្យូទ័រ ម៉ាស៊ីនព្រីន ម៉ាស៊ីនស្កែន និងម៉ាស៊ីនថតចម្លង។

-ខ្វះសៀវភៅចុះបញ្ជីក្នុងលេខាធិការដ្ឋាន និងក្របសំណុំរឿងព្រហ្មទណ្ឌ និងរដ្ឋប្បវេណី។

-ចំនួនក្រឡាបញ្ជីនៅមានភាពខ្វះខាត មិនទាន់ឆ្លើយតបទៅនឹងការកើនឡើងនៃតួលេខសំណុំរឿងក្តីនៅឡើយ។
-បញ្ហាស្រាវជ្រាវអត្តសញ្ញាណ (ក្នុងរឿព្រហ្មទណ្ឌ) ពុំសូវបានលទ្ធផលល្អដូចការចង់បាន។
-រឿងរដ្ឋប្បវេណី សមត្ថកិច្ចតុលាការរឿងដីឥតប័ណ្ណ ការចុះបញ្ជីលើកដំបូងលក់ដោយបង្ខំលើដីឥតប័ណ្ណ ការលក់គ្មានអ្នកទិញ។
-បញ្ហាស្រាវជ្រាវអត្តសញ្ញាណ (ក្នុងរឿងព្រហ្មទណ្ឌ) ពុំសូវបានលទ្ធផលល្អដូចការចង់បាន។
-របាយការណ៍មានច្រើនទម្រង់។
-សមត្ថភាពមន្ត្រីនៅមានកម្រិត។

៣.២. សំណូមពរ

-សុំឲ្យមានវគ្គបណ្តុះបណ្តាលមន្ត្រីលេខាធិការដ្ឋានបន្ថែមពាក់ព័ន្ធការងារចុះបញ្ជីដោយដៃ និងតាមប្រព័ន្ធ រួមនឹងអត្ថបទច្បាប់ថ្មីៗផ្សេងៗទៀត។
-ស្នើសុំផ្តល់បន្ថែមក្រឡាបញ្ជី ដើម្បីឱ្យសមស្របទៅតាមចំនួនរឿងក្តី ដែលកំពុងកើនឡើង។
-ស្នើសុំផ្តល់បន្ថែមក្រឡាបញ្ជី ដើម្បីឱ្យសមស្របទៅតាមចំនួនរឿងក្តី ដែលកំពុងកើនឡើង។
-ស្នើសុំមន្ត្រីរដ្ឋបាលបន្ថែម។
-ស្នើសុំទម្រង់របាយការណ៍តែមួយអាចប្រើបានគ្រប់កន្លែង។

៣.៣. ទិសដៅការងារសម្រាប់ឆ្នាំ ២០២៥

១-ជម្រុញនូវការដោះស្រាយរាល់បញ្ហាប្រឈម និងពង្រឹងសាមគ្គីភាពផ្ទៃក្នុង ពូតដៃគ្នាជាឆ្លងមួយដើម្បីរួមគ្នាបំពេញការងារដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋ ជាពិសេសក្នុងការបម្រើសេវាយុត្តិធម៌ឱ្យបានឆាប់រហ័ស យុត្តិធម៌ និងមានគុណភាព។

២-ពង្រឹងការទំនាក់ទំនងជាមួយស្ថាប័នផ្សេងៗ ដើម្បីជម្រុញកិច្ចសហការល្អក្នុងការអនុវត្តច្បាប់ និង មានប្រសិទ្ធភាពនៃដំណើរការនីតិវិធី។

៣-ជម្រុញចំណាត់ការរឿងក្តីព្រហ្មទណ្ឌ និងរដ្ឋប្បវេណីឱ្យបានទាន់ពេលវេលា ត្រឹមត្រូវតាមនីតិវិធីច្បាប់ និងប្រកាន់ខ្ជាប់នូវអភិក្រមទាំង៤ របស់ គឺ លឿន ត្រឹមត្រូវ យុត្តិធម៌ និងមិនពុករលួយ ។

៤-បន្តពង្រឹងក្រមសីលធម៌ការងារ និងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មន្ត្រីនៅក្នុងអង្គភាព។

៥-បន្តការប្រជុំផ្ទៃក្នុងដោះស្រាយបញ្ហាប្រឈម ដែលមានមតិមិនស្របគ្នាក្នុងការអនុវត្ត។

៦-បន្តជម្រុញលើចំណាត់ការលើបទល្មើសសម្អាតប្រាក់ (ពុករលួយ ឆបោក រំលោភទំនុកចិត្ត ព្រៃឈើ ជួញដូរមនុស្ស និងបទល្មើសគ្រឿងញៀន) បទល្មើសលួចគ្រប់ប្រភេទ បទល្មើសចរាចរណ៍ ជាពិសេសបទល្មើសក្មេងទំនើង។

៧-បង្កើនសមត្ថភាពមន្ត្រីរាជការ ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាល។

៨-បន្តគាំទ្រ និងអនុវត្ត លើផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលជាអាទិ៍គឺ៖
-ការពង្រឹងនូវការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ
-ការពង្រឹងភាពស្អាតស្អំ និងក្រមសីលធម៌ វិជ្ជាជីវៈរបស់មន្ត្រីក្នុងការអនុវត្តច្បាប់
-ពង្រឹងយន្តការពិន័យការងារ និងការធ្វើទំនើបកម្មរដ្ឋបាលយុត្តិធម៌
-លើកកំពស់ការផ្តល់សេវាច្បាប់ យុទ្ធសាស្ត្រ លើកកំពស់សេវាផ្នែកច្បាប់
-ពង្រឹង និងកែលម្អយន្តការដោះស្រាយវិវាទ ដែលអាចឆ្លើយតបនឹងសភាពការជាក់ស្តែងក្នុង សង្គមប្រកបដោយប្រសិទ្ធភាព

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងជ្រាបជារបាយការណ៍ដោយសេចក្តីអនុគ្រោះបំផុត។

ថ្ងៃពុធ ៧កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២៥

បានឃើញ និង ឯកភាព	
បាត់ដំបង ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២៥	
ព្រះរាជអាជ្ញា	**ប្រធានសាលាដំបូង**
កែវ សុជាតិ	ជា ចំរើនស្មី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង និងអយ្យការអមសាលាដំបូង
ខេត្តពោធិ៍សាត់
លេខ:.....១៨៥១.....រប/២៥

របាយការណ៍ការងារសង្ខេបរបស់សាលាដម្រះក្តី
សម្រាប់សន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារអនាគត ឆ្នាំ២០២៥
សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់

==========

១. ស្ថានភាពទូទៅ

ក-ធនធានមនុស្ស ៖ សរុបរួម: ៨៣ រូប ស្រី២០រូប ក្នុងនោះចៅក្រម ០៩រូប ស្រី ០២រូប (រួមទាំងប្រធាន និងអនុប្រធានសាលាដំបូង) ចៅក្រមកម្មសិក្សា ០២រូប ស្រី០០រូប ព្រះរាជអាជ្ញា-រង ០៤រូប ស្រី០២រូប ព្រះរាជអាជ្ញារងកម្មសិក្សា ០១រូប ស្រី០០រូប អាជ្ញាសាលា ០១រូប ស្រី០០រូប ក្រឡាបញ្ជីសាលាដំបូង ១២រូប ស្រី០១រូប ក្រឡាបញ្ជីអយ្យការ ០៦រូប ស្រី០១រូប ក្រឡាបញ្ជីសាលាដំបូងកម្មសិក្សា០១រូប ស្រី០០រូប ក្រឡាបញ្ជីអយ្យការកម្មសិក្សាស្រី ០១រូប ប្រធាន-អនុប្រធាន និងមន្ត្រីលេខាធិការដ្ឋាន ២៨ រូប ស្រី១៣រូប និងមន្ត្រីកិច្ចសន្យា ១៨រូប ស្រី១១រូប ។

ខ-ហេដ្ឋារចនាសម្ព័ន្ធ៖

-បច្ចុប្បន្នសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់មានទំហំផ្ទៃដី ១៧៥៥ម^{2} ស្ថិតនៅក្នុងភូមិ៣លញ្ជែក១ សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ មានចំនួន០២អាគារ ស្មើនឹង៣៥បន្ទប់ ក្នុងនោះ មានសាលប្រជុំចំនួន០១បន្ទប់ សាលសវនាការ ចំនួន០២បន្ទប់ ឃ្លាំងដាក់សំណុំរឿងចំនួន០២បន្ទប់ អាជ្ញាសាលាចំនួន០១បន្ទប់ , ការិយាល័យប្រតិភូគណៈមេធាវី ចំនួន០១បន្ទប់ និងលេខាធិការដ្ឋាន ចំនួន០១បន្ទប់ធំ និងទើបទទួលបានដីទំហំ ២ហិកតា ដែលរដ្ឋបាលសាលាខេត្តពោធិ៍សាត់ ផ្តល់ជូនសម្រាប់ធ្វើឃ្លាំងវត្ថុតាង ។

គ-លទ្ធផលសន្និបាតផ្ទៃក្នុងស្ថាប័ន ២០២៤ ៖

១.ត្រួតពិនិត្យឡើងវិញទាក់ទងនឹងដីកាបង្គាប់ឲ្យនាំខ្លួន ដីកាបង្គាប់ឲ្យចាប់ខ្លួន និងដីកាបញ្ឈប់ចាប់ខ្លួន ដើម្បីតាមដានការអនុវត្តដីកាទាំងនេះ ធ្វើយ៉ាងណាអោយមានប្រសិទ្ធភាព។

២.ការឃុំខ្លួនបណ្តោះអាសន្នលើស ស្នើសុំអោយក្រឡាបញ្ជីរបស់ចៅក្រមស៊ើបសួរ ធ្វើតារាងតាមដានការឃុំខ្លួន(អនីតិជន, នីតិជន) ដើម្បីជៀសវាងការឃុំខ្លួនលើស។

៣.កិច្ចការបញ្ជូនក្នុងសំណុំរឿងរដ្ឋប្បវេណី គឺទទួលស្គាល់ថាពិតជាមានការលំបាក ចំពោះការស្នើសុំមានការចាត់តាំងមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន សាលាដំបូងនឹងប្រជុំពិភាក្សាឡើងវិញជាមួយមន្ត្រីប្រៃសណីយ៍

សាកសួរអំពីបញ្ហានេះ មួយវិញទៀតទុកពេលអោយអាជ្ញាសាលាទៅសិក្សាបន្ថែមអំពីបញ្ហានេះ និងសម្រេចនៅពេលក្រោយ។

៤.ដីកាបង្គាប់ឲ្យនាំខ្លួន ចៅក្រមស៊ើបសួរទាំងអស់ត្រូវតែកំណត់កាលបរិច្ឆេទអោយបានត្រឹមត្រូវ ជាគោលការណ៍រយៈពេល០១ខែពីថ្ងៃចេញដីកា (ករណីនីតិជន) និងកន្លះខែ (ករណីអនីតិជន) ដើម្បីជៀសវាងការខុសគ្នារវាងចៅក្រមនីមួយៗនាំអោយមានការលំបាកដល់មន្ត្រីនគរបាលយុត្តិធម៌។

៥.ចំពោះដីកាបង្គាប់ឲ្យចាប់ខ្លួនតាមអំណាចសាលក្រម ស្របតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមជំនុំជម្រះដែលប្រកាសចេញដីកាបង្គាប់ឲ្យចាប់ ត្រូវចេញដីកា និងចុះលេខត្រាមៗ ហើយបើចៅក្រមជំនុំជម្រះសម្រេចអំពីការបញ្ឈប់ការចាប់ខ្លួន ក៏ត្រូវចេញដីកាបញ្ឈប់ការចាប់ខ្លួន និងបញ្ជូនដីកាទៅសមត្ថកិច្ច ដើម្បីជៀសវាងការបន្តអនុវត្តដីកាបង្គាប់អោយចាប់ខ្លួន។

៦.ចំពោះសាលក្រមព្រហ្មទណ្ឌ ចៅក្រមត្រូវផ្តល់អោយរដ្ឋបាលអោយទាន់ពេលវេលាតាមការកំណត់របស់ច្បាប់ ដើម្បីងាយស្រួលចាត់ការបញ្ជូនបន្តទៅខាងពន្ធនាគារ និងស្ថាប័នពាក់ព័ន្ធ។

៧.ការពង្រឹងសន្តិសុខក្នុងបរិវេណសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់ មន្ត្រីសន្តិសុខត្រូវត្រួតពិនិត្យអាវុធជាតិផ្ទុះ របស់របរគ្រោះថ្នាក់ មុនអនុញ្ញាតឲ្យប្រជាពលរដ្ឋចូលមកក្នុងបរិវេណតុលាការ ។

ឃ-ព្រឹត្តិការណ៍ ឬកម្មវិធីការចារនាទ ៖

-ថ្ងៃទី០២ ខែមករា ឆ្នាំ២០២៤ **ឯកឧត្តម តេង រតនា និងឯកឧត្តម កូយ កាន់យ៉ា** បានបើកសន្និបាតបូកសរុបលទ្ធផលប្រចាំឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់សាលាដំបូងខេត្តពោធិ៍សាត់ និងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

-ថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៤ **ឯកឧត្តម តេង រតនា ឯកឧត្តម កូយ កាន់យ៉ា លោកអនុប្រធាន លោកប្រធាន-អនុប្រធានលេខាធិការដ្ឋាន** បានចូលរួមប្រជុំបូកសរុបលទ្ធផលប្រចាំឆ្នាំ២០២៣ និងលើកទិសដៅឆ្នាំ ២០២៤ របស់ សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ក្រោមអធិបតីភាព **ឯកឧត្តម សម ប៊ុនថុន និងឯកឧត្តម នួន សាន** នៅសាលាឧទ្ធរណ៍បាត់ដំបង។

-ថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣ **ឯកឧត្តម តេង រតនា និងឯកឧត្តម កូយ កាន់យ៉ា** បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយស្តីពីការណែនាំអំពីការអនុវត្តយុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីតាមតុលាការ និងយុទ្ធនាការត្រួតពិនិតភាពមិនប្រក្រតីនៅតាមតុលាការ នៅបណ្ឌិតសភាភូមិន្ទយុត្តិធម៌កម្ពុជារាជធានីភ្នំពេញ។

-ថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤ **ឯកឧត្តម តេង រតនា និងឯកឧត្តម កូយ កាន់យ៉ា** បានបើកការប្រជុំស្តីពីការផ្សព្វផ្សាយកិច្ចប្រជុំរបស់ក្រសួងយុត្តិធម៌ស្តីពីយុទ្ធនាការអនុវត្តការជម្រុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទនៃសាលាដំបូងខេត្តពោធិ៍សាត់។

-ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៤ **ឯកឧត្តម តេង រតនា និងឯកឧត្តម កូយ កាន់យ៉ា លោកអនុប្រធានចៅក្រម ព្រះរាជអាជ្ញារង លោកប្រធានលេខាធិការដ្ឋាន** បានចូលរួមសន្និបាតប្រជុំបូកសរុបលទ្ធផលប្រចាំឆ្នាំ២០២៣ និងលើកទិសដៅឆ្នាំ២០២៤ របស់ក្រសួងយុត្តិធម៌ ក្រោមអធិបតីភាព**ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** នៅរាជធានីភ្នំពេញ។

-ថ្ងៃទី២៨-២៩ ខែវិច្ឆិកា ឆ្នាំ២០២៤ ឯកឧត្តមប្រធាន និងលោកប្រធានលេខា បានចូលរួមសិក្ខាសាលាស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគាំទ្រវិស័យយុត្តិធម៌ និងកម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** នៅសណ្ឋាគារសុខាភ្នំពេញ។

២. សមិទ្ធផលការងារ

ក. អយ្យការអមសាលាដំបូង ៖ ប្រចាំឆ្នាំ២០២៤

ក.១. ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌ

-សំណុំរឿងសល់ពីមុន ២៩៥ រឿង

-សំណុំរឿងចូលថ្មី ១១០៧ រឿង

-សំណរឿងចាត់ការរួច ១៣២៧ រឿង

-សំណុំរឿងកំពុងចាត់ការ ៧៥ រឿង

ក.២. កិច្ចការពាក់ព័ន្ធនឹងការអនុវត្តទោស និងពន្ធនាគារ

-ទណ្ឌិតសល់ពីមុន ១៨១០ នាក់(សាលដីកាតុលាការកំពូល២០នាក់ , សាលដីកាសាលាឧទ្ធរណ៍ ២០០នាក់ , សាលក្រមស្តាពរ១៥៩០នាក់)

-ទណ្ឌិតចូលថ្មី ១៦១១នាក់(សាលដីកាតុលាការកំពូល១៣នាក់, សាលដីកាសាលាឧទ្ធរណ៍ ៣៧នាក់ , សាលក្រមស្តាពរ១៥៦១នាក់)

-ទណ្ឌិតអនុវត្តទោស រួច ១១៩៥នាក់(តាមសាលដីកាតុលាការកំពូល០៧នាក់, តាមសាលដីកាសាលាឧទ្ធរណ៍៨១នាក់ , សាលាក្រមស្តាពរ ១១០៧នាក់)

-ទណ្ឌិតកំពុងអនុវត្តទោស ២២២៦នាក់(សាលដីកាតុលាការកំពូល២៦នាក់, សាលដីកាសាលាឧទ្ធរណ៍១៥៦នាក់ , សាលាក្រម ២០៤៤នាក់)

ក.៣. កិច្ចការពាក់ព័ន្ធជាមួយនឹងមន្ត្រីនគរបាលយុត្តិធម៌

-ប្រជុំមន្ត្រីនគរបាលយុត្តិធម៌ ចំនួន២លើក

-ចុះអធិការកិច្ចតាម អធិការដ្ឋាននគរបាលក្រុង/ស្រុក និងកងរាជអាវុធហត្ថ ជាប្រចាំ

-ចុះត្រួតពិនិត្យពន្ធនាគារ

ក.៤. កិច្ចការផ្សេងទៀតរបស់ស្ថាប័នអយ្យការ

-ចូលរួមសហការអធិការកិច្ចរបស់សាលាឧទ្ធរណ៍

- ចូលរួមកិច្ចប្រជុំគណៈបញ្ជាការឯកភាពខេត្ត

-ចូលរួមវាយតម្លៃកម្រិតកែប្រែរបស់ទណ្ឌិត ដើម្បីស្នើសុំបន្ធូរបន្ថយទោយ និងលើកលែងទោស ។

ខ. សាលាដំបូង ៖ ប្រចាំឆ្នាំ២០២៤

ខ.១. ចំណាត់ការលើសំណុំរឿងព្រហ្មទណ្ឌ

ខ.១.១. ដំណាក់កាលស៊ើបសួរ

-សំណុំរឿងសល់ពីមុន ៤៧៦ រឿង

-សំណុំរឿងចូលថ្មី ៨១៨ រឿង

-សំណរឿងចាត់ការរួច ៩៦៧ រឿង
-សំណុំរឿងកំពុងចាត់ការ ៣២៧ រឿង

ខ.១.២. ដំណាក់កាលជំនុំជម្រះ

-សំណុំរឿងសល់ពីមុន ១៧៥ រឿង
-សំណុំរឿងចូលថ្មី ៧៦៤ រឿង
-សំណរឿងចាត់ការរួច ៨០៨ រឿង
-សំណុំរឿងកំពុងចាត់ការ ១៣១ រឿង

ខ.២. ចំណាត់ការលើសំណុំរឿងរដ្ឋប្បវេណី

-សំណុំរឿងសល់ពីមុន ៦៦១ រឿង
-សំណុំរឿងចូលថ្មី ២៨៣២ រឿង
-សំណរឿងចាត់ការរួច ៣០៧៦ រឿង
-សំណុំរឿងកំពុងចាត់ការ ៤១៧ រឿង

ខ.៣. ចំណាត់ការសំណុំរឿងអនុវត្ត

ខ.៣.១.សំណុំរឿងអនុវត្តដោយចៅក្រម

-សំណុំរឿងសល់ពីមុន ៦៦ រឿង
-សំណុំរឿងចូលថ្មី ៨៤ រឿង
-សំណរឿងចាត់ការរួច ៦៥ រឿង
-សំណុំរឿងកំពុងចាត់ការ ៨៥ រឿង

ខ.៣.២.សំណុំរឿងអនុវត្តដោយអាជ្ញាសាលា

-សំណុំរឿងសល់ពីមុន ៤៧ រឿង
-សំណុំរឿងចូលថ្មី ១១ រឿង
-សំណរឿងចាត់ការរួច ៤៨ រឿង
-សំណុំរឿងកំពុងចាត់ការ ១០ រឿង

ខ.៤. កិច្ចការផ្សេងទៀតរបស់សាលាដំបូង

-ចូលរួមសហការអធិការកិច្ចជាមួយសភាស៊ើបសួរសាលាឧទ្ធរណ៍
-ចូលរួមកិច្ចប្រជុំគណៈបញ្ជាការឯកភាពខេត្ត

៣. បញ្ហាប្រឈម និងសំណូមពរ

១.កកស្ទះ និងខ្វះឃ្លាំងដាក់វត្ថុតាង ស្នើសុំថវិការធ្វើឃ្លាំង និងពន្លឿននីតិវិធីលក់ឡាយឡុងវត្ថុតាង។
២.កង្វះមន្ត្រីបម្រើការក្នុងអង្គភាពប្រជាពលរដ្ឋកង្វះការយល់ដឹងពាក់ព័ន្ធនឹងការអនុវត្តច្បាប់ ស្នើសុំព្រះរាជអាជ្ញារងចំនួន០១រូប ចៅក្រមចំនួន០២រូប ក្រឡាបញ្ជីចំនួន១០រូប មន្ត្រីអាជ្ញាសាលាចំនួន ០១ រូប និងសុំមន្ត្រីរដ្ឋបាល ០៥រូប ។

៣.ស្នើសុំធ្វើវិសោធនកម្មមាត្រា ២៤៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដើម្បីបន្ថែមអាជ្ញាធរភូមិ ឃុំ សង្កាត់ ស្រុក-ក្រុង និងប៉ុស្តិ៍នគរបាល ឲ្យមាននីតិសម្បទាក្នុងការបញ្ជូន។

៤. ទិសដៅការងារសម្រាប់ឆ្នាំ ២០២៥

១.ពង្រឹងការគោរពវិន័យ គោរពពេលវេលា បទបញ្ជាផ្ទៃក្នុងឲ្យបានម៉ត់ចត់ និងប្រកបការងារដោយក្រមសីលធម៌ វិជ្ជាជីវៈ គឺនៅតែជាកាតព្វកិច្ចរបស់មន្ត្រីទាំងអស់នៅសាលាដំបូងនិងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

២.សាលាដំបូងនិងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់ ដាក់ផែនការបន្តចំណាត់ការលើសំណុំរឿងក្តីទាំងអស់ ជាពិសេសសំណុំរឿងអត្ថិភាពទាំង០៤ ទាក់ទងនិងសំណុំរឿងគ្រឿងញៀន សំណុំរឿងចរាចរណ៍ សំណុំរឿងអគ្រានុកូលដ្ឋាន និងសំណុំរឿងក្មេងទំនើង ឱ្យបានលឿន ត្រឹមត្រូវ ម៉ឺងម៉ាត់ និងតឹងរឹងបំផុត។

៣.ជម្រុញការដោះស្រាយសំណុំរឿងរដ្ឋប្បវេណី និងសំណុំរឿងព្រហ្មទណ្ឌទូទៅអោយបានលឿន ឆាប់រហ័ស ត្រឹមត្រូវយុត្តិធម៌ និងមិនប្រព្រឹត្តអំពើពុករលួយ ក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ ដើម្បីឲ្យប្រជាពលរដ្ឋមានជំនឿទុកចិត្តខ្ពស់មកលើប្រព័ន្ធតុលាការ។

៤-បន្តកិច្ចសហការរវាងសាលាដំបូង និងអយ្យការអមសាលាដំបូង ដើម្បីធានាឱ្យមានការឯកភាពផ្ទៃក្នុង ដើម្បីផ្តល់លទ្ធភាពឱ្យការងាររដ្ឋបាលរឹតតែដំណើរការបានល្អថែមទៀត និងធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តច្បាប់ ជាពិសេសបន្តកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធ ដូចជា កងរាជអាវុធហត្ថខេត្ត ស្នងការនគរបាលខេត្ត និងអង្គភាពពាក់ព័ន្ធដែលបម្រើការក្នុងវិស័យយុត្តិធម៌ ធ្វើយ៉ាងណាអោយការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន ដីកាបង្គាប់ឲ្យចាប់ខ្លួន និងដីកាបញ្ឈប់ចាប់ខ្លួន មានប្រសិទ្ធភាព ត្រឹមត្រូវតាមច្បាប់។

ថ្ងៃអង្គារ ៦កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ពោធិ៍សាត់, ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៥

ប្រធានលេខាធិការដ្ឋានរដ្ឋបាល

ឃ្យៀង សុម៉ុនី

បានឃើញ និង ឯកភាព

ពោធិ៍សាត់ , ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៥

ព្រះរាជអាជ្ញា

ភួយ កាន់យ៉ា

ប្រធានសាលាដំបូង

គេន រតនា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តប៉ៃលិន
លេខ ០០០៥ រ.ប/២៥

របាយការណ៍ការងារសេសទ្ធេបរបស់សាលាដម្រះក្តី
សម្រាប់សន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារអនាគត ឆ្នាំ២០២៥
សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តប៉ៃលិន

==========

១. ស្ថានភាពទូទៅ

១.១ ធនធានមនុស្ស ៖ សរុបរួម៖ ៤៤រូប ក្នុងនោះ ចៅក្រម ០៦រូប(រួមទាំងប្រធានសាលាដំបូង) ព្រះរាជអាជ្ញា-រង ០៣រូប ក្រឡាបញ្ជីសាលាដំបូង ១០រូប ក្រឡាបញ្ជីអយ្យការ ០៥រូប ប្រធាន -អនុប្រធាន និងមន្ត្រីលេខាធិការដ្ឋាន ១៣រូប និងមន្ត្រីកិច្ចសន្យា ០៧រូប។

១.២ ហេដ្ឋារចនាសម្ព័ន្ធ

សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តប៉ៃលិនមានដីទំហំ ២,៦០០ (ពីរពាន់ប្រាំមួយរយ) ម៉ែត្រការ៉ែ, អគារចំនួន ៣ ខ្នង ក្នុងនោះមាន ចំណតរថយន្តចំនួន០១ ចំណតជាក់ម៉ូតូចំនួន ០២, សាលប្រជុំចំនួន ០១ , សាលសវនាការចំនួន ០១, ឃ្លាំងវត្ថុតាងចំនួន ០២ ,ឃ្លាំងសម្រាប់ដាក់សម្ភារៈចំនួន ០១ ។

១.៣ លទ្ធផលសន្និបាតឆ្នៃក្នុងស្ថាប័ន ២០២៤

-ពង្រឹងវិន័យក្នុងការអនុវត្តការងារ និងក្រមសីលធម៌វិជ្ជាជីវៈ។

-ពន្លឿនការផ្តល់របាយការណ៍ និងបញ្ជូនសាលក្រម បានឆាប់រហ័ស និងទាន់ពេលវេលាទៅក្រសួងយុត្តិធម៌ និងស្ថាប័នពាក់ព័ន្ធ។

-ពន្លឿនការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋឱ្យមានភាពងាយស្រួល និងឆាប់រហ័ស ។

-ពន្លឿនការដោះស្រាយសំណុំរឿងទាំងព្រហ្មទណ្ឌ និងរដ្ឋប្បវេណីឱ្យបានឆាប់រហ័ស ត្រឹមត្រូវ យុត្តិធម៌ និងមិនពុករលួយ ។

-យកចិត្តទុកដាក់ក្នុងការដោះស្រាយសំណុំរឿងអាទិភាពដូចជា សំណុំរឿងពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន សំណុំរឿងពាក់ព័ន្ធនឹងបទល្មើសគ្រោះថ្នាក់ចរាចរណ៍ និងសំណុំរឿងពាក់ព័ន្ធនឹងអត្រានុកូលដ្ឋាន ។

-រៀបចំកិច្ចប្រជុំជាមួយមន្ទីរ អង្គភាព មន្ត្រីនគរបាលយុត្តិធម៌ និងស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាប្រឈមនានាក្នុងពេលអនុវត្តនីតិវិធីច្បាប់ និងធានាឱ្យបាននូវប្រសិទ្ធិភាពការងារ និងយុត្តិធម៌ជូនភាគីពាក់ព័ន្ធ ។

-ផ្សព្វផ្សាយ និងណែនាំបន្តអំពីការអនុវត្តយុទ្ធនាការជម្រុញ និងពន្លឿនការដោះស្រាយរឿងក្តីតាមតុលាការ និងយុទ្ធនាការត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីតាមតុលាការដែលដាក់ចេញដោយ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី។

-អនុវត្តឱ្យបានត្រឹមត្រូវ ម៉ឺងម៉ាត់ និងតឹងរ៉ឹងបំផុតចំពោះសំណុំរឿងគ្រឿងញៀន ដើម្បីធានាឱ្យបាននូវភាពត្រឹមត្រូវ តម្លាភាព និងយុត្តិធម៌ ព្រមទាំងធ្វើការផ្សព្វផ្សាយអំពីចំណាត់ការគ្រប់នីតិវិធី ។

-ជម្រុញ និងពន្លឿនការអនុវត្តសំណុំរឿងគ្រោះថ្នាក់ចរាចរណ៍ ដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះឱ្យបានឆាប់រហ័ស ។

-ផ្តល់ភាពងាយស្រួលជូនប្រជាពលរដ្ឋពាក់ព័ន្ធជាមួយសំណុំរឿងអត្រានុកូលដ្ឋានដោយ ពិនិត្យ និងសម្រេចឱ្យបានត្រឹមត្រូវតាមច្បាប់ ។

-មានទំនាក់ទំនងការងារល្អ ជាមួយរដ្ឋបាលខេត្ត និងស្ថាប័នពាក់ព័ន្ធជុំវិញខេត្ត។

១.៤ កិច្ចប្រជុំផ្សេងៗ

-រៀបចំកិច្ចប្រជុំជាមួយក្រុមការងារគណកម្មការទី៦ នៃសភា សរុបចំនួន ០១ លើក ។

-រៀបចំកិច្ចប្រជុំផ្សព្វផ្សាយអំពីដំណោះស្រាយសំណុំរឿងអាទិភាព បទល្មើសគ្រឿងញៀន បទល្មើសគ្រោះថ្នាក់ចរាចរណ៍ និងសំណុំរឿងអត្រានុកូលដ្ឋាន ចំនួន ០១ លើក ។

-រៀបចំកិច្ចប្រជុំជាមួយសាលាឧទ្ធរណ៍បាត់ដំបងសរុបចំនួន ០២ លើក ។
-ចូលរួមកិច្ចប្រជុំជាមួយសាលាខេត្តសរុបចំនួន ១២ លើក ។
-ចូលរួមកិច្ចប្រជុំជាមួយមន្ទីរផ្សេងៗសរុបចំនួន ០១ លើក ។
-ចូលរួមកិច្ចប្រជុំជាមួយមន្ទីរផ្សេងៗសរុបចំនួន ១០ លើក ។
-រៀបចំកិច្ចប្រជុំផ្សេងៗសរុបចំនួន ០២ លើក ។

២. សមិទ្ធផលការងារ

ក. អយ្យការអមសាលាដំបូង

ក.១. ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌ

+សំណុំរឿងសល់ពីមុន	៧៤រឿង
+សំណុំរឿងចូលថ្មី	២៩៦រឿង
+សំណុំរឿងចាត់ការរួច	៣៤១រឿង ក្នុងនោះមាន៖
-RI	២៣៧រឿង
-ជម្រះផ្ទាល់	០៦រឿង
-តម្កល់រឿងទុកឥតចាត់ការ	៩៦រឿង
-បញ្ចូលសំណុំរឿង	០១រឿង
-ផ្ទេរសមត្ថកិច្ច	០១រឿង
+សំណុំរឿងកំពុងចាត់ការ	២៩រឿង

ក.២. កិច្ចការពាក់ព័ន្ធនឹងការអនុវត្តទោស និងពន្ធនាគារ

ក.២.១ ជនជាប់ឃុំក្នុងពន្ធនាគារ

+សរុបរួម	៥៨៩នាក់ ក្នុងនោះមាន៖
-ស្រី	២៩នាក់
-អនីតិជន	៥៧នាក់ (ស្រី ០៣នាក់)
-ជនបរទេស	២៦នាក់ (ស្រី ០២នាក់)

ក.២.២ ការអនុវត្តទោស

+សល់ពីមុន	២១២សាលក្រម/សាលដីកា
+ចូលថ្មី	១២៩០សាលក្រម/សាលដីកា
+ចាត់ការរួច	១៥៩សាលក្រម/សាលដីកា
+កំពុងអនុវត្ត	៣៤៣សាលក្រម/សាលដីកា

ក.៣. កិច្ចការពាក់ព័ន្ធជាមួយនឹងមន្ត្រីនគរបាលយុត្តិធម៌

អយ្យការបានចុះអធិការកិច្ចនៅស្នងការ, មេបញ្ជាការ, អធិការក្រុង-ស្រុក និងពន្ធនាគារ ចំនួន **០៤លើក** ក្នុងនោះមានដូចជា ៖

-នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤ ឯកឧត្តម ព្រះរាជអាជ្ញា ចុះត្រួតពិនិត្យសៀវភៅជនជាប់ឃុំ ប៉ុស្តិ៍សុខភាព បន្ទប់ឃុំឃាំងជនជាប់ឃុំ ក្នុងអង្គភាពន្ធនាគារខេត្តប៉ៃលិន។

-នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤ ឯកឧត្តម ព្រះរាជអាជ្ញា ចុះត្រួតពិនិត្យបញ្ជីសំណុំរឿង សៀវភៅទទួលពាក្យបណ្តឹង បញ្ជីឃាត់ខ្លួន បន្ទប់ឃុំឃាំង នៅអធិការក្រុងប៉ៃលិន និងស្រុកសាលាក្រៅ។

-នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៤ ឯកឧត្តម ព្រះរាជអាជ្ញា ចុះត្រួតពិនិត្យសៀវភៅជនជាប់ឃុំ ប៉ុស្តិ៍សុខភាព បន្ទប់ឃុំឃាំងជនជាប់ឃុំ នៅអង្គភាពន្ធនាគារខេត្តប៉ៃលិន។

-នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៤ ឯកឧត្តម ព្រះរាជអាជ្ញា ចុះត្រួតពិនិត្យបញ្ជីសំណុំរឿង សៀវភៅទទួលពាក្យបណ្តឹង បញ្ជីឃាត់ខ្លួន បន្ទប់ឃុំឃាំង នៅអង្គភាពស្នងការ និងមេបញ្ជាការកងរាជអាវុធហត្ថខេត្តប៉ៃលិន។

ខ. សាលាដំបូង៖

ខ.១. ចំណាត់ការលើសំណុំរឿងព្រហ្មទណ្ឌ

ខ.១.១-សំណុំរឿងស៊ើបសួរ

-សំណុំរឿងសល់ពីមុនចំនួន ១០២ រឿង
-សំណុំរឿងចូលថ្មីចំនួន ២៣០ រឿង
-សំណុំរឿងចាត់ការរួចចំនួន ២៤៨ រឿង(លើកលែងចោទ១១រឿង)
-សំណុំរឿងកំពុងចាត់ការចំនួន ៨៤ រឿង

ខ.១.២-សំណុំរឿងជំនុំជម្រះ

-សំណុំរឿងសល់ពីមុនចំនួន ៣២ រឿង
-សំណុំរឿងចូលថ្មីចំនួន ២៣១ រឿង
-សំណុំរឿងចាត់ការរួចចំនួន ២១៥ រឿង
-សំណុំរឿងកំពុងចាត់ការចំនួន ៤៨ រឿង

ខ.២-ការងារតុលាការរដ្ឋបាវណី

ខ.២.១-តុលាការរដ្ឋបាវណី

-សំណុំរឿងសល់ពីមុនចំនួន ៦៩ រឿង
-សំណុំរឿងចូលថ្មីចំនួន ៦២១ រឿង
-សំណុំរឿងចាត់ការរួចចំនួន ៥៨០ រឿង
-សំណុំរឿងកំពុងចាត់ការចំនួន ៤១ រឿង

ខ.៣-ចំណាត់ការលើសំណុំរឿងផ្សេងទៀត

ខ.៣.១-តុលាការអនុវត្តដោយបង្ខំ

-សំណុំរឿងសល់ពីមុនចំនួន ៦៩ រឿង
-សំណុំរឿងចូលថ្មីចំនួន ៣៧ រឿង
-សំណុំរឿងចាត់ការរួចចំនួន ៤៥ រឿង
-សំណុំរឿងកំពុងចាត់ការចំនួន ៦១ រឿង

ខ.៤-កិច្ចការផ្សេងទៀតរបស់សាលាដំបូង

ខ.៤-១-ការងារកោសលវិច័យគ្រឿងញៀន

-បញ្ជូនសំណាកគ្រឿងញៀនទៅអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានចំនួន **០៦** លើក ស្មើ ៥៥ សំណុំរឿង និងទទួលសំណាក់គ្រឿងញៀនពីមន្ទីរពិសោធន៍គ្រឿងញៀន បានចំនួន **៥៤** រឿង។

ខ.៤.២-ការងារចុះបញ្ជីសំណុំរឿងតាមប្រព័ន្ធព័តមានវិទ្យា (DATA BASE)

ខ.៤.២.១-សំណុំរឿងព្រហ្មទណ្ឌស៊ើបសួរ

-បានបញ្ចូលទិន្នន័យសំណុំរឿងស៊ើបសួរ ចំនួន ២១៨ រឿង
-បានបញ្ចូលទិន្នន័យដីកាដំណោះស្រាយ ចំនួន ២៣០ រឿង

ខ.៤.២.២-សំណុំរឿងព្រហ្មទណ្ឌជំនុំជម្រះ

-បានបញ្ចូលទិន្នន័យសំណុំរឿងជំនុំជម្រះ ចំនួន ១៩៤ រឿង
-បានបញ្ចូលទិន្នន័យ(File)សាលក្រម ចំនួន ២១៥ រឿង

៣. បញ្ហាប្រឈម និងសំណូមពរ

៣.១ បញ្ហាប្រឈម

-ខ្វះខាតកញ្ចប់ថវិកាចំណាយលើបេសកកម្ម។
-ខ្វះខាតមន្ត្រីក្របខណ្ឌ និងមន្ត្រីកិច្ចសន្យាសម្រាប់បំពេញការងារតាមការិយាល័យនីមួយៗ។
-កង្វះសម្ភារៈការិយាល័យមានដូចជា ម៉ាស៊ីនហ្វូតូកូពី,កុំព្យូទ័រ,ម៉ាស៊ីនស្កេន និងទូរជាក់ឯកសារ។
-ខ្វះមន្ត្រីអាជ្ញាសាលាក្នុងការអនុវត្តកិច្ចការអាជ្ញាសាលា ។
-មន្ត្រីអនុវត្តដីកាចាប់ខ្លួន ឫនាំខ្លួន មិនមានការឆ្លើយតបមកវិញ។ ។
-ពិបាកស្រាវជ្រាវរកឯកសារមួយចំនួន ពាក់ព័ន្ធនឹងសំណុំរឿងអនុវត្តដោយបង្ខំនៅមន្ទីរសុរិយោដី។

៣.២ សំណូមពរ

-ស្នើសុំកញ្ចប់ថវិកាបេសកកម្មបន្ថែម។

-ស្នើសុំសម្ភារៈការិយាល័យមានដូចជា ម៉ាស៊ីនហ្វូតូកូពី,កុំព្យូទ័រ,ម៉ាស៊ីនស្កេន និងទូដាក់ឯកសារ។
-ស្នើសុំមន្ត្រីក្របខណ្ឌ និងមន្ត្រីកិច្ចសន្យាបន្ថែមសម្រាប់បំពេញការងារតាមការិយាល័យនីមួយៗ។
-ស្នើសុំមន្ត្រីអាជ្ញាសាលា ០១ រូប ។
-ស្នើកិច្ចសហការល្អជាមួយអាជ្ញាធរពាក់ព័ន្ធ លើការអនុវត្តដីកាចាប់ ដីកានាំ និងដីកាមួយចំនួនក្នុងសំណុំរឿងអនុវត្តដោយបង្ខំ។

៤. ទិសដៅការងារសម្រាប់ឆ្នាំ ២០២៥

-ធ្វើការពង្រឹងលើការងាររដ្ឋបាលចុះបញ្ជីសំណុំរឿងព្រហ្មទណ្ឌតាមប្រព័ន្ធអេឡិចត្រូនិច(DATA BASE) ឲ្យស្របតាមអនុក្រឹត្យលេខ២១ អនក្រ.ប.ក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦។
-ធ្វើការគ្រប់គ្រងលើការងារចុះបញ្ជីសំណុំរឿងព្រហ្មទណ្ឌ និងរដ្ឋប្បវេណី ឱ្យបានពេញលេញនិងត្រឹមត្រូវតាមបែបបទថ្មី។
-ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នឭមាស និងប្រចាំឆ្នាំឲ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។
-ពង្រឹងការប្រជុំមន្ត្រីនគរបាលយុត្តិធម៌ អនុវត្តឱ្យបានត្រឹមត្រូវតាមតួនាទីមន្ត្រីនគរបាលយុត្តិធម៌និងឲ្យបានត្រឹមត្រូវតាមក្រមនីតិវិធីព្រហ្មទណ្ឌ។
-ជម្រុញឱ្យមន្ត្រីនគរបាលយុត្តិធម៌អនុវត្តគ្រប់ដីការបស់តុលាការឲ្យបានត្រឹមត្រូវ និងឆ្លើយតបមកតុលាការវិញអោយបានទាន់ពេលវេលា។
-ពន្លឿននីតិវិធីដល់ចៅក្រម និងព្រះរាជអាជ្ញារងឲ្យធ្វើការដោះស្រាយសំណុំរឿងឱ្យបានលឿន ត្រឹមត្រូវយុត្តិធម៌ និងមិនពុករលួយ។
-ត្រួតពិនិត្យមើលការឃុំខ្លួនបណ្តោះអាសន្ន ជៀសវាងការឃុំខ្លួនលើសនីតិវិធីច្បាប់កំណត់។
-ធ្វើការត្រួតពិនិត្យពន្ធនាគារជាប្រចាំ យ៉ាងហោចណាស់ឱ្យបានមួយខែម្តង។
-ធ្វើការតាមដាននៅការកកស្ទះសំណុំរឿងរបស់ចៅក្រមនីមួយៗ។
-ជំរុញការអនុវត្តការងាររបស់លោក-លោកស្រីក្រឡាបញ្ជី ក្នុងការធ្វើរបាយការណ៍ បញ្ជូនសាលក្រម និងកិច្ចការមួយចំនួនតាមការចាំបាច់ ឲ្យបានឆាប់រហ័ស និងទាន់ពេលវេលាមកលេខាធិការដ្ឋាន។
-ជំរុញឲ្យមន្ត្រីទទួលបន្ទុកបញ្ជូនសាលក្រមព្រហ្មទណ្ឌ ទៅក្រសួងឲ្យទាន់ពេលវេលា។
-ធ្វើការរៀបចំបែងចែកការងារក្នុងឆ្នាំ២០២៥ ដល់មន្ត្រីលេខាធិការដ្ឋានរដ្ឋបាលឲ្យស្របតាមអនុក្រឹត្យលេខ២១អនក្រ.បក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅលេខាធិការដ្ឋានរដ្ឋបាលខេត្តប៉ៃលិនឲ្យមានប្រសិទ្ធិភាពខ្ពស់។
-ពិនិត្យ និងយកចិត្តទុកដាក់ក្នុងការដោះស្រាយសំណុំរឿងអាទិភាពដូចជា សំណុំរឿងពាក់ព័ន្ធនឹងបទល្មើសគ្រឿង ញៀនសំណុំរឿងពាក់ព័ន្ធនឹងបទល្មើសគ្រោះថ្នាក់ចរាចរណ៍ និងសំណុំរឿងពាក់ព័ន្ធនឹងអត្រានុកូលដ្ឋាន។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលជ្រាបជារបាយការណ៍ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ប៉ៃលិន, ថ្ងៃទី០២ ខែមករា ឆ្នាំ២០២៥
ប្រធានលេខាធិការដ្ឋានរដ្ឋបាល

ពិន សុមុខ

ថ្ងៃព្រហស្បតិ៍ ៤កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ប៉ៃលិន, ថ្ងៃទី០២ ខែមករា ឆ្នាំ២០២៥

ព្រះអជអាជ្ញា

អេង ឃុនច័យ

ប្រធានសាលាដំបូង

គីម មេង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង និងអយ្យការអម
សាលាដំបូងខេត្តឧត្តរមានជ័យ

របាយការណ៍ការងារសង្ខេបរបស់សាលាដម្រះក្តី
សម្រាប់សន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារអាទិភាព ឆ្នាំ២០២៥
សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ

១. ស្ថានភាពទូទៅ

ក-ធនធានមនុស្ស

ល.រ	មុខតំណែង	ចំនួន	ស្រី	ជនពិការ
១.សាលាដំបូង		**សរុប ៧រូប**	**សរុប ២រូប**	**សរុប ០រូប**
១	ប្រធានសាលាដំបូង	១រូប	០រូប	
២	អនុប្រធានសាលាដំបូង	១រូប	០រូប	
៣	ចៅក្រម	០៥រូប	២រូប	
២.អយ្យការអមសាលាដំបូង		**សរុប ០៤រូប**	**សរុប ០រូប**	**សរុប ០រូប**
១	ព្រះរាជអាជ្ញា	១រូប	០ស្រី	
២	ព្រះរាជអាជ្ញារង	៣រូប	០រូប	
៣.ក្រឡាបញ្ជី		**សរុប ១៣រូប**	**សរុប ៤រូប**	**សរុប ០រូប**
១	ក្រឡាបញ្ជីតុលាការ	៨រូប	២រូប	
២	ក្រឡាបញ្ជីអយ្យការ	៤រូប	១រូប	
៣	ក្រឡាបញ្ជីកម្មសិក្សា	១រូប	១រូប	
៤.អាជ្ញាសាលា		**សរុប ០រូប**	**សរុប ០រូប**	**សរុប ០រូប**
១	អាជ្ញាសាលា	០រូប	០រូប	
២	អាជ្ញាសាលាកម្មសិក្សា	០រូប	០រូប	
៥.លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង		**សរុប ៣២រូប**	**សរុប ១៥រូប**	**សរុប ០រូប**
១	ប្រធានលេខាធិការដ្ឋាន	១រូប	០រូប	
២	អនុប្រធានលេខាធិការដ្ឋាន	៤រូប	០រូប	
៣	ប្រធានការិយាល័យ	៣រូប	២រូប	
៤	អនុប្រធានការិយាល័យ	៧រូប	៤រូប	
៥	មន្ត្រីគ្រប់គ្រងរដ្ឋបាល "ក"	២រូប	០រូប	

៦	មន្ត្រីក្រមការ "ខ"	០រូប	០រូប	
៧	លេខាធិការ "គ"	០រូប	០រូប	
៨	មន្ត្រីកម្មសិក្សា	០រូប	០រូប	
៩	មន្ត្រីជាប់កិច្ចសន្យា	**១៥**រូប	**៩**រូប	

ខ-ហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន

សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យមាន៖

- ដីទំហំ(៦៥៤៦^{២})
- អគារសាលាដំបូង និងអយ្យការអមសាលាដំបូងចំនួន ០១ខ្នង ទំហំ(១៤មx៣៥មx២)
- រោងដាក់រថយន្តចំនួន ០១ខ្នងទំហំ (៣៣មx៣ម)
- អគារស្នាក់នៅចំនួន ០១ខ្នងទំហំ (៨មx៣៥មx៣)
  - បន្ទប់ស្នាក់នៅ ២ជាន់មានចំនួន ១៦បន្ទប់
  - សាលប្រជុំជាន់ផ្ទាល់ដីចំនួន ០១បន្ទប់ធំ
- អគារឃ្លាំងសំណុំរឿងចំនួន ០១ខ្នងទំហំ (៩មx៣២មx២)
  - ជាន់ទី១ឃ្លាំងដាក់សំណុំរឿង
  - ជាន់ផ្ទាល់ដីមានបន្ទប់ការិយាល័យចំនួន ០៤បន្ទប់ និងសាលប្រជុំតូច ចំនួន ០១បន្ទប់
- អគារលេខាធិការដ្ឋានរដ្ឋបាលចំនួន ០១ខ្នងទំហំ (១០មx២៧មx២)
  - បន្ទប់ការិយាល័យមានចំនួន ០៨បន្ទប់ និងសាលប្រជុំជាន់ទី១ចំនួន ០១បន្ទប់។

គ-ព្រឹត្តិការណ៍ ឬកម្មវិធីការងារនានា

- ថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៤ ឯកឧត្តម **អ៊ុំ ចាន់ថុល** ប្រធានសាលាដំបូងខេត្ត ឯកឧត្តម **តូច សុកក្តី** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ និងលោក **ហែល ឆេងហុង** ប្រធានលេខាធិការដ្ឋានរដ្ឋបាល បានចូលរួមសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ នៅសាលាឧទ្ធរណ៍បាត់ដំបង។

- ថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ ឯកឧត្តម **អ៊ុំ ចាន់ថុល** ប្រធានសាលាដំបូងខេត្ត ឯកឧត្តម **តូច សុកក្តី** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ និងលោក **ហែល ឆេងហុង** ប្រធានលេខាធិការដ្ឋានរដ្ឋបាល បានចូលរួមកិច្ចប្រជុំស្តីពីការផ្សព្វផ្សាយ និងណែនាំអំពីការអនុវត្តយុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីតាមតុលាការ និងយុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** នៅទីស្តីការក្រសួងយុត្តិធម៌។

- ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៤ ឯកឧត្តម **អ៊ុំ ចាន់ថុល** ប្រធានសាលាដំបូងខេត្ត ឯកឧត្តម **តូច សុកក្តី** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ និងលោក **ហែល ឆេងហុង** ប្រធានលេខាធិការដ្ឋានរដ្ឋបាលបានជួបប្រជុំស្តីពីការអនុវត្តយុទ្ធនាការជម្រុញ និងពន្លឿនការដោះស្រាយរឿងក្តី

នៅសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ ក្រោយអធិបតីភាព ឯកឧត្តម **សូរ ចាន់ធី** រដ្ឋលេខាធិការក្រសួងយុត្តិធម៌។

- ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៤ ឯកឧត្តម **អ៊ុំ ចាន់ថុល** ប្រធានសាលាដំបូងខេត្ត ឯកឧត្តម **តូច សុកក្តី** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ និងលោក **ហៃ ឆេងហុង** ប្រធានលេខាធិការដ្ឋានរដ្ឋបាល បានចូលរួមមហាសន្និបាទបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ទូទាំងប្រទេសឆ្នាំ២០២៣ និងកំណត់ទិសដៅការងារអាទិភាពបន្តឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** នៅទីស្តីការក្រសួងយុត្តិធម៌។

- ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ឯកឧត្តម **អ៊ុំ ចាន់ថុល** ប្រធានសាលាដំបូងខេត្ត ឯកឧត្តម **តូច សុកក្តី** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ បានចូលរួមកិច្ចកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅផែនការឆ្នាំ២០២៤ របស់ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី។

- ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៤ ឯកឧត្តម **អ៊ុំ ចាន់ថុល** ប្រធានសាលាដំបូងខេត្ត ឯកឧត្តម **តូច សុកក្តី** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ បានចូលរួមកិច្ចប្រជុំស្តីពីការពិនិត្យនិងពិភាក្សាអំពីការងារពាក់ព័ន្ធនឹងចំណាត់ការលើក្មេងទំនើងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** នៅទីស្តីការក្រសួងយុត្តិធម៌។

- ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៤ ឯកឧត្តម **អ៊ុំ ចាន់ថុល** ប្រធានសាលាដំបូងខេត្ត ឯកឧត្តម **តូច សុកក្តី** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ និងលោក **ហៃ ឆេងហុង** ប្រធានលេខាធិការដ្ឋានរដ្ឋបាល បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក។

- ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤ ឯកឧត្តម **អ៊ុំ ចាន់ថុល** ប្រធានសាលាដំបូងខេត្ត ឯកឧត្តម **តូច សុកក្តី** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ បានចូលរួមកិច្ចប្រជុំការងារបន្ទាន់ទូទាំងសាលាជម្រះក្តី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** នៅទីស្តីការក្រសួងយុត្តិធម៌។

- ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៤ ឯកឧត្តម **អ៊ុំ ចាន់ថុល** ប្រធានសាលាដំបូងខេត្ត ឯកឧត្តម **តូច សុកក្តី** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ និងលោក **ហៃ ឆេងហុង** ប្រធានលេខាធិការដ្ឋានរដ្ឋបាលបានជួបប្រជុំស្តីពីការជំរុញការអនុវត្តយុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តី នៅសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ ក្រោយអធិបតីភាព ឯកឧត្តម **សម ប៊ុនថុន** ប្រធានសាលាឧទ្ធរណ៍បាត់ដំបង និងឯកឧត្តមបណ្ឌិត **នួន សាន** អគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង។

- ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៤ ឯកឧត្តម **អ៊ុំ ចាន់ថុល** ប្រធានសាលាដំបូងខេត្ត ឯកឧត្តម **តូច សុកក្តី** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ និងលោក **ហៃ ឆេងហុង** ប្រធានលេខាធិការដ្ឋានរដ្ឋបាល បានចូលរួមសិក្ខាសាលាស្តីពីកម្មវិធីកែទម្រង់ការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គាំទ្រវិស័យយុត្តិធម៌ និងកម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** នៅទីស្តីការក្រសួងយុត្តិធម៌។

២. សមិទ្ធផលការងារ

ក. អយ្យការអមសាលាដំបូង៖

ក.១-ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌ

បរិយាយ	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	សល់កំពុងចាត់ការ
ប្រចាំឆ្នាំ២០២៤	៥៥	៤២៦	៤៧១	១០
ប្រចាំខែមករា ឆ្នាំ២០២៥	១០	២៧	១៧	២០
ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥	២០	៣៨	២៣	៣៥

ក.២-កិច្ចការពាក់ព័ន្ធនឹងការអនុវត្តទោស និងពន្ធនាគារ

ក.២.១-ការអនុវត្តទោសដោយព្រះរាជអាជ្ញា

បរិយាយ	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	សល់កំពុងចាត់ការ
ប្រចាំឆ្នាំ២០២៤	២៨៩	៤៨០	១៣៥	៦៣៤
ប្រចាំខែមករា ឆ្នាំ២០២៥	៦៣៤	៥៧	១៨	៦៧៣
ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥	៦៧៣	០៥	១៣	៦៦៥

ក.២.២-ពន្ធនាគារខេត្តឧត្តរមានជ័យ

ជនជាប់ឃុំ	ប្រចាំឆ្នាំ២០២៤		ប្រចាំខែមករា ឆ្នាំ២០២៥		ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥	
	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី
ជនត្រូវចោទ	៤១៦	២៤	៤១	០១	២៩	០៣
ជនជាប់ចោទ	៤០២	៣១	០៦	០០	១៦	០០
ពិរុទ្ធជន	៩១៦	៦៨	១១៤	០៧	៨៣	០៣
ទណ្ឌិត	៤២៥	២២	៥២	០១	០០	០០
សរុបរួម	**២១៥៩**	**១៤៥**	**២១៣**	**០៩**	**១២៨**	**០៦**

ខ. សាលាដំបូង៖

ខ.១-ចំណាត់ការលើសំណុំរឿងព្រហ្មទណ្ឌ

ខ.១.១-ដំណាក់កាលស៊ើបសួរ

បរិយាយ	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	សល់កំពុងចាត់ការ
ប្រចាំឆ្នាំ២០២៤	១៨៤	៣៤៤	៤៥៧	៧១
ប្រចាំខែមករា ឆ្នាំ២០២៥	៧១	២៧	១៨	៨០
ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥	៨០	១៦	១៨	៧៨

ខ.១.២-ដំណាក់កាលជំនុំជម្រះ

បរិយាយ	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	សល់កំពុងចាត់ការ
ប្រចាំឆ្នាំ២០២៤	៨២	៤៦១	៥៣០	១៣
ប្រចាំខែមករា ឆ្នាំ២០២៥	១៣	១៧	០២	២៨
ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥	២៨	២៤	០១	៥១

ខ.២-ចំណាត់ការលើសំណុំរឿងរដ្ឋប្បវេណី

បរិយាយ	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	សល់កំពុងចាត់ការ
ប្រចាំឆ្នាំ២០២៤	៥២២	១៤៥៨	១៦៦៤	៣១៦
ប្រចាំខែមករា ឆ្នាំ២០២៥	៣១៦	១៧០	២០១	២៨៥
ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥	២៨៥	១២២	១៣៦	២៧១

ខ.៣-ចំណាត់ការសំណុំរឿងអនុវត្ត

បរិយាយ	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	សល់កំពុងចាត់ការ
ប្រចាំឆ្នាំ២០២៤	៨៦	១៨	៥២	៥២
ប្រចាំខែមករា ឆ្នាំ២០២៥	៥២	០៦	០៣	៥៥
ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥	៥៥	០២	០២	៥៥

៣. បញ្ហាប្រឈម និងសំណូមពរ

- ខ្វះថវិកាក្នុងបេសកកម្មជួយមន្ត្រីដោយសារមន្ត្រីមានការប្រជុំច្រើននិងការងាររផ្សេងទៀត។
- មន្ត្រីរដ្ឋបាលមិនទាន់មានការទទួលខុសត្រូវលើការងាររបស់ខ្លួនឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។
- វត្ថុតាងមានច្រើនហើយមិនទាន់បានចាត់ចែងលក់ដូរឱ្យបានទាន់ពេលវេលា និងជាហេតុនាំឱ្យខូចខាតគុណភាពវត្ថុតាង និងមិនទាន់រកកន្លែងដាក់វត្ថុតាងឱ្យបានសមរម្យ។
- បញ្ហាស្ថាពរ និងការចូលស្ថាពរនៃសាលក្រមមិនទាន់បានទាន់ពេលវេលានៅឡើយ។
- ពុំមានអ្នកផ្តល់សេវាបកប្រែភាសារជាពិសេសភាសារគថ្លង់។
- ពុំមានអាជ្ញាសាលាដើម្បីចុះអនុវត្តជីកា/ការបញ្ជូនជីកា។
- ការបំពេញការងាររដ្ឋបាលនៅមិនទាន់គ្រប់ជ្រុងជ្រោយ និងខ្វះធនធានមនុស្សសម្រាប់បម្រើការងាររដ្ឋបាលឱ្យបានពេញលេញ និងពេញសមត្ថភាពដើម្បីសមស្របនឹងការងារ។
- ការចុះលេខលើសៀវភៅដំណាក់កាលអយ្យការ, សៀវភៅស៊ើបសួរ និងសៀវភៅដំនុំជម្រះនៅមានភាពខ្វះចន្លោះមិនទាន់អនុវត្តឱ្យបានពេញលេញនៅឡើយ។
- ការចេញសាលក្រម និងសេចក្តីសម្រេចផ្សេងៗនៅមានភាពយឺតយ៉ាវនៅឡើយ និងមានកំហុសបច្ចេកទេសមួយចំនួនពិសេសលេខសាលក្រម។
- ការបង្វិលជីកា ឬលិខិតផ្សេងៗពីសំណាក់មន្ត្រីនគរបាលយុត្តិធម៌នូវមានភាពយឺតយ៉ាវនៅឡើយ។

៤. ទិសដៅការងារសម្រាប់ឆ្នាំ ២០២៥

- បន្តពង្រឹងការគ្រប់គ្រងវត្តមានមន្ត្រីរដ្ឋបាល តាមរយៈការបន្តប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងវត្តមានស្កែនតាមរយៈ(QR Code)និងពង្រឹងការអនុវត្តកាតព្វកិច្ចការងាររបស់មន្ត្រីរដ្ឋបាលទាំងអស់ឱ្យបានរយៈពេល ៨ (ប្រាំបី) ម៉ោងក្នុងមួយថ្ងៃ និងចំនួន ៥ (ប្រាំ)ថ្ងៃក្នុងមួយសប្តាហ៍ ឬ៤០(សែសិប)ម៉ោងក្នុងសប្តាហ៍។

- បង្កើតក្រុមការងារជាមន្ត្រីជាប់កិច្ចសន្យាចំនួន ០៤រូប ដាច់ដោយឡែក ដើម្បីបញ្ចូលសំណុំរឿងព្រហ្មទណ្ឌឱ្យចប់ត្រឹមខែ**មិថុនា** ឆ្នាំ២០**២៥** និងចាប់ផ្តើមបញ្ចូលទិន្នន័យសំណុំរឿងរដ្ឋប្បវេណីបន្តតាមផែនការរបស់ក្រសួងយុត្តិធម៌។
- សំណើសុំកញ្ចប់ថវិកាបន្ថែមសម្រាប់ចំណាយទូទាត់ថ្លៃបេសកកម្ម។
- សំណើសុំអាជ្ញាសាលាចំនួន ០១រូប។
- ជម្រុញដល់មន្ត្រីនគរបាលយុត្តិធម៌ និងមន្ទីរអង្គភាពពាក់ព័ន្ធដែលទទួលបន្ទុកអនុវត្តដីកាផ្សេងៗឱ្យមានប្រសិទ្ធភាព និងបង្ខិលដីកា ឬលទ្ធផលការងារត្រឡប់មកវិញឱ្យបានឆាប់រហ័ស និងទាន់ពេលវេលា ដើម្បីពង្រឹងការអនុវត្តច្បាប់។
- ពង្រឹងយន្តការត្រួតពិនិត្យ តាមដាន និងជម្រុញការអនុវត្តការងារ និងពង្រឹងក្រមសីលធម៌វិជ្ជាជីវៈចៅក្រម ព្រះរាជអាជ្ញារង ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាលទាំងអស់ឱ្យម៉ឺងម៉ាត់ និងហ្មត់ចត់ឡើងវិញ។
- បន្តពង្រឹងទំនាក់ទំនង កិច្ចសហការ និងសាមគ្គីផ្ទៃក្នុងអង្គភាពរវាងតុលាការ និងអយ្យការ និងលេខាធិការដ្ឋានរដ្ឋបាលឱ្យកាន់តែរឹងមាំ។
- បន្តពន្លឿនការដោះស្រាយសំណុំរឿងទាំងអស់ពិសេសសំណុំរឿងអត្រានុកូលដ្ឋាន, សំណុំរឿងចរាចរណ៍, សំណុំរឿងគ្រឿងញៀន, និងសំណុំរឿងក្មេងទំនើងឱ្យបានឆាប់រហ័ស ម៉ឺងម៉ាត់ ត្រឹមត្រូវតាមច្បាប់ និងស្អាតស្អំ។
- ពង្រឹងការចេញសាលក្រមឱ្យបានលឿន និងទាន់ពេលវេលា។

ថ្ងៃពុធ ៧កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ឧត្តរមានជ័យ, ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៥
ប្រធានលេខាធិការដ្ឋានរដ្ឋបាល

ហោល ឆេងហុច

បានឃើញ និង ឯកភាព
ថ្ងៃពុធ ៧កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ឧត្តរមានជ័យ, ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៥

ព្រះរាជអាជ្ញា

ភួច សុភក្តី

ប្រធានសាលាដំបូង

ស៊ុំ ចាន់ថុល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង និងអយ្យការអម
សាលាដំបូងខេត្តបន្ទាយមានជ័យ
លេខ...៧០៧.....របាយការណ៍ការងារសរុបលទ្ធផលការងារវិស័យយុត្តិធម៌ ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារអនាគត ឆ្នាំ២០២៥
សាលាដំបូងខេត្តបន្ទាយមានជ័យ និងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ

១. ស្ថានភាពទូទៅ

ក- ធនធានមនុស្ស

ល.រ	មុខតំណែង	ចំនួន	ស្រី
១.សាលាដំបូង		**សរុប ១២រូប**	
១	ប្រធានសាលាដំបូង	១រូប	០រូប
២	អនុប្រធានសាលាដំបូង	៣រូប	០រូប
៣	ចៅក្រម	៨រូប	១រូប
២.អយ្យការអមសាលាដំបូង		**សរុប ៩រូប**	
១	ព្រះរាជអាជ្ញា	១រូប	០រូប
២	ព្រះរាជអាជ្ញារង	៨រូប	០រូប
៣	ព្រះរាជអាជ្ញារងកម្មសិក្សា	០រូប	០រូប
៣.ក្រឡាបញ្ជី		**សរុប ២៩រូប**	
១	ក្រឡាបញ្ជីតុលាការ	១៦រូប	៦រូប
២	ក្រឡាបញ្ជីអយ្យការ	៨រូប	០រូប
៣	ក្រឡាបញ្ជីកម្មសិក្សា	៥រូប	១រូប
៤.អាជ្ញាសាលា		**សរុប ០០រូប**	
១	អាជ្ញាសាលា	០រូប	០រូប
៥.លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង		**សរុប ៤៥រូប**	
១	ប្រធានលេខាធិការដ្ឋាន	១រូប	០រូប
២	អនុប្រធានលេខាធិការដ្ឋាន	៣រូប	២រូប
៣	ប្រធានការិយាល័យ	៤រូប	៣រូប
៤	អនុប្រធានការិយាល័យ	៥រូប	១រូប
៥	មន្ត្រីគ្រប់គ្រងរដ្ឋបាល "ក"	៦រូប	៥រូប
៦	មន្ត្រីក្រមការ "ខ"	០រូប	០រូប
៧	លេខាធិការ "គ"	២រូប	០រូប
៨	មន្ត្រីកម្មសិក្សា	៣រូប	២រូប

អាសយដ្ឋាន ៖ ភូមិគោរដ្ឋាន សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ (+៨៥៥) ៥៤ ៧១១ ៣៣៣ អ៊ីម៉ែល ៖ ad.bmccourt@gmail.com

៩	មន្ត្រីជាប់កិច្ចសន្យា	២១រូប	១១រូប

ខ- ហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន

សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ៖

- អាគារ៤ខ្នង ដី២ល្វែង១កន្លែង និងដីសម្រាប់ សង់ផ្ទះមុខងារ១កន្លែង

គ. លទ្ធផលសន្និបាតផ្ទៃក្នុងស្ថាប័នសម្រាប់ឆ្នាំ ២០២៤

ឃ. ព្រឹត្តិការណ៍ ឬកម្មវិធីការងារផ្សេងៗ

- ប្រជុំសាលាខេត្ត ចំនួន ៦៦លើក
- ប្រជុំមន្ទីរហិរញ្ញវត្ថុ ចំនួន ០១លើក
- ប្រជុំក្រសួងយុត្តិធម៌ ចំនួន ០៦លើក
- សិក្ខាសាលារាជបណ្ឌិតសភា ចំនួន ១១លើក

២. សមិទ្ធផលការងារ

ក. អយ្យការអមសាលាដំបូង៖

ក.១. **ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌ**

ប្រចាំឆ្នាំ/ខែ	រឿងសល់	ចូលថ្មី	ចាត់ការរួច	កំពុងចាត់ការ	ផ្សេងៗ
២០២៤	២៤២	២០២៥	២១៥៦	១១១	

ក.២. **កិច្ចការពាក់ព័ន្ធនឹងការអនុវត្តទោស និងពន្ធនាគារ**

ប្រចាំឆ្នាំ/ខែ	អនុវត្តសេចក្តីសម្រេច	ដោះលែងទណ្ឌិត	ទណ្ឌិតអនុវត្តទោស	ផ្សេងៗ
២០២៤	៧៤១	៦៥៣	៣០៩	

ក.៣. **កិច្ចការពាក់ព័ន្ធជាមួយនឹងមន្ត្រីនគរបាលយុត្តិធម៌**

.ចុះអធិការកិច្ចពន្ធនាគារ បានចំនួន៖ ១២ លើក

.ប្រជុំមន្ត្រីនគរបាលយុត្តិធម៌ បានចំនួន៖ ០២ លើក

.ចេញដីការអនុញ្ញាតឲ្យបើកអង្កេតបឋម បានចំនួន៖ ១៧៥ រឿង

.ចេញដីកាបញ្ជាឲ្យចូលខ្លួន បានចំនួន៖ ១៤ លើក

ក.៤. **កិច្ចការផ្សេងទៀតរបស់ស្ថាប័នអយ្យការ** (ប្រសិនបើមាន)

ខ. សាលាដំបូង៖

ខ.១. **ចំណាត់ការលើសំណុំរឿងព្រហ្មទណ្ឌ**

ខ.១.១. **ដំណាក់កាលស៊ើបសួរ**

ប្រចាំ	រឿងសល់	ចូលថ្មី	ចាត់ការរួច	កំពុងចាត់ការ	ផ្សេងៗ
២០២៤	៤៤៤	១៣៤២	១៦៣១	១៥៥	

ខ.១.២. **ដំណាក់កាលជំនុំជម្រះ**

ប្រចាំ	រឿងសល់	ចូលថ្មី	ចាត់ការរួច	កំពុងចាត់ការ	ផ្សេងៗ
២០២៤	១៧៩	១២៩៩	១៤១៩	៥៩	

ខ.២. **ចំណាត់ការលើសំណុំរឿងរដ្ឋប្បវេណី**

ខ.២.១. **ចំណាត់ការលើសំណុំរឿងរដ្ឋប្បវេណីអង្គសេចក្តី**

ប្រចាំ	រឿងសល់	ចូលថ្មី	ចាត់ការរួច	កំពុងចាត់ការ	ផ្សេងៗ
២០២៤	៤៧៣	៦៦០	៩៣៥	១៩៨	

ខ.២.២. **ចំណាត់ការលើសំណុំរឿងរដ្ឋប្បវេណីរក្សាការពារ**

ប្រចាំ	រឿងសល់	ចូលថ្មី	ចាត់ការរួច	កំពុងចាត់ការ	ផ្សេងៗ
២០២៤	២២	៨៤	៩៩	៧	

ខ.២.៣. **ចំណាត់ការលើសំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹង**

ប្រចាំ	រឿងសល់	ចូលថ្មី	ចាត់ការរួច	កំពុងចាត់ការ	ផ្សេងៗ
២០២៤	១៧០	១៨៤៦	១៩៨១	៣៥	

ខ.២.៤. **ចំណាត់ការសំណុំរឿងផ្សេងទៀត**

ប្រចាំ	រឿងសល់	ចូលថ្មី	ចាត់ការរួច	កំពុងចាត់ការ	ផ្សេងៗ
២០២៤	៣០២	១៤៨	១៧២	២៧៨	០

ខ.៣. **កិច្ចការផ្សេងទៀតរបស់សាលាដំបូង (ប្រសិនបើមាន)**

៣. បញ្ហាប្រឈម និងសំណូមពរ

ក.បញ្ហាប្រឈម

- **ដំណាក់កាលអយ្យការ ស៊ើបសួរ និងជំនុំជម្រះ:**

-ចំនួនក្រឡាបញ្ជីនៅមានភាពខ្វះខាត មិនទាន់ឆ្លើយតបទៅនឹងការកើនឡើងនៃតួលេខសំណុំរឿងក្តីនៅឡើយ។

-មិនទាន់មានមន្ត្រីអាជ្ញាសាលាទទួលបន្ទុកការងារអនុវត្ត។

-ការបញ្ជូនដីកា ឬលិខិតជូនដំណឹងផ្សេងៗក្នុងរឿងក្តីព្រហ្មទណ្ឌភាគច្រើនមិនបានលទ្ធផលត្រឡប់មកវិញ ព្រោះលំនៅដ្ឋានខ្លះឆ្ងាយដាច់ស្រយាល និងភាគច្រើនភាគី គឺជាជនចំណាកស្រុក ឬចាកចេញពីមូលដ្ឋាន (បាត់ខ្លួនតែម្តង) បណ្តាលឲ្យសំណុំរឿងកកស្ទះ ។

-ការធ្វើកោសលវិច័យផ្សេងៗ ពិសេសទាក់ទិននឹងបទល្មើសគ្រឿងញៀនត្រូវការពេលវេលាយូរ នាំឲ្យប៉ះពាល់ដល់ ការឃុំខ្លួនជនត្រូវចោទ និងប៉ះពាល់ដល់ការសម្រេចសេចក្តី។

-បញ្ហាស្រាវជ្រាវអត្តសញ្ញាណ (ក្នុងរឿងព្រហ្មទណ្ឌ) ពុំទទួលបានលទ្ធផលនៃការស្រាវជ្រាវ។

-ការអនុវត្តដីកាឲ្យដំណឹងពី សាលក្រមកំបាំងមុខនៅមានការលំបាកច្រើន ដោយមន្ត្រីនគរបាលយុត្តិធម៌ ពុំបានបញ្ជូនដីកានេះមកតុលាការវិញឲ្យបានគ្រប់ចំនួន ដែលធ្វើឲ្យតុលាការពិបាកក្នុងការបញ្ជាក់ពីសាលក្រមចូលស្តាពរចំពោះដើមបណ្តឹង និងជនជាប់ចោទកំបាំងមុខ។

-បញ្ហាក្នុងការប្រមូលចំណូលលើប្រាក់ពិន័យ ដោយសារទណ្ឌិតខ្លះពុំមានប្រាក់សម្រាប់បង់ និងពុំមានឯកសារ បញ្ជាក់ពីធនធាន ដែលអាចរឹបអូសលក់ឡាយឡុងតាមនីតិវិធី។

-ការយល់ដឹងរបស់ភាគីនៅមានកម្រិត។

-វត្ថុតាងគ្រប់ប្រភេទពុំទាន់បាន ចាត់ចែងតាមអំណាចសាលក្រមស្ថាពរ ជាហេតុបណ្តាលឲ្យកកស្ទះ ធ្វើឲ្យវត្ថុតាង ទាំងនោះខូចគុណភាព និងតម្លៃក្នុងការប្រមូលថវិកាចូលរដ្ឋ។

❖ **ការងាររលេខាធិការដ្ឋានរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងកិច្ចការអយ្យការ**

-កិច្ចការរដ្ឋបាលមួយចំនួនមិនទាន់អនុវត្តឲ្យបានរលូនតាមអនុក្រឹតលេខ ២១ អនក្រ.បក ចុះថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ ២០១៦ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង។

-ខ្វះអគារស្នាក់នៅសម្រាប់ចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ដែលមានសុវត្ថិភាពល្អប្រសើរ។

-ខ្វះឥណទានបៀវត្សប្រចាំឆ្នាំ ដោយមន្ត្រីផ្ទេរចេញ-ចូល ក្រោយការគ្រោងថវិកាបៀវត្ស។

-ការបូកសរុបរបាយការណ៍មិនបានទាន់ពេលវេលាតាមការស្នើសុំរបស់ក្រសួងយុត្តិធម៌ ដោយហេតុថាការបញ្ជូនរបាយការណ៍មកការិយាល័យកិច្ចការតុលាការមានការយឺតយ៉ាវ។

-សំណុំរឿងក្តីចាត់ការរួចភាគច្រើនមិនបានបញ្ចូលទៅក្នុងឃ្លាំងរក្សាទុកឲ្យបានត្រឹមត្រូវ។

-ការយឺតយ៉ាវក្នុងការអនុវត្តកិច្ចលទ្ធកម្ម ដោយសាររង់ចាំផែនការលទ្ធកម្មប្រចាំឆ្នាំ។

-ការចំណាយទទួលភ្ញៀវជាតិ ពុំទាន់មានគោលការណ៍ច្បាស់លាស់សម្រាប់ការទូទាត់។

-មិនមានកញ្ចប់ឥណទានថវិកាសម្រាប់រៀបចំពិធីបុណ្យជាតិសំខាន់ៗ ដែលអាជ្ញាធរខេត្តតម្រូវឲ្យចូលរួមជាកាតព្វកិច្ចខានមិនបាន ដូចជា៖ ពិធីបុណ្យអុំទូក ជាដើម។

-ខ្វះខាតមធ្យោបាយធ្វើដំណើរបំពេញការងាររដ្ឋបាល និងចំណាត់ការសំណុំរឿង។

-គ្មានដីសម្រាប់ដាក់វត្ថុតាង ដោយសព្វថ្ងៃនេះ សាលាដំបូងខេត្ត បានជួលដីសម្រាប់ទុកដាក់វត្ថុតាងមួយចំនួន ដូចជា៖ រថយន្ត និងម៉ូតូ គឺមិនមានដំបូល ដែលជាហេតុធ្វើឲ្យវត្ថុតាងទាំងនោះបាត់បង់គុណភាពស្ទើរតែទាំងស្រុង។

-ការលក់ឡាយឡុងវត្ថុតាង ដែលរឹបអូសជាសម្បត្តិរដ្ឋមិនទាន់បានអនុវត្ត។

-ដីកាកោះរបស់សាលាឧទ្ធរណ៍ ដែលឲ្យក្រឡាបញ្ជីសាលាដំបូងបញ្ជូនឲ្យសាមីភាគីពុំមានសោហ៊ុយ។

ខ.សំណូមពរ

-ស្នើសុំផ្តល់បន្ថែមក្រឡាបញ្ជី ដើម្បីឲ្យសមស្របទៅតាមចំនួនរឿងក្តី ដែលកំពុងកើនឡើង ។

-ស្នើសុំមន្ត្រីអាជ្ញាសាលាចំនួនពីរ (០២) រូប ដើម្បីទទួលបន្ទុកការងារអនុវត្ត។

-ស្នើសុំមន្ត្រីលេខាធិការដ្ឋានចំនួនដប់ (១០)រូប និងមន្ត្រីជាប់កិច្ចសន្យាចំនួនដប់(១០)រូប ។

-ស្នើសុំផ្តល់មធ្យោបាយធ្វើដំណើរ និងបំពេញការងាររដ្ឋបាល និងចំណាត់ការសំណុំរឿង។

-ស្នើសុំទីតាំងដីសម្រាប់ដាក់វត្ថុចាប់យក។

-ស្នើសុំគោលការណ៍អនុញ្ញាត សម្រាប់ការលក់ឡាយឡុងវត្ថុតាង ដែលរឹបអូសជាសម្បត្តិរដ្ឋឲ្យបានឆាប់រហ័ស។

៤. ទិសដៅការងារសម្រាប់ឆ្នាំ ២០២៥

ទោះបីសាលាដំបូង និងអយ្យការអមសាលាដំបូង បានជួបប្រទះការលំបាកមួយចំនួនក្តី ក៏យើងខ្ញុំបានប្តេជ្ញាចិត្តខិតខំជំនះរាល់ឧបសគ្គ និងដាក់ចេញនូវទិសដៅអនុវត្តបន្ត ដូចខាងក្រោម៖

-ធ្វើចំណាត់ការនីតិវិធី និងរកយុត្តិធម៌ឲ្យបានកាន់តែល្អប្រសើរ និងឆាប់រហ័សជូនភាគីនៃរឿងក្តី។

-ប្រឹងប្រែងឲ្យអស់សមត្ថភាពចាត់ការសំណុំរឿងព្រហ្មទណ្ឌ សំណុំរឿងរដ្ឋប្បវេណីចាស់ៗ និងថ្មីឲ្យបានកាន់តែឆាប់រហ័ស។

-បន្តពង្រឹងសាមគ្គីភាពផ្ទៃក្នុង ក្រមសីលធម៌ និងអនុវត្តរាល់កិច្ចការតុលាការគំរូ ដែលបានអនុវត្តកន្លងមក ឲ្យកាន់តែល្អប្រសើរ។

-បន្តអនុវត្តតាមអភិក្រម **លឿន ត្រឹមត្រូវ យុត្តិធម៌ និងមិនពុករលួយ** ។

-គោរពពេលវេលាធ្វើការ មានក្រមសីលធម៌ និងវិន័យការងារឲ្យបានល្អប្រសើរ។

-ការប្រើប្រាស់ពាក្យសម្តីល្អៗ និងឥរិយាបថការងារប្រកបដោយភាពថ្លៃថ្នូរចំពោះភាគី និងអ្នកពាក់ព័ន្ធ។

-បន្តយកចិត្តទុកដាក់ចាត់ការជាអាទិភាពចំពោះរឿងក្តីព្រហ្មទណ្ឌ ដែលមានជនជាប់ឃុំជាកុមារនិងស្ត្រី។

-ដាក់ផែនការដោះស្រាយសំណុំរឿងអនុវត្តដោយបង្ខំ។

-ចាត់ការរឿងក្តីទំនាស់ដីធ្លីប្រកបដោយយុត្តិធម៌ និងមានភាពច្បាស់លាស់ចំពោះទីតាំងដីទំនាស់ និងការពិនិត្យ កស្តុតាង និងឯកសារផ្សេងៗ។

-ការពង្រឹងសមត្ថភាពបន្ថែម និងពង្រឹងសាមគ្គីភាពផ្ទៃក្នុង និងបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ច។

-បន្តជម្រុញចំណាត់ការសំណុំរឿងគ្រឿងញៀនឲ្យបានឆាប់រហ័ស ។

-បន្តខិតខំជូនដំណឹងសាលក្រមកំបាំងមុខ ដើម្បីឲ្យបានចំណារស្ថាពរយកទៅអនុវត្ត។

-បន្តរៀបចំកិច្ចប្រជុំការងាររដ្ឋបាល និងបច្ចេកទេសជាប្រចាំខែរវាងចៅក្រម តំណាងអយ្យការ ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាលឲ្យបានទៀងទាត់។

-បន្តដាក់កម្មវិធីប្រជុំជាមួយមន្ត្រីនគរបាលយុត្តិធម៌ និងមន្ទីរពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាប្រឈមនានាឲ្យបានទាន់ពេលវេលា។

-បន្តប្រមូលសាលក្រមព្រហ្មទណ្ឌ ដែលមិនទាន់បញ្ជូនមកលេខាធិការដ្ឋានរដ្ឋបាល។

-ជម្រុញចំណាត់ការរឿងចូលឃ្លាំងឱ្យបានឆាប់រហ័ស។

-បន្តការងារវត្តចាប់យកដោយស្រង់បញ្ជីជាប្រចាំខែ និងធ្វើឆ្លងផ្ទាត់ ព្រមទាំងធ្វើបច្ចុប្បន្នភាព។

-ពង្រឹងការងារបញ្ជីប្រចាំខែ របាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំ០៩ខែ និងប្រចាំឆ្នាំ ឲ្យមានភាពត្រឹមត្រូវ និងទាន់ពេលវេលា។

-ធ្វើការស្រាវជ្រាវច្បាប់បន្ថែម ដើម្បីពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់។

-បន្តពង្រឹងសាមគ្គីភាពផ្ទៃក្នុងនិងសហការជាមួយអង្គភាពពាក់ព័ន្ធ។

-តុលាការ ត្រូវតែជាទីកន្លែងដែលប្រជាពលរដ្ឋ អាចជឿទុកចិត្ត និងកាន់តែមានជំនឿទុកចិត្ត។

-តុលាការ មានដំណើរការប្រកបដោយតម្លាភាព សមត្ថភាព និងប្រសិទ្ធភាព។

-ចៅក្រម ព្រះរាជអាជ្ញារង ក្រឡាបញ្ជី និងមន្ត្រីលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ត្រូវតែមានមុខជំនាញវិជ្ជាជីវៈ និងការយល់ដឹងខ្ពស់។

-ការស៊ើបសួរ និងដោះស្រាយរឿងក្តីរបស់តុលាការត្រូវបានធ្វើឡើងដោយមិនលំអៀង យុត្តិធម៌ និងប្រកបដោយវិជ្ជាជីវៈ។

-ចូលរួមអនុវត្តរាល់ទិសដៅផែនការសកម្មភាព នៃគោលនយោបាយកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ឲ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃអង្គារ ៦កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅបន្ទាយមានជ័យ, ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៥

ប្រធានលេខាធិការដ្ឋានរដ្ឋបាល

ធឿន ៖ ធីណា

បានឃើញ និង ឯកភាព

ថ្ងៃអង្គារ ៦កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅបន្ទាយមានជ័យ, ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៥

ប្រធានសាលាដំបូង

សុខ ៖ ភុន្នី

ព្រះរាជអាជ្ញា

អ៊ឹក ៖ ទណ្ឌារ័ត្ន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង និងអយ្យការអម
សាលាដំបូងខេត្តសៀមរាប

របាយការណ៍ការងារសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥

សម្រាប់សន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ ឆ្នាំ២០២៤ និងកំណត់ទិសដៅការងារអាទិភាព ឆ្នាំ២០២៥

សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តសៀមរាប

==========

១. ស្ថានភាពទូទៅ

ក- ធនធានមនុស្ស

-ប្រធានសាលាដំបូង អនុប្រធានសាលាដំបូង និងចៅក្រម	ចំនួន ១៥រូប
-ព្រះរាជអាជ្ញា-ព្រះរាជអាជ្ញារង	ចំនួន ១១រូប
-ក្រឡាបញ្ជី	ចំនួន ៥៣រូប
-អាជ្ញាសាលា	ចំនួន ០២រូប
-មន្ត្រីលេខាធិការដ្ឋានរដ្ឋបាល	ចំនួន ៥៤រូប

ខ- ហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន

បច្ចុប្បន្ន សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តសៀមរាប មានអាគារចំនួន ០៣ខ្នង។ អាគារទីមួយត្រូវបានសាងសង់រួចរាល់នៅឆ្នាំ២០០៦ អាគារទីពីរត្រូវបានសាងសង់រួចរាល់នៅឆ្នាំ២០១៦ និងអាគារទីបីត្រូវបានសាងសង់រួចរាល់នៅឆ្នាំ២០២១៩។

គ. លទ្ធផលសន្និបាតផ្ទៃក្នុងស្ថាប័នសម្រាប់ឆ្នាំ ២០២៤

នៅថ្ងៃចន្ទ ៨កើត ខែបុស្ស ឆ្នាំរោង ឆស័ក ពស.. ២៥៦៨ ត្រូវនឹងថ្ងៃទី០៦ ខែមករា ឆ្នាំ២០២៥ វេលាម៉ោង ០៨ និង ៣០នាទីព្រឹក សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តសៀមរាប បានរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៤ និងកំណត់ទិសដៅការងារឆ្នាំ២០២៥ ក្រោមអធិបតីភាព ឯកឧត្តម **ហុក ង៉ាន់ឆ៊ីណា** ប្រធានសាលាដំបូង ឯកឧត្តម **មាស ច័ន្ទពិសិដ្ឋ** ព្រះរាជអាជ្ញា អមសាលាដំបូងខេត្តសៀមរាប និងលោក **ច័ន្ទ សត្ថា** អគ្គនាយករង នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ និងជាតំណាងក្រសួងយុត្តិធម៌។ អង្គសន្និបាតនេះ មានសមាសភាពអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តសៀមរាប សរុបចំនួន ១៣៣នាក់។

ឃ. ព្រឹត្តិការណ៍ ឬកម្មវិធីការងារឆ្លង (កិច្ចប្រជុំ ឬជំនួបពិភាក្សាការងារជាមួយស្ថាប័នពាក់ព័ន្ធ ជាអាទិ៍ សាលាខេត្ត, ពន្ធនាគារ, មន្ត្រីនគរបាលយុត្តិធម៌, ប្រតិភូ ឬក្រុមការងាររបស់ក្រសួងយុត្តិធម៌...) បានចំនួន ៣៦៤លើក ។

២. សមិទ្ធផលការងារ

ក. អយ្យការអមសាលាដំបូង៖

ក.១. ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌ

ល.រ	សំណុំរឿងព្រហ្មទណ្ឌ	សស់ពីមុន	ចូលថ្មី	ចាត់ការរួច	កំពុងចាត់ការ
០១	សំណុំរឿងព្រហ្មទណ្ឌឆ្នាំ២០២៤	២៨៣	១៦១២	១២៩៧	២៨

ក.២. កិច្ចការពាក់ព័ន្ធនឹងការអនុវត្តទោស និងពន្ធនាគារ

-ទិន្នន័យសរុបអ្នកជាប់ពន្ធនាគារ សរុបមានចំនួន ២២៦៦នាក់ ។

-ការអនុវត្តដោះលែងតាមសាលក្រម និងសាលដីកា បានចំនួន **៧១៥នាក់** ។

-ការអនុវត្តទណ្ឌិតពិន័យជាប្រាក់ចូលថវិការដ្ឋមានចំនួន **១០៦នាក់** ទទួលប្រាក់ពិន័យចូលរដ្ឋចំនួន **២៦នាក់** ស្មើនឹង **៩៧,៧០០,០០០** (កៅសិបប្រាំពីរលានប្រាំពីរសែន)រៀល ។

-ការចុះពិនិត្យពន្ធនាគារ គឺចុះពិនិត្យមួយខែម្តង សរុបមានចំនួន **១២ដង ក្នុងមួយឆ្នាំ** ។

-ការបន្ធូរបន្ថយទោស និងលើកលែងទោស មានចំនួន ០៣លើក សរុបចំនួន **១៨នាក់** (**ស្រី០២នាក់**) ។

ក.៣. កិច្ចការពាក់ព័ន្ធជាមួយនឹងមន្ត្រីនគរបាលយុត្តិធម៌

ល.រ	អង្គភាពនគរបាលយុត្តិធម៌	ស្នើសុំស៊ើបអង្កេតបឋម (រឿង)	ដីកាបញ្ជាឲ្យចូលខ្លួន (រឿង)
	សរុប	៣២៦រឿង	៥រឿង

ក.៤. កិច្ចការផ្សេងទៀតរបស់ស្ថាប័នអយ្យការ (ប្រសិនបើមាន)

-ការបញ្ជូនសាលក្រមទៅពន្ធនាគារខេត្តសៀមរាបមានចំនួន **១២២៥សាលក្រម** ។

-ការបញ្ជូនសាលក្រមទៅសាលាឧទ្ធរណ៍មានចំនួន **១២៤៣សាលក្រម** ។

-ការបញ្ជូនជនសង្ស័យទៅមជ្ឈមណ្ឌលអប់រំកែប្រែ និងស្ថានីតិសម្បទា សរុបចំនួន **១៨៦នាក់** ។

ខ. សាលាដំបូង៖

ខ.១. ចំណាត់ការលើសំណុំរឿងព្រហ្មទណ្ឌ

ខ.១.១. ដំណាក់កាលស៊ើបសួរ

ល.រ	សំណុំរឿងព្រហ្មទណ្ឌស៊ើបសួរ	សស់ពីមុន	ចូលថ្មី	ចាត់ការរួច	កំពុងចាត់ការ
០១	សំណុំរឿងព្រហ្មទណ្ឌឆ្នាំ២០២៤	២៨៣	១២៥២	១២០៥	៣៣០

ខ.១.២. ដំណាក់កាលជំនុំជម្រះ

ល.រ	សំណុំរឿងព្រហ្មទណ្ឌជំនុំជម្រះ	សស់ពីមុន	ចូលថ្មី	ចាត់ការរួច	កំពុងចាត់ការ
០១	សំណុំរឿងព្រហ្មទណ្ឌឆ្នាំ២០២៤	១៤៥	១២៩៥	១២៥០	១៩០

ខ.២. ចំណាត់ការលើសំណុំរឿងរដ្ឋប្បវេណី

ល.រ	សំណុំរឿងរដ្ឋប្បវេណី	សស់ពីមុន	ចូលថ្មី	ចាត់ការរួច	កំពុងចាត់ការ
០២	សំណុំរឿងរដ្ឋប្បវេណីឆ្នាំ២០២៤	៦៦៦	៨៣០១	៨៣៧១	៥៩៦

ខ.៣. ចំណាត់ការសំណុំរឿងផ្សេងទៀត

ល.រ	សំណុំរឿងដោះលែងដោយមានលក្ខខណ្ឌ	សស់ពីមុន	ចូលថ្មី	ចាត់ការរួច	កំពុងចាត់ការ
០២	សំណុំរឿងឆ្នាំ២០២៤	០០	០១	០១	០០

ខ.៤. កិច្ចការផ្សេងទៀតរបស់សាលាដំបូង (ប្រសិនបើមាន)

៣. បញ្ហាប្រឈម និងសំណូមពរ

៣.១. បញ្ហាប្រឈម

៣.១.១. បញ្ហាប្រឈមក្នុងកិច្ចការរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ

-ខ្វះថវិកាប្រចាំឆ្នាំ សម្រាប់ផ្តត់ផ្តង់ដំណើរការកិច្ចការរដ្ឋបាល និងកិច្ចការបច្ចេកទេសសំណុំរឿង។

-ខ្វះក្របសំណុំរឿងរដ្ឋប្បវេណី និងសំណុំរឿងព្រហ្មទណ្ឌ (ការបើកផ្តល់ដោយក្រសួងយុត្តិធម៌ បានតែ ៦៤០ក្របសំណុំរឿង តែជាក់ស្តែងសាលាដំបូង និងអយ្យការអមសាលាដំបូង មានតម្រូវក្របសំណុំរឿងក្នុងមួយឆ្នាំអស់ចំនួន ១៣,០៤០ក្របសំណុំរឿង ដោយមិនទាន់គិតក្របសំណុំរឿងបង្គាទុក)

-ខ្វះសម្ភារៈប្រើប្រាស់ដូចជា កុំព្យូទ័រ ម៉ាស៊ីនព្រីន ម៉ាស៊ីនស្កេន ម៉ាស៊ីនថតចម្លងសរុបចំនួន ៥០គ្រឿង។

-ខ្វះធនធានមនុស្សដូចជា ចៅក្រម ព្រះរាជអាជ្ញារង ក្រឡាបញ្ជី អាជ្ញាសាលា មន្ត្រីរដ្ឋបាល និងមន្ត្រីជាប់កិច្ចសន្យា (ចៅក្រម ឬព្រះរាជអាជ្ញាក្នុងម្នាក់ចាត់ការសំណុំរឿងចំនួន ២៨៧)។

-វត្ថុតាងដែលត្រូវបានរឹបអូសតាមអំណាចសាលក្រមស្ថាពរ ត្រូវបានរក្សាទុក ជាយូរឆ្នាំមកហើយ និងមានលក្ខណៈចាស់ទ្រុឌទ្រោមបាត់គុណភាព និងធ្លាក់ចុះតម្លៃជាបន្តបន្ទាប់។

-ខ្វះឃ្លាំងរក្សាទុកវត្ថុតាង និងឃ្លាំងរក្សាទុកសំណុំរឿងចាត់ការរួច។

៣.១.២. បញ្ហាប្រឈមក្នុងកិច្ចការបច្ចេកទេស

៣.១.២.១. បញ្ហាប្រឈមក្នុងសំណុំរឿងព្រហ្មទណ្ឌ ដំណាក់កាលអយ្យការ

-ចំពោះសំណុំរឿងព្រហ្មទណ្ឌមួយចំនួនដែលយឺតយ៉ាវ គឺដោយសារការប្រមូលកស្តុតាងមិនទាន់គ្រប់គ្រាន់ ទើបតំណាងអយ្យការប្រើនីតិវិធីបើកការចោទប្រកាន់តាមរយៈការបើកការស៊ើបសួរ ច្រើនជាងនីតិវិធីការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬតាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ហើយសំណុំរឿងខ្លះទៀតពុំមានសាវតាជាតិរបស់ជនត្រូវចោទគ្រប់គ្រាន់ដើម្បីធ្វើការបញ្ជូនទៅជំនុំជម្រះបាន។

-ខ្វះម៉ាស៊ីនធ្វើកោសលវិច័យ (Crim Investigation) ដែលធ្វើចំណាត់ការសំណុំរឿងយឺតយ៉ាវ

-បច្ចេកទេសកសាងសំណុំរឿងរបស់មន្ត្រីនគរបាលយុត្តិធម៌នៅមានកម្រិត (ឧទាហរណ៍៖ រឿងចរាចរណ៍មិនបានបញ្ជាក់ឲ្យបានច្បាស់នូវកំហុស, រឿងគ្រឿងញៀនខ្វះរូបថតវត្ថុតាង...)

-សំណុំរឿងមួយចំនួនមានការស្មុគស្មាញ ហើយភាគីនៅក្នុងសំណុំរឿងមានចំនួនច្រើននាក់ ដែលតម្រូវឱ្យប្រើរយៈពេលច្រើន ដើម្បីធ្វើការកោះហៅភាគី និងសាក្សីនានា ដើម្បីមានមូលដ្ឋានចំណាត់ការបន្ត។

៣.១.២.២. បញ្ហាប្រឈមក្នុងសំណុំរឿងព្រហ្មទណ្ឌ ដំណាក់កាលចៅក្រមស៊ើបសួរ

-ការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ដោយពុំមានរបាយការណ៍ស្តីពីការអនុវត្តដីកាត្រឡប់មកវិញ ឬការផ្តល់លទ្ធផលត្រឡប់មកវិញពុំទាន់ពេលវេលា។

-ករណីបទល្មើសចរាចរណ៍បង្កឡើងដោយអញ្ញាតជន ការស្រាវជ្រាវអត្តសញ្ញាណរបស់ជនត្រូវចោទ ពុំទទួលបានលទ្ធផលពីមន្ត្រីនគរបាលយុត្តិធម៌ ឬមន្ទីរស្ថាប័នជំនាញ។

-ធនាគារមួយចំនួនមិនសហការផ្តល់អត្តសញ្ញាណរបស់ម្ចាស់គណនី ចំណែកក្រុមហ៊ុនទូរស័ព្ទមិនសហការផ្តល់អត្តសញ្ញាណរបស់ម្ចាស់លេខទូរស័ព្ទ ដែលជាហេតុធ្វើឱ្យការកំណត់អត្តសញ្ញាណជនត្រូវចោទ ដែលប្រព្រឹត្តបទល្មើសពាក់ព័ន្ធនឹងប្រព័ន្ធបច្ចេកវិទ្យាមានការលំបាក ឬពុំអាចធ្វើបាន។

-ការកសាងសំណុំរឿងចរាចរណ៍ សំណុំរឿងគ្រឿងញៀន និងសំណុំរឿងបទល្មើសផ្សេងៗទៀត ក្នុងករណីខ្លះ មិនទាន់ពេញលេញគ្រប់ជ្រុងជ្រោយ។សំណុំរឿងខ្លះផ្តែកតែលើចម្លើយសារភាពរបស់ជនត្រូវចោទ។

-ការធ្វើកោសល្យវិច័យផ្សេងៗ ពិសេសទាក់ទិននឹងបទល្មើសគ្រឿងញៀនត្រូវការពេលវេលាយូរដើម្បីទទួលបានលទ្ធផលកោសលវិច័យពីអ្នកជំនាញ (ម៉ាស៊ីនមានតែមួយទូទាំងប្រទេស)។

-ការកោះហៅ ឬការបញ្ជូនឯកសារនីតិវិធីផ្សេងៗឆ្លងខេត្តមានការលំបាក ដោយភាគច្រើនមិនទទួលបានលទ្ធផលត្រឡប់មកវិញ ឬត្រឡប់មកមិនទាន់ពេលវេលា។

-ការចាត់តាំងមេធាវី ដើម្បីការពារអនីតិជន ឬជនត្រូវចោទក្នុងបទឧក្រិដ្ឋ មិនអាចធ្វើបានភ្លាមៗ ករណីបទល្មើសជាក់ស្តែង ដែលមានជនត្រូវចោទត្រូវបានឃាត់ខ្លួនបញ្ជូនមកចំពោះមុខចៅក្រមស៊ើបសួរ។

-មិនមានភ្នាក់ងារសង្គមកិច្ចគ្រប់គ្រាន់ចូលរួមស្តាប់ចម្លើយអនីតិជនភ្លាមៗ ឬទទួលយកអនីតិជន ករណីចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនអនីតិជនជាបណ្តោះអាសន្ន។

៣.១.២.៣. បញ្ហាប្រឈមក្នុងសំណុំរឿងព្រហ្មទណ្ឌ ដំណាក់កាលចៅក្រមជំនុំជម្រះ

-ក្នុងករណីខ្លះ សំណុំរឿងជំនុំជម្រះត្រូវចាត់របៀបបង្វិលទៅចៅក្រមស៊ើបសួរវិញ ដើម្បីឱ្យចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរបន្ថែម ដោយសារមិនទាន់បានបំពេញកិច្ចស៊ើបសួរបានមូលនៅឡើយ ដែលជាហេតុធ្វើឱ្យការជំនុំជម្រះត្រូវលើក ឬពន្យារពេល។

-សាក្សី ឬភាគីមិនបានចូលរួមសវនាការ ដោយមិនបានទទួលព័ត៌មានថា ពួកគាត់បានទទួលដីកាកោះ ឬមិនបានទទួលដីកាកោះ ដែលករណីខ្លះតម្រូវឱ្យលើកកាលបរិច្ឆេទសវនាការ។ ការកោះហៅ ឬបញ្ជូនឯកសារនីតិវិធីផ្សេងៗឆ្លងខេត្តមានការលំបាក ឬគ្មានប្រសិទ្ធភាព។

-ការប្តឹងជិតចិត្តចៅក្រមជំនុំជម្រះដោយភាគីធ្វើឱ្យសវនាការមានការយឺតយ៉ាវ។

-អវត្តមានមេធាវីនាពេលសវនាការ ដោយមិនមានអ្នកជំនួស ដែលជាហេតុតម្រូវឱ្យតុលាការត្រូវលើកពេលសវនាការ។

-មន្ត្រីនគរបាលយុត្តិធម៌ដែលជាអ្នកកសាងសំណុំរឿងពុំចូលខ្លួនតាមការកោះហៅរបស់តុលាការ។

៣.១.២.៤. បញ្ហាប្រឈមក្នុងសំណុំរឿងរដ្ឋប្បវេណី

-ពាក្យបណ្តឹង និងពាក្យសុំធ្វើឡើងពុំបានត្រឹមត្រូវតាមច្បាប់កំណត់ ដែលតម្រូវឱ្យមានការកែតម្រូវ ដែលនាំឱ្យមានការអូសបន្លាយពេលវេលា។

-ក្នុងសំណុំរឿងកែតម្រូវអត្រានុកូលដ្ឋានខ្លះ អ្នកដាក់ពាក្យសុំផ្តល់ឯកសារកសុតាងមិនបានពេញលេញគ្រប់ជ្រុងជ្រោយ ដែលជាហេតុនាំឱ្យមានការអូសបន្លាយពេលវេលា។

-សំណុំរឿងអនុវត្តដោយបង្ខំ មិនអាចបញ្ចប់ជាស្ថាពរ ដោយហេតុថា មិនមានអ្នកចូលរួមដាក់ពាក្យដេញថ្លៃទិញអចលនវត្ថុ ឬចលនវត្ថុ ដែលជាកម្មវត្ថុនៃការលក់ដោយបង្ខំ, ការកំណត់អត្តសញ្ញាណទ្រព្យមិនបានច្បាស់លាស់, នីតិវិធីនៃការប្រគល់អចលនវត្ថុជូនអ្នកទិញមានការរារាំងពីកូនបំណុល, នីតិវិធីនៃការផ្ទេរកម្មសិទ្ធិមានលក្ខណៈស្មុគស្មាញ(មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ទាមទារឱ្លង់ច្បាប់ដើម ឬត្រូវការស្នាមមេដៃពីកូនបំណុលនៃការអនុវត្តជាដើម)។

-ការបញ្ជូនដីកា សេចក្តីសម្រេច ឬលិខិតផ្សេងៗទៅភាគី មិនបានសម្រេច ឬមានការលំបាក ដោយមូលហេតុថាភាគីបានចាកចេញពីអាសយដ្ឋាន។

-កិច្ចសហការពីស្ថាប័ន ឬមន្ត្រីជំនាញនៅមានកម្រិត ដោយស្ថាប័ន ឬមន្ត្រីជំនាញមួយចំនួនមិនផ្តល់លទ្ធផល តាមការស្នើសុំរបស់ចៅក្រមទទួលបន្ទុកសំណុំរឿង។

៣.១.២.៥. បញ្ហាប្រឈមក្នុងសំណុំរឿងអាជ្ញាសាលា

-គ្មានមធ្យោបាយធ្វើដំណើរ ព្រោះកន្លែងអនុវត្ត និងកន្លែងត្រូវបញ្ជូនលិខិតនៅឆ្ងាយ។

-គ្មានឃ្លាំងរក្សាទុករថយន្ត ឬចលនវត្ថុដែលត្រូវបានរឹបអូសដោយអាជ្ញាសាលា ។

-ពិបាករកអ្នកវាយតម្លៃចលនវត្ថុដើម្បីមានមូលដ្ឋានសម្រេចកំណត់តម្លៃលក់ឡាយឡុង។

៣.២. សំណូមពរ

-ស្នើសុំបង្កើនកញ្ចប់ថវិកាប្រចាំឆ្នាំ និងផ្តល់សម្ភារបរិក្ខារ កុំព្យូទ័រ ម៉ាស៊ីនព្រីន ម៉ាស៊ីនស្កេន ម៉ាស៊ីនថតចម្លង ជាអាទិ៍។

-ស្នើសុំផ្តល់ក្រឡាបញ្ជី មន្ត្រីរដ្ឋបាល និងមន្ត្រីជាប់កិច្ចសន្យាបន្ថែម ដើម្បីបង្កើនប្រសិទ្ធភាពការងារ។

-ស្នើសុំផ្តល់មន្ត្រីអាជ្ញាសាលាបន្ថែម ដើម្បីបង្កើនប្រសិទ្ធភាពការងារ។

-ស្នើសុំពន្លឿននីតិវិធីចាត់ចែងវត្ថុតាង ដែលរក្សាទុកនៅសាលាដំបូង តាមអំណាចសាលក្រម ឬសាលដីកាស្ថាពរ។

-ស្នើសុំសហការសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធ ដើម្បីពន្លឿនការឆ្លើយតបប្រកបដោយប្រសិទ្ធភាពរបស់ក្រសួងពាក់ព័ន្ធ ចំពោះដីកាផ្សេងៗរបស់តុលាការ។

៤. ទិសដៅការងារសម្រាប់ឆ្នាំ ២០២៥

៤.១. ទិសដៅការងារក្នុងសំណុំរឿងព្រហ្មទណ្ឌ ជំណាក់កាលអយ្យការ

-ប្រជុំជាមួយមន្ត្រីនគរបាលយុត្តិធម៌នៅតាមបណ្តាក្រុង ស្រុក។ ប្រជុំដឹកនាំការងារក្នុងស្ថាប័នអយ្យការ ដើម្បីពន្លឿនចំណាត់ការសំណុំរឿងឲ្យបានឆាប់រហ័សជាងមុន។

-បន្តយកចិត្តទុកដាក់ចំណាត់ការសំណុំរឿងពាក់ព័ន្ធបទល្មើសសម្អាតប្រាក់ ជួញដូរមនុស្ស ជួញដូរគ្រឿងញៀន។ល។

-ជំរុញសមត្ថកិច្ចឲ្យផ្សព្វផ្សាយ អប់រំ ប្រជាពលរដ្ឋចូលរួមគោរពច្បាប់ចរាចរណ៍។

-សម្របសម្រួលសំណុំរឿងព្រហ្មទណ្ឌ លក្ខណៈបទមជ្ឈិមស្រាល ដើម្បីអនុវត្តគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់។

-ជំរុញមន្ត្រីនគរបាលយុត្តិធម៌ធ្វើការស៊ើបអង្កេតប្រមូលភស្តុតាងឱ្យបានឆាប់រហ័ស ពេញលេញគ្រប់ជ្រុងជ្រោយ មុននឹងបញ្ជូនសំណុំរឿងមកកាន់តំណាងអយ្យការដើម្បីចាត់ការបន្ត។

-សំណុំរឿងស៊ើបអង្កេតបឋម ព្រះរាជអាជ្ញាចាត់ឱ្យព្រះរាជអាជ្ញារងធ្វើការស៊ើបអង្កេតឱ្យអស់លទ្ធភាព មុននឹងធ្វើការសម្រេច។ បើពិនិត្យឃើញថាមានភស្តុតាងគ្រប់គ្រាន់ តំណាងអយ្យការត្រូវចោទប្រកាន់តាមរយៈការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ប៉ុន្តែបើពិនិត្យឃើញថាពុំមានបទល្មើសនោះទេ ឬពុំមានភស្តុតាងធ្ងន់ល្មម ត្រូវតម្កល់រឿងទុកឥតចាត់ការឱ្យបានលឿន។

-ជំរុញឱ្យប្រើជម្រើសនៃការចោទប្រកាន់ផ្សេងៗទៀត ក្រៅពីធ្វើនីតិវិធីបើកការស៊ើបសួរ ដូចជា ធ្វើនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងតាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ដើម្បីឱ្យចំណាត់ការសំណុំរឿងកាន់តែមានភាពឆាប់រហ័ស និងមានប្រសិទ្ធភាពខ្ពស់។

-ពន្លឿននីតិវិធីក្នុងការឆ្លើយតបសំណុំរឿងត្រឡប់ពីចៅក្រមស៊ើបសួរ ទាក់ទិននឹងការជូនដំណឹងអំពីការបិទការស៊ើបសួរ ដីកាបញ្ជូនរឿងឱ្យពិនិត្យ និងធ្វើដីកាសន្និដ្ឋានស្តាពរក្នុងរយៈពេលកំណត់នៅក្នុងច្បាប់។

-ក្នុងដំណាក់កាលជំនុំជម្រះក្នុងសំណុំរឿងព្រហ្មទណ្ឌ តំណាងអយ្យការកោះហៅជនជាប់ទាក់ទិន ក្នុងសំណុំរឿងឱ្យបានឆាប់រហ័ស។

-ចាត់ឱ្យព្រះរាជអាជ្ញារងចុះពិនិត្យជនជាប់ឃុំនៅពន្ធនាគារខេត្តសៀមរាបជារៀងរាល់ខែ ដើម្បីពិនិត្យ មើល និងតាមដានជនជាប់ឃុំ មន្ត្រីគ្រប់គ្រងពន្ធនាគារ និងបញ្ហាប្រឈមនានា ដែលកើតមានឡើងក្នុងពន្ធនាគារខេត្តសៀមរាប។

-រៀបចំយន្តការតាមដានចំណាត់ការសំណុំរឿងរបស់តំណាងអយ្យការ តាមការណែនាំរបស់ក្រសួងយុត្តិធម៌ ដោយមានចុះបញ្ជីសំណុំរឿង របាយការណ៍ចំណាត់ការ និងបញ្ចូលសំណុំរឿងទៅក្នុងប្រព័ន្ធ Database ជាប្រចាំ។

៣.២. ឱសដៅការងារក្នុងសំណុំរឿងព្រហ្មទណ្ឌ ដំណាក់កាលចៅក្រមស៊ើបសួរ

-ចៅក្រមស៊ើបសួរត្រូវពិនិត្យភាពចាំបាច់ នៃការឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្នឱ្យបានហ្មត់ចត់ បំផុត ដើម្បីធានាការពារសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ជនត្រូវចោទ។

-ចំពោះសំណុំរឿងដែលមានជនត្រូវចោទស្ថិតនៅក្នុងឃុំបណ្តោះអាសន្ន ពិសេសអនីតិជន ចៅក្រមស៊ើបសួរត្រូវពន្លឿននីតិវិធីស៊ើបសួរឱ្យបានឆាប់រហ័ស ដើម្បីចៀសវាងការឃុំខ្លួនជនត្រូវចោទលើសចិរវេលាដែលច្បាប់កំណត់ និងចៀសវាងការពន្យារពេលឃុំខ្លួនជាបណ្តោះអាសន្នដោយមិនមានមូលហេតុសមស្រប។

-ជំរុញមន្ត្រីនគរបាលយុត្តិធម៌ ស្ថាប័ន មន្ទីរ និងអង្គភាពពាក់ព័ន្ធ ដែលទទួលបន្ទុកអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួសដីកាកោះ និងលិខិតនីតិវិធីផ្សេងៗ ឱ្យអនុវត្តការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព និងបង្វិលដីកា ឬលទ្ធផលការងារត្រឡប់មកវិញឱ្យបានឆាប់រហ័ស និងទាន់ពេលវេលា។

-ចំពោះសំណុំរឿងគ្រឿងញៀន ចៅក្រមស៊ើបសួរត្រូវបន្តពង្រឹងការអនុវត្ត និងដកសំណាកគ្រឿងញៀនដើម្បីធ្វើកោសលវិច័យ និងបញ្ជូនសំណាកទៅធ្វើកោសលវិច័យឱ្យបានឆាប់រហ័ស និងអនុវត្តឱ្យបានត្រឹមត្រូវតាមបែបបទនៃការដក និងបញ្ជូនសំណាកទៅមន្ទីរពិសោធន៍គ្រឿងញៀន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

-ចំពោះសំណុំរឿងចរាចរណ៍ ចៅក្រមស៊ើបសួរត្រូវពិនិត្យសំណុំរឿងឱ្យបានហ្មត់ចត់ និងកោះហៅមន្ត្រីនគរបាលយុត្តិធម៌ដែលជាអ្នកកសាងសំណុំរឿងមកសាកសួរបន្ថែម ដើម្បីកំណត់អត្ថិភាព និងនត្ថិភាពនៃកំហុសឱ្យបានច្បាស់លាស់។

-ចៅក្រមស៊ើបសួរត្រូវបង្កើនការយកចិត្តទុកដាក់លើចំណាត់ការសំណុំរឿងឱ្យបានហ្មត់ចត់ គ្រប់ជ្រុងជ្រោយ និងត្រឹមត្រូវតាមនីតិវិធី មុននឹងសម្រេចបិទការស៊ើបសួរ យ៉ាងយូរបំផុតរយៈពេល ០៣ខែ លើកលែងតែសំណុំរឿងមានភាពស្មុគស្មាញ។

៣.៣. ឱសដៅការងារក្នុងសំណុំរឿងព្រហ្មទណ្ឌ ដំណាក់កាលជំនុំជម្រះ

-ចៅក្រមត្រូវប្រគល់សាលក្រមព្រហ្មទណ្ឌដែលបានប្រកាសរួចទៅលេខាធិការដ្ឋានរដ្ឋបាលឱ្យបានឆាប់រហ័ស និងយ៉ាងយូរបំផុតរយៈពេល ០១សប្តាហ៍ (ករណីសំណុំរឿងមានជនជាប់ចោទនៅក្នុងឃុំ) និងរយៈពេល ០២សប្តាហ៍ (ករណី

សំណុំរឿងមានជនជាប់ចោទនៅក្រៅឃុំ ឬគេចខ្លួន) គិតចាប់ពីថ្ងៃប្រកាសសាលក្រម ដើម្បីធានាសិទ្ធិតាមនីតិវិធីច្បាប់របស់ភាគីពាក់ព័ន្ធ។

-ចៅក្រម និងក្រឡាបញ្ជីត្រូវពន្លឿននីតិវិធីការចារការចូលជាស្ថាពរនៃសាលក្រមព្រហ្មទណ្ឌឱ្យបានឆាប់ហ័ស។

-ចៅក្រមត្រូវពង្រឹងប្រសិទ្ធភាពនៃការសរសេរសាលក្រម ពិសេសចំណុចសំអាងហេតុ ដោយត្រូវយកចិត្តទុកដាក់ពិនិត្យអង្គច្បាប់ និងអង្គហេតុឱ្យបានហ្មត់ចត់ ផ្អែកលើកស្តីតាងលើសពីរឿតិសង្ស័យ។

-ចំពោះសំណុំរឿងដែលមានជនជាប់ចោទជាប់ឃុំជាបណ្តោះអាសន្ន ចៅក្រមត្រូវបើកសវនាការជំនុំជម្រះ និងប្រកាសសាលក្រមក្នុងរយៈពេលយ៉ាងយូរ ០១ខែ និង ១៥ថ្ងៃ លើកលែងតែសំណុំរឿងមានលក្ខណៈស្មុគស្មាញ។

៣.៤. ឯសដៅការងារក្នុងសំណុំរឿងរដ្ឋប្បវេណី

-បញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធ Database ឱ្យបានទាន់ពេលវេលា និងបញ្ជូនទៅចៅក្រមឱ្យបានឆាប់ហ័សបំផុត។

-ត្រូវបញ្ជូនសេចក្តីសម្រេច ដីកាកោះ និងលិខិតនីតិវិធីផ្សេងៗឱ្យដល់ភាគីឱ្យបានទាន់ពេលវេលា។

-ចៅក្រមត្រូវសម្រេចឱ្យបានឆាប់ហ័ស ចំពោះពាក្យបណ្តឹង ពាក្យសុំ ពាក្យសុំតវ៉ា ឬបណ្តឹងទាស់របស់ភាគី។

-ចំពោះសំណុំរឿងពាក់ព័ន្ធនឹងអត្រានុកូលដ្ឋាន ដែលត្រូវសម្រេចដោយដីកាសម្រេច ចៅក្រមត្រូវសម្រេចសេចក្តីក្នុងរយៈពេលយ៉ាងយូរ ០១ខែ គិតពីថ្ងៃទទួលបានសំណុំរឿងមកចាត់ការ លើកលែងតែសំណុំរឿងមានលក្ខណៈស្មុគស្មាញ។

-នៅពេលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានបញ្ចប់ ហើយចំណុចវិវាទត្រូវបានកំណត់រួចរាល់ ចៅក្រមគប្បីកំណត់កាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅក្នុងកំណត់ហេតុនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលតែម្តង ដោយមិនចាំបាច់ធ្វើដីកាកោះ ឬលិខិតអញ្ជើញម្តងទៀតឡើយ។

-ក្នុងករណីភាគីស្នើសុំតុលាការលើកកាលបរិច្ឆេទនីតិវិធីផ្សេងៗ ចៅក្រមត្រូវកំណត់កាលបរិច្ឆេទថ្មីនៅថ្ងៃបន្ទាប់ និងមិនគួរអនុញ្ញាតឱ្យភាគីស្នើសុំលើកកាលបរិច្ឆេទច្រើនដងឡើយ។

៣.៥. ឯសដៅការងាររួម

-ត្រូវប្រកាន់ខ្ជាប់អភិក្រម "**លឿន ត្រឹមត្រូវ យុត្តិធម៌ និងមិនពុករលួយ**" ក្នុងចំណាត់ការសំណុំរឿង។

-ត្រូវមានឆន្ទៈទទួលខុសត្រូវខ្ពស់ លះបង់ពេលវេលា ប្តេជ្ញាចិត្តពន្លឿន និងយកចិត្តទុកដាក់ខ្ពស់បំផុតក្នុងចំណាត់ការសំណុំរឿង ជាពិសេសសំណុំរឿងគ្រឿងញៀន សំណុំរឿងចរាចរណ៍ និងសំណុំរឿងអត្រានុកូលដ្ឋាន។

-ប្រព័ន្ធរំលឹកអំពីរយៈពេលនៃការឃុំខ្លួន និងប្រព័ន្ធរំលឹកកម្មវិធីសវនាការតាមរយៈក្រុមតេឡេក្រាម។

-ចាត់តាំងក្រឡាបញ្ជីរដ្ឋបាលចំនួន ០២(ពីរ)រូប តាមការិយាល័យចៅក្រមនីមួយៗ ដើម្បីទទួលបន្ទុកទទួលឯកសារផ្សេងៗសម្រាប់ចៅក្រម។

-បង្កើតក្រុមការងារផ្ទៃក្នុង ដើម្បីពិនិត្យការអនុវត្ត និងសហការអនុវត្តក្នុងយុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តី និងយុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ ដើម្បីសហការគ្រប់ជ្រុងជ្រោយជាមួយក្រសួងយុត្តិធម៌។

-បង្កើតក្រុមការងារអ្នកនាំពាក្យ និងប្រតិកម្មរហ័ស ប្រចាំសាលាដំបូងខេត្តសៀមរាប ដើម្បីសម្របសម្រួលព័ត៌មានឆ្លើយតបអំពីការងារចាំបាច់មួយចំនួន និង សហការជាមួយក្រុមការងារយុទ្ធនាការរបស់ក្រសួងយុត្តិធម៌។

ថ្ងៃអង្គារ ៦កើ ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
សៀមរាប, ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៥
ប្រធានលេខាធិការដ្ឋានរដ្ឋបាល

យិន ស្រាង

បានឃើញ និង ឯកភាព
សៀមរាប ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៥
ព្រះរាជអាជ្ញា

ហាស ចន្ថាភិរដ្ឋ

ប្រធានសាលាដំបូង

ហុក ង៉ាន់ឆីណា

សាលាដំបូង និងអយ្យការអម
សាលាដំបូងខេត្តព្រះសីហនុ
លេខ..៨៨៥..ស.ប/៨៥

របាយការណ៍ការងារសង្ខេបរបស់សាលាដម្រះក្តី
សម្រាប់សន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារអាទិភាព ឆ្នាំ២០២៥
សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ

១.ស្ថានភាពទូទៅ

ក.ធនធានមនុស្ស

គិតត្រឹមថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៥ សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ មានមន្ត្រីក្របខណ្ឌមុខងារសាធារណៈ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យា ដូចខាងក្រោម៖

ល.រ	មុខតំណែង	ចំនួន	ស្រី
សាលាដំបូង		**សរុប ១៣រូប**	
១	ប្រធានសាលាដំបូង	១រូប	០រូប
២	អនុប្រធានសាលាដំបូង	៥រូប	០រូប
៣	ចៅក្រម	៧រូប	២រូប
អយ្យការអមសាលាដំបូង		**សរុប ១២រូប**	
១	ព្រះរាជអាជ្ញា	១រូប	០រូប
២	ព្រះរាជអាជ្ញារង	១១រូប	០រូប
ក្រឡាបញ្ជី		**សរុប ៣៥រូប**	
១	ក្រឡាបញ្ជីតុលាការ	២៤រូប	៤រូប
២	ក្រឡាបញ្ជីអយ្យការ	១១រូប	២រូប
អាជ្ញាសាលា		**សរុប ០១រូប**	
១	អាជ្ញាសាលា	១រូប	០រូប
លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង		**សរុប ៥៣រូប**	
១	ប្រធានលេខាធិការដ្ឋាន	១រូប	០រូប
២	អនុប្រធានលេខាធិការដ្ឋាន	៤រូប	០រូប

ផ្លូវ RCI ភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
St. RCI Village 3, Sangkat 1, Preah Sihanouk City, Preah Sihanouk Province.

៣	ប្រធានការិយាល័យ	៤រូប	២រូប
៤	អនុប្រធានការិយាល័យ	៨រូប	៣រូប
៥	មន្ត្រីគ្រប់គ្រងរដ្ឋបាល "ក"	២២រូប	៩រូប
៦	មន្ត្រីក្រមការ "ខ"	១រូប	០រូប
៧	លេខាធិការ "គ"	១រូប	០រូប
៨	មន្ត្រីជាប់កិច្ចសន្យា	១២រូប	៦រូប

ខ.ហេដ្ឋារចនាសម្ព័ន្ធ

សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តព្រះសីហនុមាន៖

-អគារសាលាដំបូង និងអយ្យការអមសាលាដំបូង ចំនួន០១ មានទំហំអគារ១៣មx៤៥ម កម្ពស់៤ជាន់ និងសាលសវនាការចំនួន ០៣។

-អគារលេខាធិការដ្ឋានរដ្ឋបាល ចំនួន០១ មានទំហំអគារ១២មx២០ម កម្ពស់៣ជាន់។

-សាលប្រជុំធំ០១ និងសាលប្រជុំតូច០១។

-ឃ្លាំងតម្កល់វត្ថុចាប់យក ចំនួន០១។

គ.លទ្ធផលសន្និបាតផ្ទៃក្នុងស្ថាប័ន ២០២៤

-ចំណាត់ការលើសំណុំរឿង តាមដំណាក់កាលនីមួយៗ បានទាន់ពេលវេលា មានភាពឆាប់រហ័ស និងមានប្រសិទ្ធភាពខ្ពស់។

-បញ្ជូនសំណាកគ្រឿងញៀនទៅធ្វើកោសល្យវិច្ច័យ បានឆាប់រហ័ស និងទទួលលទ្ធផលត្រលប់មកវិញទាន់ពេលវេលា។

-ប្រើប្រាស់យន្តការតាមប្រព័ន្ធតេលេក្រាមជាមួយមន្ត្រីនគរបាលយុត្តិធម៌ មន្ត្រី ក្រឡាបញ្ជី ក្នុងការបញ្ជូនឯកសារ និងការវិលត្រលប់ឯកសារមកវិញមានភាពរលូន។

-ការបញ្ជូនសំណុំរឿងប្តឹងឧទ្ធរណ៍ ទៅសាលាឧទ្ធរណ៍ព្រះសីហនុ ទាន់ពេលវេលា។

-ការបញ្ជូនសាលក្រម ដីកាសម្រេច ឯកសាររដ្ឋបាលទៅស្ថាប័នរឹអង្គភាពពាក់ព័ន្ធបានភាពឆាប់រហ័ស។

-បានដឹកនាំ និងសម្របសម្រួល សកម្មភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌ក្នុងដែនសមត្ថកិច្ច និងបានចុះត្រួតពិនិត្យពន្ធនាគារ។

ឃ.ព្រឹត្តិការណ៍ ឬកម្មវិធីការចារនោនា

-បានចូលរួមពិធីបុណ្យជាតិ និងព្រឹត្តិការណ៍នានា ចំនួន ១២ដង។

-ដឹកនាំប្រជុំប្រចាំខែ និងកិច្ចការផ្សេងៗ (ប្រជុំតូច ធំ) ចំនួន ៦៩ដង។

-បានចូលរួមប្រជុំជាមួយសាលាឧទ្ធរណ៍ព្រះសីហនុ ចំនួន ០២ដង។

-សិក្ខាសាលា ចំនួន១៣ដង។

-បានចូលរួមប្រជុំជាមួយរដ្ឋបាលសាលាខេត្តព្រះសីហនុ ចំនួន ១៣ដង។

-ការឃោសនា និងផ្សព្វផ្សាយព័ត៌មានសាធារណៈចំនួន ១៩ដង។

-សន្និបាតផ្ទៃក្នុង ចំនួន ០១ដង។

២.សមិទ្ធផលការងារ

ក.អយ្យការអមសាលាដំបូង

ក.១.ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌ

ប្រចាំឆ្នាំ/ខែ	រឿងសល់ពីខែមុន	រឿងចូលថ្មី	រឿងចាត់ការរួច	រឿងកំពុងចាត់ការ	ផ្សេងៗ
២០២៤	២៦៧	១៧០០	១៧៩០	១៧៧	
មករា	១៧៧	១៣៩	១២៥	១៩១	
កុម្ភៈ	១៩១	១០៥	១១៤	១៨២	

ក.២.កិច្ចការពាក់ព័ន្ធនឹងការអនុវត្តទោស និងពន្ធនាគារ

ប្រចាំឆ្នាំ/ខែ	រឿងសល់ពីខែមុន	រឿងចូលថ្មី	រឿងចាត់ការរួច	រឿងកំពុងចាត់ការ	ផ្សេងៗ
២០២៤	១០២២	៨៥៥	៨៥៨	១០១៩	
មករា	១០១៩	៣៨៨	៤០	១៣៦៧	
កុម្ភៈ	១៣៦៧	១៩៣	៨១	១៤៧៩	

ក.៣.កិច្ចការពាក់ព័ន្ធជាមួយនឹងមន្ត្រីនគរបាលយុត្តិធម៌

-ចុះអធិការកិច្ច និងត្រួតពិនិត្យតាមបណ្តាអង្គភាពនគរបាលយុត្តិធម៌ក្នុងដែនសមត្ថកិច្ច ជាប្រចាំខែ ត្រីមាស ឆមាស។

-ដឹកនាំ និងសម្របសម្រួលការងាររបស់មន្ត្រីនគរបាលយុត្តិធម៌។

-ចុះអធិការកិច្ច និងត្រួតពិនិត្យជាប្រចាំ នៅពន្ធនាគារខេត្តព្រះសីហនុ។

-ចូលរួមប្រជុំវាយតម្លៃអំពីការបន្ធូរបន្ថយទោស និងលើកលែងទោសដល់ជនជាប់ឃុំ ដែលបានបំពេញលក្ខខណ្ឌច្បាប់ទទួលសិទ្ធិក្នុងការស្នើរសុំលើកលែងទោស និងបន្ធូរបន្ថយទោស។

ខ.សាលាដំបូង៖

ខ.១.ចំណាត់ការលើសំណុំរឿងព្រហ្មទណ្ឌ

ខ.១.១.ដំណាក់កាលស៊ើបសួរ

ប្រចាំឆ្នាំ/ខែ	រឿងសល់ពីខែមុន	រឿងចូលថ្មី	រឿងចាត់ការរួច	រឿងកំពុងចាត់ការ	ផ្សេងៗ
២០២៤	៥៦៦	១៣៩៩	១៤៨៤	៤៨១	
មករា	៤៨១	១៣៨	១០៥	៥១៤	
កុម្ភៈ	៥១៤	៩៣	១១០	៤៩៧	

ខ.១.២.ដំណាក់កាលជំនុំជម្រះ

ប្រចាំឆ្នាំ/ខែ	រឿងសល់ពីខែមុន	រឿងចូលថ្មី	រឿងចាត់ការរួច	រឿងកំពុងចាត់ការ	ផ្សេងៗ
២០២៤	៣៨៥	១៣០៣	១៤១៩	២៦៩	
មករា	២៦៩	១៥៨	៦៤	៣៦៣	
កុម្ភៈ	៣៦៣	១៨៦	១៣៤	៤១៥	

ខ.១.៣.ចំណាត់ការលើសំណុំរឿងរដ្ឋប្បវេណី

ប្រចាំឆ្នាំ/ខែ	រឿងសល់ពីខែមុន	រឿងចូលថ្មី	រឿងចាត់ការរួច	រឿងកំពុងចាត់ការ	ផ្សេងៗ
២០២៤	៧៤៤	៥៩៥	៩៧៦	៣៦៣	
មករា	៣៦៣	៧៦	៤៣	៣៩៦	
កុម្ភៈ	៣៩៦	៤២	៥៤	៣៨៤	

ខ.១.៤ ចំណាត់ការសំណុំរឿងអនុវត្ត

ប្រចាំឆ្នាំ/ខែ	រឿងសល់ពីខែមុន	រឿងចូលថ្មី	រឿងចាត់ការរួច	រឿងកំពុងចាត់ការ	ផ្សេងៗ
២០២៤	១៥០	១៣៨	១៦៥	១២៣	
មករា	១២៣	៨	៩	១២២	
កុម្ភៈ	១២២	៨	១០	១២០	

ខ.២. កិច្ចការផ្សេងទៀតរបស់សាលាដំបូង

-ដឹកនាំប្រជុំផ្ទៃក្នុង ចំនួន ១៩ដង។

-បានផ្សព្វផ្សាយ ពិភាក្សា ទៅលើទម្រង់របាយការណ៍ និងឯកសារផ្សេងៗ ដល់ លោក លោកស្រីចៅក្រម និងមន្ត្រីលេខាធិការដ្ឋាន ជាប្រចាំ។

-បានចាត់ការរឿងក្តីគ្រប់ប្រភេទដែលនៅសល់ពីឆ្នាំចាស់ និងរឿងក្តីចូលថ្មី ឆាប់រហ័ស ត្រឹមត្រូវ និងប្រកបដោយការទទួលខុសត្រូវខ្ពស់។

-បន្តពង្រឹងសមត្ថភាពរបស់ចៅក្រម និងមន្ត្រីលេខាធិការដ្ឋានរដ្ឋបាល តាមរយៈការបណ្តុះបណ្តាល និងការចែករំលែកចំណេះដឹងផ្ទៃក្នុង។

៣. បញ្ហាប្រឈម

-កង្វះអ្នកជំនាញបកប្រែភាសាបរទេស ព្រោះសំណុំរឿង ក្នុងសាលាដំបូងខេត្តព្រះសីហនុ មានជនបរទេសច្រើនជាតិសាសន៍។

-កង្វះក្រឡាបញ្ជី និងមន្ត្រីអាជ្ញាសាលា។

-កង្វះទីតាំង ឬឃ្លាំងដាក់វត្ថុចាប់យក, កន្លែងដាក់វត្ថុចាប់យកមានភាពតូចចង្អៀត។

-បណ្តឹងជិតចិត្តមានចំនួនច្រើន ក្នុងសំណុំរឿងតែមួយ និងការស្នើសុំពន្យាពេលក្នុងនីតិវិធីច្រើនដងជាដដែលៗ ធ្វើឱ្យការដោះស្រាយសំណុំរឿង មានភាពយឺតយ៉ាវ។

-ការអនុវត្តលក់មិនមានអ្នកទិញ មានការលំបាកចំពោះអចលនវត្ថុ ដែលមិនទាន់បាន ចុះបញ្ជី និង ឈានដល់ដំណាក់កាលលក់ តែពុំមានអ្នកទិញ។

-ការបង្វិលត្រឡប់នៃដីការកោះ និងឯកសារផ្សេងៗ ពុំទាន់មានប្រសិទ្ធភាពខ្ពស់។

៤. សំណូមពរ

-ស្នើសុំអ្នកបកប្រែភាសាបរទេស និងប្រាក់ឧបត្ថម្ភ។

-ស្នើសុំឃ្លាំងដាក់វត្ថុចាប់យក។

-ស្នើសុំក្រឡាបញ្ជី និងមន្ត្រីអាជ្ញាសាលាបន្ថែម។

- ស្នើសុំបង្កើតវគ្គបណ្តុះបណ្តាលមន្ត្រី ផ្នែករដ្ឋបាល និងពត៌មានវិទ្យា។

៥. ទិសដៅការងារសម្រាប់ឆ្នាំ ២០២៥

-បន្តអនុវត្តច្បាប់ឱ្យបានម៉ឺងម៉ាត់ ត្រឹមត្រូវ និងយុត្តិធម៌ ដើម្បីរួមចំណែកលើកកម្ពស់ការបម្រើសេវាសាធារណៈឱ្យមានប្រសិទ្ធភាព ធានាបាននូវការការពារផលប្រយោជន៍ និងសុវត្ថិភាពសង្គម តាមរយៈយន្តការកាត់ក្តីឱ្យបានឆាប់រហ័ស ពិសេសសំណុំរឿងហានិភ័យ និងសំណុំរឿងដែលត្រូវយកចិត្តទុកដាក់ខ្ពស់។

-ត្រូវបន្តអនុវត្តដោយហ្មត់ចត់ និងកំណត់កាលបរិច្ឆេទជំនុំជម្រះ ឱ្យបានឆាប់រហ័សរឿងក្តីគ្រប់ប្រភេទ របាយការណ៍ នៃការបញ្ជូន ការជូនដំណឹងអំពីសេចក្តីសម្រេចនានា ដល់ភាគី ដើម្បីធានាប្រសិទ្ធភាពនៃ ការអនុវត្តសិទ្ធិទទួលបាននូវសេវាយុត្តិធម៌ ឆាប់រហ័សរបស់ប្រជាពលរដ្ឋ និងលើកកម្ពស់វិស័យច្បាប់ឱ្យកាន់តែមានលក្ខណៈល្អប្រសើរ។

-ត្រូវបង្កើនសមត្ថភាពជំនាញ ការគោរពវិន័យបទបញ្ជាផ្ទៃក្នុងឱ្យបានហ្មត់ចត់ ដោយប្រកាន់ខ្ជាប់នូវ អភិក្រមទាំងប្រាំ របស់សម្តេចអគ្គមហាសេនាបតីតេជោ (ឆ្នុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់) និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានខ្លឹមសារថា "សម្អាតផ្ទះយើង" ព្រមទាំងអនុវត្តឱ្យបានម៉ឺនម៉ាត់នូវក្រមសីលធម៌វិជ្ជាជីវៈ ដែលមានចែងក្នុងច្បាប់។

-ត្រូវបន្តខិតខំរៀបចំសេចក្តីសម្រេចគ្រប់ប្រភេទឱ្យមានលក្ខណៈត្រឹមត្រូវទាំងផ្នែកអង្គហេតុ សំអាងហេតុ និងផ្នែកសេចក្តីសម្រេច ដែលមានកំណត់ក្នុងច្បាប់។

-ត្រូវបន្តសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធ និងអង្គភាពនានា ដែលបម្រើវិស័យយុត្តិធម៌ ឱ្យបានល្អប្រសើរ ដើម្បីលើកកម្ពស់ និងការពង្រឹងប្រសិទ្ធភាព នៃច្បាប់ក្នុងវិស័យយុត្តិធម៌ ឱ្យកាន់តែល្អប្រសើរ។

-ត្រូវរិតចំណងសាមគ្គីភាពផ្ទៃក្នុងឱ្យបានល្អប្រសើរ។

-ជម្រុញការចុះបញ្ជីសំណុំរឿងក្តីតាមប្រព័ន្ធទិន្នន័យ ឲ្យបានឆាប់រហ័ស និងទាន់ពេលវេលា។

-ជម្រុញឲ្យមាន ប្រព័ន្ធទិន្នន័យចុះបញ្ជីសំណុំរឿងរដ្ឋប្បវេណី របស់ក្រសួងយុត្តិធម៌។

-ជម្រុញឲ្យមានការបណ្តុះបណ្តាល ជំនាញកិច្ចការរដ្ឋបាល លេខាធិការដ្ឋាន ដល់មន្ត្រីលេខាធិការដ្ឋាន។

ថ្ងៃអង្គារ ៦កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ខេត្តព្រះសីហនុ, ថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៥

ប្រធានលេខាធិការដ្ឋានរដ្ឋបាល

ឈឹ ចាន់ណារ័ត្ន

បានឃើញ និង ឯកភាព

ខេត្តព្រះសីហនុ, ថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៥

ប្រធានសាលាដំបូង

ង៉ោ ចន្ទី

ព្រះរាជអាជ្ញា

អ៊ុច ត្រាយ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង និងអយ្យការអម
សាលាដំបូងខេត្តកោះកុង

របាយការណ៍ការងារសង្ខេប
សម្រាប់សន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារអនាគត ឆ្នាំ២០២៥
សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកោះកុង

==========

១. ស្ថានភាពទូទៅ

ក- ធនធានមនុស្ស

- សាលាដំបូងខេត្តកោះកុង: ដឹកនាំដោយប្រធានសាលាដំបូងចំនួន០១ រូប អនុប្រធានចំនួន០១ រូប មានចៅក្រម ចំនួន០៧ រូប (ស្ត្រី០១រូប) និងក្រឡាបញ្ជីចំនួន១០ (ស្ត្រី០៣រូប) ។

- **អយ្យការអមសាលាដំបូងខេត្តកោះកុង**: ដឹកនាំដោយព្រះរាជអាជ្ញាចំនួន០១រូប (ស្រី) មានព្រះរាជអាជ្ញារងចំនួន០៣រូប និង មានក្រឡាបញ្ជីចំនួន០៥ រូប។

- **លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង**: ដឹកនាំដោយប្រធានលេខាធិការដ្ឋានរដ្ឋបាលស្តីទី ចំនួន ០១រូប អនុប្រធានចំនួន០២រូប ស្រី០១រូប មានមន្ត្រីរដ្ឋបាលចំនួន២០រូប មន្ត្រីជាប់កិច្ចសន្យាចំនួន២៣រូប ជាជំនួយការ ។

ខ. ព្រឹត្តិការណ៍ ឬកម្មវិធីការងារឆានាន (កិច្ចប្រជុំ ឬជំនួបពិភាក្សាការងារជាមួយស្ថាប័នដែលមានការពាក់ព័ន្ធ ជាអាទិ៍ សាលាខេត្ត, ពន្ធនាគារ, មន្ត្រីនគរបាលយុត្តិធម៌, ប្រតិភូ ឬក្រុមការងាររបស់ក្រសួងយុត្តិធម៌, កិច្ចប្រជុំខេត្តជាប់ព្រំដែន)សរុបចំនួន ១៦ លើក ។

២. សមិទ្ធផលការងារ

ក. អយ្យការអមសាលាដំបូង:

ក.១. ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌ

ឆ្នាំ	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	សល់ពីមុនកំពង់ចាត់ការ	ផ្សេងៗ
២០២៤	៥៧	៤៥៨	៤៩៥	២០	
ខែមករា ២០២៥	២០	៤៧	៤៣	២៤	
ខែកុម្ភៈ ២០២៥	២៤	២៦	២៤	២៦	

ក.២. កិច្ចការពាក់ព័ន្ធនឹងការអនុវត្តទោស និងពន្ធនាគារ

ក.២.១- ការអនុវត្តទោសក្នុងពន្ធនាគារខេត្តកោះកុង ក្នុងឆ្នាំ២០២៤ មានចំនួន សរុប ៦៣៥ ក្នុងនោះមាន:

- អនុវត្តទោសដោយសាលក្រមមានចំនួន ៥៨៤នាក់ ស្រី២៥នាក់

- អនុវត្តទោសដោយសាលដីកាសាលាឧទ្ធរណ៍មានចំនួន ៤៨នាក់ ស្រី០៧នាក់
- អនុវត្តទោសដោយសាលដីកាតុលាកំពូលមានចំនួន ០៧នាក់ ស្រី០១នាក់

ក.២.២- ការអនុវត្តទោសក្នុងពន្ធនាគារខេត្តកោះកុង ក្នុងខែមករា ឆ្នាំ២០២៥ មានចំនួនសរុប ៦២៧ ក្នុងនោះមាន៖

- អនុវត្តទោសដោយសាលក្រមមានចំនួន ៥៧៥នាក់ ស្រី៣៥នាក់
- អនុវត្តទោសដោយសាលដីកាសាលាឧទ្ធរណ៍មានចំនួន ៤៥នាក់ ស្រី០៨នាក់
- អនុវត្តទោសដោយសាលដីកាតុលាកំពូលមានចំនួន ០៧នាក់ ស្រី០១នាក់

ក.២.៣- ការអនុវត្តទោសក្នុងពន្ធនាគារខេត្តកោះកុង ក្នុងខែកុម្ភៈ ឆ្នាំ២០២៥ មានចំនួនសរុប ៦១៥ ក្នុងនោះមាន៖

- អនុវត្តទោសដោយសាលក្រមមានចំនួន ៥៦៥នាក់ ស្រី៣៥នាក់
- អនុវត្តទោសដោយសាលដីកាសាលាឧទ្ធរណ៍មានចំនួន ៤៣នាក់ ស្រី០៨នាក់
- អនុវត្តទោសដោយសាលដីកាតុលាកំពូលមានចំនួន ០៧នាក់ ស្រី០១នាក់

ក.២.៤- ជនជាប់ឃុំជាក់ស្តែង ក្នុងឆ្នាំ២០២៤ មានចំនួន សរុប ៧៥១នាក់ ស្រី ៥៧នាក់ ក្នុងនោះមាន៖

- ជនត្រូវចោទ ចំនួន ៨២នាក់ ស្រី១៤នាក់ អនីតិជន ០៤នាក់ ស្រី០០នាក់ ជនបរទេស ០២នាក់ ស្រី០០នាក់។
-នាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ឯកឧត្តម **សួស ឡា** ប្រធានសាលាដំបូង និងឯកឧត្តម **វង្ស ប៊ុនវិសុទ្ធ** ព្រះរាជអាជ្ញា បានចូលរួមកិច្ចប្រជុំបូកសរុបការងារប្រចាំឆ្នាំ២០២៣ និងលើកផែនការឆ្នាំ២០២៤ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (ក.ជ.ក.ស) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំវិដួល ជាន់ទី ១ វិមានសន្តិភាព ទីស្តីការគណៈរដ្ឋមន្ត្រី។

-នាថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ លោក **ឈន ចាន់ដែត** ប្រធានលេខាធិការដ្ឋានរដ្ឋបាល បានចូលរួមសិក្ខាសាលាស្តីពីវឌ្ឍនភាពយុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ(គ.ជ.ព) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **កើត រិទ្ធ** ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៅរាជបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា។

-នាថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤ លោក **ឈន ចាន់ដែត** ប្រធានលេខាធិការដ្ឋានរដ្ឋបាល បានចូលរួមសិក្ខាសាលាផ្លាស់ប្តូរបទពិសោធន៍ក្រឡាបញ្ជី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **សួន ឥសាល** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ នៅសាលប្រជុំ នៃភោជនីយដ្ឋានទន្លេបាសាក់២។

-នាថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៤ ឯកឧត្តម **សួស ឡា** ប្រធានសាលាដំបូង និងឯកឧត្តម **វង្ស ប៊ុនវិសុទ្ធ** ព្រះរាជអាជ្ញា បានចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផល នៃការអនុវត្តយុទ្ធនាការជំរុញនិងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និងយុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **កើតរិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៅទីស្តីការក្រសួងយុត្តិធម៌។

-នាថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៤ ឯកឧត្តម **សួស ឡា** ប្រធានសាលាដំបូង និងឯកឧត្តម **វង្ស ប៊ុនវិសុទ្ធ** ព្រះរាជអាជ្ញា បានចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីប្រគល់វិញ្ញាបនបត្រដល់សិស្សមេធាវី និងសិក្ខាកាមមេធាវី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅមជ្ឈមណ្ឌលសន្និបាទ និងពិព័រណ៌អន្តរជាតិជ្រោយចង្វារ។

-នាថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤ ឯកឧត្តម **សួស ឡា** ប្រធានសាលាដំបូង និងឯកឧត្តម **វង្ស ប៊ុនវិសុទ្ធ** ព្រះរាជអាជ្ញា បានចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផល នៃការអនុវត្តយុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និងយុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **កើតរិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៅបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា។

២. សមិទ្ធផលការងារ

ក. អយ្យការអមសាលាដំបូង៖

ក.១. ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌ

សំណុំរឿង			ចំណាត់ការ			សល់កំពុងចាត់ការ			% នៃចំណាត់ការ		
សរុប	ចាស់	ថ្មី	សរុប	ចាស់	ថ្មី	សរុប	ចាស់	ថ្មី	សរុប	ចាស់	ថ្មី
១៣៩៥	១៤៥	១២៥០	១៣៣០	១៤៥	១១៨៥	៦៥	០	៦៥	៩៥%	១០០%	៩៥%

ក.២. កិច្ចការពាក់ព័ន្ធនឹងការអនុវត្តទោស និងពន្ធនាគារ

ក.២.១. ការអនុវត្តទោសដោយព្រះរាជអាជ្ញា

សេចក្តីសម្រេចស្តាពរ	រឿងចាស់	ចូលថ្មី	សរុប	ចាត់ការរួច	សល់កំពុងចាត់ការ
សាលក្រមព្រហ្មទណ្ឌ	៦៣១	៧៩៣	១៤២៤	៥១៥	៩០៩
សាលដីកាព្រហ្មទណ្ឌសាលាឧទ្ធរណ៍	១៣	១៧	៣០	៥	២៥
សាលដីកាព្រហ្មទណ្ឌតុលាការកំពូល	៦	៦	១២	០	១២
សរុប	**៦៥០**	**៨១៦**	**១៤៦៦**	**៥២០**	**៩៤៦**

ក.២.២. ពន្ធនាគារខេត្តកំពង់ចាម

ជនជាប់ឃុំ	សរុបរួម		អនីតិជន		នីតិជន		ជនបរទេស	
	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី
ជនត្រូវចោទ	៣១១	១៥	៣៧	១	២៧៣	១៤	១	០
ជនជាប់ចោទ	៣០៩	៦	៦៨	១	២៤១	៥	០	០
ពិរុទ្ធជន	៥១៨	៧	៤៥	០	៤៧០	៧	៣	០
ទណ្ឌិត	៩៤៦	២០	២៩	០	៩១៥	២០	២	០
សរុប	**២០៨៤**	**៤៨**	**១៧៩**	**២**	**១៨៩៩**	**៤៦**	**៦**	**០**

ក.៣. កិច្ចការពាក់ព័ន្ធជាមួយនឹងមន្ត្រីនគរបាលយុត្តិធម៌

-នាថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២៤ អយ្យការអមសាលាដំបូងខេត្តកំពង់ចាម បានរៀបចំកិច្ចប្រជុំស្តីពី "**ព្រះរាជអាជ្ញា និងមន្ត្រីនគរបាលយុត្តិធម៌**" ដោយមានការចូលរួមពីអង្គភាពនគរបាលយុត្តិធម៌ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម ក្រោមអធិបតីភាពឯកឧត្តម **វង្ស ប៊ុនវិសុទ្ធ** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តកំពង់ចាម។

-ក្រោមការចាត់តាំងរបស់ឯកឧត្តម **វង្ស ប៊ុនវិសុទ្ធ** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តកំពង់ចាម បានចាត់តាំងលោកព្រះរាជអាជ្ញារងទាំងអស់ ចុះទៅធ្វើអធិការកិច្ចនៅស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តកំពង់ចាម និងតាមបណ្តាអធិការដ្ឋាននគរបាល បញ្ជាការដ្ឋានកងរាជអាវុធហត្ថក្រុងស្រុកទាំង១០ នៃខេត្តកំពង់ចាម ដើម្បីធ្វើការពិនិត្យទៅលើបញ្ជីបណ្តឹង មណ្ឌលឃាត់ខ្លួន ព្រមទាំងដោះស្រាយបញ្ហាប្រឈមផ្សេងៗដែលកើតមានក្នុងពេលអនុវត្តនីតិវិធី ជាលទ្ធផលលោកព្រះរាជអាជ្ញារងទាំងអស់ បានធ្វើការពិនិត្យលើការងារទាំងអស់ប្រកបដោយប្រសិទ្ធភាព។

ខ. សាលាដំបូង៖

ខ.១. ចំណាត់ការលើសំណុំរឿងព្រហ្មទណ្ឌ

ខ.១.១. ដំណាក់កាលស៊ើបសួរ

សំណុំរឿង			ចំណាត់ការ			សល់កំពុងចាត់ការ			% នៃចំណាត់ការ		
សរុប	ចាស់	ថ្មី	សរុប	ចាស់	ថ្មី	សរុប	ចាស់	ថ្មី	សរុប	ចាស់	ថ្មី
១២៨៥	៤៤០	៨៤៥	៩៨០	៣៩០	៥៩០	៣០៥	៥០	២៥៥	៧៦%	៨៩%	៧០%

ខ.១.២. ដំណាក់កាលជំនុំជម្រះ

សំណុំរឿង			ចំណាត់ការ			សល់កំពុងចាត់ការ			% នៃចំណាត់ការ		
សរុប	ចាស់	ថ្មី	សរុប	ចាស់	ថ្មី	សរុប	ចាស់	ថ្មី	សរុប	ចាស់	ថ្មី
១១៥០	២៤៥	៩០៥	៩៤៦	២១៦	៧៣០	២០៤	២៩	១៧៥	៨២%	៨៨%	៨១%

ខ.២. ចំណាត់ការលើសំណុំរឿងរដ្ឋប្បវេណី

សំណុំរឿង			ចំណាត់ការ			សល់កំពុងចាត់ការ			% នៃចំណាត់ការ		
សរុប	ចាស់	ថ្មី	សរុប	ចាស់	ថ្មី	សរុប	ចាស់	ថ្មី	សរុប	ចាស់	ថ្មី
៧០៨៣	១៧០៤	៥៣៧៩	៥៧៤២	១០៧៤	៤៦៦៨	១៣៤១	៦៣០	៧១១	៨១%	៦៣%	៨៧%

ខ.៣. ចំណាត់ការសំណុំរឿងអនុវត្ត

សំណុំរឿង			ចំណាត់ការ			សល់កំពុងចាត់ការ			% នៃចំណាត់ការ		
សរុប	ចាស់	ថ្មី	សរុប	ចាស់	ថ្មី	សរុប	ចាស់	ថ្មី	សរុប	ចាស់	ថ្មី
៤៨៨	៣៥០	១៣៨	៤៥	២២	២៣	៤៤៣	៣២៨	១១៥	៩%	៦%	១៧%

៣. បញ្ហាប្រឈម និងសំណូមពរ

៣.១. បញ្ហាប្រឈម

-ភាពមិនច្បាស់លាស់ នៃសេចក្តីសម្រេចរបស់តុលាការ "លិខិតអនុវត្តមាត្រា៣៥០ និងមាត្រា៤៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី" ដែលនាំឱ្យមានការលំបាកក្នុងការកំណត់សមត្ថកិច្ចរបស់តុលាការអនុវត្ត ឬ អាជ្ញាសាលា ដែលនាំឱ្យមានការផ្ទេរសមត្ថកិច្ចទៅវិញទៅមកនាំឱ្យខាតពេលវេលា

-ការបញ្ជូនដីកាមិនដល់ភាគីដែលត្រូវទទួលការបញ្ជូន ដោយកត្តាផ្សេងៗ ដូចជាការចំណាកស្រុក ការផ្លាស់ប្តូរទីលំនៅជាដើម

-គ្មានមន្ត្រីអាជ្ញាសាលា នាំឱ្យការបញ្ជូនមានការលំបាក ដែលក្រឡាបញ្ជីធ្វើការងារបច្ចេកទេសផង និងទទួលបន្ទុកកិច្ចការបញ្ជូនផង

-ការប្រើប្រាស់សេវាកម្មរបស់ប្រៃសណីយ៍ដើម្បីបញ្ជូន ឬ កោះហៅ ឬ ជូនដំណឹងអំពីសេចក្តីសម្រេចផ្សេងៗ របស់តុលាការមិនមានប្រសិទ្ធភាព

-សាលក្រមបានបញ្ជូនទៅពន្ធនាគាររួចរាល់ ប៉ុន្តែមន្ត្រីពន្ធនាគារពុំបានធ្វើបច្ចុប្បន្នភាពហើយទាមទារឱ្យចៅក្រមទទួលបន្ទុកផ្តល់ម្តងទៀត។

៣.២. សំណូមពរ

-ស្នើឱ្យមានកិច្ចប្រជុំជាមួយពន្ធនាគារដើម្បីពិភាក្សាបញ្ហាបញ្ជូនសាលក្រម ការចារសាលក្រមស្តាពរ ការធ្វើបញ្ជីបច្ចុប្បន្នភាព នៃសាលក្រមជាដើម

-ក្រឡាបញ្ជីសូមបញ្ជូនសាលក្រម សាលក្រមកំបាំងមុខ និងសាលក្រមស្តាពរមករដ្ឋបាលឱ្យបានឆាប់រហ័ស ដើម្បីរដ្ឋបាលចាត់ចែងបន្តឱ្យមានប្រសិទ្ធភាព

-ស្នើដល់ចៅក្រមជំនុំជម្រះ ឬ ក្រុមប្រឹក្សាជំនុំជម្រះអនុវត្តការបញ្ឈប់អានុភាពដីកាចាប់ខ្លួនរបស់ចៅក្រមស៊ើបសួរ និងចេញដីកាចាប់ខ្លួនតាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

-ស្នើសុំឱ្យគ្រប់សាលក្រម ឬ សេចក្តីសម្រេចរបស់តុលាការ ត្រូវមានសំអាងហេតុ និងសំអាងច្បាប់ឱ្យបានច្បាស់លាស់

-ស្នើសុំឱ្យក្រឡាបញ្ជីដែលចារស្តាពរលើសាលក្រមព្រហ្មទណ្ឌ ត្រូវចុះហត្ថលេខា និងវាយត្រាដោយក្រឡាបញ្ជី និងចៅក្រមទទួលបន្ទុកឱ្យរួចរាល់មុនបញ្ជូនចេញទៅរដ្ឋបាល។

៤. ទិសដៅការងារសម្រាប់ឆ្នាំ ២០២៥

-កំណត់ឱ្យមានកិច្ចប្រជុំផ្ទៃក្នុងអំពីបែបបទនៃការអនុវត្ត និងកំណត់សមត្ថកិច្ចរបស់ស្ថាប័នអនុវត្តដែលជាតុលាការ និងអាជ្ញាសាលា

-កំណត់ឱ្យមានកិច្ចប្រជុំផ្ទៃក្នុងដើម្បីកំណត់អំពីចំនួនសាលក្រមកំបាំងមុខ និងការជូនដំណឹងអំពីសាលក្រមកំបាំងមុខ

-ជម្រុញការអនុវត្តសំណុំរឿងអាទិភាព រួមមានសំណុំរឿងគ្រឿងញៀន សំណុំរឿងចរាចរណ៍ សំណុំរឿងក្មេងទំនើង និងសំណុំរឿងអគ្រានុកូលដ្ឋាន

-ជម្រុញការអនុវត្តឱ្យមានប្រសិទ្ធភាព តាមយុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និងយុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ

-ជម្រុញអនុវត្តតាមគោលការណ៍ណែនាំរបស់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ដោះស្រាយសំណុំរឿងចាស់ឱ្យបាន ៩៥% និងចាត់ការសំណុំរឿងថ្មីឱ្យបាន ៨៥% នៃសំណុំរឿងសរុប

-កំណត់ឱ្យមានកិច្ចប្រជុំរវាងតុលាការ អយ្យការ និងពន្ធនាគារ អំពីការដោះស្រាយបញ្ហាការបញ្ជូនសាលក្រមរួចទាមទារឱ្យផ្តល់ម្តងទៀត

-យកចិត្តទុកដាក់ធ្វើ និងបញ្ជូនសាលក្រមក្នុងរយៈពេល១០ ថ្ងៃ ក្រោយការប្រកាសសាលក្រម

-កំណត់ឱ្យមានកិច្ចប្រជុំដើម្បីពិភាក្សាអំពីរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នលើអនីតិជន និងបញ្ហាផ្សេងៗ

-កំណត់ឱ្យមានកិច្ចប្រជុំកម្រិតបច្ចេកទេស អំពីការអនុវត្តមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ថ្ងៃចន្ទ ៥កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
កំពង់ចាម, ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២៥
ប្រធានលេខាធិការដ្ឋានរដ្ឋបាល

ឈន-ចាន់ដែត

បានឃើញ និង ឯកភាព
កំពង់ចាម, ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២៥
ព្រះអជអាជ្ញា

ទឡ-ប៊ុនវិសុទ្ធ

ប្រធានសាលាដំបូង

សួស-ឡា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង និងអយ្យការអម
សាលាដំបូងខេត្តកំពង់ធំ

របាយការណ៍ការងារសេសចេញរបស់សាលាជម្រះក្តី
សម្រាប់សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំយុត្តិធម៌ ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារអាទិភាព ឆ្នាំ២០២៥
សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកំពង់ធំ

I. ស្ថានភាពទូទៅ

សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកំពង់ធំ គឺជាសាលាជម្រះក្តីជាន់ទាប ដែលមានទីតាំងស្ថិតនៅភូមិទី៧ សង្កាត់កំពង់ធំ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ហើយមានលេខាធិការដ្ឋានរដ្ឋបាលជាសេនាធិការឱ្យ សាលាដំបូង និងអយ្យការអមសាលាដំបូង តាមមាត្រា១០ មាត្រា៣២ មាត្រា៣៣ និងមាត្រា៣៤ នៃច្បាប់ស្តីការរៀបចំអង្គការតុលាការ។

ក- ធនធានមនុស្ស

ល.រ	តួនាទី	ចំនួន	ស្ត្រី	ផ្សេងៗ
ក.សាលាដំបូងខេត្តកំពង់ធំ				
១	ប្រធានសាលាដំបូង	០១ រូប	០០ រូប	
២	អនុប្រធានសាលាដំបូង	០១ រូប	០០ រូប	
៣	ចៅក្រម	១០ រូប	០២ រូប	
៤	ក្រឡាបញ្ជី	១៦ រូប	០៤ រូប	
សរុប		**២៨ រូប**	**០៦ រូប**	
ខ.អយ្យការអមសាលាដំបូងខេត្តកំពង់ធំ				
១	ព្រះរាជអាជ្ញា	០១ រូប	០០ រូប	
២	ព្រះរាជអាជ្ញារង	០៦ រូប	០១ រូប	
៣	ក្រឡាបញ្ជី	០៨ រូប	០២ រូប	
សរុប		**១៥ រូប**	**០២ រូប**	
គ.លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តកំពង់ធំ				
១	ប្រធានលេខាធិការដ្ឋាន	០១ រូប	០០ រូប	
២	អនុប្រធានលេខាធិការដ្ឋាន	០៤ រូប	០០ រូប	
៣	ប្រធានការិយាល័យ	០៤ រូប	០៤ រូប	
៤	អនុប្រធានការិយាល័យ	០៨ រូប	០៥ រូប	
៥	មន្ត្រីគ្រប់គ្រងរដ្ឋបាល	១៨ រូប	១១ រូប	

៦	មន្ត្រីក្រមការ	០០ រូប	០០ រូប	
៧	លេខាធិការដ្ឋបាល	០០ រូប	០០ រូប	
៨	មន្ត្រីជាប់កិច្ចសន្យា	១៤ រូប	៩ រូប	
៩	អ្នកជំនួយការ	១៨ រូប	១២ រូប	
សរុប		**៦៩ រូប**	**៤១ រូប**	
សរុបរួម		**១១២ រូប**	**៤៩ រូប**	

២- ហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន

សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកំពង់ធំ មានអគារធ្វើការចំនួន ៤ ក្នុងនោះអគារធំចំនួន ០២ និងអគារតូចចំនួន ២ ក្នុងនោះមានអគារសាលប្រជុំចំនួន ០១ ដែលអាចផ្ទុកអ្នកចូលរួមបានចំនួន ៩០នាក់ ដោយបំពាក់ម៉ាស៊ីនត្រជាក់ និងឧបករណ៍បំពងសម្លេង សម្រួលការប្រជុំ ឬប្រារព្ធកម្មវិធីធំៗបាន និងមានឡាំងមួយដែលទើបបានជួលសម្រាប់ដាក់វត្ថុតាងចំនួន ០១ ដែលមានទំហំ ២០ម៉ែត្រ គុណនឹង ២៥ ម៉ែត្រ ។

គ. លទ្ធផលសន្និដ្ឋានផ្ទៃក្នុងស្ថាប័នសម្រាប់ឆ្នាំ ២០២៤

-បានពង្រឹងសមត្ថភាព ចៅក្រម ព្រះរាជអាជ្ញារង ក្រឡាបញ្ជី និងមន្ត្រីលេខាធិការដ្ឋានរដ្ឋបាលតាម រយៈការបណ្តុះបណ្តាល និងការចែករំលែកចំណេះដឹងផ្ទៃក្នុង

-បានចាត់ការរឿងក្តីគ្រប់ប្រភេទដែលនៅសល់ពីឆ្នាំចាស់ និងរឿងក្តីចូលថ្មី បានឆាប់រហ័ស ត្រឹមត្រូវ យុត្តិធម៌ និងប្រកបដោយការទទួលខុសត្រូវខ្ពស់

-លើកកម្ពស់ក្នុងការផ្តល់សេវាយុត្តិធម៌តាមរយៈការរៀបចំ និងផ្តល់ជូននូវគម្រូឯកសារពាក្យបណ្តឹង ពាក្យស្នើសុំបញ្ចូលសាក្សី ពាក្យស្នើសុំបញ្ចូលកស្តុតាង និងឯកសារនានា ដល់ប្រជាពលរដ្ឋដែលមកកសេវាយុត្តិធម៌

-គ្រប់គ្រង ពង្រឹងសមត្ថភាព និងក្រមសីលធម៌របស់មន្ត្រីនគរបាលយុត្តិធម៌តាមរយៈការចុះអធិការកិច្ចជាប្រចាំ និងការដាក់ចេញនូវការបណ្តុះបណ្តាល ការអប់រំ សិក្ខាសាលា នៅស្នងការដ្ឋាននគរបាលខេត្ត បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត បណ្តាអធិការដ្ឋាន និងបញ្ជាការដ្ឋានកងរាជអាវុធហត្ថក្រុង/ស្រុក

-បានពង្រឹងប្រសិទ្ធភាពការងារក្នុងការគ្រប់គ្រងពន្ធនាគារខេត្តកំពង់ចាម តាមរយៈការដាក់ចេញនូវទិសដៅក្នុងការចុះអធិការកិច្ចពន្ធនាគារជាប្រចាំ ការពង្រឹងលើការទាមទារប្រាក់ពិន័យ និងការដាក់គុកបង្ខំរូបកាយ

-សហការចុះធ្វើការអប់រំផ្សព្វផ្សាយច្បាប់ ជាមួយរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុងស្រុក សម្រាប់ធ្វើការផ្សព្វផ្សាយអំពីច្បាប់ព្រហ្មទណ្ឌ នីតិវិធីព្រហ្មទណ្ឌ បទល្មើសគ្រឿងញៀន បទល្មើសចរាចរណ៍ ការជួញដូរមនុស្សជាអាទិ៍

ឃ. ព្រឹត្តិការណ៍ ឬកម្មវិធីការងារនានា

-ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៤៖ ចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារគ្រប់គ្រង និងការពារធនធានធម្មជាតិក្នុងភូមិសាស្ត្រខេត្តកំពង់ធំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **ងួន រតនៈ** អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ និងជាប្រធានគណៈកម្មការគ្រប់គ្រងការពារធនធានធម្មជាតិ។

-ថ្ងៃទី០៧ ខែសីហា និងថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២៤៖ កិច្ចប្រជុំស្តីពីការពង្រឹងកិច្ចសហការអនុវត្តច្បាប់ព្រហ្មទណ្ឌ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **រស់ សារ៉ាំ** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តកំពង់ធំ នៅសាលាស្រុកសន្ទុក និងសាលាស្រុកកំពង់ស្វាយ ។

-ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៤៖ កិច្ចប្រជុំស្តីពី ការពង្រឹងការអនុវត្តនីតិវិធីពាក់ព័ន្ធពន្ធនាគារ និងបញ្ហាប្រឈមផ្សេងៗ។

-ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២៤៖ កិច្ចប្រជុំស្តីពីការពង្រឹងការអនុវត្តវិធានការនិរន្តរាយ និងការផ្សព្វផ្សាយការអនុវត្តនីតិវិធីពាក់ព័ន្ធមន្ត្រីនគរបាលយុត្តិធម៌។

-ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៤៖ ការចុះអធិការកិច្ចរបស់សភាស៊ើបសួរសាលាឧទ្ធរណ៍ក្បួងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ក្បួងឃ្មុំ។

II. សមិទ្ធផលការងារ

ក. អយ្យការអមសាលាដំបូង៖

ក.១. ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌ

ល.រ	សំណុំរឿងសរុប	សំណុំរឿងសល់ពីមុន	សំណុំរឿងចូលថ្មី	សំណុំរឿងចាត់ការរួច	សំណុំរឿងកំពុងចាត់ការ	ផ្សេងៗ
១	១៤៨៩	២២៥ រឿង	១២៦៤ រឿង	១៣៦២ រឿង	១២៧ រឿង	

ក.២. កិច្ចការពាក់ព័ន្ធនឹងការអនុវត្តទោស និងពន្ធនាគារ

ក.២.១ អំពីជនជាប់ឃុំក្នុងពន្ធនាគារ

បរិយាយ	សរុបរួម		អនីតិជន		នីតិជន		ជនបរទេស	
	ប្រុស	ស្រី	ប្រុស	ស្រី	ប្រុស	ស្រី	ប្រុស	ស្រី
ក.ប្រចាំឆ្នាំ២០២៤								
ជនត្រូវចោទ	២១៦	០៨	២៣	០០	១៩៣	០៨	០១	០១
ជនជាប់ចោទ	៩៧	០៣	១៤	០០	៨៣	០៣	០០	០០
ពិរុទ្ធជន	២៥៧	០៩	១៩	០០	២៣៨	០៩	០៤	០០
ទណ្ឌិត	៤៨០	០៦	១៨	០០	៤៦២	០៦	០២	០០
សរុបជនជាប់ឃុំ	១០៥០	២៦	៧៤	០០	៩៧៦	២៦	០៧	០១

ក.២.២ ការអនុវត្តទោសដោយព្រះរាជអាជ្ញា

ល.រ	សេចក្តីសម្រេចស្តាពរ	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	កំពុងចាត់ការ
ក.ប្រចាំឆ្នាំ២០២៤					
១	សាលក្រមព្រហ្ម	៤២	៣៨	៦៦	១៤
២	សាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍	០០	០០	០០	០០
៣	សាលដីកាព្រហ្មទណ្ឌរបស់តុលាការកំពូល	០១	០១	០១	០១
៤	សាលក្រម ឬសាលដីការបស់តុលាការបរទេស	០០	០០	០០	០០
សរុប		**៤៣**	**៣៩**	**៦៧**	**១៥**

ក.៣. កិច្ចការពាក់ព័ន្ធជាមួយនឹងមន្ត្រីនគរបាលយុត្តិធម៌

-ចុះអធិការកិច្ចនៅក្នុងពន្ធនាគារខេត្តកំពង់ធំ ធ្វើឡើងជារៀងរាល់០១ខែម្តង ។

-បានធ្វើការប្រជុំស្តីអំពីកិច្ចសហការ ការអនុវត្តច្បាប់ព្រហ្មទណ្ឌ ជាមួយនឹងគណៈបញ្ជាការឯកភាពក្រុង/ស្រុក (ស្រុកកំពង់ស្វាយ និងស្រុកសន្ទុក)។

-បានចូលរួមធ្វើសម្បថ ជូននគរបាលយុត្តិធម៌ ដូចជាមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកំពង់ធំ ។

-បានធ្វើការប្រជុំស្តីពីការអនុវត្តដីកា ជាមួយអង្គភាពមន្ត្រីនគរបាលយុត្តិធម៌ ក្នុងដែនសមត្ថកិច្ចខេត្តកំពង់ធំ រួមមានស្នងការនគរបាលខេត្តកំពង់ធំ, កងរាជអាវុធហត្ថខេត្តកំពង់ធំ, មន្ទីរបរិស្ថានខេត្តកំពង់ធំ និងមន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទខេត្តកំពង់ធំ (មន្ត្រីរដ្ឋបាលជលផល និងរដ្ឋបាលព្រៃឈើ)។

-ចូលរួមសម្របសម្រួលជាមួយអាជ្ញាធរដែនដីមាន រដ្ឋបាលសាលាខេត្ត អភិបាលក្រុង/ស្រុក ក្នុងការបង្ការទប់ស្កាត់បទល្មើសព្រៃឈើ ព្រៃលិចទឹក និងបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ។

ខ. សាលាដំបូង៖

ខ.១. ចំណាត់ការលើសំណុំរឿងព្រហ្មទណ្ឌ

ខ.១.១. ដំណាក់កាលស៊ើបសួរ

ល.រ	សំណុំរឿងសរុប	សំណុំរឿងសល់ពីមុន	សំណុំរឿងចូលថ្មី	សំណុំរឿងចាត់ការរួច	សំណុំរឿងកំពុងចាត់ការ	ផ្សេងៗ
១	២១២៦	១២២៦ រឿង	៩០០ រឿង	៨៧៣ រឿង	៣៥៣ រឿង	

ខ.១.២. ដំណាក់កាលជំនុំជម្រះ

ល.រ	សំណុំរឿងសរុប	សំណុំរឿងសល់ពីមុន	សំណុំរឿងចូលថ្មី	សំណុំរឿងចាត់ការរួច	សំណុំរឿងកំពុងចាត់ការ	ផ្សេងៗ
១	១០៧២	២៦៧ រឿង	៨០៥ រឿង	៩០៣ រឿង	១៦៩ រឿង	

ខ.២. ចំណាត់ការលើសំណុំរឿងរដ្ឋប្បវេណី

ក.សំណុំរឿងអន្តរសេចក្តី

ល.រ	សំណុំរឿងសរុប	សំណុំរឿងសល់ពីមុន	សំណុំរឿងចូលថ្មី	សំណុំរឿងចាត់ការរួច	សំណុំរឿងកំពុងចាត់ការ	ផ្សេងៗ
១	៧០៩	២៣៦ រឿង	៤៧៣ រឿង	៤៩៣ រឿង	២១៦ រឿង	

ខ.សំណុំរឿងមិនមែនបណ្តឹង

ល.រ	សំណុំរឿងសរុប	សំណុំរឿងសល់ពីមុន	សំណុំរឿងចូលថ្មី	សំណុំរឿងចាត់ការរួច	សំណុំរឿងកំពុងចាត់ការ	ផ្សេងៗ
១	៣២១៦	១៤៥ រឿង	៣០៧១ រឿង	៣១៨៥ រឿង	៣១ រឿង	

ខ.៣. ចំណាត់ការសំណុំរឿងផ្សេងទៀត

គ.សំណុំរឿងរក្សាការពារ						
ល.រ	សំណុំរឿងសរុប	សំណុំរឿងសល់ពីមុន	សំណុំរឿងចូលថ្មី	សំណុំរឿងចាត់ការរួច	សំណុំរឿងកំពុងចាត់ការ	ផ្សេងៗ
១	១១១	២០ រឿង	៩១ រឿង	៩៨ រឿង	១៣ រឿង	
ឃ.សំណុំរឿងអនុវត្តរក្សាការពារ						
ល.រ	សំណុំរឿងសរុប	សំណុំរឿងសល់ពីមុន	សំណុំរឿងចូលថ្មី	សំណុំរឿងចាត់ការរួច	សំណុំរឿងកំពុងចាត់ការ	ផ្សេងៗ
១	៣៤	០៨ រឿង	២៦ រឿង	៣៣ រឿង	០១ រឿង	
ង.សំណុំរឿងអនុវត្តដោយបច្ចុំ						
ល.រ	ចៅក្រម	សំណុំរឿងសល់ពីមុន	សំណុំរឿងចូលថ្មី	សំណុំរឿងចាត់ការរួច	សំណុំរឿងកំពុងចាត់ការ	ផ្សេងៗ
សរុប		១៣៥ រឿង	៩១ រឿង	៥២ រឿង	១៧៤ រឿង	

III. បញ្ហាប្រឈម និងសំណូមពរ

១. កង្វះខាតមន្ត្រីអនុវត្តកិច្ចការបញ្ជូន ៖

១.១.ក្រឡាបញ្ជី ដើម្បីអនុវត្តកិច្ចសំណុំរឿងរដ្ឋប្បវេណី និងព្រហ្មទណ្ឌ។

១.២.អាជ្ញាសាលា ដើម្បីអនុវត្តកិច្ចការបញ្ជូននៅក្នុងសំណុំរឿងរដ្ឋប្បវេណី និងការជូនដំណឹងនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ។

២. កង្វះខាតថវិកាក្នុងការអនុវត្ត ជាពិសេសថវិកាក្នុងសំណុំរឿងព្រហ្មទណ្ឌ ។

៣. កង្វះខាតបច្ចេកទេសក្នុងការអនុវត្តច្បាប់ ជាពិសេសមន្ត្រីអនុវត្ត មិនទាន់មានការយល់ដឹងអំពីនីតិវិធីបញ្ជូនឱ្យបានត្រឹមត្រូវ បណ្តាលឱ្យការបញ្ជូនមានភាពយឺតយ៉ាវ ឬ មិនអាចទទួលយកបាន។

៤. ខ្វះអាជ្ញាសាលា ដើម្បីអនុវត្តការជូនដំណឹង និងចុះនិទ្ទេសអំពីកិច្ចការបញ្ជូន។

៥. បន្ទប់សម្រាប់ថែរក្សាសំណុំរឿងមានភាពតូចចង្អៀត។

៦. ខ្វះទូសម្រាប់ដាក់សំណុំរឿង ដើម្បីរក្សាសំណុំរឿងដែលត្រូវបញ្ចូលក្នុងឃ្លាំងកើនឡើងជារៀងរាល់ថ្ងៃ។

៧. ខ្វះសម្ភារការិយាល័យ ។

៨. ខ្វះកាម៉េរាសុវត្ថិភាព ដើម្បីបំពាក់នូវស្ថាប័ន និងឃ្លាំងរក្សាទុកវត្ថុតាង។

IV. ទិសដៅការងារសម្រាប់ឆ្នាំ ២០២៥

១. ស្នើសុំបន្ថែមចំនួនក្រឡាបញ្ជី ។

២. ស្នើសុំមន្ត្រីអាជ្ញាសាលា ក្នុងស្ថានភាពដែលមិនមានអាជ្ញាសាលា ដើម្បីសម្រួលដល់ការអនុវត្តកិច្ចការបញ្ជូនក្នុងរឿងរដ្ឋប្បវេណី និងការជូនដំណឹងក្នុងរឿងព្រហ្មទណ្ឌ នឹងជំរុញឱ្យមានអ្នកអនុវត្តកិច្ចការជំនួស(1) ។ មន្ត្រីអនុវត្តកិច្ចការជំនួសនេះ ត្រូវបានជ្រើសតាំងដោយ ឯកឧត្តមព្រះរាជអាជ្ញា (មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា) ដោយទទួលការអនុញ្ញាតពីប្រធានសាលាដំបូង ។

៣. រៀបចំគម្រោងថវិកា ដោយបន្ថែមឱ្យបានច្បាស់ពីភាពចាំបាច់សម្រាប់ពង្រឹងការអនុវត្តក្នុងការដោះស្រាយសំណុំរឿងឱ្យបានឆាប់រហ័ស និងត្រឹមត្រូវ។

៤.ជំរុញការដោះស្រាយសំណុំរឿង ទាំងរដ្ឋប្បវេណី និងព្រហ្មទណ្ឌ ឱ្យបានលឿនឆាប់រហ័សត្រឹមត្រូវ និងយុត្តិធម៌។

៥. រៀបចំឱ្យមានជាបទបង្ហាញខ្លីៗ ដើម្បីពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់

---

1. ផ្អែកតាម ប្រការ ៣ នៃប្រកាសលេខ ៣០ កយប្រក/០៧ ស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧

៦. ព្យាយាម ប្រើប្រាស់វិធីផ្សះផ្សាសម្របសម្រួលក្នុងសំណុំរឿងរដ្ឋប្បវេណីឱ្យបានច្រើន ដើម្បីកាត់បន្ថយវិវាទ និងចរិកគូកាគី ធ្វើឱ្យមានភាពសុខដុមរមនាក្នុងសង្គម ស្របតាមគោលការណ៍ដែលបានដាក់ចេញដោយ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** ។

ថ្ងៃអង្គារ ២កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
កំពង់ធំ, ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤
ប្រធានលេខាធិការដ្ឋានរដ្ឋបាល

សួ សុចន្ធារ៉ែត

បានឃើញ និងឯកភាព
ថ្ងៃអង្គារ ២កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
កំពង់ធំ, ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

ព្រះរាជអាជ្ញា

រស់ សារ៉ាំ

ប្រធានសាលាដំបូង

ជួន ទណ្ឌា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង និងអយ្យការអម
សាលាដំបូងខេត្តព្រះវិហារ
លេខ: ៥៤០ ស.ប/២៥

របាយការណ៍ការងារសង្ខេបរបស់សាលាដម្រះក្តី
សម្រាប់សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំយុត្តិធម៌ ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារអនាគត ឆ្នាំ២០២៥
របស់សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តព្រះវិហារ

==========

១. ស្ថានភាពទូទៅ

១.១- ស្ថិតិធនធានមនុស្ស

ក-ផ្នែកសាលាដំបូងខេត្តព្រះវិហារ

ប្រធានសាលាដំបូង	អនុប្រធានសាលាដំបូង	ចៅក្រម	ក្រឡាបញ្ជី
០១រូប	០១រូប(ស្រី០០រូប)	០៣រូប(ស្រី ០១រូប)	១២រូប(ស្រី០០រូប) ព្យួរបៀវត្ស ០២រូប
សរុប ១៧រូប (ស្រី ០១រូប) ព្យួរបៀវត្ស ០២រូប			

ខ-ផ្នែកអយ្យការអមសាលាដំបូងខេត្តព្រះវិហារ

ព្រះរាជអាជ្ញា	ព្រះរាជអាជ្ញារង	ក្រឡាបញ្ជី
០១រូប	០២រូប(ស្រី០០រូប)	០៤រូប(ស្រី០០រូប)
សរុប ០៧រូប (ស្រី ០០រូប)		

គ-ផ្នែកលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តព្រះវិហារ

ប្រធានលេខា	អនុប្រធានលេខា	ប្រ.ការិយាល័យ	អនុ.ការិយាល័យ	មន្ត្រីរដ្ឋបាល	មន្ត្រីជាប់កិច្ចសន្យា
០១រូប (ស្រី០១រូប)	០១រូប (ស្រី០១រូប)	០៤រូប (ស្រី ០៤រូប)	០០រូប	០៧រូប (ស្រី០៤)	០៦រូប (ស្រី០៣រូប)
សរុប ១៩រូប (ស្រី ១៣រូប)					
សរុបរួម ៤៣រូប (ស្រី ១៤រូប) ក្រឡាបញ្ជីព្យួរបៀវត្ស ០២រូប					

១.២-ហេដ្ឋានរចនាសម្ព័ន្ធ

សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តព្រះវិហារ មានអាគារសម្រាប់បម្រើការងារចំនួន ០២ អាគារ៖

-អាគារចាស់ចំនួន ០១អាគារ មានចំនួន២២ បន្ទប់ ក្នុងនោះមានសាលសវនាការចំនួន ០២ បន្ទប់ កំពុងបម្រើការងារសព្វថ្ងៃ។

-អាគារថ្មីចំនួន ០១អាគារ មានចំនួន ៥២ ក្នុងនោះមានសាលសវនាការចំនួន ០៤ (ធំ ០២,តូច០២)និងសាលប្រជុំចំនួន ០២ និងរោងចំណតរថយន្តចំនួន ០១ (សាងសង់រួចមិនទាន់បំពាក់សម្ភារៈបរិក្ខាគ្រប់គ្រាន់នៅឡើយ)។

១.៣-លទ្ធផលសន្តិបាតផ្ទៃក្នុងស្ថាប័ន ២០២៤

-បន្តជម្រុញពន្លឿនការដោះស្រាយរឿងក្តីព្រហ្មទណ្ឌ និងរឿងក្តីរដ្ឋប្បវេណី ឲ្យបានឆាប់រហ័សត្រឹមត្រូវនិងយុត្តិធម៌ ជាពិសេសសំណុំរឿងអាទិភាពទាំង៣ (គ្រឿងញៀន ចាចរណ៍ និងអត្រានុកូលដ្ឋាន) និងសំណុំរឿងពាក់ព័ន្ធនឹងក្មេងទំនើង។

-បន្តពង្រឹងក្រមសីលធម៌ការងារ និងក្រមសីលធម៌ផ្ទៃក្នុង សម្រាប់មន្ត្រីអង្គភាព និងពង្រីកកិច្ចសហប្រតិបត្តិការការងារ ឲ្យកាន់តែល្អប្រសើរបន្ថែមទៀត រវាងសាលាដំបូងជាមួយអង្គភាពខាងក្រៅជាពិសេសមន្ត្រីនគរបាលយុត្តិធម៌។

-ជម្រុញស្នើសុំឲ្យមានអាជ្ញាសាលា ដើម្បីសម្រួលកាត់បន្ថយកិច្ចការងារបញ្ជូនរបស់ក្រឡាបញ្ជីជៀសវាងការកកស្ទះចំណាត់ការសំណុំរឿង ។

-ព្យាយាមប្រើប្រាស់និតិវិធីផ្សះផ្សាសម្របសម្រួលក្នុងសំណុំរឿងរដ្ឋប្បវេណីអោយបានច្រើន ដើម្បីកាត់បន្ថយការចំណាយថវិការបស់គូវិវាទ ធ្វើអោយមានភាពសុខដុមរមនាក្នុងសង្គម ស្របតាមគោលការណ៍ ណែនាំរបស់ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**។

-រឹតបន្តឹងលើបទល្មើសសម្អាតប្រាក់ បទល្មើសគ្រឿងញៀន បទល្មើសជួញដូរមនុស្ស បទល្មើសពុករលួយ ព្រមទាំងបទល្មើសចាចរណ៍ បទល្មើសចោរកម្ម និងបទល្មើសល្បែងស៊ីសងខុសច្បាប់ ។

-ស្នើសុំអោយចៅក្រម និងក្រឡាបញ្ជីទាំងអស់ យកចិត្តទុក្ខដាក់នៅពេលចេញដីកាសម្រេចឃុំខ្លួនមិនត្រូវគូសសញ្ញា(✓)នោះឡើយ គឺត្រូវបំពេញរយៈពេលឃុំខ្លួនអោយបានពេញលេញ។

-សហការ និងបង្ក្រាបបាល់បទល្មើសឆ្លងដែន ដែលកើតមាននៅតាមបណ្តាព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសឡាវ ។

១.៤-កិច្ចប្រជុំផ្សេងៗ

-រៀបចំកិច្ចប្រជុំការចុះអធិការកិច្ចរបស់សាលាឧទ្ធរណ៍ត្បូងឃ្មុំ សរុបចំនួន ០១លើក
-រៀបចំកិច្ចប្រជុំមន្ត្រីនគរបាលយុត្តិធម៌សរុបចំនួន ០១លើក
-ចូលរួមកិច្ចប្រជុំជាមួយសាលាខេត្តសរុបចំនួន ៤៨ លើក
-កិច្ចប្រជុំជាមួយពន្ធនាគារសរុបចំនួន ០២លើក
-កិច្ចប្រជុំផ្សេងៗសរុបចំនួន ០៣លើក

២. សមិទ្ធផលការងារ

ក. អយ្យការអមសាលាដំបូង៖

ក.១. ចំណាត់ការអយ្យការ៖

បរិយាយ	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	សល់កំពុងចាត់ការ
ប្រចាំឆ្នាំ២០២៤	៧២	៥៨២	៦១៩	៣៥

ក.២.កិច្ចការពាក់ព័ន្ធនឹងការអនុវត្តទោស និងពន្ធនាគារ

ក.២.១.អំពីជនជាប់ឃុំក្នុងពន្ធនាគារ

ជនជាប់ឃុំសរុប	ជនត្រូវចោទ		ជនជាប់ចោទ		ពិរុទ្ធជន		ទណ្ឌិត	
	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី
ប្រចាំឆ្នាំ២០២៤	១៦៦	១៤	១១៥	១១	២៥៧	១៧	១៦៩	០៧
សរុបរួម ៧០៧ ស្រី ៤៩ នាក់								

ក.២.២.កិច្ចការអនុវត្តទោសដោយព្រះរាជអាជ្ញា

បរិយាយ	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	កំពុងចាត់ការ
ប្រចាំឆ្នាំ២០២៤	១៤១	១០៤	៧៦	១៦៩

ខ. សាលាដំបូង៖

ខ.១. ចំណាត់ការលើសំណុំរឿងព្រហ្មទណ្ឌ

ខ.១.១. ដំណាក់កាលស៊ើបសួរ៖

បរិយាយ	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	សល់កំពុងចាត់ការ
ប្រចាំឆ្នាំ២០២៤	២៣៦	៤៨៥	៥៣២	១៨៩

ខ.១.២. ដំណាក់កាលជំនុំជម្រះ៖

បរិយាយ	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	សល់កំពុងចាត់ការ
ប្រចាំឆ្នាំ២០២៤	១២៦	៤២៩	៣៩៦	១៥៩

ខ.២. ចំណាត់ការលើសំណុំរឿងរដ្ឋប្បវេណី

លរ.	សំណុំរឿង	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	កំពុងចាត់ការ
ក.ប្រចាំឆ្នាំ២០២៤					
១	សំណុំរឿងអង្គសេចក្តី	៥០	១២៧	៨២	៩៥
២	សំណុំរឿងរក្សាការពារ	០៤	២០	១៧	០៧
៣	សំណុំរឿងរដ្ឋប្បវេណីមិនមែនបណ្តឹង	៧៦	៤២១	៤៥២	៤៥
៤	សំណុំរឿងអនុវត្តរក្សាការពារ	០៤	០៨	១២	០០
៥	សំណុំរឿងអនុវត្តដោយបង្ខំ	៣១	០៩	០២	៣៨
៦	សំណុំរឿងរដ្ឋប្បវេណីផ្សេងៗ	០៣	១២	១១	០៤
សរុប		១៦៨	៥៩៧	៥៧៦	១៨៩

ខ.៣.ចំណាត់ការសំណុំរឿងផ្សេងទៀត

បរិយាយ	សល់ពីមុន	ចូលថ្មី	ចាត់ការរួច	កំពុងចាត់ការ
ក.ប្រចាំឆ្នាំ២០២៤				
១.សំណុំរឿងរដ្ឋប្បវេណីអនុវត្តដោយចៅក្រម	២៨	១៧	១៤	៣១
២.សំណុំរឿងរដ្ឋប្បវេណីអនុវត្តដោយអាជ្ញាសាលា ឬ តំណាងអយ្យការ	០៧	០៤	០២	០៩
៣.សំណុំរឿងអនុវត្តសំណងរដ្ឋប្បវេណីក្នុងរឿងព្រហ្មទណ្ឌដោយចៅក្រម	០៩	០៤	០៤	០៩

៣.បញ្ហាប្រឈម សំណូមពរ

៣.១.បញ្ហាប្រឈម

-ខ្វះចៅក្រម

-ខ្វះព្រះរាជអាជ្ញារង

-ខ្វះក្រឡាបញ្ជី

-ខ្វះអាជ្ញាសាលា

-ខ្វះបុគ្គលិកលេខាធិការដ្ឋាន

-ខ្វះមន្ត្រីជាប់កិច្ចសន្យា

-គ្មានឃ្លាំងសំរាប់ដាក់វត្ថុតាង សម្ភារៈផ្សេងៗ

-ខ្វះសម្ភារៈបរិក្ខាសំរាប់បន្ទប់សវនាការ និងតាមការិយាល័យ ។

៣.២. សំណូមពរ

-ស្នើសុំចៅក្រមចំនួន ០៤រូប

-ស្នើសុំព្រះរាជអាជ្ញារង ចំនួន ០២រូប

-សុំក្រឡាបញ្ជីបន្ថែម ចំនួន ០៥នាក់

-បង្កើតអាជ្ញាសាលាឲ្យបានឆាប់

-សុំជ្រើសរើសមន្ត្រីក្របខណ្ឌបន្ថែមចំនួន ១០រូប (ស្នើសុំជ្រើសរើសអ្នកដែលមានលំនៅដ្ឋានអចិន្ត្រៃយ៍នៅក្នុងខេត្ត ព្រះវិហារផ្ទាល់) ។

-សុំជ្រើសរើសមន្ត្រីកិច្ចសន្យាបន្ថែម

-សុំផ្តល់មធ្យោបាយសម្ភារៈសំរាប់ដំណើរការងាររដ្ឋបាល តុ កៅ អី និងទូដាក់ឯកសារ

-សុំឲ្យក្រសួងចាត់វិធានការលើវត្ថុតាងដែលបានរឹបអូសជាសម្បត្តិរដ្ឋ ដើម្បីលក់ឡាយឡុងឲ្យបានឆាប់ព្រោះវត្ថុតាង មានសភាពចាស់ទ្រុឌទ្រោមខ្លាំង(យូរឆ្នាំ) និងពុំមានកន្លែងរក្សាទុក។

៤. ទិសដៅអនុវត្តសម្រាប់ឆ្នាំ២០២៤

-ជំរុញការងារស៊ើបសួរសំណុំរឿងព្រហ្មទណ្ឌដែលសល់ពីមុន(សំណុំរឿងចាស់និងថ្មី)ឲ្យបានលឿនឆាប់រហ័សនិងមានភាពត្រឹមត្រូវស្របតាមច្បាប់ជូនប្រជាពលរដ្ឋ។

-ជំរុញការងារជំនុំជំរះរឿងក្តីជំនុំជំរះរឿងក្តីព្រហ្មទណ្ឌនិងរដ្ឋប្បវេណីតាមកម្មវិធីដែលបានរៀបចំទុកជាមុនអោយបានលឿននិងមានភាពត្រឹមត្រូវស្របតាមច្បាប់។

-រៀបចំរចនាសម្ព័ន្ធលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង។

-ជំរុញនិងបង្កើនប្រសិទ្ធភាពការងារអនុវត្តច្បាប់។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីនាងខ្ញុំ។

ថ្ងៃពុធ ៧កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

ព្រះវិហារ,ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២៥

ប្រធានលេខាធិការដ្ឋានរដ្ឋបាល

ជុំ - អង្គីយ៉ា

បានឃើញ និងឯកភាព

ថ្ងៃពុធ ៧កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

ព្រះវិហារ, ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២៥

ជ.ប្រធានសាលាដំបូង

សម្ផស្ស មុនិតា

ជ.ព្រះរាជអាជ្ញា

ស្រេង ភុម្មា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង និងអយ្យការអម
សាលាដំបូងខេត្តក្រចេះ
លេខាធិការដ្ឋានរដ្ឋបាល
លេខ: ០១២ ស.ម/២៥

របាយការណ៍ការងារសង្ខេបរបស់សាលាដម្រះក្តី
សម្រាប់សន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារអនាគត ឆ្នាំ២០២៥
សាលាដំបូងខេត្តក្រចេះ និងអយ្យការអមសាលាដំបូងខេត្តក្រចេះ

១. ស្ថានភាពទូទៅ

ក. ធនធានមនុស្ស

សាលាដំបូងខេត្តក្រចេះ

ប្រធានសាលាដំបូង	អនុប្រធានសាលាដំបូង	ចៅក្រម	ក្រឡាបញ្ជីតុលាការ
១រូប	១រូប (ស្រី១រូប)	៧រូប (ស្រី១រូប)	១៥រូប (ស្រី៥រូប)
សរុប ២៤រូប (ស្រី៧រូប)			

អយ្យការអមសាលាដំបូងខេត្តក្រចេះ

ព្រះរាជអាជ្ញា	ព្រះរាជអាជ្ញារង	ក្រឡាបញ្ជីអយ្យការ
១រូប	៣រូប	៥រូប (ស្រី១រូប)
សរុប ៩រូប (ស្រី១រូប)		

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តក្រចេះ

ប្រធានលេខា	អនុប្រធានលេខា	ប្រ.ការិយាល័យ	អនុ.ការិយាល័យ	មន្ត្រីរដ្ឋបាល	មន្ត្រីកិច្ចសន្យា
១រូប(ស្រី១រូប)	៣រូប (ស្រី២រូប)	៤រូប (ស្រី២រូប)	៣រូប(ស្រី១រូប)	៤រូប(ស្រី២រូប)	១៧រូប(ស្រី១០រូប)
សរុប ៣២ រូប (ស្រី១៨រូប)					
សរុបរួម ៦៥ រូប (ស្រី២៦រូប)					

ខ. ហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន

សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តក្រចេះ មានអគារធំចំនួន៣អគារ និងអគារតូចចំនួន២អគារ (មួយអគារជាអគារជំនាន់បារាំង) សម្រាប់បំពេញការងារប្រចាំថ្ងៃ ដោយក្នុងនោះ មានសាលប្រជុំធំចំនួន០១បន្ទប់ បន្ទប់សវនាការចំនួន២បន្ទប់ បន្ទប់ពិភាក្សាចំនួន២បន្ទប់ បន្ទប់ឃាត់ខ្លួនចំនួន០១បន្ទប់ ឃ្លាំងរក្សាទុកសំណុំរឿងចំនួន ២បន្ទប់ ឃ្លាំងតម្កល់វត្ថុតាងចំនួន០១ និងមានបន្ទប់តូច៣នៅអគារបារាំងសម្រាប់តម្កល់វត្ថុតាង ។

គ. លទ្ធផលសន្និបាតឆ្នៃក្នុងស្ថាប័នសម្រាប់ឆ្នាំ ២០២៤

សាលាដំបូង និងអយ្យការអមសាលាដំបូង បានរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៤ និងលើកទិសដៅអនុវត្តឆ្នាំ២០២៥ នាថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៥ ក្រោមការដឹកនាំរបស់ **ឯកឧត្តម តុប ឈុនហេង** ប្រធាន

សាលាដំបូង និង **ឯកឧត្តម គី ច៊ុណ្ណារ៉ា** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូង និងមន្ត្រីរាជការទាំងអស់ នៃសាលាដំបូង និងអយ្យការអមសាលាដំបូង សរុបចំនួន៧៨រូប ដោយបានធ្វើការដោះស្រាយបញ្ហាប្រឈមនានា ដែលបានជួបប្រទះ និងកំណត់ទិសដៅការងារសម្រាប់ឆ្នាំ២០២៥ ។

ឃ. ព្រឹត្តិការណ៍ ឬកម្មវិធីការងារនានា

- ថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ **ប្រធានសាលាដំបូង និង ព្រះរាជអាជ្ញា** ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយ និងណែនាំអំពីការអនុវត្តយុទ្ធនាការជំរុញ និងពន្លឿន ការដោះស្រាយរឿងក្តីតាមតុលាការ និងយុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** ។

- ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤ **ប្រធានសាលាដំបូង និង ព្រះរាជអាជ្ញារង** ចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០២៤ របស់សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំក្រោមអធិបតីភាពរបស់ **ឯកឧត្តមប្រធានសាលាឧទ្ធរណ៍ត្បូងឃ្មុំ និង ឯកឧត្តមអគ្គព្រះរាជអាជ្ញា** នៃមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ នៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ ។

- ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៤ **ប្រធានសាលាដំបូង** បានចូលរួមកិច្ចប្រជុំពិនិត្យពាក្យសុំអន្តរាគមន៍ ដែលទទួលបានពីគណៈកម្មការដឹកនាំ និងអនុវត្តយុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការនៅសាលប្រជុំថ្មីនៃក្រសួងយុត្តិធម៌ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** ។

- ថ្ងៃទី២៧ ២៨ ២៩ ខែមីនា ឆ្នាំ២០២៤ **ប្រធានសាលាដំបូង និង ព្រះរាជអាជ្ញា** បានចូលរួមសន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ទូទាំងប្រទេស ឆ្នាំ២០២៣ និងលើកទិសដៅការអាទិភាព ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** នៅនៅសណ្ឋាគារហ្គាឌិនស៊ីធី ។

- ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ **ប្រធានសាលាដំបូង** បានចូលរួមកិច្ចប្រជុំពិនិត្យពាក្យសុំអន្តរាគមន៍ ដែលទទួលបានពីគណៈកម្មការដឹកនាំ និងអនុវត្តយុទ្ធនាការត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** នៅសណ្ឋាគារហ្គាឌិនស៊ីធី ។

- ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ **ប្រធានសាលាដំបូង និង ព្រះរាជអាជ្ញា** បានចូលរួមកិច្ចប្រជុំរបស់គណៈកម្មការគ្រប់គ្រង និងចាត់ចែងវត្ថុតាង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** នៅសាលប្រជុំទីស្តីការក្រសួងយុត្តធម៌ ។

- ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៤ **ប្រធានសាលាដំបូង និង ព្រះរាជអាជ្ញា** បានចូលរួមកិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការងារពាក់ព័ន្ធនឹងចំណាត់ការលើករណីក្មេងទំនើង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** នៅទីស្តីការក្រសួងយុត្តិធម៌ ។

- ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៤ **ប្រធានសាលាដំបូង** បានចូលរួមកិច្ចប្រជុំត្រៀមលក្ខណៈសម្បត្តិបណ្តុះបណ្តាលសម្រាប់សិស្សក្រឡាបញ្ជីជំនាន់ទី៩ នៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ឆ្នាំ២០២៤-២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតរដ្ឋ ឈន ព្រាលឹង** ប្រធានបណ្ឌិតសភាភូមិន្ទយុត្តិធម៌កម្ពុជានៅ បន្ទប់ វិបុលសុខ ជាន់ផ្ទាល់ដី នៃអគារពហុបំណងវិស័យយុត្តិធម៌ ។

- ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤ **ប្រធានសាលាដំបូង និង ព្រះរាជអាជ្ញា** បានចូលរួមកិច្ចប្រជុំនៅទីស្តីការក្រសួងយុត្តិធម៌ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** ។

- ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៤ **ប្រធានលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង** បានចូលរួមក្នុងកិច្ចប្រជុំ ស្តីពីការរៀបចំគម្រោងថវិកា និងផែនការយុទ្ធសាស្ត្រថវិការបស់សាលាជម្រះក្តី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ខាន់ ភណ្ណៈ រដ្ឋលេខាធិការក្រសួងយុត្តិធម៌** នៅសាលប្រជុំទីស្តីការក្រសួងយុត្តិធម៌ ។

- ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៤ **ប្រធានសាលាដំបូង និង ព្រះរាជអាជ្ញា** បានចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលនៃការអនុវត្តយុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និងយុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** នៅទីស្តីការក្រសួងយុត្តិធម៌ ។

- ថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៤ **ប្រធានសាលាដំបូង** បានចូលបណ្តុះបណ្តាលបច្ចេកទេសតាក់តែងដីកានានា ដែលចេញដោយអយ្យការ និងការអនុវត្តបណ្តឹងអាជ្ញាដោយស្ថាប័នអយ្យការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** ។

- ថ្ងៃទី០៦ ០៧ ០៨ ខែសីហា ឆ្នាំ២០២៤ **ប្រធានសាលាដំបូង** បានចូលរួមកម្មវិធីការពារបាយការណ៍កម្មសិក្សាផ្នែកព្រហ្មទណ្ឌសម្រាប់សិស្សចៅក្រម និងព្រះរាជអាជ្ញាជំនាន់ទី១១ និងសិស្សចៅក្រមផ្នែកក្នុងជំនាន់ទី២ នៅបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា បន្ទប់វិមានអាកាស ។

- ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៤ **ប្រធានសាលាដំបូង និង ព្រះរាជអាជ្ញា** បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយ អំពីកិច្ចសហប្រតិបត្តិការតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា ឡាវ វៀតណាម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** នៅសាលប្រជុំធំ នៃទីស្តីការក្រសួងយុត្តិធម៌ ។

- ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤ **ប្រធានសាលាដំបូង និង ព្រះរាជអាជ្ញា** បានចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលនៃការអនុវត្តយុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និងយុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** នៅទីស្តីការក្រសួងយុត្តិធម៌ ។

- ថ្ងៃទី២៨ ២៩ ខែវិច្ឆិកា ឆ្នាំ២០២៤ **ប្រធានសាលាដំបូង និង ព្រះរាជអាជ្ញា** បានចូលរួមសិក្ខាសាលា ស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគាំទ្រវិស័យយុត្តិធម៌ និងកម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** នៅសណ្ឋាគារសុខាភ្នំពេញ ។

២. សមិទ្ធផលការងារ

ក. អយ្យការអមសាលាដំបូង

ក.១. ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌ

បរិយាយ	សល់ពីមុន	ចូលថ្មី	សំណុំរឿងចាត់ការរួច	សល់កំពុងចាត់ការ
ឆ្នាំ២០២៤	៦២	៧៧៣	៧៩២	៤៣
ខែមករា ឆ្នាំ២០២៥	៤៣	៧៤	៥៤	៦៣
ខែកុម្ភៈ ឆ្នាំ២០២៥	៦៣	៥១	៥៧	៥៧

ក.២. កិច្ចការពាក់ព័ន្ធនឹងការអនុវត្តទោស និងពន្ធនាគារ

ក.២.១. ការអនុវត្តទោសដោយព្រះរាជអាជ្ញា

បរិយាយ	សល់ពីមុន	ចូលថ្មី	សំណុំរឿងចាត់ការរួច	សល់កំពុងចាត់ការ
ឆ្នាំ២០២៤	២៤៦	៤៣០	២៣៦	៤៤០
ខែមករា ឆ្នាំ២០២៥	៤៤០	៤១	៤៣	៤៣៨
ខែកុម្ភៈ ឆ្នាំ២០២៥	៤៣៨	៣០	៣៣	៤៣៥

ក.២.២. ពន្ធនាគារខេត្តក្រចេះ

ជនជាប់ឃុំ	ប្រចាំឆ្នាំ២០២៤		ប្រចាំខែមករា ឆ្នាំ២០២៥		ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥	
	សរុប	**ស្រី**	**សរុប**	**ស្រី**	**សរុប**	**ស្រី**
ជនត្រូវចោទ	១០៤ នាក់	០៧ នាក់	៨៥ នាក់	០៥ នាក់	១០៨ នាក់	១០ នាក់
ជនជាប់ចោទ	១៦៨ នាក់	០៥ នាក់	១៣៥ នាក់	០៥ នាក់	៦៧ នាក់	០៥ នាក់
ពិរុទ្ធជន	២៨៤ នាក់	១៨ នាក់	៣២០ នាក់	១៨ នាក់	៣៨០ នាក់	១៩ នាក់
ទណ្ឌិត	៣៩០ នាក់	១៨ នាក់	៣១០ នាក់	២១ នាក់	៣១៥ នាក់	២២ នាក់
សរុបរួម	៩៤៦ នាក់	៤៨ នាក់	៨៥០ នាក់	៤៩ នាក់	៨៧០ នាក់	៥៦ នាក់

ក.៣. កិច្ចការពាក់ព័ន្ធជាមួយនឹងមន្ត្រីនគរបាលយុត្តិធម៌

- អយ្យការអមសាលាដំបូងខេត្តក្រចេះ បានអញ្ជើញមន្ត្រីនគរបាលយុត្តិធម៌ រួមមានអង្គភាពនគរបាលយុត្តិធម៌ នៃស្នងការដ្ឋាននគរបាលខេត្តក្រចេះ និងបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តក្រចេះ ដើម្បីប្រជុំទាក់ទងនឹងការពព្រឹងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងការត្រួតពិនិត្យលទ្ធផលការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ ប្រចាំឆ្នាំ២០២៤ និងលើកទិសដៅការងារសម្រាប់ឆ្នាំ២០២៥ និងបានដោះស្រាយបញ្ហាប្រឈមមួយចំនួនផងដែរ ។

- ក្រោមការចាត់តាំងរបស់ **ឯកឧត្តម គី ច៊ុណ្ណារ៉ា** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តក្រចេះ បានចាត់តាំងលោកព្រះរាជអាជ្ញារងទាំងអស់ ចុះទៅធ្វើអធិការកិច្ចនៅស្នងការដ្ឋាននគរបាលខេត្តក្រចេះ បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តក្រចេះ មូលដ្ឋានកងរាជអាវុធហត្ថក្រុង/ស្រុកទាំង៧ អធិការដ្ឋាននគរបាលក្រុង/ស្រុកទាំង៧ និងបានណែនាំឲ្យធ្វើសៀវភៅបញ្ជីទទួលបណ្តឹង បញ្ជីឃាត់ខ្លួន និងត្រួតពិនិត្យមណ្ឌលឃាត់ខ្លួន នៅតាមមូលដ្ឋានក្រុងស្រុកទាំងអស់ ព្រមទាំងដោះស្រាយបញ្ហាប្រឈមផ្សេងៗ ដែលកើតមានក្នុងពេលអនុវត្តនីតិវិធី។ជាលទ្ធផលលោកព្រះរាជអាជ្ញារងទាំងអស់ បានធ្វើការពិនិត្យលើការងារទាំងអស់ប្រកបដោយប្រសិទ្ធភាព។

- **ឯកឧត្តម គី ច៊ុណ្ណារ៉ា** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តក្រចេះ បានចាត់តាំងលោក **អឿន សំអុល** ព្រះរាជអាជ្ញារង ចុះត្រួតពិនិត្យពន្ធនាគារមានដូចខាងក្រោម៖

+ តំណាងអយ្យការទទួលបន្ទុកពន្ធនាគារ បានចុះអធិការកិច្ចជារៀងរាល់ខែយ៉ាងតិចមួយម្តង។
+ អនុវត្តសេចក្តីសម្រេច។
+ បានដោះលែងទណ្ឌិតតាមសាលដីកាកំពូល, សាលដីកាឧទ្ធរណ៍, ដីកាសម្រេច និងទណ្ឌិតកំពុងអនុវត្តទោស។

ខ. សាលាដំបូង

ខ.១. ចំណាត់ការលើសំណុំរឿងព្រហ្មទណ្ឌ

ខ.១.១. ដំណាក់កាលស៊ើបសួរ

បរិយាយ	សល់ពីមុន	ចូលថ្មី	សំណុំរឿងចាត់ការរួច	សល់កំពុងចាត់ការ
ឆ្នាំ២០២៤	១៤៤	៦០៦	៧០៧	៤៣
ខែមករា ឆ្នាំ២០២៥	៤៣	៣៣	២០	៥៦
ខែកុម្ភៈ ឆ្នាំ២០២៥	៥៦	៤៩	១៦	៨៩

ខ.១.២. ដំណាក់កាលជំនុំជម្រះ

បរិយាយ	សល់ពីមុន	ចូលថ្មី	សំណុំរឿងចាត់ការរួច	សល់កំពុងចាត់ការ
ឆ្នាំ២០២៤	៦៤	៧២២	៧៦៦	២០
ខែមករា ឆ្នាំ២០២៥	២០	៤៨	២២	៤៦
ខែកុម្ភៈ ឆ្នាំ២០២៥	៤៦	៣៦	៤៦	៣៦

ខ.២. ចំណាត់ការលើសំណុំរឿងរដ្ឋប្បវេណី

បរិយាយ	ប្រភេទសំណុំរឿង	ឆ្នាំ២០២៤	ខែមករា ឆ្នាំ២០២៥	ខែកុម្ភៈ ឆ្នាំ២០២៥
សល់ពីមុន	រឿងក្តី នៃបណ្តឹង	១០១	៣៧	៤៨
	សំណុំរឿងរក្សាការពារ	៨	១	២
	រឿងក្តីរដ្ឋប្បវេណី មិនមែនបណ្តឹង	៣៨	៣	១៣
	ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន	០	០	០
ចូលថ្មី	រឿងក្តី នៃបណ្តឹង	១៨២	២៤	២៧
	សំណុំរឿងរក្សាការពារ	២៤	២	៣
	រឿងក្តីរដ្ឋប្បវេណី មិនមែនបណ្តឹង	១៦៦០	១១២	១៧១
	ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន	០	០	០
សំណុំរឿង ចាត់ការរួច	រឿងក្តី នៃបណ្តឹង	២៤៦	១៣	១១
	សំណុំរឿងរក្សាការពារ	៣១	១	២
	រឿងក្តីរដ្ឋប្បវេណី មិនមែនបណ្តឹង	១៦៩៥	១០២	១៥៨
	ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន	០	០	០
សំណុំរឿង សល់កំពុងចាត់ការ	រឿងក្តី នៃបណ្តឹង	៣៧	៤៨	៦៤
	សំណុំរឿងរក្សាការពារ	១	២	៣
	រឿងក្តីរដ្ឋប្បវេណី មិនមែនបណ្តឹង	៣	១៣	២៦
	ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន	០	០	០

ខ.៣. សំណុំរឿងអនុវត្តដោយបង្ខំ

បរិយាយ	សល់ពីមុន	ចូលថ្មី	សំណុំរឿងចាត់ការរួច	សល់កំពុងចាត់ការ
ឆ្នាំ២០២៤	៣៨	៥៦	៦៤	៣០
ខែមករា ឆ្នាំ២០២៥	៣០	២	៤	៦៨
ខែកុម្ភៈ ឆ្នាំ២០២៥	៦៨	២	០	៣០

៣. បញ្ហាប្រឈម និងសំណូមពរ

៣.១. បញ្ហាប្រឈម

- ការស្នើសុំមេធាវីភ្លាមៗ សម្រាប់រឿងក្តីអនីតិជន ។
- ពុំមានអ្នកបកប្រែភាសាបរទេស និងភាសាគ ជាផ្លូវការ ។
- វត្ថុតាង ដែលរឹបអូសជាសម្បត្តិរដ្ឋ មិនទាន់ចាត់ចែងលក់ឡាយឡុងបាន និងបន្សល់ទុកជាច្រើនឆ្នាំមកហើយ បណ្តាលឲ្យខូចខាត ព្រោះគ្មានឃ្លាំងសម្រាប់ទុកដាក់ ។
- ការបញ្ជូនដីកាកោះ ដីកាផ្សេងទៀតទៅភាគី និងអង្គភាពផ្សេងៗ មិនបានបង្វិលមកវិញ ឲ្យទាន់ពេលវេលា ជាហេតុធ្វើឲ្យមានភាពយឺតយ៉ាវដល់នីតិវិធី ។

៣.២. សំណូមពរ

- ស្នើសុំមន្ត្រីអាជ្ញាសាលាចំនួន ០២រូប ។
- ស្នើសុំមន្ត្រីលេខាធិការដ្ឋានរដ្ឋបាលបន្ថែម ។
- ស្នើសុំមន្ត្រីជាប់កិច្ចសន្យាបន្ថែម ។

៤. ទិសដៅការងារសម្រាប់ឆ្នាំ ២០២៥

-បន្តពង្រឹងសាមគ្គីភាពផ្ទៃក្នុងតាមរយៈរបៀបរបបធ្វើការងារឲ្យមានផែនការច្បាស់លាស់ ដោយមានការគោរព

អង្គការវិន័យ និងប្រតិទិនវេនយាមប្រចាំការ ថ្ងៃឈប់សំរាក និងថ្ងៃបុណ្យផ្សេងៗ ។

- បន្តធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំឲ្យទាន់ពេលវេលា ។
- តាមដានការឃុំខ្លួនបណ្តោះអាសន្ន ជៀសវាងការឃុំខ្លួនលើសនីតិវិធីច្បាប់កំណត់ ។
- បន្តជម្រុញចំណាត់ការសំណុំរឿងគ្រប់ប្រភេទឲ្យបានឆាប់រហ័ស ។
- បន្តរៀបចំសំណុំរឿងចាត់ការរួច ដាក់បញ្ចូលឃ្លាំងឲ្យបានត្រឹមត្រូវ ។
- បន្តជម្រុញការចុះបញ្ជីសំណុំរឿងក្តីតាមប្រព័ន្ធ *Data Base* ឲ្យបានច្បាស់លាស់ និងទាន់ពេលវេលា ។
- រៀបចំកិច្ចប្រជុំឲ្យបានញឹកញាប់ជាមួយមន្ត្រីក្នុងអង្គភាព និងមន្ត្រីនៃអង្គភាពពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាប្រឈមនានាឲ្យបានទាន់ពេលវេលា ដោយជៀសវាងឲ្យបាននូវភាពអសកម្មក្នុងការងារ ។
- បន្តពង្រឹងទំនាក់ទំនងល្អ ជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធ ។
- បំបែកសៀវភៅចុះលេខសាលក្រមចាត់របៀប និងសាលក្រមមុនអង្គសេចក្តី ចេញពីសៀវភៅចុះលេខសាលក្រមសម្រេច ។
- បំបែកសៀវភៅចុះលេខសំណុំរឿងស៊ើបសួរជំនួស, បណ្តឹងជិតចិត្ត, បណ្តឹងសុំដោះលែងមានលក្ខខណ្ឌ (សម្រាប់សាលាដំបូង) ។
- បំបែកសៀវភៅចុះលេខលិខិតចូលដកពាក្យបណ្តឹង, បណ្តឹងបន្ថែម និងបណ្តឹងតប (សម្រាប់អយ្យការ) ។
- បំបែកសៀវភៅចុះលេខពិសេសសម្រាប់សាលាដំបូង៖
  + ដីកាដំណោះស្រាយ (សៀវភៅមួយដាច់ដោយឡែក)។
  + ដីការក្សាការឃុំខ្លួន, ដីកាពន្យាពេលឃុំខ្លួន និងដីកាបង្គាប់ឲ្យដោះលែង (ប្រើរួមជាមួយសៀវភៅចុះលេខដីកាបង្គាប់ឲ្យឃុំខ្លួន)។
- បំបែកសៀវភៅចុះលេខពិសេសសម្រាប់អយ្យការ៖
  + ដីកាបញ្ជូលសំណុំរឿង, ដីកាបំបែកសំណុំរឿង, ដីកាសម្រេចផ្ទេរសមត្ថកិច្ច(សៀវភៅមួយដាច់ដោយឡែក)។
  + ដីកាបង្គាប់ឲ្យចាប់ខ្លួន, ដីកាបញ្ឈប់ឲ្យចាប់ខ្លួន, ដីកាបញ្ជារឲ្យចូលខ្លួន (សៀវភៅមួយដាច់ដោយឡែក)។
- បំបែកសៀវភៅចុះលេខដីកាបញ្ជូន សម្រាប់អយ្យការក្នុងការបញ្ជូន ដីកាបង្គាប់ឲ្យចាប់ខ្លួន, ដីកាបញ្ឈប់ឲ្យចាប់ខ្លួន, ដីកាបញ្ជារឲ្យចូលខ្លួន (សៀវភៅមួយដាច់ដោយឡែក)។

ថ្ងៃពុធ ៧កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស២៥៦៨
ក្រចេះ, ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២៥

បានឃើញ និងឯកភាព
ក្រចេះ, ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២៥



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង និងអយ្យការអម
សាលាដំបូងខេត្តស្ទឹងត្រែង
លេខាធិការដ្ឋានរដ្ឋបាល
លេខ ៨៨៨ រប/២៥

របាយការណ៍សង្ខេបរបស់សាលាជម្រះក្តី
សម្រាប់សន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារអាទិភាព ឆ្នាំ២០២៥
សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តស្ទឹងត្រែង

១. ស្ថានភាពទូទៅ

ក.ធនធានមនុស្ស

ក.១.សាលាដំបូង

នៅសាលាដំបូងមានចៅក្រមសរុបចំនួន១០រូប ក្នុងនោះមានប្រធានសាលាដំបូង១រូប អនុប្រធានសាលាដំបូងចំនួន ១រូប ចៅក្រមចំនួន៨រូប (ស្ត្រី១រូប) និងមានក្រឡាបញ្ជីចំនួន ៩រូប (ស្រី៣រូប ។

ក.២.អយ្យការអមសាលាដំបូង

អយ្យការអមសាលាដំបូង មានព្រះរាជអាជ្ញា ១រូប ព្រះរាជអាជ្ញារង ២រូប ព្រះរាជអាជ្ញារងកម្ម សិក្សា ចំនួន ២រូប និងក្រឡាបញ្ជី ៥រូប ។

ក.៣.លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង

មន្ត្រីរាជការបម្រើការងារនៅលេខាធិការដ្ឋានរដ្ឋបាលសរុបចំនួន ១៥ រូប មានប្រធានលេខាធិការដ្ឋាន ១រូប អនុប្រធានលេខាធិការដ្ឋានចំនួន ៥រូប (ស្ត្រី ៣ រូប) ប្រធានការិយាល័យចំនួន ២រូប អនុប្រធានការិយាល័យចំនួន ៣រូប មន្ត្រីគ្រប់គ្រងរដ្ឋបាលចំនួន ៤រូប (ស្ត្រី១ រូប) ។

ខ.ហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន

សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តស្ទឹងត្រែង មានដីចំនួន ២ប្លង់ ដែលដីទី១ (មួយ) ដីសាងសង់អាគាររដ្ឋបាល មានទំហំ ១៦២៧(មួយពាន់ប្រាំរយម្ភៃប្រាំពីរ) ម៉ែត្រការេ និងមានអាគារសរុបចំនួន៣ខ្នង ស្ថិតនៅភូមិព្រៃក សង្កាត់-ក្រុង-ខេត្តស្ទឹងត្រែង និងដីទី២ ដីសាងសង់ឃ្លាំងវត្ថុតាង មានទំហំ ៧២៤៧ (ប្រាំពីរពាន់ពីររយសែសិបប្រាំពីរ) ម៉ែត្រការេ ស្ថិតនៅភូមិ-ឃុំ-ស្រុក ថាឡាបរីវ៉ាត់ ខេត្តស្ទឹងត្រែង កំពុងសាងសង់។

គ-លទ្ធផលសន្និបាតផ្ទៃក្នុងស្ថាប័នសម្រាប់ឆ្នាំ២០២៤

ផ្អែកតាមលទ្ធផលការងារសម្រេច និងការពិភាក្សាក្នុងសន្និបាតប្រចាំឆ្នាំ២០២៤ និងលើកទិសដៅការងារសម្រាប់ឆ្នាំ២០២៥ អង្គសន្និបាតបានសម្រេចលទ្ធផលដូចខាងក្រោម៖

១-រដ្ឋបាលត្រូវសម្របសម្រួល ការងារជាមួយ តំណាងអយ្យការ ចៅក្រម និងក្រឡាបញ្ជី ឲ្យកាន់តែមានភាពច្បាស់លាស់។

២-ធានាឲ្យបាននូវកិច្ចការដំណើរការ ការងាររដ្ឋបាលសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តស្ទឹងត្រែង ប្រកបដោយប្រសិទ្ធិភាពរហ័ស និងទាន់ពេលវេលា។

៣-បន្តការងារបញ្ជូនសំណុំរឿងជាប់បណ្តឹងឧទ្ធរណ៍ឲ្យបានឆាប់រហ័សទៅសាលាឧទ្ធរណ៍។

៤-បន្តការផ្សព្វផ្សាយសកម្មភាពនានា របស់សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តស្ទឹងត្រែង និងលិខិតបទដ្ឋានគតិយុត្ត ឲ្យបានកាន់តែទូលំទូលាយតាមរយៈគេហទំព័រ និងហ្វេសបុកផេក របស់អង្គភាព។

៥-ពង្រឹងការចុះបញ្ជីរឿងក្តីឲ្យបានបានទាន់ពេលវេលា និងល្អប្រសើរ។

៦-ជម្រុញមន្ត្រីរាជការនៅសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តស្ទឹងត្រែង ឲ្យប្តេជ្ញាចិត្តបំពេញការងារប្រកបដោយការទទួលខុសត្រូវខ្ពស់ និងសកម្ម។

៧-ជម្រុញការងារដោះស្រាយរឿងក្តីគ្រប់ប្រភេទឲ្យបានឆាប់រហ័ស ទាន់ពេលវេលា និងសម្រេចឲ្យបានតាមផែនការដែលក្រសួងយុត្តិធម៌បានដាក់ចេញ។

ឃ-ព្រឹត្តិការណ៍ ឬកម្មវិធីការងារនានា

នៅក្នុងឆ្នាំ២០២៤ សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តស្ទឹងត្រែង បានចូលរួមកិច្ចការងារពិធីនានារួមមាន៖

១-បានប្រជុំមន្ត្រីនគរបាលយុត្តិធម៌ចំនួន២លើក

២-បានចូលរួមមហាសន្និបាតក្រសួងយុត្តិធម៌

៣-បានចូលរួមសន្និបាតសាលាឧទ្ធរណ៍ត្បូងឃ្មុំ

៤-បានចុះទៅប្រកាស ព្រះរាជក្រឹត្យ លើកលែងទោស បន្ធូបន្ថយទោស នៅពន្ធនាគារខេត្តស្ទឹងត្រែង ចំនួន៣លើក

៥-បានចូលរួមជាមួយប្រតិភូ តុលាការកំពូល ទៅចូលរួមប្រជុំជាមួយតុលាការតាមព្រំដែន កម្ពុជា វៀតណាម និងឡាវ នៅសាធារណៈរដ្ឋសង្គមនិយមវៀតណាម។

២-សមិទ្ធផលការងារ

ក-អយ្យការអមសាលាដំបូង៖

ក.១ ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌ

-សំណុំរឿងនៅសល់ពីឆ្នាំ ២០២៣	សរុបចំនួន ១០១ រឿង
-សំណុំរឿងចូលថ្មី ឆ្នាំ២០២៤	សរុបចំនួន ៥៣១ រឿង
-តម្កល់រឿងទុកឥតចាត់ការ	សរុបចំនួន ១៤០ រឿង
-បញ្ចូលសំណុំរឿង	សរុបចំនួន ០២ រឿង
-បញ្ជូនសំណុំរឿងទៅស៊ើបសួរ	សរុបចំនួន ៤១២ រឿង
-បញ្ជូនសំណុំរឿងទៅជំនុំជម្រះផ្ទាល់	សរុបចំនួន ១៦ រឿង
-សំណុំរឿងសល់កំពុងចាត់ការ	សរុបចំនួន ៥៧ រឿង

ក.២.កិច្ចការពាក់ព័ន្ធនឹងការអនុវត្តទោស និងពន្ធនាគារ

១.ជនត្រូវចោទក្នុងឃុំ	**ចំនួន ១៣៧ នាក់ (ស្រី ០៩នាក់)**
-អនីតិជន	ចំនួន ១៧នាក់
-នីតិជន	ចំនួន ១១១នាក់ (ស្រី០៨នាក់)

២.ជនជាប់ចោទក្នុងឃុំ **ចំនួន ៨៦ នាក់ (ស្រី ០២នាក់)**

-អនីតិជន ចំនួន ០៨នាក់

-នីតិជន ចំនួន ៧៧នាក់ (ស្រី០២នាក់)

៣.ពិរុទ្ធជនក្នុងឃុំ **ចំនួន ៥៤៧ នាក់ (ស្រី ០៩នាក់)**

-អនីតិជន ចំនួន ១១នាក់

-នីតិជន ចំនួន ៥៣១នាក់ (ស្រី០៩នាក់)

៤.ទណ្ឌិតក្នុងឃុំ **ចំនួន ៣២០ នាក់ (ស្រី ០៦នាក់)**

-អនីតិជន ចំនួន ០២នាក់

-នីតិជន ចំនួន ៣១៨នាក់ (ស្រី០៦នាក់)

៥.ជនជាប់ក្នុងឃុំសរុប **ចំនួន ១០៩០ នាក់ (ស្រី ២៦នាក់)**

-អនីតិជន ចំនួន ៣៨នាក់

-នីតិជន ចំនួន ១០៣៣នាក់ (ស្រី២៥នាក់)

ក.៣ កិច្ចការពាក់ព័ន្ធនឹងមន្ត្រីនគរបាលយុត្តិធម៌

អយ្យការអមសាលាដំបូងខេត្តស្ទឹងត្រែង នៅឆ្នាំ២០២៤ បានអនុវត្តការងារជាមួយមន្ត្រីនគរបាលយុត្តិធម៌រួមមាន៖

-ដឹកនាំស៊ើបអង្កេត និងចុះពិនិត្យទីតាំងកើតហេតុ

-ធ្វើអធិការកិច្ចនៅអង្គភាពនានា ដែលជាអង្គភាពមន្ត្រីនគរបាលយុត្តិធម៌

-ចុះត្រួតពិនិត្យបញ្ជីទទួលបញ្ជីទទួលពាក្យបណ្តឹង និងបញ្ជីឃាត់ខ្លួន នៅអង្គភាពមន្ត្រីនគរបាលយុត្តិធម៌។

ខ.សាលាដំបូង៖

ខ.១.ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌ

ខ.១.១ ដំណាក់ការស៊ើបសួរ

-សំណុំរឿងស៊ើបសួរសល់ពីឆ្នាំ២០២៣ ចំនួន ១៨៧ រឿង

-សំណុំរឿងចូលថ្មី ឆ្នាំ២០២៤ ចំនួន ៤១៨ រឿង

-សំណុំរឿងចាត់ការរួច ចំនួន ៤១៩ រឿង

-សំណុំរឿងសល់កំពុងចាត់ការ ចំនួន ១៨៦ រឿង

-សំណុំរឿងជាប់បណ្តឹងឧទ្ធរណ៍ ចំនួន ០២ រឿង

ខ.១.២.ដំណាក់កាលជំនុំជម្រះ

-សំណុំរឿងជំនុំជម្រះសល់ពីឆ្នាំ ២០២៣ ចំនួន៧១ រឿង

-សំណុំរឿងចូលថ្មី ឆ្នាំ២០២៤ ចំនួន៣៥១រឿង

-សំណុំរឿងចាត់ការរួច ចំនួន៣០៨ រឿង

-សំណុំរឿងសល់កំពុងចាត់ការ ចំនួន១១៤ រឿង

-សំណុំរឿងជាប់បណ្តឹងឧទ្ធរណ៍ ចំនួន ១៣ រឿង

ខ.២.ចំណាត់ការលើសំណុំរឿងរដ្ឋប្បវេណី

ខ.២.១.រឿងក្តីនៃបណ្តឹង

-សំណុំរឿងសល់ពីឆ្នាំ ២០២៣ ចំនួន ៨៤ រឿង
-សំណុំរឿងចូលថ្មី ឆ្នាំ ២០២៤ ចំនួន ១១៤ រឿង
-សំណុំរឿងចាត់ការរួច ចំនួន ១១៦ រឿង
-សំណុំរឿងសល់កំពុងចាត់ការ ចំនួន ៨២ រឿង

ខ.២.២.សំណុំរឿងរក្សាការពារ

-សំណុំរឿងសល់ពីឆ្នាំ ២០២៣ ចំនួន ០៥ រឿង
-សំណុំរឿងចូលថ្មី ឆ្នាំ ២០២៤ ចំនួន ២០ រឿង
-សំណុំរឿងចាត់ការរួច ចំនួន ២៣ រឿង
-សំណុំរឿងសល់កំពុងចាត់ការ ចំនួន ០២ រឿង

ខ.២.៣.រឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង

-សំណុំរឿងសល់ពីឆ្នាំ ២០២៣ ចំនួន ១៣ រឿង
-សំណុំរឿងចូលថ្មី ឆ្នាំ ២០២៤ ចំនួន ៣២៧ រឿង
-សំណុំរឿងចាត់ការរួច ចំនួន ៣៣៣ រឿង
-សំណុំរឿងសល់កំពុងចាត់ការ ចំនួន ០៧ រឿង

ខ.២.៤.សំណុំរឿងអនុវត្តរក្សាការពារ

-សំណុំរឿងសល់ពីឆ្នាំ ២០២៣ ចំនួន ០១ រឿង
-សំណុំរឿងចូលថ្មី ឆ្នាំ ២០២៤ ចំនួន ១៣ រឿង
-សំណុំរឿងចាត់ការរួច ចំនួន ១៤ រឿង
-សំណុំរឿងសល់កំពុងចាត់ការ ចំនួន ០០ រឿង

ខ.២.៥.សំណុំរឿងអនុវត្តដោយបង្ខំ

-សំណុំរឿងសល់ពីឆ្នាំ ២០២៣ ចំនួន ១៧ រឿង
-សំណុំរឿងចូលថ្មី ឆ្នាំ ២០២៤ ចំនួន ១៦ រឿង
-សំណុំរឿងចាត់ការរួច ចំនួន ០៧ រឿង
-សំណុំរឿងសល់កំពុងចាត់ការ ចំនួន ២៨ រឿង

៣-បញ្ហាប្រឈម និងសំណូមពរ

ក.បញ្ហាប្រឈម

នៅសាលាដំបូង អយ្យការអមសាលាដំបូង និងលេខាធិការរដ្ឋបាលសាលាដំបូងខេត្តស្ទឹងត្រែង នៅក្នុងឆ្នាំ២០២៤ បានដោះស្រាយបញ្ហាប្រឈមជាច្រើន ហើយបញ្ហាមួយចំនួននៅមិនទាន់អាចដោះស្រាយបាននៅឡើយ ដែលបញ្ហាប្រឈមទាំងនោះរួមមាន៖

១-មន្ត្រីក្របខណ្ឌ និងមន្ត្រីជាប់កិច្ចសន្យាមានចំនួនតិច ដែលធ្វើឲ្យការងារនៅលេខាធិការដ្ឋានរដ្ឋបាល មិនអាចបំពេញការងារបានទាន់ពេលវេលាជូនក្រសួងបាន។

២-មិនមានអាជ្ញាសាលា ដើម្បីអនុវត្ត សាលក្រម សាលដីកា និងដីកាសម្រេចផ្សេងៗនៅសាលាដំបូង និងអយ្យការអមសាលាដំបូង ឲ្យស្របតាមច្បាប់នៅឡើយ។

៣-ពីមួយឆ្នាំ ទៅមួយឆ្នាំ ចំនួនទៅបំពេញបេសកកម្មមានចំនួនកើនឡើង ប៉ុន្តែថវិកាសម្រាប់ចំណាយការចុះបេសកកម្ម មិនទាន់ឆ្លើយតបតាមការចុះបំពេញបេសកកម្មនៅឡើយ។

៤-មិនមានថវិកាសម្រាប់ជួលអ្នកបកប្រែភាសាក្នុងសំណុំរឿងព្រហ្មទណ្ឌ ។

៥-មិនមានអាគារស្នាក់នៅសម្រាប់ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីរាជការដែលមិនមានទីលំនៅ នៅខេត្តស្ទឹងត្រែង។

ខ.សំណូមពរ

ដោយបញ្ហាប្រឈមទាំងអស់នេះ នៅសាលាដំបូង អយ្យការអមសាលាដំបូង និងលេខាធិការដ្ឋានរដ្ឋបាលខេត្តស្ទឹងត្រែង មិនអាចដោះស្រាយបាន ដូច្នេះ សាលាដំបូង អយ្យការអមសាលាដំបូង និងលេខាធិការដ្ឋានរដ្ឋបាលខេត្តស្ទឹងត្រែង សុំលើកជាសំណូមពរជូន ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មេត្តា ជួយដោះស្រាយនូវសំណើសំណូមពររួមមាន៖

១-ស្នើសុំផ្តល់ក្របខណ្ឌមន្ត្រីរាជការ ក្រឡាបញ្ជី និងមន្ត្រីជាប់កិច្ចសន្យាបន្ថែម

២-ស្នើសុំមន្ត្រីអាជ្ញាសាលា

៣-ស្នើសុំបន្ថែមថវិកាបំពេញបេសកកម្ម

៤-ស្នើសុំថវិកាសម្រាប់ជួលអ្នកបកប្រែភាសា ក្នុងសំណុំរឿងព្រហ្មទណ្ឌ

៥-ស្នើសុំអាគារស្នាក់នៅសម្រាប់ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីរាជការដែលមិនមានទីលំនៅ នៅខេត្តស្ទឹងត្រែង។

៤-ទិសដៅការងារសម្រាប់ឆ្នាំ ២០២៥

១-ពង្រឹងការយកចិត្តទុកដាក់បន្ថែមគ្រប់ផ្នែក ដើម្បីផ្តល់យុត្តិធម៌ ធានាបាននូវការការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម អាយុជីវិត សេចក្តីថ្លៃថ្នូរ ផលប្រយោជន៍រដ្ឋ និងឯកជន តាមច្បាប់ និងប្រកាន់ខ្ជាប់នូវអភិក្រម៥ គឺ "ងូតទឹក ដុសក្អែល ឆ្លុះកញ្ចក់ ព្យាបាល និងវះកាត់" ។

២-ចូលរួមអនុវត្តយុទ្ធនាការជម្រុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ របស់ក្រសួងយុត្តិធម៌ ដោយគោរពឲ្យបានម៉ឺងម៉ាត់នូវអភិក្រម គឺ "លឿន ត្រឹមត្រូវ និងយុត្តិធម៌ ដោយផ្អែកតាមច្បាប់ " ។

៣-បន្តការដោះស្រាយសំណុំរឿងជាអាទិភាព និងដោយម៉ឺងម៉ាត់ មានដូចជា សំណុំរឿងគ្រឿងញៀន សំណុំរឿងគ្រោះថ្នាក់ចរាចរណ៍ សំណុំរឿងបទល្មើសព្រៃឈើ ឲ្យបានឆាប់រហ័ស ត្រឹមត្រូវ និងយុត្តិធម៌ ។

៤-បន្តផ្តល់អាទិភាពជាចម្បងដល់សំណុំរឿងដែលពាក់ព័ន្ធនឹងស្ត្រី និងកុមារ (អនីតិជន) ពាក់ព័ន្ធជនជាប់ចោទឃុំ ក្នុងពន្ធនាគារ ត្រូវពន្លឿននីតិវិធីដោះស្រាយឲ្យបានឆាប់ និងដាក់កម្មវិធីជំនុំជម្រះជាអាទិភាពផងដែរ។

៥-បន្តរៀបចំប្រជុំជាមួយមន្ត្រីពន្ធនាគារ និងមន្ត្រីនគរបាលយុត្តិធម៌រៀងរាល់ឆមាស

៦-បន្តការយកចិត្តទុកដាក់ក្នុងការអនុវត្តការងារអាទិភាព ដែលដាក់ចេញដោយក្រសួងយុត្តិធម៌។

ដើម្បីសម្រេចបាននូវទិសដៅការងារសម្រាប់ឆ្នាំ២០២៥ កម្លាំងចលករសំខាន់គឺ ការដោះស្រាយបញ្ហាប្រឈមក្នុងស្ថាប័ន ជាមួយនឹងស្ថាប័នផ្សេងៗទៀតដែលពាក់ព័ន្ធត្រូវមានការសហការដោះស្រាយបញ្ហារួមគ្នា ប្រកបដោយភាពទទួលខុសត្រូវ និងស្នើសុំ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋក្រសួងយុត្តិធម៌** មេត្តាជួយដោះស្រាយបញ្ហាប្រឈម របស់សាលាដំបូង អយ្យការអមសាលាដំបូង និងលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តស្ទឹងត្រែង។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

ថ្ងៃពុធ ៧កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

ស្ទឹងត្រែង,ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២៥

ប្រធានលេខាធិការដ្ឋាន

ឡៅ លាងហេង

បានឃើញ និងឯកភាព

សូមគោរពជូន

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

ថ្ងៃពុធ ៧កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

ស្ទឹងត្រែង ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២៥

ជ. ប្រធានសាលាដំបូង

ង៉ែន ហ៊ាត់

ជ. ព្រះរាជអាជ្ញា

ឈៅ-ឃួយណារិទ្ធ

ព្រះរាជអាជ្ញារង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង និងអយ្យការអម
សាលាដំបូងខេត្តរតនគិរី
លេខ១០៤ រប/២៥

របាយការណ៍ការងារសន្ទេបរបស់សាលាដម្រះក្តី
សម្រាប់សន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ ឆ្នាំ២០២៤
និងកំណត់ទិសដៅការងារអនិតាគ ឆ្នាំ២០២៥
សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តរតនគិរី

១. ស្ថានភាពទូទៅ

១.១. ធនធានមនុស្ស

សាលាដំបូងខេត្តរតនគិរី

ប្រធានសាលាដំបូង	អនុប្រធានសាលាដំបូង	ចៅក្រម	ក្រឡាបញ្ជីតុលាការ
១ រូប	១ រូប (ស្រី ០ រូប)	៤ រូប (ស្រី ០ រូប)	១១ រូប (ស្រី ២ រូប)

អយ្យការអមសាលាដំបូងខេត្តរតនគិរី

ព្រះរាជអាជ្ញា	ព្រះរាជអាជ្ញារង	ក្រឡាបញ្ជីអយ្យការ
១ រូប	៣ រូប (ស្រី ០ រូប)	៦ រូប (ស្រី ៣ រូប)

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តរតនគិរី

ប្រធានលេខា	អនុប្រធានលេខា	ប្រធានការិយាល័យ	អនុ.ការិយាល័យ	មន្ត្រីរដ្ឋបាល	មន្ត្រី.កិច្ចសន្យា
១ រូប	១ រូប (ស្រី ០ រូប)	៤ រូប (ស្រី ១ រូប)	៧ រូប (ស្រី ៤ រូប)	២ រូប (ស្រី ១ រូប)	៩ រូប (ស្រី ៥ រូប)

១.២. ហេដ្ឋារចនាសម្ព័ន្ធ

សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តរតនគិរី មានអគារចំនួន ៤ រួមមាន ៖

- អគារធំ ចំនួន ១ ជាកន្លែងបម្រើការងាររបស់សាលាដំបូង និង អយ្យការអមសាលាដំបូង ព្រមទាំងមានបន្ទប់សាលសវនាការចំនួន ២ និងបន្ទប់ប្រជុំចំនួន ២
